# ព្រះ

# ត្រៃបិដកបាលី

នឹង

សេចក្ដីប្រែជាភាសាខ្មែរ

# សុត្តន្តបិដក

## ខុទ្ទកនិកាយ អបទាន

## ចតុត្ថភាគ

# ៧៥

បោះពុម្ពលើកទី ១

ពុទ្ធសាសនបណ្ឌិត្យ ភ្នំពេញ

ព.ស ២៥០៦

# ខុទ្ទកនិកាយស្ស អបទានំ

## ចតុត្ថោ ភាគោ

---

នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស ។

## ទ្វាចត្តាឡីសមោ ភទ្ទាលិវគ្គោ

### បឋមំ ភទ្ទាលិត្ថេរាបទានំ

(១) សុមេធោ នាម សម្ពុទ្ធោ អគ្គោ ការុណិកោ មុនិ
វិវេកកាមោ លោកគ្គោ ហិមវន្តំ ឧបាគមិ ។
អជ្ឈោគហេត្វា ហិមវន្តំ[១] សុមេធោ លោកនាយកោ
បល្លង្កំ អាភុជិត្វាន និសីទិ បុរិសាសភោ[២] ។
សមាធឹ សោ សមាបន្នោ សុមេធោ លោកនាយកោ
សត្តរត្តិន្ទិវំ ពុទ្ធោ និសីទិ បុរិសុត្តមោ ។
ខារិកាជំ គហេត្វាន វនមជ្ឈោគហឹ អហំ

---

១ ឱ. ម. ហិមវំ ។ ២ ឱ. ម. បុរិសុត្តមោ ។



# ខុទ្ទកនិកាយ អបទាន

## ចតុត្ថភាគ

---

សូមនមស្ការចំពោះព្រះមានព្រះភាគ អរហន្តសម្មាសម្ពុទ្ធអង្គនោះ ។

## ភទ្ទាលិវគ្គ ទី ៤២

### ភទ្ទាលិត្ថេរាបទាន ទី ១

(១) ព្រះសម្ពុទ្ធព្រះនាមសុមេធៈ ជាបុគ្គលខ្ពង់ខ្ពស់ ប្រកបដោយសេចក្តីករុណា ជាអ្នកប្រាជ្ញ ប្រាថ្នាសេចក្តីស្ងប់ស្ងាត់ ព្រះអង្គប្រសើរក្នុងលោក ទ្រង់បានស្តេចចូលទៅ ក្នុងព្រៃហិមពាន្ត ។ ព្រះលោកនាយក ព្រះនាមសុមេធៈ ជាបុរសដ៏ប្រសើរ លុះទ្រង់ស្តេចចូលទៅក្នុងព្រៃហិមពាន្តហើយ គង់ពែនភ្នែន ។ ព្រះពុទ្ធជាលោកនាយក ព្រះនាមសុមេធៈ អង្គនោះ ជាបុរសដ៏ប្រសើរ ទ្រង់គង់ចូលសមាធិ អស់ ៧ យប់ ៧ ថ្ងៃ ។ ខ្ញុំរែកអម្រែកបរិក្ខារ សំដៅចូលទៅកៅព្រ

តត្ថទ្ទសាសឹ សម្ពុទ្ធំ ឱឃតិណ្ណមនាសវំ ។
សម្មជ្ជនឹ គហេត្វាន សម្មជ្ជិត្វាន អស្សមំ
ចតុទណ្ឌេ ឋបេត្វាន អកាសឹ មណ្ឌបំ តទា ។
សាលបុប្ផំ គហេត្វាន មណ្ឌបំ ឆាទយឹ អហំ
បសន្នចិត្តោ សុមនោ អវន្ទឹ លោកនាយកំ(១) ។
យំ វទន្តិ សុមេធោតិ ភូរិបញ្ញំ សុមេធសំ
ភិក្ខុសង្ឃេ និសីទិត្វា ឥមា គាថា អភាសថ ។
ពុទ្ធស្ស គិរមញ្ញាយ សព្វេ ទេវា សមាគមុំ
អសំសយំ ពុទ្ធសេដ្ឋោ ធម្មំ ទេសេតិ ចក្ខុមា ។
សុមេធោ នាម សម្ពុទ្ធោ អាហុតីនំ បដិគ្គហោ
ទេវសង្ឃេ និសីទិត្វា ឥមា គាថា អភាសថ ។
យោ មេ សត្តាហំ មណ្ឌបំ ធារយិ សាលឆាទនំ(២)
តមហំ កិត្តយិស្សាមិ សុណាថ មម ភាសតោ ។

---

១ ឧ. ឆ. អភិវន្ទឹ លោកនាយកំ ។ ២ ឧ. ឆ. សាលឆាទិតំ ។



ហើយឃើញព្រះសម្ពុទ្ធ ក្នុងព្រៃនោះ ព្រះអង្គមានឱឃៈឆ្លងហើយ មិនមានអាសវៈ ។ គ្រានោះ ខ្ញុំកាន់អំបោសបោសអាស្រម ហើយលើកឈើ ៤ កំណាត់ បញ្ឈរធ្វើជាប៉ារ៉ាំ ។ ខ្ញុំមានចិត្តជ្រះថ្លា មានចិត្តរីករាយ បានយកផ្កាឈើប្រក់ប៉ារ៉ាំ ហើយថ្វាយបង្គំព្រះលោកនាយក ។ ពួកជនតែងហៅនូវព្រះសម្ពុទ្ធអង្គណា ដែលទ្រង់មានបញ្ញាដូចផែនដី មានបញ្ញាល្អ ថាសុមេធៈ ព្រះសម្ពុទ្ធអង្គនោះទ្រង់គង់ក្នុងពួកភិក្ខុ ហើយបានសម្ដែងគាថា ដូចខាងក្រោមនេះ ។ ពួកទេវតាទាំងអស់ បានដឹងព្រះពុទ្ធដីការបស់ព្រះពុទ្ធហើយ ក៏មកជួបជុំប្រាប់គ្នាថា ព្រះពុទ្ធដ៏ប្រសើរ ព្រះអង្គមានចក្ខុ នឹងសម្ដែងធម៌ដោយឥតសង្ស័យ ។ ព្រះសម្ពុទ្ធព្រះនាមសុមេធៈ ព្រះអង្គគួរទទួលនូវគ្រឿងបូជា ទ្រង់គង់ក្នុងកណ្ដាលពួកទេវតា ហើយត្រាស់គាថាទាំងនេះថា

បុគ្គលណា បាំងប៉ារ៉ាំដែលប្រក់ដោយផ្កាឈើ ថ្វាយតថាគត អស់ ៧ ថ្ងៃ តថាគត នឹងសម្ដែងសរសើរបុគ្គលនោះ អ្នកទាំងឡាយ ចូរចាំស្ដាប់តថាគតសម្ដែងចុះ ។

គាថា ក្បួនបើក្ខុបមាន

ទេវត្តោ មនុស្សោ វា   យោ បវណ្ណោ ភវិស្សតិ

បហូតភោគោ ហុត្វាន   ធាមកោតិ ភវិស្សតិ ។

សដ្ឋី(១) ជាតសហស្សានិ   សព្វាលង្ការភូសិតា

សុវណ្ណកញ្ញា ខាតដ្ឋា   ហេមគាប្យូរភិសសា ។

អាភុញ្ញា តាមណីយេកំ   គោមរត្តសមាណាកំ

សាយំ ចាតោ ឧបដ្ឋានំ   អាគច្ឆិស្សន្តិ មំ នរំ ។

តេហិ ជាតេហិ បវុតោ   រមិស្សតិ អយំ នរោ

សដ្ឋី អស្សសហស្សានិ   សព្វាលង្ការភូសិតា ។

អាជានីយា ច ជាតិយា   សិន្ធវា សីឃវាហនា

អាភុញ្ញា តាមណីយេកំ   ឥន្ទិយាចាបធារិភិ(២) ។

បរិវារេស្សន្តិមំ និច្ចំ   ពុទ្ធបូជាយិទំ ផលំ

សដ្ឋី រថសហស្សានិ   សព្វាលង្ការភូសិតា ។

ទីបា អថោបិ វេយ្យគ្ឃា   សន្នទ្ធា ឧស្សិតទ្ធជា

រកុញ្ញា តាមណីយេកំ   ចាបហាត្ថេហិ វម្មិភិ(៣) ។

១ ឱ. សដ្ឋី ។ ២ ឱ. ឥល្លិយាចាបធារិភិ ។ ៣ ឱ. ម. វម្មិហិ ។



ក្បួនបើក្ខុបមាន ទី ១

បុគ្គលនោះ បើបានកើតជាទេវតា ឬកើតជាមនុស្ស ក៏ដោយ សម្បូរដោយមាស ជាអ្នកមានភោគៈច្រើន បរិភោគតាមត្រូវ ជាប្រក្រតី ។ ស្រី ៦០ ពាន់ ដែលគេស្អិតស្អាង ដោយគ្រឿងប្រដាប់ គ្រប់យ៉ាង ជាស្រីមានខ្សែដង្កៀបមាស ប្រកបដោយគ្រឿងតាក់តែងក្បាល ជាវិការៈនៃមាស ដែលពួកស្រី មានដៃកាន់សំពត់ស្នងក្របទឹកកន្ទេរ ដំរាប កាន់ទីបម្រើនោះនេះ រាល់ពេលល្ងាចព្រឹក ។ ឯនាយនេះ ទំនងមានពួកសីហនាទតាមកោម ហើយសម្បូរយកកាយ សេះ ៦០ ពាន់ ដែលគេស្អិតស្អាង ដោយគ្រឿងប្រដាប់គ្រប់បែប ជាសេះអាជានេយ្យ និងសេះសិន្ធពពីកំណើត ជាពាហនៈ លឿន មានពួកនាយសារថី ប្រុងប្រៀបទូវេខលនិងធ្នូឡើងជិះ នឹងតាមកោមបុគ្គលនេះជានិច្ច នេះជាផលនៃពុទ្ធបូជា ។ រថ ៦០ ពាន់ ដែលគេតាក់តែងដោយប្រដាប់គ្រប់យ៉ាង បិទ ពាំងដោយស្បែកខ្លាដំបងនិងខ្លាធំ គេចងល្អហើយលើកទង់ ជ័យ មានពួកនាយសារថី មានដៃកាន់ធ្នូនិងខែលឡើងជិះ

បរិភោគេស្សុត្តិមំ ធនំ ពុទ្ធបូជាយិទំ ផលំ

សដ្ឋី កាមសហស្សានិ · បរិបុណ្ណានិ សព្វសោ ។

បហូតធនធញ្ញានិ សុសមិទ្ធានិ សព្វសោ

សទា បាតុភវិស្សន្តិ ពុទ្ធបូជាយិទំ ផលំ ។

ហត្ថី អស្សា រថា បត្តី សេនា ច ចតុរង្គិនី

បរិភោគេស្សុត្តិមំ ធនំ ពុទ្ធបូជាយិទំ ផលំ ។

អដ្ឋារសេ កប្បសតេ[១] ទេវលោកេ រមិស្សតិ

សហស្សក្ខត្តុំ រាជា ច ចក្កវត្តី ភវិស្សតិ ។

សតានំ តីណិក្ខត្តុំ ច ទេវរជ្ជំ ករិស្សតិ

បទេសរជ្ជំ វិបុលំ គណនាតោ អសង្ខិយំ ។

តឹសកប្បសហស្សម្ហិ ឱក្កាកកុលសម្ភវោ

គោតមោ នាម នាមេន សត្ថា លោកេ ភវិស្សតិ ។

តស្ស ធម្មេសុ ទាយាទោ ឱរសោ ធម្មនិម្មិតោ

សព្វាសវេ បរិញ្ញាយ វិហាសិ អនាសវោ ។

---

១ ម. អដ្ឋារសំ កប្បសតំ ។



នឹងតាមកេមបុគ្គលនោះជានិច្ច នេះជាផលនៃពុទ្ធបូជា ។ ស្រុកមួយ ៦០ ពាន់ បរិបូណ៌ដោយសព្វគ្រប់ ជាស្រុកមានទ្រព្យនិងស្រូវជាច្រើន ជារបស់សម្រេចល្អ ដោយប្រការទាំងពួង នឹងកើតមានប្រាកដសព្វកាល នេះជាផលនៃពុទ្ធបូជា ។ សេនាមានអង្គ ៤ គឺ ដំរី សេះ រថ ពលថ្មើរជើង នឹងមកតាមកេមបុគ្គលនេះជានិច្ច នេះជាផលនៃពុទ្ធបូជា ។ បុគ្គលនោះ នឹងរីករាយ ក្នុងទេវលោក អស់ ១.៨០០ កប្ប នឹងបានកើតជាស្តេចចក្រពត្តិ អស់ ១ ពាន់ដង ។ នឹងសោយទេវរជ្ជ អស់ ៣ រយដង នឹងសោយបទេសរជ្ជ ដ៏ធំទូលាយ រាប់ជាតិមិនអស់ ។ កន្លងទៅ ៣០ ពាន់កប្ប នឹងមានព្រះសាស្តា ព្រះនាមគោតម កើតក្នុងត្រកូល នៃព្រះបាទឱក្កាករាជ ត្រាស់ដឹងក្នុងលោក ។ (ព្រះសុមេធសម្ពុទ្ធទ្រង់ត្រាស់ថា) · ខ្ញុំនឹងបានទទួលមត៌កក្នុងធម៌ ជាឱរសដែលធម៌និម្មិតហើយ របស់ព្រះសាស្តានោះ ជាបុគ្គលកំណត់ដឹងនូវអាសវៈទាំងពួង ឥតមានអាសវៈ ។

## បឋមំ ញាណត្ថវិកត្ថេរាបទានំ

តិំសកប្បសហស្សម្ហិ  អទ្ទសំ លោកនាយកំ
ឋិតត្ថំ ឧទាធាយ  គវេសំ អមតំ បទំ ។
លាភា មយ្ហំ សុលទ្ធំ មេ  យមហំ ញាយំ សាសនំ
តិស្សោ វិជ្ជា អនុប្បត្តា  កតំ ពុទ្ធស្ស សាសនំ ។
នមោ តេ បុរិសាជញ្ញ  នមោ តេ បុរិសុត្តម
ញាណំ បដិកិត្តេត្វាន[១]  បត្តោម្ហិ អមតំ[២] បទំ ។
យំ យំ យោនុបបជ្ជាមិ  ទេវត្តំ អថ មានុសំ
សព្វត្ថ សុខិតោ ហោមិ  ផលម្មេ ញាណកិត្តនេ ។
ឥទំ បច្ឆិមកំ មយ្ហំ  ចរិមោ វត្តតិ ភវោ
នាគោវ ពន្ធនំ ឆេត្វា  វិហរាមិ អនាសវោ ។

---
១ ម. ម. តវ ញាណំ បកិត្តេត្វា ។ ២ ម. ម. អចលំ ។



## ញាណត្ថវិកត្ថេរាបទាន ទី ១

ក្នុងកាល ៣០ ពាន់កប្ប ខ្ញុំបានឃើញព្រះលោកនាយក ក្រោយខ្ញុំចេញផ្ទះនេះ ហើយស្វះស្វែងរក នូវអមតបទ គឺនិព្វាន ។ ខ្ញុំឈ្មោះថាមានលាភហើយ អត្តភាពជាមនុស្ស ឈ្មោះថាខ្ញុំបានល្អហើយ ព្រោះខ្ញុំបានដឹង នូវពាក្យប្រៀនប្រដៅ នៃព្រះពុទ្ធ វិជ្ជា ៣ ខ្ញុំបានដល់តាមលំដាប់ហើយ ពាក្យប្រៀនប្រដៅ របស់ព្រះពុទ្ធ ខ្ញុំក៏បានធ្វើរួចហើយ ។ បពិត្រព្រះអង្គជាបុរសអាជានេយ្យ ខ្ញុំសូមនមស្ការ ចំពោះព្រះអង្គ បពិត្រព្រះអង្គជាបុរសដ៏ខ្ពង់ខ្ពស់ ខ្ញុំសូមនមស្ការ ចំពោះព្រះអង្គ លុះខ្ញុំពោលសរសើរ ចំពោះព្រះញាណរួចហើយ ក៏បានដល់នូវអមតបទ គឺនិព្វាន ។ ខ្ញុំចូលទៅកើតក្នុងកំណើតណា ៗ ទោះជាទេវតា ឬជាមនុស្ស ខ្ញុំតែងបានសេចក្តីសុខ ក្នុងទីទាំងពួង នេះជាផលរបស់ខ្ញុំ ក្នុងការពោលសរសើរញាណ ។ នេះភពកាយជាខាងក្រោយបំផុតរបស់ខ្ញុំ ភពជាទីបំផុតកំពុងប្រព្រឹត្តទៅ ខ្ញុំជាបុគ្គលមិនមានអាសវៈ ដូចជាដំរីដ៏ប្រសើរ កាត់ផ្តាច់នូវចំណង ។

កិលេសា ឈាបិតា មយ្ហំ ភវា សព្វេ សមូហតា

នាគោវ ពន្ធនំ ឆេត្វា វិហរាមិ អនាសវោ ។

ស្វាគតំ វត មេ អាសិ មម ពុទ្ធស្ស សន្តិកេ

តិស្សោ វិជ្ជា អនុប្បត្តា កតំ ពុទ្ធស្ស សាសនំ ។

បដិសម្ភិទា ចតស្សោ វិមោក្ខាបិច អដ្ឋិមេ

ឆឡភិញ្ញា សច្ឆិកតា កតំ ពុទ្ធស្ស សាសនន្តិ ។

ឥត្ថំ សុទំ អាយស្មា ភទ្ទាលិ ថេរោ ឥមា គាថាយោ អភាសិត្ថាតិ ។

ភទ្ទាលិត្ថេរស្ស អបទានំ សមត្តំ ។

## ទុតិយំ ឯកច្ឆត្តិយត្ថេរាបទានំ

(២) ចន្ទភាគានទីតីរេ អស្សមោ សុកតោ មម

សុសុទ្ធបុឡិនាកិណ្ណេ បណ្ណសាលា សុមាបិតា ។



កិលេសទាំងឡាយ ខ្ញុំបានដុតបំផ្លាញហើយ ភពទាំងអស់ ខ្ញុំបានគាស់រំលើងចោលហើយ ខ្ញុំជាបុគ្គលមិនមានអាសវៈ ដូចជាដំរីដ៏ប្រសើរកាត់ផ្តាច់នូវខ្នង ។ ឱ! ដំណើរដែលខ្ញុំមកកាន់សំណាក់នៃព្រះពុទ្ធរបស់ខ្ញុំ ជាដំណើរល្អហ្ន៎ វិជ្ជា ៣ ខ្ញុំបានដល់តាមលំដាប់ហើយ សាសនារបស់ព្រះពុទ្ធ ខ្ញុំបានធ្វើរួចហើយ ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ តាំងសាសនា របស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ។

បានឮថា ព្រះភទ្ទាលិត្ថេរ មានអាយុ បានសំដែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

ចប់ ភទ្ទាលិត្ថេរាបទាន ។

## ឯកច្ឆត្តិយត្ថេរាបទាន ទី ២

(២) ខ្ញុំបានធ្វើអាស្រមដ៏ល្អ ពាក់ដ៏ខ្សាច់ដ៏ស្អាត ហើយសាងបណ្ណសាលា យ៉ាងល្អ ទៀបឆ្នេរស្ទឹងចន្ទភាគា ។

ឧទ្ទាលក្ខណា ចពិកា សុបតិន្នា មនោរមា
មច្ចកាចួបសម្បន្នា សុំសុមាលិសេវិតា ។
អដ្ឋា មយូរដិម ច ការវិកា ច សាលិកា
កូជន្តិ សព្វទា ឯតេ សោភយន្តា មមស្សមំ ។
កោកិលា មញ្ជុភាណី ច ហំសា ច មធុរស្សរា
អភិកូជន្តិ តេ តត្ថ សោភយន្តា មមស្សមំ ។
សីហា ព្យគ្ឃា វរាហា ច អច្ឆកោកតរច្ឆយោ
គិរិទុគ្គម្ហិ(១) នាទេន្តិ សោភយន្តា មមស្សមំ ។
ឯណីមិគា ច សរភា គោណ្ណា(២) សូករា ពហូ
គិរិទុគ្គម្ហិ នាទេន្តិ សោភយន្តា មមស្សមំ ។
ឧទ្ទាលកា ច ចម្បកា បាដលី សិន្ទុវារកា
អតិមុត្តា(៣) អសោកា ច សោភយន្តា មមស្សមំ(៤) ។

១ ឱ. គិរិទុគ្គេ ។ ២ គោទន្តា ។ ៣ ឱ. អតិមុត្តា ។ ៤ ឱ. ពុទ្ធង្គំ មម អស្សមេ ។ ម. សោភយន្តិ មមស្សមំ ។





ស្ទឹង (នោះ) មានច្រាំងរាប មានកំពង់ល្អ ជាទីគាប់ចិត្ត បរិបូណ៌ដោយសត្វត្រី និងអណ្ដើក ហ្វូងសត្វក្រពើនៅអាស្រ័យ ។ ពួកសត្វខ្លាឃ្មុំ ក្ងោក ខ្លាដំបង ការវិក និងសាលិកា តែងបន្លឺសំឡេង សព្វៗកាល សត្វទាំងនុ៎ះ ធ្វើអាស្រមរបស់ខ្ញុំឲ្យល្អ ។ ពួកតាវ៉ៅ មានសំឡេងពីរោះ និងហង្សមានសូរសព្ទពីរោះ តែងយំឆ្លើយតគ្នា (សព្វៗកាល) សត្វទាំងនុ៎ះ ធ្វើអាស្រមរបស់ខ្ញុំឲ្យល្អ ក្នុងទីនោះ ។ ពួកសីហៈ ខ្លាធំ ជ្រូក កុក ឆ្កែព្រៃ និងខ្លារខិន តែងបន្លឺសំឡេងក្បែរជ្រោះភ្នំ ធ្វើអាស្រមរបស់ខ្ញុំឲ្យល្អ ។ ពួកម្រឹគញី ម្រឹគខ្ទីង ចចក និងជ្រូកជាច្រើន តែងបន្លឺសំឡេងក្បែរជ្រោះភ្នំ ធ្វើអាស្រមរបស់ខ្ញុំឲ្យល្អ ។ ពួកដើមកន្ទ្រើង ដើមចម្បា ដើមព្រះទៀង ដើមឈើក្រឹង ដើមរំដួល និងដើមអសោក ក៏ធ្វើអាស្រមរបស់ខ្ញុំឲ្យល្អ ។

អង្កោលកា បុប្ផិតា ទេវ សត្តបណ្ណា តិត្តិជាលិកា(១)
កណិកា កណិការា ច(២) បុប្ផន្តិ មម អស្សមេ(៣) ។
នាគា សាលា ច សលឡា បុណ្ឌរីកេត្ថ បុប្ផិតា
និព្វា គត្វា សម្បវត្តា សោភន្តិ មម អស្សមេ(៤) ។
អស្សត្ថា អសនា ចេត្ត(៥) មហានាមា ច បុប្ផិតា
សាលា(៦) ច កក្កុបុប្ផា ច សោភន្តិ មម អស្សមេ ។
អម្ពា ជម្ពូ ច តិលកា នីមា ច សាលកល្យាណី
និព្វា គត្វា សម្បវត្តា សោភយន្តិ មមស្សមំ ។
អសោកា ច កាបិដ្ឋា ច គិរិមាលា ច បុប្ផិតា
និព្វា គត្វា សម្បវត្តា សោភយន្តិ មមស្សមំ ។
កទម្ពា កទលី ទេវ ឥសិមុគ្គា ច កេបិតា
ធុវំ ផលានិ ធារេន្តិ សោភយន្តិ មមស្សមំ ។

១ ម. សត្តលិតិត្តជាលិកា ។ ២ ឱ. កណ្ណិកា កណ្ណិការា ច ។ ម. កណ្ណិការា ច បុប្ផន្តិ ។ ៣ ម. សោភយន្តិ មមស្សមំ ។ ៤ ម. សោភយន្តិ មមស្សមំ ។ ៥ ឱ. អង្គិតា អសនាបេត្ត ។ ៦ ឱ. ផលា ច ។



ពួកដើមអង្កោល ដើមយុក្ក ដើមសត្តបណ្ណិ ដើមពុស ដើមកុម្ពី-ស និងដើមគណិការ បញ្ចេញផ្កាក្បែរអាស្រមរបស់ខ្ញុំ ។ ពួកដើមខ្នុង ដើមកន្ទុំ ដើមស្រល់ និងដើមស្វាយស មានផ្កាកែនៅក្នុងទីនោះ ក្លិនជាទិព្វសាយកាយ ធ្វើអាស្រមរបស់ខ្ញុំឲ្យល្អ ។ ពួកដើមពោធិ ដើមធ្នង់ ដើមផ្ទាក់ដៃ ដើមកន្ទុំ និងដើមផ្កាពៅ មានផ្កាកែ ធ្វើអាស្រមរបស់ខ្ញុំឲ្យល្អ ។ ពួកដើមស្វាយ ដើមព្រីង ដើមផ្គៀបក្តាម ដើមកន្ទុំអន្ទក់ និងដើមក្តៅខាន់ ក្លិនជាទិព្វក្រអូបសាយកាយ ធ្វើអាស្រមរបស់ខ្ញុំឲ្យល្អ ។ ពួកដើមអសោក ដើមខ្វិត ដើមទន្ទ្រស្រី មានផ្កាកែ ក្លិនជាទិព្វសាយកាយ ធ្វើអាស្រមរបស់ខ្ញុំឲ្យល្អ ។ ដើមក្តម្ព ដើមចេក ដើមសណ្តែកព្រៃ ដែលគេដាំ ទ្រទ្រង់ផ្លែជានិច្ច ធ្វើអាស្រមរបស់ខ្ញុំឲ្យល្អ ។

## ទុតិយំ ឯកច្ចត្តិយគ្រោះបកាន់

ហរីតកា អាមលកា អម្ពា ជម្ពុ វិភេទកា
កោលា ភល្លាតកា ពេល្លា ផលិនោ មម អស្សមេ ។
អវិទូរេ បោក្ខរណី សុបតិត្ថា មនោរមា
មន្ទាលកេហិ សញ្ឆន្នា បទុមុប្បលកេហិ ច ។
កត្តំ កណ្ហត្តំ បទុមា អញ្ញោ បុប្ផន្តិ កេសរី
ឱបត្តកណ្ណិកា ចេវ បុប្ផន្តិ មម អស្សមេ ។
បាឋីនា បាវុសា មច្ឆា វលជា មុញ្ជរោហិតា
អគ្គោទកម្ហិ វិចរី សោភយន្តិ មមស្សមំ ។
ឆយិតា អគ្គគន្ទិ ច អនុក្កុលេ ច កោតកា
ចិញ្ញា គច្ឆា សម្បវត្តា សោភយន្តិ មមស្សមំ ។
មធុភិសេហិ សវន្តិ ខីរសប្បិមុឡាលិភិ
ចិញ្ញា គច្ឆា សម្បវត្តា សោភយន្តិ មមស្សមំ ។



## ឯកច្ចត្តិយគ្រោះបកាន ទី ២

ពួកដើមសម៉ ដើមកន្ទួតព្រៃ ដើមស្វាយ ដើមត្រើង ដើមសម៉ពិភេទក ដើមក្រឡៅ ដើមកក់ខ្មៅ ដើមខ្នៅ មានផ្លែ ជិតអាស្រមរបស់ខ្ញុំ ។ នៅទីជិតស្រះបោក្ខរណី មានកំពង់ក្របស្មើ ជាទីត្រេកអរចិត្ត ដ៏ដេរដាសដោយលំពង់ផ្កាឈូក និងផ្កាឧប្បល ។ ពួកដើមឈូក កំពុងជាប់ផ្លែ ( ទោប ) ពួកដើមឈើ មានកេសរដទៃទៀត ៗ បញ្ចេញផ្ការីក មានខ្ទង់ ដើមកណ្ណិកាមានស្លឹកជ្រុះ បញ្ចេញផ្កា នៅទៀបអាស្រមរបស់ខ្ញុំ ។ ពួកត្រីស្លាត ត្រីក្បក ត្រីក្រាញ់ ត្រីសណ្តាយ និងត្រីឆ្ពិន កំពុងត្រាច់ទៅមក ក្នុងទឹកជ្រៅ ធ្វើអាស្រមរបស់ខ្ញុំឲ្យល្អ ។ ពួកដើមទយិតាព្រឹក្ស ដើមស្វាយក្រអូប ដើមការកេត មាននៅទៀបលំដាប់ត្រពាំង ក្លិនជាទីពួសាយគាយទៅ ធ្វើអាស្រមរបស់ខ្ញុំឲ្យល្អ ។ ក្លិនផ្កាពិដោសាយគាយ ហូរចេញមកពីក្រអៅឈូក និងមើមឈូក ដូចទឹកដោះគោ និងទឹកដោះថ្លា ធ្វើអាស្រមរបស់ខ្ញុំឲ្យល្អ ។

បុប្ផិតា សោភណា តត្ថ | អាកិណ្ណា ជលសេវិតា
ឧប្បលា បុប្ផិតា សេតា | សោភយន្តិ មមស្សមំ ។
ជជាការកិតា(១) ច(២) | អដិទុត្តភិសិតោ
ភកាចិរជក សព្ទេ | សោភយន្តិ មមស្សមំ ។
យុតមត្តមបេក្ខតា(៣) | ជិបកា សន្តត្តិតោ
កាយតោនេ(៤) អណបេក្ខា | វសន្តិ មម អស្សមេ ។
ឥក្ខញ្ញាកច្ឆខលោមា | បង្កទន្តា វនស្សិកា
វេជាផលូធក សព្ទេ | វសន្តិ មម អស្សមេ ។
អភិញ្ញាបារមិប្បត្តា | អន្តលិក្ខចរា តេ
ឧត្តិណ្ណា ឆគិ ឋតេ | សោភយន្តិ មមស្សមំ ។
តេហិ សិស្សេហិ បរិវុតោ | វសាមិ បវនេ តទា
រត្តិន្ទិវំ ន ជានាមិ | ឈានរតិសមប្បិតោ(៥) ។

១ ឧ. ឯត្តត្ថ គេតិតិ ទិស្សន្តិ ។ ២ ម. ជលាកាបេន ភរិតា ។ ៣ ឧ. យុតមត្តំ បេក្ខ-មាតា ។ ៤ ម. កាយកោនេ ។ ៥ ឱ ម. សព្វ ឈានសមប្បិតោ ។



ផ្កាឈូកចំប៉ីល្អដេរដាស ស្រស់ស្រោបដោយទឹកក្លិននោះ ពីរដើមសេតព្រឹក្ស មានផ្កាកោយចុះក្នុងទឹក ធ្វើអាស្រមរបស់ខ្ញុំឲ្យល្អ ។ ពួកតាបសទាំងអស់ ពេញទៅដោយភារៈ គឺផ្នួងសក់ ស្លៀកសំពត់ស្បែកខ្លា ទាំងប្រុងប្រង់ឡើងសំពត់សំបកឈើ ធ្វើអាស្រមរបស់ខ្ញុំឲ្យល្អ ។ (ពួកតាបសទាំងនោះ) ក្រឡេកមើលប្រមាណមួយជួរនឹម ជាបុគ្គលបរបញ្ញាចាស់ មានកិរិយាប្រព្រឹត្តដ៏ស្ងប់ស្ងាត់ជាប្រក្រតី មិនមានសេចក្ដីប្រាថ្នា ក្នុងការជាប់ចំពាក់ដោយកាម នៅក្នុងអាស្រមរបស់ខ្ញុំ ។ ពួកតាបសទាំងអស់នោះ មានក្រចកវែង រោមក្លៀកដុះវែង ១ មានមន្ទិលធ្មេញ មានធូលីលើក្បាល ប្រប្រឹងខ្លួនធូលីនិងរក្ខល នៅក្នុងអាស្រមរបស់ខ្ញុំ ។ ពួកតាបសទាំងនោះ ដល់នូវអភិញ្ញាបារមី សុទ្ធតែត្រាច់ទៅក្នុងអាកាសបាន តាបសទាំងនុះ ហោះទៅកាន់អាកាស ធ្វើអាស្រមរបស់ខ្ញុំឲ្យល្អ ។ គ្រានោះ ខ្ញុំមានពួកសិស្សទាំងនោះ ហែមហែមជាបរិវារ នៅក្នុងព្រៃធំ ដែលស្ងប់ស្ងាត់ ដោយសេចក្ដីត្រេកអរ ក្នុងឈាន ឥតដឹងយប់និងថ្ងៃ ។

ទុតិយំ ឯកបុគ្គលបេក្ខបាឋំ

ភគវា តម្ហិ សមយេ   អង្គីរសោ មហាមុនិ
ធម្មចក្កំ ជាសេដ្ឋោ   ឧប្បជ្ជិ លោកនាយកោ ។
អថ អញ្ញតរោ សិស្សោ   អាគញ្ឆិ មម សន្តិកេ
មន្តេ អជ្ឈេត្តុកាមោ សោ   ឆឡង្គំ នាម លក្ខណំ ។
ពុទ្ធោ លោកេ សមុប្បន្នោ   អង្គីរសោ មហាមុនិ
ចតុសច្ចំ បកាសេន្តោ   ទេសេសិ[1] អមតំ បទំ ។
តុដ្ឋហដ្ឋោ បមុទិតោ   ធម្មន្តរគណាសយោ[2]
អស្សមា អភិនិក្ខម្ម   ឥទំ វចនមព្រវិ ។
ពុទ្ធោ លោកេ សមុប្បន្នោ   ទ្វត្តឹសវរលក្ខណោ
ឯថ សព្វេ គមិស្សាម   សម្មាសម្ពុទ្ធសន្តិកេ
ទុក្ខបដិការា តេ   សទ្ធម្មេ ចារមិ គតា
សាធូតិ សម្បដិច្ឆិសុ   ឧត្តមត្ថំ គវេសកា ។

១ ម. ម. ទេសេតិ ។ ២ ម. ធម្មន្តរោតាសយោ ។



ឯកបុគ្គលបេក្ខបាឋ ទី ២

សម័យនោះ ព្រះមានព្រះភាគ ព្រះនាមអង្គីរស ជាអ្នកប្រាជ្ញធំ ព្រះអង្គជានាយកនៃសត្វលោក ទ្រង់កំចាត់បង់នូវងងឹតអន្ធការ ទ្រង់កើតឡើង ក្នុងលោក ។ គ្រានោះ មានសិស្សមួយរូប ចូលមកក្នុងសំណាក់ខ្ញុំ សិស្សនោះមានប្រាថ្នានឹងរៀន នូវមន្តទាំងឡាយ ឈ្មោះឆឡង្គលក្ខណៈ ។ ព្រះពុទ្ធព្រះនាមអង្គីរស ជាអ្នកប្រាជ្ញដ៏ប្រសើរផុត ទ្រង់កើតឡើងក្នុងលោក កំពុងប្រកាស នូវសច្ចៈ ៤ ហើយសម្តែងនូវអមតបទគឺនិព្វាន ។ ខ្ញុំមានសេចក្តីត្រេកអរស្រស់ស្រាយរីករាយ ជាទីអាស្រ័យនៅ នៃពួកអ្នកមានចិត្តជាធម៌ បានចេញអំពីអាស្រម ហើយពោលពាក្យនេះថា ព្រះពុទ្ធកើតឡើងហើយ ក្នុងលោក ទ្រង់មានលក្ខណៈដ៏សំខាន់ ៣២ ប្រការ ដូច្នេះ អ្នកគល់គ្នាចូរមក យើងនឹងទៅក្នុងសំណាក់នៃព្រះសម្មាសម្ពុទ្ធ ។ ពួកតាបសទាំងនោះ ជាអ្នកធ្វើតាមពាក្យខ្ញុំ ដល់នូវបារមីក្នុងព្រះសទ្ធម្ម ជាអ្នកស្វែងរក នូវប្រយោជន៍ដ៏ប្រសើរ បានទទួលថាសាធុ ។

ជដាភារភរិតា តោ    អជិនុត្តរវាសនា

ឧត្តមត្ថំ គវេសន្តា    និក្ខមឹសុ វនា តទា ។

ភគវា តម្ហិ សមយេ    អត្ថទស្សី មហាយសោ

ចតុសច្ចំ បកាសេន្តោ    ទេសេសិ អមតំ បទំ ។

សេតច្ឆត្តំ គហេត្វាន    ពុទ្ធសេដ្ឋស្ស ធារយឹ

ឯកាហំ ធារយិត្វាន    ពុទ្ធសេដ្ឋំ អវន្ទហំ ។

អត្ថទស្សី តុ ភគវា    លោកជេដ្ឋោ នរាសភោ

ភិក្ខុសង្ឃេ និសីទិត្វា    ឥមា គាថា អភាសថ ។

យោ មេ ឆត្តមធារេសិ    បសន្នោ សេហិ បាណិភិ

តមហំ កិត្តយិស្សាមិ    សុណាថ មម ភាសតោ ។

ឥមស្ស ជាយមានស្ស    ទេវត្តេ អថ មានុសេ

ធារិស្សន្តិ សទា ឆត្តំ    ឆត្តទានស្សិទំ ផលំ ។



ពួកតាបសទាំងនោះ សឹងពេញទៅដោយភារៈ គឺផ្នួងសក់ ស្លៀកពាក់ស្បែកខ្លា កំពុងស្វែងរកប្រយោជន៍ដ៏ឧត្តម ចេញចាកព្រៃ ក្នុងកាលនោះ ។ គាប់ជួនសម័យនោះ ព្រះមានព្រះភាគ ព្រះនាមអត្ថទស្សី ព្រះអង្គមានយសធំ កំពុងប្រកាសសច្ចៈ ៤ សម្តែងនូវអមតបទ គឺនិព្វាន ។ ខ្ញុំបានកាន់ស្វេតច្ឆត្រ ចាំងថ្វាយព្រះពុទ្ធដ៏ប្រសើរ លុះចាំងថ្វាយអស់មួយថ្ងៃហើយ ខ្ញុំថ្វាយបង្គំព្រះពុទ្ធដ៏ប្រសើរ ។ ចំណែកខាងព្រះមានព្រះភាគ ព្រះនាមអត្ថទស្សី ទ្រង់ជាច្បងក្នុងលោក ជានរៈដ៏ប្រសើរ ទ្រង់គង់ក្នុងពួកភិក្ខុ ហើយត្រាស់នូវគាថាទាំងនេះថា

បុគ្គលណាមានចិត្តជ្រះថ្លា បានចាំងឆត្រថ្វាយតថាគត ដោយដៃរបស់ខ្លួន តថាគត នឹងសរសើរបុគ្គលនោះ អ្នកទាំងឡាយ ចូរស្តាប់តថាគតសម្តែងចុះ ។ បុគ្គលនេះកាលកើតជាទេវតា ឬកើតជាមនុស្ស ពួកជននឹងចាំងឆត្រឲ្យ សព្វ ៗ កាល នេះជាផល នៃការថ្វាយឆត្រ ។

ទុតិយំ ឯកបុប្ផិយត្ថេរាបទានំ

សត្តសត្តតិកប្បានំ  ទេវលោកេ រមិស្សតិ
សហស្សក្ខត្តុំ រាជា ច  ចក្កវត្តី ភវិស្សតិ ។
សត្តសត្តតិក្ខត្តុញ្ច  ទេវរជ្ជំ ករិស្សតិ
បទេសរជ្ជំ វិបុលំ  គណនាតោ អសង្ខិយំ ។
អដ្ឋារសេ កប្បសតេ  គោតមោ សក្យបុង្គវោ
តមន្ធការំ នាសេត្វា  ឧប្បជ្ជិស្សតិ ចក្ខុមា ។
តស្ស ធម្មេសុ ទាយាទោ  ឱរសោ ធម្មនិម្មិតោ
សព្ពាសវេ បរិញ្ញាយ  និព្វាយិស្សតិនាសវោ(១) ។
យតោ អហំ កម្មមកំ  ពន្ទិ ពុទ្ធស្ស តាយិនោ
ឯត្ថន្តរេ ច ជាតាមិ  សេតច្ឆត្តំ អធារិតំ ។
ឥទំ បច្ឆិមកំ មយ្ហំ  ចរិមោ វត្តតេ ភវោ
ឆត្តធារណមជ្ជាសិ  មន្តោ និច្ចកាលិកំ ។

---
១ ម.-វិហរិស្សតិនាសវោ ។





បុគ្គលនោះ នឹងកើតក្នុងទេវលោក អស់ ៧៧ កប្ប នឹងបានជាស្តេចចក្រពត្តិ អស់ ១.០០០ ដង ។ ហើយទៀត បុគ្គលនោះ នឹងបានសោយទេវរជ្ជ ជាស្តេចនៃទេវតា អស់ ៧៧ ដង នឹងសោយបទេសរជ្ជ ដ៏ធំទូលាយ រាប់បានមួយអសង្ខេយ្យជាតិ ។ ក្នុងទី ១.៨០០ កប្ប ព្រះពុទ្ធព្រះនាមគោតម ជាសាក្យដ៏ប្រសើរបំផុត ព្រះអង្គមានបញ្ញាចក្ខុ ទ្រង់កំចាត់បង់នូវងងឹតអន្ធការ នឹងកើតឡើង ។ បុគ្គលនោះ នឹងបានទទួលមត៌ក ក្នុងធម៌របស់ព្រះពុទ្ធអង្គនោះ ជាឱរសដែលធម៌និម្មិតហើយ កំណត់ដឹងនូវអាសវៈទាំងអស់ ជាអ្នកមិនមានអាសវៈ នឹងបរិនិព្វាន ។

កាលណា ខ្ញុំបានធ្វើនូវកុសលកម្ម គឺបាំងឆ័ត្រថ្វាយព្រះពុទ្ធ ក្នុងចន្លោះនេះ ខ្ញុំមិនដែលស្គាល់ស្វេតឆ័ត្រ ដែលគេមិនបាំងឱ្យខ្ញុំឡើយ ។ នេះរាងកាយ ជាទីបំផុតរបស់ខ្ញុំ ភពជាទីបំផុតរបស់ខ្ញុំ កំពុងប្រព្រឹត្តទៅ ចំណែកការបាំងឆ័ត្រលើក្បាល អស់កាលជានិច្ច មានដល់ខ្ញុំថ្ងៃនេះ ។

អហោ មេ សុកតំ កម្មំ អត្ថទស្សិស្ស តាទិនោ
សព្វាសវបរិក្ខីណោ[១] នត្ថិ ទានិ បុនព្ភវោ ។
កិលេសា ឈាបិតា មយ្ហំ ភវា សព្វេ សមូហតា
នាគោវ ពន្ធនំ ឆេត្វា វិហរាមិ អនាសវោ ។
ស្វាគតំ វត មេ អាសិ មម ពុទ្ធស្ស សន្តិកេ
តិស្សោ វិជ្ជា អនុប្បត្តា កតំ ពុទ្ធស្ស សាសនំ ។
បដិសម្ភិទា ចតស្សោ វិមោក្ខាបិ ច អដ្ឋិមេ
ឆឡភិញ្ញា សច្ឆិកតា កតំ ពុទ្ធស្ស សាសនន្តិ ។

ឥត្ថំ សុទំ អាយស្មា ឯកច្ឆត្តិយោ ថេរោ ឥមា គាថាយោ អភាសិត្ថាតិ ។

ឯកច្ឆត្តិយត្ថេរស្ស អបទានំ សមត្តំ ។

---

១ សព្វាសវា បរិក្ខីណាតិ សុទ្ធិក្ខត្តំ ។



ឱហ្ន៎ ! អំពើល្អខ្ញុំធ្វើដោយប្រពៃហើយ ចំពោះព្រះពុទ្ធ ព្រះនាមអត្ថទស្សី ព្រះអង្គប្រកបដោយតាទិគុណ ខ្ញុំមានអាសវៈទាំងពួង អស់រលីងហើយ ឥឡូវនេះ ភពថ្មីមិនមានទៀតឡើយ ។ កិលេសទាំងឡាយ ខ្ញុំបានដុតបំផ្លាញហើយ ភពទាំងអស់ ខ្ញុំបានគាស់រំលើងចោលហើយ ខ្ញុំជាបុគ្គលមិនមានអាសវៈ ដូចជាដំរីដ៏ប្រសើរ កាត់ផ្តាច់ខ្សែទន្លីង ។ ឱ! ដំណើរដែលខ្ញុំមក ក្នុងសំណាក់នៃព្រះពុទ្ធ របស់ខ្ញុំ ជាដំណើរល្អហ្ន៎ វិជ្ជា ៣ ខ្ញុំបានដល់ដោយលំដាប់ហើយ សាសនា របស់ព្រះពុទ្ធ ខ្ញុំបានធ្វើតាមរួចហើយ ។ បដិ-សម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ។

បានឮថា ព្រះឯកច្ឆត្តិយត្ថេរ មានអាយុ បានសំដែងនូវគាថា ទាំងនេះ ដោយប្រការដូច្នេះ ។

ចប់ ឯកច្ឆត្តិយត្ថេរាបទាន ។

តតិយំ តិណសូលកឆាទនិយត្ថេរាបទានំ

(៣) ជាតិជរញ្ច មរណំ បច្ចវេក្ខឹ អហំ តទា
ឯកកោ អភិនិក្ខម្ម បព្វជឹ អនគារិយំ ។
ចរមានោ អនុបុព្វេន គង្គាតីរំ ឧបាគមឹ
តត្ថទ្ទសាសឹ បឋវឹ គង្គាតីរេ សមុណ្ណតំ(១) ។
អស្សមំ តត្ថ មាបេត្វា វសាមិ មម អស្សមេ(២)
សុកតោ ចង្កមោ មយ្ហំ នានាទិជគណាយុតោ ។
មមំ ឧបេន្តិ ច សត្តា កុជ្ជន្តិ ច មនោហរំ(៣)
រមមានោ សហ តេហិ វសាមិ អស្សមេ អហំ ។
មម អស្សមសាមន្តា មិគរាជា ចតុក្កមោ
អាសយា អភិនិក្ខម្ម គជ្ជី សោ អសនី វិយ ។
នទិតេ មិគរាជេ ច ហាសោ មេ ឧបបជ្ជថ
មិគរាជំ គវេសន្តោ អទ្ទសំ លោកនាយកំ ។

១ ឱ. សមុណ្ណតំ ។ ម. សមុន្នតំ ។ ២ ឱ. ម. វសាមិ អស្សមេ អហំ ។ ៣ ឱ. មមុ-បេន្តិ ច វិស្សត្ថា កូជន្តិ ច មនោហរំ ។ ម. មំ ឧបេន្តិ ច វិស្សត្ថា កូជន្តិ ច មនោហរំ ។

តិណសូលកឆាទនិយត្ថេរាបទាន ទី ៣

(៣) កាលនោះ ខ្ញុំបានពិចារណានូវជាតិជរានិងមរណៈ ខ្ញុំតែម្នាក់ឯង ចេញចាកផ្ទះ ហើយចូលទៅកាន់ផ្នួស ។ កាលខ្ញុំសញ្ចរទៅតាមលំដាប់ បានចូលទៅកាន់ឆ្នេរទន្លេគង្គា ក៏ឃើញផែនដីដុះពេញស្មើ នៅទៀបឆ្នេរទន្លេគង្គានោះ ។ ខ្ញុំបានសាងអាស្រមក្នុងទីនោះ ហើយនៅក្នុងអាស្រមរបស់ខ្ញុំ ទីចង្ក្រមដែលខ្ញុំបានធ្វើល្អហើយ សឹងប្រកបដោយពួកសត្វស្លាបផ្សេងៗ ។ ពួកសត្វតែងចូលមកជិតខ្ញុំផង បន្លឺសំឡេងគួរឲ្យពេញចិត្តផង ខ្ញុំត្រេកអរក្រៃពេក ជាមួយនឹងសត្វទាំងនោះ ហើយនៅក្នុងអាស្រម ។ ស្តេចម្រឹគមានជើង ៤ នៅជិតអាស្រមរបស់ខ្ញុំ ស្តេចម្រឹគនោះ តែងចេញអំពីលំនៅ មកស្រែកគំរាមដូចផ្គរលាន់ ។ កាលស្តេចម្រឹគបន្លឺសំឡេងឡើង ខ្ញុំក៏មានសេចក្តីត្រេកអរកើតឡើង ខ្ញុំកំពុងស្វះស្វែងរកស្តេចម្រឹគ ស្រាប់តែប្រទះឃើញព្រះលោកនាយក ។

និស្ភាជាហំ ធោរធេរំ តិស្សំ លោកគ្គនាយកំ
ហដ្ឋោ ហដ្ឋេន ចិត្តេន បូជយឹ នាគកេសរំ ។
ឧគ្គច្ឆន្តំ សុរិយំ សាលរាជំវ ផុល្លិតំ
ឱសធីវ(១) វិរោចន្តំ សន្ធំ លោកនាយកំ ។
តវ ញាណេន សព្វញ្ញុ ជោតេសិ(២) មំ សទេវកំ
តុវំ អារាធយិត្វាន ជាតិយា បរិមុច្ចរេ ។
អនស្សនេន សព្វញ្ញុ– ពុទ្ធានំ សព្វទស្សិនំ
បតន្តិ និរយំ រាគទោសេហិ ឱត្ថដា(៣) ។
តវ ទស្សនមាគម្ម សព្វញ្ញុលោកនាយកំ
បមុច្ចន្តិ ភវា សព្វេ ផុសន្តិ អមតំ បទំ ។

---

១ ឱ. ឱសធីវ ។ ២ ម. មោចេសិ ។ ៣ ឱ.ម. ឱត្ថដា ។



លុះខ្ញុំឃើញព្រះពុទ្ធ ព្រះនាមតិស្សៈ ជាទេវតាក្រៃលែងជាងទេវតា ជានាយកប្រសើរ របស់សត្វលោកហើយ ខ្ញុំមានចិត្តត្រេកអររីករាយ បានបូជាកេសរផ្កាខ្ទឹង ។ ខ្ញុំសរសើរព្រះលោកនាយក ព្រះអង្គកំពុងរុងរឿង ដូចជាព្រះអាទិត្យកាលរះឡើង ឬដូចជាស្តេចឈើមានផ្ការីក ពុំនោះសោតដូចជាផ្កាយព្រឹកផង បពិត្រព្រះសព្វញ្ញូ ព្រះអង្គទ្រង់ធ្វើខ្ញុំព្រមទាំងទេវតាឲ្យរុងរឿង ដោយញាណរបស់ព្រះអង្គ ពួកជនបានធ្វើព្រះអង្គឲ្យត្រេកអរហើយ រមែងរួចចាកជាតិ ។ ពួកជនដែលត្រូវរាគៈនិងទោសៈ គ្របសង្កត់ហើយ រមែងធ្លាក់ចុះក្នុងអវិចិនរក ព្រោះតែមិនឃើញ នូវព្រះសព្វញ្ញុពុទ្ធ ទ្រង់ឃើញហេតុទាំងពួង ។ ពួកសត្វទាំងអស់ រួចស្រឡះចាកភព ពាល់ត្រូវនូវអមតបទគឺព្រះនិព្វាន ព្រោះអាស្រ័យនូវការឃើញព្រះអង្គ ជាសព្វញ្ញូលោកនាយក ។

### តតិយំ តិណសូលកទាយកត្ថេរាបទានំ

យទា ពុទ្ធា ចក្ខុមន្តោ ឧប្បជ្ជន្តិ បភង្ករា
កិលេសេ ឈាបយិត្វាន អាលោកំ ទស្សយន្តិ តេ ។
កិត្តយិត្វាន សម្ពុទ្ធំ តិស្សំ លោកគ្គនាយកំ
ហដ្ឋោ ហដ្ឋេន ចិត្តេន តិណាស្សុលំ អបូជយិំ ។
មម សង្កប្បមញ្ញាយ តិស្សោ លោកគ្គនាយកោ
សកាសនេ និសីទិត្វា ឥមា គាថា អភាសថ ។
យោ មំ(១) បុប្ផេហិ ឆាទេសិ បសន្នោ សេហិ បាណិភិ
តមហំ កិត្តយិស្សាមិ សុណាថ មម ភាសតោ ។
បញ្ចវីសតិក្ខត្តុំ(២) ទេវរជ្ជំ ករិស្សតិ
បញ្ចសត្តតិក្ខត្តុំ ចក្កវត្តិ ករិស្សតិ ។

---
១ ម. ទេ ។ ២ ឱ. ម. បញ្ចវីសតិក្ខត្តុំ សោ ។



### តិណសូលកទាយកត្ថេរាបទាន ទី ៣

កាលណា ព្រះពុទ្ធទាំងឡាយ ព្រះអង្គមានបញ្ញាចក្ខុ ជាអ្នកធ្វើនូវពន្លឺកើតឡើង ព្រះពុទ្ធទាំងឡាយនោះ រមែងដុតកិលេស ហើយបង្ហាញនូវពន្លឺក្នុងកាលនោះ ។ ខ្ញុំសរសើរព្រះសម្ពុទ្ធ ព្រះនាមតិស្សៈ ជានាយកដ៏ប្រសើររបស់សត្វលោក ហើយបានបូជាផ្កាម្ទេស ដោយចិត្តរីករាយ ។ ឯព្រះពុទ្ធព្រះនាមតិស្សៈ ជានាយកដ៏ប្រសើរនៃសត្វលោក ទ្រង់បានជ្រាបច្បាស់ នូវសេចក្តីត្រិះរិះរបស់ខ្ញុំ ទ្រង់គង់លើអាសនៈរបស់ព្រះអង្គ ហើយសម្តែងនូវគាថាទាំងនេះថា

បុគ្គលណាមានសេចក្តីជ្រះថ្លា បានបាំងតថាគតដោយផ្កាទាំងឡាយ ដោយដៃរបស់ខ្លួន តថាគត នឹងសរសើរបុគ្គលនោះ អ្នកទាំងឡាយចូរស្តាប់តថាគតសម្តែងចុះ ។ បុគ្គលនោះ នឹងសោយទេវរជ្ជ ជាស្តេចនៃទេវតា អស់ ២៥ ដង នឹងបានជាស្តេចចក្រពត្តិ អស់ ៧៥ ដង ។

បថេសរជ្ជំ វិបុលំ គណនាតោ អសង្ខិយំ

តស្ស កម្មស្ស និស្សន្ទោ(១) ពុទ្ធានំ បូជនាយ សោ(២) ។

សាយំ បាតោ ចយំ ឃោសោ បុប្ផហំ មំ អនាចយំ(៣)

បុញ្ញកម្មេន សំយុត្តោ បុរតោ ធាតុកំវិស្សតិ ។

យំ យំ ឥច្ឆតិ កាមេហិ តំ តំ ធាតុកំវិស្សតិ

សង្កប្បំ បរិបូរេត្វា និព្វាយិស្សតិនាសវោ ។

កិលេសេ(៤) ឈាបយិត្វាន សម្បជានោ បតិស្សតោ

ឯកាសនេ និសីទិត្វា អរហត្តំ អបាបុណិំ(៥) ។

ចង្កមន្តោ និបជ្ជន្តោ និសិន្នោ អថ(៦) ឋិតោ

ពុទ្ធសេដ្ឋំ សរិត្វាន វិហរាមិ អហំ តទា(៧) ។

ចីវរេ បិណ្ឌបាតេ ច បច្ចយេ សយនាសនេ

តត្ថ មេ ឩនតា នត្ថិ ពុទ្ធបូជាយិទំ ផលំ ។

---

១ ម. និស្សន្ទេន ។ ២ ម. បេ ។ ៣ ឱ. សីសំ ន្ហាតោ ច អហំ ឃោសោ បុប្ផមា-ភន្តេ ចយន្តិ ទិស្សន្តិ ។ ម. សីសំ ន្ហាតោ ចយំ ឃោសោ បុប្ផមាចរុ ភេចបេន្តិ ទិស្ស-ន្តិ ។ ៤ ឱ. កិលេសា ។ ៥ ឱ.ម. អរហត្តមបាបុណឹ ។ ៦ ឱ.ម. ឧទ ។ ៧ ម. សទា ។





ដ៏ធំបានលាយប្រទេសកណ្ដាល មិនស្រឡាយ កប់ផងតិចបរស់ នេះជានិស្សន្ទនៃកម្ម គឺកិរិយាបូជាបុប្ផានោះ ។ បុរសនេះ ដែលបានបុរាណីកជាតតដោយផ្កាទាំងឡាយ ចាំងល្ងាច ចាំងព្រឹក នឹងទៅជាអ្នកប្រកបដោយបុញ្ញកម្ម ផលនឹងកើតប្រាកដចំពោះមុខ ។ បុរសនេះប្រាថ្នាវត្ថុណា ៗ ដោយកាមទាំងឡាយ វត្ថុនោះ ៗ នឹងកើតប្រាកដ នឹងញ៉ាំងសេចក្ដីប្រាថ្នាឲ្យពេញលេញ ជាអ្នកមិនមានអាសវៈ នឹងបរិនិព្វាន ។

ខ្ញុំដុតបំផ្លាញពួកកិលេសចោលហើយ ជាអ្នកដឹងខ្លួន ទាំងមានស្មារតី អង្គុយលើអាសនៈតែមួយ ក៏បានដល់នូវព្រះអរហត្ត ។ ខ្ញុំកំពុងដើរ កំពុងដេក កំពុងអង្គុយឬឈរ ក៏នឹកទៅរកព្រះពុទ្ធដ៏ប្រសើរ គ្រប់កាលនោះ ៗ គ្រប់វេលានោះ ខ្ញុំឥតមានសេចក្ដីខ្វះខាតដោយចីវរប្បច្ច័យ បិណ្ឌបាតប្បច្ច័យ និងសេនាសនប្បច្ច័យសោះឡើយ នេះជាផលនៃពុទ្ធបូជា ។

## តតិយំ តិណសូលកឆាទនិយត្ថេរាបទានំ

ឥទានិ បត្តោ អមតំ  សន្តំ បទមនុត្តរំ

សព្វាសវេ បរិញ្ញាយ  វិហរាមិ អនាសវោ ។

ទ្វេនវុតេ ឥតោ កប្បេ  យំ ពុទ្ធមភិបូជយឹ

ទុគ្គតឹ នាភិជានាមិ  ពុទ្ធបូជាយិទំ ផលំ ។

កិលេសា ឈាបិតា មយ្ហំ  ភវា សព្វេ សមូហតា

នាគោវ ពន្ធនំ ឆេត្វា  វិហរាមិ អនាសវោ ។

ស្វាគតំ វត មេ អាសិ  មម ពុទ្ធស្ស សន្តិកេ

តិស្សោ វិជ្ជា អនុប្បត្តា  កតំ ពុទ្ធស្ស សាសនំ ។

បដិសម្ភិទា ចតស្សោ  វិមោក្ខាបិច អដ្ឋិមេ

ឆឡភិញ្ញា សច្ឆិកតា  កតំ ពុទ្ធស្ស សាសនន្តិ ។

ឥត្ថំ សុទំ អាយស្មា តិណសូលកឆាទនិយោ ថេរោ ឥមា គាថាយោ អភាសិត្ថាតិ ។

តិណសូលកឆាទនិយត្ថេរស្ស អបទានំ សមត្តំ ។



## តិណសូលកឆាទនិយត្ថេរាបទាន ទី ៣

ឥឡូវនេះ ខ្ញុំនោះបានដល់អមតបទ គឺព្រះនិព្វាន ជាស្ថាន-ដ៏ស្ងប់ប្រសើរ ខ្ញុំកំណត់ដឹង នូវអាសវៈទាំងពួង ជាអ្នកមិនមានអាសវៈ ។ ក្នុងកប្បទី ៩២ អំពីកប្បនេះ ព្រោះហេតុដែលខ្ញុំបានបូជាព្រះពុទ្ធ ក្នុងកាលនោះ ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃពុទ្ធបូជា ។ កិលេសទាំងឡាយ ខ្ញុំបានដុតបំផ្លាញអស់ហើយ ភពទាំងពួង ខ្ញុំបានគាស់រំលើងចោលអស់ហើយ ខ្ញុំជាបុគ្គលមិនមានអាសវៈ ដូចជាដំរីប្រសើរ កាត់ផ្តាច់នូវចំណង ។ ឱ! ដំណើរដែលខ្ញុំមក ក្នុងសំណាក់ព្រះពុទ្ធរបស់ខ្ញុំ ជាដំណើរល្អហោង វិជ្ជា ៣ ខ្ញុំបានដល់តាមលំដាប់ហើយ សាសនា របស់ព្រះពុទ្ធ ខ្ញុំក៏បានធ្វើរួចហើយ ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនា របស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ។

បានឮថា ព្រះតិណសូលកឆាទនិយត្ថេរ មានអាយុ បានសម្តែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

ចប់ តិណសូលកឆាទនិយត្ថេរាបទាន ។

## ចតុត្ថំ មធុមំសទាយកត្ថេរាបទានំ

(៤) នគរេ ពន្ធុមតិយា សូករិកោ អហោសហំ
ឧក្កោដកំ រន្ធយិត្វា មធុមំសម្ហិ ឱកិរឹ(១) ។
សន្និបាតំ អហំ គន្ត្វា ឯកំ បត្តំ អហំ គហឹ(២)
បូរយិត្វាន តំ បត្តំ ភិក្ខុសង្ឃស្សទាសហំ ។
យោ វុឌ្ឍថេរកោ ភិក្ខុ និយ្យាទេសិ អហំ តទា(៣)
ឥមិនា បត្តបូរេន លភិសំ(៤) វិបុលំ សុខំ ។
ទុវេ សម្បត្តិយោ ភុត្វា សុក្កមូលេន ចោទិតោ
បច្ឆិមេ វត្តមានម្ហិ កិលេសេ ឈាបយិស្សតិ(៥)។
តត្ថ ចិត្តំ បសាទេត្វា តាវតឹសំ អគញ្ឆហំ(៦)
តត្ថ ភុត្វា បិវិត្វា ច លភាមិ វិបុលំ សុខំ ។
មណ្ឌបេ រុក្ខមូលេ វា បុព្វកម្មំ អនុស្សរឹ
អន្នបានាភិវស្សន្ត មេ អភិវស្សតិ តាវទេ ។

---

១ ឱ. មធុសប្បិត្តិ អាកិរឹ ។ ២ ឱ. គហេសហំ ។ ៣ ឱ. ម. យោ ច តត្ថ ថេរកោ ភិក្ខុ និយ្យា-ទេសិ មមំ តទា ទំស្សន្តិ ។ ៤ ឱ. ម. លភស្សុ ។ ៥ អឈាបយិស្សតិ យុត្តតរមេវ ។ ៦ ឱ. ម. អគច្ឆហំ ។





## មធុមំសទាយកត្ថេរាបទាន ទី ៤

(៤) ខ្ញុំជាអ្នកសម្លាប់ជ្រូក នៅក្នុងក្រុងពន្ធុមតី បានចំអិន គ្រឿងរងស ហើយរោយលើសាច់មានរសឆ្ញាញ់ ។ ខ្ញុំចូល ទៅកាន់ទីប្រជុំ ហើយបានយកបាត្រមួយ មកដាក់បំពេញ ដោយសាច់ឆ្ញាញ់នោះ ហើយប្រគេនដល់ព្រះភិក្ខុសង្ឃ ។ កាលនោះ ភិក្ខុអង្គណាជាថេរៈ ចាស់ជាងគេ ខ្ញុំក៏ប្រគេន ភិក្ខុនោះ ខ្ញុំបាននូវសេចក្តីសុខដ៏ទូលាយ ដោយសារការ បំពេញបាត្រ ដោយសាច់ឆ្ញាញ់នោះ ។ ខ្ញុំបានទទួលនូវ សម្បត្តិទាំងពីរ ត្រូវកុសលមូលដាស់តឿន ក៏បានដុតបំផ្លាញ កិលេស ក្នុងបច្ឆិមកាលដែលកំពុងប្រព្រឹត្តទៅ ។ ខ្ញុំធ្វើចិត្តឲ្យ ជ្រះថ្លាក្នុងទីនោះហើយ បានទៅកើតឯឋានតាវត្តិង្ស ខ្ញុំស៊ីក្តី ផឹកក្តី តែងបានសេចក្តីសុខដ៏ទូលំទូលាយ ក្នុងឋាននោះ ។ ខ្ញុំតែងរលឹកឃើញនូវបុព្វកម្ម ក្នុងមណ្ឌប ឬក្រោមគល់ឈើ គ្រឿងគឺបាយនិងទឹកតែងបង្អុរចុះដល់ខ្ញុំ ក្នុងខណៈនោះ ។

បាឡី មធុបិណ្ឌសាយកត្ថេរាបទានំ

ឥទំ បច្ឆិមកំ មយ្ហំ   ចរិមោ វត្តតេ ភវោ
ឥធាបិ អឆ្នចាំង មេ   វិស្សរេ សព្វកាលិកំ ។
គោចរំ មធុទានេន(១)   សព្វាវត្វា ករេ អហំ
សព្វាសវេ បរិញ្ញាយ   វិហរាមិ អនាសវោ ។
ឯកនវុតេ ឥតោ កប្បេ   យំ ទានមទទឹ តទា
ទុគ្គតឹ នាភិជានាមិ   មធុទានស្សិទំ ផលំ ។
កិលេសា ឈាបិតា មយ្ហំ   ភវា សព្វេ សមូហតា
នាគោវ ពន្ធនំ ឆេត្វា   វិហរាមិ អនាសវោ ។
ស្វាគតំ វត មេ អាសិ   មម ពុទ្ធស្ស សន្តិកេ
តិស្សោ វិជ្ជា អនុប្បត្តា   កតំ ពុទ្ធស្ស សាសនំ ។

---
១ ម. ឱសធានេន ។



បទុមសាយកត្ថេរាបទាន ទី ៤

នេះកន្លកាយខាងក្រោយបំផុតរបស់ខ្ញុំ ភពជាទីបំផុតរបស់ខ្ញុំ កំពុងប្រព្រឹត្តទៅ ចំណែកខាងបាយនិងទឹក របស់បុរុស មកដើម្បីខ្ញុំ ក្នុងទីនេះ សព្វ ៗ ពេល ។ ខ្ញុំអន្ទោលទៅក្នុងភព កំណត់ដឹងនូវអាសវៈទាំងអស់ ជាអ្នកមិនមានអាសវៈ ដោយការឲ្យនូវសាក់ មានសេចក្ដីញ្ញាត់នោះឯង ។ ក្នុងកប្បទី ៩១ អំពីកប្បនេះ ព្រោះហេតុដែលខ្ញុំបានឲ្យទាន ក្នុងកាលនោះ ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃការឲ្យនូវសាក់ មានសេចក្ដីញ្ញាត់នោះឯង ។ កិលេសទាំងឡាយ ខ្ញុំបានដុតបំផ្លាញហើយ ភពទាំងអស់ ខ្ញុំបានគាស់រំលើងហើយ ខ្ញុំជាបុគ្គលមិនមានអាសវៈ ដូចជាដំរីដ៏ប្រសើរកាត់ផ្ដាច់នូវទន្លីង ។ ឱ ! ដំណើរដែលខ្ញុំមក ក្នុងសំណាក់ព្រះពុទ្ធរបស់ខ្ញុំ ជាដំណើរល្អហ្ន៎ វិជ្ជា ៣ ខ្ញុំបានដល់ហើយ លំដាប់ហើយ សាសនារបស់ព្រះពុទ្ធ ខ្ញុំក៏បានធ្វើហើយ ។

បដិសម្ភិទា ចតស្សោ វិមោក្ខាបិច អដ្ឋិមេ
ឆឡភិញ្ញា សច្ឆិកតា កតំ ពុទ្ធស្ស សាសនន្តិ ។

ឥត្ថំ សុទំ អាយស្មា មធុមំសទាយកោ ថេរោ ឥមា គាថាយោ អភាសិត្ថាតិ ។

មធុមំសទាយកត្ថេរស្ស អបទានំ សមត្តំ ។

## បញ្ចមំ នាគបល្លវកត្ថេរាបទានំ

(៥) នគរេ ពន្ធុមតិយា រាជុយ្យានេ វសាមហំ
មម អស្សមសាមន្តា និសីទិ លោកនាយកោ ។
នាគបល្លវមាទាយ ពុទ្ធស្ស អភិរោបយិំ
បសន្នចិត្តោ សុមនោ សុគតំ អភិវាទយិំ ។
ឯកនវុតេ ឥតោ កប្បេ យំ បល្លវមភិបូជយិំ
ទុគ្គតិំ នាភិជានាមិ ពុទ្ធបូជាយិទំ ផលំ ។
កិលេសា ឈាបិតា មយ្ហំ ភវា សព្វេ សមូហតា
នាគោវ ពន្ធនំ ឆេត្វា វិហរាមិ អនាសវោ ។



បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ តាំងសាសនា របស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ។

បានឮថា ព្រះមធុមំសទាយកត្ថេរ មានអាយុ បានសម្តែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

ចប់ មធុមំសទាយកត្ថេរាបទាន ។

## នាគបល្លវកត្ថេរាបទាន ទី ៥

(៥) ខ្ញុំនៅក្នុងឧទ្យានរបស់ព្រះរាជា ក្នុងក្រុងពន្ធុមតី ឯព្រះលោកនាយក គង់ជិតអាស្រមរបស់ខ្ញុំ ។ ខ្ញុំមានចិត្តជ្រះថ្លា មានចិត្តរីករាយ បានយកស្លឹកខ្ទឹងទៅបូជាព្រះពុទ្ធ ហើយថ្វាយបង្គំព្រះសុគត ។ ក្នុងកប្បទី ៩១ អំពីកប្បនេះ ព្រោះហេតុដែលខ្ញុំ បានបូជាស្លឹក ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃពុទ្ធបូជា ។ កិលេសទាំងឡាយ ខ្ញុំដុតបំផ្លាញហើយ ភពទាំងអស់ ខ្ញុំគាស់រំលើងហើយ ខ្ញុំជាបុគ្គលមិនមានអាសវៈ ដូចដំរីដ៏ប្រសើរកាត់ផ្តាច់ខ្សែទន្លីង ។

ស្វាគតំ វត មេ អាសិ មម ពុទ្ធស្ស សន្តិកេ
តិស្សោ វិជ្ជា អនុប្បត្តា កតំ ពុទ្ធស្ស សាសនំ ។
បដិសម្ភិទា ចតស្សោ វិមោក្ខាបិច អដ្ឋិមេ
ឆឡភិញ្ញា សច្ឆិកតា កតំ ពុទ្ធស្ស សាសនន្តិ ។

ឥត្ថំ សុទំ អាយស្មា នាគបល្លវកោ ថេរោ ឥមា គាថាយោ អភាសិត្ថាតិ ។

នាគបល្លវកត្ថេរស្ស អបទានំ សមត្តំ ។

## ឆដ្ឋំ ឯកទីបិយត្ថេរាបទានំ

(៦) បរិនិព្វុតម្ហិ សុគតេ សិទ្ធត្ថេ លោកនាយកេ
សទេវមានុសា សព្វេ បូជេន្តិ ទិបទុត្តមំ ។
អារោបិតេ ច ចិតកេ សិទ្ធត្ថេ លោកនាយកេ
យថាសកេន ថាមេន ចិតំ បូជេន្តិ សត្ថុនោ ។





៧ ។ ដំណើរដែលខ្ញុំមក ក្នុងសំណាក់នៃព្រះពុទ្ធរបស់ខ្ញុំ ជាដំណើរល្អហ្ន៎ វិជ្ជា ៣ ខ្ញុំបានដល់តាមលំដាប់ហើយ សាសនារបស់ព្រះពុទ្ធ ខ្ញុំក៏បានធ្វើរួចហើយ ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនា របស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ។

បានឮថា ព្រះនាគបល្លវកត្ថេរ មានអាយុ បានសំដែង គាថាទាំងនេះ ដោយប្រការដូច្នេះ ។

ចប់ នាគបល្លវកត្ថេរាបទាន ។

## ឯកទីបិយត្ថេរាបទាន ទី ៦

(៦) កាលព្រះសុគតព្រះនាមសិទ្ធត្ថៈ ជាលោកនាយក ទ្រង់បរិនិព្វានហើយ ពួកមនុស្សទាំងទេវតាទាំងអស់ នាំគ្នាបូជាព្រះពុទ្ធដ៏ឧត្តម ជាងសត្វជើងពីរ ។ កាលដែលព្រះសិទ្ធត្ថៈ ជាលោកនាយក ដែលគេលើកដាក់លើជើងថ្ករហើយ ពួកមនុស្សព្រមទាំងទេវតា នាំគ្នាបូជាជើងថ្ករ នៃព្រះសាស្តា តាមសមគួរដល់កម្លាំង នៃសក្តារបស់ខ្លួន ។

សាក្ខរេ ចិតកាសស្ស ទីបំ ឧជ្ជាលយឹ អហំ
យាវ ឧទេតិ សុរិយោ ទីបំ មេ តាវ បជ្ជលិ ។
តេន កម្មេន សុកតេន ចេតនាបណិធីហិ ច
ជហិត្វា មានុសំ ទេហំ តាវតឹសំ អគញ្ឆហំ ។
តត្ថ មេ សុកតំ ព្យម្ហំ ឯកទីបន្តិ ញាយតិ
ទីបសតសហស្សានិ ព្យម្ហេ បជ្ជលរេ មម ។
ឧទយន្តោវ សុរិយោ ទេហោ មេ ជលតេ សទា
សប្បភាហិ(១) សរីរស្ស អាលោកោ ហោតិ មេ សទា ។
តិរោកុឌ្ឌំ តិរោសេលំ សមតិគ្គយ្ហ បព្វតំ
សមន្តា យោជនសតំ ទស្សាមិ ចក្ខុនា អហំ ។
សត្តសត្តតិក្ខត្តុំ ច ទេវលោកេ រមឹ អហំ
ឯកត្តឹសតិក្ខត្តុំ ច ទេវរជ្ជំ អការយឹ ។
អដ្ឋវីសតិក្ខត្តុំ ច ចក្កវត្តិ អហោសហំ
បទេសរជ្ជំ វិបុលំ គណនាតោ អសង្ខិយំ ។

---

១ ឱ. សព្ភាភាហំ ។



ខ្ញុំបានបូជាប្រទីប ក្នុងទីជិតដើមឈើ ប្រទីបរបស់ខ្ញុំ ឆេះភ្លឺ ដរាបព្រះអាទិត្យរះឡើង ។ ខ្ញុំបានលះបង់នូវរាងកាយ ជារបស់មនុស្ស ទៅកើតឯឋានតាវត្តិង្ស ដោយកម្មដែលខ្ញុំធ្វើល្អហើយនោះផង ដោយការតាំងសេចក្តីចេតនានោះផង ។ វិមានរបស់ខ្ញុំ ដែលបុញ្ញកម្មធ្វើល្អហើយ ក្នុងឋានតាវត្តិង្សនោះ គេតែងស្គាល់ថា វិមានឈ្មោះឯកទីប ព្រោះមានប្រទីបមួយសែន រុងរឿង ក្នុងវិមានរបស់ខ្ញុំនោះ ។ កាយរបស់ខ្ញុំ តែងរុងរឿងសព្វកាល ដូចព្រះអាទិត្យកាលរះឡើង ពន្លឺសរីរៈ របស់ខ្ញុំ តែងមានសព្វ ៗ កាល ជាដរាបទីមាំងឡាយ ។ ខ្ញុំមានភ្នែកៈមើលឃើញទៅ ខាងក្រៅជញ្ជាំង ខាងក្រៅភ្នំ កន្លងភ្នំ មួយរយយោជន៍ជុំវិញ ។ ខ្ញុំបានត្រេកអរក្នុងទេវលោក អស់ ៧៧ ដង បានសោយរាជ្យ ជាស្តេចទេវតាអស់ ៣១ ដង ។ ខ្ញុំបានជាស្តេចចក្រពត្តិ អស់ ២៨ ដង សោយបទេសរាជ្យ ដ៏ធំទូលាយ រាប់ជាគិតមិនអស់ ។

## ៥៩ ឯកទីបិយត្ថេរាបទានំ

ទេវលោកា ចវិត្វាន ឱក្កន្តិំ មាតុកុច្ឆិយំ
មាតុកុច្ឆិគតេ សន្តេ អក្ខិ មេ ន វិនស្សតិ(១) ។
ជាតិយា ចតុវស្សោហំ បព្វជឹ អនគារិយំ
អឌ្ឍមាសេ អសម្បត្តេ អរហត្តំ អបាបុណឹ ។
ទិព្វចក្ខុំ វិសោធេសឹ ភវា សព្វេ សមូហតា
សព្វេ កិលេសា សញ្ឆិន្នា ឯតំ ទីបស្សិទំ ផលំ ។
តិរោកុឌ្ឌំ តិរោសេលំ បព្វតញ្ចាបិ កេវលំ
សមតិក្កម្ម បស្សាមិ ឯតំ ទីបស្សិទំ ផលំ ។
វិសមា មេ សមា ហោន្តិ អន្ធការោ ន វិជ្ជតិ
នាហំ បស្សាមិ តិមិរំ ឯតំ ទីបស្សិទំ ផលំ ។
ឯកនវុតេ ឥតោ កប្បេ យំ ទីបមទទឹ តទា
ទុគ្គតឹ នាភិជានាមិ ឯតំ ទីបស្សិទំ ផលំ ។
កិលេសា ឈាបិតា មយ្ហំ ភវា សព្វេ សមូហតា
នាគោវ ពន្ធនំ ឆេត្វា វិហរាមិ អនាសវោ ។

១ ឱ. ន ទិស្សតិ ។ ម. ន វិទ្ធំសតិ ។



## ឯកទីបិយត្ថេរាបទាន ទី ៦

កាលខ្ញុំច្យុតចាកទេវលោក មកកើតក្នុងផ្ទៃមាតា សូម្បីកាលខ្ញុំនៅក្នុងផ្ទៃមាតា ភ្នែករបស់ខ្ញុំឥតខ្វាក់ឡើយ ។ ខ្ញុំមានអាយុ ៤ ឆ្នាំ បានចូលទៅកាន់ផ្នួស មិនទាន់បានកន្លះខែ ខ្ញុំក៏បានសម្រេចអរហត្ត ។ ខ្ញុំបានជំរះទិព្វចក្ខុ ភពទាំងអស់ ខ្ញុំបានគាស់រំលើងហើយ កិលេសទាំងអស់ ខ្ញុំបានផ្តាច់ផ្តិលហើយ នេះជាផលនៃប្រទីបមួយ ។ ខ្ញុំមើលឃើញទៅ ខាងក្រៅជញ្ជាំង ទាំងខាងក្រៅភ្នំ ក្នុងភ្នំទាំងអស់ នេះជាផលនៃប្រទីបមួយ ។ ប្រទេសទាំងឡាយដែលមិនរាបស្មើ ត្រឡប់ទៅជារាបស្មើ សម្រាប់ខ្ញុំ ខ្ញុំមិនមានងងឹត ខ្ញុំមិនដែលឃើញងងឹតសោះឡើយ នេះជាផលនៃប្រទីបមួយ ។ ក្នុងកប្បទី ៩៤ អំពីកប្បនេះ ព្រោះហេតុដែលខ្ញុំបានថ្វាយប្រទីប ក្នុងកាលនោះ ខ្ញុំមិនដែលស្គាល់ទុគ៌តិ នេះជាផលនៃប្រទីបមួយ ។ កិលេសទាំងឡាយ ខ្ញុំបានដុតបំផ្លាញហើយ ភពទាំងអស់ ខ្ញុំបានគាស់រំលើងហើយ ខ្ញុំជាបុគ្គលមិនមានអាសវៈ ដូចជាដំរីប្រសើរកាត់ផ្តាច់ខ្សែទន្លីង ។

ស្វាគតំ វត មេ អាសិ មម ពុទ្ធស្ស សន្តិកេ
តិស្សោ វិជ្ជា អនុប្បត្តា កតំ ពុទ្ធស្ស សាសនំ ។
បដិសម្ភិទា ចតស្សោ វិមោក្ខាបិច អដ្ឋិមេ
ឆឡភិញ្ញា សច្ឆិកតា កតំ ពុទ្ធស្ស សាសនំ ។

ឥត្ថំ សុទំ អាយស្មា ឯកទីបិយោ ថេរោ ឥមា គាថាយោ អភាសិត្ថាតិ ។

ឯកទីបិយត្ថេរស្ស អបទានំ សមត្តំ ។

## សត្តមំ ឧច្ឆង្គបុប្ផិយត្ថេរាបទានំ

[៧] នគរេ ពន្ធុមតិយា អហោសឹ មាលិកោ តទា
ឧច្ឆង្គំ បូរយិត្វាន អគមំ អន្តរាបណំ ។
ភគវា តម្ហិ សមយេ ភិក្ខុសង្ឃបុរក្ខតោ
មហតា អានុភាវេន និយ្យាតិ លោកនាយកោ ។
ទិស្វាន លោកបជ្ជោតំ វិបស្សឹ លោកតារណំ
បគ្គយ្ហ ឧច្ឆង្គំ ពុទ្ធសេដ្ឋំ អបូជយឹ ។



៩ ។ ដំណើរដែលខ្ញុំមក ក្នុងសំណាក់ព្រះពុទ្ធរបស់ខ្ញុំ ជាដំណើរល្អហ្ន៎ វិជ្ជា ៣ ខ្ញុំបានដល់តាមលំដាប់ហើយ សាសនា របស់ព្រះពុទ្ធ ខ្ញុំបានធ្វើរួចហើយ ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនា របស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ។

បានឮថា ព្រះឯកទីបិយត្ថេរ មានអាយុ បានសម្ដែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

ចប់ ឯកទីបិយត្ថេរាបទាន ។

## ឧច្ឆង្គបុប្ផិយត្ថេរាបទាន ទី ៧

(៧) កាលនោះ ខ្ញុំជាអ្នកក្រងផ្កា នៅក្នុងក្រុងពន្ធុមតី ខ្ញុំបានដាក់ផ្កាពេញថ្នក់ ហើយដើរទៅផ្សារ ។ សម័យនោះ ព្រះមានព្រះភាគ ជាលោកនាយក មានភិក្ខុសង្ឃចោមរោម កំពុងស្ដេចទៅ ដោយអានុភាពដ៏ធំ ។ ខ្ញុំបានឃើញព្រះវិបស្សី ព្រះអង្គបំភ្លឺលោក ទ្រង់ចម្លងសត្វលោក ហើយយកផ្កាអំពីថ្នក់ បូជាព្រះពុទ្ធដ៏ប្រសើរ ។

សត្តមំ ឧបដ្ឋាយកត្ថេរាបទានំ

ឯកនវុតេ ឥតោ កប្បេ ពុទ្ធសេដ្ឋំ ឧបដ្ឋហឹ

ទុគ្គតិំ នាភិជានាមិ ពុទ្ធបូជាយិទំ ផលំ ។

កិលេសា ឈាបិតា មយ្ហំ ភវា សព្វេ សមូហតា

នាគោវ ពន្ធនំ ឆេត្វា វិហរាមិ អនាសវោ ។

ស្វាគតំ វត មេ អាសិ មម ពុទ្ធស្ស សន្តិកេ

តិស្សោ វិជ្ជា អនុប្បត្តា កតំ ពុទ្ធស្ស សាសនំ ។

បដិសម្ភិទា ចតស្សោ វិមោក្ខាបិ ច អដ្ឋិមេ

ឆឡភិញ្ញា សច្ឆិកតា កតំ ពុទ្ធស្ស សាសនំ ។

ឥត្ថំ សុទំ អាយស្មា ឧបដ្ឋាយកោ ថេរោ ឥមា គាថាយោ អភាសិត្ថាតិ ។

ឧបដ្ឋាយកត្ថេរស្ស អបទានំ សមត្តំ ។

ឧបដ្ឋាយកត្ថេរាបទាន ទី ៧

ក្នុងកប្បទី ៩១ អំពីកប្បនេះ ព្រោះហេតុដែលខ្ញុំបានបម្រើព្រះពុទ្ធដ៏ប្រសើរ ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃពុទ្ធបូជា ។ កិលេសទាំងឡាយ ខ្ញុំបានដុតបំផ្លាញហើយ ភពទាំងអស់ ខ្ញុំបានគាស់រំលើងចោលហើយ ខ្ញុំជាបុគ្គលមិនមានអាសវៈ ដូចជាដំរីដ៏ប្រសើរ កាត់ផ្តាច់ខ្សែចំណង ។ ឱ! ដំណើរដែលខ្ញុំមក ក្នុងសំណាក់ព្រះពុទ្ធរបស់ខ្ញុំ ជាដំណើរល្អហ្ន៎ វិជ្ជា ៣ ខ្ញុំបានដល់តាមលំដាប់ហើយ សាសនារបស់ព្រះពុទ្ធ ខ្ញុំបានធ្វើរួចហើយ ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនា របស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ។

បានឮថា ព្រះឧបដ្ឋាយកត្ថេរ មានអាយុ បានសំដែងគាថាទាំងនេះ ដោយប្រការដូច្នេះ ។

ចប់ ឧបដ្ឋាយកត្ថេរាបទាន ។

## អដ្ឋមំ យាគុទាយកត្ថេរាបទានំ

(៨) អាហុតឹ(១) មេ គហេត្វាន អាគច្ឆឹ គាមកំ តទា

សម្បុណ្ណំ នទិកំ ទិស្វា សង្ឃារាមំ ឧបាគមឹ ។

អារញ្ញកា ធុតធរា ឈាយិនោ លូខចីវរា

វិវេកាភិរតា ធីរា សង្ឃារាមេ វសន្តិ តេ ។

គតិ តេសំ ឧបច្ឆិន្នា សុវិមុត្តាន តាទិនំ

បិណ្ឌាយ តេ ន គច្ឆន្តិ ឱរុទ្ធនទិកាយតិ(២) ។

បសន្នចិត្តោ សុមនោ វេទជាតោ កតញ្ជលី

តណ្ឌុលំ គហេត្វាន យាគុទានំ អទាសហំ ។

បចនំ(៣) យាគុំ ទត្វាន បសន្នោ សេហិ បាណិភិ

សកកម្មាភិរទ្ធោហំ តាវតឹសំ អគច្ឆហំ ។

មណិមយញ្ច មេ ព្យម្ហំ និព្វត្តិ(៤) តិទសេ គណេ

នារីគណេហិ សហិតោ(៥) មោទាមិ ព្យម្ហុត្តមេ ។

---

១ ម. អគ្គឹ ។ ២ ម. ទុរុទ្ធំ នទិកាយតិ ។ ៣ ឱ.ម. បច្ចនំ ។ ៤ ម. និព្វត្តិ ។ ៥ ឱ. សហិតោ ។ ម. មហិតោ ។



## យាគុទាយកត្ថេរាបទាន ទី ៨

(៨) កាលនោះ ខ្ញុំនាំគៀវរបស់ខ្ញុំ មកកាន់ស្រុកតូច បានឃើញស្ទឹងមានទឹកពេញច្រាំង ហើយដើរចូលទៅកាន់អារាមរបស់សង្ឃ ។ ភិក្ខុទាំងនោះ ជាអ្នកនៅក្នុងព្រៃ ប្រព្រឹត្តធុតង្គ មានឈាន មានចីវរដ៏សៅហ្មង ត្រេកអរក្នុងវិវេក ជាអ្នកប្រាជ្ញ នៅក្នុងអារាមរបស់សង្ឃ ។ ភិក្ខុទាំងនោះ លោកជាអ្នករួចស្រឡះល្អហើយ ប្រកបដោយតាទិគុណ មានដំណើរដាច់ហើយ ភិក្ខុទាំងនោះមានស្ទឹងស្ទះផ្លូវ ក៏ខានទៅបិណ្ឌបាត ។ ខ្ញុំមានចិត្តជ្រះថ្លា មានចិត្តរីករាយ មានចិត្តត្រេកអរ ហើយធ្វើអញ្ជលី យកអង្ករធ្វើបបរ ប្រគេនយាគុទាន ។ ខ្ញុំមានចិត្តជ្រះថ្លា ប្រគេនបបរ ដែលចំអិនហើយ ដោយដៃរបស់ខ្លួន ព្រោះកម្មរបស់ខ្លួន បានទៅកើតឯឋានតាវត្តិង្ស ។ វិមានជាវិការៈនៃកែវមណី កើតសម្រាប់ខ្ញុំ ក្នុងពួកទេវតាឋានតាវត្តិង្ស ខ្ញុំប្រកបដោយពួកនារី ត្រេកអរ ក្នុងវិមានដ៏ប្រសើរ ។

អដ្ឋមំ ពាកុលត្ថេរាបទានំ

តេត្តឹសក្ខត្តុំ ទេវិន្ទោ   ទេវរជ្ជមការយឹ
តឹសក្ខត្តុំ ចក្កវត្តិ   មហារជ្ជមការយឹ ។
បទេសរជ្ជំ វិបុលំ   គណនាតោ អសង្ខិយំ
ទេវលោកេ មនុស្សេ ច   អនុភោត្វា យសំ អហំ ។
បច្ឆិមេ ភវសម្បត្តេ   បព្វជឹ អនគារិយំ
សហ ឱរោបិតេ កេសេ   សព្វសម្បត្តិ រជ្ជហំ ។
ឧទយតោ វយតោ ញាណំ   សម្មសន្តោ កលេវរំ
បុរេ សិក្ខាបទានេន   អរហត្តំ អបាបុណឹ ។
សុទិន្នំ មេ ទានវរំ   ចាណាបិ សុប្បយោជិតំ(១)
តេនេវ យាគុទានេន   បត្តោម្ហិ អចលំ បទំ ។
សោកំ បរិទ្ទវំ ព្យាធឹ   ទរថំ ចិត្តតាបនំ
នាភិជានាមិ ឧប្បន្នំ   យាគុទានស្សិទំ ផលំ ។

១ ឱ. សម្បយោជិតំ ។



ពាកុលត្ថេរាបទាន ទី ៨

ខ្ញុំបានជាព្រះឥន្ទ្រ សោយរាជ្យជាស្តេចនៃទេវតា អស់ ៣៣ ដង បានសោយរាជ្យដ៏ធំ ជាស្តេចចក្រពត្តិ អស់ ៣០ ដង បានសោយប្រទេសរាជ្យ ដ៏ធំទូលាយ រាប់ជាគណនាមិនអស់ ខ្ញុំសោយនូវយស ក្នុងទេវលោកនិងមនុស្សលោក ។ ក្នុងកាលដែលដល់នូវភពជាទីបំផុត ខ្ញុំបានលះបង់សម្បត្តិទាំងអស់ ព្រមទាំងសក់ដែលគេកោរកាត់ រួចហើយចូលទៅកាន់ផ្នួស ។ មួយវិញទៀត កាលខ្ញុំពិចារណានូវសាកសពដោយកិរិយាអស់ទៅនិងការសូន្យទៅ ក៏បានសម្រេចព្រះអរហត្ត ដោយការបំពេញនូវសិក្ខា ក្នុងកាលមុន ។ ទានដ៏ប្រសើរ ខ្ញុំបានឲ្យហើយដោយប្រពៃ ទានកើតឡើងដោយដៃ ខ្ញុំបានប្រកបប្រពៃហើយ ខ្ញុំជាបុគ្គលបានដល់នូវអចលបទ គឺនិព្វាន ដោយយាគុទាននោះឯង ។ ខ្ញុំមិនដែលស្គាល់សេចក្តីសោក សេចក្តីខ្សឹកខ្សួល ការឈឺចាប់ ក្រវល់ក្រវាយនិងសេចក្តីក្តៅក្រហាយចិត្ត ដែលកើតឡើយ នេះជាផលនៃយាគុទាន ។

យាគុំ សង្ឃស្ស ទត្វាន បុញ្ញក្ខេត្តេ អនុត្តរេ
បញ្ចានិសំសេ អនុភោមិ អហោ យាគុសុយិដ្ឋតា ។
អព្យាធិតា រូបវតា ខិប្បំ ធម្មំ និតុជ្ឈិតា(១)
លាភិតា អន្នបានស្ស អាយុបញ្ចមកំ មម ។
យោ កោចិ វេទំ ទទយំ សង្ឃេ យាគុំ ទទេយ្យ សោ
ឥមានិ បញ្ច ឋានានិ បដិគ្គណ្ហេយ្យ បណ្ឌិតោ ។
ករណីយំ កតំ សព្វំ ភវា ឧគ្ឃាដិតា មយា
សព្វាសវា បរិក្ខីណា(២) នត្ថិ ទានិ បុនព្ភវោ ។
សោ អហំ វិចរិស្សាមិ គាមា គាមំ បុរា បុរំ
នមស្សមានោ សម្ពុទ្ធំ ធម្មស្ស ច សុធម្មតំ ។

១ ឱ.ម. ខិប្បំ ធម្មនិសន្តិតា ។ ២ ឱ.ម. សព្វាសវបរិក្ខីណោ ។



ខ្ញុំបានប្រគេនបបរដល់ព្រះភិក្ខុសង្ឃ ជាបុញ្ញក្ខេត្តដ៏ប្រសើរបំផុត ហើយ ក៏បានទទួលអានិសង្ស ៥ ប្រការ ឱហ្ន៎ ! ការដែលបបរខ្ញុំបានបូជាស្រួលហើយ ។ (អានិសង្ស ៥ ប្រការនោះ គឺ) ភាពជាអ្នកមិនមានជម្ងឺដម្កាត់ ១ ភាពជាអ្នកមានរូបល្អ ១ ភាពជាអ្នកត្រាស់ដឹងនូវធម៌ឆាប់ ១ ភាពជាអ្នកបានបាយនិងទឹកជាប្រក្រតី ១ ខ្ញុំមានអាយុវែង ជាគំរប់ ៥ ។ បុគ្គលណាមួយកាលធ្វើសេចក្តីត្រេកអរឲ្យកើត គប្បីប្រគេនបបរចំពោះព្រះសង្ឃ បុគ្គលនោះឈ្មោះថាបណ្ឌិត តែងទទួលឋានៈ ៥ ប្រការនេះឯង ។ ករណីយកិច្ចទាំងអស់ ខ្ញុំបានធ្វើរួចហើយ ភពទាំងឡាយ ខ្ញុំបានគាស់រំលើងចោលហើយ អាសវៈទាំងពួងរបស់ខ្ញុំ អស់រលីងហើយ ឥឡូវនេះ ភពថ្មីទៀតមិនមានទេ ។ ខ្ញុំនោះតែងដើរទៅកាន់ស្រុកតូច-ធំ និងបុរីតូច-ធំ តែងថ្វាយបង្គំនូវព្រះសម្ពុទ្ធ និងព្រះធម៌ជាសភាវៈដ៏ល្អ ។

អដ្ឋមំ យាគុទាយកត្ថេរាបទានំ

តិំសកប្បសហស្សម្ហិ យំ ទានមទទឹ តទា
ទុគ្គតិំ នាភិជានាមិ យាគុទានស្សិទំ ផលំ ។
កិលេសា ឈាបិតា មយ្ហំ ភវា សព្វេ សមូហតា
នាគោវ ពន្ធនំ ឆេត្វា វិហរាមិ អនាសវោ
ស្វាគតំ វត មេ អាសិ មម ពុទ្ធស្ស សន្តិកេ
តិស្សោ វិជ្ជា អនុប្បត្តា កតំ ពុទ្ធស្ស សាសនំ ។
បដិសម្ភិទា ចតស្សោ វិមោក្ខាបិ ច អដ្ឋិមេ
ឆឡភិញ្ញា សច្ឆិកតា កតំ ពុទ្ធស្ស សាសនន្តិ ។

ឥត្ថំ សុទំ អាយស្មា យាគុទាយកោ ថេរោ ឥមា គាថាយោ អភាសិត្ថាតិ ។

យាគុទាយកត្ថេរស្ស អបទានំ សមត្តំ ។



យាគុទាយកត្ថេរាបទាន ទី ៨

ក្នុងកប្បទី ៣០ ពាន់ អំពីកប្បនេះ ព្រោះហេតុដែលខ្ញុំបានឲ្យទាន ក្នុងកាលនោះ ខ្ញុំពុំដែលស្គាល់ទុគ្គតិ នេះជាផលនៃយាគុទាន ។ កិលេសទាំងឡាយ ខ្ញុំបានដុតបំផ្លាញហើយ ភពទាំងអស់ ខ្ញុំបានគាស់រំលើងចោលហើយ ខ្ញុំជាបុគ្គលមិនមានអាសវៈ ដូចជាដំរីដ៏ប្រសើរ កាត់ផ្តាច់ខ្សែទន្លីង ។ ឱ ! ដំណើរដែលខ្ញុំមក ក្នុងសំណាក់ព្រះពុទ្ធរបស់ខ្ញុំ ជាដំណើរល្អហោង វិជ្ជា ៣ ខ្ញុំបានដល់តាមលំដាប់ហើយ សាសនា របស់ព្រះពុទ្ធ ខ្ញុំបានធ្វើរួចស្រេចហើយ ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនា របស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ។

បានឮថា ព្រះយាគុទាយកត្ថេរ មានអាយុ បានសំដែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

ចប់ យាគុទាយកត្ថេរាបទាន ។

# នវមំ បត្តោទនទាយកត្ថេរាបទានំ

[៩] វនចារី បុរេ អាសឹ សតតំ វនកម្មិកោ

បត្តោទនំ គហេត្វាន កម្មន្តំ អគមាសហំ ។

តត្ថទ្ទសាសឹ សម្ពុទ្ធំ សយម្ភុំ អបរាជិតំ

វនា បិណ្ឌាយ និក្ខន្តំ ទិស្វា ចិត្តំ បសាទយឹ ។

បរកម្មាយនេ(១) យុត្តោ បុញ្ញញ្ច មេ ន វិជ្ជតិ

អយំ បត្តោទនោ អត្ថិ ភោជយិស្សាមិមំ មុនឹ ។

បត្តោទនំ គហេត្វាន សយម្ភុស្ស អទាសហំ

មម និជ្ឈាយមានស្ស បរិភុញ្ជិ មហាមុនិ(២) ។

តេន កម្មេន សុកតេន ចេតនាបណិធីហិ ច

ជហិត្វា មានុសំ ទេហំ តាវតឹសំ អគច្ឆហំ ។

---

១ ឱ. វិយកម្មាយនេ ។ ២ ម. ភត មុនិ ។



# បត្តោទនទាយកត្ថេរាបទាន ទី ៩

[៩] កាលពីកពមុន ខ្ញុំបានកើតជាថ្មើរព្រៃ ប្រកបការក្នុងព្រៃរឿយៗ បានយកបាយដែលចំអិនដោយអង្ករចំនួនមួយបាត្រ ហើយដើរទៅធ្វើការងារ ។ ខ្ញុំបានឃើញព្រះសម្ពុទ្ធ ជាព្រះសយម្ភូ ទ្រង់ឈ្នះមារ ព្រះអង្គកំពុងស្តេចចេញពីព្រៃ ទៅបិណ្ឌបាតក្នុងទីនោះ លុះខ្ញុំបានឃើញហើយ ក៏ញុំាងចិត្តឲ្យជ្រះថ្លាថា អញរវល់តែប្រកបក្នុងការងារ ឲ្យអ្នកដទៃ ចំណែកបុណ្យរបស់អញ មិនមាន ឥឡូវនេះ បាយដែលចំអិនដោយអង្ករមួយបាត្រនេះមាន អញនឹងនិមន្តព្រះមុនីនេះ ឲ្យឆាន់បាយនេះ ។ ខ្ញុំយកបាយដែលចំអិនដោយអង្ករមួយបាត្រ ថ្វាយព្រះសយម្ភូ កាលខ្ញុំកំពុងតែសំឡឹងមើល ព្រះមហាមុនីទ្រង់សោយ ។ ខ្ញុំលះបង់កាយ ជារបស់មនុស្សហើយ បានទៅកើតឯឋានតាវត្តិង្ស ដោយកម្មដែលធ្វើល្អហើយនោះផង ដោយការតាំងចេតនានោះផង ។

## បាលី បត្តោទនទាយកត្ថេរាបទាន

ឆត្តឹសក្ខត្តុំ(១) ទេវិន្ទោ ទេវរជ្ជមការយឹ
តេត្តឹសក្ខត្តុំ រាជា ច ចក្កវត្តិ អហោសហំ(២) ។
បទេសរជ្ជំ វិបុលំ គណនាតោ អសង្ខិយំ
សុខិតោ យសវា ហោមិ បត្តោទនស្សិទំ ផលំ ។
ភវាភវេ សំសរន្តោ លភាមិ អមិតំ ធនំ
ភោគេ មេ ឩនតា នត្ថិ បត្តោទនស្សិទំ ផលំ ។
នទីសោតបដិភាគា ភោគា និព្វត្តរេ មម
បរិមេតុំ ន សក្កោមិ បត្តោទនស្សិទំ ផលំ ។
ឥមំ ខាទ ឥមំ ភុញ្ជ ឥមម្ហិ សយនេ សយ
តេនាហំ សុខិតោ ហោមិ បត្តោទនស្សិទំ ផលំ ។

១ ឱ. ម. ឆត្តឹសក្ខត្តុំ ។



## បត្តោទនទាយកត្ថេរាបទាន ទី ៤

ខ្ញុំបានជាព្រះឥន្ទ្រ សោយរាជ្យជាស្ដេចទេវតា អស់ ៣៦ ដង បានជាស្ដេចចក្រពត្តិ អស់ ៣៣ ដង ។ បានសោយរាជ្យជាក្សត្រប្រទេសរាជ្យ ដ៏ធំទូលាយ រាប់ជាតិមិនអស់ ខ្ញុំជាអ្នកដល់សេចក្ដីសុខ មានយស នេះជាផលនៃបាយដែលចំអិនដោយអង្ករមួយនាឡិ ។ ខ្ញុំកាលអន្ទោលទៅមកក្នុងភពតូចនិងភពធំ រមែងបានទ្រព្យរាប់មិនអស់ ខ្ញុំមិនដែលមានការខ្វះខាតភោគៈឡើយ នេះជាផល នៃបាយដែលចំអិនដោយអង្ករមួយនាឡិ ។ ភោគៈទាំងឡាយដែលមានចំណែកប្រៀបដូចខ្សែទឹកទន្លេ រមែងកើតសម្រាប់ខ្ញុំ ខ្ញុំមិនអាចរាប់ភោគៈទាំងនោះឲ្យសព្វគ្រប់បានឡើយ នេះជាផលនៃបាយដែលចំអិនដោយអង្ករមួយនាឡិ ។ (ពួកជនតែងពោលថា) អ្នកចូរទំពាស៊ីចំណីនេះ ចូរបរិភោគអាហារនេះ ចូរដេកលើដំណេកនេះ ព្រោះហេតុនេះ ខ្ញុំជាបុគ្គលបានសុខស្រួល នេះជាផលនៃបាយ ដែលចំអិនដោយអង្ករមួយនាឡិ ។

ឯកនវុតេ(១) ឥតោ កប្បេ យំ ទានមទទឹ តទា

ទុគ្គតឹ នាភិជានាមិ បត្តោទកស្សិទំ ផលំ ។

កិលេសា ឈាបិតា មយ្ហំ ភវា សព្វេ សមូហតា

នាគោវ ពន្ធនំ ឆេត្វា វិហរាមិ អនាសវោ ។

ស្វាគតំ វត មេ អាសិ មម ពុទ្ធស្ស សន្តិកេ

តិស្សោ វិជ្ជា អនុប្បត្តា កតំ ពុទ្ធស្ស សាសនំ ។

បដិសម្ភិទា ចតស្សោ វិមោក្ខាបិច អដ្ឋិមេ

ឆឡភិញ្ញា សច្ឆិកតា កតំ ពុទ្ធស្ស សាសនន្តិ ។

ឥត្ថំ សុទំ អាយស្មា បត្តោទកទាយកោ ថេរោ

ឥមា គាថាយោ អភាសិត្ថាតិ ។

បត្តោទកទាយកត្ថេរស្ស អបទានំ សមត្តំ ។

---

១ ឱ. ម. ចតុន្នវុតេ ។





ក្នុងកប្បទី ៩១ អំពីកប្បនេះ ព្រោះខ្ញុំបានថ្វាយទាន

ក្នុងកាលនោះ ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃ

ការថ្វាយទឹកដោយភាជនៈ ។ កិលេសទាំងឡាយ ខ្ញុំ

ដុតកំដៅហើយ ភពទាំងអស់ ខ្ញុំគាស់រំលើងហើយ

ហើយ ខ្ញុំជាបុគ្គលមិនមានអាសវៈ ដូចជាដំរីផ្តាច់ទាំង

ចំណង ។ ឱ! ដំណើរដែលខ្ញុំមក ក្នុងសំណាក់ព្រះពុទ្ធ

របស់ខ្ញុំ ជាដំណើរល្អហ្ន៎ វិជ្ជា ៣ ខ្ញុំបានដល់តាមលំដាប់

ហើយ សាសនា របស់ព្រះពុទ្ធ ខ្ញុំបានធ្វើរួចហើយ ។

បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យ

ជាក់ច្បាស់ហើយ ទាំងសាសនា របស់ព្រះពុទ្ធ ខ្ញុំក៏បាន

ប្រតិបត្តិហើយ ។

បានឮថា ព្រះបត្តោទកទាយកត្ថេរ មានអាយុ បានសំដែង

នូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

ចប់ បត្តោទកទាយកត្ថេរាបទាន ។

# ទសមំ មញ្ចទាយកត្ថេរាបទានំ

(១០) បរិនិព្វុតេ ការុណិកេ សិទ្ធត្ថេ លោកនាយកេ
វិត្ថារិកេ បាវចនេ ទេវមនុស្សសក្កតេ ។
ចណ្ឌាលោ អាសហំ តត្ថ អាសន្ទិបីឋការកោ
តេន កម្មេន ជីវាមិ តេន បោសេមិ ទារកេ ។
អាសន្ទឹ សុកតំ កត្វា បសន្នោ សេហិ បាណិភិ
សយមេវ ឧបគន្ត្វា ភិក្ខុសង្ឃស្សទាសហំ ។
តេន កម្មេន សុកតេន ចេតនាបណិធីហិ ច
ជហិត្វា មានុសំ ទេហំ តាវតឹសំ អគច្ឆហំ ។
ទេវលោកគតោ សន្តោ មោទាមិ តិទសេ គណេ
សយនានិ មហគ្ឃានិ និព្វត្តន្តិ យទិច្ឆកំ(១) ។

១ ឱ. ម. យទិច្ឆកំ ។

# មញ្ចទាយកត្ថេរាបទាន ទី ១០

(១០) កាលព្រះលោកនាយក ព្រះនាមសិទ្ធត្ថៈ ប្រកបដោយសេចក្តីករុណា ទ្រង់បរិនិព្វានហើយ កាលសាសនា កំពុងផ្សាយចេញទៅ មានពួកទេវតានិងមនុស្សគោរពសក្ការៈហើយ ។ ខ្ញុំកើតជាមនុស្សចណ្ឌាល អ្នកធ្វើតាំងឈ្មោះអាសន្ទិ (តាំងមានជើង ៤ ស្មើ) ក្នុងទីនោះ ខ្ញុំរស់នៅដោយការងារនោះ ទាំងបានចិញ្ចឹមទារកនិងប្រពន្ធដោយការងារនោះដែរ ។ ខ្ញុំមានចិត្តជ្រះថ្លា បានធ្វើតាំងឈ្មោះអាសន្ទិ វិចិត្រយ៉ាងល្អ ដោយដៃរបស់ខ្លួន ហើយនាំចូលទៅប្រគេនព្រះភិក្ខុសង្ឃ ដោយខ្លួនឯង ។ ខ្ញុំលះបង់នូវកាយ ជារបស់មនុស្សហើយ បានទៅកើតឯឋានតាវត្តិង្ស ដោយកម្មដែលខ្លួនធ្វើល្អហើយនោះផង ដោយការតាំងចេតនានោះផង ។ ខ្ញុំកាលទៅកាន់ទេវលោក ហើយរីករាយ ក្នុងពួកទេវតា នៅឋានតាវត្តិង្ស ទីសម្រាប់ដេកមានថ្លៃច្រើន ក៏កើតឡើងតាមសេចក្តីប្រាថ្នា (របស់ខ្ញុំ) ។

បញ្ញាសក្ខត្តុំ ទេវិន្ទោ  ទេវរជ្ជមការយិំ
អសីតិក្ខត្តុំ រាជា ច  ចក្កវត្តិ អហោសហំ ។
បទេសរជ្ជំ វិបុលំ  គណនាតោ អសង្ខិយំ
សុខិតោ យសវា ហោមិ  មញ្ចទានស្សិទំ ផលំ ។
ទេវលោកា ចវិត្វាន  ឯមិ ចេ មានុសំ ភវំ
មហារហា សុសយនា  សយមេវ ភវន្តិ មេ ។
អយំ បច្ឆិមកោ មយ្ហំ  ចរិមោ វត្តតេ ភវោ
អជ្ជាបិ សយនកាលេ  សយនំ ឧបតិដ្ឋតិ ។
ចតុន្នវុតេ ឥតោ កប្បេ  យំ ទានំ អទទិំ តទា
ទុគ្គតឹ នាភិជានាមិ  មញ្ចទានស្សិទំ ផលំ ។
កិលេសា ឈាបិតា មយ្ហំ  ភវា សព្វេ សមូហតា
នាគោវ ពន្ធនំ ឆេត្វា  វិហរាមិ អនាសវោ ។
ស្វាគតំ វត មេ អាសិ  មម ពុទ្ធស្ស សន្តិកេ
តិស្សោ វិជ្ជា អនុប្បត្តា  កតំ ពុទ្ធស្ស សាសនំ ។





ខ្ញុំបានជាព្រះឥន្ទ្រ សោយរាជ្យជាស្ដេចនៃទេវតា អស់ ៥០ ដង តាំងបានជាស្ដេចចក្រពត្តិ អស់ ៨០ ដង ។ ខ្ញុំបាន សោយរាជ្យ ជាក្សត្រប្រទេសរាជ្យ ដ៏ធំទូលាយ រាប់ជាចំនួន អស់ ខ្ញុំជាបុគ្គលមានសេចក្ដីសុខ មានយស នេះជាផលនៃ ការថ្វាយគ្រែ ។ កាលខ្ញុំច្យុតចាកទេវលោក មកកាន់ភពជា របស់មនុស្សវិញ ទីសម្រាប់ដេកដ៏ល្អមានដំឡៃច្រើន ក៏កើត ឡើងឯង ៗ សម្រាប់ខ្ញុំ ។ នេះភពក្រោយបំផុត របស់ខ្ញុំ ភពជាទីបំផុតរបស់ខ្ញុំ កំពុងតែប្រព្រឹត្តទៅ ថ្ងៃនេះ ទីសម្រាប់ដេក ក៏កើតឡើង (សម្រាប់ខ្ញុំ) ក្នុងកាលជាទី ដេក ។ ក្នុងកប្បទី ៩៤ អំពីកប្បនេះ ព្រោះហេតុដែល ខ្ញុំបានប្រគេនគ្រែ ក្នុងកាលនោះ ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផល នៃការថ្វាយគ្រែ ។ កិលេសទាំងឡាយ ខ្ញុំ បានដុតបំផ្លាញហើយ ភពទាំងអស់ ខ្ញុំគាស់រំលើងចោល ហើយ ខ្ញុំជាបុគ្គលមិនមានអាសវៈ ដូចជាដំរីប្រសើរកាត់ ផ្ដាច់ចំណង ។ ឱ ! ដំណើរដែលខ្ញុំមក ក្នុងសំណាក់ព្រះ ពុទ្ធរបស់ខ្ញុំ ជាដំណើរល្អហ្ន៎ វិជ្ជា ៣ ខ្ញុំបានដល់តាមលំដាប់ ហើយ សាសនា របស់ព្រះពុទ្ធ ខ្ញុំបានធ្វើរួចហើយ ។

ទសមំ មញ្ចទាយកត្ថេរាបទានំ

បដិសម្ភិទា ចតស្សោ វិមោក្ខាបិ ច អដ្ឋិមេ
ឆឡភិញ្ញា សច្ឆិកតា កតំ ពុទ្ធស្ស សាសនន្តិ ។
ឥត្ថំ សុទំ អាយស្មា មញ្ចទាយកោ ថេរោ ឥមា
គាថាយោ អភាសិត្ថាតិ ។

មញ្ចទាយកត្ថេរស្ស អបទានំ សមត្តំ ។

ឧទ្ទានំ

កន្ទលី ឯកឆត្តោ ច តិណសូលោ ច មំសទោ
នាគបល្លវកោ[1] ឌីបំ ឧច្ឆង្គ[2] យាគុទាយកោ ។
បត្ថោទនំ មញ្ចទោ គាថាយោ គណិតា វិសា[3]
ទ្វេ សតានិ ច គាថានំ គាថា ចេកា តទុត្តរិ[4] ។

កន្ទលិវគ្គោ ទ្វាចត្តាឡីសមោ ។

---

១ ម. ម. នាគបល្លវិកោ ។ ២ ម. ឧច្ឆង្គី ។ ៣ ម. វីហ ។ ម វីស ។ ៤ ម. តទុត្ត-
រិតិ ។



មញ្ចទាយកត្ថេរាបទាន ទី ១០

បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ តាំងសាសនា របស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ។

បានឮថា ព្រះមញ្ចទាយកត្ថេរ មានអាយុ បានសម្ដែងគាថាទាំងនេះ ដោយប្រការដូច្នេះ ។

មញ្ចទាយកត្ថេរាបទាន ។

ឧទ្ទាន

កន្ទលិត្ថេរាបទាន ១ ឯកច្ឆត្តិយត្ថេរាបទាន ១ តិណសូល-កទាយកត្ថេរាបទាន ១ មធុមំសទាយកត្ថេរាបទាន ១ នាគ-បល្លវកត្ថេរាបទាន ១ ឯកទីបិយត្ថេរាបទាន ១ ឧច្ឆង្គបុប្ផិយ-ត្ថេរាបទាន១ យាគុទាយកត្ថេរាបទាន ១ បត្ថោទនទាយក-ត្ថេរាបទាន ១ មញ្ចទាយកត្ថេរាបទាន ១ ឯគាថា រាប់ទៅ ឃើញមានចំនួន ២២១ គាថា ។

ចប់ភទ្ទលិវគ្គ ទី ៤២ ។

## បឋមំ សកឹសម្មជ្ជកត្ថេរាបទានំ

(១១) វិបស្សិនោ ភគវតោ បាដលឹ ពោធិមុត្តមំ(១)

ទិស្វា ច តំ បាទបគ្គំ តត្ថ ចិត្តំ បសាទយឹ ។
សម្មជ្ជនឹ គហេត្វាន ពោធឹ សម្មជ្ជិ តាវទេ
សម្មជ្ជិត្វាន តំ ពោធឹ អវន្ទឹ បាដលឹ អហំ ។
តត្ថ ចិត្តំ បសាទេត្វា សិរេ កត្វាន អញ្ជលឹ
នមស្សមានោ តំ ពោធឹ គច្ឆឹ បដិកុដឹ អហំ ។
តាទិមគ្គេន(២) គច្ឆាមិ សរន្តោ ពោធិមុត្តមំ
អជគរោ មំ បីឡេតិ ឃោររូបោ មហព្ពលោ ។
អាសន្នេ មេ កតំ កម្មំ ផលេន តោសយី មមំ
កលេវរំ មេ គិលតិ ទេវលោកេ រមាមហំ

---

១ ម. បាដលិពោធឹ ឧត្តមំ ។ ២ ម. តាទិមគ្គេន ។



## សកឹសម្មជ្ជកត្ថេរាបទាន ទី ១

(១១) ខ្ញុំ (បានឃើញ) ដើមផ្កាទៀន ជាពោធិព្រឹក្សដ៏ឧត្តម របស់ព្រះមានព្រះភាគ ព្រះនាមវិបស្សី លុះខ្ញុំបានឃើញ ឈើដ៏ប្រសើរនោះហើយ ក៏ញុំាងចិត្តឲ្យជ្រះថ្លា ចំពោះឈើនោះ ។ ខ្ញុំចាប់យកអំបោស ហើយបោសដើមពោធិព្រឹក្ស ក្នុងពេលនោះភ្លាម លុះខ្ញុំបានបោសរួចហើយ ក៏ថ្វាយបង្គំ ដើមផ្កាទៀនជាពោធិព្រឹក្សនោះ ។ ខ្ញុំធ្វើចិត្តឲ្យជ្រះថ្លាចំពោះ ពោធិព្រឹក្សនោះ រួចធ្វើអញ្ជលីលើក្បាល នមស្ការពោធិ-ព្រឹក្សនោះ ហើយដើរថយក្រោយទៅ ។ កាលខ្ញុំកំពុងរឭក ចំពោះពោធិព្រឹក្សដ៏ប្រសើរ ហើយដើរបណ្ដើរ តាមផ្លូវជាទី ត្រាច់ទៅ ស្រាប់តែពស់ថ្លាន់មួយ ជាសត្វគួរខ្លាច មានកម្លាំងច្រើន រួបរឹតខ្ញុំ ។ អំពើដែលខ្ញុំបានធ្វើក្នុងពេលជិតៗ ក៏ញុំាងខ្ញុំឲ្យត្រេកអរចំពោះផល ចំណែកឯពស់ថ្លាន់ លេបកាយខ្ញុំចូលបាត់ទៅ ខ្ញុំបានទៅត្រេកអរក្នុងទេវលោក ។

អនាវិលំ មម ចិត្តំ  វិសុទ្ធំ បណ្ឌរំ សទា
សោកសល្លំ ន ជានាមិ  ចិត្តសន្តាបនំ មម ។
កុដ្ឋំ គណ្ឌោ កិលាសោ ច  អបមារោ វិតច្ឆិកា
ទទ្ទុ កណ្ឌុ ច មេ នត្ថិ  ផលំ សម្មជ្ជនាយិទំ ។
សោកោ ច បរិទេវោ ច(១)  ហទយេ មេ ន វិជ្ជតិ
អកត្តំ(២) ឧជុកំ ចិត្តំ  ផលំ សម្មជ្ជនាយិទំ ។
សមាធី ឫន បជ្ជាមិ(៣)  វិសុទ្ធំ(៤) ហោតិ មានសំ
យំ យំ សមាធឹ ឥច្ឆាមិ  សោ សោ សម្បជ្ជតេ មម ។
រជនីយេ ន រជ្ជាមិ  អថោ ទោសនីយេសុ ច
មោហនីយេ ន មុយ្ហាមិ  ផលំ សម្មជ្ជនាយិទំ ។

---

១ ឱ. ម. បរិទេវោ ច ។ ២ ឱ. អសត្ថំ ។ ៣ ឱ. សមាធិសុ ន សជ្ជាមិ ។ ម. សមាធីសុ ន បជ្ជាមិ ។ ៤ ម. វិសទំ ។



ចិត្តរបស់ខ្ញុំឥតមានកករល្អក់ឡើយ ជាចិត្តស្អាត សព្វ ៗ កាល ខ្ញុំមិនដែលស្គាល់ទូលសោះ គឺសេចក្ដីសោក ដែលជាហេតុញ៉ាំងចិត្តរបស់ខ្ញុំ ឲ្យក្ដៅក្រហាយឡើយ ។ រោគឃ្លង់ រោគបូស រោគស្រែង រោគឆ្កួតជ្រូក ឃ្មួនដែក ដំបៅពិស រមាស់ ខ្ញុំពុំដែលមានឡើយ នេះជាផល នៃការបោសសំអាត ។ សេចក្ដីសោក និងសេចក្ដីខ្សឹកខ្សួលក្នុងហឫទ័យ ខ្ញុំមិនដែលមានទេ ចិត្តរបស់ខ្ញុំ ជាចិត្តត្រង់ មិនកាចកាង នេះជាផលនៃការបោសសំអាត ។ ខ្ញុំដល់នូវសមាធិម្ដងទៀត ចិត្តនៃខ្ញុំជាធម្មជាតបរិសុទ្ធ ខ្ញុំប្រាថ្នាសមាធិណា ៗ សមាធិនោះ ៗ រមែងសម្រេចដល់ខ្ញុំ ។ ខ្ញុំមិនដែលត្រេកត្រអាលចំពោះរបស់ដែលគួរត្រេកត្រអាល ម្យ៉ាងទៀត ខ្ញុំមិនដែលប្រទូស្ដ ចំពោះរបស់ដែលគួរប្រទូស្ដ មិនបានវង្វេងចំពោះរបស់ដែលគួរវង្វេង នេះជាផលនៃការបោសសំអាត ។

ឯកនវុតិតោ កប្បេ យំ កម្មមករឹ តទា

ទុគ្គតឹ នាភិជានាមិ ផលំ សម្មជ្ជនាយិទំ ។

កិលេសា ឈាបិតា មយ្ហំ ភវា សព្វេ សមូហតា

នាគោវ ពន្ធនំ ឆេត្វា វិហរាមិ អនាសវោ ។

ស្វាគតំ វត មេ អាសិ មម ពុទ្ធស្ស សន្តិកេ

តិស្សោ វិជ្ជា អនុប្បត្តា កតំ ពុទ្ធស្ស សាសនំ ។

បដិសម្ភិទា ចតស្សោ វិមោក្ខាបិច អដ្ឋិមេ

ឆឡភិញ្ញា សច្ឆិកតា កតំ ពុទ្ធស្ស សាសនំ ។

ឥត្ថំ សុទំ អាយស្មា សង្កិច្ចោ ថេរោ

ឥមា គាថាយោ អភាសិត្ថាតិ ។

សង្កិច្ចត្ថេរស្ស អបទានំ សមត្តំ ។



ក្នុងកប្បទី ៩១ អំពីកប្បនេះ ព្រោះហេតុតែខ្ញុំបានធ្វើអំពើ

ល្អ ក្នុងកាលនោះ ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃ

ការបោសសំអាត ។ កិលេសទាំងឡាយ ខ្ញុំដុតបំផ្លាញ

ហើយ ភពទាំងអស់ ខ្ញុំគាស់រំលើងហើយ ខ្ញុំជា

បុគ្គលមិនមានអាសវៈ ដូចដំរីប្រសើរកាត់ផ្តាច់ខ្សែចំណង ។

ឱ! ដំណើរដែលខ្ញុំមក ក្នុងសំណាក់ព្រះពុទ្ធរបស់ខ្ញុំ ជា

ដំណើរល្អហើយ វិជ្ជា ៣ ខ្ញុំបានដល់តាមលំដាប់ហើយ សា-

សនា របស់ព្រះពុទ្ធ ខ្ញុំបានធ្វើរួចហើយ ។ បដិសម្ភិទា ៤

វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ

ទាំងសាសនា របស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ។

បានឮថា ព្រះសង្កិច្ចត្ថេរ មានអាយុ បានសំដែង

គាថាទាំងនេះ ដោយប្រការដូច្នេះ ។

ចប់ សង្កិច្ចត្ថេរាបទាន ។

## ទុតិយំ ឯកទុស្សទាយកត្ថេរាបទានំ

(១២) នគរេ ហំសវតិយា អហោសឹ តិណហារកោ
តិណហារេន ជីវាមិ តេន បោសេមិ ទារកេ ។
បទុមុត្តរោ នាម ជិនោ សព្វធម្មាន បារគូ
តមន្ធការំ នាសេត្វា ឧប្បជ្ជិ លោកនាយកោ ។
សកេ ឃរេ និសីទិត្វា ឯវំ ចិន្តេសិំ តាវទេ
ពុទ្ធោ លោកេ សមុប្បន្នោ ទេយ្យធម្មោ ន វិជ្ជតិ ។
ឥទំ មេ សាដកំ ឯកំ នត្ថិ មេ កោចិ ទាយកោ
ទុក្ខោ និរយសម្ផស្សោ រោបយិស្សាមិ ទក្ខិណំ ។
ឯវាហំ ចិន្តយិត្វាន សកំ ចិត្តំ បសាទយឹ
ឯកំ ទុស្សំ គហេត្វាន ពុទ្ធសេដ្ឋស្សទាសហំ ។
ឯកំ ទុស្សំ ទទិត្វាន ឧក្កុដ្ឋឹ សម្បវត្តយឹ
យទិ ពុទ្ធោ តុវំ វីរ តារេហិ មំ មហាមុនិ ។

## ឯកទុស្សទាយកត្ថេរាបទាន ទី ២

(១៤) ខ្ញុំកើតជាអ្នកនាំស្មៅ នៅក្នុងក្រុងហង្សវតី ខ្ញុំចិញ្ចឹមជីវិតដោយការនាំស្មៅ ចាំងចិញ្ចឹមកូនប្រពន្ធ ដោយការនាំស្មៅនោះ ។ ព្រះជិនស្រីព្រះនាមបទុមុត្តរៈ ព្រះអង្គដល់ត្រើយនៃធម៌ទាំងពួង ជានាយកនៃសត្វលោក ទ្រង់កើតឡើង ញុំាងងងឹតអន្ធការឲ្យវិនាស ។ ខ្ញុំអង្គុយនៅក្នុងផ្ទះរបស់ខ្លួន ហើយគិតយ៉ាងនេះ ក្នុងខណៈនោះថា ព្រះពុទ្ធទ្រង់ត្រាស់ហើយក្នុងលោក តែទេយ្យធម៌អាត្មាអញមិនមាន ។ អាត្មាអញមានតែសាដកមួយនេះ ( បើថ្វាយទៅ ) ពុំមានអ្នកណាមួយផ្តល់ឲ្យអាត្មាអញ ការពាល់ត្រូវនូវនរក ជាទុក្ខ បើយ៉ាងនេះ អាត្មាអញ នឹងបណ្តុះនូវទក្ខិណាទាន ។ ខ្ញុំលុះគិតឃើញយ៉ាងនេះហើយ ក៏ធ្វើចិត្តរបស់ខ្លួនឲ្យជ្រះថ្លា ខ្ញុំយកសំពត់មួយ ថ្វាយព្រះពុទ្ធដ៏ប្រសើរ ។ លុះថ្វាយសំពត់រួចហើយ ខ្ញុំស្រែកហ៊ោឡើងថា បពិត្រព្រះមហាមុនី ព្រះព្យាយាម បើព្រះអង្គជាព្រះពុទ្ធ សូមចំឡងខ្ញុំព្រះអង្គផង ។

បទុមុត្តរោ លោកវិទូ អាហុតីនំ បដិគ្គហោ
បថំ ឆាទំ បកាសេន្តោ អគមា មេ អនុហេឋនំ ។
ឥមិនា ឯកទុស្សេន ចេតនាបណិធីហិ ច
កប្បសតសហស្សានិ វិនិបាតំ ន គច្ឆតិ ។
ឆត្តឹសក្ខត្តុំ ទេវិន្ទោ ទេវរជ្ជំ ការិស្សតិ(១)
តេត្តឹសក្ខត្តុំ រាជា ច ចក្កវត្តិ ការិស្សតិ(២)
បទេសរជ្ជំ វិបុលំ គណនាតោ អសង្ខិយំ
ទេវលោកេ មនុស្សេ វា សំសរន្តោ តុវំ ភវេ ។
រូបវា គុណសម្បន្នោ អនុវត្តទេហវា(៣)
អក្ខោភំ អមិតំ ទុស្សំ លភិស្សតិ យទិច្ឆកំ ។
ឥទំ វត្វាន សម្ពុទ្ធោ ជលជុត្តមនាយកោ(៤)
នភំ អព្ភុគ្គមិ ជិនោ(៥) ហំសរាជាវ អម្ពរេ ។

១ ឱ. ការិស្សតិ ។ ២ ឱ ការិស្សតិ ។ ៣ ឱ. អនុបក្កន្តទេហវា ។ ម. អនវក្កន្តទេហវា ។ ៤ ឱ. ជលជុត្តនាយកោ ។ ៥ ឱ.ម. វីរោ ។



ព្រះពុទ្ធព្រះនាមបទុមុត្តរៈ ព្រះអង្គជ្រាបច្បាស់នូវត្រៃលោក គួរទទួលនូវគ្រឿងបូជា ទ្រង់សរសើរទានរបស់ខ្ញុំ ហើយញុំា អនុមោទនាដល់ខ្ញុំថា

បុរសនេះមិនទៅកាន់វិនិបាត អស់សែនកប្ប ដោយការឲ្យសំពត់មួយនេះផង ដោយការតំកល់ចេតនានេះផង ។ បុរសនេះ នឹងបានជាព្រះឥន្ទ សោយរាជ្យជាស្តេចនៃទេវតា អស់ ៣៦ ដង នឹងបានជាស្តេចចក្រពត្តិ អស់ ៣៣ ដង ។ នឹងបានសោយបទេសរាជ្យ ដ៏ទូលាយ រាប់ជាគិតមិនអស់ កាលអន្ទោលទៅ ក្នុងទេវលោក ឬក្នុងមនុស្សលោក ជាអ្នកមានរូបល្អ បរិបូណ៌ដោយគុណ មានទេហកាយកំពុងប្រព្រឹត្តទៅ នឹងបាននូវសំពត់តាមសេចក្តីប្រាថ្នា ជាអក្ខោភិនី រាប់មិនអស់ ។ ព្រះសម្ពុទ្ធព្រះនាមបទុមុត្តរៈ ព្រះអង្គជាអ្នកប្រាជ្ញ លុះត្រាស់ការណ៍នេះហើយ ទ្រង់ហោះទៅឯអាកាស ដូចជារាជហង្ស កាលហើរក្នុងអាកាស ។

ទុតិយំ ឯកទុស្សទាយកត្ថេរាបទានំ

យំ យំ យោនូបបជ្ជាមិ ទេវត្តំ អថ មានុសំ
ភោគេ មេ ឩនតា នត្ថិ ឯកទុស្សស្សិទំ ផលំ ។
បទុទ្ធារេ បទុទ្ធារេ ទុស្សំ និព្វត្តតេ មម
ហេដ្ឋា ទុស្សម្ហិ តិដ្ឋាមិ ឧបរិច្ឆទនំ មម ។
ចក្កវាឡំ ឧបាទាយ សកាននំ សបព្វតំ
ឥច្ឆមានោ ចហំ អជ្ជ ទុស្សេហច្ឆាទយេយ្យតំ(១) ។
តេនេវ ឯកទុស្សេន សំសរន្តោ ភវាភវេ
សុវណ្ណវណ្ណោ ហុត្វាន សំសរាមិ ភវាភវេ ។
វិបាកំ ឯកទុស្សស្ស អជ្ឈគិ តត្ថ កិត្តកំ(២)
អយំ(៣) បច្ឆិមា ជាតិ វិបច្ចតិ ឥធាបិ មេ ។
សតសហស្សេ ឥតោ កប្បេ យំ ទុស្សមទទិំ តទា
ទុគ្គតឹ នាភិជានាមិ ឯកទុស្សស្សិទំ ផលំ ។
កិលេសា ឈាបិតា មយ្ហំ ភវា សព្វេ សមូហតា
នាគោវ ពន្ធនំ ឆេត្វា វិហរាមិ អនាសវោ ។

១ ឱ. ទុស្សេហច្ឆាទយេយ្យតំ ។ ម. ទុស្សេហច្ឆាទយេយ្យហំ ។ ២ ឱ. ម. តាឡ្ហតំ ហត្ថ ចិក្ខុយន្តិ ទិស្សន្តិ ។ ៣ ម. អយំ មេ ។



ឯកទុស្សទាយកត្ថេរាបទាន ទី ២

ខ្ញុំចូលទៅកាន់កំណើតណា ៗ ទោះជាទេវតា ឬជាមនុស្ស ខ្ញុំមិនដែលមានការខ្វះខាតភោគៈឡើយ នេះជាផលនៃសំ-ពត់មួយ ។ សំពត់តែងកើតសម្រាប់ខ្ញុំ កល់ជំហាន ៗ ខាងក្រោម ខ្ញុំឈរលើសំពត់ ខាងលើ មានសំពត់បាំងខ្ញុំ ។ ថ្ងៃនេះ ខ្ញុំប្រាថ្នាបិទបាំងផែនដី ព្រមទាំងព្រៃនិងភ្នំ រហូតចក្រវាឡ ក៏អាចគ្របទីនោះ ដោយសំពត់បាន ។ ខ្ញុំ កាលអន្ទោលទៅ ក្នុងភពតូចភពធំ មានសម្បុរល្អដូចមាស ខ្ញុំអន្ទោលទៅ ក្នុងភពតូចភពធំ ដោយសារផលនៃសំ-ពត់មួយនោះឯង ។ ខ្ញុំបាននូវភពជាតិក្នុងទីនេះ ព្រោះ អាស្រ័យផលនៃសំពត់មួយ ម្យ៉ាងទៀត ជាតិនេះជាទីបំផុត របស់ខ្ញុំ អំពើនេះសោត ឲ្យផលដល់ខ្ញុំ ក្នុងជាតិនេះ ។ ក្នុងកប្បទីមួយសែន អំពីកប្បនេះ ព្រោះហេតុដែលខ្ញុំបាន ឲ្យសំពត់ ក្នុងកាលនោះ ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះ ជាផលនៃសំពត់មួយ ។ កិលេសទាំងឡាយ ខ្ញុំដុតបំផ្លាញ ហើយ ភពទាំងអស់ ខ្ញុំគាស់រំលើងហើយ ខ្ញុំជាបុគ្គល មិនមានអាសវៈ ដូចជាដំរីដ៏ប្រសើរ កាត់ផ្តាច់នូវចំណង ។

ស្វាគតំ វត មេ អាសិ មម ពុទ្ធស្ស សន្តិកេ
តិស្សោ វិជ្ជា អនុប្បត្តា កតំ ពុទ្ធស្ស សាសនំ ។
បដិសម្ភិទា ចតស្សោ វិមោក្ខាបិ ច អដ្ឋិមេ
ឆឡភិញ្ញា សច្ឆិកតា កតំ ពុទ្ធស្ស សាសនំ ។
ឥត្ថំ សុទំ អាយស្មា ឯកទុស្សទាយកោ ថេរោ
ឥមា គាថាយោ អភាសិត្ថាតិ ។

ឯកទុស្សទាយកត្ថេរស្ស អបទានំ សមត្តំ ។

## តតិយំ ឯកាសនទាយកត្ថេរាបទានំ

(១៣) ហិមវន្តស្សាវិទូរេ គោសិកោ នាម(១) បព្វតោ
អស្សមោ សុកតោ មយ្ហំ បណ្ណសាលា សុមាបិតា ។
នារទោ នាម នាមេន កស្សបោ ឥតិ មំ វិទូ
សុទ្ធមគ្គំ គវេសន្តោ វសាមិ គោសិកេ(២) តទា ។
បទុមុត្តរោ នាម ជិនោ សព្វធម្មាន បារគូ
វិវេកកាមោ សម្ពុទ្ធោ អគញ្ឆិ អនិលញ្ជសា ។

១ ម. កោសិកោ នាម ។ ឧ. គោសិតោ នាម ។ ២ ម. កោសិកេ ។ ឧ. គោសិតេ ។



ឱ! វេលាណាដែលខ្ញុំមកក្នុងសំណាក់ព្រះពុទ្ធរបស់ខ្ញុំ ជាវេលាល្អហ្ន៎ វិជ្ជា ៣ ខ្ញុំបានដល់តាមលំដាប់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំក៏បានធ្វើរួចហើយ ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនា របស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ។

បានឮថា ព្រះឯកទុស្សទាយកត្ថេរ មានអាយុ បានសំដែងគាថាទាំងនេះ ដោយប្រការដូច្នេះ ។

ចប់ ឯកទុស្សទាយកត្ថេរាបទាន ។

## ឯកាសនទាយកត្ថេរាបទាន ទី ៣

(១៣) មានភ្នំមួយ ឈ្មោះកោសិកៈ ដែលនៅជិតព្រៃហិមពាន្ត ខ្ញុំបានធ្វើអាស្រមមួយ យ៉ាងល្អ ទាំងបានកសាងបណ្ណសាលាមួយដ៏ល្អល្អះ នៅក្បែរភ្នំនោះ ។ កាលនោះ ខ្ញុំមាននាមថានារទៈ តែគេស្គាល់ខ្ញុំថាកស្សបវិញ ខ្ញុំកំពុងស្វែងរកមគ្គដ៏ស្អាត នៅជិតភ្នំកោសិកៈ ។ ព្រះជិនសិរីសព្វញ្ញូ ព្រះនាមបទុមុត្តរៈ ព្រះអង្គដល់នូវត្រើយ នៃធម៌ទាំងពួង ទ្រង់ប្រាថ្នាវិវេក បានស្ដេចយាងមកតាមផ្លូវអាកាស ។

វនន្តេ គច្ឆមានស្ស ទិស្វា រំសី មហេសិនោ
កដ្ឋមញ្ចំ បញ្ញាបេត្វា អជិនញ្ច អបត្ថរី ។
អាសនំ បញ្ញាបេត្វាន សិរសេ កាត្វាន អញ្ជលី
សោមនស្សំ បវេទេត្វា ឥទំ វចនមព្រវី ។
សល្លកត្តោ តុវំ ធីរ អាតុរំ តិកិច្ឆកោ
មម រោគបរេតស្ស(១) តិកិច្ឆំ ទេហិ នាយក ។
បុញ្ញិកាយេ បស្សន្តិ(២) ពុទ្ធសេដ្ឋំ តុវំ មុនិ(៣)
ធុវត្ថសិទ្ធឹ(៤) បប្បោន្តិ ឯតេសំ អជរោ ភវេ(៥) ។
ន មេ ទេយ្យំ តវ អត្ថិ បវត្តផលភោជហំ
ឥទំ មេ អាសនំ អត្ថិ និសីទ កដ្ឋមញ្ចកេ ។

---

១ ឱ. មមំ រោគបរេតស្ស ។ មមំ រាបរេតស្ស ។ ២ ឱ. កល្យត្តិកា យេ បស្សន្តិ ។ ម. កលត្តិកាយេ បស្សន្តិ ។ ៣ ឱ. តវំ បរេ ។ ម. តុវំ មុនេ ។ ៤ ឱ. ធុវំតសិទ្ធឹ ។ ៥ ឱ. ម. ឯតេសំ អជ្ជរោ ភវេ ។ ៦ ឱ. ន មេ ទេយ្យំ តវេត្ថិ បវត្តផលភោជិហំ ។ ម. ន មេ ទេយ្យធម្មោ អត្ថិ បវត្តផលភោជិហំ ។





ខ្ញុំបានឃើញរស្មីព្រះពុទ្ធ ព្រះអង្គស្វែងរកនូវគុណដ៏ធំ កំពុងយាងទៅទីបំផុតនៃព្រៃ ក៏បានតាក់តែងគ្រែឈើ ហើយក្រាលស្បែកខ្លាថ្វាយ ។ ខ្ញុំលុះក្រាលអាសនៈរួចហើយ ក៏ប្រណម្យអញ្ជលីលើក្បាល បានទទួលសោមនស្ស ហើយពោលពាក្យនេះថា បពិត្រព្រះអង្គជាអ្នកប្រាជ្ញ ព្រះអង្គជាពេទ្យ អ្នកព្យាបាលពួកជម្ងឺ បពិត្រព្រះនាយក សូមព្រះអង្គប្រទានឱសថព្យាបាលរោគ ដល់ខ្ញុំព្រះអង្គដែលរោគៈគ្របសង្កត់ ។ បពិត្រព្រះអង្គជាអ្នកប្រាជ្ញ ពួកជនណាជាអ្នកត្រេកអរដោយបុណ្យ បើបានឃើញព្រះអង្គ ជាព្រះពុទ្ធដ៏ប្រសើរ តែងដល់នូវការសម្រេចប្រយោជន៍ ដ៏ទៀងទាត់ ការមិនមានសេចក្ដីគ្រាំគ្រា គប្បីមានដល់ជនទាំងនោះ ។ ទេយ្យវត្ថុដែលខ្ញុំគួរថ្វាយ ចំពោះព្រះអង្គ មិនមាន (ព្រោះ) ខ្ញុំជាអ្នកបរិភោគ តែផ្លែឈើដែលជ្រុះឯង នេះអាសនៈរបស់ខ្ញុំ សូមព្រះអង្គគង់លើគ្រែឈើនេះចុះ ។

ឆសីតិ តត្ថ ភកកា  អចក្កលោវ លោសេរី
មុហុត្តំ វីតិនាមេត្វា  ឥទំ(១) វចនមព្រវិ ។
វិស្សជ្ជេថ ហោហិ មា ភាយិ  លទ្ធោ ជោតិរសោ តយា
យំ តុម្ហំ បត្ថិតំ សព្វំ  បរិបូរិស្សតាសនំ ។
ឆ ជោតំ សុកតំ បុញ្ញំ  បុញ្ញក្ខេត្តេ អនុត្តរេ
សក្កា ឧទ្ធរិតុំ អត្តា  យស្ស ចិត្តំ សុបណិហិតំ ។
ឥមិនា អាសនទានេន  ចេតនាបណិធីហិ ច
កប្បសតសហស្សានំ  វិនិបាតំ ន គច្ឆតិ ។
បញ្ញាសក្ខត្តុំ ទេវិន្ទោ  ទេវរជ្ជំ ករិស្សតិ
អសីតិក្ខត្តុំ រាជា ច  ចក្កវត្តី ភវិស្សតិ ។

១ ឱ. ឥធំ ។



ព្រះមហាមុនីនោះ ព្រះអង្គគង់លើអាសនៈនោះ [illegible] សម័យ ដែលអង្គគង់ស្ងៀម ព្រះអង្គញុំញ៉ឹមសំណាក់[illegible] ហើយ ទើបត្រាស់ពាក្យនេះថា

អ្នកចូរស្ងប់ស្ងៀមចុះ កុំភិតភ័យឡើយ (ព្រោះ) ព្រះពុទ្ធ មានរស្មីរុងរឿង អ្នកបានហើយ អាសនៈណា ដែល អ្នកប្រាថ្នាហើយ អាសនៈទាំងអស់នោះ នឹងបរិបូណ៌ដល់ អ្នក ។ បុណ្យដែលអ្នកធ្វើល្អហើយ ក្នុងបុញ្ញក្ខេត្តដ៏ប្រសើរ មិនមែនជាបុណ្យតិចតួចទេ ចិត្តរបស់បុគ្គលណា ដែល បានតំកល់ល្អហើយ បុគ្គលនោះតែងរើខ្លួនបាន ។ ដោយ ការប្រគេនអាសនៈនេះផង ដោយការតំកល់ចេតនានេះផង បុគ្គលនោះ នឹងមិនទៅកាន់វិនិបាត អស់មួយសែនកប្ប ។ បុគ្គលនោះនឹងបានជាព្រះឥន្ទ្រ សោយរាជ្យជាស្តេចទេវតា អស់ ៥០ ជាតិ នឹងបានជាស្តេចចក្រពត្តិ អស់ ៨០ ជាតិ ។

បទេសរជ្ជំ វិបុលំ	គណនាតោ សង្ខុយំ(១)
សព្វត្ថ សុខិតោ ហុត្វា	សំសារេ សំសរិស្សតិ(២) ។
ឥតោ វុត្ថាន សម្ពុទ្ធោ	ផលជុត្តមនាមកោ
ឆកំ អព្ភុគ្គមិ ធីរោ	ហំសរាជាវ អម្ពរេ ។
ហត្ថិយានំ អស្សយានំ	សរថំ សន្ទមានិកំ
លភាមិ សព្វមេវេតំ	ឯកាសនស្សិទំ ផលំ ។
កាននំ បវិសិត្វាន	យទា ឥច្ឆាមិ អាសនំ
មម សង្កប្បមញ្ញាយ	បល្លង្កោ ឧបតិដ្ឋតិ ។
វារិមជ្ឈគតោ សន្តោ	យទា ឥច្ឆាមិ អាសនំ
មម សង្កប្បមញ្ញាយ	បល្លង្កោ ឧបតិដ្ឋតិ ។
យំ យំ យោនុបបជ្ជាមិ	ទេវត្តំ អថ មានុសំ
បល្លង្កសតហស្សានិ	បរិវារេន្តិ មំ សទា ។
ទុវេ ភវេ សំសរាមិ	ទេវត្តេ អថ មានុសេ
ទុវេ កុលេ ច ជាយាមិ(៣)	ខត្តិយេ ចាបិ(៤) ព្រាហ្មណេ ។

១ ឱ. អសង្ខុយំ ។ ២ ឱ,ម. សំសរិស្សសិ ។ ៣ ឱ.ម. បជាយាមិ ។ ៤ ឱម. អថ ។





ខ្ញុំបានសោយប្រទេសរាជ្យ ដ៏ធំទូលាយ រាប់ជាចំនួនមិនអស់ កាលបើអន្ទោលទៅក្នុងសង្សារ ខ្ញុំជាអ្នកបានសេចក្ដីសុខស្រួល ក្នុងទីទាំងពួង ។ ព្រះសម្ពុទ្ធជាអ្នកប្រាជ្ញ ព្រះនាមបទុមុត្តរៈ លុះត្រាស់សំដែងនេះហើយ ក៏ហោះឡើងទៅឯគគនាល័យ ដូចជាពញាហង្ស កាលហើរក្នុងអាកាស ។

ខ្ញុំតែងបាននូវគ្រឿងទាំងអស់នោះ គឺ យានដំរី យានសេះ ព្រមទាំងរថ និងរថប្រដាប់គ្រឿង នេះជាផល នៃអាសនៈមួយ ។ កាលណា ខ្ញុំចូលទៅក្នុងព្រៃ ប្រាថ្នារកអាសនៈ ស្រាប់តែបល្ល័ង្កផុសលេចឡើង ព្រោះបានដឹងនូវសេចក្ដីត្រិះរិះរបស់ខ្ញុំ (ក្នុងកាលនោះ) ។ កាលណា បើខ្ញុំទៅនៅកណ្ដាលទឹក ប្រាថ្នារកអាសនៈ ស្រាប់តែបល្ល័ង្កផុសលេចឡើង ព្រោះបានដឹងសេចក្ដីត្រិះរិះរបស់ខ្ញុំ កាលនោះ ។ ខ្ញុំចូលទៅកាន់កំណើតណា ១ ទោះជាទេវតា ឬជាមនុស្ស បល្ល័ង្កមួយសែន តែងហែហមខ្ញុំ សព្វកាល ។ ខ្ញុំតែងអន្ទោលទៅមក ក្នុងភពពីរ គឺទេវតានិងមនុស្ស ម្យ៉ាងទៀត តែងកើតក្នុងត្រកូលពីរ គឺក្សត្រនិងព្រាហ្មណ៍ ។

ឯកាសនំ ទទិត្វាន ពុញ្ញក្ខេត្តេ អនុត្តរេ
ធម្មបល្លង្កមញ្ញាយ(១) វិហរាមិ អនាសវោ ។
សតសហស្សេ ឥតោ កប្បេ យំ ទានមទទឹ តទា
ទុគ្គតឹ នាភិជានាមិ ឯកាសនស្សិទំ ផលំ ។
កិលេសា ឈាបិតា មយ្ហំ ភវា សព្វេ សមូហតា
នាគោវ ពន្ធនំ ឆេត្វា វិហរាមិ អនាសវោ ។
ស្វាគតំ វត មេ អាសិ មម ពុទ្ធស្ស សន្តិកេ
តិស្សោ វិជ្ជា អនុប្បត្តា កតំ ពុទ្ធស្ស សាសនំ ។
បដិសម្ភិទា ចតស្សោ វិមោក្ខាបិច អដ្ឋិមេ
ឆឡភិញ្ញា សច្ឆិកតា កតំ ពុទ្ធស្ស សាសនន្តិ ។

ឥត្ថំ សុទំ អាយស្មា ឯកាសនទាយកោ ថេរោ ឥមា គាថាយោ អភាសិត្ថាតិ ។

ឯកាសនទាយកត្ថេរស្ស អបទានំ សមត្តំ ។

១ ម. ធម្មបល្លង្កមាញាយ ។



ព្រោះខ្ញុំបានថ្វាយអាសនៈមួយ ចំពោះបុញ្ញក្ខេត្តដ៏ប្រសើរ ទើបដឹងបល្ល័ង្កគឺធម៌ ជាអ្នកមិនមានអាសវៈ ។ ក្នុងកប្បទីមួយសែន អំពីកប្បនេះ ព្រោះហេតុដែលខ្ញុំថ្វាយទាន ក្នុងកាលនោះ ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃអាសនៈមួយ ។ កិលេសទាំងឡាយ ខ្ញុំដុតបំផ្លាញហើយ ភពទាំងអស់ ខ្ញុំគាស់រំលើងហើយ ខ្ញុំជាបុគ្គលមិនមានអាសវៈ ដូចជាដំរីដ៏ប្រសើរ កាត់ផ្តាច់នូវចំណង ។ ឱ ! ដំណើរដែលខ្ញុំមកក្នុងសំណាក់ព្រះពុទ្ធរបស់ខ្ញុំ ជាដំណើរល្អហ្ន៎ វិជ្ជា ៣ ខ្ញុំបានដល់តាមលំដាប់ហើយ សាសនា របស់ព្រះពុទ្ធ ខ្ញុំបានធ្វើរួចហើយ ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនា របស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ។

បានឮថា ព្រះឯកាសនទាយកត្ថេរ មានអាយុ បានសំដែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

ចប់ ឯកាសនទាយកត្ថេរបទាន ។

## ចតុត្ថំ សត្តកទម្ពបុប្ផិយត្ថេរាបទានំ

(១៤) ហិមវន្តស្ស អវិទូរេ កានត្តោ នាម(១) បព្វតោ

តស្មិំ បព្វតបស្សម្ហិ សត្ត ពុទ្ធា វសឹសុ តេ ។

កទម្ពបុប្ផំ ទិស្វាន(២) បគ្គហេត្វាន អញ្ជលិំ

សត្ត មាលាធំ គហេត្វា បុណ្ណចិត្តេន(៣) ឱកិរឹ ។

តេន កម្មេន សុកតេន ចេតនាបណិធីហិ ច

ជហិត្វា មានុសំ ទេហំ តាវតឹសំ អគច្ឆហំ ។

ចតុន្នវុតេ ឥតោ កប្បេ យំ កម្មមករឹ តទា

ទុគ្គតឹ នាភិជានាមិ ពុទ្ធបូជាយិទំ ផលំ ។

កិលេសា ឈាបិតា មយ្ហំ ភវា សព្វេ សមូហតា

នាគោវ ពន្ធនំ ឆេត្វា វិហរាមិ អនាសវោ ។

ស្វាគតំ វត មេ អាសិ មម ពុទ្ធស្ស សន្តិកេ

តិស្សោ វិជ្ជា អនុប្បត្តា កតំ ពុទ្ធស្ស សាសនំ ។

---

១ ម. កុក្កុដោ នាម ។ ២ ឱ, ម. កទម្ពំ បុប្ផិតំ ទិស្វា ។ ៣ ឱ. បុញ្ញចិត្តេន ។

## សត្តកទម្ពបុប្ផិយត្ថេរាបទាន ទី ៤

(១៤) មានភ្នំមួយ ឈ្មោះកុក្កុរៈ នៅជិតព្រៃហេមពាន្ត មានព្រះពុទ្ធ ៧ ព្រះអង្គនោះ ទ្រង់គង់នៅជាប់ភ្នំនោះ ។ ខ្ញុំឃើញផ្កាកទម្ព បានផ្គងអញ្ជលី កាន់ផ្កា ៧ ចង្កោម ហើយព្រោយដោយចិត្តពេញលេញ ។ ខ្ញុំលះបង់រាងកាយរបស់មនុស្សហើយ ក៏បានទៅកើតឯឋានតាវត្តិង្ស ដោយអំពើដែលខ្ញុំធ្វើល្អនោះផង ដោយការតំកល់ចេតនានោះផង ។ ក្នុងកប្បទី ៩៤ អំពីកប្បនេះ ព្រោះហេតុដែលខ្ញុំបានធ្វើអំពើជាកុសល ក្នុងកាលនោះ ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃពុទ្ធបូជា ។ កិលេសទាំងឡាយ ខ្ញុំបានដុតបំផ្លាញហើយ ភពទាំងអស់ ខ្ញុំគាស់រំលើងហើយ ខ្ញុំជាបុគ្គលមិនមានអាសវៈ ដូចជាដំរីដ៏ប្រសើរ កាត់ផ្តាច់នូវទន្លីង ។ ឱ ! ដំណើរដែលខ្ញុំមក ក្នុងសំណាក់នៃព្រះពុទ្ធរបស់ខ្ញុំ ជាដំណើរល្អហ្ន៎ វិជ្ជា ៣ ខ្ញុំបានដល់តាមលំដាប់ហើយ សាសនា របស់ព្រះពុទ្ធ ខ្ញុំក៏បានធ្វើរួចហើយ ។

បដិសម្ភិទា ចតស្សោ វិមោក្ខាបិ ច អដ្ឋិមេ
ឆឡភិញ្ញា សច្ឆិកតា កតំ ពុទ្ធស្ស សាសនន្តិ ។

ឥត្ថំ សុទំ អាយស្មា សត្តកទម្ពបុប្ផិយោ ថេរោ ឥមា គាថាយោ អភាសិត្ថាតិ ។

សត្តកទម្ពបុប្ផិយត្ថេរស្ស អបទានំ សមត្តំ ។

## បញ្ចមំ កោរណ្ឌបុប្ផិយត្ថេរាបទានំ

(១៨) វនកម្មិកោ បុរេ អាសឹ បិតុមាតុមតេនហំ
បសុមារេន ជីវាមិ កុសលំ មេ ន វិជ្ជតិ ។
មម អាសយសាមន្តា តិស្សោ លោកគ្គនាយកោ
បទានិ តីណិ ទស្សេសិ អនុកម្បាយ ចក្ខុមា ។
អក្កន្តេ ច បទេ ទិស្វា តិស្សនាមស្ស សត្ថុនោ
ហដ្ឋោ ហដ្ឋេន ចិត្តេន បទេ ចិត្តំ បសាទយឹ ។



បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនា របស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ។

បានឮថា ព្រះសត្តកទម្ពបុប្ផិយត្ថេរ មានអាយុ បានសំដែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

ចប់ សត្តកទម្ពបុប្ផិយត្ថេរាបទាន ។

## កោរណ្ឌបុប្ផិយត្ថេរាបទាន ទី ៥

(១៨) កាលកកមុន ខ្ញុំកើតជាបុរសអ្នកធ្វើការងារក្នុងព្រៃ ជាមួយនឹងបិតានិងមាតាខ្ញុំ ខ្ញុំរស់នៅដោយការសម្លាប់សត្វ ឯកុសលរបស់ខ្ញុំមិនមានឡើយ ។ ព្រះលោកនាយកដ៏ប្រសើរ ព្រះនាមតិស្សៈ ព្រះអង្គមានបញ្ញាចក្ខុ គង់នៅជិតលំនៅរបស់ខ្ញុំ ទ្រង់សំដែងស្នាមព្រះបាទបីកន្លែង ដោយសេចក្តីអនុគ្រោះ ។ ខ្ញុំឃើញស្នាមព្រះបាទ នៃព្រះសាស្តាព្រះនាមតិស្សៈ ដែលទ្រង់ជាន់ទុកហើយ ក៏មានចិត្តត្រេក-អរពេកពេក បានញុំាងចិត្តឲ្យជ្រះថ្លា ចំពោះស្នាមព្រះបាទ ។

## បញ្ចមំ កោរណ្ឌបុប្ផិយត្ថេរាបទានំ

កោរណ្ឌំ បុប្ផិតំ ទិស្វា ។ បាទបំ ធរណីរុហំ

សកោដកំ(១) គហេត្វាន ពុទ្ធសេដ្ឋំ(២) អបូជយឹ ។

តេន កម្មេន សុកតេន ចេតនាបណិធីហិ ច

ជហិត្វា មានុសំ ទេហំ តាវត្តឹសំ អគច្ឆហំ ។

យំ យំ យោនុបបជ្ជាមិ ទេវត្តំ អថ មានុសំ

កោរណ្ឌវណ្ណកោ ហោមិ សប្បភាសោ ភវាមហំ ។

ឯកនវុតេ ឥតោ កប្បេ យំ កម្មមករឹ តទា

ទុគ្គតឹ នាភិជានាមិ ពុទ្ធបូជាយិទំ ផលំ ។

កិលេសា ឈាបិតា មយ្ហំ ភវា សព្វេ សមូហតា

នាគោវ ពន្ធនំ ឆេត្វា វិហរាមិ អនាសវោ ។

ស្វាគតំ វត មេ អាសិ មម ពុទ្ធស្ស សន្តិកេ

តិស្សោ វិជ្ជា អនុប្បត្តា កតំ ពុទ្ធស្ស សាសនំ ។

---

១ ឱ. សកោដកំ ។ ម. សកោសកំ ។ ២ ឱ. បរសេដ្ឋំ ។



## កោរណ្ឌបុប្ផិយត្ថេរាបទាន ទី ៥

ខ្ញុំបានឃើញដើមកូរណ្ឌៈមានផ្ការីក ជាឈើដុះលើផែនដីហើយ ក៏កាច់យកផ្កាព្រមទាំងសណ្ដាប់ បូជាចំពោះព្រះពុទ្ធដ៏ប្រសើរ ។ ដោយកុសលកម្មដែលខ្ញុំធ្វើល្អនោះផង ដោយការតម្កល់ចេតនានោះផង ខ្ញុំលះបង់នូវកាយជារបស់មនុស្ស ក៏បានទៅកើតឯឋានតាវត្តិង្ស ។ ខ្ញុំទៅយកកំណើតណា ៗ ទោះជាទេវតា ឬជាមនុស្ស ខ្ញុំតែងមានសម្បុរព្រមទាំងរស្មី ដូចផ្កាកែវ ។ ក្នុងកប្បទី ៩១ អំពីកប្បនេះ ព្រោះហេតុដែលខ្ញុំបានធ្វើអំពើល្អ ក្នុងកាលនោះ ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃការបូជាព្រះពុទ្ធ ។ កិលេសទាំងឡាយ ខ្ញុំដុតបំផ្លាញហើយ ភពទាំងអស់ ខ្ញុំគាស់រំលើងហើយ ខ្ញុំជាបុគ្គលមិនមានអាសវៈ ដូចជាដំរីដ៏ប្រសើរ កាត់ផ្ដាច់ឡូទន្ទឹង ។ ឱ! ដំណើរដែលខ្ញុំមក ក្នុងសំណាក់នៃព្រះពុទ្ធរបស់ខ្ញុំ ជាដំណើរល្អហ្ន៎ វិជ្ជា ៣ ខ្ញុំបានដល់តាមលំដាប់ហើយ សាសនា របស់ព្រះពុទ្ធ ខ្ញុំក៏បានធ្វើរួចហើយ ។

បដិសម្ភិទា ចតស្សោ វិមោក្ខាបិច អដ្ឋិមេ

ឆឡភិញ្ញា សច្ឆិកតា កតំ ពុទ្ធស្ស សាសនន្តិ ។

ឥត្ថំ សុទំ អាយស្មា កោណ្ឌបុត្តិយោ ថេរោ

ឥមា គាថាយោ អភាសិត្ថាតិ ។

កោណ្ឌបុត្តិយត្ថេរស្ស អបទានំ សមត្តំ ។

## ឆដ្ឋំ ឃតមណ្ឌទាយកត្ថេរាបទានំ

(១៦) សុចិន្តិតំ ភគវន្តំ លោកជេដ្ឋំ នរាសភំ

ឧបវិដ្ឋំ មហារញ្ញំ វាតាពាធេន បីឡិតំ ។

ទិស្វា ចិត្តំ បសាទេត្វា ឃតមណ្ឌំ ឧបានយឹ

កតត្តា ឧបចិតត្តា ច(១) គង្គា ភាគីរសី អយំ(២) ។

---

១ ម. អាចិតត្តា ។ យ. ភាវិតត្តា ។ ២ ម. ភាគីរសីយំ ។



បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនា របស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ។

បានឮថា ព្រះកោណ្ឌបុត្តិយត្ថេរ មានអាយុ បានសម្ដែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

ចប់ កោណ្ឌបុត្តិយត្ថេរាបទាន ។

## ឃតមណ្ឌទាយកត្ថេរាបទាន ទី ៦

(១៦) ខ្ញុំបានឃើញនូវព្រះមានព្រះភាគ ទ្រង់មានព្រះតម្រិះល្អ ព្រះអង្គជាច្បងក្នុងលោក ប្រសើរជាងពួកនរៈ ដែលស្ដេចចូលទៅគង់ក្នុងព្រៃធំ ហើយត្រូវអាពាធកើតអំពីខ្យល់បៀតបៀន ។ លុះខ្ញុំឃើញហើយ ក៏ធ្វើចិត្តឲ្យជ្រះថ្លា ហើយនាំយកទឹកដោះថ្លា ព្រោះកុសលកម្មដែលខ្ញុំធ្វើល្អនោះផង ព្រោះសេចក្ដីគោរពក្រែងនោះផង ទន្លេគង្គាឈ្មោះភាគីរសីនេះ

ភៀ បេនាបព្ទាណបេតន្តេរាបទាន

មហាសមុទ្ទា ចត្តារោ　យទិ សព្វេ មម
អយញ្ច បថវី លោកោ　អប្បមាណា អសង្ខយា ។
មម សង្កប្បមញ្ញាយ　ភវន្តេ មធុសក្ករា
ចតុទ្ទិសា(១) ឥមេ រុក្ខា　ជាតា ធរណីរុហា ។
មម សង្កប្បមញ្ញាយ　កប្បរុក្ខា ភវន្តិ តេ
បញ្ញាសក្ខត្តុំ ទេវិន្ទោ　ទេវរជ្ជមការយិំ ។
ឯកបញ្ញាសក្ខត្តុញ្ច　ចក្កវត្តិ អហោសហំ
បទេសរជ្ជំ វិបុលំ　គណនាតោ អសង្ខយំ ។
ចតុន្នវុតេ ឥតោ កប្បេ　យំ ទានមទទិំ តទា
ទុគ្គតិំ នាភិជានាមិ　យជមណ្ឌស្សិទំ ផលំ ។
កិលេសា ឈាបិតា មយ្ហំ ភវា សព្វេ សមូហតា
នាគោវ ពន្ធនំ ឆេត្វា　វិហរាមិ អនាសវោ ។

---
១ ឱ. ម. ចតុទ្ទីបា ។



បេនាបព្ទាណបេតន្តេរាបទានទី ៦

បើមហាសមុទ្រទាំង ៤ គឺញុំាងទឹកដោះ ឲ្យសម្រេចដល់ខ្ញុំ ម្យ៉ាងទៀត ផែនដីជាសាគរៈដ៏ធំនេះ ប្រមាណមិនបាន ។ ការ មិនអស់ ក៏កើតទៅជាទឹកឃ្មុំនិងស្ករក្រាម ព្រោះតម្រិះ របស់ខ្ញុំ ។ ដើមឈើទាំងឡាយនេះ ជាឈើដុះលើផែនដី ដែលបិតនៅក្នុងទិសទាំង ៤ ឈើទាំងនោះ ក៏កើតទៅជាដើម កល្បព្រឹក្ស ព្រោះដឹងតម្រិះរបស់ខ្ញុំ ។ ខ្ញុំបានកើតជាព្រះឥន្ទ្រ សោយរាជ្យជាស្តេចទេវតា អស់ ៥០ ដង ។ បានជាស្តេច ចក្រពត្តិ ៥១ ដង បានសោយរាជ្យក្នុងប្រទេស ដ៏ទូលំទូលាយ រាប់ជាគណនាមិនអស់ ។ ក្នុងកប្បទី ៩៤ អំពីកប្បនេះ ព្រោះ ហេតុដែលខ្ញុំបានថ្វាយទាន ក្នុងកាលនោះ ខ្ញុំមិនដែលស្គាល់ ទុគ្គតិ នេះជាផលនៃទឹកដោះថ្លា ។ កិលេសទាំងឡាយ ខ្ញុំ ដុតបំផ្លាញហើយ ភពទាំងអស់ ខ្ញុំគាស់រំលើងចោលហើយ ខ្ញុំជាអ្នកមិនមានអាសវៈ ដូចដំរីដ៏ប្រសើរកាត់ផ្តាច់ខ្សែចំណង ។

ស្វាគតំ វត មេ អាសិ មម ពុទ្ធស្ស សន្តិកេ

តិស្សោ វិជ្ជា អនុប្បត្តា កតំ ពុទ្ធស្ស សាសនំ

បដិសម្ភិទា ចតស្សោ វិមោក្ខាបិ ច អដ្ឋិមេ

ឆឡភិញ្ញា សច្ឆិកតា កតំ ពុទ្ធស្ស សាសនន្តិ ។

ឥត្ថំ សុទំ អាយស្មា ឃដមណ្ឌទាយកោ ថេរោ

ឥមា គាថាយោ អភាសិត្ថាតិ ។

ឃដមណ្ឌទាយកត្ថេរស្ស អបទានំ សមត្តំ ។

## សត្តមំ ឯកធម្មស្សវនីយត្ថេរាបទានំ

(៦៧) បទុមុត្តរោ នាម ជិនោ សព្វធម្មាន បារគូ

ចតុសច្ចំ បកាសេន្តោ សន្តារេសិ ពហុំ ជនំ ។

អហំ តេន សមយេន ជដិលោ ឧគ្គតាបនោ

ធុនន្តោ វាកចីរានិ គច្ឆាមិ អម្ពរេ តទា ។

ពុទ្ធសេដ្ឋស្ស ឧបរិ គន្តុំ ន វិសហាមហំ

បក្ខីវ សេលមាសជ្ជ គមនំ ន លភាមហំ ។



៤ ។ ដំណើរដែលខ្ញុំមក ក្នុងសំណាក់នៃព្រះពុទ្ធរបស់ខ្ញុំ ជាដំណើរល្អហ្ន៎ វិជ្ជា ៣ ខ្ញុំបានដល់មានលំដាប់ហើយ សាសនារបស់ព្រះពុទ្ធ ខ្ញុំក៏បានធ្វើហើយ ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនា របស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ។

បានឮថា ព្រះឃដមណ្ឌទាយកត្ថេរ មានអាយុ បានសំដែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

ចប់ ឃដមណ្ឌទាយកត្ថេរាបទាន ។

## ឯកធម្មស្សវនីយត្ថេរាបទាន ទី ៧

(១៧) ព្រះជិនស្រី ព្រះនាមបទុមុត្តរៈ ទ្រង់ដល់នូវត្រើយ នៃធម៌ទាំងពួង ទ្រង់ប្រកាសនូវសច្ចៈទាំង ៤ បានញុំាងជនច្រើនឲ្យឆ្លងទុក្ខហើយ ។ សម័យនោះ ខ្ញុំជាជដិល មានតបធម៌ដ៏ខ្ពង់ខ្ពស់ រលាស់នូវចីវរសំបកឈើ ហើយហោះទៅឰដ៏អាកាស ក្នុងកាលនោះ ។ ខ្ញុំមិនអាចហោះទៅខាងលើព្រះពុទ្ធ ដ៏ប្រសើរឡើយ ខ្ញុំមិនបានទៅដំណើរទៅមុខ ប្រៀបដូចសត្វស្លាបដែលទើសទាក់ភ្នំ ។

## គាថា វិមានបុរសដែលគោរពមាតា

ឧឡារោ ពោធយិត្វាន(១)  ឋាំ កញ្ញាមិ អត្តរេ
ន មេ សតិ ភុត្តមុត្តំ  សរិយាមផរិកោសនំ ។
ហត្ថមេតំ កលេសិស្សំ  អនេក្ខកិ ឈនេយ្យហំ
ទិវោហារេ្ត អត្តលិត្វា  សត្តមស្សោសំ សត្តុនោ ។
សមេន វធិនេយន  សមធិយេន វត្តកា
អច្ចុតិ ការេត្តស្ស  តញ្ញោ ទុក្ខហិ តតា ។
អច្ចុសញ្ញាមុត្តយ(២)  អតមាសំ មមស្សំ
យាវតាយុំ វសិត្វាន  តតោ កាលំ កតោ អហំ ។
ចរិមេ វត្តមានម្ហិ  សទ្ធម្មស្សវនំ សរំ
តេន កម្មេន សុកតេន  ចេតនាបណិធីហិ ច ។
ជហិត្វា មានុសំ ទេហំ  តាវតឹសំ អគញ្ឆហំ
តិសកប្បសហស្សានិ  ទេវលោកេ រមឹ អហំ ។

---

១ ឱ. ពោធិសិត្វាន ។ ម. ពោក្ខមិត្វាន ។ ២ ឱ. អនិច្ចសញ្ញំ ឧគ្គយ្ហ ។ ម. អនិច្ចសញ្ញំ បគ្គយ្ហ ។



## រឿងបុរសដែលបម្រើមាតា ទី ៣

កាលបើយ៉ាងនេះ ខ្ញុំចុះទៅក្នុងទឹក ហើយហោះទៅឰដីអា-
កាសទៀត (តែខ្ញុំទៅមុខមិនរួច) ការញ៉ាំងឥរិយាបថឲ្យ
កម្រើកបែបនេះ ខ្ញុំមិនធ្លាប់មានទេ ។ (ខ្ញុំគិតថា) ធ្វើដូចម្ដេច
ហ្ន៎ អាត្មាអញ នឹងបានដឹងហេតុការណ៍នេះអេះ បើដូច្នោះ
មានតែអាត្មាអញ នឹងស្វែងរក នូវហេតុការណ៍នោះ ។
ខ្ញុំក៏ចុះអំពីអាកាស បានឮនូវសំឡេងនៃព្រះសាស្ដា ដែល
កំពុងសម្ដែងនូវអនិច្ចតាធម៌ ដោយសំឡេងដ៏ពីរោះ គួររីក-
រាយគួរស្ដាប់ ខ្ញុំក៏ចងចាំអនិច្ចតាធម៌នោះ ក្នុងកាលនោះ ។
លុះខ្ញុំចងចាំនូវអនិច្ចសញ្ញាហើយ ក៏បានទៅឯអាស្រមរបស់
ខ្ញុំវិញ ខ្ញុំនៅទីនោះដរាបលុះអស់អាយុ ហើយធ្វើមរណកាល
ក្នុងអាស្រមនោះ ។ កាលតពីខាងក្រោយ កំពុងប្រព្រឹត្ត
ទៅ ខ្ញុំក៏នឹកឃើញនូវការស្ដាប់ព្រះសទ្ធម្ម ព្រោះអំពើដែល
ខ្ញុំធ្វើល្អនោះផង ព្រោះការតាំងទុកនូវចេតនានោះផង ។ ខ្ញុំ
លះបង់កាយជារបស់មនុស្សហើយ ក៏បានទៅកើត ក្នុង
ឋានតាវត្តិង្ស ខ្ញុំត្រេកអរក្នុងទេវលោក អស់ ៣ ម៉ឺនកប្ប ។

ឯកបញ្ញាសក្ខត្តុញ្ច ទេវរជ្ជមការយឹ
ឯកត្តឹសតិក្ខត្តុញ្ច ចក្កវត្តិ អហោសហំ ។
បទេសរជ្ជំ វិបុលំ គណនាតោ អសង្ខិយំ
អនុភោមិ សកំ បុញ្ញំ សុខិតោហំ ភវាភវេ ។
អនុស្សរាមិ តំ សញ្ញំ សំសរន្តោ ភវាភវេ
ន កោដិបំ វិជានាមិ(១) ចិញ្ញាណំ អនុត្តំ បទំ ។
បិតុ គេហេ និសីទិត្វា សមណោ ភាវិតិន្ទ្រិយោ
តាទិ ស(២) បវិធេត្តា អសិទ្ធំ គុត្តាហារំ(៣) ។
អនិច្ចាវត សង្ខារា ឧប្បាទវយធម្មិនោ
ឧប្បជ្ជិត្វា និរុជ្ឈន្តិ តេសំ វូបសមោ សុខោ ។
សហ គាថំ សុណិត្វាន បុព្វសញ្ញំ អនុស្សរិំ(៤)
ឯកាសនេ និសីទិត្វា អរហត្តមបាបុណិំ ។

---

១ ឱ. ន កោដិំ វិជានាមិ ។ ម. ន កោដិ បដិវិជ្ឈាមិ ។ ២ ឱ. កប្បាយ ។ ៣ ឱ. វិត្តាហារំ ។ ៤ ឱ. ម បុព្វសញ្ញមនុស្សរឹ ។



ខ្ញុំបានសោយទេវរាជ្យ ជាស្តេចនៃពួកទេវតា អស់ ៥១ ដង បានជាស្តេចចក្រពត្តិ អស់ ៣១ ដង ។ បានសោយប្រទេសរាជ្យ ដ៏ធំទូលាយ រាប់ជាគិតមិនអស់ ខ្ញុំបានសោយផលបុណ្យរបស់ខ្លួន ដល់នូវសេចក្តីសុខ ក្នុងភពតូចភពធំ ។ កាលខ្ញុំអន្ទោលទៅ ក្នុងភពតូចនិងភពធំ តែងរំលឹកឃើញនូវសញ្ញានោះ តែមិនអាចនឹងកាត់ផ្តាច់ នូវមិច្ឆារេ បទមិនឃ្លៀងឃ្លាតបាន ដោយហេតុណាមួយឡើយ ។ មានសមណៈមួយរូប មានឥន្ទ្រិយអប់រំហើយ គង់នៅក្នុងផ្ទះនៃបិតារបស់ខ្ញុំ ហើយសម្តែងនូវគាថា ពោលនូវអនិច្ចតាធម៌ក្នុងផ្ទះនោះថា ឱហ្ន៎ សង្ខារទាំងឡាយ មិនទៀងទេ មានកិរិយាកើតឡើង និងការវិនាសទៅវិញជាធម្មតា ព្រោះកើតឡើងហើយ រមែងរលត់ទៅវិញ លុះតែការរម្ងាប់នូវសង្ខារទាំងឡាយនោះ ទើបនាំមកនូវសេចក្តីសុខ ។ ខ្ញុំបានស្តាប់ធម៌ ព្រមទាំងគាថា ហើយនឹកឃើញនូវសញ្ញាទាំងពួង អង្គុយលើអាសនៈមួយ ក៏ដល់នូវព្រះអរហត្ត ។

សត្តមំ ឯកធម្មសវនិយត្ថេរាបទានំ

[illegible] សត្ថុសាសនេ ករោន្តិ អបាតុលំ
[illegible] ធម្មស្សវនស្សិទំ ផលំ ។
[illegible] វេស្សន្តរោ ... ធម្មំ អសុណិ តទា
[illegible] ហេតុជាតមិ ធម្មស្សវនស្សិទំ ផលំ ។
[illegible] សោបចិតា ... ភវា សព្វេ សមូហតា
[illegible] វិហរាមិ អនាសវោ ។
[illegible] មម ពុទ្ធស្ស សន្តិកេ
[illegible] តាទិ ពុទ្ធស្ស សាសនំ ។
[illegible] វិមោក្ខាបិច អដ្ឋិមេ
[illegible] កតំ ពុទ្ធស្ស សាសនន្តិ ។

[illegible] ឯកធម្មសវនិយោ ថេរោ [illegible]
[illegible] ។

[illegible] ឯកធម្មសវនិយត្ថេរាបទានំ [illegible] ។



ឯកធម្មស្សវនិយត្ថេរាបទាន ទី ៧

ខ្ញុំបានដល់ព្រះអរហត្ត តាំងពីអាយុ ៧ ឆ្នាំ ព្រះសម្ពុទ្ធបាន ញុំាងខ្ញុំឲ្យបានឧបសម្បទា នេះជាផលនៃការស្ដាប់ព្រះធម៌ ។ ក្នុងកប្បទីមួយសែន អំពីកប្បនេះ ព្រោះហេតុដែលខ្ញុំបានស្ដាប់ធម៌ ក្នុងកាលនោះ ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃការស្ដាប់ធម៌ ។ កិលេសទាំងឡាយ ខ្ញុំបានដុតចោលហើយ ភពទាំងអស់ ខ្ញុំបានគាស់រំលើងហើយ ខ្ញុំជាអ្នកមិនមានអាសវៈ ដូចជាដំរីកាត់ខ្សែចំណង ។ ឱ ! ដំណើរដែលខ្ញុំមកក្នុងសំណាក់ នៃព្រះពុទ្ធរបស់ខ្ញុំ ជាដំណើរល្អហ្ន៎ វិជ្ជា ៣ ខ្ញុំបានដល់ហើយ សាសនារបស់ព្រះពុទ្ធ ខ្ញុំបានធ្វើហើយ ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនា របស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ។

បានឮថា ព្រះឯកធម្មស្សវនិយត្ថេរ មានអាយុ បានសម្ដែងគាថាទាំងនេះ ដោយប្រការដូច្នេះ ។

ចប់ ឯកធម្មស្សវនិយត្ថេរាបទាន ។

## អដ្ឋមំ សុបិត្តិកត្ថេរាបទានំ

(១៨) នគរេ ហំសវតិយា អហោសឹ កស្សកោ តទា
កសិកម្មេន ជីវាមិ តេន បោសេមិ ទារកេ ។
សុសម្បន្នំ តទា ខេត្តំ ធញ្ញំ មេ ផលិនំ(១)អហុ
បាកកាលេ ច សម្បត្តេ ឯវំ ចិន្តេសហំ តទា ។
ន មេត្តំ(២) ន បដិរូបំ ជានន្តស្ស គុណាគុណំ
យោហំ សង្ឃេ អទត្វាន អគ្គំ ភុញ្ជេយ្យមត្តជា(៣) ។
សម្ពុទ្ធោ អសមោ លោកេ(៤) ទ្វត្តឹសវរលក្ខណោ
តតោ ច ការិតោ(៥)សង្ឃោ បុញ្ញក្ខេត្តំ អនុត្តរំ(៦) ។
តត្ថ ទស្សាមិហំ ទានំ នវសស្សំ បុរេ បុរេ
ឯវាហំ ចិន្តយិត្វាន ហដ្ឋោ បីតិកមានសោ(៧) ។

---

១ ឱ. ផលិតំ ។ ២ ឱ.ម. ឆន្នំ ។ ៣ ឱ. ភុញ្ជេយ្យំ អហំ តទា ។ ម. ភុញ្ជេយ្យ អហំ តទា ។ ៤ ឱ.ម. អយំ ពុទ្ធោ អសមសមោ ។ ៥ ឱ.ម. បការិតោ ។ ៦ ឱ.ម. បុញ្ញក្ខេត្តំ អនុត្តរោ ។ ៧ ឱ.ម. បីណិតមានសោ ។



## សុបិត្តិកត្ថេរាបទាន ទី ៨

(១៨) កាលនោះ ខ្ញុំជាអ្នកស្រែ នៅក្នុងនគរហង្សវតី ចិញ្ចឹមជីវិតដោយកសិកម្ម ចិញ្ចឹមនូវប្រពន្ធនិងកូន ក៏ដោយកសិកម្មនោះដែរ ។ កាលនោះ ស្រែ (របស់ខ្ញុំ) បានស្រូវបរិបូណ៌ នេះជាផលរបស់ខ្ញុំ កាលស្រូវទុំបរិបូណ៌ហើយ ក្នុងកាលណោះ ខ្ញុំគិតយ៉ាងនេះថា កាលអាត្មាអញមិនទាន់ឲ្យទានដ៏ប្រសើរ ចំពោះព្រះសង្ឃសោះ បរិភោគតែខ្លួនឯង (អំពើនេះ) មិនសមរម្យ មិនសមគួរដល់អាត្មាអញ ដែលជាអ្នកដឹងនូវគុណនិងទោសឡើយ ។ ព្រះសម្ពុទ្ធ មិនមានបុគ្គលស្មើក្នុងលោក ទ្រង់មានព្រះលក្ខណៈ ៣២ ដ៏ប្រសើរ តាំងព្រះសង្ឃមានចិត្តអប់រំហើយ ជាស្រែបុណ្យ ដ៏ប្រសើរ (មានក្នុងលោកហើយ) ។ អញនឹងប្រគេន នូវស្រូវថ្មី ជាទានចំពោះព្រះភិក្ខុសង្ឃនោះមុនគេ លុះខ្ញុំគិតយ៉ាងនេះហើយ ជាអ្នកត្រេកអរ មានចិត្តប្រកបដោយបីតិ ។

អដ្ឋមំ សុចិត្តវគ្គបឋមំ

...ឧញ្ញាហរិត្វា(១) សម្ពុទ្ធំ ឧបសង្កមិ

...សម្ពុទ្ធំ លោកនាថំ ...សតំ ៗ

... សត្ថា ... ឥទំ វចនមព្រវិ

...សម្បន្នំ ឥធ ហោសិ បត្តំ មុនេ(២)

... ឧទាហាយ អធិភាសេហិ បក្កាម(៣)

... លោកវិទូ អាហុតីនំ បដិគ្គហោ ៗ

... សង្ឃមញ្ញាយ ឥទំ វចនមព្រវិ

...ច បដិបន្នា ចត្តារោ ច ផលេ ឋិតា ៗ

...សង្ឃោ ឧជុភូតោ បញ្ញាសីលសមាហិតោ

យជមានានំ មនុស្សានំ បុញ្ញបេក្ខាន បាណិនំ

ករោតំ(៤) ឱបធិកំ បុញ្ញំ(៥) សង្ឃេ ទិន្នំ មហប្ផលំ

...សង្ឃេ ... ... តំ សង្ឃេ ... ៗ

---

១ ម. [illegible] ។ ២ ឱ. [illegible] ។ ៣ ម. [illegible] ។
៤ ម. [illegible] ។ ៥ ម. [illegible] ។



សុចិត្តវគ្គបឋមទី ៨

ខ្ញុំយកស្រូវ អំពីស្រែចូលទៅរកព្រះសម្ពុទ្ធ លុះចូលទៅដល់ព្រះសម្ពុទ្ធ ព្រះអង្គជាច្បងក្នុងលោក ទ្រង់ប្រសើរជាងពួកនរៈហើយ ក៏ថ្វាយបង្គំព្រះបាទានៃព្រះសាស្ដា រួចក្រាបទូលថា បពិត្រព្រះមុនី សំទូងថ្មី (របស់ខ្ញុំ) បរិបូណ៌ហើយ ចាំងព្រះអង្គក៏គង់នៅក្នុងទីនេះ បពិត្រព្រះអង្គមានចក្ខុ សូមព្រះអង្គអាស្រ័យនូវសេចក្ដីអនុគ្រោះ ហើយទទួលនិមន្ត ៗ ព្រះសម្ពុទ្ធ ព្រះនាមបទុមុត្តរៈ ព្រះអង្គជ្រាបច្បាស់នូវត្រៃលោក គួរទទួលនូវគ្រឿងបូជា ព្រះអង្គជ្រាបនូវសេចក្ដីត្រិះរិះរបស់ខ្ញុំហើយ ទ្រង់សំដែងនូវពាក្យនេះថា បុគ្គល ៤ ពួក កំពុងប្រតិបត្តិ បុគ្គល ៤ ពួក ឋិតនៅក្នុងផល ៗ នេះជាសង្ឃមានព្រះទ័យស្លូតត្រង់ ប្រកបដោយបញ្ញា និងសីល ទាន ដែលមនុស្សទាំងឡាយអ្នកបូជា ជាសត្វប្រាថ្នាបុណ្យ កាលធ្វើនូវការសន្សំបុណ្យ បានឲ្យហើយចំពោះព្រះសង្ឃ រមែងមានផលច្រើន ឯសំទូងនៃអ្នកនេះ ដែលអ្នកគប្បីឲ្យចំពោះព្រះសង្ឃនោះ ក៏មានផលច្រើន ដូច្នោះដែរ ៗ

[illegible] ឧទ្ទិសិត្វាន ភិក្ខូ នេត្វា [illegible] ឃរំ(១)

[illegible] យេ សន្តិ(២) ភិក្ខុសង្ឃស្ស [illegible] ។

[illegible] ឧទ្ទិសិត្វាន ភិក្ខូ នេត្វានហំ ឃរំ

[illegible] ភិក្ខុសង្ឃស្សទាសហំ ។

[illegible] សុភាវេន ចេតនាបណិធីហិ ច

[illegible] នេហិ តាវតិំសំ អគញ្ឆហំ ។

[illegible] សោវណ្ណំ សុបកស្សរំ(៣)

[illegible] តិំសយោជនវិត្ថតំ ។

[illegible] ។

១ [illegible] ២ [illegible] ៣ [illegible]





អ្នកប្រុសខ្ញុំសំពោះសង្ឃ ហើយនាំភិក្ខុទាំងឡាយ ទៅឯផ្ទះ

របស់ខ្លួន ប្រប្រគេននូវភត្ត ដែលអ្នកគាត់តែងរួចហើយ

ដែលមានក្នុងផ្ទះ ដល់ភិក្ខុសង្ឃនុះ ។ ខ្ញុំក៏បានចូលសំពោះ

សង្ឃ ហើយនាំភិក្ខុទាំងឡាយទៅឯផ្ទះ ភត្តណា ដែលខ្ញុំ

តាក់តែងហើយក្នុងផ្ទះ ខ្ញុំក៏ប្រគេនភត្តនោះ ដល់ភិក្ខុសង្ឃ

ខ្ញុំលះបង់នូវកាយ ជារបស់មនុស្សហើយ ក៏ទៅកើតក្នុង

ឋានតាវត្តិង្ស ដោយកំពើដែលខ្ញុំ បានធ្វើល្អហើយនោះផង

ដោយការតាំងទុកនូវចេតនានោះផង ។ វិមានរបស់ខ្ញុំ មាន

ពណ៌ល្អ មាន[illegible] ដែលបុញ្ញកម្មតាក់តែងហើយ ក្នុង

វេហាសភាគនោះ ជាវិមានមានកំពស់ ៦០ យោជន៍ មានទំហំ

៣០ យោជន៍ ។

ចប់ [illegible] វិមានទី [illegible] ។

## អដ្ឋមំ សុចិន្តិតត្ថេរាបទានំ

[illegible] ករំ មយ្ហំ　　នាវិកណសមាគតំ
[illegible] ចតុទ្ធា ច　　វសាមិ និចរសេ អហំ ។
[illegible] សុគន្ធំ(១) ច　　ចេវជ្ជមត្តរយំ
[illegible] ញ្ញាតំ　　ចេវជ្ជមត្តរយំ(២) ។
[illegible] ញ្ញាតំ　　ចក្ខាផ្តិ អហោសហំ
[illegible] វិបុលំ　　ករណាតោ អសង្ខិយំ ។
[illegible] សិវិកេ　　លភាមិ អមិតំ ធនំ
[illegible] ធនំ　　នវវត្ថស្សិទំ ផលំ ។
[illegible] សណ្ហានិ　　សតិកំ សុខុមាលិកំ
[illegible] វត្ថំ　　នវវត្ថស្សិទំ ផលំ ។
[illegible]　　នវត្ថំ លភាមហំ
[illegible]　　នវវត្ថស្សិទំ ផលំ ។
[illegible]　　[illegible] លភាមហំ ឥ
[illegible]　　នវវត្ថស្សិទំ ផលំ ។

១ ម. [illegible] ២ ម. [illegible]



## សុចិន្តិតត្ថេរាបទាន ទី ៨

សំពត់ដែលខ្ញុំបានឲ្យក្នុងកាលជាមនុស្សជាតិ ខ្ញុំបានកើតជាជង្គ ដំរីជង្គ នៅក្នុងឋានទេវលោក ។ ខ្ញុំបានសោយទេវសម្បត្តិ ជាស្តេចនៃទេវតា អស់ ៣.០០០ ដង បានជាស្តេចចក្រពត្តិ អស់ ៥០០ ដង បានសោយរាជ្យសម្បត្តិដ៏ទូលាយ កប់ ជាច្រើនកប់ ។ ខ្ញុំកាលអន្ទោលទៅក្នុងភពតូចភពធំ រមែង បាននូវទ្រព្យច្រើនរាប់មិនអស់ ខ្ញុំមិនមានការខ្វះខាត ដោយការ តាំងឡើងឱ្យទ្រព្យ នេះជាផលនៃសំពត់ថ្មី ។ ខ្ញុំបាននូវគ្រឿង គ្រប់មុខនេះ គឺ យានដំរី យានសេះ វ ... រថ ក្រទេះគ្រឿង នេះជាផលនៃសំពត់ថ្មី ។ ខ្ញុំបាននូវគ្រឿងគ្រប់មុខ នេះ គឺ សំពត់ថ្មី វត្ថុឈើថ្មី និងគ្រឿងតែងខ្លួនថ្មីមានតម្លៃ ... នេះជាផលនៃសំពត់ថ្មី ។ ខ្ញុំបាននូវគ្រឿងគ្រប់ មុខនេះ គឺ សំពត់សូត្រ សំពត់កម្ពល សំពត់សម្បក ឈើ ... នេះជាផលនៃសំពត់ថ្មី ។

នាសិតស្សំ នាសកេណំ ជាតិយោ សមសណ្ឋិតា

អហាសិ សញ្ញមេវេតំ ឧទិសស្សគស្សិឆំ ផលំ ។

... សិតំ ខុណ្ណំ ... បរិក្ខតោ ន វិជ្ជតិ

... ពេតសិតំ ទុក្ខំ ហាមយេ មេ ន វិជ្ជតិ ។

... មាន ឥមំ តុញ្ញ ឥមម្ហិ សយនេ សយ

អហាសិ សញ្ញមេវេតំ ឧទិសស្សស្សិឆំ ផលំ ។

... ... ចរិយោ វត្ថេ កតេ

... ... មមំ តោសេតិ សព្វទា ។

... ... ... ... ...

... ... ... ... ... ។

... ... ... ... ...

... ... ... ... ... ។



ខ្ញុំបានឲ្យនូវគ្រប់មុខនេះ គឺ ពួកខ្ញុំស្រី ពួកខ្ញុំប្រុស និងពួក

ជាប្រុះទឹក មានខ្លួនជាក់តែងស្អេកហើយ នេះជាផលនៃសំ-

ពត់ថ្មី ។ ខ្ញុំមិនមានសម្ផស្សត្រជាក់និងក្ដៅ បំពាល់ឡើយ

ទាំងមិនមានសេចក្ដីក្ដៅក្រហាយ ម្យ៉ាងទៀត ទុក្ខ

ប្រព្រឹត្តទៅក្នុងចិត្ត មិនមានក្នុងហឫទ័យរបស់ខ្ញុំឡើយ ។ ខ្ញុំ

បាននូវភាពប្រាកដ ទាំងអស់នេះជា សូមអ្នកភិរមន៍នូវផែនេះ

សូមអ្នកបរិភោគនូវផែនេះ សូមអ្នកសម្រាន្ត លើទីសយនៈ

នេះ នេះជាផលនៃសំពត់ថ្មី ។ នេះរកដ៏កាយខាងក្រោយ

បំផុត ... នេះ គតខាងក្រោយកំពុងប្រព្រឹត្តទៅ ក្នុងថ្ងៃ

នេះ ទេយ្យធម៌របស់ខ្ញុំ តែងញ៉ាំងខ្ញុំ ឲ្យត្រេកអរសព្វ ។

កាល ។ ខ្ញុំបានឲ្យសំពត់ថ្មី ចំពោះព្រះសង្ឃ ជាគណៈដ៏

ប្រសើរបំផុត ហើយបាននូវគតិសម្បត្តិ ៨ ដ៏សមគួរដល់កម្ម

របស់ខ្លួន គឺ ខ្ញុំជាអ្នកមានសម្បុរល្អ ១ មានយស ១ មាន

សេចក្ដីសុខច្រើនមិនមានរោគ ១ មានដំណើរច្រើន សព្វ ៗ

កាល ១ ... ... សព្វ ៗ កាល ១ ។

អដ្ឋមំ សុបិន្តព្យាករណំ

ភវិស្សតិ អបចាយន្តិ    យេ កេចិ បវិសន្តិតា

អធម្មេន គហេត្វា កេចិ    ធុរេ ធុរេ លភាមហំ ។

កិច្ចស្ស ផលស្ស ច អត្ថេ    តុច្ឆសេដ្ឋស្ស សម្មតា

ភវិស្សតិ សមតិក្កម្ម    នេត្តិ បរកំ នាយកា ។

មហិតិ ជនសស្សញ្ញា    ឥត្ថា សព្វេ កណ្ណាមេ

សំរោធិសិសេ អនុភោម៉    ជនស្សសុខំ ផលំ ។

កាលេសរកាសេដ្ឋិនោ កាមេយ្យ យំ    តាឲបធនំ ធនា

បុត្តំ នាកិជាតាម៉    ជនស្សសុខំ ផលំ ។

ពហុពោធិ ពលោបិតា មហ្សំ    កក់ សព្វេ សម្បាតា

ពលពោ៍ តស្ស មេត្តា    វិភាគំ អនាសរប៉ ។

ព្យាពាធំ ភាគ ពេ ភាសំ    ឥឥ តុច្ឆស្ស សន្តិកេ

សោតាប្បំ ពិទូ តេដ្ឋិតា    ពោធិ តុច្ឆស្ស សាសនំ ។



សុបិន្តព្យាករណ៍ ទី ៨

ផងតាំងក្អមធំមួយ ដែលកស្រ័យនៅលើផែនដី ផង

តាំងនោះ តែងតែតាំងនៅក្រុងខ្ញុំ ១ ទៀតច្រើនមួយ

(ទាន) ខ្ញុំតែងបាន (ក្អមទៀតទាំងនោះ) ដូចនេះ ១ ។

ទាយកទាំងឡាយ តែងលែងទឹកក្នុងក្អមទាំងអស់ ហើយ

ឲ្យផល់ខ្ញុំតែម្នាក់ឯង ក្នុងកណ្ដាលនៃក្អមធំ ឬក្នុងទីដ៏-

នោះព្រះអង្គនៃព្រះសម្មាសម្ពុទ្ធដ៏ប្រសើរ ១ ។ ខ្ញុំឲ្យនូវសំនួនថ្មី

ជាដំបូង ចំពោះព្រះអង្គ ជានិងរះដ៏ឧត្តម ទើបបាន

នូវគាថាសម្ដែងទាំងនេះ នេះជាផលនៃសំនួនថ្មី ។ ក្នុងកប្ប

ទីមួយសែន អំពីកប្បនេះ ព្រោះហេតុដែលខ្ញុំ បានឲ្យនូវ

ទាន ក្នុងកាលនោះ ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផល

នៃសំនួនថ្មី ។ កិលេសទាំងឡាយ ខ្ញុំដុតបំផ្លាញហើយ ភព

ទាំងអស់ ខ្ញុំគាស់រំលើងហើយ ខ្ញុំជាអ្នកមិនមានអាសវៈ

ព្រោះជាដំរីកាត់នូវចំណង ។ ឱ! ដំណើរដែលខ្ញុំមក ក្នុងសំ-

ណាក់នៃព្រះពុទ្ធរបស់ខ្ញុំ ជាដំណើរល្អហើយ វិជ្ជា ៣ ខ្ញុំបាន

សម្រេចហើយ សាសនារបស់ព្រះពុទ្ធ ខ្ញុំបានធ្វើហើយ ។

បដិសម្ភិទា ចតស្សោ វិមោក្ខាបិ ច អដ្ឋិមេ
ឆឡភិញ្ញា សច្ឆិកតា កតំ ពុទ្ធស្ស សាសនំ ។

ឥត្ថំ សុទំ អាយស្មា សុចិន្តិតោ ថេរោ ឥមា គា-
ថាយោ អភាសិត្ថាតិ ។

សុចិន្តិតត្ថេរស្ស អបទានំ សមត្តំ ។

## នវមំ សោណ្ណកិង្កណិយត្ថេរាបទានំ

(៤៩) [illegible] អត្ថិកំ [illegible]

[illegible] កាសី [illegible] ។
[illegible] លោកជេដ្ឋោ នរាសភោ
[illegible] មហាវនំ ។
[illegible] [illegible]
[illegible] [illegible] ។
[illegible] [illegible](១) [illegible]
[illegible] [illegible] ។

[illegible]





បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើ
ឲ្យជាក់ច្បាស់ហើយ ពាក្យប្រៀនប្រដៅ របស់ព្រះពុទ្ធ ខ្ញុំបាន
ប្រតិបត្តិហើយ ។

បានឮថា ព្រះសុចិន្តិតត្ថេរ មានអាយុ បានសម្តែងនូវគាថា
ទាំងនេះ ដោយប្រការដូច្នេះ ។

ចប់ សុចិន្តិតត្ថេរាបទាន ។

## សោណ្ណកិង្កណិយត្ថេរាបទាន ទី៩

(៤៩) ខ្ញុំចេញទៅកាន់ផ្លូវ ដោយសត្វ [illegible]
[illegible] [illegible] ។ ក្នុងសម័យនោះ ព្រះ
មានព្រះភាគ ព្រះនាមអត្ថទស្សី ជាច្បងក្នុងលោក ប្រ
សើរជាងនរៈ បានត្រាស់ឡើង ហើយចូលទៅកាន់មហាវន ។
[illegible] របស់ខ្ញុំអស់ហើយ [illegible] ខ្ញុំលើក
[illegible] ហើយក្រាបព្រះសម្ពុទ្ធដ៏ឧត្តម [illegible]
[illegible] ។ ខ្ញុំមានចិត្តរីករាយ មានចិត្តខ្ពង់ខ្ពស់ មានសេចក្តី
ជ្រះថ្លា [illegible] កណ្តឹងមាសទាំងឡាយ ។

## សោណកោដិកណ្ណត្ថេរាបទានំ

សម្មុខា វិយ សម្ពុទ្ធំ  ថូបំ បរិចរិំ អហំ
តេន ចេតោបសាទេន  អត្ថទស្សិស្ស តាទិនោ ។
ទេវលោកំ គតោ សន្តោ  លភាមិ វិបុលំ សុខំ
សុវណ្ណវណ្ណោ តត្ថាសិ(១)  ពុទ្ធបូជាយិទំ ផលំ ។
អសីតិកោដិយោ មយ្ហំ  ទាសិយោ សមលង្កតា
សទា មយ្ហំ ឧបដ្ឋន្តិ  ពុទ្ធបូជាយិទំ ផលំ ។
សដ្ឋិ តុរិយសហស្សានិ  ភេរិយោ បណវានិ ច
សង្ខា ច ឌិណ្ឌិមា តត្ថ  វគ្គុ វទន្តិ ទុន្ទុភិ(២) ។
ចុល្លាសីតិសហស្សានិ  ហត្ថិយោ(៣) សមលង្កតា
តិធាបភិន្នា មាតង្គា(៤)  កុញ្ជរា សដ្ឋិហាយនា ។
ហេមជាលាភិសញ្ឆន្នា  ឧបដ្ឋានំ ករោន្តិ មេ
ពលកាយេ គជេ ចេវ  ឩនតា មេ ន វិជ្ជតិ ។
សោវណ្ណកិង្កណិបុប្ផានំ  វិបាកំ អនុភោមហំ
អដ្ឋតាលីសក្ខត្តុំ ច  ទេវរជ្ជមការយិំ ។

---

១ ម. អត្តាសិ ។ ២ ឱ. វគ្គុ វទតិ ទុន្ទុភី ។ ម. វគ្គូ វទន្តិ ទុន្ទុភី ។ ៣ ឱ. ហត្ថិ-នោ ។ ៤ ម. តិធាបភិន្នមាតង្គា ។



## សោណកោដិកណ្ណត្ថេរាបទាន ទី ៤

ខ្ញុំបម្រើនូវព្រះស្តូប នៃព្រះមានព្រះភាគ ព្រះនាមអត្ថទស្សី ព្រះអង្គមិនជាប់ជំពាក់ដោយលោកធម៌ ដោយចិត្តជ្រះថ្លានោះ ដូចជាបម្រើព្រះសម្ពុទ្ធ គង់ទំពារព្រះកេត្រ ។ កាលខ្ញុំទៅកើតក្នុងទេវលោក រមែងបាននូវសេចក្តីសុខដ៏ធំទូលាយ ជាអ្នកមានសម្បុរដូចមាស ក្នុងទេវលោកនោះ នេះជាផលនៃពុទ្ធបូជា ។ នារីទាំងឡាយរបស់ខ្ញុំ ៨០ កោដិ មានខ្លួនតាក់តែងល្អ បម្រើខ្ញុំសព្វ ៗ កាល នេះជាផលនៃពុទ្ធបូជា ។ តូរ្យតន្ត្រីយ ៦ ហ្មឺន ស្គរ ភេរី សង្ខ សំភោរ និងស្គរធំ មានសំឡេងពីរោះប្រគំក្នុងទីនោះ ។ ដំរីទាំងឡាយ ៨ ហ្មឺន ៤ ពាន់ ប្រដាប់តាក់តែងល្អ ដំរីមាតង្គៈទាំងឡាយចុះប្រេងបីកន្លែង អាយុ ៦០ ឆ្នាំ ទើបចាយកំឡាំង ដែលដៅដាសដោយបណ្តាញមាស ធ្វើនូវការបម្រើខ្ញុំ ខ្ញុំមិនមានការខ្វះខាតពួកពល ក្នុងកាលណាឡើយ ។ ខ្ញុំតែងទទួលផលនៃផ្កាកណ្តឹងមាស ខ្ញុំបានធ្វើជាស្តេចនៃទេវតា អស់ ៤៨ ដង ។

បញ្ចសត្តតិក្ខត្តុញ្ច ចក្កវត្តិ អហោសហំ

បទេសរជ្ជំ ឯកាសតំ បថវិយា តារយើ អហំ ។

...ភវាជិ បត្តោ អមតំ ...ត្ថិរំ ពុទ្ធស្សំ បទំ(១)

...ជា បរិក្ខីណា នត្ថិទានិ បុនព្ភវោ ។

...ស ឥតោ កប្បេ យំ បុប្ផមភិបូជយឹ

ទុគ្គតឹ នាភិជានាមិ ពុទ្ធបូជាយិទំ ផលំ ។

កិលេសា ឈាបិតា មយ្ហំ ភវា សព្វេ សមូហតា

នាគោវ ពន្ធនំ ឆេត្វា វិហរាមិ អនាសវោ ។

ស្វាគតំ វត មេ អាសិ មម ពុទ្ធស្ស សន្តិកេ

តិស្សោ វិជ្ជា អនុប្បត្តា កតំ ពុទ្ធស្ស សាសនំ ។

១ ឱ. [illegible] ។



ខ្ញុំបានជាស្ដេចចក្រពត្តិ អស់ ៧៥ ដង បានសោយរាជ្យលើ ផែនដី អស់ ១០១ ដង ។ ឥឡូវនេះ ខ្ញុំបានដល់ព្រះនិព្វាន ឈ្មោះអមតៈ ជាបទដ៏ប្រសើរ ដែលបុគ្គលឃើញបាន ដោយកម្រ សំយោជនៈទាំងឡាយ (របស់ខ្ញុំ) អស់ហើយ ហើយ ឥឡូវនេះ ភពថ្មីមិនមានទៀតឡើយ ។ ក្នុងកប្ប ទី ១,៨០០ អំពីកប្បនេះ ព្រោះហេតុដែលខ្ញុំបានបូជាផ្កាក្នុង កាលនោះ ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃពុទ្ធបូជា ។ កិលេសទាំងឡាយ ខ្ញុំដុតបំផ្លាញអស់ហើយ ភពទាំងអស់ ខ្ញុំដកបំបាត់ហើយ ខ្ញុំជាអ្នកមិនមានអាសវៈ ដូចជា ដំរីផ្ដាច់ខ្សែចំណង ។ ឱ! ដំណើរដែលខ្ញុំមក ក្នុង សំណាក់នៃព្រះពុទ្ធរបស់ខ្ញុំ ជាដំណើរល្អហើយ វិជ្ជា ៣ ខ្ញុំបាន ដល់ហើយ សាសនា របស់ព្រះពុទ្ធ ខ្ញុំបានធ្វើហើយ ។

បដិសម្ភិទា ចតស្សោ វិមោក្ខាបិច អដ្ឋិមេ
ឆឡភិញ្ញា សច្ឆិកតា កតំ ពុទ្ធស្ស សាសនំ ។

ឥត្ថំ សុទំ អាយស្មា សោវណ្ណកឹកណិយោ ថេរោ
ឥមា គាថាយោ អភាសិត្ថាតិ ។

សោវណ្ណកឹកណិយត្ថេរស្ស អបទានំ សមត្តំ ។

# ទសមំ សោវណ្ណកោន្តរិកត្ថេរាបទានំ

[៤០] អនោមទស្សិំ ពុទ្ធំ អត្តទន្តំ សមាហិតំ
ឥរិយមានំ ព្រហ្មបថេ ចិត្តូបសមេ រតំ ។
និត្តិណ្ណោឃំ សម្ពុទ្ធំ ឈាយិំ ឈានរតំ មុនិំ
ឧបវិដ្ឋំ សមាបន្នំ ឥន្ទីវរទលប្បភំ(១) ។

១. ម. [illegible] ។ ២. [illegible] ។





បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនា របស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ។

បានឮថា ព្រះសោវណ្ណកឹកណិយត្ថេរ មានអាយុ បានសំដែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

ចប់ សោវណ្ណកឹកណិយត្ថេរាបទាន ។

# សោវណ្ណកោន្តរិកត្ថេរាបទាន ទី ១០

[៤០] (ខ្ញុំបានឃើញ) នូវព្រះពុទ្ធ ព្រះអង្គមានព្រះហឫទ័យអប់រំហើយ មានព្រះហឫទ័យទូន្មានហើយ មានព្រះហឫទ័យតំកល់ខ្ជាប់ខ្ជួនហើយ ទ្រង់ប្រព្រឹត្ត ត្រេកអរក្នុងការរម្ងាប់ចិត្ត ដែលជាគន្លងប្រសើរ ទ្រង់ឆ្លងផុតនូវជំនន់ ទ្រង់ត្រាស់ដឹងប្រពៃ ទ្រង់មានឈាន ត្រេកអរក្នុងឈាន ទ្រង់[illegible] [illegible] ។

អលាពុនោទកំ គយ្ហ ពុទ្ធសេដ្ឋំ ឧបាគមឹ
ពុទ្ធបាទេ វន្ទិត្វាន អលាពុមទាសហំ ។
អនុមោទិ ច សម្ពុទ្ធោ បទុមុត្តរនាមកោ
ឥមំ ឧទកមាហត្វា បាទមូលេ ឋបេហិ មេ ។
សាធូតិហំ បដិស្សុត្វា សត្ថុ គារវតាយ វេ
ឧទកំ លាពុនាហត្វា ពុទ្ធសេដ្ឋំ ឧបានយឹ ។
អនុមោទិ មហាវីរោ ចិត្តំ និព្វាបយំ មម
ឥមិនា លាពុទានេន សង្កប្បោ តេ សមិជ្ឈតុ ។
អដ្ឋារសេ ឥតោ កប្បេ(១) ទេវលោកេ រមឹ អហំ
តេត្តឹសក្ខត្តុំ រាជា ច ចក្កវត្តិ អហោសហំ ។
ទិវា យទិ វា រត្តឹ ចង្កមន្តស្ស តិដ្ឋតោ
[illegible](២) [illegible] [illegible] ។

១ [illegible] ។



(លុះយើញហើយ) ខ្ញុំដងទឹក ដោយសម្បកឃ្លោក ហើយចូលទៅគាល់ព្រះសម្ពុទ្ធប្រសើរ ខ្ញុំបានថ្វាយព្រះបាទ នៃព្រះសម្ពុទ្ធ ហើយថ្វាយសម្បកឃ្លោកនោះ ។ ចំណែកព្រះសម្ពុទ្ធ ព្រះនាមបទុមុត្តរៈ ទ្រង់បន្ទាប់ខ្ញុំថា អ្នកចូរយកទឹកដោយសម្បកឃ្លោកនេះ ហើយដាក់ក្នុងទីជិតបាតបាទតថាគតចុះ ។ ខ្ញុំក៏ទទួលថា សាធុ ដោយសេចក្ដីគោរពចំពោះព្រះសាស្ដា ហើយយកទឹកដោយសម្បកឃ្លោក ចូលទៅថ្វាយព្រះសម្ពុទ្ធដ៏ប្រសើរ ។ ព្រះសម្ពុទ្ធទ្រង់មានព្យាយាមធំ បានញុំាងចិត្តរបស់ខ្ញុំឲ្យរលត់ ទ្រង់អនុមោទនាថា តម្រិះត្រូវបូរសម្រេចដល់អ្នក ដោយកិរិយាឲ្យនូវសម្បកឃ្លោកនេះចុះ ។ ក្នុងកប្បទី ១៨ អំពីកប្បនេះ ខ្ញុំត្រេកអរក្នុងទេវលោក រីឯរាប់បានជាស្ដេចចក្រពត្តិ ៣៣ ដង ។ កាលខ្ញុំដើរក្ដី ឈរក្នុងវេលាថ្ងៃ ឬក្នុងវេលាយប់ ជនទាំងឡាយតែងឈរ [illegible] [illegible] នៅពីខាងមុខខ្ញុំ ។

## ទសមំ សោណ្ណកោន្តរិកត្ថេរាបទានំ

ពុទ្ធស្ស ឧត្តាន លាពុំ លភាមិ សោណ្ណកោន្តរំ(១)
អាប្បុកិរំ តរំ(២) តារំ វិបុលំ ហោតិ តាទិសុ
សតសហស្សេ ឥតោ កប្បេ យំ លាពុមទទឹ(៣) តទា
ទុគ្គតិំ នាភិជានាមិ អលាពុស្ស ឥទំ ផលំ ។
កិលេសា ឈាបិតា មយ្ហំ ភវា សព្វេ សមូហតា
នាគោវ ពន្ធនំ ឆេត្វា វិហរាមិ អនាសវោ ។
ស្វាគតំ វត មេ អាសិ មម ពុទ្ធស្ស សន្តិកេ
តិស្សោ វិជ្ជា អនុប្បត្តា កតំ ពុទ្ធស្ស សាសនំ ។
បដិសម្ភិទា ចតស្សោ វិមោក្ខាបិ ច អដ្ឋិមេ
ឆឡភិញ្ញា សច្ឆិកតា កតំ ពុទ្ធស្ស សាសនំ ។

១. [illegible]



## សោណ្ណកោន្តរិកត្ថេរាបទាន ទី ១០

ព្រោះខ្ញុំថ្វាយសម្បកឃ្លោក ដល់ព្រះសម្ពុទ្ធ ទើបខ្ញុំបានលើ ប្រាក់ជាវិការៈនៃមាស ការបូជាសម្បូរ៍នៃបន្តិចបន្តួចដែលខ្ញុំ ធ្វើហើយ ចំពោះបុគ្គលទាំងឡាយ ដែលមិនញាប់ញ័រដោយ លោកធម៌ រមែងនាំប្រយោជន៍ជាគ្រឿងបូជាដ៏ធំទូលាយ ។ ក្នុង កប្បទីមួយសែន អំពីកប្បនេះ ព្រោះហេតុដែលខ្ញុំបាន ថ្វាយសម្បកឃ្លោក ក្នុងកាលនោះ ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃសម្បកឃ្លោក ។ កិលេសទាំងឡាយ ខ្ញុំដុត បំផ្លាញអស់ហើយ ភពទាំងអស់ ខ្ញុំគាស់រំលើងចោលហើយ ខ្ញុំជាអ្នកមិនមានអាសវៈ ដូចដំរីដ៏ប្រសើរកាត់ខ្សែទន្លីង ។ ឱ! ដំណើរដែលខ្ញុំមក ក្នុងសំណាក់នៃព្រះសម្ពុទ្ធរបស់ខ្ញុំ ជា ដំណើរល្អពិត វិជ្ជា ៣ ខ្ញុំបានដល់ហើយ សាសនារបស់ ព្រះពុទ្ធ ខ្ញុំបានធ្វើហើយ ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និង អភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនា របស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ។

ឥត្ថំ សុទំ អាយស្មា សោវណ្ណកោន្តរិកោ[១] ថេរោ ឥមា គាថាយោ អភាសិត្ថាតិ ។

សោវណ្ណកោន្តរិកត្ថេរស្ស អបទានំ សមត្តំ ។

### ឧទ្ទានំ

សកិំសម្មជ្ជកោ ថេរោ ឯកទុស្សាសនទាយកោ[២]
កទម្ពកោរណ្ឌកទា[៣] ឃតសវនិកោបិ ច
សុចិន្តិកោ កិង្កណិកោ សោវណ្ណកោន្តរិកោបិ ច
[illegible] គាថាយោ ឯកាសត្តតិមេវ ច ។

សកិំសម្មជ្ជកវគ្គោ តេចត្តាលីសោ ។

---

១ ឱ. សោវណ្ណកន្តរិកោ ។ ២ ឱ. ឯកទុស្សី តាសនី ។ ម. ឯកទុស្សី ឯកាសនី ។
៣ ឱ. កោរណ្ឌកទា ។





បានឮថា ព្រះសោវណ្ណកោន្តរិកត្ថេរ មានអាយុ បានសម្ដែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

ចប់ សោវណ្ណកោន្តរិកត្ថេរាបទាន ។

### ឧទ្ទាន

សកិំសម្មជ្ជកត្ថេរាបទាន ១ ឯកទុស្សទាយកត្ថេរាបទាន ១ ឯកាសនទាយកត្ថេរាបទាន ១ សត្តកទម្ពបុប្ផិយត្ថេរាបទាន ១ កោរណ្ឌបុប្ផិយត្ថេរាបទាន ១ ឃតមណ្ឌទាយកត្ថេរាបទាន ១ ឯកធម្មស្សវនិយត្ថេរាបទាន ១ សុចិន្តិកត្ថេរាបទាន ១ សោណ្ណកិង្កណិយត្ថេរាបទាន ១ សោវណ្ណកោន្តរិកត្ថេរាបទាន ១ ក្នុងសកិំសម្មជ្ជកវគ្គនេះ មានគាថា ១៣២ ។

ចប់ សកិំសម្មជ្ជកវគ្គ ទី ៤៣ ។

## បញ្ចបញ្ញាសមោ ឯកវិហារិវគ្គោ

## បឋមំ ឯកវិហារិយត្ថេរាបទានំ

[illegible] ក្ខន្តោ ភាវេន្ត? ព្រហ្មពន្ធុ មហាយសោ

[illegible] ស្សបោ នាម គោត្តេន ឧប្បជ្ជិ វទតំ វរោ ។

[illegible] និក្កិលេសោ [illegible]

[illegible] អនិមិត្តរតោ [illegible] ។

[illegible] (១) [illegible]

[illegible] ។

[illegible]

[illegible] ។

[illegible]

# ឯកវិហារិវគ្គ ទី ៥៥

## ឯកវិហារិយត្ថេរាបទាន ទី ១

(៥១) ព្រះសម្ពុទ្ធ ព្រះនាមកស្សបៈ ដោយគោត្រ ព្រះអង្គមានផៅពង្សប្រសើរ ទ្រង់មានយសប្រសើរជាងអ្នកប្រាជ្ញទាំងឡាយ ទ្រង់ត្រាស់ឡើងហើយក្នុងកប្បនេះ ។ ព្រះអង្គមិនមានធម៌នាំឲ្យយឺតយូរ មិនជាប់ការប្រាណ៍ ទ្រង់មានព្រះហឫទ័យស្មើអាកាស ព្រះអង្គច្រើនទៅដោយធម៌ដ៏សូន្យចាកកិលេស ព្រះអង្គមិនញាប់ញ័រ ដោយលោកធម៌ ទ្រង់ត្រេកអរក្នុងអនិមិត្ត គង់នៅហើយ ។ ព្រះអង្គមានព្រះហឫទ័យមិនជាប់ជំពាក់ មិនមានកិលេសជាគ្រឿងលាប មិនច្របូកច្របល់ ក្នុងត្រកូលនិងក្នុងគណៈ ព្រះអង្គជាអ្នកប្រាជ្ញ ប្រកបដោយករុណាដ៏ធំ ទ្រង់ឈ្លាសវៃក្នុងឧបាយ ជាគ្រឿងណែនាំ ។ ព្រះអង្គប្រកបក្នុងកិច្ចរបស់បុគ្គលដទៃ [illegible]នូវពួកមនុស្ស ព្រមទាំងទេវតា ឲ្យទៅកាន់ផ្លូវជាទីទៅកាន់ព្រះនិព្វាន ជាគ្រឿងញុំាងកក់ក្តៅឲ្យរីងស្ងួត ។

អមតំ បាបយិស្សាមិ ជាតិមរណភញ្ជនំ

មហាបរិសមជ្ឈេ សោ និសិន្នោ លោកតារណោ ។

ការវីករុតោ នាថោ ព្រហ្មឃោសោ តថាគតោ

ឧទ្ធរន្តោ មហាទុគ្គា(១) វិប្បនដ្ឋេ អនាយកេ ។

ទេសេន្តោ វិរជំ ធម្មំ ទិដ្ឋោ មេ លោកនាយកោ

តស្ស ធម្មំ សុណិត្វាន(២) បព្វជឹ អនគារិយំ ។

បព្វជិត្វា តទាហំ ចិន្តេន្តោ ជិនសាសនំ

ឯកកោវ វនេ រម្មេ(៣) វសឹ សំសគ្គបីឡិតោ ។

សកាយវូបកាសោ មេ(៤) ហេតុភូតោ មមាភវិ

មនសោ វូបកាសស្ស(៥) សំសគ្គភយទស្សិនោ ។

---

១ ឱ. ម. មហាទុគ្គ ។ ២ ឱ. ម. សុណិត្វាហំ ។ ៣ ឱ. ឯកកោ បវនេ រម្មេ ។
៤ ឱ. សកាយា វូបកាសោ មេ ។ ៥ ឱ. វូបកាសស្ស ។



ព្រះអង្គជាអ្នកចម្លងសត្វលោក ទ្រង់គង់ក្នុងកណ្ដាល នៃបរិសទ្យធំ ( ទ្រង់សំដែង ) ឲ្យអមតៈ គឺព្រះនិព្វាន ដែលជាគ្រឿងក្រេកអរហើនក្រៃលែង ជាគ្រឿងកំចាត់ ជាតិនិងមរណៈបាន ។ ព្រះតថាគត ទ្រង់ជាទីពឹងនៃសត្វលោក ព្រះអង្គមានសំឡេងដូចសត្វការវិក មានសំឡេងគឹកកង ប្រៀបសំឡេងនៃព្រហ្ម ទ្រង់ស្រោចស្រង់ពួកសត្វ ដែលដល់ហើយនូវសេចក្ដីវិនាស មិនមានអ្នកដឹកនាំព្រះអង្គឲ្យរួចចាកទុក្ខធំ ។ ព្រះអង្គជានាយកនៃសត្វលោក ទ្រង់សំដែងធម៌ដ៏ប្រាសចាកធូលី ខ្ញុំបានឃើញហើយ តាំងបានស្ដាប់ធម៌របស់ព្រះអង្គ ហើយចូលទៅកាន់ផ្នួស ។ លុះខ្ញុំបួសស្រេចហើយ ក៏ប្រឹងយកចិត្តទុកដាក់ នឹងសាសនានៃព្រះជិនស្រី ត្រូវសេចក្ដីជាប់ចំពាក់បៀតបៀន ក៏នៅក្នុងព្រៃជាទីរីករាយតែម្នាក់ឯង ។ ការចេញចាកពួក ដោយកាយរបស់ខ្លួននៃខ្ញុំ ជាហេតុនៃការចេញចាកពួកដោយចិត្តនៃខ្ញុំ ដែលជាអ្នកឃើញភ័យ ក្នុងការជាប់ចំពាក់ ក៏មានមកដល់ខ្ញុំ ។

កិលេសា ឈាបិតា មយ្ហំ ភវា សព្វេ សមូហតា

នាគោវ ពន្ធំ ឆេត្វា វិហរាមិ អនាសវោ ។

ស្វាគតំ វត មេ អាសិ មម ពុទ្ធស្ស សន្តិកេ

តិស្សោ វិជ្ជា អនុប្បត្តា កតំ ពុទ្ធស្ស សាសនំ ។

បដិសម្ភិទា ចតស្សោ វិមោក្ខាបិ ច អដ្ឋិមេ

ឆឡភិញ្ញា សច្ឆិកតា កតំ ពុទ្ធស្ស សាសនន្តិ ។

ឥត្ថំ សុទំ អាយស្មា ឯកវិហារិយោ(១) ថេរោ គាថាយោ

អភាសិត្ថាតិ ។

ឯកវិហារិយត្ថេរគាថា និដ្ឋិតា ។

(១) ឯកវិហារិ ។





កិលេសទាំងឡាយ ខ្ញុំដុតចោលហើយ ភពទាំងអស់ ខ្ញុំ
គាស់រំលើងចោលហើយ ខ្ញុំជាអ្នកមិនមានអាសវៈ ដូចដំរី
ដ៏ប្រសើរ ផ្តាច់នូវចំណង ។ ឱ! ដំណើរដែលខ្ញុំមក ក្នុង
សំណាក់នៃព្រះពុទ្ធរបស់ខ្ញុំ ជាដំណើរល្អហ្ន៎ វិជ្ជា ៣ ខ្ញុំបាន
ដល់ហើយ សាសនា របស់ព្រះពុទ្ធ ខ្ញុំបានធ្វើហើយ ។
បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យ
ជាក់ច្បាស់ហើយ ទាំងសាសនា របស់ព្រះពុទ្ធ ខ្ញុំក៏បាន
ប្រតិបត្តិហើយ ។

បានឮថា ព្រះឯកវិហារិយត្ថេរ មានអាយុ បានសំដែងនូវគាថា
ទាំងនេះ ដោយប្រការដូច្នេះ ។

ចប់ ឯកវិហារិយត្ថេរគាថា ។

## ទុតិយំ ឯកសង្ខិយត្ថេរាបទានំ

(៤៤) វិបស្សិនោ ភគវតោ មហាពោធិមហោ អហុ

មហាជនា សមាគម្ម បូជេន្តិ ពោធិមុត្តមំ ។

មហាសោកាករហិតោ បញ្ញោ(១) ពុទ្ធសេដ្ឋោ ករិស្សតិ

យស្សាយំ ឦទិសោ(២) ពោធិ បូជនីយោ សទ្ធោ ។

តទា សង្ខំ គហេត្វាន ពោធិរុក្ខំ ឧបដ្ឋហិំ

ធមេន្តោ សព្វទិវសំ អវន្ទិំ ពោធិមុត្តមំ ។

អាសន្នគេ កតំ កម្មំ ទេវលោកំ អបាបយិំ

កឡេវរំ មេ បតិតំ ទេវលោកេ រមាមហំ ។

សដ្ឋិ កប្បសហស្សម្ហិ [illegible]

សទា មយ្ហំ ឧបដ្ឋន្តិ ពុទ្ធបូជាយិទំ ផលំ ។

---

១ ឱ. ម. ឱ ហៅថា បញ្ញោ ។ ២ ឱ. ឯទិសោ ។



## ឯកសង្ខិយត្ថេរាបទាន ទី ២

(៤៤) មានពិធីធ្វើដើមពោធិព្រឹក្ស របស់ព្រះមានព្រះភាគ ព្រះនាមវិបស្សី មហាជនមកជួបជុំគ្នាបូជាដើមពោធិព្រឹក្សដ៏ឧត្តម ។ ដើមពោធិព្រឹក្សប្រាកដដូច្នេះ របស់ព្រះសាស្តាអង្គណា ដែលជនតាំងព្យាយាមបូជា ព្រះសាស្តាអង្គនោះ ជាព្រះសម្ពុទ្ធដ៏ប្រសើរ ទ្រង់មានប្រាជ្ញា ព្រះអង្គប្រាសចាកសេចក្តីសោកដ៏ធំ ។ សម័យនោះ ខ្ញុំកាន់ស័ង្ខចូលទៅបម្រើពោធិព្រឹក្ស ខ្ញុំផ្លុំស័ង្ខហើយថ្វាយបង្គំពោធិព្រឹក្សដ៏ឧត្តម រាល់ៗថ្ងៃ ។ កុសលកម្មដែលខ្ញុំធ្វើហើយក្នុងទីជិត ខ្ញុំក៏បានទៅកើតក្នុងទេវលោក សាកសព ខ្ញុំទម្លាក់ចោលហើយ ខ្ញុំត្រេកអរក្នុងទេវលោក ។ ខ្ញុំកើតក្នុងត្រកូល ស្រស់ស្រាយរីករាយអស់ ៦ ម៉ឺន កប្បត្រូវ នោះតែងបម្រើខ្ញុំ សព្វ ១ កាល នេះជាផលនៃការបូជា ។

ឯកសត្តតិតោ កប្បេ  រាជា អាសិ សុទស្សនោ
ចាតុរន្តោ វិជិតាវី  ជម្ពុមណ្ឌស្ស(១) ឥស្សរោ ។
តតោ អដ្ឋសតា(២) តុរិយា  បរិវេន្តិ មំ សទា
អនុភោមិ សកំ កម្មំ  ឧបដ្ឋានស្សិទំ ផលំ ។
យំ យំ យោនូបបជ្ជាមិ  ទេវត្តំ អថ មានុសំ
មាតុកុច្ឆិគតស្សាបិ  វជ្ជរេ ភេរិយោ សទា ។
ឧបដ្ឋិត្វាន(៣) សម្ពុទ្ធំ  អនុភោត្វាន សម្បទា
សិវំ អមលំ អមរំ(៤)  បត្តោម្ហិ អចលំ បទំ ។
ឯកនវុតេ ឥតោ កប្បេ  យំ កម្មមករិំ តទា
ទុគ្គតិំ នាភិជានាមិ  តូរិយស្សិទំ ផលំ ។
កិលេសា ឈាបិតា មយ្ហំ  ភវា សព្វេ សមូហតា
នាគោវ ពន្ធនំ ឆេត្វា  វិហរាមិ អនាសវោ ។

---

១ ឱ. ជម្ពុសណ្ឌស្ស ។ ម. ជម្ពុមណ្ឌស្ស ។ ២ ឱ. អដ្ឋសតា តុរិយា ។ ម. អដ្ឋសតា ភូរា ។
៣ ម. ឧបដ្ឋិត្វា ។ ៤ ឱ. ម. សិវំ សុខទំ អមតំ ។



ក្នុងកប្បទី ៧១ ខ្ញុំបានកើតជាស្តេចព្រះនាមសុទស្សនៈ ជាអ្នកឈ្នះសង្គ្រាម មានសមុទ្រទាំង ៤ ជាព្រំប្រទល់ ជាឥស្សរៈក្នុងជម្ពូទ្វីប ។ សំណាក់នោះ តូរ្យតន្ត្រី ៨០០ តែងហោមរោមខ្ញុំ សព្វ ១ កាល ខ្ញុំបានទទួលផលនៃកុសលកម្មរបស់ខ្លួន នេះជាផលនៃការបម្រើ ។ ខ្ញុំកើតក្នុងកំណើតណា ១ គឺ ជាទេវតា ឬជាមនុស្ស កាលដែលខ្ញុំឋិតនៅក្នុងផ្ទៃនៃមាតា ស្គរទាំងឡាយ តែងប្រគំ សព្វ ១ កាល ។ ព្រោះខ្ញុំបម្រើនូវព្រះសម្ពុទ្ធ ទើបបានសម្បត្តិទាំងឡាយ ហើយដល់នូវព្រះនិព្វាន ជាបទដ៏ក្សេម មិនមានមន្ទិល មិនចេះស្លាប់ មិនកម្រើក ។ ក្នុងកប្បទី ៩១ អំពីកប្បនេះ ព្រោះហេតុដែលខ្ញុំបានធ្វើនូវកុសលកម្ម ក្នុងកាលនោះ ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃតូរ្យបូជា ។ កិលេសទាំងឡាយ ខ្ញុំដុតបំផ្លាញហើយ ភពទាំងអស់ ខ្ញុំគាស់រំលើងចោលហើយ ខ្ញុំជាអ្នកមិនមានអាសវៈ ដូចជាដំរីដ៏ប្រសើរផ្តាច់នូវចំណង ។

ស្វាគតំ វត មេ អាសិ មម ពុទ្ធស្ស សន្តិកេ
តិស្សោ វិជ្ជា អនុប្បត្តា កតំ ពុទ្ធស្ស សាសនំ ។
បដិសម្ភិទា ចតស្សោ វិមោក្ខាបិ ច អដ្ឋិមេ
ឆឡភិញ្ញា សច្ឆិកតា កតំ ពុទ្ធស្ស សាសនន្តិ ។

ឥត្ថំ សុទំ អាយស្មា ឯកសញ្ញិយោ ថេរោ ឥមា គាថាយោ អភាសិត្ថាតិ ។

ឯកសញ្ញិយត្ថេរស្ស អបទានំ សមត្តំ ។

## តតិយំ បាដិហីរសញ្ញកត្ថេរាបទានំ

(២៣) បទុមុត្តរោ នាម ជិនោ អាហុតីនំ បដិគ្គហោ
វសីសតសហស្សេហិ នគរំ បាវិសី តទា ។
នគរំ បវិសន្តស្ស ឧបសន្តស្ស តាទិនោ
រតនា បជ្ជលន្តិស្សុ(១) និគ្ឃោសោ អាសិ តាវទេ ។

១ ម. រតនានិ បជ្ជលីសុ ។ ឱ. រតនានិ បជ្ជោតីសុ ។



ឱ! ដំណើរដែលខ្ញុំមក ក្នុងសំណាក់នៃព្រះពុទ្ធរបស់ខ្ញុំ ជាដំណើរល្អហ្ន៎ វិជ្ជា ៣ ខ្ញុំបានដល់ហើយ សាសនា របស់ព្រះពុទ្ធ ខ្ញុំបានធ្វើហើយ ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ។

បានឮថា ព្រះឯកសញ្ញិយត្ថេរ មានអាយុ បានសម្ដែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

ចប់ ឯកសញ្ញិយត្ថេរាបទាន ។

## បាដិហីរសញ្ញកត្ថេរាបទាន ទី ៣

(២៣) ព្រះជិនស្រីព្រះនាមបទុមុត្តរៈ ទ្រង់គួរទទួលគ្រឿងបូជា ក្នុងកាលនោះ ព្រះអង្គស្ដេចចូលទៅក្នុងនគរ មួយអន្លើដោយភិក្ខុមួយសែនអង្គ សុទ្ធតែជាអ្នកស្ទាត់ស្ទាញ ។ កាលព្រះសម្ពុទ្ធ ទ្រង់មានព្រះហឫទ័យស្ងប់រម្ងាប់ មិនញាប់ញ័រដោយលោកធម៌ ស្ដេចចូលទៅក្នុងនគរ ក្នុងខណៈនោះ មានសំឡេងកងរំពង ក្នុងការក្រោកទទួល គ្រឿងប្រដាប់ ។

### តតិយំ បាដិហីរសញ្ញកត្ថេរាបទានំ

ពុទ្ធស្ស អាគតកាលេ អាវជ្ជិតបក្ខិកា(១)
សយំ វីណា បវជ្ជិំសុ ពុទ្ធស្ស បវិសតោ បុរំ ។
ពុទ្ធសេដ្ឋំ នមស្សាមិ បទុមុត្តរំ មហាមុនឹ
បាដិហីរញ្ច បស្សិត្វា តត្ថ ចិត្តំ បសាទយឹ ។
អហោ ពុទ្ធោ អហោ ធម្មោ អហោ នោ សត្ថុសម្បទា
អចេតនាបិ តុរិយា សយមេវ បវជ្ជរេ ។
សតសហស្សេតោ កប្បេ យំ សញ្ញមលភឹ តទា
ទុគ្គតឹ នាភិជានាមិ ពុទ្ធសញ្ញាយិទំ ផលំ ។
កិលេសា ឈាបិតា មយ្ហំ ភវា សព្វេ សមូហតា
នាគោវ ពន្ធនំ ឆេត្វា វិហរាមិ អនាសវោ ។

១ ម. អាវជ្ជិតបក្ខិកា ។ ឧ. អាវជ្ជិតបក្ខិកា ។



### បាដិហីរសញ្ញកត្ថេរាបទាន ទី ៣

ក្នុងកាលនោះ ព្រះសម្ពុទ្ធស្ដេចចូលទៅក្នុងបុរី ពិណទាំងឡាយបុគ្គលឥតប្រគំឥតវាយឡើយ ក៏ស្រាប់តែប្រគំដោយខ្លួនឯង ដោយអានុភាពនៃព្រះពុទ្ធ ។ ខ្ញុំក៏នមស្ការនូវព្រះពុទ្ធដ៏ប្រសើរ ព្រះនាមបទុមុត្តរៈ ជាអ្នកប្រាជ្ញធំផង ឃើញនូវបាដិហារ្យ ហើយញុំាងចិត្តឲ្យជ្រះថ្លា ក្នុងបាដិហារ្យនោះផងថា ឱ! ព្រះពុទ្ធ ឱ! ព្រះធម៌ ឱ! សម្បទានៃព្រះសាស្ដា របស់យើងទាំងឡាយ តូរ្យតន្ត្រីទាំងឡាយ សូម្បីឥតចេតនាសោះ ក៏បែរជាប្រគំដោយខ្លួនឯង ។ ក្នុងកប្បមួយសែន អំពីកប្បនេះ ព្រោះហេតុដែលខ្ញុំបាននូវសញ្ញា ក្នុងកាលនោះ ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃសេចក្ដីសំគាល់ក្នុងព្រះសម្ពុទ្ធ ។ កិលេសទាំងឡាយ ខ្ញុំបានដុតបំផ្លាញហើយ ភពទាំងពួង ខ្ញុំគាស់រំលើងចោលហើយ ខ្ញុំជាអ្នកមិនមានអាសវៈ ដូចជាដំរីដ៏ប្រសើរផ្ដាច់នូវទន្លីង ។

ស្វាគតំ វត មេ អាសិ មម ពុទ្ធស្ស សន្តិកេ
តិស្សោ វិជ្ជា អនុប្បត្តា កតំ ពុទ្ធស្ស សាសនំ ។
បដិសម្ភិទា ចតស្សោ វិមោក្ខាបិ ច អដ្ឋិមេ
ឆឡភិញ្ញា សច្ឆិកតា កតំ ពុទ្ធស្ស សាសនន្តិ ។

ឥត្ថំ សុទំ អាយស្មា ជាតិបូជកោ ថេរោ ឥមា គាថាយោ អភាសិត្ថាតិ ។

ជាតិបូជកត្ថេរស្ស អបទានំ សមត្តំ ។

## បត្តំ ញាណត្ថវិកត្ថេរាបទានំ

(៦៤) កណិការំវ ជលិតំ ទីបរុក្ខំវ ជោតិតំ
កញ្ចនំវ វិរោចន្តំ អទ្ទសំ ទិបទុត្តមំ ។



ៗ។ ដំណើរដែលខ្ញុំមក ក្នុងសំណាក់នៃព្រះពុទ្ធរបស់ខ្ញុំ ជាដំណើរល្អពិត វិជ្ជា ៣ ខ្ញុំបានដល់ហើយ សាសនា របស់ព្រះពុទ្ធ ខ្ញុំបានធ្វើហើយ ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ។

បានឮថា ព្រះជាតិបូជកត្ថេរ មានអាយុ បានសម្តែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

ចប់ ជាតិបូជកត្ថេរាបទាន ។

## ញាណត្ថវិកត្ថេរាបទាន ទី ៤

(៤៤) ខ្ញុំឃើញព្រះសម្ពុទ្ធ ទ្រង់ឧត្តមជាងសត្វជើងពីរ ទ្រង់រុងរឿងដូចផ្កាកណិការ ឬដូចដើមទីបព្រឹក្ស ដ៏ភ្លឺព្រោងព្រាត រុងរោចន៍ ដូចជាមាសក្តីនាលប្រាលះឆ្ពៅ ។

តាមណ្ឌលំ បបេត្វាន    ភកាសំញ្ញ គុណ្ណាតំ
ឃតាំសំ អតិធំ គាត្វា    ពុទ្ធសេដ្ឋំ ជរំ អហំ ។
តមច្ឆកាំ វិជមំ    មោហជាលសមាគុលំ
ញាណាលោកំ ឧសរ្ឋយិត្វា    តិលេណ្ណា(១) អសិ តុរំ មុនិ ។
សមុទ្ទរសំមិ លោកំ    សញ្ញាវត្ថិ អនុត្តរំ
ញាណេន(២) តេ ឧបមានត្ថិ    យាវតា ជគតោ គតិ ។
តេន ញាណេន សព្វញ្ញូ    សព្វញ្ញូតិ(៣) បវុច្ចតិ
វន្ទាមិ តំ មហាវីរំ    សព្វញ្ញុំ អបរាសរំ ។
សតសហស្សតោ តាបេ្យ    ពុទ្ធសេដ្ឋំ ជរំ អហំ
ឧក្កដ្ឋំ ពាកិជាពាមំ    ញាណត្ថមពាយិតំ(៤) នលិំ ។

១ ឱ. ញាណលោកំ ទស្សយិត្វា និតិណ្ណោ   ម. ញាណាលោកំ ទស្សេត្វាន តតិណ្ណោ ។
២ ឱ ប. ញាណោ ។ ៣ ឱ ឥតិ ភោត្ត ។   ៤ ឱ ញាណត្ថវិតាយិទំ ។ ម ញាណត្ថវិយំ ។



ខ្ញុំគាស់ទុកនូវដងរែក សំពត់សម្បកឈើនិងក្អមទឹក ហើយធ្វើសំពត់ស្បែកខ្លាធៀនស្មាខាង ពោលសរសើរនូវព្រះពុទ្ធដ៏ប្រសើរថា បពិត្រព្រះមហាមុនី ព្រះអង្គទ្រង់កំចាត់បង់នូវងងឹតអន្ធការ ដ៏ដេរដាសដោយបណ្ដាញ គឺមោហៈ ទ្រង់សម្ដែងនូវពន្លឺគឺញាណ ព្រះអង្គទ្រង់ឆ្លងទុក្ខផុតហើយ ព្រះអង្គទ្រង់ស្រោចស្រង់នូវលោកទាំងអស់នេះ ដែលមិនទាន់រើខ្លួនរួច ដំណើរនៃផែនដីមានកំណត់ត្រឹមណា សេចក្ដីប្រៀបផ្ទឹម ដោយញាណរបស់ព្រះអង្គ មិនមានកំណត់ត្រឹមនោះឡើយ ។ ព្រះសម្ពុទ្ធ ដែលអ្នកប្រាជ្ញទាំងឡាយហៅថាសព្វញ្ញូ សព្វញ្ញូ ព្រោះញាណនោះ ខ្ញុំសូមថ្វាយបង្គំនូវព្រះសព្វញ្ញូអង្គនោះ ដែលមានព្យាយាមធំ ទាំងមិនមានអាសវៈ ។ ក្នុងកប្បទីមួយសែន អំពីកប្បនេះ ព្រោះហេតុដែលខ្ញុំពោលសរសើរនូវព្រះសម្ពុទ្ធដ៏ប្រសើរ ក្នុងកាលនោះ ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃសេចក្ដីសរសើរនូវព្រះញាណ ។

កិលេសា ឈាបិតា មយ្ហំ　ភវា សព្វេ សមូហតា
នាគោវ ពន្ធនំ ឆេត្វា　វិហរាមិ អនាសវោ ។
ស្វាគតំ វត មេ អាសិ　មម ពុទ្ធស្ស សន្តិកេ
តិស្សោ វិជ្ជា អនុប្បត្តា　កតំ ពុទ្ធស្ស សាសនំ ។
បដិសម្ភិទា ចតស្សោ　វិមោក្ខាបិច អដ្ឋិមេ
ឆឡភិញ្ញា សច្ឆិកតា　កតំ ពុទ្ធស្ស សាសនន្តិ ។

ឥត្ថំ សុទំ អាយស្មា ញាណត្ថវិកោ ថេរោ ឥមា គាថាយោ អភាសិត្ថាតិ ។

ញាណត្ថវិកត្ថេរស្ស អបទានំ សមត្តំ ។

## បញ្ចមំ ឧច្ឆុខណ្ឌិកត្ថេរាបទានំ

(៤៨) នគរេ ពន្ធុមតិយា　ទ្វារបាលោ អហោសហំ
អទ្ទសំ វិរជំ ពុទ្ធំ　សព្វធម្មាន បារគុំ ។
ឧច្ឆុខណ្ឌិកមាទាយ　ពុទ្ធសេដ្ឋស្សទាសហំ
បសន្នចិត្តោ សុមនោ　វិបស្សិស្ស មហេសិនោ ។





កិលេសទាំងឡាយ ខ្ញុំដុតកំទេចហើយ ភពទាំងអស់ ខ្ញុំគាស់រំលើងហើយ ខ្ញុំជាអ្នកមិនមានអាសវៈ ដូចជាដំរីប្រសើរកាត់ផ្តាច់នូវចំណង ។ ឱ! ដំណើរដែលខ្ញុំមកក្នុងសំណាក់នៃព្រះពុទ្ធរបស់ខ្ញុំ ជាដំណើរល្អហ្ន៎ វិជ្ជា ៣ ខ្ញុំបានដល់ហើយ សាសនា របស់ព្រះពុទ្ធ ខ្ញុំបានធ្វើហើយ ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនា របស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិរួចហើយ ។

បានឮថា ព្រះញាណត្ថវិកត្ថេរ មានអាយុ បានសម្តែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

ចប់ ញាណត្ថវិកត្ថេរាបទាន ។

## ឧច្ឆុខណ្ឌិកត្ថេរាបទាន ទី ៥

(៤៨) ខ្ញុំកើតជាអ្នកឆ្មាំទ្វារ ក្នុងនគរពន្ធុមតី បានឃើញព្រះពុទ្ធ ព្រះអង្គមានធូលីទៅប្រាសហើយ ទ្រង់ដល់នូវត្រើយនៃធម៌ទាំងពួង ។ ខ្ញុំមានចិត្តជ្រះថ្លា មានចិត្តត្រេកអរ បានយកអំពៅមួយកំណាត់ ទៅថ្វាយព្រះពុទ្ធដ៏ប្រសើរ ព្រះនាមវិបស្សី ព្រះអង្គជាអ្នកស្វែងរកនូវគុណដ៏ធំ ។

បញ្ចមំ ឧច្ឆុខណ្ឌិកត្ថេរាបទានំ

ឯកនវុតេ ឥតោ កប្បេ យំ ឧច្ឆុមទទឹ តទា
ទុគ្គតឹ នាភិជានាមិ ឧច្ឆុខណ្ឌស្សិទំ ផលំ ។
កិលេសា ឈាបិតា មយ្ហំ ភវា សព្វេ សមូហតា
នាគោវ ពន្ធនំ ឆេត្វា វិហរាមិ អនាសវោ ។
ស្វាគតំ វត មេ អាសិ មម ពុទ្ធស្ស សន្តិកេ
តិស្សោ វិជ្ជា អនុប្បត្តា កតំ ពុទ្ធស្ស សាសនំ ។
បដិសម្ភិទា ចតស្សោ វិមោក្ខាបិច អដ្ឋិមេ
ឆឡភិញ្ញា សច្ឆិកតា កតំ ពុទ្ធស្ស សាសនំ ។

ឥត្ថំ សុទំ អាយស្មា ឧច្ឆុខណ្ឌិកោ ថេរោ ឥមា គាថាយោ អភាសិត្ថាតិ ។

ឧច្ឆុខណ្ឌិកត្ថេរស្ស អបទានំ សមត្តំ ។



ឧច្ឆុខណ្ឌិកត្ថេរាបទាន ទី ៥

ក្នុងកប្បទី ៩១ អំពីកប្បនេះ ព្រោះហេតុដែលខ្ញុំបានថ្វាយអំពៅ ក្នុងកាលនោះ ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃអំពៅមួយកំណាត់ ។ កិលេសទាំងឡាយ ខ្ញុំដុតបំផ្លាញហើយ ភពទាំងអស់ ខ្ញុំបានគាស់រំលើងហើយ ខ្ញុំជាបុគ្គលមិនមានអាសវៈ ដូចជាដំរីប្រសើរ កាត់ផ្តាច់ទន្លីងទន្លីង ។ ឱ ! ដំណើរដែលខ្ញុំមក ក្នុងសំណាក់នៃព្រះពុទ្ធរបស់ខ្ញុំ ជាដំណើរល្អហ្ន៎ វិជ្ជា ៣ ខ្ញុំបានដល់ហើយ សាសនា របស់ព្រះពុទ្ធ ខ្ញុំក៏បានធ្វើហើយ ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនា របស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ។

បានឮថា ព្រះឧច្ឆុខណ្ឌិកត្ថេរ មានអាយុ បានសំដែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

ចប់ ឧច្ឆុខណ្ឌិកត្ថេរាបទាន ។

# ឆដ្ឋំ កលម្ពទាយកត្ថេរាបទានំ

(៥៦) រោមសោ នាម សម្ពុទ្ធោ វសតិ បព្វតន្តរេ

កលម្ពំ តស្ស បាទាសឹ បសន្នោ សេហិ បាណិភិ ។

ចតុន្នវុតេ ឥតោ កប្បេ យំ ទានមទទឹ តទា

ទុគ្គតឹ នាភិជានាមិ កលម្ពស្ស ឥទំ ផលំ ។

កិលេសា ឈាបិតា មយ្ហំ ភវា សព្វេ សមូហតា

នាគោវ ពន្ធនំ ឆេត្វា វិហរាមិ អនាសវោ ។

ស្វាគតំ វត មេ អាសិ មម ពុទ្ធស្ស សន្តិកេ

តិស្សោ វិជ្ជា អនុប្បត្តា កតំ ពុទ្ធស្ស សាសនំ ។

បដិសម្ភិទា ចតស្សោ វិមោក្ខាបិច អដ្ឋិមេ

ឆឡភិញ្ញា សច្ឆិកតា កតំ ពុទ្ធស្ស សាសនំ ។

ឥត្ថំ សុទំ អាយស្មា កលម្ពទាយកោ ថេរោ ឥមា គាថាយោ អភាសិត្ថាតិ ។

កលម្ពទាយកត្ថេរស្ស អបទានំ សមត្តំ ។





# កលម្ពទាយកត្ថេរាបទាន ទី ៦

(៥៦) ព្រះសម្ពុទ្ធ ព្រះនាមរោមសៈ គង់នៅក្នុងចន្លោះភ្នំ ខ្ញុំមានចិត្តជ្រះថ្លា បានថ្វាយដំឡូងដូង ដល់ព្រះសម្ពុទ្ធអង្គនោះ ដោយដៃនៃខ្លួន ។ ក្នុងកប្បទី ៩៤ អំពីកប្បនេះ ព្រោះហេតុដែលខ្ញុំបានថ្វាយទាន ក្នុងកាលនោះ ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃដំឡូងដូង ។ កិលេសទាំងឡាយ ខ្ញុំដុតបំផ្លាញហើយ ភពទាំងអស់ ខ្ញុំបានគាស់រំលើងហើយ ខ្ញុំជាបុគ្គលមិនមានអាសវៈ ដូចជាដំរីប្រសើរកាត់ផ្តាច់ទន្លីង ។ ឱ! ដំណើរដែលខ្ញុំមក ក្នុងសំណាក់នៃព្រះពុទ្ធរបស់ខ្ញុំ ជាដំណើរល្អហ្ន៎ វិជ្ជា ៣ ខ្ញុំបានដល់ហើយ សាសនា របស់ព្រះពុទ្ធ ខ្ញុំបានធ្វើហើយ ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនា របស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ។

បានឮថា ព្រះកលម្ពទាយកត្ថេរ មានអាយុ បានសម្តែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

ចប់ កលម្ពទាយកត្ថេរាបទាន ។

## សត្តមំ អម្ពាដកទាយកត្ថេរាបទានំ

[៦៧] បវនេ(១) ពុទ្ធំ ទិស្វាន សយម្ភុំ អបរាជិតំ
អម្ពាដកំ គហេត្វាន សយម្ភុស្ស អទាសហំ ។
ឯកត្តឹសេ ឥតោ កប្បេ យំ ផលំ អទទឹ តទា
ទុគ្គតឹ នាភិជានាមិ ផលទានស្សិទំ ផលំ ។
កិលេសា ឈាបិតា មយ្ហំ ភវា សព្វេ សមូហតា
នាគោវ ពន្ធនំ ឆេត្វា វិហរាមិ អនាសវោ ។
ស្វាគតំ វត មេ អាសិ មម ពុទ្ធស្ស សន្តិកេ
តិស្សោ វិជ្ជា អនុប្បត្តា កតំ ពុទ្ធស្ស សាសនំ ។
បដិសម្ភិទា ចតស្សោ វិមោក្ខាបិ ច អដ្ឋិមេ
ឆឡភិញ្ញា សច្ឆិកតា កតំ ពុទ្ធស្ស សាសនន្តិ ។

ឥត្ថំ សុទំ អាយស្មា អម្ពាដកទាយកោ ថេរោ ឥមា គាថាយោ អភាសិត្ថាតិ ។

អម្ពាដកទាយកត្ថេរស្ស អបទានំ សត្តមំ ។

---

១ ម. វិបិនេតិ ទិស្សតិ ។

## អម្ពាដកទាយកត្ថេរាបទានទី ៧

[៦៧] ខ្ញុំបានឃើញព្រះសម្ពុទ្ធ ជាព្រះសយម្ភូ គង់នៅក្នុងព្រៃធំ ព្រះអង្គទ្រង់ឈ្នះកិលេសមារ ហើយយកផ្លែម្កាក់ទៅថ្វាយព្រះសយម្ភូ ។ ក្នុងកប្បទី ៣១ អំពីកប្បនេះ ព្រោះហេតុដែលខ្ញុំ បានថ្វាយផ្លែម្កាក់ ក្នុងកាលនោះ ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃការថ្វាយផ្លែម្កាក់ ។ កិលេសទាំងឡាយ ខ្ញុំដុតបំផ្លាញហើយ ភពទាំងអស់ ខ្ញុំបានគាស់រំលើងហើយ ខ្ញុំជាបុគ្គលមិនមានអាសវៈ ដូចជាដំរីប្រសើរកាត់ផ្តាច់ខ្សែចំណង ។ ឱ! ដំណើរដែលខ្ញុំមក ក្នុងសំណាក់នៃព្រះពុទ្ធរបស់ខ្ញុំ ជាដំណើរល្អហើយ វិជ្ជា ៣ ខ្ញុំបានដល់ហើយ សាសនារបស់ព្រះពុទ្ធ ខ្ញុំបានធ្វើហើយ ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនា របស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ។

បានឮថា ព្រះអម្ពាដកទាយកត្ថេរ មានអាយុ បានសំដែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

ចប់ អម្ពាដកទាយកត្ថេរាបទាន ។

## អដ្ឋមំ ហរីតកិទាយកត្ថេរាបទានំ

(៤៨) ហរីតកី(១) អាមលកំ អម្ពជម្ពុវិភីតកំ

កោលំ ភល្លាតកំ ពេល្លំ សយមេវាហរាមហំ ។

ទិស្វាន បព្ភារគតំ ឈាយឹ ឈានរតំ មុនឹ

អាពាធេន អាបីឡិតំ អទុតិយំ(២) មហាមុនឹ ។

ហរីតកឹ គហេត្វាន សយម្ភុស្ស អទាសហំ

ខាទមត្តម្ហិ ភេសជ្ជំ(៣) ព្យាធិ បស្សម្ភិ តាវទេ ។

បហីនទរថោ ពុទ្ធោ អនុមោទនិយំ អកា(៤)

ភេសជ្ជទានេនិមិនា ព្យាធិវូបសមេន ច ។

ទេវភូតោ មនុស្សោ វា ជាតោ វា អញ្ញជាតិយា

សព្វត្ថ សុខិតោ ហោហិ មា ច តេ ព្យាធិមាគមា ។

---

១ ឱ. ហរីតកំ ។ ២ ឱ. បបីឡិតំ អទុតិយំ ។ ម. អាបីឡិតំ អទុតិយំ ។ ៣ ឱ.ម. ខាទមត្តម្ហិ ភេសជ្ជេ ។ ៤ ម. អនុមោទមកាសិ វេ ។





## ហរីតកិទាយកត្ថេរាបទាន ទី ៨

(៤៨) ខ្ញុំកំពុងតែនាំយក នូវផ្លែសម៉ ផ្លែកន្ទួតព្រៃ ផ្លែស្វាយ ផ្លែព្រីង ផ្លែសម៉ាភេទក៍ ផ្លែពុទ្រា ផ្លែក្រខុប និងផ្លែព្នៅ ដោយខ្លួនឯង ។ ខ្ញុំបានឃើញព្រះសម្ពុទ្ធ ជាអ្នកប្រាជ្ញ ព្រះអង្គគង់នៅក្នុងញកភ្នំ ទ្រង់មានឈាន ត្រេកអរក្នុងឈាន ជាមហាមុនីដ៏ឯក ដែលកំពុងត្រូវអាពាធបៀតបៀន ។ ខ្ញុំយកផ្លែសម៉ទៅថ្វាយព្រះសយម្ភូ ភេសជ្ជៈ គ្រាន់តែខ្ញុំធ្វើរួចហើយ ព្យាធិក៏ស្ងប់ក្នុងខណៈនោះភ្លាម ។ ព្រះសម្ពុទ្ធ ទ្រង់លះបង់សេចក្តីក្រវល់ក្រវាយ បានធ្វើអនុមោទនា ព្រោះភេសជ្ជទាននេះផង ព្រោះការរម្ងាប់នូវព្យាធិនេះផងថា អ្នកកើតជាទេវតាក្តី ជាមនុស្សក្តី ឬកើតក្នុងជាតិដទៃក្តី សូមឲ្យជាអ្នកដល់នូវសេចក្តីសុខ ក្នុងទីទាំងពួង មួយទៀត សូមកុំឲ្យព្យាធិកើតមានដល់អ្នកឡើយ ។

## អដ្ឋមំ ហរីតកិទាយកត្ថេរាបទានំ

ឥទំ វត្វាន សម្ពុទ្ធោ សយម្ភូ អបរាជិតោ
នភំ អព្ភុគ្គមិ ធីរោ ហំសរាជាវ អម្ពរេ ។
[illegible] ហរីតកិមទំ(១) សយម្ភុស្ស មហេសិនោ
[illegible] ព្យាធិ មេ នូបបជ្ជថ ។
អយំ បច្ឆិមកោ មយ្ហំ ចរិមោ វត្តតេ ភវោ
តិស្សោ វិជ្ជា អនុប្បត្តា កតំ ពុទ្ធស្ស សាសនំ ។
ចតុន្នវុតេ ឥតោ កប្បេ ភេសជ្ជមទទឹ តទា
ទុគ្គតឹ នាភិជានាមិ ភេសជ្ជស្ស ឥទំ ផលំ ។
កិលេសា ឈាបិតា មយ្ហំ ភវា សព្វេ សមូហតា
នាគោវ ពន្ធនំ ឆេត្វា វិហរាមិ អនាសវោ ។
ស្វាគតំ វត មេ អាសិ មម ពុទ្ធស្ស សន្តិកេ
តិស្សោ វិជ្ជា អនុប្បត្តា កតំ ពុទ្ធស្ស សាសនំ ។

១ ឧ. ហរីតកមទំ ។ ម. ហរីតកំ ទទំ ។



## ហរីតកីទាយកត្ថេរាបទាន ទី ៨

ព្រះសម្ពុទ្ធ ជាព្រះសយម្ភូ ទ្រង់ឈ្នះកិលេស ជាអ្នកប្រាជ្ញ លុះត្រាស់ពាក្យនេះហើយ ក៏ទ្រង់ហោះទៅឯអាកាស ដូចជាស្តេចហង្សដែលហើរទៅឰដ៏អាកាស ។ កាលដែលខ្ញុំបានថ្វាយផ្លែសម៉ៅដល់ព្រះសយម្ភូ ជាមហេសី ព្យាធិក៏មិនកើតឡើងដល់ខ្ញុំ ព្រោះហេតុជាតិនេះ ។ នេះកាន់កាយខាងក្រោយបំផុតរបស់ខ្ញុំ ភពខាងក្រោយ កំពុងប្រព្រឹត្តទៅ វិជ្ជា ៣ ខ្ញុំបានដល់ហើយ សាសនារបស់ព្រះពុទ្ធ ខ្ញុំបានធ្វើហើយ ។ ក្នុងកប្បទី ៩៤ អំពីកប្បនេះ ព្រោះហេតុដែលខ្ញុំបានថ្វាយភេសជ្ជៈ ក្នុងកាលនោះ ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃភេសជ្ជៈ ។ កិលេសទាំងឡាយ ខ្ញុំដុតបំផ្លាញហើយ ភពទាំងអស់ ខ្ញុំដកចោលហើយ ខ្ញុំជាបុគ្គលមិនមានអាសវៈ ដូចជាដំរីដ៏ប្រសើរកាត់ផ្តាច់ទន្ទីង ។ ៩ ។ ដំណើរដែលខ្ញុំមកក្នុងសំណាក់នៃព្រះពុទ្ធរបស់ខ្ញុំ ជាដំណើរល្អហ្ន៎ វិជ្ជា ៣ ខ្ញុំបានដល់ហើយ សាសនារបស់ព្រះពុទ្ធ ខ្ញុំបានធ្វើហើយ ។

បដិសម្ភិទា ចតស្សោ វិមោក្ខាបិ ច អដ្ឋិមេ
ឆឡាភិញ្ញា សច្ឆិកតា កតំ ពុទ្ធស្ស សាសនន្តិ ។
ឥត្ថំ សុទំ អាយស្មា មហាបរិវារកោ ថេរោ
ឥមា គាថាយោ អភាសិត្ថាតិ ។

មហាបរិវារកត្ថេរស្ស អបទានំ អដ្ឋមំ ។

## នវមំ អម្ពបិណ្ឌិយត្ថេរាបទានំ

(៦៩) ហត្ថីរាជា តទា អាសឹ ឦសាទន្តោ ឧរូឡ្ហវា(១)
វិចរន្តោ ព្រហារញ្ញេ អទ្ទសំ លោកនាយកំ ។
អម្ពបិណ្ឌី តតោ គយ្ហ អទាសឹ សត្ថុនោ អហំ
បដិគ្គណ្ហិ មហាវីរោ សម្ពុទ្ធោ លោកនាយកោ ។
មម និជ្ឈាយមានស្ស បរិភុញ្ជិ តទា ជិនោ
តត្ថ ចិត្តំ បសាទេត្វា តុសិតំ ឧបបជ្ជហំ ។
តតោ អហំ ចវិត្វាន ចក្កវត្តី អហោសហំ
ឯតេនេវ ឧបាយេន អនុភោត្វាន សម្បទា ។

១ ម. ឧរុឡ្ហា ។



បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនា របស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ។

បានឮថា ព្រះមហាបរិវារកត្ថេរ មានអាយុ បានសំដែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

ចប់ មហាបរិវារកត្ថេរាបទាន ។

## អម្ពបិណ្ឌិយត្ថេរាបទាន ទី ៩

(៦៩) កាលនោះ ខ្ញុំកើតជាស្តេចដំរី មានភ្លុកដ៏ទន្ទុំ មានកំឡាំងច្រើន កំពុងត្រាច់ទៅក្នុងព្រៃធំ ក៏បានឃើញព្រះបរមលោកនាយក ។ ខ្ញុំបានយកផ្លែស្វាយមួយចង្កោម ថ្វាយព្រះសាស្តា ឯព្រះសម្ពុទ្ធ ទ្រង់មានព្យាយាមធំ ជាលោកនាយក ទ្រង់បានទទួល ។ កាលនោះ ខ្ញុំកំពុងតែសំឡឹងមើល ព្រះជិនស្រីទ្រង់សោយហើយ ខ្ញុំក៏ញុំាងចិត្តឲ្យជ្រះថ្លា ចំពោះព្រះអង្គ ហើយបានទៅកើត ក្នុងឋានតុសិត ។ ខ្ញុំច្យុតចាកឋានតុសិតនោះមក បានជាស្តេចចក្រពត្តិ សោយនូវសម្បត្តិទាំងឡាយ ដោយឧបាយនុ៎ះឯង ។

នវមំ អម្ពបិណ្ឌិយត្ថេរាបទានំ

បធានំ បហិតត្តោហំ ឧបសន្តោ និរូបធិ
សព្វាសវេ បរិញ្ញាយ វិហរាមិ អនាសវោ ។
ចតុន្នវុតេ ឥតោ កប្បេ យំ ផលមទទឹ តទា
ទុគ្គតឹ នាភិជានាមិ ផលទានស្សិទំ ផលំ ។
កិលេសា ឈាបិតា មយ្ហំ ភវា សព្វេ សមូហតា
នាគោវ ពន្ធនំ ឆេត្វា វិហរាមិ អនាសវោ ។
ស្វាគតំ វត មេ អាសិ មម ពុទ្ធស្ស សន្តិកេ
តិស្សោ វិជ្ជា អនុប្បត្តា កតំ ពុទ្ធស្ស សាសនំ ។
បដិសម្ភិទា ចតស្សោ វិមោក្ខាបិច អដ្ឋិមេ
ឆឡភិញ្ញា សច្ឆិកតា កតំ ពុទ្ធស្ស សាសនំ ។

ឥត្ថំ សុទំ អាយស្មា អម្ពបិណ្ឌិយោ ថេរោ ឥមា គាថាយោ អភាសិត្ថាតិ ។

អម្ពបិណ្ឌិយត្ថេរស្ស អបទានំ សមត្តំ ។



អម្ពបិណ្ឌិយត្ថេរាបទាន ទី ៩

ខ្ញុំមានចិត្តបញ្ជូនទៅកាន់ព្យាយាម ជាអ្នកស្ងប់រម្ងាប់ មិនមានឧបធិកិលេស កំណត់ដឹងនូវអាសវៈទាំងពួង ជាអ្នកមិនមានអាសវៈ ។ ក្នុងកប្បទី ៩៤ អំពីកប្បនេះ ព្រោះហេតុដែលខ្ញុំបានឲ្យទាន ក្នុងកាលនោះ ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃការថ្វាយផ្លែឈើ ។ កិលេសទាំងឡាយ ខ្ញុំដុតបំផ្លាញហើយ ភពទាំងអស់ ខ្ញុំដកចោលហើយ ខ្ញុំជាបុគ្គលមិនមានអាសវៈ ដូចជាដំរីប្រសើរកាត់ផ្តាច់នូវចំណង ។ ឱ ! ដំណើរដែលខ្ញុំមកក្នុងសំណាក់នៃព្រះពុទ្ធរបស់ខ្ញុំ ជាដំណើរល្អហោង វិជ្ជា ៣ ខ្ញុំបានដល់ហើយ សាសនារបស់ព្រះពុទ្ធ ខ្ញុំបានធ្វើហើយ ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនា របស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ។

បានឮថា ព្រះអម្ពបិណ្ឌិយត្ថេរ មានអាយុ បានសំដែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

ចប់ អម្ពបិណ្ឌិយត្ថេរាបទាន ។

## ទសមំ ជម្ពុផលិយត្ថេរាបទានំ

[៣០] បទុមុត្តរពុទ្ធស្ស លោកជេដ្ឋស្ស តាទិនោ
បិណ្ឌាយ វិចរន្តស្ស ធារតោ ឧត្តមំ យសំ ។
អគ្គផលំ គហេត្វាន វិប្បសន្នេន ចេតសា
ទក្ខិណេយ្យស្ស វីរស្ស អទាសិំ សត្ថុនោ អហំ ។
តេន កម្មេន ទិបទិន្ទ លោកជេដ្ឋ នរាសភ
បត្តោម្ហិ អចលំ ឋានំ ហិត្វា ជយបរាជយំ ។
សតសហស្សិតោ កប្បេ យំ ផលមទទិំ តទា
ទុគ្គតិំ នាភិជានាមិ អគ្គផលស្សិទំ ផលំ ។
កិលេសា ឈាបិតា មយ្ហំ ភវា សព្វេ សមូហតា
នាគោវ ពន្ធនំ ឆេត្វា វិហរាមិ អនាសវោ ។





## ជម្ពុផលិយត្ថេរាបទាន ទី ១០

[៣០] កាលព្រះសម្ពុទ្ធ ព្រះនាមបទុមុត្តរៈ ជាច្បងក្នុងលោក ព្រះអង្គមិនញាប់ញ័រ ដោយលោកធម៌ ទ្រង់ទ្រទ្រង់នូវយសដ៏ឧត្តម ទ្រង់ស្តេចយាងបិណ្ឌបាត ។ ខ្ញុំមានចិត្តជ្រះថ្លា បានយកផ្លែឈើដំបូង ចូលទៅថ្វាយព្រះសាស្តា ព្រះអង្គជាទក្ខិណេយ្យបុគ្គល ជាអ្នកប្រាជ្ញទៀម (ហើយពោលថា) បពិត្រព្រះអង្គជាធំជាងសត្វជើងពីរ ជាច្បងក្នុងលោក ប្រសើរជាងពួកជន ខ្ញុំព្រះអង្គសូមលះបង់នូវការឈ្នះ និងការចាញ់ ហើយដល់នូវធម៌ មិនកម្រើកគឺព្រះនិព្វាន ដោយកុសលកម្មនោះ ។ ក្នុងកប្បទីមួយសែន អំពីកប្បនេះ ព្រោះហេតុដែលខ្ញុំបានឲ្យទាន ក្នុងកាលនោះ ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃទានផ្លែឈើដំបូង ។ កិលេសទាំងឡាយ ខ្ញុំដុតបំផ្លាញហើយ ភពទាំងពួង ខ្ញុំបានផ្តាច់ហើយ ខ្ញុំជាបុគ្គលមិនមានអាសវៈ ដូចជាដំរីប្រសើរកាត់ផ្តាច់នូវទន្លីង ។

ទសមំ ជម្ពុផលិយត្ថេរាបទានំ

ស្វាគតំ វត មេ អាសិ   មម ពុទ្ធស្ស សន្តិកេ
តិស្សោ វិជ្ជា អនុប្បត្តា   កតំ ពុទ្ធស្ស សាសនំ ។
បដិសម្ភិទា ចតស្សោ   វិមោក្ខាបិច អដ្ឋិមេ
ឆឡភិញ្ញា សច្ឆិកតា   កតំ ពុទ្ធស្ស សាសនន្តិ ។

ឥត្ថំ សុទំ អាយស្មា ជម្ពុផលិយោ(១) ថេរោ ឥមា គាថាយោ អភាសិត្ថាតិ ។

ជម្ពុផលិយត្ថេរស្ស អបទានំ សមត្តំ ។

ឧទ្ទានំ

ថេរោ ឯកវិហារី ច   សង្ខិយោ បាដិហីរកោ
ថវិកោ ឧច្ឆុខណ្ឌី ច   កឡម្ពម្ពាដកប្បទា ។
ហរីតកម្ពបិណ្ឌី ច   ជម្ពុទោ(២) ចសមោ យតិ
ឆឡាសីតិ ច គាថាយោ   គណិតាយោ វិភាវិហិ ។

ឯកវិហារិវគ្គោ បញ្ចបញ្ញាសោ ។

---

១ ម. អម្ពផលិយោ ។ ២ ម. អម្ពទោ ។



ជម្ពុផលិយត្ថេរាបទាន ទី ១០

ឱ! ដំណើរដែលខ្ញុំមក ក្នុងសំណាក់នៃព្រះពុទ្ធរបស់ខ្ញុំ ជាដំណើរល្អហ្ន៎ វិជ្ជា ៣ ខ្ញុំបានដល់ហើយ សាសនារបស់ព្រះពុទ្ធ ខ្ញុំបានធ្វើហើយ ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ។

បានឮថា ព្រះជម្ពុផលិយត្ថេរ មានអាយុ បានសំដែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

ចប់ ជម្ពុផលិយត្ថេរាបទាន ។

ឧទ្ទាន

ឯកវិហារិយត្ថេរាបទាន ១ ឯកសង្ខិយត្ថេរាបទាន ១ បាដិហីរសញ្ញកត្ថេរាបទាន ១ ញាណត្ថវិកត្ថេរាបទាន ១ ឧច្ឆុខណ្ឌិកត្ថេរាបទាន ១ កឡម្ពទាយកត្ថេរាបទាន ១ អម្ពាដកទាយកត្ថេរាបទាន ១ ហរីតកិទាយកត្ថេរាបទាន ១ អម្ពបិណ្ឌិយត្ថេរាបទាន ១ ជម្ពុផលិយត្ថេរាបទាន ១ ជាគំរប់ ១០ គាថាចំនួន ៨៦ អ្នកប្រាជ្ញបានរាប់ហើយ ។

ចប់ ឯកវិហារិកវគ្គ ទី ៥៥ ។

## បញ្ចបញ្ញាសមោ វិភេទកិវគ្គោ

### បឋមំ វិភេទកពីជិយត្ថេរាបទានំ

(៣១) កកុសន្ធោ មហាវីរោ សព្វធម្មាន បារគូ
គណម្ហា វូបកដ្ឋោ សោ អគមាសិ វនន្តរំ ។
វីជវីជំ គហេត្វាន លតាយ អាចរិ(១) អហំ
ភគវា តម្ហិ សមយេ ឈាយតេ បព្វតន្តរេ ។
ទិស្វានហំ ទេវទេវំ វិប្បសន្នេន ចេតសា
ទក្ខិណេយ្យស្ស វីរស្ស វីជវីជមទាសហំ ។
ឥមស្មឹយេវ កប្បស្មឹ យំ វីជមទទឹ(២) តទា
ទុគ្គតឹ នាភិជានាមិ វីជវីជស្សិទំ ផលំ ។
កិលេសា ឈាបិតា មយ្ហំ ភវា សព្វេ សមូហតា
នាគោវ ពន្ធនំ ឆេត្វា វិហរាមិ អនាសវោ ។

---

១ ឱ. អាវុណឹ ។ ម. អវិរ ។ ២ ឱ. ផលមទទឹ ។ ម. វីជមទទឹ ។

## វិភេទកិវគ្គ ទី ៥៥

### វិភេទកពីជិយត្ថេរាបទាន ទី ១

(៣១) ព្រះសម្ពុទ្ធ ព្រះនាមកកុសន្ធៈ មានព្យាយាមធំ ទ្រង់ដល់នូវត្រើយ នៃធម៌ទាំងពួង ព្រះអង្គទ្រង់ចៀសចេញចាកពួក ហើយស្តេចទៅកាន់ចន្លោះព្រៃ ។ ខ្ញុំយកផ្លែសម៉ពិភេទក៍ដោតនឹងវល្លិ៍ សម័យនោះ ព្រះមានព្រះភាគ ទ្រង់ចម្រើនឈាន ត្រង់ចន្លោះភ្នំ ខ្ញុំបានឃើញព្រះមានព្រះភាគ ជាទេវតាក្រៃលែងជាងទេវតា ក៏មានចិត្តជ្រះថ្លា ហើយថ្វាយផ្លែសម៉ពិភេទក៍ ដល់ព្រះអង្គ ជាអ្នកប្រាជ្ញ ជាទក្ខិណេយ្យបុគ្គល ។ ក្នុងកប្បនេះឯង ព្រោះហេតុដែលខ្ញុំបានថ្វាយផ្លែសម៉ពិភេទក៍ ក្នុងកាលនោះ ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃផ្លែសម៉ពិភេទក៍ ។ កិលេសទាំងឡាយ ខ្ញុំដុតបំផ្លាញហើយ ភពទាំងអស់ ខ្ញុំដកចោលហើយ ខ្ញុំជាបុគ្គលមិនមានអាសវៈ ដូចជាដំរីប្រសើរ កាត់ផ្តាច់នូវចំណង ។

ស្វាគតំ វត មេ អាសិ មម ពុទ្ធស្ស សន្តិកេ

តិស្សោ វិជ្ជា អនុប្បត្តា កតំ ពុទ្ធស្ស សាសនំ ។

បដិសម្ភិទា ចតស្សោ វិមោក្ខាបិ ច អដ្ឋិមេ

ឆឡភិញ្ញា សច្ឆិកតា កតំ ពុទ្ធស្ស សាសនំ ។

ឥត្ថំ សុទំ អាយស្មា វិភេទកពីជិយោ(១) ថេរោ ឥមា គាថាយោ អភាសិត្ថាតិ ។

វិភេទកពីជិយត្ថេរស្ស អបទានំ សមត្តំ ។

## ទុតិយំ កោលទាយកត្ថេរាបទានំ

(៣៦) អជិនេន និវត្ថោហំ វាកចីរធរោ តទា

ខារិយា បូរយិត្វាន កោលំ ហាសិំ មមស្សមំ(២) ។

តម្ហិ កាលេ សិខី ពុទ្ធោ ឯកោ អទុតិយោ អហុ

មមស្សមំ ឧបាគច្ឆិ ជោតេន្តោ(៣) សព្វកាលិកំ ។

---

១ ឱ. វិភីតកមិញ្ជិយោ ។ ២ ឱ. ខារិភារំ ហរិត្វាន កោលមាហរិ មមស្សមន្តិ ទិស្សតិ ។ ម. ខារិយា បូរយិត្វាន កោលំ ហាសិ មមស្សមន្តិ ទិស្សតិ ។ ៣ ម. ជោតេន្តោ ។



ឱ ! ដំណើរដែលខ្ញុំមកក្នុងសំណាក់នៃព្រះពុទ្ធរបស់ខ្ញុំ ជាដំណើរល្អហ្ន៎ វិជ្ជា ៣ ខ្ញុំបានដល់ហើយ សាសនារបស់ព្រះពុទ្ធ ខ្ញុំបានធ្វើហើយ ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ។

បានឮថា ព្រះវិភេទកពីជិយត្ថេរ មានអាយុ បានសម្ដែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

ចប់ វិភេទកពីជិយត្ថេរាបទាន ។

## កោលទាយកត្ថេរាបទាន ទី ២

(៣៦) កាលនោះ ខ្ញុំស្លៀកស្បែកខ្លា ទ្រទ្រង់សំពត់សម្បកឈើ បានរែកផ្លែពុទ្រាមួយអម្រែក ទៅឯអាស្រមរបស់ខ្ញុំ ។ ក្នុងកាលនោះ ព្រះសម្ពុទ្ធ ព្រះនាមសិខី ព្រះអង្គមិនមានបុគ្គលជាគំរប់ពីរ ទ្រង់រុងរឿងសព្វ ១ កាល ទ្រង់ស្ដេចចូលទៅក្នុងអាស្រមរបស់ខ្ញុំ តែមួយព្រះអង្គឯង ។

សកំ ចិត្តំ បសាទេត្វា វន្ទិត្វាន ច សត្ថុនំ

ឧះការេត្វាហំ បគ្គយ្ហ គោលំ ពុទ្ធស្សទាសហំ

ឯកត្តិំសេ ឥតោ កប្បេ យំ ផលំ អទទឹ តទា

ទុគ្គតឹ នាភិជានាមិ គោលទានស្សិទំ ផលំ ។

កិលេសា ឈាបិតា មយ្ហំ ភវា សព្វេ សមូហតា

នាគោវ ពន្ធនំ ឆេត្វា វិហរាមិ អនាសវោ ។

ស្វាគតំ វត មេ អាសិ មម ពុទ្ធស្ស សន្តិកេ

តិស្សោ វិជ្ជា អនុប្បត្តា កតំ ពុទ្ធស្ស សាសនំ ។

បដិសម្ភិទា ចតស្សោ វិមោក្ខាបិច អដ្ឋិមេ

ឆឡភិញ្ញា សច្ឆិកតា កតំ ពុទ្ធស្ស សាសនំ ។

ឥត្ថំ សុទំ អាយស្មា គោលទាយកោ ថេរោ ឥមា គាថាយោ អភាសិត្ថាតិ ។

គោលទាយកត្ថេរស្ស អបទានំ សមត្តំ ។





ខ្ញុំញ៉ាំងចិត្តរបស់ខ្លួន ឲ្យជ្រះថ្លា ហើយថ្វាយបង្គំព្រះសាស្តា ព្រះអង្គមានគុណ ប្រកាន់យកនូវផ្លែព្រា ដោយដៃទាំងពីរ ថ្វាយដល់ព្រះពុទ្ធ ។ ក្នុងកប្បទី ៣១ អំពីកប្បនេះ ព្រោះហេតុដែលខ្ញុំបានថ្វាយផ្លែព្រា ក្នុងកាលនោះ ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃការថ្វាយផ្លែព្រា ។ កិលេសទាំងឡាយ ខ្ញុំដុតបំផ្លាញហើយ ភពទាំងពួង ខ្ញុំដកចោលហើយ ខ្ញុំជាបុគ្គលមិនមានអាសវៈ ដូចជាដំរីប្រសើរ កាត់ផ្តាច់នូវចំណង ។ ឱ ! ដំណើរដែលខ្ញុំមក ក្នុងសំណាក់នៃព្រះពុទ្ធរបស់ខ្ញុំ ជាដំណើរល្អពិត វិជ្ជា ៣ ខ្ញុំបានដល់ហើយ សាសនា របស់ព្រះពុទ្ធ ខ្ញុំបានធ្វើហើយ ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនា របស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ។

បានឮថា ព្រះគោលទាយកត្ថេរ មានអាយុ បានសម្តែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

ចប់ គោលទាយកត្ថេរាបទាន ។

## តតិយំ ពិល្លផលិយត្ថេរាបទានំ

(៣៣) ចន្ទភាគានទីតីរេ អស្សមោ សុកតោ មម
ពិល្លរុក្ខេហិ អាកិណ្ណោ នានាទុមនិសេវិតោ ។
សុគន្ធំ ពិល្លំ ទិស្វាន ពុទ្ធសេដ្ឋំ អនុស្សរំ
ខារិកំ បូរយិត្វាន តុដ្ឋោ សំវិគ្គមានសោ ។
កកុសន្ធំ ឧបាគម្ម ពិល្លបក្កមទាសហំ
បុញ្ញក្ខេត្តស្ស ធីរស្ស(១) វិប្បសន្នេន ចេតសា ។
ឥមស្មឹយេវ កប្បស្មឹ យំ ផលំ អទទឹ តទា
ទុគ្គតឹ នាភិជានាមិ ផលទានស្សិទំ ផលំ ។
កិលេសា ឈាបិតា មយ្ហំ ភវា សព្វេ សមូហតា
នាគោវ ពន្ធនំ ឆេត្វា វិហរាមិ អនាសវោ ។
ស្វាគតំ វត មេ អាសិ មម ពុទ្ធស្ស សន្តិកេ
តិស្សោ វិជ្ជា អនុប្បត្តា កតំ ពុទ្ធស្ស សាសនំ ។

---
១ ឱ. ម. វីរស្ស ។

## ពិល្លផលិយត្ថេរាបទាន ទី ៣

(៣៣) អាស្រមរបស់ខ្ញុំ ខ្ញុំបានធ្វើល្អហើយ ទៀបឆ្នេរស្ទឹងចន្ទភាគា ជាអាស្រមដ៏ដេរដាសដោយដើមព្នៅ ទាំងមានពួកឈើផ្សេងៗ ដុះនៅក្បែរអាស្រមនោះ ។ ខ្ញុំបានឃើញផ្លែព្នៅមានក្លិនក្រអូប បានបេះផ្លែព្នៅនោះ ដាក់ពេញការះ គឺអម្រែកហើយត្រេកអរ មានចិត្តសង្វេគនឹកដល់ព្រះសម្ពុទ្ធដ៏ប្រសើរ ។ ខ្ញុំបានចូលទៅគាល់ព្រះអង្គ ព្រះនាមកកុសន្ធៈ ហើយថ្វាយផ្លែព្នៅទុំដល់ព្រះសម្ពុទ្ធ ជាអ្នកប្រាជ្ញ ជាស្រែបុណ្យដោយចិត្តជ្រះថ្លា ។ ក្នុងកប្បនេះ ព្រោះហេតុដែលខ្ញុំបានថ្វាយផ្លែព្នៅ ក្នុងកាលនោះ ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃការថ្វាយផ្លែព្នៅ ។ កិលេសទាំងឡាយ ខ្ញុំដុតបំផ្លាញចេញហើយ ភពទាំងអស់ ខ្ញុំបានដកឡើងហើយ ខ្ញុំជាបុគ្គលមិនមានអាសវៈ ដូចជាដំរីដ៏ប្រសើរ កាត់ផ្តាច់ទន្លីង ។ ឱ ! ដំណើរដែលខ្ញុំមកក្នុងសំណាក់នៃព្រះពុទ្ធរបស់ខ្ញុំ ជាដំណើរល្អហ្ន៎ វិជ្ជា ៣ ខ្ញុំបានដល់ហើយ សាសនារបស់ព្រះពុទ្ធ ខ្ញុំបានធ្វើហើយ ។

បដិសម្ភិទា ចតស្សោ វិមោក្ខាបិ ច អដ្ឋិមេ

ឆឡភិញ្ញា សច្ឆិកតា កតំ ពុទ្ធស្ស សាសនន្តិ ។

ឥត្ថំ សុទំ អាយស្មា វេលុវផលិយោ ថេរោ ឥមា

គាថាយោ អភាសិត្ថាតិ ។

វេលុវផលិយត្ថេរស្ស អបទានំ សមត្តំ ។

## ចតុត្ថំ ភល្លាតកទាយកត្ថេរាបទានំ

(៣៦) សុវណ្ណវណ្ណំ សម្ពុទ្ធំ ទ្វត្តិំសវរលក្ខណំ

បវនគ្គេន(១) គច្ឆន្តំ សាលរាជំវ ផុល្លិតំ ។

តិណសន្ថរំ(២) បញ្ញាបេត្វា ពុទ្ធសេដ្ឋំ អយាចហំ

អនុកម្បតុ មំ ពុទ្ធោ ភិក្ខំ ឥច្ឆាមិ ទាតវេ ។

---

១ ម. វិបិនគ្គេន ។ ២ ឱ.ប. តិណត្ថរំ ។



បដិសម្ភិទា ៤ វិមោក្ខ ៨ អភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យ ជាក់ច្បាស់ហើយ ទាំងសាសនា របស់ព្រះពុទ្ធ ខ្ញុំក៏បាន ប្រតិបត្តិហើយ ។

បានឮថា ព្រះវេលុវផលិយត្ថេរ មានអាយុ បានសំដែងនូវ គាថាទាំងនេះ ដោយប្រការដូច្នេះ ។

ចប់ វេលុវផលិយត្ថេរាបទាន ។

## ភល្លាតកទាយកត្ថេរាបទាន ទី ៤

(៣៦) ព្រះសម្ពុទ្ធ មានវណ្ណៈដូចមាស មានលក្ខណៈ ៣២ ដ៏ប្រសើរ ទ្រង់ស្តេចទៅកាន់ជាយព្រៃ ព្រះអង្គដូចជាសាលរាជព្រឹក្ស បានផ្ការីកហើយ ។ ខ្ញុំក្រាលកម្រាលស្មៅ រួចហើយអារាធនាព្រះសម្ពុទ្ធដ៏ប្រសើរថា សូមព្រះសម្ពុទ្ធអនុគ្រោះខ្ញុំព្រះអង្គ ខ្ញុំព្រះអង្គប្រាថ្នានឹងថ្វាយចង្ហាន់ ។

អនុកម្បកោ ការុណិកោ អត្ថទស្សី មហាយសោ
មម សង្កប្បមញ្ញាយ ឱរុយ្ហ(១) មម អស្សមេ ។
ឱរោហិត្វាន សម្ពុទ្ធោ និសីទិ បណ្ណសន្ថរេ
កប្បកម្មំ គហេត្វាន ពុទ្ធសេដ្ឋស្សទាសហំ ។
មម និជ្ឈាយមានស្ស បរិនិព្វុ តទា ជិនោ
តត្ថ ចិត្តំ បសាទេត្វា អភិវន្ទិំ តទា ជិនំ ។
អដ្ឋារសេ កប្បសតេ យំ ផលំ អទទិំ តទា
ទុគ្គតិំ នាភិជានាមិ ផលទានស្សិទំ ផលំ ។
កិលេសា ឈាបិតា មយ្ហំ ភវា សព្វេ សមូហតា
នាគោវ ពន្ធនំ ឆេត្វា វិហរាមិ អនាសវោ ។
ស្វាគតំ វត មេ អាសិ មម ពុទ្ធស្ស សន្តិកេ
តិស្សោ វិជ្ជា អនុប្បត្តា កតំ ពុទ្ធស្ស សាសនំ

---

១ ឱ.ម. ឱរុហិ ។ ម. ឱរូហិ ។



ឯព្រះសម្ពុទ្ធ ទ្រង់ព្រះនាមអត្ថទស្សី ទ្រង់អនុគ្រោះ ប្រកបដោយករុណា ទ្រង់មានយសធំ ទ្រង់ជ្រាបនូវសេចក្តីត្រិះរិះរបស់ខ្ញុំ ហើយស្តេចចូលទៅក្នុងអាស្រមរបស់ខ្ញុំ ។ ព្រះសម្ពុទ្ធស្តេចចូលទៅគង់លើកម្រាលស្លឹកឈើ ខ្ញុំបានយកផ្លែក្រខុប ថ្វាយព្រះសម្ពុទ្ធដ៏ប្រសើរ ។ កាលខ្ញុំកំពុងសំឡឹងមើល ព្រះជិនស្រីទ្រង់សោយរួចហើយ ខ្ញុំក៏ញ៉ាំងចិត្តឲ្យជ្រះថ្លាចំពោះព្រះអង្គ ហើយថ្វាយបង្គំព្រះជិនស្រី ក្នុងកាលនោះ ។ ក្នុងកប្បទី ១.៨០០ ព្រោះហេតុដែលខ្ញុំបានថ្វាយផ្លែឈើក្នុងកាលនោះ ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃការថ្វាយផ្លែឈើ ។ កិលេសទាំងឡាយ ខ្ញុំដុតបំផ្លាញហើយ ភពទាំងអស់ ខ្ញុំដកចោលហើយ ខ្ញុំជាបុគ្គលមិនមានអាសវៈ ដូចជាដំរីដ៏ប្រសើរ កាត់ផ្តាច់នូវចំណង ។ ឱ! ដំណើរដែលខ្ញុំមកក្នុងសំណាក់នៃព្រះពុទ្ធរបស់ខ្ញុំ ជាដំណើរល្អហ្ន៎ វិជ្ជា ៣ ខ្ញុំបានដល់ហើយ សាសនារបស់ព្រះពុទ្ធ ខ្ញុំបានធ្វើហើយ ។

បដិសម្ភិទា ចតស្សោ វិមោក្ខាបិច អដ្ឋិមេ
ឆឡភិញ្ញា សច្ឆិកតា កតំ ពុទ្ធស្ស សាសនន្តិ ។

ឥត្ថំ សុទំ អាយស្មា ភល្លាតកទាយកោ ថេរោ ឥមា គាថាយោ អភាសិត្ថាតិ ។

ភល្លាតកទាយកត្ថេរស្ស អបទានំ សមត្តំ ។

## បញ្ចមំ ឧម្មាបុប្ផិយត្ថេរាបទានំ

(៣៨) និគ្រោធេ ហរិតោភាសេ សំវិរូឡ្ហម្ហិ បាទបេ
ឧម្មាមាលំ[១] បគ្គយ្ហ ពោធិយា អភិរោបយឹ ។
ឥមស្មឹយេវ កប្បស្មឹ យំ ពោធិមភិបូជយឹ
ទុគ្គតឹ នាភិជានាមិ ពោធិបូជាយិទំ ផលំ ។
កិលេសា ឈាបិតា មយ្ហំ ភវា សព្វេ សមូហតា
នាគោវ ពន្ធនំ ឆេត្វា វិហរាមិ អនាសវោ ។

---

១ ឱ. ប. ឧក្កុម្ហិមាលំ ។ ម. ឧត្តលិមាលំ ។



បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនា របស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ។

បានឮថា ព្រះភល្លាតកទាយកត្ថេរ មានអាយុ បានសម្តែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

ចប់ ភល្លាតកទាយកត្ថេរាបទាន ។

## ឧម្មាបុប្ផិយត្ថេរាបទាន ទី ៥

(៣៨) កាលដើមជ្រៃ ជាពោធិព្រឹក្សដុះឡើង មានពន្លឺខៀវខ្ចី ខ្ញុំបានយកកម្រងផ្កាកប្បាស ទៅបូជាពោធិព្រឹក្សនោះ ។ ក្នុងកប្បនេះ ព្រោះហេតុដែលខ្ញុំបានបូជាពោធិព្រឹក្សក្នុងកាលនោះ ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផល នៃការបូជាពោធិព្រឹក្ស ។ កិលេសទាំងឡាយ ខ្ញុំដុតបំផ្លាញហើយ ភពទាំងអស់ ខ្ញុំដកចោលហើយ ខ្ញុំជាបុគ្គលមិនមានអាសវៈ ដូចជាដំរីដ៏ប្រសើរ កាត់ផ្តាច់នូវចំណង ។

ស្វាគតំ វត មេ អាសិ   មម ពុទ្ធស្ស សន្តិកេ
តិស្សោ វិជ្ជា អនុប្បត្តា   កតំ ពុទ្ធស្ស សាសនំ ។
បដិសម្ភិទា ចតស្សោ   វិមោក្ខាបិច អដ្ឋិមេ
ឆឡភិញ្ញា សច្ឆិកតា   កតំ ពុទ្ធស្ស សាសនំ ។

ឥត្ថំ សុទំ អាយស្មា ឧម្មាបុប្ផិយោ[1] ថេរោ ឥមា គាថាយោ អភាសិត្ថាតិ ។

ឧម្មាបុប្ផិយត្ថេរស្ស អបទានំ សមត្តំ ។

## ឆដ្ឋំ អម្ពាដកិយត្ថេរាបទានំ

(៣៦) សុបុប្ផិតំ សាលវនំ   ឱគ្គយ្ហ វេស្សភូ មុនិ
និសីទិ គិរិទុគ្គេសុ   អភិជាតោវ កេសរី ។
បសន្នចិត្តោ សុមនោ   អម្ពាដកមបូជយឹ
បុញ្ញក្ខេត្តំ មហាវីរំ   បសន្នោ សេហិ បាណិភិ ។

១. ឱ.ម. ឧត្តុប្ផុប្ផិយោ ។ ម. ខត្តលិកុប្ផិយោ ។



ឱ ! ដំណើរដែលខ្ញុំមក ក្នុងសំណាក់នៃព្រះពុទ្ធរបស់ខ្ញុំ ជាដំណើរល្អហ្ន៎ វិជ្ជា ៣ ខ្ញុំបានដល់ហើយ សាសនា របស់ព្រះពុទ្ធ ខ្ញុំបានធ្វើហើយ ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ តាំង សាសនា របស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ។

បានឮថា ព្រះឧម្មាបុប្ផិយត្ថេរ មានអាយុ បានសម្តែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

ចប់ ឧម្មាបុប្ផិយត្ថេរាបទាន ។

## អម្ពាដកិយត្ថេរាបទាន ទី ៦

(៣៦) ព្រះសម្ពុទ្ធ ព្រះនាមវេស្សភូ ជាអ្នកប្រាជ្ញ ស្តេចចូលទៅក្នុងសាលវ័ន (ព្រៃរាំងភ្នំ) ដែលមានផ្ការីកល្អ ហើយគង់ក្បែរជ្រោះភ្នំ ដែលគេទៅបានដោយលំបាក ដូចកេសរសីហ៍ ជាសត្វមានជាតិខ្ពស់ ។ ខ្ញុំមានចិត្តជ្រះថ្លា មានចិត្តរីករាយ បានបូជាផ្លែម្កាក់ ចំពោះព្រះសម្ពុទ្ធ ជាស្រែបុណ្យ ដែលមានព្យាយាមធំ ដោយដៃរបស់ខ្លួន ។

ឯកត្តឹសេ ឥតោ កប្បេ យំ ពុទ្ធមភិបូជយឹ
ទុគ្គតឹ នាភិជានាមិ ពុទ្ធបូជាយិទំ ផលំ ។
កិលេសា ឈាបិតា មយ្ហំ ភវា សព្វេ សមូហតា
នាគោវ ពន្ធនំ ឆេត្វា វិហរាមិ អនាសវោ ។
ស្វាគតំ វត មេ អាសិ មម ពុទ្ធស្ស សន្តិកេ
តិស្សោ វិជ្ជា អនុប្បត្តា កតំ ពុទ្ធស្ស សាសនំ ។
បដិសម្ភិទា ចតស្សោ វិមោក្ខាបិច អដ្ឋិមេ
ឆឡភិញ្ញា សច្ឆិកតា កតំ ពុទ្ធស្ស សាសនន្តិ ។

ឥត្ថំ សុទំ អាយស្មា អម្ពាដកិយោ ថេរោ ឥមា គាថាយោ អភាសិត្ថាតិ ។

អម្ពាដកិយត្ថេរស្ស អបទានំ សមត្តំ ។



ក្នុងកប្បទី ៣១ អំពីកប្បនេះ ព្រោះហេតុដែលខ្ញុំបានបូជា ផ្កា ក្នុងកាលនោះ ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃពុទ្ធបូជា ។ កិលេសទាំងឡាយ ខ្ញុំដុតបំផ្លាញហើយ ភពទាំងពួង ខ្ញុំដកចោលហើយ ខ្ញុំជាបុគ្គលមិនមានអាសវៈ ដូចជាដំរីដ៏ប្រសើរ កាត់ផ្តាច់នូវទន្លីង ។ ឱ ! ដំណើរដែលខ្ញុំមក ក្នុងសំណាក់នៃព្រះពុទ្ធរបស់ខ្ញុំ ជាដំណើរល្អហ្ន៎ វិជ្ជា ៣ ខ្ញុំបានដល់ហើយ សាសនា របស់ព្រះពុទ្ធ ខ្ញុំបានធ្វើហើយ ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនា របស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ។

បានឮថា ព្រះអម្ពាដកិយត្ថេរ មានអាយុ បានសំដែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

ចប់ អម្ពាដកិយត្ថេរាបទាន ។

# សត្តមំ សីហាសនិកត្ថេរាបទានំ

(៣៧) បទុមុត្តរស្ស ភគវតោ សព្វភូតហិតេសិនោ
បសន្នចិត្តោ សុមនោ សីហាសនមទាសហំ ។
ទេវលោកេ មនុស្សេ ច យត្ថ យត្ថូបបជ្ជហំ
លភាមិ វិបុលំ ព្យម្ហំ សីហាសនស្សិទំ ផលំ ។
សុវណ្ណរូបិយមយា(១) លោហិតង្កមយា ពហូ
មណិមយា ច បល្លង្កា និព្វត្តន្តិ មមំ សទា ។
ពោធិយា អាសនំ កត្វា ជលជុត្តមនាមិនោ
ឧច្ចេ កុលេ បជាយាមិ អហោ ធម្មសុធម្មតា ។
សតសហស្សេ ឥតោ កប្បេ សីហាសនមទាសហំ
ទុគ្គតឹ នាភិជានាមិ សីហាសនស្សិទំ ផលំ ។
កិលេសា ឈាបិតា មយ្ហំ ភវា សព្វេ សមូហតា
នាគោវ ពន្ធនំ ឆេត្វា វិហរាមិ អនាសវោ ។

---

១ ឱ. សោវណ្ណមយា រូបិយមយា ។ ម. សោវណ្ណមយា រូបិយា ។

# សីហាសនិកត្ថេរាបទាន ទី ៧

(៣៧) ខ្ញុំមានចិត្តជ្រះថ្លា មានចិត្តរីករាយ បានថ្វាយសីហាសនៈ ដល់ព្រះមានព្រះភាគ ព្រះនាមបទុមុត្តរៈ ព្រះអង្គស្វែងរកប្រយោជន៍ ដល់សត្វទាំងពួង ។ ខ្ញុំទៅកើតក្នុងទីណា ៗ គឺទេវលោក ឬក្នុងមនុស្សលោក រមែងបានទទួលវិមានដ៏ធំទូលាយ ក្នុងទីនោះ ៗ នេះជាផលនៃសីហាសនៈ ។ បល្ល័ង្កទាំងឡាយដ៏ច្រើន សុទ្ធតែជាវិការៈនៃមាស និងប្រាក់ផង ជាវិការៈនៃកែវក្រហមផង ជាវិការៈនៃកែវមណីផង តែងកើតឡើងសម្រាប់ខ្ញុំសព្វ ១ កាល ។ ខ្ញុំកើតក្នុងត្រកូលខ្ពស់ ព្រោះតែធ្វើអាសនៈទៀបដើមពោធិព្រឹក្ស ថ្វាយព្រះសម្ពុទ្ធព្រះនាមបទុមុត្តរៈ ឱ ! ភាពនៃព្រះធម៌ជាធម៌ដ៏ល្អ ។ ក្នុងកប្បទីមួយសែន អំពីកប្បនេះ ព្រោះហេតុដែលខ្ញុំបានធ្វើនូវសីហាសនៈក្នុងកាលនោះ ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃសីហាសនៈ ។ កិលេសទាំងឡាយ ខ្ញុំដុតបោលហើយ ភពទាំងពួង ខ្ញុំដកចោលហើយ ខ្ញុំជាបុគ្គលមិនមានអាសវៈ ដូចជាដំរីដ៏ប្រសើរ កាត់ផ្តាច់នូវខ្នើង ។

ស្វាគតំ វត មេ អាសិ    មម ពុទ្ធស្ស សន្តិកេ
តិស្សោ វិជ្ជា អនុប្បត្តា    កតំ ពុទ្ធស្ស សាសនំ ។
បដិសម្ភិទា ចតស្សោ    វិមោក្ខាបិ ច អដ្ឋិមេ
ឆឡភិញ្ញា សច្ឆិកតា    កតំ ពុទ្ធស្ស សាសនំ ។

ឥត្ថំ សុទំ អាយស្មា សីហាសនិកោ ថេរោ ឥមា គាថាយោ អភាសិត្ថាតិ ។

សីហាសនិកត្ថេរស្ស អបទានំ សមត្តំ ។

## អដ្ឋមំ បាទបីឋិយត្ថេរាបទានំ

(៣៨) សុមេធោ នាម សម្ពុទ្ធោ ការុណិកោ មហាមុនិ[១]
តារយិត្វា ពហូ សត្តេ    និព្វុតោ សោ មហាយសោ ។
សីហាសនស្ស សាមន្តា    សុមេធស្ស មហេសិនោ
បសន្នចិត្តោ សុមនោ    បាទបីឋមការយឹ ។
កត្វាន កុសលំ កម្មំ    សុខបាកំ សុខុទ្រយំ[២]
បុញ្ញកម្មេន សំយុត្តោ    តាវតឹសំ អគច្ឆហំ ។

១ ឱ. ម. អគ្គោ ការុណិកោ មុនិ ។ ២ ឱ. សុខុទ្ទយំ ។



៤ ។ ដំណើរដែលខ្ញុំបានមក ក្នុងសំណាក់នៃព្រះពុទ្ធរបស់ខ្ញុំ ជាដំណើរល្អហ្ន៎ វិជ្ជា ៣ ខ្ញុំបានដល់ហើយ សាសនារបស់ព្រះពុទ្ធ ខ្ញុំក៏បានធ្វើហើយ ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនា របស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ។

បានឮថា ព្រះសីហាសនិកត្ថេរ មានអាយុ បានសម្តែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

ចប់ សីហាសនិកត្ថេរាបទាន ។

## បាទបីឋិយត្ថេរាបទាន ទី ៨

(៣៨) ព្រះសម្ពុទ្ធ ព្រះនាមសុមេធៈ ជាអ្នកប្រាជ្ញធំ ប្រកបដោយករុណា ទ្រង់ចម្លងនូវសត្វទាំងឡាយដ៏ច្រើន ព្រះអង្គមានយសធំ ទ្រង់បរិនិព្វានហើយ ។ ខ្ញុំមានចិត្តជ្រះថ្លា មានចិត្តរីករាយ បានធ្វើតាំងសម្រាប់ទ្រព្រះបាទ ក្នុងទីជិតនៃសីហាសនៈ របស់ព្រះសម្ពុទ្ធ ព្រះនាមសុមេធៈព្រះអង្គស្វែងរកនូវគុណធំនោះ ។ ខ្ញុំធ្វើកុសលមានសុខជាវិបាក មានសុខជាកំរៃ ប្រកបដោយបុញ្ញកម្ម ក៏ទៅកើតក្នុងឋានតាវត្តិង្ស ។

ឥត្ថំ មេ វសមានស្ស បុញ្ញកម្មសមង្គិនោ
បធានំ ឧទ្ធរន្តស្ស សោណ្ណបីឋំ ករន្តិ មេ ។
លាភា តេសំ សុលទ្ធន្តេ(១) យេ លភន្តិ ឧបស្សុតឹ
និព្វុតេ តារំ កត្វាន លភន្តិ វិបុលំ សុខំ ។
មយាបិ សុកតំ កម្មំ ភណ្ឌាវេដ្ឋ សុបយោជិតំ
បាទបីឋំ ការេត្វាន សោណ្ណបីឋំ លភាមហំ ។
យំ យំ ទិសំ បក្កមាមិ គោនចិ គច្ឆយេនហំ
សោណ្ណបីឋេ អក្កមាមិ(២) បុញ្ញកម្មស្សិទំ ផលំ ។
តិំសកប្បសហស្សម្ហិ យំ កម្មមករឹ តទា
ទុគ្គតឹ នាភិជានាមិ បាទបីឋស្សិទំ ផលំ ។
កិលេសា ឈាបិតា មយ្ហំ ភវា សព្វេ សមូហតា
នាគោវ ពន្ធនំ ឆេត្វា វិហរាមិ អនាសវោ ។

១ ឱ. សុលទ្ធំ ហេ ។ ម. សុលទ្ធំ វោ ។ ២ ម. សោណ្ណបីឋេនក្កមាមិ ។





កាលខ្ញុំ នៅក្នុងវេលាកាលនោះ ជាអ្នកប្រកបដោយបុណ្យកម្ម កាលខ្ញុំដំណើរផុតឡើង តាំងជាវិការៈនៃមាស ក៏កើតឡើងសម្រាប់ខ្ញុំ ៗ ឱ! ជាលាភរបស់គេហើយ ឱ! អត្តភាពជាមនុស្ស ឈ្មោះថាគេបានល្អហើយ ព្រោះថា ជនទាំងឡាយ បានទទួលការចូលទៅជិតស្តាប់ ធ្វើនូវគ្រឿងសក្ការៈថ្វាយព្រះសម្ពុទ្ធ ដែលទ្រង់បរិនិព្វានហើយ រមែងបានទទួលសេចក្តីសុខដ៏ធំទូលាយ ៗ អំពើខ្ញុំធ្វើល្អហើយ ខ្ញុំប្រកបល្អហើយក្នុងការជួញ ខ្ញុំបានតាំងជាវិការៈនៃមាស ព្រោះតែខ្ញុំធ្វើនូវតាំងសម្រាប់ជើងព្រះធាតុ ៗ ខ្ញុំចេញទៅក្នុងទិសណា ៗ ដោយកិច្ចណានីមួយ ខ្ញុំក៏ជាន់លើតាំងមាស នេះជាផលនៃបុញ្ញកម្ម ៗ ក្នុងកប្បទី ៣ ម៉ឺន ព្រោះហេតុដែលខ្ញុំបានធ្វើនូវអំពើកុសលក្នុងកាលនោះ ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃតាំងសម្រាប់ជើងព្រះធាតុ ៗ កិលេសទាំងឡាយខ្ញុំដុតហើយ ភពទាំងពួង ខ្ញុំបានដករំលាស់ហើយ ខ្ញុំជាបុគ្គលមិនមានអាសវៈ ដូចជាដំរីប្រសើរកាត់ផ្តាច់នូវទន្លីង ៗ

សាគតំ វត មេ អាសិ មម ពុទ្ធស្ស សន្តិកេ

តិស្សោ វិជ្ជា អនុប្បត្តា កតំ ពុទ្ធស្ស សាសនំ ។

បដិសម្ភិទា ចតស្សោ វិមោក្ខាបិ ច អដ្ឋិមេ

ឆឡភិញ្ញា សច្ឆិកតា កតំ ពុទ្ធស្ស សាសនំ ។

ឥត្ថំ សុទំ អាយស្មា បាទបីឋិយោ ថេរោ ឥមា គាថាយោ អភាសិត្ថាតិ ។

បាទបីឋិយត្ថេរស្ស អបទានំ សមត្តំ ។

## នវមំ វេទិយការកត្ថេរាបទានំ

(៣៩) បទុមុត្តរស្ស ពុទ្ធស្ស ពោធិយា បាទបុត្តមេ

វេទិយំ សុកតំ កត្វា សកំ ចិត្តំ បសាទយឹ ។

អត្ថោបករណំ(១) មយ្ហំ កតានិ អកតានិ ច

អន្តលិក្ខា បវស្សន្តិ វេទិកាយ ឥទំ(២) ផលំ ។

ឧភតោ ព្យូឡ្ហសង្គាមេ បក្ខន្ទន្តោ ភយានកេ

ភយភេរវំ ន បស្សាមិ វេទិកាយ ឥទំ ផលំ ។

---

១ ម.យ. អថោបក្ខរានិ ។ ២ ម. វេទិកាយមិទំ ។



ឱ! ដំណើរដែលខ្ញុំបានមក ក្នុងសំណាក់នៃព្រះពុទ្ធរបស់ខ្ញុំ ជាដំណើរល្អហ្ន៎ វិជ្ជា ៣ ខ្ញុំបានដល់ហើយ សាសនារបស់ព្រះពុទ្ធ ខ្ញុំក៏បានធ្វើហើយ ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនា របស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ។

បានឮថា ព្រះបាទបីឋិយត្ថេរ មានអាយុ បានសម្តែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

ចប់ បាទបីឋិយត្ថេរាបទាន ។

## វេទិយការកត្ថេរាបទាន ទី ៩

(៣៩) ខ្ញុំកសាងកំពែងដ៏ល្អ ទៀបដើមពោធិព្រឹក្សដ៏ឧត្តម របស់ព្រះសម្ពុទ្ធ ព្រះនាមបទុមុត្តរៈ ហើយញុំាងចិត្តរបស់ខ្លួនឲ្យជ្រះថ្លា ។ គ្រឿងឧបករណ៍ទាំងឡាយដ៏ប្រសើរលើសលុប ដែលគេធ្វើហើយក្តី គេមិនទាន់ធ្វើហើយក្តី តែងធ្លាក់ចុះមកអំពីអាកាស នេះជាផលនៃកំពែង ។ ខ្ញុំស្ទុះចូលទៅក្នុងសង្គ្រាម ជាទីគួរខ្លាចដោយចំណែកទាំងពីរ ក៏មិនឃើញនូវភ័យដែលគួរខ្លាច នេះជាផលនៃកំពែង ។

មម សង្កប្បមញ្ញាយ   ត្យម្ភិ ចិត្តតោ សុកិ

សយជាតិ មហាក្បាង   វេទិកាយ ឥទំ ផលំ ៗ

សតសហស្សេ ឥតោ កប្បេ យំ វេទិកមការយឹ

ទុគ្គតឹ នាភិជានាមិ   វេទិកាយ ឥទំ ផលំ ៗ

កិលេសា ឈាបិតា មយ្ហំ   ភវា សព្វេ សមូហតា

នាគោវ ពន្ធនំ ឆេត្វា   វិហរាមិ អនាសវោ ៗ

ស្វាគតំ វត មេ អាសិ   មម ពុទ្ធស្ស សន្តិកេ

តិស្សោ វិជ្ជា អនុប្បត្តា   កតំ ពុទ្ធស្ស សាសនំ ៗ

បដិសម្ភិទា ចតស្សោ   វិមោក្ខាបិច អដ្ឋិមេ

ឆឡភិញ្ញា សច្ឆិកតា   កតំ ពុទ្ធស្ស សាសនន្តិ ៗ

ឥត្ថំ សុទំ អាយស្មា វេទិយការកោ ថេរោ ឥមា គាថាយោ អភាសិត្ថាតិ ៗ

វេទិយការកត្ថេរស្ស អបទានំ សមត្តំ ៗ





វិមានដ៏ល្អ រមែងកើតឡើង មិនេកតាំងឡាយជារបស់ខាង តម្លៃច្រើន ក៏កើតឡើង ព្រោះដឹងនូវសេចក្តីត្រិះរិះរបស់ខ្ញុំ នេះជាផលនៃកំពែង ។ ក្នុងកប្បទីមួយសែន អំពីកប្បនេះ ព្រោះហេតុដែលខ្ញុំបានធ្វើនូវកំពែងក្នុងកាលនោះ ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃកំពែង ។ កិលេសទាំងឡាយ ខ្ញុំដុតបំផ្លាញហើយ ភពទាំងអស់ ខ្ញុំដកចោលហើយ ខ្ញុំជាបុគ្គលមិនមានអាសវៈ ដូចជាដំរីដ៏ប្រសើរ កាត់ផ្តាច់នូវទន្លីង ។ ឱ ! ដំណើរដែលខ្ញុំមក ក្នុងសំណាក់នៃព្រះពុទ្ធរបស់ខ្ញុំ ជាដំណើរល្អហើយ វិជ្ជា ៣ ខ្ញុំបានដល់ហើយ សាសនារបស់ព្រះពុទ្ធ ខ្ញុំក៏បានធ្វើហើយ ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនា របស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ។

បានឮថា ព្រះវេទិយការកត្ថេរ មានអាយុ បានសម្តែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

ចប់ វេទិយការកត្ថេរាបទាន ។

## ទសមំ ពោធិឃរការកត្ថេរាបទានំ

(៤០) សិទ្ធត្ថស្ស ភគវតោ ទិបទិន្ទស្ស តាទិនោ
បសន្នចិត្តោ សុមនោ ពោធិឃរមការយឹ ។
តុសិតំ ឧបបជ្ជម្ហិ វសាមិ រតនេ ឃរេ
ន មេ សីតំ វា ឧណ្ហំ វា វាតោ គត្តេ ន សម្ផុសេ ។
បញ្ចសដ្ឋិម្ហិតោ កប្បេ ចក្កវត្តិ អហោសហំ
កាសិកំ នាម នគរំ វិស្សុកម្មេន មាបិតំ ។
ទសយោជនអាយាមំ អដ្ឋយោជនវិត្ថតំ
ន តម្ហិ នគរេ អត្ថិ កដ្ឋំ វល្លី ច មត្តិកា ។
តិរិយំ យោជនំ អាសិ អឌ្ឍយោជនវិត្ថតំ
មង្គលោ នាម បាសាទោ វិស្សុកម្មេន មាបិតោ ។
ចុល្លាសីតិសហស្សានិ ថម្ភា សោវណ្ណយា អហុ
មណិមយា ច និយ្យូហា ឆទនំ រូបិយំ អហុ ។



## ពោធិឃរការកត្ថេរាបទាន ទី ១០

(៤០) ខ្ញុំមានចិត្តជ្រះថ្លា មានចិត្តរីករាយ បានធ្វើរោងនៃដើមពោធិព្រឹក្ស របស់ព្រះមានព្រះភាគ ព្រះនាមសិទ្ធត្ថៈ ព្រះអង្គជាធំជាងសត្វជើងពីរ ព្រះអង្គមិនញាប់ញ័រ ដោយលោកធម៌ ។ ខ្ញុំបានទៅកើតក្នុងឋានតុសិត នៅក្នុងផ្ទះកែវ សម្ផស្សត្រជាក់ក្ដី ក្ដៅក្ដី ខ្យល់ក្ដី មិនដែលពាល់ត្រូវខ្លួនខ្ញុំឡើយ ។ ក្នុងកប្បទី ៦៥ អំពីកប្បនេះ ខ្ញុំកើតជាស្ដេចចក្រពត្តិ នគររបស់ស្ដេចនោះ ឈ្មោះកាសិកៈ ដែលវិស្សុកម្មទេវបុត្រសាងថ្វាយ ។ (នគរនោះ) មានបណ្ដោយ ១០ យោជន៍ ទទឹង ៨ យោជន៍ ឈើក្ដី វល្លិក្ដី ដីស្អិតក្ដី មិនមានក្នុងនគរនោះឡើយ ។ ប្រាសាទឈ្មោះមង្គលៈ ដែលវិស្សុកម្មទេវបុត្រសាងថ្វាយ មានទទឹង១ យោជន៍ ទំហំកន្លះយោជន៍ ។ សសរ ៨.៤០០០ សុទ្ធជាវិការៈនៃមាស ប្រាសាទកំពូល ជាវិការៈនៃកែវមណី ដំបូលជាវិការៈនៃប្រាក់ ។

សព្វសោណ្ណមយំ យំ វិស្សុកម្មេន មាបិតំ
អជ្ឈាវុត្ថំ មយា ឃរំ យានទានស្សិទំ ផលំ ។
តេ សព្វេ អនុភោត្វាន ទេវមានុសកេ ភវេ
អជ្ជ បត្តាម្ហិ និព្វានំ សន្តបទំ(១) អនុត្តរំ ។
តិំសកប្បសហស្សម្ហិ(២) គោធិយំ មទាសហំ
ទុគ្គតឹ នាភិជានាមិ យានទានស្សិទំ ផលំ ។
កិលេសា ឈាបិតា មយ្ហំ ភវា សព្វេ សមូហតា
នាគោវ ពន្ធនំ ឆេត្វា វិហរាមិ អនាសវោ ។
ស្វាគតំ វត មេ អាសិ មម ពុទ្ធស្ស សន្តិកេ
តិស្សោ វិជ្ជា អនុប្បត្តា កតំ ពុទ្ធស្ស សាសនំ ។
បដិសម្ភិទា ចតស្សោ វិមោក្ខាបិច អដ្ឋិមេ
ឆឡភិញ្ញា សច្ឆិកតា កតំ ពុទ្ធស្ស សាសនន្តិ ។

---

១ ឱ. សន្តិបទំ ។ ម. សន្តិបទំ ឧត្តរំ ។ ២ ឱ. ចតុន្នវុតេ ឥតោ កប្បេ ។





ផ្ទះជាវិការៈនៃមាសទាំងអស់ ដែលវិស្សុកម្មទេវបុត្រ សាងថ្វាយហើយ ផ្ទះនុ៎ះខ្ញុំនៅអាស្រ័យហើយ នេះជាផលនៃការឲ្យខ្ទឿង ។ ខ្ញុំបានសោយទ្រព្យ ជារបស់ទេវតា និងមនុស្សទាំងអស់នោះហើយ ដល់នូវព្រះនិព្វាន ជាបទដ៏ស្ងប់ប្រសើរក្នុងថ្ងៃនេះ ។ ក្នុងកប្បទី ៣ ម៉ឺន ព្រោះហេតុដែលខ្ញុំបានធ្វើខ្ទឿងគោធិព្រឹក្ស ក្នុងកាលនោះ ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃការឲ្យខ្ទឿង ។ កិលេសទាំងឡាយខ្ញុំដុតបំផ្លាញហើយ ភពទាំងអស់ខ្ញុំ ដកចោលហើយ ខ្ញុំជាបុគ្គលមិនមានអាសវៈ ព្រោះបានកាត់ចំណង ដូចជាដំរីកាត់ផ្តាច់នូវទន្លីង ។ ឱ ! ដំណើរដែលខ្ញុំមក ក្នុងសំណាក់នៃព្រះពុទ្ធរបស់ខ្ញុំ ជាដំណើរល្អហ្ន៎ វិជ្ជា ៣ ខ្ញុំបានដល់ហើយ សាសនារបស់ព្រះពុទ្ធ ខ្ញុំបានធ្វើហើយ ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនា របស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ។

ឥត្ថំ សុទំ អាយស្មា ពោធិឃរការកោ ថេរោ

ឥមា គាថាយោ អភាសិត្ថាតិ ។

ពោធិឃរការកត្ថេរស្ស អបទានំ សមត្តំ ។

ឧទ្ទានំ

វិភេទកី(១) កោលផលី(២) ពិល្លភល្លាតកប្បទោ(៣)

ឧត្តលី អម្ពាដកី ចេវ(៤) អាសនី(៥) បាទបីឋកោ ។

វេទិកោ(៦) ពោធិឃរិកោ គាថាយោ គណិតាបិ ច(៧)

ឯកូនាសីតិកា សព្វា អស្មិំ វគ្គេ បកិត្តិតា ។

វិភេទកីវគ្គោ បញ្ចចត្តាឡីសោ ។

---

១ ឱ. វិភីតកី ។ ម. វិភេទកំ ។ ២ ឱ. កោលផលី ។ ៣ ឱ. ពល្លភល្លាតកប្បទោ ។ ម. ពិល្លភល្លាតកប្បិ ច ។ ៤ ឱ. និគ្រោធម្ពាដកី ចេវ ។ ម. និគ្រោធម្ពដកី ចេវ ។ ៥ ឱ. អាសនី ។ ៦ ឱ. វេទិកោ ។ ៧ ឱ. គណិតាវិហ ។



បានឮថា ព្រះពោធិឃរការកត្ថេរ មានអាយុ បានសម្ដែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

ចប់ពោធិឃរការកត្ថេរាបទាន ។

ឧទ្ទាន

វិភេទកពីជិយត្ថេរាបទាន ១ កោលទាយកត្ថេរាបទាន ១ ពិល្លផលិយត្ថេរាបទាន ១ ភល្លាតកទាយកត្ថេរាបទាន ១ ឧត្តាលបុប្ផិយត្ថេរាបទាន ១ អម្ពាដកិយត្ថេរាបទាន ១ សីហាសនិកត្ថេរាបទាន ១ បាទបីឋិយត្ថេរាបទាន ១ វេទិយការកត្ថេរាបទាន ១ ពោធិឃរការកត្ថេរាបទាន ១ គាថាទាំងឡាយ ដែលលោកសម្ដែងទុកហើយ ក្នុងវគ្គនេះ រាប់ទៅឃើញទាំងអស់ មានចំនួន ៧៩ គាថា ។

ចប់វិភេទកិវគ្គ ទី ៤៥ ។

---

## ឆចត្តាឡីសោ ជគតិវគ្គោ

## បឋមំ ជគតិទាយកត្ថេរាបទានំ

[៤១] ធម្មទស្សិស្ស មុនិនោ ពោធិយា បាទបុត្តមេ
បសន្នចិត្តោ សុមនោ ជគតឹ ការយឹ អហំ ។
ទរិតោ បព្វតាតោ វា រុក្ខតោ បតិតោ អហំ
ចុតោ បតិដ្ឋំ វិន្ទាមិ ជគតិយា ឥទំ ផលំ ។
ន មេ ចោរា វិហេសន្តិ(១) នាតិមញ្ញន្តិ ខត្តិយា
សព្វាមិត្តេតិក្កមាមិ ជគតិយា ឥទំ ផលំ ។
យំ យំ យោនុបបជ្ជាមិ ទេវត្តំ អថ មានុសំ
សព្វត្ថ បូជិតោ ហោមិ ជគតិយា ឥទំ ផលំ ។
អដ្ឋារសេ កប្បសតេ ជគតឹ ការយឹ អហំ
ទុគ្គតឹ នាភិជានាមិ ជគតិទានស្សិទំ ផលំ ។
កិលេសា ឈាបិតា មយ្ហំ ភវា សព្វេ សមូហតា
នាគោវ ពន្ធនំ ឆេត្វា វិហរាមិ អនាសវោ ។

---

១ ឱ. បលោភន្តិ ។

## ជគតិវគ្គ ទី ៤៦

## ជគតីទាយកត្ថេរាបទាន ទី ១

[៤១] ខ្ញុំមានចិត្តជ្រះថ្លា មានចិត្តរីករាយ បានឲ្យគេពូនផែនដី ជិតដើមពោធិព្រឹក្សដ៏ឧត្តម របស់ព្រះមហាមុនី ព្រះនាមធម្មទស្សី ។ ខ្ញុំរបូតធ្លាក់ក្នុងជ្រោះក្តី អំពីភ្នំក្តី អំពីដើមឈើក្តី រមែងបាននូវទីពឹង នេះជាផលនៃការពូនផែនដី ។ ពួកចោរទាំងឡាយ មិនហ៊ានបៀតបៀនខ្ញុំ ក្សត្រទាំងឡាយមិនហ៊ានមើលងាយខ្ញុំ ខ្ញុំកន្លងផុតនូវសត្រូវទាំងពួង នេះជាផលនៃការពូនផែនដី ។ ខ្ញុំកើតក្នុងកំណើតណា ៗ គឺជាទេវតា ឬជាមនុស្ស អ្នកផងតែងបូជាក្នុងទីទាំងពួង នេះជាផលនៃការពូនផែនដី ។ ក្នុងកប្បទី ១.៨០០ អំពីកប្បនេះ ព្រោះហេតុដែលខ្ញុំបានឲ្យគេពូនផែនដី ក្នុងកាលនោះ ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃការពូនផែនដី ។ កិលេសទាំងឡាយ ខ្ញុំដុតបំផ្លាញហើយ ភពទាំងពួង ខ្ញុំដកចោលហើយ ខ្ញុំមិនមានអាសវៈ ព្រោះបានកាត់បំណង់ ដូចជាដំរីកាត់ផ្តាច់នូវទន្ទឹង ។

ស្វាគតំ វត មេ អាសិ   មម ពុទ្ធស្ស សន្តិកេ
តិស្សោ វិជ្ជា អនុប្បត្តា   កតំ ពុទ្ធស្ស សាសនំ ។
បដិសម្ភិទា ចតស្សោ   វិមោក្ខាបិ ច អដ្ឋិមេ
ឆឡភិញ្ញា សច្ឆិកតា   កតំ ពុទ្ធស្ស សាសនន្តិ ។

ឥត្ថំ សុទំ អាយស្មា ជគតិទាយកោ ថេរោ ឥមា គាថាយោ អភាសិត្ថាតិ ។

ជគតិទាយកត្ថេរស្ស អបទានំ សមត្តំ ។

## ទុតិយំ មោរហត្ថិយត្ថេរាបទានំ

(៤៦) មោរហត្ថំ គហេត្វាន   ឧបេសិំ លោកនាយកំ
បសន្នចិត្តោ សុមនោ   មោរហត្ថំ អទាសហំ ។
ឥមិនា មោរហត្ថេន   ចេតនាបណិធីហិ ច
និព្វុតា មេ តយោ[១] អគ្គី   លភាមិ វិបុលំ សុខំ ។
អហោ ពុទ្ធា អហោ ធម្មា   អហោ នោ សត្ថុ សម្បទា
ទត្វានហំ មោរហត្ថំ   លភាមិ វិបុលំ សុខំ ។

១ ឱ. និព្វុត្តិ មេ តយោ ។ ម. និព្វាយិំសុ តយោ ។





ន ! ខ្ញុំមកល្អហើយ ក្នុងសំណាក់នៃព្រះពុទ្ធរបស់ខ្ញុំ វិជ្ជា ៣ ខ្ញុំបានដល់ហើយ សាសនារបស់ព្រះពុទ្ធ ខ្ញុំបានធ្វើហើយ ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនា របស់ព្រះពុទ្ធ ខ្ញុំក៏បាន ប្រតិបត្តិហើយ ។

បានឮថា ព្រះជគតិទាយកត្ថេរ មានអាយុ បានសម្តែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

ចប់ ជគតិទាយកត្ថេរាបទាន ។

## មោរហត្ថិយត្ថេរាបទាន ទី ២

(៤៦) ខ្ញុំមានចិត្តជ្រះថ្លា មានចិត្តរីករាយ បានយកផ្លិតស្លាបក្ងោក ចូលទៅថ្វាយព្រះលោកនាយក ។ ភ្លើងទាំង ៣ របស់ខ្ញុំរលត់ហើយ ខ្ញុំបាននូវសេចក្តីសុខដ៏ធំទូលាយ ដោយសារផ្លិតស្លាបក្ងោកនេះផង ដោយការតំកល់នូវចេតនានេះផង ។ ឱហ្ន៎ ព្រះពុទ្ធ ឱហ្ន៎ ព្រះធម៌ ឱហ្ន៎ សម្បទារបស់ព្រះសាស្តា នៃយើងទាំងឡាយ ខ្ញុំបាននូវសេចក្តីសុខដ៏ធំទូលាយ ព្រោះបានថ្វាយផ្លិតស្លាបក្ងោក ។

ទិជត្តិ(១) ចេតុតា មយ្ហំ ភវា សព្វេ សមូហតា
សញ្ញាសក បរិជ្ជិណ្ណា(២) ឆិន្នានិ ពុទ្ធកេ ។
បជាត្តិសេ វគោ ការេ្យ យំ នាម មធិគ្គតា
ទុគ្គតិំ ជាតិជាជាមិ មោឃរាជស្សិមំ ផលំ ។
កិលេសា ឈាបិតា មយ្ហំ ភវា សព្វេ សមូហតា
នាគោវ ពន្ធនំ ឆេត្វា វិហរាមិ អនាសវោ ។
ស្វាគតំ វត មេ អាសិ មម ពុទ្ធស្ស សន្តិកេ
តិស្សោ វិជ្ជា អនុប្បត្តា កតំ ពុទ្ធស្ស សាសនំ ។
បដិសម្ភិទា ចតស្សោ វិមោក្ខាបិ ច អដ្ឋិមេ
ឆឡភិញ្ញា សច្ឆិកតា កតំ ពុទ្ធស្ស សាសនន្តិ ។

ឥត្ថំ សុទំ អាយស្មា មោឃរាជោ ថេរោ ឥមា គាថាយោ អភាសិត្ថាតិ ។

មោឃរាជត្ថេរស្ស អបទានំ សមត្តំ ។

១ ឱ. តិទត្តិ ។ ២ ម. សញ្ញាសវបរិជ្ជិណ្ណោ ។





ភ្លើងទាំង ៣ របស់ខ្ញុំរលត់ហើយ ភពទាំងពួង ខ្ញុំដកចោលហើយ អាសវៈទាំងពួងអស់រលីងហើយ ឥឡូវនេះ ភពថ្មីមិនមានទៀតឡើយ ។ ក្នុងកប្បទី ៣១ អំពីកប្បនេះ ព្រោះហេតុដែលខ្ញុំបានឲ្យទាន ក្នុងកាលនោះ ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃផ្តិលស្លាបក្អែក ។ កិលេសទាំងឡាយខ្ញុំដុតបំផ្លាញហើយ ភពទាំងពួង ខ្ញុំដកចោលអស់ហើយ ខ្ញុំមិនមានអាសវៈ ព្រោះបានកាត់ចំណង ដូចជាដំរីដ៏ប្រសើរកាត់ផ្តាច់នូវចំណង ។ ឱ ! ខ្ញុំមកល្អហើយក្នុងសំណាក់នៃព្រះពុទ្ធរបស់ខ្ញុំ វិជ្ជា ៣ ខ្ញុំបានដល់ហើយ សាសនារបស់ព្រះពុទ្ធ ខ្ញុំបានធ្វើហើយ ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ។

បានឮថា ព្រះមោឃរាជត្ថេរ មានអាយុ បានសម្តែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

ចប់ មោឃរាជត្ថេរាបទាន ។

## តតិយំ សីហាសនពីជិយត្ថេរាបទានំ

(៤៣) តិស្សស្សាហំ ភគវតោ ពោធិរុក្ខំ អវន្ទិហំ
បគ្គយ្ហ វីជនិំ តត្ថ សីហាសនមវីជហំ(១) ។
ឆន្នវុតេ ឥតោ កប្បេ សីហាសនមវីជហំ(២)
ទុគ្គតិំ នាភិជានាមិ វីជនាយ ឥទំ ផលំ ។
កិលេសា ឈាបិតា មយ្ហំ ភវា សព្វេ សមូហតា
នាគោវ ពន្ធនំ ឆេត្វា វិហរាមិ អនាសវោ ។
ស្វាគតំ វត មេ អាសិ មម ពុទ្ធស្ស សន្តិកេ
តិស្សោ វិជ្ជា អនុប្បត្តា កតំ ពុទ្ធស្ស សាសនំ ។
បដិសម្ភិទា ចតស្សោ វិមោក្ខាបិច អដ្ឋិមេ
ឆឡភិញ្ញា សច្ឆិកតា កតំ ពុទ្ធស្ស សាសនន្តិ ។

ឥត្ថំ សុទំ អាយស្មា សីហាសនពីជិយោ ថេរោ ឥមា គាថាយោ អភាសិត្ថាតិ ។

សីហាសនពីជិយត្ថេរស្ស អបទានំ សមត្តំ ។

---

១-២ ឱ. សីហាសនមវីជហំ ។ ម. សីហាសនមវីជិហំ ។



## សីហាសនពីជនិយត្ថេរាបទាន ទី ៣

(៤៣) ខ្ញុំបានទៅថ្វាយបង្គំពោធិព្រឹក្ស របស់ព្រះមានព្រះភាគ ព្រះនាមតិស្សៈ រួចហើយខ្ញុំកាន់ផ្លិតបក់ទូលសីហាសនៈ (អាសនៈដ៏ប្រសើរ) ដែលគេតំកល់ក្នុងទីនោះ ។ ក្នុងកប្បទី ៩៦ អំពីកប្បនេះ ព្រោះហេតុដែលខ្ញុំបានបក់ទូលសីហាសនៈ ក្នុងកាលនោះ ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃការបក់ ។ កិលេសទាំងឡាយ ខ្ញុំដុតបំផ្លាញហើយ ភពទាំងពួង ខ្ញុំដកចោលហើយ ខ្ញុំមិនមានអាសវៈ ព្រោះបានកាត់ចំណង ដូចជាដំរីកាត់ផ្ដាច់នូវខ្នង ។ ឱ! ខ្ញុំមកល្អហើយ ក្នុងសំណាក់នៃព្រះពុទ្ធរបស់ខ្ញុំ វិជ្ជា ៣ ខ្ញុំបានដល់ហើយ សាសនារបស់ព្រះពុទ្ធ ខ្ញុំបានធ្វើហើយ ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនា របស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ។

បានឮថា ព្រះសីហាសនពីជិយត្ថេរ មានអាយុ បានសម្ដែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

ចប់ សីហាសនពីជនិយត្ថេរាបទាន ។

## ចតុត្ថំ តិណុក្កធារិយត្ថេរាបទានំ

(៤៤) បទុមុត្តរស្ស ពុទ្ធស្ស ពោធិយា បាទបុត្តមេ[១]
បសន្នចិត្តោ សុមនោ តយោ ឧក្កេ អធារយឹ ។
សតសហស្សិតោ កប្បេ យំ ឧក្កមធារយឹ
ទុគ្គតឹ នាភិជានាមិ ឧក្កាទានស្សិទំ ផលំ ។
កិលេសា ឈាបិតា មយ្ហំ ភវា សព្វេ សមូហតា
នាគោវ ពន្ធនំ ឆេត្វា វិហរាមិ អនាសវោ ។
ស្វាគតំ វត មេ អាសិ មម ពុទ្ធស្ស សន្តិកេ
តិស្សោ វិជ្ជា អនុប្បត្តា កតំ ពុទ្ធស្ស សាសនំ ។
បដិសម្ភិទា ចតស្សោ វិមោក្ខាបិ ច អដ្ឋិមេ
ឆឡភិញ្ញា សច្ឆិកតា កតំ ពុទ្ធស្ស សាសនន្តិ ។

ឥត្ថំ សុទំ អាយស្មា តិណុក្កធារិយោ ថេរោ ឥមា គាថាយោ អភាសិត្ថាតិ ។

តិណុក្កធារិយត្ថេរស្ស អបទានំ សមត្តំ ។

---

១ ឱ. បាទុត្តមេ ។

## តិណុក្កធារិយត្ថេរាបទាន ទី ៤

(៤៤) ខ្ញុំមានចិត្តជ្រះថ្លា មានចិត្តរីករាយ បានកាន់គប់ភ្លើង ៣ (តំកល់ទុក) ត្រង់ដើមពោធិព្រឹក្សដ៏ឧត្តម របស់ព្រះពុទ្ធ ព្រះនាមបទុមុត្តរៈ ។ ក្នុងកប្បទីមួយសែន អំពីកប្បនេះ ព្រោះហេតុដែលខ្ញុំកាន់គប់ភ្លើង ក្នុងកាលនោះ ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃការឲ្យនូវគប់ភ្លើង ។ កិលេសទាំងឡាយ ខ្ញុំដុតបំផ្លាញហើយ ភពទាំងពួង ខ្ញុំដកហើយ ខ្ញុំមិនមានអាសវៈ ព្រោះបានកាត់ចំណងដូចជាដំរីកាត់ផ្ដាច់នូវទន្លីង ។ ឱ ខ្ញុំមកល្អហើយ ក្នុងសំណាក់នៃព្រះពុទ្ធរបស់ខ្ញុំ វិជ្ជា ៣ ខ្ញុំបានដល់ហើយ សាសនារបស់ព្រះពុទ្ធ ខ្ញុំបានធ្វើហើយ ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនា របស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ។

បានឮថា ព្រះតិណុក្កធារិយត្ថេរ មានអាយុ បានសម្ដែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

ចប់ តិណុក្កធារិយត្ថេរាបទាន ។

## បញ្ចមំ អក្កមនទាយកត្ថេរាបទានំ

(៤៥) កកុសន្ធស្ស មុនិនោ ព្រាហ្មណស្ស វុសីមតោ
ទិវាវិហារំ វជតោ អក្កមនមទាសហំ ។
ឥមស្មឹយេវ កប្បស្មឹ យំ ទានមទទឹ តទា
ទុគ្គតឹ នាភិជានាមិ អក្កមនស្សិទំ ផលំ ។
កិលេសា ឈាបិតា មយ្ហំ ភវា សព្វេ សមូហតា
នាគោវ ពន្ធនំ ឆេត្វា វិហរាមិ អនាសវោ ។
ស្វាគតំ វត មេ អាសិ មម ពុទ្ធស្ស សន្តិកេ
តិស្សោ វិជ្ជា អនុប្បត្តា កតំ ពុទ្ធស្ស សាសនំ ។
បដិសម្ភិទា ចតស្សោ វិមោក្ខាបិច អដ្ឋិមេ
ឆឡភិញ្ញា សច្ឆិកតា កតំ ពុទ្ធស្ស សាសនំ ។

ឥត្ថំ សុទំ អាយស្មា អក្កមនទាយកោ ថេរោ ឥមា គាថាយោ អភាសិត្ថាតិ ។

អក្កមនទាយកត្ថេរស្ស អបទានំ សមត្តំ ។



## អក្កមនទាយកត្ថេរាបទាន ទី ៥

(៤៥) ខ្ញុំបានថ្វាយកម្រាលសម្រាប់ជាន់ ដល់ព្រះមុនី ព្រះនាមកកុសន្ធៈ ជាខីណាស្រពព្រាហ្មណ៍ មានព្រហ្មចរិយធម៌នៅហើយ ដែលស្តេចទៅកាន់ទីជាទីសម្រាក ក្នុងវេលាថ្ងៃ ។ ក្នុងកប្បនេះឯង ព្រោះហេតុដែលខ្ញុំបានថ្វាយទានក្នុងកាលនោះ ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃកម្រាលសម្រាប់ជាន់ ។ កិលេសទាំងឡាយ ខ្ញុំដុតបំផ្លាញហើយ ភពទាំងអស់ ខ្ញុំដកចោលហើយ ខ្ញុំមិនមានអាសវៈ ព្រោះបានកាត់ចំណង ដូចដំរីកាត់ផ្តាច់នូវចំណង ។ ឱ! ខ្ញុំមកល្អហើយ ក្នុងសំណាក់នៃព្រះពុទ្ធរបស់ខ្ញុំ វិជ្ជា ៣ ខ្ញុំបានដល់ហើយ សាសនារបស់ព្រះពុទ្ធ ខ្ញុំបានធ្វើហើយ ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ។

បានឮថា ព្រះអក្កមនទាយកត្ថេរ មានអាយុ បានសម្តែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

ចប់ អក្កមនទាយកត្ថេរាបទាន ។

## ឆដ្ឋំ វនកោរណ្ឌិយត្ថេរាបទានំ

(៦៦) សិទ្ធត្ថស្ស ភគវតោ លោកជេដ្ឋស្ស តាទិនោ
វនេ កោរណ្ឌមាទាយ ពុទ្ធស្ស អភិរោបយិំ ។
ចតុន្នវុតេ ឥតោ កប្បេ យំ បុប្ផមភិរោបយិំ
ទុគ្គតឹ នាភិជានាមិ ពុទ្ធបូជាយិទំ ផលំ ។
កិលេសា ឈាបិតា មយ្ហំ ភវា សព្វេ សមូហតា
នាគោវ ពន្ធនំ ឆេត្វា វិហរាមិ អនាសវោ ។
ស្វាគតំ វត មេ អាសិ មម ពុទ្ធស្ស សន្តិកេ
តិស្សោ វិជ្ជា អនុប្បត្តា កតំ ពុទ្ធស្ស សាសនំ ។
បដិសម្ភិទា ចតស្សោ វិមោក្ខាបិច អដ្ឋិមេ
ឆឡភិញ្ញា សច្ឆិកតា កតំ ពុទ្ធស្ស សាសនំ ។

ឥត្ថំ សុទំ អាយស្មា វនកោរណ្ឌិយោ ថេរោ ឥមា គាថាយោ អភាសិត្ថាតិ ។

វនកោរណ្ឌិយត្ថេរស្ស អបទានំ សមត្តំ ។

វីសតិមំ ភាណវារំ ។

## វនកោរណ្ឌិយត្ថេរាបទាន ទី ៦

(៦៦) ខ្ញុំបានយកផ្កាកន្ទុយក្អែកក្នុងព្រៃ ទៅបូជាចំពោះព្រះពុទ្ធព្រះនាមសិទ្ធត្ថៈ ជាព្រះភាគ ជាធំក្នុងលោក ទ្រង់មិនញាប់ញ័រដោយលោកធម៌ ។ ក្នុងកប្បទី ៩៤ អំពីកប្បនេះ ព្រោះហេតុដែលខ្ញុំបានបូជាផ្កា ក្នុងកាលនោះ ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃពុទ្ធបូជា កិលេសទាំង-ឡាយ ខ្ញុំដុតបំផ្លាញហើយ ភពទាំងអស់ ខ្ញុំដកចោលហើយ ខ្ញុំមិនមានអាសវៈ ព្រោះបានកាត់ចំណង ដូចជាដំរីកាត់ផ្តាច់ចំណងទន្លីង ។ ឱ! ខ្ញុំមកល្អហើយ ក្នុងសំណាក់នៃព្រះពុទ្ធរបស់ខ្ញុំ វិជ្ជា ៣ ខ្ញុំបានដល់ហើយ សាសនារបស់ព្រះពុទ្ធ ខ្ញុំបានធ្វើហើយ ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ។

បានឮថា ព្រះវនកោរណ្ឌិយត្ថេរ មានអាយុ បានសំដែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

ចប់ វនកោរណ្ឌិយត្ថេរាបទាន ។

ចប់ ភាណវារៈ ទី ២០ ។

# សត្តមំ ឯកច្ឆត្តិយត្ថេរាបទានំ

[៤៧] អង្គារជាតា បឋវី កុក្កុឡានុគតា មហី
បទុមុត្តរោ ភគវា អព្ភោកាសម្ហិ ចង្កមិ ។
បណ្ឌរំ ឆត្តមាទាយ អទ្ធានំ បដិបជ្ជហំ
តត្ថ ទិស្វាន សម្ពុទ្ធំ វិត្តិ មេ ឧបបជ្ជថ ។
មរីចិយោផុដា ភូមិ អង្គារាវ មហី អយំ
ឧបហន្តិ[១] មហាវាតា សរីរស្សុខេបនា[២] ។
សីតំ ឧណ្ហំ វិហនតិ វាតាតបនិវារណំ
បដិគ្គណ្ហ ឥមំ ឆត្តំ ផស្សយិស្សាមិ និព្វុតិំ ។
អនុកម្បកោ ការុណិកោ បទុមុត្តរោ មហាយសោ
មម សង្កប្បមញ្ញាយ បដិគ្គណ្ហិ តទា ជិនោ ។
តិំសកប្បានិ ទេវិន្ទោ ទេវរជ្ជមការយិំ
សតានំ បញ្ចក្ខត្តុំ ច ចក្កវត្តិ អហោសហំ ។

១ ឱ. ឧបហិយន្តិ ។ ២ ឱ. សរីរស្សុខេបនា ។ ម. សរីរស្សុខេបនា ។





# ឯកច្ឆត្តិយត្ថេរាបទាន ទី ៧

[៤៧] ផែនដីកំពុងក្តៅដូចរងើកភ្លើង ផែនដីកំពុងប្រព្រឹត្តទៅដូចជាផេះ ព្រះមានព្រះភាគព្រះនាមបទុមុត្តរៈ ទ្រង់ចង្ក្រមក្នុងទីវាល ។ ខ្ញុំបានកាន់ឆ័ត្រស ដើរទៅកាន់ផ្លូវឆ្ងាយ ខ្ញុំឃើញព្រះសម្ពុទ្ធហើយ ក៏កើតគំនិតក្នុងចិត្តនោះថា ផែនដីផ្សាយចេញនូវថ្ងៃបណ្តើរក្តៅ ផែនដីនេះក្តៅដូចជារងើកភ្លើង ខ្យល់ធំខ្លាំងតាំងឡើង បំបុកនូវធូលីទៅកាន់សរីរកាយ ។ ឆត្រនេះ សម្រាប់ការពារខ្យល់និងកំដៅថ្ងៃ កំចាត់បង់នូវត្រជាក់និងក្តៅ សូមព្រះអង្គទទួលយកនូវឆត្រនេះចុះ ខ្ញុំព្រះអង្គនឹងបាននូវព្រះនិព្វាន ។ កាលនោះ ព្រះជិនស្រី ព្រះនាមបទុមុត្តរៈ មានយសច្រើន ទ្រង់អនុគ្រោះ ប្រកបដោយសេចក្តីករុណា ទ្រង់បានទទួលយក ព្រោះជ្រាបនូវតម្រិះរបស់ខ្ញុំ ។ ខ្ញុំកើតជាព្រះឥន្ទ្រ ជាស្តេចទេវតា សោយរាជ្យក្នុងទេវលោក អស់ ៣០ កប្ប បានជាស្តេចចក្រពត្តិ អស់ ៥០០ ដង ។

សត្តមំ ឯកច្ឆត្តិយត្ថេរាបទានំ

បទេសរជ្ជំ វិបុលំ   គណនាតោ អសង្ខិយំ
អនុភោមិ សកំ កម្មំ   បុព្វេ សុកតមត្តនោ ។
អយំ មេ បច្ឆិមា ជាតិ   ចរិមោ វត្តតេ ភវោ
អជ្ជាបិ សេតច្ឆត្តំ មេ   សព្វកាលំ ធរីយតិ ។
សតសហស្សេ ឥតោ កប្បេ   យំ ឆត្តមទទឹ តទា
ទុគ្គតឹ នាភិជានាមិ   ឆត្តទានស្សិទំ ផលំ ។
កិលេសា ឈាបិតា មយ្ហំ   ភវា សព្វេ សមូហតា
នាគោវ ពន្ធនំ ឆេត្វា   វិហរាមិ អនាសវោ ។
ស្វាគតំ វត មេ អាសិ   មម ពុទ្ធស្ស សន្តិកេ
តិស្សោ វិជ្ជា អនុប្បត្តា   កតំ ពុទ្ធស្ស សាសនំ ។
បដិសម្ភិទា ចតស្សោ   វិមោក្ខាបិច អដ្ឋិមេ
ឆឡភិញ្ញា សច្ឆិកតា   កតំ ពុទ្ធស្ស សាសនន្តិ ។

ឥត្ថំ សុទំ អាយស្មា ឯកច្ឆត្តិយោ ថេរោ ឥមា គាថាយោ អភាសិត្ថាតិ ។

ឯកច្ឆត្តិយត្ថេរស្ស អបទានំ សមត្តំ ។



ឯកច្ឆត្តិយត្ថេរាបទាន ទី ៧

បានសោយបទេសរាជ្យ ដ៏ទូលាយ រាប់ជាតិមិនអស់ ខ្ញុំបានទទួលផលនៃកម្មរបស់ខ្លួន ដែលខ្លួនធ្វើល្អហើយ ក្នុងកាលមុន ។ នេះជាតិជាទីបំផុតរបស់ខ្ញុំ ភពខាងក្រោយកំពុងប្រព្រឹត្តទៅ ថ្ងៃនេះឆត្រស គេតែងបាំងឲ្យខ្ញុំ សព្វ ៗ កាល ។ ក្នុងកប្បទីមួយសែន អំពីកប្បនេះ ព្រោះហេតុដែលខ្ញុំបានថ្វាយឆត្រក្នុងកាលនោះ ខ្ញុំមិនដែលស្គាល់ទុគ៌តិ នេះជាផលនៃការថ្វាយឆត្រ ។ កិលេសទាំងឡាយ ខ្ញុំដុតបំផ្លាញហើយ ភពទាំងអស់ ខ្ញុំដកចោលហើយ ខ្ញុំមិនមានអាសវៈ ព្រោះបានកាត់បំណង់ ដូចជាដំរីកាត់ផ្តាច់ខ្សែទន្លីង ។ ឱ ! ខ្ញុំមកល្អហើយ ក្នុងសំណាក់នៃព្រះពុទ្ធរបស់ខ្ញុំ វិជ្ជា ៣ ខ្ញុំបានដល់ហើយ សាសនារបស់ព្រះពុទ្ធ ខ្ញុំបានធ្វើហើយ ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនា របស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ។

បានឮថា ព្រះឯកច្ឆត្តិយត្ថេរ មានអាយុ បានសម្តែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

ចប់ ឯកច្ឆត្តិយត្ថេរាបទាន ។

## អដ្ឋមំ ជាតិបុប្ផិយត្ថេរាបទានំ

(៤៨) បរិនិព្វុតេ ភគវតិ បទុមុត្តរេ មហាយសេ
បុប្ផចង្កោដកោ គហេត្វា(១) សរីរំ អភិរោបយឹ ។
តត្ថ ចិត្តំ បសាទេត្វា និម្មានំ អគមាសហំ
ទេវលោកគតោ សន្តោ បុញ្ញកម្មំ ចរាមហំ(២) ។
អម្ពរា បុប្ផវស្សោ មេ សព្វកាលំ បវស្សតិ
សម្ភវាមិ(៣) មនុស្សេ វេ(៤) រាជា ហោមិ មហាយសោ ។
តហឹ កុសុមវស្សោ មេ អភិវស្សតិ សព្វទា
តាយេសុ(៥) បុប្ផបូជាយ វាហសា សព្វទស្សិនោ ។
អយំ បច្ឆិមកោ មយ្ហំ ចរិមោ វត្តតេ ភវោ
អជ្ជាបិ បុប្ផវស្សោ មេ អភិវស្សតិ សព្វទា ។

---

១ ឱ. បុប្ផចង្កោដិកេ គត្វា ។ ម. បុប្ផចង្កោដកេ គត្វា ។ ២ ឱ.ម. សរាមហំ ។ ៣ ឱ.ម. សំសរាមិ ។ ៤ ឱ. ចេ ។ ម. ច ។ ៥ ឱ. តាយេវ ។ ម. តស្សេវ ។



## ជាតិបុប្ផិយត្ថេរាបទានទី ៨

(៤៨) កាលព្រះមានព្រះភាគ ព្រះនាមបទុមុត្តរៈ មានយសធំ ទ្រង់បរិនិព្វានហើយ ខ្ញុំយកផ្កាដាក់ក្នុងប្រអប់ ទៅបូជាទូលព្រះសរីរៈព្រះអង្គ ។ ព្រោះញុំាងចិត្តឲ្យជ្រះថ្លា ក្នុងព្រះសរីរៈនោះ ខ្ញុំក៏បានទៅកើតក្នុងទេវលោក ឈ្មោះនិម្មានរតី លុះខ្ញុំទៅកើតក្នុងទេវលោកហើយ រលឹកឃើញនូវបុញ្ញកម្មនោះ ។ ភ្លៀងផ្កាបង្អុរចុះមកអំពីអាកាស សម្រាប់ខ្ញុំ សព្វ ៗ កាល ខ្ញុំកើតក្នុងពួកមនុស្ស បានជាស្តេចមានយសច្រើន ។ ភ្លៀងផ្កាបង្អុរចុះមកក្នុងទីនោះ សព្វ ៗ កាល សម្រាប់ខ្ញុំ ដែលជាអ្នកឃើញនូវធម៌ទាំងពួង ដោយហេតុព្រោះការបូជាផ្កា ចំពោះព្រះសរីរកាយនៃព្រះពុទ្ធ ។ នេះភពជាទីបំផុតរបស់ខ្ញុំ ភពខាងក្រោយ កំពុងប្រព្រឹត្តទៅ ថ្ងៃនេះ ភ្លៀងផ្កាបង្អុរចុះ សម្រាប់ខ្ញុំ ក្នុងកាលទាំងពួង ។

សតសហស្សិតោ កប្បេ យំ បុប្ផំ អភិរោបយិំ

ទុគ្គតឹ នាភិជានាមិ បុប្ផបូជាយិទំ ផលំ ។

កិលេសា ឈាបិតា មយ្ហំ ភវា សព្វេ សមូហតា

នាគោវ ពន្ធនំ ឆេត្វា វិហរាមិ អនាសវោ ។

ស្វាគតំ វត មេ អាសិ មម ពុទ្ធស្ស សន្តិកេ

តិស្សោ វិជ្ជា អនុប្បត្តា កតំ ពុទ្ធស្ស សាសនំ ។

បដិសម្ភិទា ចតស្សោ វិមោក្ខាបិច អដ្ឋិមេ

ឆឡភិញ្ញា សច្ឆិកតា កតំ ពុទ្ធស្ស សាសនន្តិ ។

ឥត្ថំ សុទំ អាយស្មា ជាតិបុប្ផិយោ ថេរោ ឥមា គាថាយោ អភាសិត្ថាតិ ។

ជាតិបុប្ផិយត្ថេរស្ស អបទានំ សមត្តំ ។

ក្នុងកប្បទីមួយសែន អំពីកប្បនេះ ព្រោះហេតុដែលខ្ញុំបានបូជាផ្កា ក្នុងកាលនោះ ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃការបូជានូវព្រះសរីរកាយ ។ កិលេសទាំងឡាយ ខ្ញុំដុតបំផ្លាញហើយ ភពទាំងអស់ ខ្ញុំដកចោលហើយ ខ្ញុំមិនមានអាសវៈ ព្រោះបានកាត់បំណង ដូចដំរីកាត់ផ្តាច់នូវចំណង ។ ឱ! ខ្ញុំមកល្អហើយ ក្នុងសំណាក់នៃព្រះពុទ្ធរបស់ខ្ញុំ វិជ្ជា ៣ ខ្ញុំបានដល់ហើយ សាសនា របស់ព្រះពុទ្ធ ខ្ញុំបានធ្វើហើយ ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនា របស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ។

បានឮថា ព្រះជាតិបុប្ផិយត្ថេរ មានអាយុ បានសំដែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

ចប់ ជាតិបុប្ផិយត្ថេរាបទាន ។

## នវមំ សត្តិបណ្ណិយត្ថេរាបទានំ

[៨៩] នីហរន្តេ សរីរម្ហិ វជ្ជមានាសុ ភេរិសុ
បសន្នចិត្តោ សុមនោ សត្តិបុប្ផំ អបូជយឹ(១) ។
សតសហស្សេ ឥតោ កប្បេ យំ បុប្ផំ អភិបូជយឹ
ទុគ្គតឹ នាភិជានាមិ បុប្ផបូជាយិទំ ផលំ ។
កិលេសា ឈាបិតា មយ្ហំ ភវា សព្វេ សមូហតា
នាគោវ ពន្ធនំ ឆេត្វា វិហរាមិ អនាសវោ ។
ស្វាគតំ វត មេ អាសិ មម ពុទ្ធស្ស សន្តិកេ
តិស្សោ វិជ្ជា អនុប្បត្តា កតំ ពុទ្ធស្ស សាសនំ ។
បដិសម្ភិទា ចតស្សោ វិមោក្ខាបិ ច អដ្ឋិមេ
ឆឡភិញ្ញា សច្ឆិកតា កតំ ពុទ្ធស្ស សាសនន្តិ ។

ឥត្ថំ សុទំ អាយស្មា សត្តិបណ្ណិយោ(២) ថេរោ ឥមា គាថាយោ អភាសិត្ថាតិ ។

សត្តិបណ្ណិយត្ថេរស្ស អបទានំ សមត្តំ ។

---

១ ម. បត្តិបុប្ផមបូជយឹ ។ ឱ. សត្តិបុប្ផមបូជយឹ ។ ២ ម. បត្តិបុប្ផិយោ ។





## សត្តិបណ្ណិយត្ថេរាបទាន ទី ៩

(៨៩) កាលព្រះសរីរៈ (នៃព្រះសម្ពុទ្ធ) ដែលពួកជនកំពុងនាំចេញ ស្គរគេកំពុងប្រគំថ្វាយ ខ្ញុំមានចិត្តជ្រះថ្លា មានចិត្តរីករាយ បានបូជាផ្កាម្ទេះ ។ ក្នុងកប្បទីមួយសែន អំពីកប្បនេះ ព្រោះហេតុដែលខ្ញុំបានបូជាផ្កា ក្នុងកាលនោះ ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃការបូជាព្រះសរីរៈ ។ កិលេសទាំងឡាយ ខ្ញុំដុតបំផ្លាញហើយ ភពទាំងអស់ ខ្ញុំដកចោលហើយ ខ្ញុំមិនមានអាសវៈ ព្រោះបានកាត់ចំណង ដូចជាដំរីកាត់ផ្តាច់នូវចំណង ។ ឱ! ខ្ញុំមកល្អហើយ ក្នុងសំណាក់នៃព្រះពុទ្ធរបស់ខ្ញុំ វិជ្ជា ៣ ខ្ញុំបានដល់ហើយ សាសនារបស់ព្រះពុទ្ធ ខ្ញុំបានធ្វើហើយ ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនា របស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ។

បានឮថា ព្រះសត្តិបណ្ណិយត្ថេរ មានអាយុ បានសំដែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

ចប់ សត្តិបណ្ណិយត្ថេរាបទាន ។

## ទសមំ គន្ធបូជកត្ថេរាបទានំ

(៥០) ចិតកេសុ ឈាយមានេសុ(១) នានាគន្ធេ សមាហតេ(២)
បសន្នចិត្តោ សុមនោ គន្ធមុដ្ឋឹ អបូជយឹ ។
សតសហស្សេ ឥតោ កប្បេ ចិតកំ យំ អបូជយឹ
ទុគ្គតឹ នាភិជានាមិ ចិតបូជាយិទំ ផលំ ។
កិលេសា ឈាបិតា មយ្ហំ ភវា សព្វេ សមូហតា
នាគោវ ពន្ធនំ ឆេត្វា វិហរាមិ អនាសវោ ។
ស្វាគតំ វត មេ អាសិ មម ពុទ្ធស្ស សន្តិកេ
តិស្សោ វិជ្ជា អនុប្បត្តា កតំ ពុទ្ធស្ស សាសនំ ។
បដិសម្ភិទា ចតស្សោ វិមោក្ខាបិ ច អដ្ឋិមេ
ឆឡភិញ្ញា សច្ឆិកតា កតំ ពុទ្ធស្ស សាសនន្តិ ។

ឥត្ថំ សុទំ អាយស្មា គន្ធបូជកោ ថេរោ ឥមា គាថាយោ អភាសិត្ថាតិ ។

គន្ធបូជកត្ថេរស្ស អបទានំ សមត្តំ ។

---

១ ឱ.ម. ចិតេសុ កិរមានេសុ ។ ម. ចិតកេសុ កិរមានេសុ ។ ២ ឱ. សមាគតេ ។

## គន្ធបូជកត្ថេរាបទាន ទី ១០

(៥០) កាលពួកជនកំពុងធ្វើជើងថ្ករ កំពុងរាំបកគ្រឿងក្រអូបផ្សេង ៗ ខ្ញុំក៏មានចិត្តជ្រះថ្លា មានចិត្តរីករាយ បានបូជានូវគ្រឿងក្រអូបមួយក្ដាប់ ។ ក្នុងកប្បទីមួយសែន អំពីកប្បនេះ ព្រោះហេតុដែលខ្ញុំបានបូជាជើងថ្ករ ក្នុងកាលនោះ ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃការបូជាជើងថ្ករ ។ កិលេសទាំងឡាយ ខ្ញុំដុតបំផ្លាញហើយ ភពទាំងអស់ ខ្ញុំបានដកចោលហើយ ខ្ញុំមិនមានអាសវៈ ព្រោះបានកាត់បំណង ដូចជាដំរីកាត់ផ្ដាច់នូវចំណង ។ ឱ ! ខ្ញុំមកល្អហើយ ក្នុងសំណាក់នៃព្រះពុទ្ធរបស់ខ្ញុំ វិជ្ជា ៣ ខ្ញុំបានដល់ហើយ សាសនា របស់ព្រះពុទ្ធ ខ្ញុំបានធ្វើហើយ ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនា របស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ។

បានឮថា ព្រះគន្ធបូជកត្ថេរ មានអាយុ បានសម្ដែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

ចប់ គន្ធបូជកត្ថេរាបទាន ។

## ឧទ្ទានំ

ជគតី មោរហត្ថិ(១) ច អាសនំ ឧក្កធារកោ
អក្កមំ វនកោរណ្ឌិ ឆត្តោ ជាតិបុប្ផកោ ។
សត្តិបណ្ណិយោ ថេរោ ច(២) ទសមោ គន្ធបូជកោ
សត្តសដ្ឋី ច គាថាយោ គណិតាយោ វិភាវិភិ ។

ជគតិទាយកវគ្គោ ឆចត្តាលីសមោ ។

---

១ ឱ. ម. មោរហត្ថី ច ។ ២ ឱ. សត្តិបណ្ណី ច យោ ថេរោ ។ ម. បត្តិបុប្ផិ ច យោ ថេរោ ។



## ឧទ្ទាន

ជគតិទាយកត្ថេរាបទាន ១ មោរហត្ថិយត្ថេរាបទាន ១ សីហា-សនពីជិយត្ថេរាបទាន ១ តិណុក្កធារិយត្ថេរាបទាន ១ អក្ក-មនទាយកត្ថេរាបទាន ១ វនកោរណ្ឌិយត្ថេរាបទាន ១ ឯក-ច្ឆត្តិយត្ថេរាបទាន ១ ជាតិបុប្ផិយត្ថេរាបទាន ១ សត្តិបណ្ណិ-យត្ថេរាបទាន ១ គន្ធបូជកត្ថេរាបទាន ជាគម្រប់ ១០ ឯគាថា មានចំនួន ៦៧ ដែលពួកអ្នកប្រាជ្ញរាប់ឃើញហើយ ។

ចប់ ជគតិទាយកវគ្គ ទី ៤៦ ។

## សត្តបញ្ញាសមោ សាលបុប្ផិវគ្គោ

## បឋមំ សាលកុសុមិយត្ថេរាបទានំ

(៥១) បរិនិព្វុតេ ភគវតិ ជលជុត្តមនាមកេ
អារោបិតម្ហិ ចិតកេ សាលបុប្ផំ អបូជយឹ(១) ។
សតសហស្សិតោ កប្បេ យំ បុប្ផមភិបូជយឹ
ទុគ្គតឹ នាភិជានាមិ ចិតបូជាយិទំ ផលំ ។
កិលេសា ឈាបិតា មយ្ហំ ភវា សព្វេ សមូហតា
នាគោវ ពន្ធនំ ឆេត្វា វិហរាមិ អនាសវោ ។
ស្វាគតំ វត មេ អាសិ មម ពុទ្ធស្ស សន្តិកេ
តិស្សោ វិជ្ជា អនុប្បត្តា កតំ ពុទ្ធស្ស សាសនំ ។
បដិសម្ភិទា ចតស្សោ វិមោក្ខាបិ ច អដ្ឋិមេ
ឆឡភិញ្ញា សច្ឆិកតា កតំ ពុទ្ធស្ស សាសនំ ។

ឥត្ថំ សុទំ អាយស្មា សាលកុសុមិយោ ថេរោ ឥមា គាថាយោ អភាសិត្ថាតិ ។

សាលកុសុមិយត្ថេរស្ស អបទានំ សមត្តំ ។

---

១ ឱ.ម. បុប្ផមភិបូជយឹ ។

## សាលបុប្ផិវគ្គ ទី ៥៧

## សាលកុសុមិយត្ថេរាបទាន ទី ១

(៥១) កាលព្រះមានព្រះភាគ ព្រះនាមបទុមុត្តរៈ ទ្រង់បរិនិព្វានហើយ ខ្ញុំបានបូជាផ្កាចំពោះជើងថ្ករ ដែលគេលើកឡើងហើយ ។ ក្នុងកប្បទីមួយសែន អំពីកប្បនេះ ព្រោះហេតុដែលខ្ញុំបានបូជាផ្កា ក្នុងកាលនោះ ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃការបូជាជើងថ្ករ ។ កិលេសទាំងឡាយ ខ្ញុំដុតបំផ្លាញហើយ ភពទាំងអស់ ខ្ញុំដកចោលហើយ ខ្ញុំមិនមានអាសវៈ ព្រោះបានកាត់ចំណង ដូចដំរីកាត់ផ្តាច់នូវទន្លីង ។ ឱ! ខ្ញុំមកល្អហើយ ក្នុងសំណាក់នៃព្រះពុទ្ធរបស់ខ្ញុំ វិជ្ជា ៣ ខ្ញុំបានដល់ហើយ សាសនារបស់ព្រះពុទ្ធ ខ្ញុំបានធ្វើហើយ ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ។

បានឮថា ព្រះសាលកុសុមិយត្ថេរ មានអាយុ បានសម្តែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

ចប់ សាលកុសុមិយត្ថេរាបទាន ។

# ទុតិយំ ចិតកបូជកត្ថេរាបទានំ

(៥២) ឈាយមានស្ស ភគវតោ សិខិនោ លោកពន្ធុនោ
អដ្ឋ ចម្បកបុប្ផានិ ចិតកំ អភិរោបយឹ ។
ឯកត្តឹសេ ឥតោ កប្បេ យំ បុប្ផំ អភិរោបយឹ
ទុគ្គតឹ នាភិជានាមិ ពុទ្ធបូជាយិទំ(១) ផលំ ។
កិលេសា ឈាបិតា មយ្ហំ ភវា សព្វេ សមូហតា
នាគោវ ពន្ធនំ ឆេត្វា វិហរាមិ អនាសវោ ។
ស្វាគតំ វត មេ អាសិ មម ពុទ្ធស្ស សន្តិកេ
តិស្សោ វិជ្ជា អនុប្បត្តា កតំ ពុទ្ធស្ស សាសនំ ។
បដិសម្ភិទា ចតស្សោ វិមោក្ខាបិ ច អដ្ឋិមេ
ឆឡភិញ្ញា សច្ឆិកតា កតំ ពុទ្ធស្ស សាសនន្តិ ។

ឥត្ថំ សុទំ អាយស្មា ចិតកបូជកោ ថេរោ ឥមា គាថាយោ អភាសិត្ថាតិ ។

ចិតកបូជកត្ថេរស្ស អបទានំ សមត្តំ ។

១ ម. ចិតបូជាយិទំ ។



# ចិតកបូជកត្ថេរាបទាន ទី ២

(៥២) កាលព្រះមានព្រះភាគ ព្រះនាមសិខី ជាលោកពន្ធុ ដែលគេកំពុងបូជាភ្លើង ខ្ញុំបានបូជាផ្កាចម្ប៉ា ៨ ទង ចំពោះជើងថ្ករ ។ ក្នុងកប្បទី ៣១ អំពីកប្បនេះ ព្រោះហេតុដែលខ្ញុំបានបូជាផ្កា ក្នុងកាលនោះ ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃពុទ្ធបូជា ។ កិលេសទាំងឡាយ ខ្ញុំដុតបំផ្លាញហើយ ភពទាំងអស់ ខ្ញុំដកចោលហើយ ខ្ញុំមិនមានអាសវៈ ព្រោះបានកាត់ចំណង ដូចជាដំរីកាត់ផ្តាច់នូវទន្លីង ។ ឱ ! ខ្ញុំមកល្អហើយ ក្នុងសំណាក់នៃព្រះពុទ្ធរបស់ខ្ញុំ វិជ្ជា ៣ ខ្ញុំបានដល់ហើយ សាសនារបស់ព្រះពុទ្ធ ខ្ញុំបានធ្វើហើយ ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនា របស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ។

បានឮថា ព្រះចិតកបូជកត្ថេរ មានអាយុ បានសំដែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

ចប់ ចិតកបូជកត្ថេរាបទាន ។

## តតិយំ ចិតកនិព្វាបកត្ថេរាបទានំ

(៤៣) ឌយ្ហមានេ សរីរម្ហិ វេស្សភុស្ស មហេសិនោ

គន្ធោទកំ គហេត្វាន ចិតំ និព្វាបយឹ អហំ ។

ឯកត្តឹសេ ឥតោ កប្បេ ចិតំ និព្វាបយឹ អហំ

ទុគ្គតឹ នាភិជានាមិ គន្ធោទកស្សិទំ ផលំ ។

កិលេសា ឈាបិតា មយ្ហំ ភវា សព្វេ សមូហតា

នាគោវ ពន្ធនំ ឆេត្វា វិហរាមិ អនាសវោ ។

ស្វាគតំ វត មេ អាសិ មម ពុទ្ធស្ស សន្តិកេ

តិស្សោ វិជ្ជា អនុប្បត្តា កតំ ពុទ្ធស្ស សាសនំ ។

បដិសម្ភិទា ចតស្សោ វិមោក្ខាបិច អដ្ឋិមេ

ឆឡភិញ្ញា សច្ឆិកតា កតំ ពុទ្ធស្ស សាសនំ ។

ឥត្ថំ សុទំ អាយស្មា ចិតកនិព្វាបកោ ថេរោ ឥមា គាថាយោ អភាសិត្ថាតិ ។

ចិតកនិព្វាបកត្ថេរស្ស អបទានំ សមត្តំ ។

## ចិតកនិព្វាបកត្ថេរាបទាន ទី ៣

(៤៣) កាលសរីរៈរបស់ព្រះវេស្សភូ ទ្រង់ស្វែងរកគុណដ៏ធំ ដែលជនកំពុងបូជាភ្លើង ខ្ញុំបានយកទឹកអប់រំលត់ភ្លើង ។ ក្នុងកប្បទី ៣១ អំពីកប្បនេះ ព្រោះហេតុដែលខ្ញុំរំលត់ភ្លើង ក្នុងកាលនោះ ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃទឹកអប់ ។ កិលេសទាំងឡាយ ខ្ញុំដុតបំផ្លាញហើយ ភពទាំងអស់ ខ្ញុំផ្តាច់ហើយ ខ្ញុំមិនមានអាសវៈ ព្រោះបានកាត់បំណង ដូចជាដំរីកាត់ផ្តាច់នូវទន្លីង ។ ឱ ! ខ្ញុំមកល្អហើយ ក្នុងសំណាក់នៃព្រះពុទ្ធរបស់ខ្ញុំ វិជ្ជា ៣ ខ្ញុំបានដល់ហើយ សាសនា របស់ព្រះពុទ្ធ ខ្ញុំបានធ្វើហើយ ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនា របស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ។

បានឮថា ព្រះចិតកនិព្វាបកត្ថេរ មានអាយុ បានសំដែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

ចប់ ចិតកនិព្វាបកត្ថេរាបទាន ។

## បត្តំ សេតុទាយកត្ថេរាបទានំ

(៥៨) វិបស្សិនោ ភគវតោ ចង្កមន្តស្ស សម្មុខា
បសន្នចិត្តោ សុមនោ សេតុំ ការាបយឹ អហំ ។
ឯកនវុតេ ឥតោ កប្បេ យំ សេតុំ ការយឹ អហំ
ទុគ្គតឹ នាភិជានាមិ សេតុទានស្សិទំ ផលំ ។
កិលេសា ឈាបិតា មយ្ហំ ភវា សព្វេ សមូហតា
នាគោវ ពន្ធនំ ឆេត្វា វិហរាមិ អនាសវោ ។
ស្វាគតំ វត មេ អាសិ មម ពុទ្ធស្ស សន្តិកេ
តិស្សោ វិជ្ជា អនុប្បត្តា កតំ ពុទ្ធស្ស សាសនំ ។
បដិសម្ភិទា ចតស្សោ វិមោក្ខាបិ ច អដ្ឋិមេ
ឆឡភិញ្ញា សច្ឆិកតា កតំ ពុទ្ធស្ស សាសនន្តិ ។

ឥត្ថំ សុទំ អាយស្មា សេតុទាយកោ ថេរោ ឥមា គាថាយោ អភាសិត្ថាតិ ។

សេតុទាយកត្ថេរស្ស អបទានំ អដ្ឋមំ ។



## សេតុទាយកត្ថេរាបទាន ទី ៨

(៥៨) ខ្ញុំមានចិត្តជ្រះថ្លា មានចិត្តរីករាយ បានឲ្យគេធ្វើស្ពានថ្វាយ ក្នុងទីចំពោះព្រះភក្ត្រ នៃព្រះមានព្រះភាគព្រះនាមវិបស្សី កំពុងចង្ក្រម ។ ក្នុងកប្បទី ៩៨ អំពីកប្បនេះ ព្រោះហេតុដែលខ្ញុំបានឲ្យគេធ្វើស្ពាន ក្នុងកាលនោះ ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃការថ្វាយស្ពាន ។ កិលេសទាំងឡាយ ខ្ញុំដុតបំផ្លាញហើយ ភពទាំងអស់ ខ្ញុំផ្ដាច់ផ្ដាលហើយ ខ្ញុំមិនមានអាសវៈ ព្រោះបានកាត់ចំណងដូចជាដំរីកាត់ផ្ដាច់ខ្សែទន្លីង ។ ឱ! ខ្ញុំមកល្អហើយ ក្នុងសំណាក់នៃព្រះពុទ្ធរបស់ខ្ញុំ វិជ្ជា ៣ ខ្ញុំបានដល់ហើយ សាសនារបស់ព្រះពុទ្ធ ខ្ញុំបានធ្វើហើយ ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនា របស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ។

បានឮថា ព្រះសេតុទាយកត្ថេរ មានអាយុ បានសម្ដែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

ចប់ សេតុទាយកត្ថេរាបទាន ។

## បញ្ចមំ សុមនតាលវណ្ដិយត្ថេរាបទានំ

(៤៨) សិទ្ធត្ថស្ស ភគវតោ តាលវណ្ដំ(១) អទាសហំ

សុមនេហិ បដិច្ឆន្នំ ធារយាមិ មហាយសំ ។

ចតុន្នវុតេ ឥតោ កប្បេ តាលវណ្ដំ អទាសហំ

ទុគ្គតឹ នាភិជានាមិ តាលវណ្ដស្សិទំ ផលំ ។

កិលេសា ឈាបិតា មយ្ហំ ភវា សព្វេ សមូហតា

នាគោវ ពន្ធនំ ឆេត្វា វិហរាមិ អនាសវោ ។

ស្វាគតំ វត មេ អាសិ មម ពុទ្ធស្ស សន្តិកេ

តិស្សោ វិជ្ជា អនុប្បត្តា កតំ ពុទ្ធស្ស សាសនំ ។

បដិសម្ភិទា ចតស្សោ វិមោក្ខាបិ ច អដ្ឋិមេ

ឆឡភិញ្ញា សច្ឆិកតា កតំ ពុទ្ធស្ស សាសនំ ។

ឥត្ថំ សុទំ អាយស្មា សុមនតាលវណ្ដិយោ ថេរោ

ឥមា គាថាយោ អភាសិត្ថាតិ ។

សុមនតាលវណ្ដិយត្ថេរស្ស អបទានំ សមត្តំ ។

---

១ ម. តាលវណ្ដំ ។

## សុមនតាលវណ្ដិយត្ថេរាបទាន ទី ៥

(៤៨) ខ្ញុំបានយកតាលវណ្ដ មកស្រោបដោយផ្កាម្លិះ ហើយថ្វាយព្រះមានព្រះភាគ ព្រះនាមសិទ្ធត្ថៈ ទ្រង់មានយសធំ ។ ក្នុងកប្បទី ៩៤ អំពីកប្បនេះ ព្រោះហេតុដែលខ្ញុំថ្វាយតាលវណ្ដ ក្នុងកាលនោះ ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃតាលវណ្ដ ។ កិលេសទាំងឡាយ ខ្ញុំដុតចោលហើយ ភពទាំងពួង ខ្ញុំដកចោលហើយ ខ្ញុំមិនមានអាសវៈ ព្រោះបានកាត់ចំណង ដូចជាដំរីកាត់ផ្ដាច់ខ្សែទន្លីង ។ ឱ ! ខ្ញុំមកល្អហើយ ក្នុងសំណាក់នៃព្រះពុទ្ធរបស់ខ្ញុំ វិជ្ជា ៣ ខ្ញុំបានដល់ហើយ សាសនារបស់ព្រះពុទ្ធ ខ្ញុំបានធ្វើហើយ ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនា របស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ។

បានឮថា ព្រះសុមនតាលវណ្ដិយត្ថេរ មានអាយុ បានសំដែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

ចប់ សុមនតាលវណ្ដិយត្ថេរាបទាន ។

# ឆដ្ឋំ អវដផលិយត្ថេរាបទានំ

(៨៦) សតរំសិ នាម ភគវា សយម្ភូ អបរាជិតោ
វិវេកកាមោ សម្ពុទ្ធោ គោចរាយាភិនិក្ខមិ ។
ផលហត្ថោ អហំ ទិស្វា ឧបគច្ឆឹ នរាសភំ
បសន្នចិត្តោ សុមនោ អវដំ អទទឹ ផលំ(១) ។
ចតុន្នវុតេ ឥតោ កប្បេ យំ ផលំ អទទឹ តទា
ទុគ្គតឹ នាភិជានាមិ ផលទានស្សិទំ ផលំ ។
កិលេសា ឈាបិតា មយ្ហំ ភវា សព្វេ សមូហតា
នាគោវ ពន្ធនំ ឆេត្វា វិហរាមិ អនាសវោ ។
ស្វាគតំ វត មេ អាសិ មម ពុទ្ធស្ស សន្តិកេ
តិស្សោ វិជ្ជា អនុប្បត្តា កតំ ពុទ្ធស្ស សាសនំ ។

១ ម. អវណ្ដុផលំ ។



# អវដផលិយត្ថេរាបទាន ទី ៦

(៨៦) ព្រះសម្ពុទ្ធ មានព្រះភាគ ជាសយម្ភូ ទ្រង់មានរស្មីច្រើន ព្រះអង្គឈ្នះកិលេសមារ ទ្រង់ប្រាថ្នានូវវិវេក ស្តេចចេញទៅដើម្បីគោចរ ។ ខ្ញុំកាន់ផ្លែឈើក្នុងដៃ លុះឃើញព្រះពុទ្ធ ដ៏ប្រសើរជាងពួកនរៈហើយ ក៏ចូលទៅជិត ខ្ញុំមានចិត្តជ្រះថ្លា មានចិត្តរីករាយ បានថ្វាយនូវផ្លែឈើឥតទងនោះ ។ ក្នុងកប្បទី ៩៤ អំពីកប្បនេះ ព្រោះហេតុដែលខ្ញុំបានថ្វាយផ្លែឈើ ក្នុងកាលនោះ ខ្ញុំមិនដែលស្គាល់ទុគ៌តិ នេះជាផលនៃការថ្វាយផ្លែឈើ ។ កិលេសទាំងឡាយ ខ្ញុំដុតបំផ្លាញហើយ ភពទាំងពួង ខ្ញុំដកចោលហើយ ខ្ញុំមិនមានអាសវៈ ព្រោះបានកាត់បំណង់ ដូចដំរីកាត់ផ្តាច់នូវចំណង ។ ឱ ! ខ្ញុំមកល្អហើយក្នុងសំណាក់នៃព្រះពុទ្ធរបស់ខ្ញុំ វិជ្ជា ៣ ខ្ញុំបានដល់ហើយ សាសនារបស់ព្រះពុទ្ធ ខ្ញុំបានធ្វើហើយ ។

បដិសម្ភិទា ចតស្សោ  វិមោក្ខាបិច អដ្ឋិមេ
ឆឡភិញ្ញា សច្ឆិកតា  កតំ ពុទ្ធស្ស សាសនន្តិ ។

ឥត្ថំ សុទំ អាយស្មា អវដផលិយោ ថេរោ ឥមា គាថាយោ អភាសិត្ថាតិ ។

អវដផលិយត្ថេរស្ស អបទានំ សមត្តំ ។

## សត្តមំ លពុជផលទាយកត្ថេរាបទានំ

(៤៧) នគរេ ពន្ធុមតិយា  អារាមិកោ អហំ តទា
អទ្ទសំ វិរជំ ពុទ្ធំ  គច្ឆន្តំ អនិលញ្ជសេ ។
លពុជផលមាទាយ  ពុទ្ធសេដ្ឋស្សទាសហំ
អាកាសេវ ឋិតោ សន្តោ  បដិគ្គណ្ហិ មហាយសោ ។
វិត្តិសញ្ជននោ មយ្ហំ  ទិដ្ឋធម្មសុខាវហោ
ផលំ ពុទ្ធស្ស ទត្វាន  វិប្បសន្នេន ចេតសា ។
អធិគច្ឆឹ តទា បីតឹ  វិបុលំ សុខមុត្តមំ
ឧប្បជ្ជតេ(១)បេ(២) រតនំ  និព្វត្តស្ស តហឹ តហឹ ។

---

១ ឱ. ម. ឧប្បជ្ជតេវ ។ ២ ឱ. ម. ខេលព្វា ត្តិ ។





បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនា របស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ។

បានឮថា ព្រះអវដផលិយត្ថេរ មានអាយុ បានសម្តែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

ចប់ អវដផលិយត្ថេរាបទាន ។

## លពុជផលទាយកត្ថេរាបទាន ទី ៧

[៤៧] ក្នុងកាលនោះ ខ្ញុំជាញោមវត្ត ក្នុងនគរពន្ធុម-វតី បានឃើញព្រះពុទ្ធ ទ្រង់ប្រាសចាកធូលី កំពុងស្តេចយាងទៅក្នុងអាកាស ។ ខ្ញុំបានយកផ្លែខ្នុរសម្ល ទៅថ្វាយដល់ព្រះពុទ្ធប្រសើរ ឯព្រះពុទ្ធមានយសច្រើន ទ្រង់ឈរទទួលក្នុងអាកាស ។ ព្រះអង្គញុំាងសេចក្តីត្រេកអរឲ្យកើតដល់ខ្ញុំ ទ្រង់នាំមកនូវសេចក្តីសុខ ក្នុងបច្ចុប្បន្ន ព្រោះបានថ្វាយផ្លែខ្នុរដល់ព្រះពុទ្ធ ដោយចិត្តជ្រះថ្លានោះ ។ ក្នុងកាលណោះ ខ្ញុំបាននូវបីតិ ដ៏ធំទូលាយ ជាសុខដ៏ឧត្តម កែវក៏កើតឡើងសម្រាប់ខ្ញុំ ដែលកើតក្នុងភពនោះៗ ។

ឯកនវុតេ ឥតោ កប្បេ យំ ផលំ អទទឹ តទា
ទុគ្គតឹ នាភិជានាមិ ផលទានស្សិទំ ផលំ ។
កិលេសា ឈាបិតា មយ្ហំ ភវា សព្វេ សមូហតា
នាគោវ ពន្ធនំ ឆេត្វា វិហរាមិ អនាសវោ ។
ស្វាគតំ វត មេ អាសិ មម ពុទ្ធស្ស សន្តិកេ
តិស្សោ វិជ្ជា អនុប្បត្តា កតំ ពុទ្ធស្ស សាសនំ ។
បដិសម្ភិទា ចតស្សោ វិមោក្ខាបិច អដ្ឋិមេ
ឆឡភិញ្ញា សច្ឆិកតា កតំ ពុទ្ធស្ស សាសនំ ។

ឥត្ថំ សុទំ អាយស្មា លពុជផលទាយកោ ថេរោ ឥមា គាថាយោ អភាសិត្ថាតិ ។

លពុជផលទាយកត្ថេរស្ស អបទានំ សមត្តំ ។

## អដ្ឋមំ មិលក្ខុផលទាយកត្ថេរាបទានំ

(៤៨) វនន្តរេ(១) ពុទ្ធំ ទិស្វា(២) អត្ថទស្សឹ មហាយសំ
បសន្នចិត្តោ សុមនោ មិលក្ខុស្ស(៣) ផលំ អទឹ(៤) ។

---

១ ឱ. វនគ្គេ ។ ២ ឱ. ទិស្វាន ។ ៣ ឱ. បិលក្ខុស្ស ។ ម. ពិលក្ខុស្ស ។ ៤ ឱ. អទា ។



ក្នុងកប្បទី ៩១ អំពីកប្បនេះ ព្រោះហេតុដែលខ្ញុំបានថ្វាយផ្លែឈើ ក្នុងកាលនោះ ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃការថ្វាយផ្លែឈើ ។ កិលេសទាំងឡាយ ខ្ញុំដុតបំផ្លាញហើយ ភពទាំងអស់ ខ្ញុំដកចោលហើយ ខ្ញុំមិនមានអាសវៈ ព្រោះបានកាត់ចំណង ដូចជាដំរីកាត់ផ្តាច់នូវចំណង ។ ឱ! ខ្ញុំមកល្អហើយ ក្នុងសំណាក់នៃព្រះពុទ្ធរបស់ខ្ញុំ វិជ្ជា ៣ ខ្ញុំបានដល់ហើយ សាសនារបស់ព្រះពុទ្ធ ខ្ញុំបានធ្វើហើយ ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនា របស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ។

បានឮថា ព្រះលពុជផលទាយកត្ថេរ មានអាយុ បានសំដែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

ចប់ លពុជផលទាយកត្ថេរាបទាន ។

## មិលក្ខុផលទាយកត្ថេរាបទាន ទី ៨

(៤៨) ខ្ញុំបានឃើញព្រះពុទ្ធ ព្រះនាមអត្ថទស្សី មានយសច្រើន គង់នៅក្នុងចន្លោះព្រៃ ហើយមានចិត្តជ្រះថ្លា មានចិត្តរីករាយ បានថ្វាយផ្លែល្វៀប (ដល់ព្រះអង្គ) ។

អដ្ឋារសេ កប្បសតេ យំ ផលំ អទទឹ តទា
ទុគ្គតឹ នាភិជានាមិ ផលទានស្សិទំ ផលំ ។
កិលេសា ឈាបិតា មយ្ហំ ភវា សព្វេ សមូហតា
នាគោវ ពន្ធនំ ឆេត្វា វិហរាមិ អនាសវោ ។
ស្វាគតំ វត មេ អាសិ មម ពុទ្ធស្ស សន្តិកេ
តិស្សោ វិជ្ជា អនុប្បត្តា កតំ ពុទ្ធស្ស សាសនំ ។
បដិសម្ភិទា ចតស្សោ វិមោក្ខាបិ ច អដ្ឋិមេ
ឆឡភិញ្ញា សច្ឆិកតា កតំ ពុទ្ធស្ស សាសនំ ។

ឥត្ថំ សុទំ អាយស្មា មិលក្ខុផលទាយកោ[១] ថេរោ
ឥមា គាថាយោ អភាសិត្ថាតិ ។

មិលក្ខុផលទាយកត្ថេរស្ស អបទានំ សមត្តំ ។

## នវមំ សយម្បដិភាណិយត្ថេរាបទានំ

(៨៩) កកុធំ វិលសន្តំវ[២] ទេវទេវំ នរាសភំ
រថិយំ បដិបជ្ជន្តំ កោ ទិស្វា នប្បសីទតិ ។

---
១ ឱ. បិលក្ខុផលទាយកោ ។ ២ ឱ. វិលម្ពន្តំវ ។





ក្នុងកប្បទី ១.៨០០ ព្រោះហេតុដែលខ្ញុំ បានឲ្យផ្លែល្វា ក្នុងកាលនោះ ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃការឲ្យនូវផ្លែល្វា ។ កិលេសទាំងឡាយ ខ្ញុំដុតបំផ្លាញហើយ ភពទាំងអស់ ខ្ញុំផ្ដាច់ហើយ ខ្ញុំមិនមានអាសវៈ ព្រោះបានកាត់ចំណង ដូចជាដំរីកាត់ផ្ដាច់នូវចំណង ។ ឱ! ខ្ញុំមកល្អហើយ ក្នុងសំណាក់នៃព្រះពុទ្ធរបស់ខ្ញុំ វិជ្ជា ៣ ខ្ញុំបានដល់ហើយ សាសនារបស់ព្រះពុទ្ធ ខ្ញុំបានធ្វើហើយ ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ។

បានឮថា ព្រះមិលក្ខុផលទាយកត្ថេរ មានអាយុ បានសម្ដែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

ចប់ មិលក្ខុផលទាយកត្ថេរាបទាន ។

## សយម្បដិភាណិយត្ថេរាបទាន ទី ៩

(៨៩) ខ្ញុំបានសរសើរថា ព្រះពុទ្ធ ជាទេវតាក្រៃលែងជាងទេវតា ព្រះអង្គប្រសើរជាងនរៈ មានព្រះដំណើរល្អស្ទន់ បីដូចដើមថ្កុលត្រូវខ្យល់ ទ្រង់កំពុងស្ដេចទៅតាមច្រក បុគ្គលណាឃើញហើយ នឹងមិនជ្រះថ្លាម្ដេចបាន ។

តមន្ធការំ នាសេត្វា សន្តារេត្វា ពហុំ ជនំ
ញាណាលោកេន ជោតន្តំ កោ ទិស្វា នប្បសីទតិ ។
វសីសតសហស្សេហិ និយ្យន្តំ លោកនាយកំ
ឧទ្ធរន្តំ ពហូ សត្តេ កោ ទិស្វា នប្បសីទតិ ។
អាហនិត្វា(១) ធម្មភេរិំ មទ្ទន្តំ តិត្ថិយេ គណេ
សីហនាទំ នទន្តំ(២) កោ ទិស្វា នប្បសីទតិ ។

យាវតា ព្រហ្មលោកម្ហា អាគន្ត្វាន សព្រហ្មកា
បុច្ឆន្តិ និបុណេ បញ្ហេ កោ ទិស្វា នប្បសីទតិ ។
យស្សញ្ជលិំ ករិត្វាន រាជាវន្តិ(៣) សទេវកា
តេន បុញ្ញំ អនុភោន្តិ កោ ទិស្វា នប្បសីទតិ ។
សព្វេ ជនា សមាគន្ត្វា សម្បវារេន្តិ(៤) ចក្ខុមំ
ន វិកម្បតិ អជ្ឈិដ្ឋោ កោ ទិស្វា នប្បសីទតិ ។

---

១ ឱ. អាហន្ត្វា ។ ២ ឱ. វិនទន្តំ ។ ម. វិនទន្តំ ។ ៣ ឱ. ម. អាយាចន្តិ ។
៤ ម. សព្វំ ភិវន្តិ ។



ព្រះពុទ្ធទ្រង់កំចាត់បង់នូវងងឹតអន្ធការ ទ្រង់ចម្លងនូវជនច្រើន ទ្រង់រុងរឿងដោយពន្លឺគឺញាណ បុគ្គលណាឃើញហើយ នឹងមិនជ្រះថ្លាម្តេចបាន ។ ព្រះលោកនាយក ទ្រង់ស្តេចទៅជាមួយនឹងព្រះខីណាស្រពមួយសែន ដែលស្ទាត់ជំនាញ ទ្រង់ស្រង់នូវសត្វទាំងឡាយដ៏ច្រើន បុគ្គលណាឃើញហើយ នឹងមិនជ្រះថ្លាម្តេចបាន ។ ព្រះពុទ្ធនាំមកនូវធម្មភេរី ទ្រង់ញាំញីនូវពួកតិរ្ថិយ បន្លឺឡើងនូវសីហនាទ បុគ្គលណាឃើញហើយ នឹងមិនជ្រះថ្លាម្តេចបាន ។ ពួកទេវតា ព្រមទាំងព្រហ្ម ហូតដល់ព្រហ្មលោក មកសួរនូវបញ្ហាដ៏ល្អិត អ្នកណាឃើញហើយ នឹងមិនជ្រះថ្លាម្តេចបាន ។ ពួកជន ព្រមទាំងទេវតា ធ្វើនូវអញ្ជលីបួងសួងចំពោះព្រះពុទ្ធអង្គណា រមែងបានទទួលនូវបុណ្យ ដោយសារព្រះពុទ្ធអង្គនោះ បុគ្គលណាឃើញហើយ នឹងមិនជ្រះថ្លាម្តេចបាន ។ ជនទាំងពួងមកព្រមគ្នា ហើយបវារណាព្រះពុទ្ធមានចក្ខុ ព្រះអង្គដែលគេអារាធនាហើយ រមែងមិនញាប់ញ័រ បុគ្គលណាឃើញហើយ នឹងមិនជ្រះថ្លាម្តេចបាន ។

នគរំ បវិសតោ យស្ស រវន្តិ(១) ភេរិយោ ពហូ
វិនទន្តិ គជា មត្តា(២) កោ តំ ទិស្វា នប្បសីទតិ ។
វីថិយា គច្ឆតោ យស្ស បភា(៣) ជោតតេ សទា
អព្ភុន្នតា សមា ហោន្តិ កោ តំ ទិស្វា នប្បសីទតិ ។
ព្យាហរន្តស្ស(៤) ពុទ្ធស្ស ចក្កវាឡម្ហិ សុយ្យតិ
សព្វេ សត្តេ វិញ្ញាបេតិ កោ តំ ទិស្វា នប្បសីទតិ ។
សតសហស្សេ ឥតោ កប្បេ យំ ពុទ្ធមភិកិត្តយឹ
ទុគ្គតឹ នាភិជានាមិ កិត្តនាយ ឥទំ ផលំ ។
កិលេសា ឈាបិតា មយ្ហំ ភវា សព្វេ សមូហតា
នាគោវ ពន្ធនំ ឆេត្វា វិហរាមិ អនាសវោ ។

១ ឱ. អនុទន្តិ ។ ២ ឱ. សក្កាភា ។ ម. សក្វិចា ។ ៣ ឱ. អភ្ធេ ។ ម. អភ្ធិ ។
៤ ឱ. វ្យាហរន្តេ ប ។



ស្គរជាច្រើនរមែងបន្លឺឡើង ដំរីទាំងឡាយ ដែលចុះប្រេង រមែងបន្លឺឡើង ចំពោះព្រះសម្ពុទ្ធអង្គណា កាលដែលស្ដេចចូលទៅកាន់ទីក្រុង បុគ្គលណាឃើញ (ព្រះពុទ្ធអង្គនោះ) ហើយ នឹងមិនជ្រះថ្លាម្ដេចបាន ។ ឯពន្លឺនៃព្រះពុទ្ធអង្គណា ដែលកំពុងស្ដេចទៅតាមផ្លូវ រមែងរុងរឿង សព្វ ៗ កាល ស្មើទាំងឡាយ (របស់ព្រះពុទ្ធអង្គនោះ) ខ្ពង់ខ្ពស់ឡើងក្រពេក បុគ្គលណាឃើញហើយ នឹងមិនជ្រះថ្លាម្ដេចបាន ។ បុគ្គលឮ (នូវសំឡេង) នៃព្រះពុទ្ធ កាលពោលក្នុងចក្រវាឡ ព្រះអង្គញ៉ាំងសត្វទាំងអស់ឲ្យដឹងច្បាស់ បុគ្គលណាឃើញហើយ នឹងមិនជ្រះថ្លាម្ដេចបាន ។ ក្នុងកប្បទីមួយសែន អំពីកប្បនេះ ព្រោះហេតុដែលខ្ញុំបានសរសើរនូវព្រះពុទ្ធ ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃសេចក្ដីសរសើរ ។ កិលេសទាំងឡាយ ខ្ញុំដុតបំផ្លាញហើយ ភពទាំងអស់ ខ្ញុំផ្ដាច់ហើយ ខ្ញុំមិនមានអាសវៈ ព្រោះបានកាត់ចំណង ដូចជាដំរីកាត់ផ្ដាច់នូវទន្លីង ។

ស្វាគតំ វត មេ អាសិ មម ពុទ្ធស្ស សន្តិកេ
តិស្សោ វិជ្ជា អនុប្បត្តា កតំ ពុទ្ធស្ស សាសនំ ។
បដិសម្ភិទា ចតស្សោ វិមោក្ខាបិច អដ្ឋិមេ
ឆឡភិញ្ញា សច្ឆិកតា កតំ ពុទ្ធស្ស សាសនន្តិ ។

ឥត្ថំ សុទំ អាយស្មា សយម្បដិភាណិយោ ថេរោ ឥមា គាថាយោ អភាសិត្ថាតិ ។

សយម្បដិភាណិយត្ថេរស្ស អបទានំ សមត្តំ ។

## ទសមំ និមិត្តព្យាករណិយត្ថេរាបទានំ

(៦០) អជ្ឈោគាហេត្វា ហិមវន្តំ(១) មន្តេ វាចេមហន្តទា
ចតុបញ្ញាសសហស្សានិ សិស្សា មយ្ហំ ឧបដ្ឋហុំ ។
អធិតា វេទគូ សព្វេ ឆឡង្គេ ពារមឹ គតា
សកវិជ្ជាហុបត្ថទ្ធា ហិមវន្តេ វសន្តិ តេ ។

១ ឧ. ម. កេចិ ។



ឱ ! ខ្ញុំមកល្អហើយ ក្នុងសំណាក់នៃព្រះពុទ្ធរបស់ខ្ញុំ វិជ្ជា ៣ ខ្ញុំបានដល់ហើយ សាសនារបស់ព្រះពុទ្ធ ខ្ញុំបានធ្វើហើយ ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនា របស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ។

បានឮថា ព្រះសយម្បដិភាណិយត្ថេរ មានអាយុ បានសម្តែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

ចប់ សយម្បដិភាណិយត្ថេរាបទាន ។

## និមិត្តព្យាករណិយត្ថេរាបទាន ទី ១០

(៦០) កាលនោះ ខ្ញុំចូលទៅក្នុងព្រៃហិមពាន្ត បង្រៀនមន្តដល់ពួកសិស្ស ឯសិស្សចំនួន ៥៤.០០០ នាក់ បានបម្រើខ្ញុំ ។ សិស្សទាំងអស់នោះ ជាអ្នករៀនវេទ ដល់នូវបារមីក្នុងអង្គ ៦ ដែលប្រឹងដោយវិជ្ជារបស់ខ្លួន នៅក្នុងព្រៃហិមពាន្ត ។

ទសមំ និមិត្តព្យាករណំ ភូមិកម្បនំ

ចវិត្វា តុសិតា កាយា  ទេវបុត្តោ មហាយសោ
ឧប្បជ្ជិ មាតុកុច្ឆិស្មឹ  សម្បជានោ បដិស្សុតោ ។
សម្ពុទ្ធេ ឧបបជ្ជន្តេ  ទសសហស្សិ កម្បថ(១)
អន្ធា ចក្ខុំ អលភិំសុ(២)  ឧប្បជ្ជន្តម្ហិ នាយកេ ។
សព្វាការេ បកម្បិត្ថ(៣)  កោសលា វសុធា អយំ
និគ្ឃោសសទ្ទំ សុត្វាន  វិម្ហយិំសុ(៤) មហាជនា ។
សព្វេ ជនា សមាគម្ម  អគតុំ មម សន្តិកេ
វសុធាយំ បកម្បិត្ថ  កិំវិបាកោ ភវិស្សតិ ។
វិធស្សាមិ(៥) តទា តេសំ  មា ភាយិត្ថ ឆត្តិ ភោ ភយំ(៦)
វិស្សដ្ឋា ហោថ សព្វេបិ  ឧប្បាទោយំ សុវត្ថិកោ(៧) ។

១ ឧ. បកម្បថ ។ ២ ឧ. អលត្ថំសុ ។ ៣ ឧ. សព្វាការំ បកម្បិត្ថ ។ ម. សព្វាការំ បកម្បិត្ថ ។
៤ ឧ. វិម្ហិតំសុ ។ ៥ ឧ. ម. អភិណ្ហំ ។ ៦ ឧ. មា ភេត្ថ ឆត្តិ ភោ ភយំ ។ ម. មា ភេថ
ឆត្តិ ភោ ។ ៧ ម. សុវត្ថិកោ ។



និមិត្តព្យាករណ៍ផែនដីកក្រើក ទី ១០

ទេវបុត្តមួយអង្គ មានយសច្រើន បានច្យុតចាកពួកទេវតាក្នុងឋានតុសិត មកចាប់បដិសន្ធិក្នុងផ្ទៃព្រះមាតា ជាអ្នកដឹងខ្លួន មានស្មារតី ។ កាលព្រះសម្ពុទ្ធ បានត្រាស់ លោកធាតុមួយម៉ឺន ញាប់ញ័រ កាលព្រះនាយក ទ្រង់បានត្រាស់ ពួកជនខ្វាក់ភ្នែក ក៏បានភ្នែក ។ ផែនដីនេះទាំងមូលញាប់ញ័រ ហើយដោយប្រការ ៦ មហាជនក៏តក់ស្លុត ព្រោះឮសំឡេងគឹកកង ។ ជនទាំងអស់បានទៅប្រជុំគ្នា ក្នុងសំណាក់ខ្ញុំ សួរខ្ញុំថា ផែនដីនេះញាប់ញ័រ តើនឹងមានផលដូចម្ដេច ។ កាលណោះ ខ្ញុំប្រាប់ពួកជនទាំងនោះថា អ្នកទាំងឡាយ កុំខ្លាចអ្វីឡើយ ភ័យនឹងមិនកើត ដល់អ្នកទាំងឡាយទេ អ្នកទាំងអស់គ្នា កុំស្ញើសឡើយ ការណ៍ដែលកើតឡើងនេះ ប្រកបដោយសេចក្ដីសុខ និងសេចក្ដីចំរើនទេតើ ។

អដ្ឋហេតូហិ សម្ផុដ្ឋា(១) វសុធាយំ បកម្បតិ
តថា និមិត្តា និស្សដ្ឋា ឱភាសោ វិបុលោ មហា ។
អសំសយំ ពុទ្ធសេដ្ឋោ ឧប្បជ្ជិស្សតិ ចក្ខុមា
សញ្ញាបេត្វាន ជនតំ បញ្ចសីលេ ការេសហំ(២) ។
សុត្វាន បញ្ច សីលានិ ពុទ្ធុប្បាទញ្ច ទុល្លភំ
ឧព្វេគជាតា សុមនា តុដ្ឋហដ្ឋា អហេសុ(៣) តេ ។
ទ្វេនវុតេ ឥតោ កប្បេ យំ និមិត្តំ វិយាករិំ
ទុគ្គតិំ នាភិជានាមិ ព្យាករណស្សិទំ ផលំ ។
កិលេសា ឈាបិតា មយ្ហំ ភវា សព្វេ សមូហតា
នាគោវ ពន្ធនំ ឆេត្វា វិហរាមិ អនាសវោ ។
ស្វាគតំ វត មេ អាសិ មម ពុទ្ធស្ស សន្តិកេ
តិស្សោ វិជ្ជា អនុប្បត្តា កតំ ពុទ្ធស្ស សាសនំ ។

---

១ ម. អដ្ឋហេតុ និស្សំសយំ ។ ២ ឱ. ការេមហំ ។ ៣ ឱ. អាសីសុ ។ ម. អហំសុ ។



ផែនដីនេះ ដែលហេតុទាំង ៨ ហាក់ប៉ះពាល់ហើយ រមែងញ័រ និមិត្តទាំងឡាយប្រាកដឡើង ពន្លឺដ៏ធំទូលាយប្រាកដឡើង ក៏ព្រោះហេតុនោះ ។ ព្រះពុទ្ធប្រសើរ ទ្រង់មានចក្ខុ នឹងត្រាស់ដោយឥតសង្ស័យ ខ្ញុំញុំាងប្រជុំជនឲ្យដឹងច្បាស់ហើយ ទើបសម្តែងនូវសីល ៥ ។ ពួកជនទាំងនោះ លុះបានស្តាប់នូវសីល ៥ ផង នូវការកើតឡើងនៃព្រះពុទ្ធ ដែលបុគ្គលរកបានដោយកម្រផង ក៏មានចិត្តអណ្តែតឡើង មានចិត្តរីករាយ ជាអ្នកត្រេកអរស្រស់ស្រាយ ។ ក្នុងកប្បទី ៩២ អំពីកប្បនេះ ព្រោះហេតុដែលខ្ញុំ បានព្យាករណ៍នូវនិមិត្ត ក្នុងកាលនោះ ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃការព្យាករណ៍ ។ កិលេសទាំងឡាយ ខ្ញុំដុតបំផ្លាញហើយ ភពទាំងអស់ ខ្ញុំដកចោលហើយ ខ្ញុំមិនមានអាសវៈ ព្រោះបានកាត់ចំណង ដូចជាដំរីកាត់ផ្តាច់នូវទន្លីង ។ ឱ! ខ្ញុំមកល្អហើយ ក្នុងសំណាក់នៃព្រះពុទ្ធរបស់ខ្ញុំ វិជ្ជា ៣ ខ្ញុំបានដល់ហើយ សាសនា របស់ព្រះពុទ្ធ ខ្ញុំបានធ្វើហើយ ។

បដិសម្ភិទា ចតស្សោ វិមោក្ខាបិ ច អដ្ឋិមេ
ឆឡភិញ្ញា សច្ឆិកតា កតំ ពុទ្ធស្ស សាសនំ ។

ឥត្ថំ សុទំ អាយស្មា និមិត្តព្យាករណិយោ ថេរោ ឥមា គាថាយោ អភាសិត្ថាតិ ។

និមិត្តព្យាករណិយត្ថេរស្ស អបទានំ សមត្តំ ។

## ឧទ្ទានំ

សាលកុសុមិយោ(១) ថេរោ បូជា ចិតាយកោបិ ច
សេតុទោ តាលវណ្ដី(២) ច អវដី(៣) លពុជម្បុតោ(៤)
មិលក្ខុបដិភាណី(៥) ច វេយ្យាករណិយោ និជា(៦)
ទ្វេសត្តតិ(៧) ច គាថាយោ គណិតាយោ វិភាវិភិ ។

សាលបុប្ផិវគ្គោ(៨) សត្តចត្តាឡីសោ ។

---

១ ឱ. សាលបុប្ផិ ច យោ ។ ២ ម. តាលវណ្ដោ ។ ៣ ឱ. អវណ្ណុំ ។ ៤ ឱ. ម. លពុជម្ពុជ្ជ-តោ ។ ៥ ម. បិលក្ខុបដិកណិ ។ ៦ ឱ. វេយ្យាករណោ ទិនោ ។ ៧ ឱ. ទ្វេ សតញ្ចៅ ។ ៨ ម. សាលកុសុមិយវគ្គោ ។





បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនា របស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ។

បានឮថា ព្រះនិមិត្តព្យាករណិយត្ថេរ មានអាយុ បានសម្ដែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

ចប់ និមិត្តព្យាករណិយត្ថេរាបទាន ។

## ឧទ្ទាន

សាលកុសុមិយត្ថេរាបទាន ១ ចិតកបូជកត្ថេរាបទាន ១ ចិតកនិព្វាបកត្ថេរាបទាន ១ សេតុទាយកត្ថេរាបទាន ១ តាលវណ្ដិយត្ថេរាបទាន ១ អវដលិយត្ថេរាបទាន ១ លពុជទាយកត្ថេរាបទាន ១ មិលក្ខុផលទាយកត្ថេរាបទាន ១ សយម្បដិភាណិយត្ថេរាបទាន ១ និមិត្តព្យាករណិយត្ថេរាបទាន ១ ឯគាថា ៧២ ពួកអ្នកប្រាជ្ញ បានរាប់រៀបហើយ ។

ចប់ សាលបុប្ផិវគ្គ ទី ៤៧ ។

# អដ្ឋបញ្ញាសោ នឡមាលិវគ្គោ

## បឋមំ នឡមាលិយត្ថេរាបទានំ

(៦១) សុវណ្ណវណ្ណំ សម្ពុទ្ធំ អាហុតីនំ បដិគ្គហំ
បវនគ្គេន(១) គច្ឆន្តំ អទ្ទសំ លោកនាយកំ ។
នឡមាលំ គហេត្វាន និក្ខមន្តោ ច តាវទេ
តត្ថទ្ទសាសិំ សម្ពុទ្ធំ ឱឃតិណ្ណមនាសវំ ។
បសន្នចិត្តោ សុមនោ នឡមាលំ អបូជយិំ
ទក្ខិណេយ្យំ មហាវីរំ សព្វលោកានុកម្បកំ ។
ឯកត្តិំសេ ឥតោ កប្បេ យំ បុប្ផំ អភិបូជយិំ
ទុគ្គតិំ នាភិជានាមិ ពុទ្ធបូជាយិទំ ផលំ ។
កិលេសា ឈាបិតា មយ្ហំ ភវា សព្វេ សមូហតា
នាគោវ ពន្ធនំ ឆេត្វា វិហរាមិ អនាសវោ ។
ស្វាគតំ វត មេ អាសិ មម ពុទ្ធស្ស សន្តិកេ
តិស្សោ វិជ្ជា អនុប្បត្តា កតំ ពុទ្ធស្ស សាសនំ ។

១ ម. វិបិនគ្គេ ។

# នឡមាលិវគ្គ ទី ៥៨

## នឡមាលិយត្ថេរាបទាន ទី ១

(៦៦) ខ្ញុំបានឃើញនូវព្រះសម្ពុទ្ធ មានវណ្ណៈដូចមាស ជាលោកនាយក ទ្រង់គួរទទួលនូវគ្រឿងបូជា ស្តេចទៅតាមជាយព្រៃ ។ ខ្ញុំកាន់យកកម្រងផ្កាបបុស ហើយចេញទៅក្នុងខណៈនោះ បានឃើញព្រះសម្ពុទ្ធ ទ្រង់ឆ្លងនូវឱឃៈ ព្រះអង្គមិនមានអាសវៈ គង់នៅក្នុងព្រៃនោះ ។ ខ្ញុំមានចិត្តជ្រះថ្លា មានចិត្តត្រេកអរ បានបូជាកម្រងផ្កាបបុស ចំពោះព្រះពុទ្ធជាទក្ខិណេយ្យបុគ្គល ព្រះអង្គមានព្យាយាមច្រើន ទ្រង់អនុគ្រោះសព្វសត្វលោក ។ ក្នុងកប្បទី ៣១ អំពីកប្បនេះ ព្រោះហេតុដែលខ្ញុំបូជាផ្កា ក្នុងកាលនោះ ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃពុទ្ធបូជា ។ កិលេសទាំងឡាយ ខ្ញុំដុតបំផ្លាញហើយ ភពទាំងពួង ខ្ញុំផ្តាច់ផ្តិលហើយ ខ្ញុំមិនមានអាសវៈ ព្រោះបានកាត់ចំណង ដូចជាដំរីកាត់ផ្តាច់នូវទន្លីង ។ ឱ! ខ្ញុំមកល្អហើយ ក្នុងសំណាក់នៃព្រះពុទ្ធរបស់ខ្ញុំ វិជ្ជា ៣ ខ្ញុំបានដល់ហើយ សាសនារបស់ព្រះពុទ្ធ ខ្ញុំបានធ្វើហើយ ។

បដិសម្ភិទា ចតស្សោ   វិមោក្ខាបិ ច អដ្ឋិមេ
ឆឡភិញ្ញា សច្ឆិកតា   កតំ ពុទ្ធស្ស សាសនំ ។

ឥត្ថំ សុទំ អាយស្មា ធម្មមាលិយោ ថេរោ ឥមា
គាថាយោ អភាសិត្ថាតិ ។

ធម្មមាលិយត្ថេរស្ស អបទានំ សមត្តំ ។

# ទុតិយំ មណិបូជកត្ថេរាបទានំ

(៦២) បទុមុត្តរោ នាម ជិនោ   សព្វធម្មាន បារគូ
វិវេកកាមោ សម្ពុទ្ធោ   គច្ឆតេ អនិលញ្ជសេ ។
អវិទូរេ ហិមវន្តស្ស   មហាជាតស្សរោ អហុ
តត្ថ មេ ភវនំ អាសិ   បុញ្ញកម្មេន សំយុតំ ។
ភវនា និក្ខមិត្វាន   អទ្ទសំ លោកនាយកំ
ឥន្ទីវរំវ ជលិតំ   អាទិត្តំវ ហុតាសនំ ។



បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនា របស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ។

បានឮថា ព្រះធម្មមាលិយត្ថេរ មានអាយុ បានសម្ដែង នូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

ចប់ ធម្មមាលិយត្ថេរាបទាន ។

# មណិបូជកត្ថេរាបទាន ទី ២

(៦៤) ព្រះជិនស្រីសម្ពុទ្ធ ព្រះនាមបទុមុត្តរៈ ទ្រង់ដល់នូវត្រើយនៃធម៌ទាំងពួង ទ្រង់ប្រាថ្នានូវវិវេក កំពុងតែស្ដេចទៅតាមអាកាស ។ មានជាតស្រះ ដ៏ធំមួយ នៅជិតព្រៃហិមពាន្ត ឯលំនៅរបស់ខ្ញុំ ដែលប្រកបដោយបុញ្ញកម្ម នៅជិតស្រះនោះ ។ ខ្ញុំចេញអំពីលំនៅ បានឃើញព្រះលោកនាយក ទ្រង់ភ្លឺដូចជាផ្កាជត្រឹក្ស រុងរឿងដូចជាភ្លើង ។

វិចិនំ នាទ្ទសិ(១) បុប្ផំ  បូជយំសន្តិ(២) នាយកំ
សកំ ចិត្តំ បសាទេត្វា  អវន្ទឹ សត្ថុនោ អហំ ។
មមំ សីសេ មណឹ(៣) គយ្ហ(៤)  បូជយឹ លោកនាយកំ
ឥមាយ មណិបូជាយ  វិបាកោ ហោតុ ភទ្ទកោ ។
បទុមុត្តរោ លោកវិទូ  អាហុតីនំ បដិគ្គហោ
អន្តលិក្ខេ ឋិតោ សត្ថា  ឥមំ គាថំ អភាសថ ។
សោ តេ ឥជ្ឈតុ សង្កប្បោ  លភតុ វិបុលំ សុខំ
ឥមាយ មណិបូជាយ  អនុភោហិ មហាយសំ ។
ឥទំ វត្វាន សម្ពុទ្ធោ  ជលជុត្តមនាមកោ
អគមាសិ ពុទ្ធសេដ្ឋោ  យស្ស(៥) ចិត្តំ បសាទិតំ ។
សដ្ឋិកប្បានិ ទេវិន្ទោ  ទេវរជ្ជមការយឹ
អនេកសតក្ខត្តុញ្ច  ចក្កវត្តិ អហោសហំ ។

---

១ ម. វិចិនំ នទ្ទសំ ។ ២ បូជយិស្សន្តិ ឥតិ យុត្តតរំ ។ ៣ ឱ. ម. មម សីសេ មណឹ ។ ៤ ម. គណ្ហ ។ ៥ ឱ. ម. យត្ថ ។



ខ្ញុំមិនឃើញផ្កាដែលគួរបេះថ្វាយ ទើបគិតថា អញនឹងបូជាអ្វី ដល់ព្រះលោកនាយក ឲ្យចិត្តរបស់ខ្លួនជ្រះថ្លា ហើយថ្វាយបង្គំព្រះសាស្តានេះ ។ ខ្ញុំយកកែវមណីប្រដាប់ក្បាលនៃខ្ញុំ បូជាព្រះលោកនាយក ទូលព្រះពុទ្ធថា សូមឲ្យផលដ៏ចំរើនសម្រេចដល់ខ្ញុំ ដោយសារបូជាកែវមណីនេះ ។ ព្រះសាស្តា ព្រះនាមបទុមុត្តរៈ ទ្រង់ជ្រាបច្បាស់នូវត្រៃលោក ព្រះអង្គគួរទទួលគ្រឿងបូជា ទ្រង់ឈរសម្តែងក្នុងអាកាស នូវគាថានេះថា កម្មនោះសូមឲ្យសម្រេចដល់អ្នក អ្នកចូរបាននូវសេចក្តីសុខដ៏ធំទូលាយ អ្នកចូរបាននូវយសដ៏ធំ ដោយការបូជានូវកែវមណីនេះចុះ ។ ព្រះសម្ពុទ្ធព្រះនាមបទុមុត្តរៈ លុះពោលពាក្យនេះហើយ ទើបស្តេចចូលទៅ ចិត្តដែលគេតំកល់ទុក ចំពោះបុគ្គលណា (បុគ្គលនោះ) គឺព្រះពុទ្ធដ៏ប្រសើរ ។ ខ្ញុំកើតជាព្រះឥន្ទ្រ ជាស្តេចទេវតា សោយទេវរាជ្យ អស់ ៦០ កប្ប បានជាស្តេចចក្រពត្តិ ច្រើនលើកដង ។

ពុទ្ធានុស្មឹ សវន្តស្ស   ទេវត្តស្ស មេ សតោ
មណិ និព្វត្តតេ មយ្ហំ   អាលោកករណោ មម[១] ។
ឆឡាសីតិសហស្សានិ   នារិយោ មេ បរិគ្គហា
វិចិត្តវត្ថាភរណា   អាមុត្តមណិកុណ្ឌលា ។
អឡារបម្ហា[២] ហសុលា   សុសញ្ញា តនុមជ្ឈិមា
បរិវារេន្តិ មំ និច្ចំ   មណិបូជាយិទំ ផលំ ។
សោណ្ណមយា[៣] មណិមយា   លោហិតង្គមយា[៤] តថា
ភណ្ឌា មេ សុកតា ហោន្តិ   យទិច្ឆសិ បិលន្ធនា[៥] ។
កូដាគារា គុហា រម្មា   សយនញ្ច មហារហំ
មម សង្កប្បមញ្ញាយ   និព្វត្តន្តិ យទិច្ឆកំ ។
លាភា តេសំ សុលទ្ធញ្ច   យេ លភន្តិ ឧបស្សុតឹ
បុញ្ញក្ខេត្តំ មនុស្សានំ   ឱសធំ សព្វបាណិនំ ។

---

១ ម. មមំ ។ ២ ឱ.ប. អាឡារបម្ហា ។ ៣ ឱ. សោវណ្ណមយា ។ ៤ ម. លោហិតង្គ-មយា ។ ៥ ឱ. ភណ្ឌា កតាកតា ហោន្តិ យទិច្ឆាយ បិលន្ធនា ។





ខ្ញុំកាលកើតជាទេវតា មានសតិ បានរលឹកឃើញនូវបុញ្ញកម្ម ឯកែវមណី ជាវត្ថុធ្វើពន្លឺ ក៏កើតឡើង សម្រាប់ខ្ញុំ ។ ខ្ញុំគ្រប់គ្រងនារី ៨៦.០០០ សឹងមានសំពត់និងគ្រឿងអាភរណៈដ៏វិចិត្រ ពាក់នូវកែវមណីនិងកុណ្ឌល ។ នារីទាំងនោះមានមុខទូលាយ ញញឹមស្រស់ មានគ្រគាកល្អ មានចង្កេះរៀវ តែងចោមរោមខ្ញុំជានិច្ច នេះជាផលនៃការបូជាកែវមណី ។ ភណ្ឌៈតាំងខ្លួនរបស់ខ្ញុំ ជាវិការៈនៃមាស ជាវិការៈនៃកែវមណី ជាវិការៈនៃកែវក្រហម ដែលជាងរចនាល្អ ជាគ្រឿងប្រដាប់សម្រេចតាមសេចក្តីប្រាថ្នា ។ ផ្ទះកំពូល គុហាគួរត្រេកអរ ទីដេកមានថ្លៃច្រើន តែងកើតឡើង សមតាមសេចក្តីប្រាថ្នា ព្រោះដឹងតម្រិះរបស់ខ្ញុំ ។ ឱ ! ជាលាភ របស់គេហើយ ឱ ! អត្តភាពជាមនុស្ស ឈ្មោះថាគេបានល្អហើយ ព្រោះហេតុដែលគេបាន នូវការចូលទៅអែបស្តាប់ពុទ្ធេទ ជាបុញ្ញក្ខេត្តរបស់មនុស្ស ជាឱសថរបស់សត្វទាំងពួង ។

បព្វជិំ សុកតំ កម្មំ    យោហំ អទ្ទក្ខិំ នាយកំ
វិពាធា សុមុត្តោម្ហិ(១)    បត្តោម្ហិ(២) អចលំ បទំ ។
យំ យំ យោនូបបជ្ជាមិ    ទេវត្តំ អថ មានុសំ
ទិវសេ រត្តិញ្ច(៣)    អាលោកោ ហោតិ មេ សទា
តាយេវ មណិបូជាយ    អនុភោត្វាន សម្បទា
ញាណាលោកោ មយា ទិដ្ឋោ    បត្តោម្ហិ អចលំ បទំ ។
សតសហស្សេ ឥតោ កប្បេ    យំ មណិមភិបូជយិំ
ទុគ្គតិំ នាភិជានាមិ    មណិបូជាយិទំ ផលំ ។
កិលេសា ឈាបិតា មយ្ហំ    ភវា សព្វេ សមូហតា
នាគោវ ពន្ធនំ ឆេត្វា    វិហរាមិ អនាសវោ ។
ស្វាគតំ វត មេ អាសិ    មម ពុទ្ធស្ស សន្តិកេ
តិស្សោ វិជ្ជា អនុប្បត្តា    កតំ ពុទ្ធស្ស សាសនំ ។
បដិសម្ភិទា ចតស្សោ    វិមោក្ខាបិច អដ្ឋិមេ
ឆឡភិញ្ញា សច្ឆិកតា    កតំ ពុទ្ធស្ស សាសនំ ។

---

១ ម.ម. បមុត្តម្ហិ ។ ២ ម. បត្តោ ប ។ ៣ ម.ម. សមន្តា សព្វតោ ។



អំពើដែលខ្ញុំធ្វើល្អហើយ ព្រោះខ្ញុំបានឃើញព្រះពុទ្ធជានាយក ខ្ញុំរួចស្រឡះហើយចាកវិបាក ខ្ញុំបានដល់នូវអចលបទគឺព្រះនិព្វាន ។ ខ្ញុំទៅកាន់កំណើតណា ៗ គឺជាទេវតា ឬជាមនុស្ស ពន្លឺក៏មានសម្រាប់ខ្ញុំ ទាំងថ្ងៃទាំងយប់ សព្វ ៗ កាល ។ ខ្ញុំសោយសម្បត្តិទាំងឡាយ ដោយសារការបូជានូវកែវមណីនោះឯង ពន្លឺគឺញាណខ្ញុំឃើញហើយ ខ្ញុំបានដល់នូវអចលបទ គឺព្រះនិព្វាន ។ ក្នុងកប្បទីមួយសែន អំពីកប្បនេះ ព្រោះហេតុដែលខ្ញុំបូជាកែវមណី ក្នុងកាលនោះ ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃការបូជាកែវមណី ។ កិលេសទាំងឡាយ ខ្ញុំដុតបំផ្លាញហើយ ភពទាំងពួង ខ្ញុំដកចោលហើយ ខ្ញុំមិនមានអាសវៈ ព្រោះបានកាត់ចំណង ដូចជាដំរីកាត់ផ្តាច់នូវចំណង ។ ឱ ! ខ្ញុំមកល្អហើយ ក្នុងសំណាក់នៃព្រះពុទ្ធរបស់ខ្ញុំ វិជ្ជា ៣ ខ្ញុំបានដល់ហើយ សាសនា របស់ព្រះពុទ្ធ ខ្ញុំបានធ្វើហើយ ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនា របស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ។

ឥត្ថំ សុទំ អាយស្មា មណិបូជកោ ថេរោ ឥមា គាថាយោ អភាសិត្ថាតិ ។

មណិបូជកត្ថេរស្ស អបទានំ សមត្តំ ។

## តតិយំ ឧក្កាសតិកត្ថេរាបទានំ

[៦៣] កោសិកោ នាម ភគវា ចិត្តកូដេ វសី តទា
ឈាយី ឈានរតោ ពុទ្ធោ វិវេកាភិរតោ មុនិ ។
អជ្ឈោគហេត្វា ហិមវន្តំ នារីគណបុរក្ខតោ
អទ្ទសំ កោសិកំ ពុទ្ធំ បុណ្ណមាយេវ(១) ចន្ទិមំ ។
ឧក្កាសតេ គហេត្វាន បរិវារេសហន្តទា
សត្តរត្តិន្ទិវំ ពុទ្ធំ(២) អដ្ឋមេន អគច្ឆហំ ។
វុដ្ឋិតំ កោសិកំ ពុទ្ធំ សយម្ភុំ អបរាជិតំ
បសន្នចិត្តោ វន្ទិត្វា ឯកំ ភិក្ខំ អទាសហំ ។

១ ម. បុណ្ណមាសេវ ។ ២ ម. បត្វា ។ ម. ពុទ្ធោ ។





បានឮថា ព្រះមណិបូជកត្ថេរ មានអាយុ បានសម្តែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

ចប់ មណិបូជកត្ថេរាបទាន ។

## ឧក្កាសតិកត្ថេរាបទាន ទី ៣

(៦៣) កាលនោះ ព្រះមានព្រះភាគ ជាមុនី ព្រះនាមកោសិកៈ ព្រះអង្គមានឈាន ត្រេកអរក្នុងឈាន អភិរម្យក្នុងវិវេក គង់នៅលើភ្នំចិត្តកូដ ។ ខ្ញុំមានពួកនារីហែហមកោម ដើរចូលទៅក្នុងព្រៃហិមពាន្ត បានឃើញព្រះពុទ្ធ ព្រះនាមកោសិកៈ ដូចព្រះចន្ទពេញបូណ៌មី ។ ក្នុងកាលនោះ ខ្ញុំកាន់គប់ភ្លើង ១០០ ឈរគ្រវេបំភ្លឺព្រះពុទ្ធ អស់៧យប់៧ថ្ងៃ ខ្ញុំត្រឡប់ទៅផ្ទះវិញ ក្នុងថ្ងៃទី ៨ ។ ខ្ញុំមានចិត្តជ្រះថ្លា ថ្វាយបង្គំព្រះពុទ្ធ ព្រះនាមកោសិកៈ ជាព្រះសយម្ភូ ទ្រង់ឈ្នះកិលេស ព្រះអង្គស្តេចចេញ ខ្ញុំបានថ្វាយភិក្ខាមួយចំណែក ។

តេន កម្មេន ទិបទិន្ទ លោកជេដ្ឋ នរាសភ
ឧប្បជ្ជឹ តុសិតេ កាយេ ឯកភិក្ខាយិទំ ផលំ ។
ទិវសេ ចេវ រត្តិញ្ច អាលោកោ ហោតិ មេ សទា
សមន្តា យោជនសតំ ឱភាសេន ផរាមហំ ។
បញ្ចបញ្ញាសកប្បម្ហិ ចក្កវត្តិ អហោសហំ
ចាតុរន្តោ វិជិតាវី ជម្ពុមណ្ឌស្ស ឥស្សរោ ។
តទា មេ នគរំ អាសិ ឥទ្ធំ ផីតំ សុនិម្មិតំ
តឹសយោជនអាយាមំ វិត្ថារេន ច វីសតិ ។
សោភនំ នាម នគរំ វិស្សុកម្មេន(១) មាបិតំ
ទសសទ្ទា វិវិត្តំ សម្មតាឡសមាហិតំ ។
ន តម្ហិ នគរេ អត្ថិ វល្លិ កដ្ឋញ្ច មត្តិកា
សព្វសោណ្ណមយំ យេវ ជោតតេ និច្ចកាលិកំ ។

---

១ ឱ. វិស្សកម្មេន ។



បពិត្រព្រះអង្គជាធំជាងសត្វពីរជើង ជាច្បងក្នុងលោក ប្រសើរជាងពួកនរៈ ខ្ញុំទៅកើតក្នុងឋានតុសិត ដោយកម្មនោះ នេះជាផលនៃភិក្ខាមួយចំណែក ។ ពន្លឺរមែងមានដល់ខ្ញុំ ទាំងថ្ងៃទាំងយប់ សព្វ១កាល ខ្ញុំផ្សាយពន្លឺទៅកាន់ទី ១០០ យោជន៍ ដោយជុំវិញ ។ ក្នុងកប្បទី ៥៥ ខ្ញុំបានជាស្តេចចក្រពត្តិឈ្នះសង្គ្រាម មានសមុទ្រទាំង ៤ ជាព្រំប្រទល់ ជាធំក្នុងមណ្ឌលនៃជម្ពូទ្វីប ។ ក្នុងកាលនោះ នគររបស់ខ្ញុំ សម្បូណ៌ កុះករ ដែលវិស្សុកម្មនិម្មិតល្អហើយ ទីក្រុងនោះ មានបណ្តោយប្រវែង ៣០ យោជន៍ ទទឹងប្រវែង ២០ យោជន៍ ។ ទីក្រុងនោះ ឈ្មោះសោភនៈ ដែលវិស្សុកម្មនិម្មិតហើយ ជាទីស្ងប់ស្ងាត់ចាកសំឡេងទាំង ១០ ប្រការ ប្រកបដោយភ្លេងប្រគំដ៏ពីរោះ ។ ក្នុងនគរនោះ មិនមានវល្លិ ឈើ ដីស្អិត មានសុទ្ធតែមាសទាំងអស់ រុងរឿងអស់កាលជានិច្ច ។

ចតុបាការបរិក្ខិត្តំ តយោ គព្ភា បណាមយា
វេមជ្ឈេ មាលបន្តិ(១) ច វិស្សុកម្មេន មាបិតា ។
ទសសហស្សពោក្ខរណី(២) បទុមុប្បលឆាទិតា
បុណ្ឌរីកាទិសញ្ឆន្នា នានាគន្ធសមេរិតា ។
ចតុន្នវុតេ ឥតោ កប្បេ យំ ឧក្កំ ធារយឹ អហំ
ទុគ្គតឹ នាភិជានាមិ ឧក្កាធារស្សិទំ ផលំ ។
កិលេសា ឈាបិតា មយ្ហំ ភវា សព្វេ សមូហតា
នាគោវ ពន្ធនំ ឆេត្វា វិហរាមិ អនាសវោ ។
ស្វាគតំ វត មេ អាសិ មម ពុទ្ធស្ស សន្តិកេ
តិស្សោ វិជ្ជា អនុប្បត្តា កតំ ពុទ្ធស្ស សាសនំ ។
បដិសម្ភិទា ចតស្សោ វិមោក្ខាបិច អដ្ឋិមេ
ឆឡភិញ្ញា សច្ឆិកតា កតំ ពុទ្ធស្ស សាសនន្តិ ។

---

១ ឱ, ពាលបន្តិ ។ ២ ឱ, ទសសហស្សា ពោក្ខរញ្ញោ ។ ឱ, ទសសហស្ស ពោក្ខរញ្ញោ ។





ដំណាក់មានរបស់ ៣ យ៉ាងនេះគឺ កំពែងបួនជ្រុង ១ របៀបដើម ត្រគេជាវិការៈនៃកែវមណីក្នុងទីកាត់កណ្ដាល ដែលវិស្សុកម្មនិម្មិតល្អហើយ ១ ស្រះបោក្ខរណីមួយម៉ឺន មានឈូកឧប្បលគ្រប់គ្រាក ដេរដាសដោយឈូកសជាដើម ផ្សាយក្លិនផ្សេងៗ ១ ។ ក្នុងកប្បទី ៩៤ អំពីកប្បនេះ ព្រោះហេតុដែលខ្ញុំបំភ្លឺគប់ភ្លើង ក្នុងកាលនោះ ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃការបំភ្លឺគប់ភ្លើង ។ កិលេសទាំងឡាយ ខ្ញុំដុតបំផ្លាញហើយ ភពទាំងពួង ខ្ញុំដកពោលហើយ ខ្ញុំមិនមានអាសវៈ ព្រោះបានកាត់ចំណង ដូចដំរីកាត់ផ្ដាច់ខ្សែទន្ទឹង ។ ឱ! ខ្ញុំមកល្អហើយ ក្នុងសំណាក់នៃព្រះពុទ្ធរបស់ខ្ញុំ វិជ្ជា ៣ ខ្ញុំបានដល់ហើយ សាសនារបស់ព្រះពុទ្ធ ខ្ញុំបានធ្វើហើយ ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនា របស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ។

ឥត្ថំ សុទំ អាយស្មា ឧក្ខាសតិកោ ថេរោ ឥមា គាថាយោ អភាសិត្ថាតិ ។

ឧក្ខាសតិកត្ថេរស្ស អបទានំ សមត្តំ ។

## ចតុត្ថំ សុមនវីជនិយត្ថេរាបទានំ

(៦៤) វិបស្សិនោ ភគវតោ ពោធិយា បាទបុត្តមេ
សុមនោ ពីជនឹ គយ្ហ អវីជឹ ពោធិមុត្តមំ ។
ឯកនវុតេ ឥតោ កប្បេ អវីជឹ ពោធិមុត្តមំ
ទុគ្គតឹ នាភិជានាមិ ពីជនាយ ឥទំ ផលំ ។
កិលេសា ឈាបិតា មយ្ហំ ភវា សព្វេ សមូហតា
នាគោវ ពន្ធនំ ឆេត្វា វិហរាមិ អនាសវោ ។
ស្វាគតំ វត មេ អាសិ មម ពុទ្ធស្ស សន្តិកេ
តិស្សោ វិជ្ជា អនុប្បត្តា កតំ ពុទ្ធស្ស សាសនំ ។



បានឮថា ព្រះឧក្ខាសតិកត្ថេរ មានអាយុ បានសំដែងនូវគាថា ទាំងនេះ ដោយប្រការដូច្នេះ ។

ចប់ ឧក្ខាសតិកត្ថេរាបទាន ។

## សុមនវីជនិយត្ថេរាបទាន ទី ៤

(៦៤) ខ្ញុំមានចិត្តរីករាយ ចំពោះពោធិព្រឹក្សដ៏ឧត្តម របស់ព្រះមានព្រះភាគ ព្រះនាមវិបស្សី ហើយយកផ្លិតទៅ បក់ថ្វាយ នូវពោធិព្រឹក្សដ៏ឧត្តម ។ ក្នុងកប្បទី ៩១ អំពី កប្បនេះ ព្រោះហេតុដែលខ្ញុំ បានបក់នូវពោធិព្រឹក្សដ៏ ឧត្តម ក្នុងកាលនោះ ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផល នៃការបក់ផ្លិត ។ កិលេសទាំងឡាយ ខ្ញុំដុតបំផ្លាញហើយ ភពទាំងពួង ខ្ញុំដកចោលហើយ ខ្ញុំមិនមានអាសវៈ ព្រោះ បានកាត់ចំណង ដូចជាដំរីកាត់ផ្តាច់នូវទន្លីង ។ ឱ ! ខ្ញុំមក ល្អហើយ ក្នុងសំណាក់នៃព្រះពុទ្ធរបស់ខ្ញុំ វិជ្ជា ៣ ខ្ញុំបាន ដល់ហើយ សាសនា របស់ព្រះពុទ្ធ ខ្ញុំបានធ្វើហើយ ។

បដិសម្ភិទា ចតស្សោ វិមោក្ខាបិ ច អដ្ឋិមេ
ឆឡភិញ្ញា សច្ឆិកតា កតំ ពុទ្ធស្ស សាសនំ ។

ឥត្ថំ សុទំ អាយស្មា សុមនវីជនិយោ ថេរោ ឥមា
គាថាយោ អភាសិត្ថាតិ ។

សុមនវីជនិយត្ថេរស្ស អបទានំ សមត្តំ ។

## បញ្ចមំ កុម្មាសទាយកត្ថេរាបទានំ

(៦៥) ឯសនាយ ចរន្តស្ស វិបស្សិស្ស មហេសិនោ
រិត្តកំ បត្តំ ទិស្វាន កុម្មាសំ បូរយឹ អហំ ។
ឯកនវុតេ ឥតោ កប្បេ យំ ភិក្ខំ អទទឹ តទា
ទុគ្គតឹ នាភិជានាមិ កុម្មាសស្ស ឥទំ ផលំ ។



បដិសម្ភិទា ៤ វិមោក្ខ ៨ អភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនា របស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ។

បានឮថា ព្រះសុមនវីជនិយត្ថេរ មានអាយុ បានសម្ដែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

ចប់ សុមនវីជនិយត្ថេរាបទាន ។

## កុម្មាសទាយកត្ថេរាបទាន ទី ៥

(៦៥) កាលព្រះពុទ្ធ ព្រះនាមវិបស្សី ទ្រង់ស្វែងរកគុណដ៏ធំ ទ្រង់ស្តេចទៅដើម្បីបិណ្ឌបាត ខ្ញុំឃើញបាត្រទទេហើយ ក៏ដាក់នំឲ្យពេញ (បាត្រ) ។ ក្នុងកប្បទី ៩១ អំពីកប្បនេះ ព្រោះហេតុដែលខ្ញុំបានឲ្យនូវភិក្ខា ក្នុងកាលនោះ ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃនំ ។

កិលេសា ឈាបិតា មយ្ហំ ភវា សព្វេ សមូហតា
នាគោវ ពន្ធនំ ឆេត្វា វិហរាមិ អនាសវោ ។
ស្វាគតំ វត មេ អាសិ មម ពុទ្ធស្ស សន្តិកេ
តិស្សោ វិជ្ជា អនុប្បត្តា កតំ ពុទ្ធស្ស សាសនំ ។
បដិសម្ភិទា ចតស្សោ វិមោក្ខាបិច អដ្ឋិមេ
ឆឡភិញ្ញា សច្ឆិកតា កតំ ពុទ្ធស្ស សាសនំ ។

ឥត្ថំ សុទំ អាយស្មា កុម្មាសទាយកោ ថេរោ ឥមា គាថាយោ អភាសិត្ថាតិ ។

កុម្មាសទាយកត្ថេរស្ស អបទានំ សមត្តំ ។

## ឆដ្ឋំ កុសដ្ឋកទាយកត្ថេរាបទានំ

(៦៦) កស្សបស្ស ភគវតោ ព្រាហ្មណស្ស វុសីមតោ
បសន្នចិត្តោ សុមនោ កុសដ្ឋកមទាសហំ ។



កិលេសទាំងឡាយ ខ្ញុំដុតបំផ្លាញហើយ ភពទាំងពួង ខ្ញុំដកចោលហើយ ខ្ញុំមិនមានអាសវៈ ព្រោះបានកាត់ចំណង ដូចដំរីកាត់ផ្តាច់ខ្សែទន្លីង ។ ឱ ! ខ្ញុំមកល្អហើយ ក្នុងសំណាក់នៃព្រះពុទ្ធរបស់ខ្ញុំ វិជ្ជា ៣ ខ្ញុំបានដល់ហើយ សាសនារបស់ព្រះពុទ្ធ ខ្ញុំបានធ្វើហើយ ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនា របស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ។

បានឮថា ព្រះកុម្មាសទាយកត្ថេរ មានអាយុ បានសម្តែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

ចប់ កុម្មាសទាយកត្ថេរាបទាន ។

## កុសដ្ឋកទាយកត្ថេរាបទាន ទី ៦

(៦៦) ខ្ញុំមានចិត្តជ្រះថ្លា មានចិត្តរីករាយ បានថ្វាយស្លាក ៨ ក្តាប់ ដល់ព្រះមានព្រះភាគ ព្រះនាមកស្សបៈ ជាទីណាសព្រាហ្មណ៍ ព្រះអង្គមានព្រហ្មចរិយធម៌នៅរួចហើយ ។

ឯកម្ហិយេវ កប្បម្ហិ កុសដ្ឋកមទាសហំ
ទុគ្គតិំ នាភិជានាមិ កុសដ្ឋកស្សិទំ ផលំ ។
កិលេសា ឈាបិតា មយ្ហំ ភវា សព្វេ សមូហតា
នាគោវ ពន្ធនំ ឆេត្វា វិហរាមិ អនាសវោ ។
ស្វាគតំ វត មេ អាសិ មម ពុទ្ធស្ស សន្តិកេ
តិស្សោ វិជ្ជា អនុប្បត្តា កតំ ពុទ្ធស្ស សាសនំ ។
បដិសម្ភិទា ចតស្សោ វិមោក្ខាបិច អដ្ឋិមេ
ឆឡភិញ្ញា សច្ឆិកតា កតំ ពុទ្ធស្ស សាសនំ ។

ឥត្ថំ សុទំ អាយស្មា កុសដ្ឋកទាយកោ ថេរោ ឥមា គាថាយោ អភាសិត្ថាតិ ។

កុសដ្ឋកទាយកត្ថេរស្ស អបទានំ សមត្តំ ។

## សត្តមំ គិរិបុន្នាគិយត្ថេរាបទានំ

(៦៧) សោភិតោ នាម សម្ពុទ្ធោ ចិត្តកូដេ វសី តទា
គហេត្វា គិរិបុន្នាគំ សយម្ភុំ អភិបូជយឹ ។





ក្នុងកប្បនេះឯង ព្រោះហេតុដែលខ្ញុំបានថ្វាយស្បូវ ៨ ក្តាប់ ក្នុងកាលនោះ ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃស្បូវ ៨ ក្តាប់ ។ កិលេសទាំងឡាយ ខ្ញុំដុតបំផ្លាញហើយ ភពទាំង-ពួង ខ្ញុំដកចោលហើយ ខ្ញុំមិនមានអាសវៈ ព្រោះបានកាត់ចំណង ដូចជាដំរីកាត់ផ្តាច់ទន្លប់ទន្ទឹង ។ ឱ ! ខ្ញុំមកល្អហើយ ក្នុងសំណាក់នៃព្រះពុទ្ធរបស់ខ្ញុំ វិជ្ជា ៣ ខ្ញុំបានដល់ហើយ សាសនា របស់ព្រះពុទ្ធ ខ្ញុំបានធ្វើហើយ ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនា របស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ។

បានឮថា ព្រះកុសដ្ឋកទាយកត្ថេរ មានអាយុ បានសម្តែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

ចប់ កុសដ្ឋកទាយកត្ថេរាបទាន ។

## គិរិបុន្នាគិយត្ថេរាបទាន ទី ៧

(៦៧) គ្រានោះ ព្រះសម្ពុទ្ធព្រះនាមសោភិតៈ ទ្រង់គង់លើភ្នំចិត្តកូដ ខ្ញុំយកផ្កាបុសនាគភ្នំ ទៅបូជាព្រះសយម្ភូ ។

ចតុន្នវុតេ ឥតោ កប្បេ សម្ពុទ្ធមភិបូជយឹ[១]

ទុគ្គតឹ នាភិជានាមិ ពុទ្ធបូជាយិទំ ផលំ ។

កិលេសា ឈាបិតា មយ្ហំ ភវា សព្វេ សមូហតា

នាគោវ ពន្ធនំ ឆេត្វា វិហរាមិ អនាសវោ ។

ស្វាគតំ វត មេ អាសិ មម ពុទ្ធស្ស សន្តិកេ

តិស្សោ វិជ្ជា អនុប្បត្តា កតំ ពុទ្ធស្ស សាសនំ ។

បដិសម្ភិទា ចតស្សោ វិមោក្ខាបិច អដ្ឋិមេ

ឆឡភិញ្ញា សច្ឆិកតា កតំ ពុទ្ធស្ស សាសនន្តិ ។

ឥត្ថំ សុទំ អាយស្មា តិបុប្ផិយោ ថេរោ ឥមា គាថាយោ អភាសិត្ថាតិ ។

តិបុប្ផិយត្ថេរស្ស អបទានំ សមត្តំ ។

---

១ ឱ.ម. យំ ពុទ្ធមភិបូជយឹ ។



ក្នុងកប្បទី ៩៤ អំពីកប្បនេះ ព្រោះហេតុដែលខ្ញុំបូជានូវព្រះសម្ពុទ្ធ ក្នុងកាលនោះ ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃពុទ្ធបូជា ។ កិលេសទាំងឡាយ ខ្ញុំដុតបំផ្លាញហើយ ភពទាំងពួង ខ្ញុំដកចោលហើយ ខ្ញុំមិនមានអាសវៈ ព្រោះបានកាត់ចំណង ដូចជាដំរីកាត់ផ្ដាច់នូវទន្លីង ។ ឱ! ខ្ញុំមកល្អហើយ ក្នុងសំណាក់នៃព្រះពុទ្ធរបស់ខ្ញុំ វិជ្ជា ៣ ខ្ញុំបានដល់ហើយ សាសនា របស់ព្រះពុទ្ធ ខ្ញុំបានធ្វើហើយ ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនា របស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ។

បានឮថា ព្រះតិបុប្ផិយត្ថេរ មានអាយុ បានសំដែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

ចប់ តិបុប្ផិយត្ថេរាបទាន ។

## អដ្ឋមំ វល្លិការផលទាយកត្ថេរាបទានំ

(៦៨) សុមេធោ នាម សម្ពុទ្ធោ តក្ការាយំ វសី តទា
វល្លិការផលំ គយ្ហ សយម្ភុស្ស អទាសហំ ។
ឯកត្តឹសេ ឥតោ កប្បេ យំ ផលំ អទទឹ តទា
ទុគ្គតឹ នាភិជានាមិ ផលទានស្សិទំ ផលំ ។
កិលេសា ឈាបិតា មយ្ហំ ភវា សព្វេ សមូហតា
នាគោវ ពន្ធនំ ឆេត្វា វិហរាមិ អនាសវោ ។
ស្វាគតំ វត មេ អាសិ មម ពុទ្ធស្ស សន្តិកេ
តិស្សោ វិជ្ជា អនុប្បត្តា កតំ ពុទ្ធស្ស សាសនំ ។
បដិសម្ភិទា ចតស្សោ វិមោក្ខាបិច អដ្ឋិមេ
ឆឡភិញ្ញា សច្ឆិកតា កតំ ពុទ្ធស្ស សាសនំ ។

ឥត្ថំ សុទំ អាយស្មា វល្លិការផលទាយកោ ថេរោ ឥមា គាថាយោ អភាសិត្ថាតិ ។

វល្លិការផលទាយកត្ថេរស្ស អបទានំ សត្តមំ ។

## វល្លិការផលទាយកត្ថេរាបទាន ទី ៧

(៦៨) គ្រានោះ ព្រះសម្ពុទ្ធ ព្រះនាមសុមេធៈ គង់នៅក្នុងក្រុងឈ្មោះតក្ករ ខ្ញុំបានយកផ្លែគុយ ទៅថ្វាយព្រះសយម្ភូ ។ ក្នុងកប្បទី ៣១ អំពីកប្បនេះ ព្រោះហេតុដែលខ្ញុំបានថ្វាយផ្លែឈើ ក្នុងកាលនោះ ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផល នៃការថ្វាយផ្លែឈើ ។ កិលេសទាំងឡាយ ខ្ញុំដុតបំផ្លាញហើយ ភពទាំងអស់ ខ្ញុំដកចោលហើយ ខ្ញុំមិនមានអាសវៈ ព្រោះបានកាត់បំណង ដូចជាដំរីកាត់ផ្តាច់នូវទន្លីង ។ ឱ ! ខ្ញុំមកល្អហើយ ក្នុងសំណាក់នៃព្រះពុទ្ធរបស់ខ្ញុំ វិជ្ជា ៣ ខ្ញុំបានដល់ហើយ សាសនារបស់ព្រះពុទ្ធ ខ្ញុំបានធ្វើហើយ ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនា របស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ។

បានឮថា ព្រះវល្លិការផលទាយកត្ថេរ មានអាយុ បានសំដែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

ចប់ វល្លិការផលទាយកត្ថេរាបទាន ។

## នវមំ ឧបាហនទាយកត្ថេរាបទានំ

(៦៩) អនោមទស្សី ភគវា លោកជេដ្ឋោ នរាសភោ

ទិវាវិហារា និក្ខម្ម វីថិមារុយ្ហ(១) ចក្ខុមា ។

ឧបាហនំ សុកតំ គយ្ហ អទ្ធានំ បដិបជ្ជហំ

តត្ថទ្ទសាសឹ សម្ពុទ្ធំ បត្តិកំ ចារុទស្សនំ ។

សកំ ចិត្តំ បសាទេត្វា និហរិត្វាន ឧបាហនំ

ឧបាហនេ ឋបេត្វាន ឥទំ វចនមព្រវឹ ។

អភិរូហ មហាវីរ សុគតិន្ទ វិនាយក

ឥតោ ផលំ លភិស្សាមិ សោ មេ អត្ថោ សមិជ្ឈតុ ។

អនោមទស្សី ភគវា លោកជេដ្ឋោ នរាសភោ

ឧបាហនំ អភិរូហិត្វា ឥទំ វចនមព្រវិ ។

---

១ ឱ ម. មគ្គមារោ ។





## ឧបាហនទាយកត្ថេរាបទាន ទី ៩

[៦៩] ព្រះមានព្រះភាគ ព្រះនាមអនោមទស្សី ជាធំក្នុងលោក ប្រសើរជាងនរៈ មានចក្ខុ ទ្រង់ចេញអំពីកន្លែងសម្រាកក្នុងវេលាថ្ងៃ ស្តេចទៅតាមថ្នល់ ។ ខ្ញុំកាន់ស្បែកជើងដែលខ្ញុំធ្វើល្អហើយ ដើរទៅកាន់ផ្លូវឆ្ងាយ បានឃើញព្រះសម្ពុទ្ធ ទ្រង់ស្តេចទៅដោយព្រះបាទទទេ ព្រះអង្គមានព្រះកាយ ប្រកបដោយគ្រឿងប្រដាប់ដូចមាស ។ ខ្ញុំញុំាងចិត្តរបស់ខ្លួនឲ្យជ្រះថ្លា យកស្បែកជើងទៅតំកល់ទុក ជិតព្រះបាទ ហើយពោលនូវពាក្យនេះថា បពិត្រព្រះសុគតជាធំ ជានាយក មានព្យាយាមច្រើន សូមព្រះអង្គពាក់នូវស្បែកជើង ខ្ញុំព្រះអង្គនឹងបាននូវផល អំពីស្បែកជើងនេះ សូមឲ្យសម្រេចប្រយោជន៍នោះដល់ខ្ញុំ ។ ព្រះមានព្រះភាគ ព្រះនាមអនោមទស្សី ជាធំក្នុងលោក ប្រសើរជាងនរៈ ទ្រង់ពាក់នូវស្បែកជើង ហើយត្រាស់ព្រះគាថានេះថា

យោ ទានំ មេ អទាសិ បសន្នោ សេហិ បាណិភិ

តមហំ កិត្តយិស្សាមិ សុណាថ មម ភាសតោ ។

ពុទ្ធស្ស គិរមញ្ញាយ សព្វេ ទេវា សមាគតា

ឧទគ្គចិត្តា សុមនា វេទជាតា កតញ្ជលី ។

ទានង៉េមេវ ទានេន[១] សុចិតោយំ ភវិស្សតិ

បញ្ចបញ្ញាសក្ខត្តុំ ទេវរជ្ជំ ករិស្សតិ ។

សហស្សក្ខត្តុំ រាជា ច ចក្កវត្តី ភវិស្សតិ

បទេសរជ្ជំ វិបុលំ គណនាតោ អសង្ខិយំ ។

អបរិមេយ្យេ ឥតោ កប្បេ ឱក្កាកកុលសម្ភវោ

គោតមោ នាម នាមេន សត្ថា លោកេ ភវិស្សតិ ។

តស្ស ធម្មេសុ ទាយាទោ ឱរសោ ធម្មនិម្មិតោ

សព្វាសវេ បរិញ្ញាយ និព្វាយិស្សតិនាសវោ ។

---

១ ឱ.ម. ទានេនំ បកាសេត ។





បុគ្គលណាមានចិត្តជ្រះថ្លា បានថ្វាយស្បៀងដល់តថាគត ដោយដៃរបស់ខ្លួន តថាគតនឹងសរសើរបុគ្គលនោះ អ្នកទាំងឡាយចូរស្តាប់ នូវការសំដែងដែលតថាគតនឹងសំដែងចុះ ។ ទេវតាទាំងអស់ បានដឹងនូវពាក្យរបស់ព្រះពុទ្ធ ក៏មកប្រជុំគ្នា មានចិត្តខ្ពស់ឡើង មានចិត្តរីករាយ មានសេចក្តីត្រេកអរធ្វើនូវអញ្ជលី ។ បុគ្គលនេះនឹងដល់នូវសេចក្តីសុខ ព្រោះការថ្វាយនូវស្បៀងដើង នឹងសោយរាជ្យជាស្តេចទេវតាអស់ ៥៥ ដង ។ នឹងបានជាស្តេចចក្រពត្តិមួយពាន់ដង នឹងសោយបទេសរាជ្យដ៏ធំទូលាយ រាប់ជាតិមិនអស់ ។ ក្នុងកប្បប្រមាណមិនបាន អំពីកប្បនេះ ព្រះសាស្តាមាននាមថាគោតម ទ្រង់កើតក្នុងត្រកូលឱក្កាកៈ នឹងបានត្រាស់ក្នុងលោក ។ (បុរសនេះ) នឹងបានជាអ្នកទទួលនូវមត៌ក ក្នុងធម៌របស់ព្រះគោតមនោះ ជាឱរសដែលធម៌និម្មិតហើយ កំណត់ដឹងនូវអាសវៈទាំងពួង ជាអ្នកមិនមានអាសវៈ នឹងបរិនិព្វាន ។

ទេវលោកេ មនុស្សេ វា និព្វត្តិស្សតិ បញ្ញវា
ទេវយានបដិភាគំ យានំ បដិលភិស្សតិ ។

បាសាទា សិវិកា វយ្ហំ ហត្ថិនោ សមលង្កតា
រថា វាជញ្ញសំយុត្តា សទា បាតុភវន្តិ មេ ។

អគារា និក្ខមន្តោបិ រថេន និក្ខមឹ អហំ
កេសេសុ ឆិជ្ជមានេសុ អរហត្តំ អបាបុណឹ ។

លាភា មយ្ហំ សុលទ្ធំ មេ វាណិជំ សុប្បយោជិតំ
ទត្វាន បានធឹ ឯកំ បត្តោម្ហិ អចលំ បទំ ។

អបរិមេយ្យេ ឥតោ កប្បេ យំ ទានមទាសហំ
ទុគ្គតឹ នាភិជានាមិ ទានស្ស ឥទំ ផលំ ។



(បុរសនេះឯង) បើកើតក្នុងទេវលោក ឬក្នុងមនុស្សលោក រមែងជាអ្នកមានប្រាជ្ញា នឹងបាននូវយាន មានចំណែកប្រៀបដោយយានទេវតា ។

ប្រាសាទ វោមាស ដំរីប្រដាប់ព្រមហើយ រថដែលទឹមដោយសេះអាជានេយ្យ រមែងកើតប្រាកដដល់ខ្ញុំ សព្វ ៗ កាល ។ ខ្ញុំទុកជាកាលចេញទៅអំពីលំនៅ តែងចេញទៅដោយរថ កាលសក់កំពុងគេកោរ ខ្ញុំក៏បានដល់អរហត្ត ។ ឱ! ជាលាភរបស់ខ្ញុំហើយ អត្តភាពជាមនុស្ស ឈ្មោះថាខ្ញុំបានល្អហើយ ការជួញ ខ្ញុំប្រកបល្អហើយ ព្រោះខ្ញុំបានថ្វាយស្បែកជើងមួយសម្រាប់ ក៏បានដល់អចលបទគឺព្រះនិព្វាន ។ ក្នុងកប្បប្រមាណមិនបាន អំពីកប្បនេះ ព្រោះហេតុដែលខ្ញុំបានឲ្យស្បែកជើង ក្នុងកាលនោះ ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃស្បែកជើង ។

កិលេសា ឈាបិតា មយ្ហំ ភវា សព្វេ សមូហតា
នាគោវ ពន្ធនំ ឆេត្វា វិហរាមិ អនាសវោ ។
ស្វាគតំ វត មេ អាសិ មម ពុទ្ធស្ស សន្តិកេ
តិស្សោ វិជ្ជា អនុប្បត្តា កតំ ពុទ្ធស្ស សាសនំ ។
បដិសម្ភិទា ចតស្សោ វិមោក្ខាបិ ច អដ្ឋិមេ
ឆឡភិញ្ញា សច្ឆិកតា កតំ ពុទ្ធស្ស សាសនន្តិ ។

ឥត្ថំ សុទំ អាយស្មា ពានធិយកោ ថេរោ ឥមា គាថាយោ អភាសិត្ថាតិ ។

ពានធិយកត្ថេរស្ស អបទានំ សមត្តំ ។

# ទសមំ បុប្ផចង្កោដិយត្ថេរាបទានំ

(៧០) មិគលុទ្ទោ បុរេ អាសិ អរញ្ញេ កាននេ អហំ
វាតមិគំ គវេសន្តោ ចង្កមំ អទ្ទសំ អហំ ។
ឧច្ចង្គេន បុប្ផំ គយ្ហ ចង្កមេ ឱកិរឹ អហំ
បសន្នចិត្តោ សុមនោ សុគតស្ស សិរីមតោ ។





កិលេសទាំងឡាយ ខ្ញុំដុតបំផ្លាញហើយ ភពទាំងពួង ខ្ញុំដកចោលអស់ហើយ ខ្ញុំជាអ្នកមិនមានអាសវៈ ព្រោះបានកាត់ចំណង ដូចជាដំរីកាត់ផ្តាច់នូវទន្ទឹង ៗ ឱ ! ខ្ញុំមកល្អហើយ ក្នុងសំណាក់នៃព្រះពុទ្ធរបស់ខ្ញុំ វិជ្ជា ៣ ខ្ញុំបានដល់ហើយ សាសនា របស់ព្រះពុទ្ធ ខ្ញុំបានធ្វើហើយ ៗ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនា របស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ៗ

បានឮថា ព្រះពានធិយកត្ថេរ មានអាយុ បានសម្តែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ៗ

ចប់ ពានធិយកត្ថេរបទាន ៗ

# បុប្ផចង្កោដិយត្ថេរាបទាន ទី ១០

(៧០) ក្នុងកាលមុន ខ្ញុំកើតជាព្រានម្រឹគនៅក្នុងព្រៃ កំពុងស្វែងរកសត្វឈ្លូស ក៏បានឃើញនូវទីចង្ក្រម ៗ ខ្ញុំមានចិត្តជ្រះថ្លា មានចិត្តរីករាយ ចំពោះព្រះសុគត ទ្រង់មានសិរី ហើយកើបយកផ្កាខ្ទប់មួយថ្លុក មករោយក្នុងទីចង្ក្រម ៗ

ឯកត្តឹសេ ឥតោ កប្បេ ពុទ្ធិំ ចិត្តំ លភឹ

ទុគ្គតឹ នាភិជានាមិ ពុទ្ធិនស្ស ឥទំ ផលំ ។

កិលេសា ឈាបិតា មយ្ហំ ភវា សព្វេ សមូហតា

នាគោវ ពន្ធនំ ឆេត្វា វិហរាមិ អនាសវោ ។

ស្វាគតំ វត មេ អាសិ មម ពុទ្ធស្ស សន្តិកេ

តិស្សោ វិជ្ជា អនុប្បត្តា កតំ ពុទ្ធស្ស សាសនំ ។

បដិសម្ភិទា ចតស្សោ វិមោក្ខាបិច អដ្ឋិមេ

ឆឡភិញ្ញា សច្ឆិកតា កតំ ពុទ្ធស្ស សាសនំ ។

ឥត្ថំ សុទំ អាយស្មា ពុទ្ធសញ្ញិកោ ថេរោ ឥមា

គាថាយោ អភាសិត្ថាតិ ។

ពុទ្ធសញ្ញិកត្ថេរស្ស អបទានំ សមត្តំ ។



ក្នុងកប្បទី ៣១ អំពីភទ្ទកប្បនេះ ព្រោះហេតុដែលខ្ញុំ បាន

ទៅយកយន្តដីខ្ជប់ ក្នុងកាលនោះ ខ្ញុំមិនដែលស្គាល់ទុគ្គតិ

នេះជាផលនៃដីខ្ជប់ ។ កិលេសទាំងឡាយ ខ្ញុំដុតបំផ្លាញ

ហើយ ភពទាំងអស់ ខ្ញុំដកហោលហើយ ខ្ញុំមិនមានអាសវៈ

ព្រោះបានកាត់ចំណង ដូចជាដំរីកាត់ផ្តាច់ទន្លប់ ។ ឱ ! ខ្ញុំ

មកល្អហើយ ក្នុងសំណាក់នៃព្រះពុទ្ធរបស់ខ្ញុំ វិជ្ជា ៣ ខ្ញុំបាន

ដល់ហើយ សាសនា របស់ព្រះពុទ្ធ ខ្ញុំបានធ្វើហើយ ។

បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យ

ជាក់ច្បាស់ហើយ ទាំងសាសនា របស់ព្រះពុទ្ធ ខ្ញុំក៏បាន

ប្រតិបត្តិហើយ ។

បានឮថា ព្រះពុទ្ធសញ្ញិកត្ថេរ មានអាយុ បានសំដែងនូវ

គាថាទាំងនេះ ដោយប្រការដូច្នេះ ។

ចប់ ពុទ្ធសញ្ញិកត្ថេរាបទាន ។

### ឧទ្ទានំ

នឡមាលិ មណិធរោ ឧក្កាសតិកាវីជនិ

កុម្មាសញ្ច កុសដ្ឋញ្ច គិរិបុន្នាគិយោបិច

វល្លិការោ បានធិទោ អថោ បុឡិនចង្កមោ

គាថាយោ បញ្ចនវុតិ គណិតាយោ វិភាវិភិ ។

នឡមាលិវគ្គោ អដ្ឋចត្តាលីសោ ។

---

### ឧទ្ទាន

នឡមាលិយត្ថេរាបទាន ១ មណិបូជកត្ថេរាបទាន ១ ឧក្កាសតិកត្ថេរាបទាន ១ វីជនិយត្ថេរាបទាន ១ កុម្មាសទាយកត្ថេរាបទាន ១ កុសដ្ឋកទាយកត្ថេរាបទាន ១ គិរិបុន្នាគិយត្ថេរាបទាន ១ វល្លិកាផលទាយកត្ថេរាបទាន ១ បានធិទាយកត្ថេរាបទាន ១ បុឡិនចង្កមិយត្ថេរាបទាន ១ ឯគាថាមាន ចំនួន ៩៥ ពួកអ្នកប្រាជ្ញរាប់ឃើញហើយ ។

ចប់ នឡមាលិវគ្គ ទី ៤៨ ។

---

## ឯកូនបញ្ញាសមោ បំសុកូលវគ្គោ

### បឋមំ បំសុកូលសញ្ញកត្ថេរាបទានំ

(៧១) តិស្សោ នាមាសិ ភគវា សយម្ភូ លោកនាយកោ
បំសុកូលំ ឋបេត្វាន វិហារំ បាវិសី ជិនោ ។
សជ្ជិតំ(១) ធនុមាទាយ ភក្ខត្ថសរិសំ(២) អហំ
មណ្ឌលគ្គំ គហេត្វាន កាននំ បាវិសឹ អហំ ។
តត្ថទ្ទសំ បំសុកូលំ ទុមគ្គេ លគ្គិតំ តទា
ចាបំ តត្ថេវ និក្ខិប្ប សីសេ(៣)កត្វាន អញ្ជលឹ ។
បសន្នចិត្តោ សុមនោ វិបុលាយ ច បីតិយា
ពុទ្ធសេដ្ឋំ សរិត្វាន បំសុកូលំ អវន្ទហំ(៤) ។
ទ្វេនវុតេ ឥតោ កប្បេ យំ បំសុកូលមវន្ទហំ
ទុគ្គតឹ នាភិជានាមិ វន្ទនាយ ឥទំ ផលំ ។

---

១ ឱ. តិយង្គំ ។ ម. វិនតំ ។ ២ ឱ. អក្ខិត្តោ យមលី ។ ម. ភក្ខត្ថាយ ចរឹ ។ ៣ ឱ. ម. សីសេ ។ ៤ ឱ អវន្ទិហំ ។

## បំសុកូលវគ្គ ទី ៤៩

### បំសុកូលសញ្ញកត្ថេរាបទាន ទី ១

(៧១) ព្រះដ៏ទ្រង់មានព្រះភាគ ព្រះនាមតិស្សៈ ជាព្រះសយម្ភូ ជាលោកនាយក ព្រះអង្គបានតំកល់ទុកនូវសំពត់បង្សុកូល ហើយស្តេចចូលទៅកាន់វិហារ ។ ខ្ញុំបានកាន់យកធ្នូ ដែលខ្លួនរៀបចំស្រេចហើយ មានតាំងទឹកបំពង់ កាន់ដាវដើរចូលទៅកាន់ព្រៃ ។ គ្រានោះ ខ្ញុំបានឃើញសំពត់បង្សុកូល ដែលព្រះអង្គពាក់ទុកលើចុងឈើ ក្នុងទីនោះ ខ្ញុំបានដាក់បំពង់ព្រួញចុះ ក្នុងទីនោះឯង ហើយបានធ្វើអញ្ជលីលើសិរ្សៈ ។ ខ្ញុំមានចិត្តជ្រះថ្លា រីករាយដោយបីតិដ៏ធំទូលាយ នឹករលឹកចំពោះព្រះពុទ្ធដ៏ប្រសើរ ហើយថ្វាយបង្គំនូវសំពត់បង្សុកូល ។ ក្នុងកប្បទី៩២ អំពីកប្បនេះ ព្រោះហេតុដែលខ្ញុំបានថ្វាយបង្គំនូវសំពត់បង្សុកូល ក្នុងកាលនោះ ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃការថ្វាយបង្គំ ។

កិលេសា ឈាបិតា មយ្ហំ ភវា សព្វេ សមូហតា
នាគោវ ពន្ធនំ ឆេត្វា វិហរាមិ អនាសវោ ។
ស្វាគតំ វត មេ អាសិ មម ពុទ្ធស្ស សន្តិកេ
តិស្សោ វិជ្ជា អនុប្បត្តា កតំ ពុទ្ធស្ស សាសនំ ។
បដិសម្ភិទា ចតស្សោ វិមោក្ខាបិ ច អដ្ឋិមេ
ឆឡភិញ្ញា សច្ឆិកតា កតំ ពុទ្ធស្ស សាសនន្តិ ។

ឥត្ថំ សុទំ អាយស្មា បំសុកូលសញ្ញកោ ថេរោ ឥមា គាថាយោ អភាសិត្ថាតិ ។

បំសុកូលសញ្ញកត្ថេរស្ស អបទានំ សមត្តំ ។

## ទុតិយំ ពុទ្ធសញ្ញកត្ថេរាបទានំ

(៧២) អជ្ឈាយកោ មន្តធរោ តិណ្ណំ វេទាន បារគូ
លក្ខណេ ឥតិហាសេ ច សនិឃណ្ឌុសកេដុភេ ។
[illegible] សិស្សា អាយន្តិ មេ តទា
តេសាហំ មន្តេ(១) វាចេមិ រត្តិន្ទិវមតន្ទិតោ ។

១ ន. មន្តេ ។



កិលេសទាំងឡាយ ខ្ញុំដុតបំផ្លាញអស់ហើយ ភពទាំងពួង ខ្ញុំដកចោលហើយ ខ្ញុំមិនមានអាសវៈ ព្រោះបានកាត់ចំណង ដូចជាដំរីកាត់ផ្តាច់ទន្លីង ។ ឱ ! ខ្ញុំមកល្អហើយ ក្នុងសំណាក់នៃព្រះពុទ្ធរបស់ខ្ញុំ វិជ្ជា ៣ ខ្ញុំបានដល់ហើយ សាសនា របស់ព្រះពុទ្ធ ខ្ញុំបានធ្វើហើយ ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនា របស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ។

បានឮថា ព្រះបង្សុកូលសញ្ញកត្ថេរ មានអាយុ បានសម្ដែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

ចប់ បង្សុកូលសញ្ញកត្ថេរាបទាន ។

## ពុទ្ធសញ្ញកត្ថេរាបទាន ទី ២

(៧៦) ខ្ញុំជាអ្នកស្វាធ្យាយមន្ត ទ្រទ្រង់នូវមន្ត ដល់នូវត្រើយ នៃត្រៃវេទ ក្នុងលក្ខណសាស្ត្រ និងឥតិហាសសាស្ត្រ ព្រមទាំងនិឃណ្ឌុសាស្ត្រ និងកេដុភសាស្ត្រ ។ ក្នុងកាលនោះ ពួកសិស្សរបស់ខ្ញុំ មកកាន់ (សំណាក់) នៃខ្ញុំ ប្រៀបដូចជាខ្សែទឹកស្ទឹង ខ្ញុំក៏បានបង្រៀនមន្ត ដល់សិស្សទាំងនោះ ឥតមានខ្ជិលច្រអូស ទាំងយប់ទាំងថ្ងៃ ។

សិទ្ធត្ថោ នាម សម្ពុទ្ធោ លោកេ ឧប្បជ្ជិ តាវទេ
តមន្ធការំ នាសេត្វា ញាណាលោកំ បវត្តយិ ។
មម អញ្ញាតកោ សិស្សោ សិស្សានំ សោ កថេសិ មេ
សុត្វាន តេ ឯតមត្ថំ អារោចេសុំ មមំ តទា ។
ពុទ្ធោ លោកេ សមុប្បន្នោ សព្វញ្ញូ លោកនាយកោ
តស្សានុវត្តតិ ជនោ លាភោ មយ្ហំ ន វិជ្ជតិ(១) ។
អធិច្ចុប្បត្តិកា ពុទ្ធា ចក្ខុមន្តោ មហាយសា
យន្នូនាហំ ពុទ្ធសេដ្ឋំ បស្សេយ្យំ លោកនាយកំ ។
អជិនំ មេ គហេត្វាន វាកចីរំ កមណ្ឌលុំ
អស្សមា អភិនិក្ខម្ម សិស្សេ អាមន្តយិំ អហំ ។
ឧទុម្ពរកបុប្ផំវ(២) ចន្ទម្ហិ សសកំ យថា
វាយសានំ យថា ខីរំ ទុល្លភំ លោកនាយកំ ។

---

១ ឱ. ន ហេស្សតិ ។ ២ ឱ. ឧទុម្ពរបុប្ផំវ ។



សម័យនោះឯង ព្រះសម្ពុទ្ធព្រះនាមសិទ្ធត្ថៈ បានកើតឡើងហើយក្នុងលោក ទ្រង់ញុំាងសេចក្តីងងឹតដ៏ក្រៃលែងឲ្យវិនាស ហើយញុំាងពន្លឺនៃញាណ ឲ្យប្រព្រឹត្តទៅ ។ ក្នុងកាលនោះ មានសិស្សម្នាក់របស់ខ្ញុំ បានប្រាប់ដល់ពួកសិស្សរបស់ខ្ញុំ លុះពួកសិស្សទាំងនោះឮហើយ ទើបប្រាប់សេចក្តីនោះ ដល់ខ្ញុំ (ខ្ញុំក៏បានគិតថា) ព្រះសព្វញ្ញូ ជាលោកនាយក ព្រះអង្គបានកើតឡើងក្នុងលោកហើយ ជនតែងប្រព្រឹត្តតាមនូវព្រះសម្មាសម្ពុទ្ធអង្គនោះ ឯអាត្មាអញគ្មានលាភនឹងគេសោះ ។ ព្រះពុទ្ធទាំងឡាយ មានចក្ខុ មានយសធំ ព្រះអង្គទ្រង់កើតឡើង ព្រោះអាស្រ័យហេតុ បើដូច្នោះ អាត្មាអញគួរទៅមើលព្រះសម្មាសម្ពុទ្ធដ៏ប្រសើរ ព្រះអង្គជាលោកនាយក ។ ខ្ញុំបានកាន់យកស្បែកខ្លា សំពត់សម្បកឈើនិងកុណ្ឌិកទឹករបស់ខ្ញុំ ចេញអំពីអាស្រម ហើយហៅពួកសិស្សមកប្រាប់ថា ការឃើញនូវព្រះពុទ្ធ ជាលោកនាយក គឺម្របុគ្គលបានដោយកម្រ ដូចជាផ្កាឧទុម្ពរ ឬដូចជារូបនៃសត្វទន្សាយក្នុងវង់ព្រះចន្ទ្រ ឬក៏ដូចជាទឹកដោះនៃសត្វក្អែក ។

ពុទ្ធោ លោកម្ហិ ឧប្បន្នោ  មនុស្សត្តំបិ ទុល្លភំ
ឧភោសុ វិជ្ជមានេសុ  សវណញ្ច សុទុល្លភំ ។
ពុទ្ធោ លោកេ សមុប្បន្នោ ចក្ខុំ លទ្ធាម តេ តយំ
ឯថ សព្វេ គមិស្សាម  សម្មាសម្ពុទ្ធសន្តិកំ ។
កមណ្ឌលុធរា សព្វេ  ខរាជិននិវាសិនោ
តេ ជដាភារភរិតា  និក្ខម្ម បវនា តទា ។
យុគមត្តំ បេក្ខមានា  ឧត្តមត្ថំ គវេសិនោ
អាយន្តិ នាគតោតាវ[1]  អសម្ភីតាវ កេសរី ។
អប្បកាសា អលោលុប្បា[2] និបកា សន្តវុត្តិនោ
ឧញ្ឆាយ ចរមានា តេ  ពុទ្ធសេដ្ឋំ ឧបាគមុំ ។

១ ម. អាសន្តិ គេសរោភោ ។ ២ ឧ. អប្បកាសា អលោលុតា ។ ម. អប្បាភិច្ឆា អលោ-លុប្បា ។





ព្រះសម្មាសម្ពុទ្ធ ព្រះអង្គកើតឡើង ក្នុងលោក និងភាពជាមនុស្ស ទាំងពីរនេះ កម្របុគ្គលបានដោយងាយ កាលបើហេតុទាំងពីរនេះមានហើយ ការស្តាប់ធម៌ ក៏កម្របុគ្គលបានងាយដែរ ។ ព្រះសម្មាសម្ពុទ្ធ បានកើតហើយ ក្នុងលោក ពួកយើងឈ្មោះថាបាននូវចក្ខុ សេចក្តីចម្រើន នឹងមានដល់យើង អ្នកទាំងឡាយចូរមកចុះ យើងទាំងអស់ នឹងនាំគ្នាទៅកាន់សំណាក់ព្រះសម្មាសម្ពុទ្ធ ។ កាលនោះ ពួកតាបសទាំងអស់ ទ្រទ្រង់នូវកុណ្ឌីទឹក ស្លៀកពាក់ស្បែកខ្លាទាំងក្រចក តាបសទាំងនោះ ទ្រទ្រង់នូវភារៈគឺជដាសក់ បានចេញទៅអំពីព្រៃ ។ តាបសទាំងនោះ ជាអ្នកស្វែងរកនូវប្រយោជន៍ដ៏ឧត្តម ក្រឡេកមើលមួយជួរទឹមដើរមក ឥតមានសេចក្តីតក់ស្លុត បីដូចជាកូនដំរី ឬដូចជាកេសរពេជ-សីហ៍ ឥតមានសេចក្តីតក់ស្លុតឡើយ ។ តាបសទាំងអស់នោះ ជាអ្នកមិនតក់ស្លុត មិនល្មេះល្មោះ មានប្រាជ្ញាឆ្មិនឆ្លៅ ជាអ្នកប្រព្រឹត្តស្ងៀម តាបសទាំងអស់នោះ កាលត្រាច់រកផលាផល បានចូលទៅគាល់ព្រះពុទ្ធដ៏ប្រសើរ ។

និយន្តេ យោជនេ នេសេ(១) ព្យាធិ មេ ឧបបជ្ជថ

ពុទ្ធសេដ្ឋំ សរិត្វាន តត្ថ កាលំ កតោ អហំ ។

ចតុន្នវុតេ ឥតោ កប្បេ យំ សញ្ញមលភឹ តទា

ទុគ្គតឹ នាភិជានាមិ ពុទ្ធសញ្ញាយិទំ ផលំ ។

កិលេសា ឈាបិតា មយ្ហំ ភវា សព្វេ សមូហតា

នាគោវ ពន្ធនំ ឆេត្វា វិហរាមិ អនាសវោ ។

ស្វាគតំ វត មេ អាសិ មម ពុទ្ធស្ស សន្តិកេ

តិស្សោ វិជ្ជា អនុប្បត្តា កតំ ពុទ្ធស្ស សាសនំ ។

បដិសម្ភិទា ចតស្សោ វិមោក្ខាបិច អដ្ឋិមេ

ឆឡភិញ្ញា សច្ឆិកតា កតំ ពុទ្ធស្ស សាសនន្តិ ។

ឥត្ថំ សុទំ អាយស្មា ពុទ្ធសញ្ញកោ ថេរោ ឥមា

គាថាយោ អភាសិត្ថាតិ ។

ពុទ្ធសញ្ញកត្ថេរស្ស អបទានំ សមត្តំ ។

១ ឧ.ម. សេសេ ។



ព្យាធិបានកើតឡើងដល់ខ្ញុំ ដែលនៅក្នុងប្រទេសប្រមាណមួយយោជន៍កន្លះ (អំពីព្រះពុទ្ធគង់នៅ) ខ្ញុំបាននឹកដល់ព្រះសម្មាសម្ពុទ្ធដ៏ប្រសើរ ហើយធ្វើមរណកាល ក្នុងទីនោះ ។ ក្នុងកប្បទី ៩៤ អំពីកប្បនេះ ព្រោះហេតុដែលខ្ញុំបាននូវសេចក្ដីសំគាល់ក្នុងកាលនោះ ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃសេចក្ដីសំគាល់នូវព្រះសម្មាសម្ពុទ្ធ ។ កិលេសទាំងឡាយ ខ្ញុំដុតបំផ្លាញហើយ ភពទាំងពួង ខ្ញុំដកចោលចេញហើយ ខ្ញុំមិនមានអាសវៈ ព្រោះបានកាត់ចំណង ដូចជាដំរីកាត់ផ្ដាច់នូវចំណង ។ ឱ ! ខ្ញុំមកល្អហើយ ក្នុងសំណាក់នៃព្រះពុទ្ធរបស់ខ្ញុំ វិជ្ជា ៣ ខ្ញុំបានដល់ហើយ សាសនា របស់ព្រះពុទ្ធ ខ្ញុំបានធ្វើហើយ ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ។

បានឮថា ព្រះពុទ្ធសញ្ញកត្ថេរ មានអាយុ បានសំដែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

ចប់ ពុទ្ធសញ្ញកត្ថេរាបទាន ។

# តតិយំ ភិសទាយកត្ថេរាបទានំ

(៧៣) ឱគ្គយ្ហាហំ(១) បោក្ខរណឹ នានាកុញ្ជរសេវិតំ
ឧទ្ធរាមិ ភិសំ តត្ថ អសនហេតុ(២) អហំ តទា ។
ភគវា តម្ហិ សមយេ បទុមុត្តរសវ្ហយោ
រត្តម្ពរធរោ ពុទ្ធោ គច្ឆសិ(៣) អនិលញ្ជសេ ។
ធុនន្តោ បំសុកូលានិ សទ្ទំ អស្សោសហំ តទា
ឧទ្ធំ និជ្ឈាយមានោហំ អទ្ទសំ លោកនាយកំ ។
តត្ថេវ ឋិតកោ សន្តោ អាយាចឹ លោកនាយកំ
មធុំ ភិសេហិ សវតិ ខីរសប្បិ មុឡាលិភិ ។
បដិគ្គណ្ហាតុ មេ ពុទ្ធោ អនុកម្បាយ ចក្ខុមា
តតោ ការុណិកោ សត្ថា ឱរោហិត្វា មហាយសោ ។
បដិគ្គណ្ហិ មម ភិក្ខំ អនុកម្បាយ ចក្ខុមា
បដិគ្គហេត្វា សម្ពុទ្ធោ អកា មេ អនុមោទនំ ។

១ ម. ឱគ្គយ្ហាយំ ។ ២ ឱ. ឃាសហេតុ ។ ម. ឃសហេតុ ។ ៣ ឱ. គច្ឆតិ ។

# ភិសទាយកត្ថេរាបទាន ទី ៣

(៧៣) កាលនោះ ខ្ញុំបានចុះកាន់ស្រះបោក្ខរណី ដែលដំរីនានាតែងអាស្រ័យ ខ្ញុំបានដកក្រអៅឈូក ក្នុងស្រះនោះ ព្រោះហេតុនៃសេចក្តីស្រេកឃ្លាន ។ សម័យនោះ ព្រះសម្ពុទ្ធ មានព្រះភាគ ព្រះនាមបទុមុត្តរៈ ដែលមានព្រះហឫទ័យល្អ ទ្រទ្រង់នូវសំពត់ពណ៌ក្រហម ស្តេចទៅតាមផ្លូវអាកាស ។ គ្រានោះ ខ្ញុំកំពុងរលាស់នូវសំពត់បង្សុកូល បានឮសំឡេង ខ្ញុំក្រឡេកមើលទៅខាងលើ ក៏បានឃើញព្រះលោកនាយក ។ ខ្ញុំឈរនៅក្នុងទីនោះឯង ហើយបានអា-រាធនាព្រះលោកនាយក ទាំងកំពុងកាន់ក្រអៅឈូកមានរសផ្អែមដោយពាក្យថា ទឹកដោះនិងសប្បិហូរចេញអំពីក្រអៅឈូក ។ សូមព្រះសម្ពុទ្ធជាម្ចាស់ មានចក្ខុ ជាសាស្តា មានយសធំ ប្រកបដោយសេចក្តីករុណា ស្តេចចុះមកអំពីអាកាសនោះ ហើយទ្រង់ទទួលដោយសេចក្តីអនុគ្រោះដល់ខ្ញុំ ។ ព្រះសម្ពុទ្ធមានចក្ខុ ទ្រង់ទទួលភិក្ខារបស់ខ្ញុំ ដោយសេចក្តីអនុគ្រោះ លុះទ្រង់ទទួលហើយ ទ្រង់ធ្វើអនុមោទនាដល់ខ្ញុំថា

សុខី ហោហិ មហាបុញ្ញ គតិ តុយ្ហំ សមិជ្ឈតុ

ឥមិនា ភិសទានេន លភស្សុ វិបុលំ សុខំ ។

ឥទំ វត្វាន សម្ពុទ្ធោ ជលជុត្តមនាមកោ

ភិក្ខមាទាយ សម្ពុទ្ធោ អម្ពរេនាគមា ជិនោ ។

តតោ ភិសំ គហេត្វាន អាគច្ឆឹ មម អស្សមំ

ភិសំ រុក្ខេ លគ្គេត្វាន មម ទានំ អនុស្សរឹ ។

មហាវាតោ វុដ្ឋហិត្វា សញ្ចាលេសិ វនំ តទា

អាកាសោ អភិនាទិត្ថ អសនិយា ផលន្តិយា ។

តតោ មេ អសនិបាតោ មត្ថកេ និបតី តទា

សោហំ(1) និសិន្នកោ សន្តោ តត្ថ កាលំ កតោ អហំ ។

បុញ្ញកម្មេន សំយុត្តោ តុសិតំ ឧបបជ្ជហំ ។

កលេវរម្មេ បតិតំ ទេវលោកេ រមាមហំ ។

---

១ ម. សោហំ ។



ម្នាលអ្នកមានបុណ្យច្រើន អ្នកចូរជាបុគ្គលដល់នូវសេចក្តីសុខចុះ គតិរបស់អ្នក ចូរសម្រេចចុះ អ្នកចូរបាននូវសេចក្តីសុខដ៏ធំទូលាយ ដោយការឲ្យនូវក្រអៅឈូកនេះចុះ ។ ព្រះសម្ពុទ្ធ ព្រះនាមបទុមុត្តរៈ លុះទ្រង់ត្រាស់អនុមោទនានេះហើយ ព្រះជិនស្រីសម្ពុទ្ធ ទ្រង់ទទួលភិក្ខា ហើយស្តេចមកតាមផ្លូវអាកាស ។ ខ្ញុំបានកាន់យកក្រអៅឈូកអំពីទីនោះ ហើយមកអាស្រមរបស់ខ្ញុំ ខ្ញុំបានព្យួរក្រអៅឈូកលើមែកឈើ ហើយរឭកនូវទានរបស់ខ្ញុំ ។ គ្រានោះ ខ្យល់ធំបានតាំងឡើង ហើយញ៉ាំងព្រៃឲ្យញាប់ញ័រ អាកាសក៏បន្លឺឡើងដោយសំឡេងរន្ទះបាញ់ ។ ក្នុងកាលនោះ អសនិបាតធ្លាក់ត្រូវក្បាលខ្ញុំ ខ្ញុំនោះកំពុងអង្គុយ ក៏ធ្វើមរណកាលក្នុងទីនោះ ។ ខ្ញុំប្រកបដោយបុញ្ញកម្ម ហើយបានទៅកើតក្នុងឋានតុសិត សាកសពរបស់ខ្ញុំធ្លាក់ចុះ ខ្ញុំត្រេកអរក្នុងទេវលោក ។

តតិយំ ភិសទាយកត្ថេរាបទានំ

ឆឡាសីតិសហស្សានំ    ជាតិយោ សមលង្កតា
សាយំ បាតំ ឧបដ្ឋន្តិ    ភិសទានស្សិទំ ផលំ ។
មនុស្សយោនិមាគញ្ឆិំ    សុខិតោ ហោមហំ តទា
ភោគេ មេ ឩនតា នត្ថិ    ភិសទានស្សិទំ ផលំ ។
អនុកម្បិតកោ(១) តេន    ទេវទេវេន តាទិនា
សព្វាសវបរិក្ខីណោ    នត្ថិ ទានិ បុនព្ភវោ ។
សតសហស្សេ ឥតោ កប្បេ    យំ ភិក្ខមទទឹ តទា
ទុគ្គតឹ នាភិជានាមិ    ភិសទានស្សិទំ ផលំ ។
កិលេសា ឈាបិតា មយ្ហំ    ភវា សព្វេ សមូហតា
នាគោវ ពន្ធនំ ឆេត្វា    វិហរាមិ អនាសវោ ។
ស្វាគតំ វត មេ អាសិ    មម ពុទ្ធស្ស សន្តិកេ
តិស្សោ វិជ្ជា អនុប្បត្តា    កតំ ពុទ្ធស្ស សាសនំ ។

១ ម. អនុកម្បិតត្តា ។



ភិសទាយកត្ថេរាបទាន ទី ៣

ពួកនារី៨ម៉ឺន៦ពាន់ គាត់តែងគ្រឿងប្រដាប់ប្រដា តែងបំរើខ្ញុំទាំងល្ងាចទាំងព្រឹក នេះជាផលនៃការឲ្យក្រអៅឈូក ។ ក្នុងកាលនោះ ខ្ញុំបានមកកាន់កំណើតនៃមនុស្ស ដល់នូវសេចក្ដីសុខ សេចក្ដីខ្វះខាតភោគៈរបស់ខ្ញុំ មិនមានឡើយ ។ នេះជាផលនៃការថ្វាយក្រអៅឈូក ។ ខ្ញុំជាអ្នកត្រូវព្រះតាទិបុគ្គលជាទេវតាក្នុងទេវតានោះ អនុគ្រោះហើយ ក៏មានអាសវៈទាំងពួង អស់ឥតសេសសល់ ឥឡូវនេះភពថ្មីរបស់ខ្ញុំ មិនមានឡើយ ។ ក្នុងកប្បទីមួយសែន អំពីកប្បនេះ ព្រោះហេតុដែលខ្ញុំបានឲ្យភិក្ខា ក្នុងកាលនោះ ខ្ញុំមិនដែលស្គាល់ទុគ្គតិនេះជាផលនៃការឲ្យក្រអៅឈូក ។ កិលេសទាំងឡាយ ខ្ញុំដុតបំផ្លាញហើយ ភពទាំងពួង ខ្ញុំដកចោលហើយ ខ្ញុំមិនមានអាសវៈ ព្រោះបានកាត់បំណង់ ដូចជាដំរីកាត់ផ្ដាច់នូវទន្លីង ។ ឱ ! ខ្ញុំមកល្អហើយ ក្នុងសំណាក់នៃព្រះពុទ្ធរបស់ខ្ញុំ វិជ្ជា ៣ ខ្ញុំបានដល់ហើយ សាសនារបស់ព្រះពុទ្ធ ខ្ញុំបានធ្វើហើយ ។

បដិសម្ភិទា ចតស្សោ  វិមោក្ខាបិ ច អដ្ឋិមេ

ឆឡភិញ្ញា សច្ឆិកតា  កតំ ពុទ្ធស្ស សាសនន្តិ ។

ឥត្ថំ សុទំ អាយស្មា ភិសទាយកោ ថេរោ ឥមា

គាថាយោ អភាសិត្ថាតិ ។

ភិសទាយកត្ថេរស្ស អបទានំ សមត្តំ ។

## ចតុត្ថំ ញាណត្ថវិកត្ថេរាបទានំ

(៧៤) ទក្ខិណោ ហិមវន្តស្ស  សុកតោ អស្សមោ មម

ឧត្តមត្ថំ គវេសន្តោ  វសាមិ បវនេ(១) តទា ។

លាភាលាភេន សន្តុដ្ឋោ  មូលេន ច ផលេន ច

អគោមសន្តោ អចរំ(២)  វសាមិ ឯកាកោ(៣) អហំ ។

សុមេធោ នាម សម្ពុទ្ធោ  លោកេ ឧប្បជ្ជិ តាវទេ

ចតុសច្ចំ បកាសេតិ  ឧទ្ធរន្តោ មហាជនំ ។

---

១ ម. វិបិនេ ។ ២ ម. អន្វេសន្តោ អាចរិយំ ។ ៣ ម. ឯកកោ ។





បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនា របស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ។

បានឮថា ព្រះភិសទាយកត្ថេរ មានអាយុ បានសំដែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

ចប់ ភិសទាយកត្ថេរាបទាន ។

## ញាណត្ថវិកត្ថេរាបទាន ទី ៤

[៧៤] អាស្រមរបស់ខ្ញុំគេធ្វើហើយ ក្នុងទិសខាងត្បូង នៃហិមវន្តប្រទេស ក្នុងកាលនោះ ខ្ញុំកំពុងស្វែងរកនូវប្រយោជន៍ដ៏ឧត្តម នៅក្នុងព្រៃ ។ ខ្ញុំជាអ្នកសន្តោសដោយលាភនិងអលាភ ជាអ្នកប្រព្រឹត្តមិនចិតសំបក នៃមើមឈើ និងផ្លែឈើ ហើយនៅតែម្នាក់ឯង ។ ព្រះសម្ពុទ្ធព្រះនាមសុមេធៈ បានកើតក្នុងលោក ទ្រង់ស្រោចស្រង់នូវមហាជន ហើយប្រកាសនូវសច្ចធម៌ទាំង ៤ ក្នុងខណៈនោះ ។

នាហំ សុណោមិ សម្ពុទ្ធំ នបិ មេ កោចិ សាសតិ
អដ្ឋវស្សេ អតិក្កន្តេ អស្សោសិំ លោកនាយកំ ។
អគ្គិ ទារុំ(១) និហរិត្វា សម្មជ្ជិត្វាន អស្សមំ
ខារិការំ គហេត្វាន និក្ខមិំ វនា អហំ ។
ឯករត្តិំ វសន្តោហំ គាមេសុ និគមេសុ ច
អនុបុព្វេន ចន្ទវតិំ តទាហំ ឧបសង្កមិំ ។
ភគវា តម្ហិ សមយេ សុមេធោ លោកនាយកោ
ឧទ្ធរន្តោ ពហូ សត្តេ ទេសេតិ អមតំ បទំ ។
ជនកាយមតិក្កម្ម វន្ទិត្វា ជិនសាគរំ(២)
ឯកំសំ អជិនំ កត្វា សន្ថវិំ លោកនាយកំ ។
តុវំ សត្ថា ច កេតុ ច ធជោ យូបោ ច បាណិនំ
បរាយណោ បតិដ្ឋា ច ទីបោ ច ទិបទុត្តមោ ។

ឯកវីសតិមំ ភាណវារំ ។

១ ឱ.ម. អគ្គិទារុំ ។ ២ ឱ. ជិនសាគរំ ។ ម. ជិនសាគរំ ។



ខ្ញុំមិនដែលបានស្តាប់នូវព្រះសម្ពុទ្ធ ទាំងឥតមានអ្នកណាមួយប្រៀនប្រដៅខ្ញុំឡើយ លុះកន្លង ៨ ឆ្នាំទៅ ទើបខ្ញុំបានស្តាប់ព្រះលោកនាយក ។ ខ្ញុំបាននាំយកភ្លើងនិងឧសចេញហើយ បោសព្រះអាស្រម រួចបានកាន់នូវព្រែកចេញទៅ អំពីព្រៃធំ ។ ក្នុងកាលនោះ ខ្ញុំនៅក្នុងស្រុកនិងនិគម អស់មួយរាត្រី ។ ហើយបានចូលទៅក្នុងក្រុងឈ្មោះចន្ទវតី ដោយលំដាប់ ។ ក្នុងសម័យនោះ ព្រះមានព្រះភាគ ព្រះនាមសុមេធៈ ជាលោកនាយក ទ្រង់ស្រោចស្រង់នូវពពួកសត្វជាច្រើន កំពុងសំដែងនូវអមតបទ ។ ខ្ញុំកន្លងនូវពួកជនហើយថ្វាយបង្គំ នូវពាក្យប្រដៅនៃព្រះជិនស្រី បានធ្វើនូវស្បែកខ្លាឆៀងស្មាម្ខាង ហើយពោលសរសើរគុណ នៃព្រះលោកនាយកថា

ព្រះអង្គជាសាស្តា ដូចជាទង់ ដូចជាទង់ជ័យ ឬដូចប្រាសាទ ជាទីពឹងពំនាក់របស់ពួកសត្វ ជាប្រទីប ទ្រង់ឧត្តមជាងសត្វជើងពីរ ។

ចប់ ភាណវារៈ ទី ២១ ។

នេបុញ្ញោ ទស្សនេន តេ តារេសិ ជនតំ តុវំ
នត្ថញ្ញោ តារកោ លោកេ តវុត្តរិតរោ(១) មុនេ ។
សក្កា ហវេ កុសគ្គេន បមេតុំ សាគរុត្តមោ(២)
ន ត្វេវ តវ សព្វញ្ញុ(៣) ញាណំ សក្កា បមេតវេ ។
តុលទណ្ឌេ(៤) ឋបេត្វាន មហី(៥) សក្កា ធរេតវេ
ន ត្វេវ តវ បញ្ញាយ បមាណំ អត្ថិ ចក្ខុម ។
អាកាសោ មិនិតុំ សក្កា រជ្ជុយា អង្គុលេន វា
ន ត្វេវ តវ សព្វញ្ញុ សីលំ សក្កា បមេតវេ ។
មហាសមុទ្ទេ ឧទកំ អាកាសោ ច វសុន្ធរេ(៦)
បរិមេយ្យានិ ឯតានិ អប្បមេយ្យោសិ ចក្ខុម ។

---

១ ម. តវុត្តរិតរោ ។ ២ ម. សាគរុត្តមេ ។ ៣ ឱ.ម. សព្វញ្ញូ ។ ៤ ឱ. តុលមណ្ឌលេ ។ ៥ ឱ. មហី ។ ម. មហិំ ។ ៦ ឱ. វសុន្ធរា ។



បពិត្រព្រះមុនី ព្រះអង្គជាអ្នកប្រាជ្ញ ទ្រង់មានព្រះប្រាជ្ញ ដ៏ល្អិតក្នុងទស្សនញាណ ទ្រង់ញុំាងពួកជនឲ្យឆ្លង ទីដទៃ បុគ្គលដទៃជាអ្នកចម្លងឲ្យលើសលុបជាងព្រះអង្គ ក្នុងលោក មិនមានឡើយ ។ សមុទ្រសាគរដ៏ឧត្តម បុគ្គលអាចនឹងប្រមាណដោយចុងស្បូវបាន ឯសព្វញ្ញុតញ្ញាណរបស់ព្រះអង្គ បុគ្គលមិនអាចប្រមាណបានឡើយ ។ ផែនដីបុគ្គលអាចដាក់លើផ្ទឹងជញ្ជីង ដើម្បីថ្លឹងបាន បពិត្រព្រះអង្គមានចក្ខុ (តែដីនេះ) ស្មើដោយបញ្ញារបស់ព្រះអង្គ មិនមានឡើយ ។ អាកាស គេអាចវាស់ដោយខ្សែ ឬដោយអង្គុលីបាន បពិត្រព្រះសព្វញ្ញូ សីលរបស់ព្រះអង្គ បុគ្គលមិនអាចប្រមាណបានឡើយ ។ បពិត្រព្រះអង្គមានចក្ខុ ទឹកក្នុងមហាសមុទ្រក្តី អាកាសក្តី ផែនដីក្តី របស់ទាំងអម្បាលនេះ បុគ្គលអាចប្រមាណបាន ឯព្រះអង្គឥតមានបុគ្គលប្រមាណបានឡើយ ។

ឆហិ គាថាហិ សព្វញ្ញុំ   កិត្តយិត្វា មហាយសំ
អញ្ជលិំ បគ្គហេត្វាន   តុណ្ហី អដ្ឋាសហំ តទា ។
យំ វទន្តិ សុមេធោតិ   ភូរិបញ្ញំ(១) សុមេធសំ
ភិក្ខុសង្ឃេ និសីទិត្វា   ឥមា គាថា អភាសថ ។
យោ មេ ញាណំ បកិត្តេសិ   វិប្បសន្នេន ចេតសា(២)
តមហំ កិត្តយិស្សាមិ   សុណាថ មម ភាសតោ ។
សត្តសត្តតិ កប្បានិ   ទេវលោកេ រមិស្សតិ
សហស្សក្ខត្តុំ ទេវិន្ទោ   ទេវរជ្ជំ ករិស្សតិ ។
អនេកសតក្ខត្តុញ្ច   ចក្កវត្តិ ភវិស្សតិ
បទេសរជ្ជំ វិបុលំ   គណនាតោ អសង្ខិយំ ។
ទេវភូតោ មនុស្សោ វា   បុញ្ញកម្មសមាហិតោ
អនូនមនសង្កប្បោ   តិក្ខបញ្ញោ ភវិស្សតិ ។

---
១ ឱ.ម. ភូរិបញ្ញំ ។ ២ ឱ. បសន្នោ សេហិ បាណិហិ ។





គ្រានោះ ខ្ញុំបានសរសើរនូវព្រះសព្វញ្ញូ មានយសធំ ដោយព្រះគាថាទាំងឡាយ ៦ ហើយឈរផ្គងនូវអញ្ជលីទៅស្ងៀម ។ ជនទាំងឡាយតែងហៅ នូវព្រះមានព្រះភាគអង្គណា ដែលមានព្រះបញ្ញាដូចផែនដី ទ្រង់ទំលាយបង់នូវកិលេស ថាសុមេធៈ ព្រះមានព្រះភាគអង្គនោះ ទ្រង់គង់នៅកណ្តាលភិក្ខុសង្ឃ ហើយត្រាស់នូវព្រះគាថាទាំង-ឡាយនេះថា

បុគ្គលណា បានសរសើរញាណរបស់តថាគត ដោយចិត្តជ្រះថ្លា តថាគត នឹងសរសើរនូវបុគ្គលនោះ អ្នកទាំង-ឡាយ ចូរស្តាប់ពាក្យតថាគតសំដែងចុះ ។ បុគ្គលនោះ នឹងត្រេកអរ ក្នុងទេវលោក អស់ ៧៧ កប្ប នឹងបានជាធំជាងទេវតា សោយរាជ្យជាស្តេចនៃទេវតា អស់មួយពាន់ដង ។ នឹងបានជាស្តេចចក្រពត្តិ ច្រើនរយជាតិ នឹងបានគ្រប់គ្រងប្រទេសរាជ្យ ដ៏ធំទូលាយ នឹងគណនារាប់មិនបាន ។ បើកើតជាទេវតា ឬជាមនុស្ស នឹងជាអ្នកប្រកបដោយបុញ្ញកម្ម មានសេចក្តីត្រិះរិះមិនខានថយ ទាំងមានប្រាជ្ញាមោះមុត ។

តិំសកប្បសហស្សម្ហិ ឱក្កាកកុលសម្ភវោ
គោតមោ នាម នាមេន សត្ថា លោកេ ភវិស្សតិ ។
អគារា អភិនិក្ខម្ម បព្វជិស្សតិកិញ្ចនោ
ជាតិយា សត្តវស្សេន អរហត្តំ បាបុណិស្សតិ(១) ។
យតោ សរាមិ អត្តានំ យតោ បត្តោស្មិ សាសនំ
ឯត្ថន្តរេ ន ជានាមិ ចេតនំ អមនោរមំ ។
សំសរិត្វា ភវាភវេ សម្បត្តានុភវិំ អហំ
ភោគេ មេ ឩនតា នត្ថិ ផលំ ញាណស្ស ថោមនេ ។
តិធគ្គី និព្វុតា មយ្ហំ ភវា សព្វេ សមូហតា
សព្វាសវបរិក្ខីណោ នត្ថិ ទានិ បុនព្ភវោ ។

---
១ ឱ. ម. ផុសិស្សតិ ។



កន្លងទៅ ៣០.០០០ កប្ប ព្រះសាស្តាព្រះនាមគោតម កើតក្នុងត្រកូលនៃស្តេចឧក្កាកៈ ត្រាស់ឡើងក្នុងលោក ។ (កុល-បុត្រនេះ) ជាអ្នកមិនមានកង្វល់ ចេញចាកផ្ទះហើយបួស នឹងបានសម្រេចព្រះអរហត្ត ក្នុងអាយុ ៧ ឆ្នាំ រាប់អំពីឆ្នាំកំណើតមក ។

ខ្ញុំរលឹកឃើញនូវខ្លួន ដោយហេតុណា ខ្ញុំបានដល់នូវសាសនា ដោយហេតុណា ក្នុងចន្លោះនេះ ខ្ញុំមិនធ្លាប់ដឹងនូវចេតនា ដែលមិនជាទីត្រេកអរនៃចិត្តទេ ។ ខ្ញុំអន្ទោលទៅមកក្នុងភពតូចភពធំហើយ តែងទទួលនូវសម្បត្តិ ឯសេចក្តីខ្វះខាតភោគៈរបស់ខ្ញុំ គ្មានឡើយ នេះជាផលក្នុងការសរ-សើរនូវព្រះញាណ ។ ភ្លើង ៣ ប្រការរបស់ខ្ញុំ រលត់ហើយ ភពទាំងពួង ខ្ញុំបានដកចោលចេញហើយ ខ្ញុំមានអាសវៈទាំងពួងអស់ហើយ ឥឡូវនេះ ភពថ្មីមិនមានទៀតឡើយ ។

តឹសកប្បសហស្សម្ហិ យំ ញាណមភិថោមយឹ(១)

ទុគ្គតឹ នាភិជានាមិ ផលំ ញាណស្ស ថោមនេ ។

កិលេសា ឈាបិតា មយ្ហំ ភវា សព្វេ សមូហតា

នាគោវ ពន្ធនំ ឆេត្វា វិហរាមិ អនាសវោ ។

ស្វាគតំ វត មេ អាសិ មម ពុទ្ធស្ស សន្តិកេ

តិស្សោ វិជ្ជា អនុប្បត្តា កតំ ពុទ្ធស្ស សាសនំ ។

បដិសម្ភិទា ចតស្សោ វិមោក្ខាបិ ច អដ្ឋិមេ

ឆឡភិញ្ញា សច្ឆិកតា កតំ ពុទ្ធស្ស សាសនំ ។

ឥត្ថំ សុទំ អាយស្មា ញាណត្ថវិកោ ថេរោ ឥមា គាថាយោ អភាសិត្ថាតិ ។

ញាណត្ថវិកត្ថេរស្ស អបទានំ សមត្តំ ។

១ ម. ញាណមថវឹ អហំ ។





ក្នុងកប្បទី ៣០.០០០ អំពីកប្បនេះ ព្រោះហេតុដែលខ្ញុំបានសរសើរនូវព្រះញាណក្នុងកាលនោះ ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលក្នុងការសរសើរនូវព្រះញាណ ។ កិលេសទាំងឡាយ ខ្ញុំដុតបំផ្លាញហើយ ភពទាំងពួង ខ្ញុំដកចោលហើយ ខ្ញុំជាបុគ្គលមិនមានអាសវៈ ព្រោះបានកាត់បំណង់ ដូចជាដំរីកាត់ផ្តាច់នូវចំណង ។ ឱ ! ខ្ញុំមកល្អហើយ ក្នុងសំណាក់នៃព្រះពុទ្ធរបស់ខ្ញុំ វិជ្ជា ៣ ខ្ញុំបានដល់ហើយ សាសនារបស់ព្រះពុទ្ធ ខ្ញុំបានធ្វើហើយ ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនា របស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ។

បានឮថា ព្រះញាណត្ថវិកត្ថេរ មានអាយុ បានសម្តែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

ចប់ ញាណត្ថវិកត្ថេរាបទាន ។

# បញ្ចមំ បច្ឆនមាលិយត្ថេរាបទានំ

(៧៨) បញ្ចកាមគុណេ ហិត្វា បិយរូបេ មនោរមេ
អសីតិកោដិយោ ហិត្វា បព្វជឹ អនគារិយំ ។
បព្វជិត្វាន កាយេន បាបកម្មំ វិវជ្ជយឹ
វចីទុច្ចរិតំ ហិត្វា នទីកូលេ វសាមហំ ។
ឯកកំ មំ វិហរន្តំ ពុទ្ធសេដ្ឋោ ឧបាគមិ
នាហំ ជានាមិ ពុទ្ធោតិ អកាសឹ បដិសន្ថារំ ។
ករិត្វា បដិសន្ថារំ នាមគោត្តំ អបុច្ឆហំ
ទេវតា នុសិ គន្ធព្វោ អាទុ[១] សក្កោ បុរិន្ទទោ ។
កោ វា ត្វំ កស្ស វា បុត្តោ មហាព្រហ្មា ឥធាគតោ
វិរោចេសិ[២] ទិសា សព្វា ឧទយំ សុរិយោ យថា ។
សហស្សារានិ ចក្កានិ បាទេ ទិស្សន្តិ មារិស
កោ វា ត្វំ កស្ស វា បុត្តោ កថំ ជានេមុ តំ មយំ ។

---
១ ឱ. ឧទុ ។ ២ ឱ. ម. វិរោចសិ ។



# បច្ឆនមាលិយត្ថេរាបទាន ទី ៥

(៧៨) ខ្ញុំលះបង់នូវកាមគុណទាំង ៥ ដែលមានសភាពជាទីស្រឡាញ់ ជាទីត្រេកអរនៃចិត្ត លះបង់នូវសម្បត្តិ ៨០ កោដិ ហើយចូលទៅកាន់ផ្នួស ។ លុះខ្ញុំបួសហើយ បានវៀរនូវបាបកម្មដោយកាយ លះបង់នូវវចីទុច្ចរិត ហើយនៅជិតច្រាំងស្ទឹង ។ ព្រះសម្ពុទ្ធដ៏ប្រសើរ ស្តេចបានចូលមករកខ្ញុំ ដែលកំពុងនៅតែម្នាក់ឯង ខ្ញុំក៏មិនស្គាល់ព្រះអង្គថាជាព្រះពុទ្ធទេ តែខ្ញុំបានធ្វើបដិសន្ថារៈ ។ លុះខ្ញុំធ្វើបដិសន្ថារៈហើយ បានសួរនូវនាមនិងគោត្រថា អ្នកជាទេវតា ឬជាគន្ធព្វ ឬមួយអ្នកជាព្រះឥន្ទ្រ ធ្លាប់ឲ្យទានក្នុងកាលមុន អ្នកជាអ្វី អ្នកជាបុត្ររបស់បុគ្គលណា ឬអ្នកជាមហាព្រហ្មមកក្នុងទីនេះ បានញុំាងទិសទាំងពួងឲ្យភ្លឺច្រាល ដូចព្រះអាទិត្យកំពុងរះ ។ ម្នាលអ្នកនិទ្ទុក្ខ ចក្រទាំងឡាយ មានកាំមួយពាន់ ប្រាកដក្នុងបាទា (នៃអ្នក) អ្នកជាអ្វី អ្នកជាបុត្ររបស់បុគ្គលណា ដូចម្តេចហ្ន៎ យើងនឹងស្គាល់អ្នក ។

នាមគោត្តំ បវេទេហិ    សំសយំ អបនេហិ មេ

នម្ហិ ទេវោ ន គន្ធព្វោ    នម្ហិ សក្កោ បុរិន្ទទោ ។

ព្រហ្មភាវោ ច មេ នត្ថិ    ឯតេសំ ឧត្តមោ អហំ

អតីតោ វិសយំ តេសំ    ទាលយិំ កាមពន្ធនំ ។

សព្វេ កិលេសេ ឈាបេត្វា    បត្តោ សម្ពោធិមុត្តមំ

តស្ស វាចំ សុណិត្វាហំ    ឥទំ វចនមព្រវិំ ។

យទិ ពុទ្ធោសិ សព្វញ្ញូ    និសីទ ត្វំ មហាមុនិ

តមហំ បូជយិស្សាមិ    ទុក្ខស្សន្តករោ តុវំ ។

បត្ថរិត្វា អជិនចម្មំ    អទាសិ សត្ថុនោ អហំ

និសីទិ តត្ថ ភគវា    សីហោវ គិរិគព្ភរេ ។

ខិប្បំ បព្វតមារុយ្ហ    អម្ពស្ស ផលមគ្គហិំ

សាលកល្យាណិកំ បុប្ផំ    ចន្ទនញ្ច មហារហំ ។





សូមអ្នកប្រាប់ នូវនាមនិងគោត្រ (របស់អ្នក) ចូរបន្សាត់នូវសេចក្តីសង្ស័យរបស់ខ្ញុំចេញ ។

តថាគតមិនមែនជាទេវតា មិនមែនជាគន្ធព្វ តថាគតមិនមែនជាព្រះឥន្ទ្រ ធ្លាប់ឲ្យទានក្នុងកាលមុនទេ ។ មួយទៀត តថាគតមិនមែនជាព្រហ្មទេ តថាគត ប្រសើរជាងជនទាំងនោះ បានកន្លងនូវវិស័យរបស់ជនទាំងនោះ ហើយផ្តាច់បង់នូវចំណងគឺកាម ។ តថាគតដុតបង់នូវកិលេសទាំងអស់ហើយ បានដល់នូវសេចក្តីត្រាស់ដឹងដ៏ប្រសើរ ។

ខ្ញុំបានស្តាប់នូវពាក្យ របស់ព្រះពុទ្ធនោះ ហើយពោលនូវពាក្យនេះថា បពិត្រព្រះមហាមុនី បើព្រះអង្គជាសព្វញ្ញុពុទ្ធជាមហាមុនី សូមព្រះអង្គគង់សិន ខ្ញុំនឹងបូជាព្រះអង្គ ព្រោះព្រះអង្គជាអ្នកធ្វើនូវទីបំផុត នៃទុក្ខបានហើយ ។ ខ្ញុំបានក្រាលនូវស្បែកខ្លាថ្វាយព្រះសាស្តា ព្រះមានព្រះភាគ ទ្រង់គង់លើស្បែកខ្លានោះ ដូចជាសត្វសីហៈ ដែលឋិតនៅលើញកនៃភ្នំ ។ ខ្ញុំបានឡើងភ្នំជាប្រញាប់ ហើយបេះយកផ្លែស្វាយ ផ្កាក្តៅនាង និងខ្លឹមចន្ទន៍ដ៏មានដំឡៃច្រើន ។

ទិស្វា បគ្គយ្ហ តំ សត្ថុំ　　ឧបេត្វា លោកនាយកំ
ផលំ ពុទ្ធស្ស ទត្វាន　　សាលបុប្ផំ អបូជយឹ ។
ចន្ទនំ អនុលិម្បិត្វា　　អវន្ទឹ សត្ថុនោ អហំ
បសន្នចិត្តោ សុមនោ　　វិបុលាយ ច បីតិយា ។
អជិនម្ហិ និសីទិត្វា　　សុមេធោ លោកនាយកោ
មម កម្មំ បកិត្តេសិ　　ហាសយន្តោ មមំ តទា ។
ឥមិនា ផលទានេន　　គន្ធមាលេហិ ចូភយំ
បញ្ចវីសេ កប្បសតេ　　ទេវលោកេ រមិស្សតិ ។
អនូនមនសង្កប្បោ　　វសវត្តី ភវិស្សតិ
ឆព្វីសតិកប្បសតេ　　មនុស្សត្តំ គមិស្សតិ ។
ភវិស្សតិ ចក្កវត្តី　　ចាតុរន្តោ មហិទ្ធិកោ
វេភារំ នាម(១) នគរំ　　វិស្សុកម្មេន មាបិតំ ។

---

១ ម.ម. វេភារំ នាម ។



ខ្ញុំបានលើកផ្គង់ នូវរបស់ទាំងអស់នុ៎ះ ជាប្រញាប់ បង្អោន ចូលទៅរកព្រះលោកនាយក ខ្ញុំបានថ្វាយផ្លែឈើ បានបូជាផ្កាក្ដៅខាន់ដល់ព្រះពុទ្ធ ។ ខ្ញុំលាបនូវខ្លឹមចន្ទន៍ ហើយបានថ្វាយបង្គំព្រះសាស្តា ខ្ញុំមានចិត្តជ្រះថ្លា រីករាយដោយបីតិដ៏ធំទូលាយ ។ ក្នុងកាលនោះ ព្រះសុមេធៈ ជាលោកនាយក ដែលកំពុងគង់លើស្បែកខ្លា ទ្រង់ញុំាងខ្ញុំឲ្យរីករាយ ហើយទ្រង់សំដែង នូវកុសលកម្មរបស់ខ្ញុំថា

ក្នុងកប្បទី ២.៥០០ បុគ្គលនេះ នឹងត្រេកអរ ក្នុងទេវលោក ដោយហេតុទាំងពីរយ៉ាង គឺដោយការឲ្យនូវផ្លែឈើនេះផង ដោយការឲ្យគ្រឿងក្រអូប និងកម្រងផ្កានេះផង ។ បុគ្គលនេះ នឹងមានសេចក្ដីត្រិះរិះមិនទុនថយ ប្រព្រឹត្តទៅក្នុងអំណាចនៃខ្លួន ក្នុងកប្បទី ២.៦០០ បុគ្គលនេះ នឹងដល់ នូវភាពជាមនុស្ស ។ នឹងបានជាស្ដេចចក្រពត្តិ មានសមុទ្រទាំង ៤ ជាព្រំប្រទល់ ទាំងមានឫទ្ធិធំ ឯទីក្រុងឈ្មោះវេភារៈ ជាក្រុងដែលវិស្សុកម្មទេវបុត្រនិម្មិតថ្វាយ ។

ហោស្សតិ សព្វសោវណ្ណំ    នានារតនភូសិតំ
ឯតេន ឧបាយេន    សំសរិស្សតិ យោនិយោ[១] ។
សព្វត្ថ សុខិតោ ហុត្វា    ទេវត្តេ អថ មានុសេ
បច្ឆិមេ ភវសម្បត្តេ    ព្រហ្មពន្ធុ ភវិស្សតិ ។
អគារា អភិនិក្ខម្ម    អនគារី ភវិស្សតិ
អភិញ្ញាតិបត្តយោ[២] ហុត្វា    និព្វាយិស្សតិនាសវោ ។
ឥទំ វត្វាន សម្ពុទ្ធោ    សុមេធោ លោកនាយកោ
មម និជ្ឈាយមានស្ស    បក្កាមិ អនិលញ្ជសេ ។
តេន កម្មេន សុកតេន    ចេតនាបណិធីហិ ច
ជហិត្វា មានុសំ ទេហំ    តុសិតំ ឧបបជ្ជហំ ។
តុសិតតោ ចវិត្វាន    និព្វត្តឹ មាតុកុច្ឆិយា
ភោគេ មេ ឩនតា នត្ថិ    យម្ហិ កុច្ឆិ វសាមហំ ។
មាតុកុច្ឆិគតេ មយិ[៣]    អន្នបានញ្ច ភោជនំ
មាតុយា មម ឆន្ទេន    និព្វត្តតិ យទិច្ឆកំ ។

---

១ ឱ. យោនិសោ ។ ប សោ ភវេ ។ ២ ម. អភិញ្ញា បារគូ ។ ៣ ឱ. ម. មយ្ហំ ។



ទីក្រុងឈ្មោះកេតុៈនោះ ជាមាសទាំងអស់ ស្អិតស្អាងដោយ រតនៈផ្សេង ៗ បុគ្គលនេះនឹងអន្ទោលទៅ កាន់កំណើតទាំងឡាយ ដោយឧបាយនេះឯង ។ បុគ្គលនេះនឹងមានសេចក្តីសុខ ក្នុងទីទាំងពួង គឺជា ក្នុងទេវតា ឬក្នុងមនុស្សលោក លុះដល់បច្ឆិមភព នឹងបានជាព្រាហ្មណ៍ (ផៅពង្សនៃបុគ្គលដ៏ប្រសើរ) ។ បុគ្គលនេះ នឹងចេញចាកផ្ទះ ទៅជាអ្នកបួស ជាបុគ្គលដល់នូវត្រើយនៃអភិញ្ញា មិនមានអាសវៈ ហើយបរិនិព្វាន ។

ព្រះសម្ពុទ្ធ ព្រះនាមសុមេធៈ ជាលោកនាយក លុះទ្រង់ព្យាករនូវកម្មរបស់ខ្ញុំនេះហើយ កាលខ្ញុំកំពុងតែសំឡឹងមើល ព្រះអង្គទ្រង់ស្ដេចចៀសចេញទៅ តាមផ្លូវអាកាស ។ ខ្ញុំលះបង់នូវកាយជារបស់មនុស្សហើយ ចូលទៅកើតក្នុងតុសិត ដោយកម្មដែលខ្ញុំធ្វើល្អនោះផង ដោយការតាំងចិត្តទុកនូវចេតនានោះផង ។ លុះខ្ញុំច្យុតអំពីឋានតុសិត បានមកកើតក្នុងផ្ទៃនៃមាតា ខ្ញុំមិនខ្វះខាតភោគៈ ខ្ញុំនៅក្នុងគភ៌នៃមាតាណា កាលខ្ញុំនៅក្នុងគភ៌មាតានោះ បាយក្តី ទឹកក្តី ភោជនក្តី តែងកើតឡើងសម្រាប់មាតា តាមសេចក្តីប្រាថ្នារបស់ខ្ញុំ ។

ជាតិយា បញ្ចវស្សេន បព្វជឹ អនគារិយំ
ឱរោបិតម្ហិ កេសម្ហិ អរហត្តំ អបាបុណឹ ។
បុព្វកម្មំ គវេសន្តោ ឱរេន ឧទ្ទសិំ(១) អហំ
តឹសកប្បសហស្សម្ហិ មម កម្មំ អនុស្សរឹ ។
នមោ តេ បុរិសាជញ្ញ នមោ តេ បុរិសុត្តម
តវ សាសនមាគម្ម បត្តោម្ហិ អចលំ បទំ ។
តឹសកប្បសហស្សម្ហិ សម្ពុទ្ធមភិបូជយឹ(២)
ទុគ្គតឹ នាភិជានាមិ ពុទ្ធបូជាយិទំ ផលំ ។
កិលេសា ឈាបិតា មយ្ហំ ភវា សព្វេ សមូហតា
នាគោវ ពន្ធនំ ឆេត្វា វិហរាមិ អនាសវោ ។
ស្វាគតំ វត មេ អាសិ មម ពុទ្ធស្ស សន្តិកេ
តិស្សោ វិជ្ជា អនុប្បត្តា កតំ ពុទ្ធស្ស សាសនំ ។

---

១ ឱ. ឧទ្ទសំ ។ ២ ឱ. ម. យំ ពុទ្ធមភិបូជយិំ ។



ខ្ញុំមានអាយុ ៥ ឆ្នាំ ក៏ចេញចាកផ្ទះមក បានចូលទៅកាន់ផ្នួស កាលដែលគេកំពុងតែកោរសក់ ខ្ញុំក៏បានសម្រេចព្រះអរហត្ត ។ ខ្ញុំកាលស្វែងរកនូវបុព្វកម្ម (របស់ខ្ញុំ) ក៏មិនបានឃើញបុព្វកម្មខាងអាយ តែបានរឹកឃើញនូវបុព្វកម្មរបស់ខ្ញុំក្នុងកប្បទី ៣០.០០០ ។ បពិត្របុរសអាជានេយ្យ ខ្ញុំសូមថ្វាយបង្គំព្រះអង្គ បពិត្របុរសដ៏ឧត្តម ខ្ញុំសូមថ្វាយបង្គំព្រះអង្គ ខ្ញុំបានអាស្រ័យនូវសាសនារបស់ព្រះអង្គហើយ ទើបដល់នូវអចលបទគឺព្រះនិព្វាន ។ ក្នុងកប្បទី ៣០.០០០ អំពីកប្បនេះ ព្រោះហេតុដែលខ្ញុំ បានបូជាព្រះសម្ពុទ្ធ ក្នុងកាលនោះ ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃពុទ្ធបូជា ។ កិលេសទាំងឡាយ ខ្ញុំដុតបំផ្លាញហើយ ភពទាំងពួង ខ្ញុំដកចោលចេញហើយ ខ្ញុំជាបុគ្គលមិនមានអាសវៈ ព្រោះបានកាត់ចំណង ដូចជាដំរីកាត់ផ្តាច់នូវទន្ទឹង ។ ខ្ញុំមកល្អហើយ ក្នុងសំណាក់នៃព្រះពុទ្ធរបស់ខ្ញុំ វិជ្ជា ៣ ខ្ញុំបានដល់ហើយ សាសនា របស់ព្រះពុទ្ធ ខ្ញុំបានធ្វើហើយ ។

បដិសម្ភិទា ចតស្សោ   វិមោក្ខាបិ ច អដ្ឋិមេ

ឆឡភិញ្ញា សច្ឆិកតា   កតំ ពុទ្ធស្ស សាសនន្តិ ។

ឥត្ថំ សុទំ អាយស្មា ចន្ទនមាលិយោ ថេរោ ឥមា

គាថាយោ អភាសិត្ថាតិ ។

ចន្ទនមាលិយត្ថេរស្ស អបទានំ សមត្តំ ។

## ឆដ្ឋំ ធាតុបូជកត្ថេរាបទានំ

(៧៦) និព្វុតេ លោកនាថម្ហិ សិទ្ធត្ថេ លោកនាយកេ

មម ញាតី សមានេត្វា   ធាតុបូជំ អកាសហំ ។

ចតុន្នវុតេ ឥតោ កប្បេ   យំ ធាតុមភិបូជយិំ

ទុគ្គតិំ នាភិជានាមិ   ធាតុបូជាយិទំ ផលំ ។

កិលេសា ឈាបិតា មយ្ហំ   ភវា សព្វេ សមូហតា

នាគោវ ពន្ធនំ ឆេត្វា   វិហរាមិ អនាសវោ ។



បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនា របស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ។

បានឮថា ព្រះចន្ទនមាលិយត្ថេរ មានអាយុ បានសម្តែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

ចប់ ចន្ទនមាលិយត្ថេរាបទាន ។

## ធាតុបូជកត្ថេរាបទាន ទី ៦

(៧៦) កាលព្រះលោកនាថ ព្រះនាមសិទ្ធត្ថៈ ជាលោកនាយក ស្តេចបរិនិព្វានហើយ ខ្ញុំបានប្រជុំពួកញាតិរបស់ខ្ញុំ ហើយធ្វើនូវការបូជាព្រះធាតុ ។ ក្នុងកប្បទី ៩៤ អំពីកប្បនេះ ព្រោះហេតុដែលខ្ញុំ បានបូជាព្រះធាតុ ក្នុងកាលនោះ ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃការបូជាព្រះធាតុ ។ កិលេសទាំងឡាយ ខ្ញុំដុតបំផ្លាញហើយ ភពទាំងពួង ខ្ញុំដកចោលអស់ហើយ ខ្ញុំជាបុគ្គលមិនមានអាសវៈ ព្រោះបានកាត់បំណង់ ដូចដំរីប្រសើរកាត់ផ្តាច់នូវទន្លីង ។

ស្វាគតំ វត មេ អាសិ មម ពុទ្ធស្ស សន្តិកេ
តិស្សោ វិជ្ជា អនុប្បត្តា កតំ ពុទ្ធស្ស សាសនំ ។
បដិសម្ភិទា ចតស្សោ វិមោក្ខាបិ ច អដ្ឋិមេ
ឆឡភិញ្ញា សច្ឆិកតា កតំ ពុទ្ធស្ស សាសនន្តិ ។
ឥត្ថំ សុទំ អាយស្មា ធាតុបូជកោ ថេរោ ឥមា
គាថាយោ អភាសិត្ថាតិ ។

ធាតុបូជកត្ថេរស្ស អបទានំ សមត្តំ ។

## សត្តមំ បុឡិនុប្បាទកត្ថេរាបទានំ

(៧៧) បព្វតេ ហិមវន្តម្ហិ ទេវលោ នាម តាបសោ
តត្ថ មេ ចង្កមោ អាសិ អមនុស្សេហិ មាបិតោ[1] ។
ជដាភារស្ស[2] គរុតា កមណ្ឌលុធរោ តទា[3]
ឧត្តមត្ថំ គវេសន្តោ បវនា និក្ខមឹ តទា ។

១ ឱ. អមនុស្សីមាបិតោ ។ ២ ឱ. ជដាភារេន ។ ៣ ម. សទា ។



ខ្ញុំមកល្អហើយ ក្នុងសំណាក់នៃព្រះពុទ្ធរបស់ខ្ញុំ វិជ្ជា ៣ ខ្ញុំបានដល់ហើយ សាសនា របស់ព្រះពុទ្ធ ខ្ញុំបានធ្វើហើយ ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនា របស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ។

បានឮថា ព្រះធាតុបូជកត្ថេរ មានអាយុ បានសំដែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

ចប់ ធាតុបូជកត្ថេរាបទាន ។

## បុឡិនុប្បាទកត្ថេរាបទាន ទី ៧

(៧៧) ខ្ញុំកើតជាតាបស ឈ្មោះទេវលៈ នៅទៀប ភ្នំហិមពាន្ត ពួកអមនុស្សបានតាក់តែងទីចង្រ្កមឲ្យខ្ញុំ ក្នុង ព្រៃហិមពាន្តនោះ ។ ក្នុងកាលនោះឯង ខ្ញុំបានប្រដាប់នូវ គ្រឿងប្រដាប់ គឺក្ដួនសក់ ច្រេចនូវកុណ្ឌីទឹក ក៏ពុងតែ ស្វែងរកនូវប្រយោជន៍ដ៏ឧត្តម ហើយចេញទៅអំពីព្រៃ ។

ចុល្លាសីតិសហស្សានិ សិស្សា មយ្ហំ ឧបដ្ឋហុំ
សកកម្មាភិបសុតា វសន្តិ បព្វតេ តទា ។
អស្សមា អភិនិក្ខម្ម អកំ បុឡិនចេតិយំ
នានាបុប្ផំ សមានេត្វា តំ ចេតិយំ អបូជយិំ ។
តត្ថ ចិត្តំ បសាទេត្វា អស្សមំ បវិសាមហំ
សព្វេ សិស្សា សមាគន្ត្វា ឯតមត្ថំ អបុច្ឆិសុំ ។
បុឡិនេន កតោ ថូបោ យំ ត្វំ នមស្សសិ
មយម្បិ ញាតុមិច្ឆាម បុដ្ឋោ អាចិក្ខ នោ តុវំ ។
និដ្ឋា នោ វេ(១) មន្តបទេ ចក្ខុមន្តា មហាយសា
តេ ខោ អហំ នមស្សាមិ ពុទ្ធសេដ្ឋេ មហាយសេ ។

---

១ ម. ទិដ្ឋា តោ ។ ឱ. ទិដ្ឋា នុ ។





ក្នុងកាលនោះ សិស្សទាំងឡាយរបស់ខ្ញុំ ប្រមាណ៨៤.០០០ នាក់ បានចូលមកនៅបំរើខ្ញុំ សិស្សទាំងនោះ មានសេចក្តីខ្វល់ខ្វាយក្នុងកិច្ចការរបស់ខ្លួន ហើយនៅក្នុងព្រៃ ។ ខ្ញុំបានចេញអំពីអាស្រម ហើយធ្វើព្រះចេតិយ ដ៏ហើយដោយដីខ្សាច់ ខ្ញុំបានប្រមូលផ្កាផ្សេង ៗ ហើយបូជាទៅព្រះចេតិយនោះ ។ ខ្ញុំបានញ៉ាំងចិត្តឲ្យជ្រះថ្លា ក្នុងចេតិយនោះ ហើយបានចូលទៅកាន់អាស្រមវិញ ។

ពួកសិស្សទាំងអស់នាំគ្នាមកហើយ បានសួរសេចក្តីនេះថា បពិត្រទេវៈ លោកថ្វាយបង្គំទៅព្រះស្តូបណា ព្រះស្តូបនោះ ដែលលោកធ្វើហើយ ដោយដីខ្សាច់ ម្យ៉ាងទៀត យើងខ្ញុំទាំងឡាយចង់ដឹង លោកកាលបើយើងខ្ញុំទាំងឡាយសួរហើយ សូមមេត្តាប្រាប់ដល់យើងខ្ញុំទាំងឡាយ ។

ព្រះសម្ពុទ្ធទាំងឡាយ ទ្រង់មានចក្ខុ មានយសធំ (ប្រាកដ) ក្នុងបទរបស់មន្តនៃអ្នកទាំងឡាយ យើងឃើញហើយតើ ខ្ញុំថ្វាយបង្គំទៅព្រះសម្មាសម្ពុទ្ធទាំងឡាយនោះ ជាព្រះពុទ្ធដ៏ប្រសើរ មានយសធំ ។

កីទិសា តេ មហាវីរ សព្វញ្ញូ លោកនាយកា
កឹវណ្ណា កឹសីលា កីទិសា តេ មហាយសា ។
ពត្តឹសលក្ខណា ពុទ្ធា ចត្តារីស(១) ទិជាបិ ច
នេត្តា គោបខុមា(២) តេសំ ជិញ្ជុកផលសន្និភា ។
គច្ឆមានា ច តេ ពុទ្ធា យុគមត្តញ្ច បេក្ខរេ
ន តេសំ ជាណុ នទតិ សន្ធិសទ្ទោ ន សុយ្យតិ ។
គច្ឆមានា ច សុគតា អតុរិតា(៣) គច្ឆរេ
បឋមំ ទក្ខិណំ បាទំ ពុទ្ធានំ ឯស ធម្មតា ។

១ ឱ.ម. ពត្តាឡីស ។ ២ ឱ.ម. គោបមុខា ។ ៣ ឱ.ម. ឧទ្ធរន្តា ។



ព្រះសព្វញ្ញូទាំងនោះ ជាលោកនាយក ទ្រង់មានព្យាយាមធំ ប្រាកដដូចម្ដេច មានគុណដូចម្ដេច មានសីលដូចម្ដេច ព្រះសម្ពុទ្ធទាំងនោះមានយសធំ ប្រាកដដូចម្ដេច ។

ព្រះពុទ្ធទាំងឡាយ មានលក្ខណៈ ៣២ មានព្រះទន្ត ៤០ គត់ មានកំណើតពីរផង ព្រះនេត្រនៃព្រះសម្មាសម្ពុទ្ធទាំងនោះ ស្រដៀងនឹងភ្នែកកូនគោ ប្រាកដស្មើដោយផ្លែនៃទំពាំងបូរ ។ ព្រះសម្ពុទ្ធទាំងនោះ កាលស្ដេចនឹងទៅ ទ្រង់ក្រឡេកមើល នូវទីចម្ងាយមួយជួរទឹមផង ព្រះជាណុនៃព្រះសម្មាសម្ពុទ្ធទាំងនោះ មិនលាន់ឮសូរផង សំឡេងទីកនៃព្រះជាណុ របស់ព្រះសម្មាសម្ពុទ្ធទាំងនោះ មិនឮសូរផង ។ ព្រះសម្ពុទ្ធទាំងនោះ កាលស្ដេចទៅ ក៏ទ្រង់ទៅដោយល្អ ទៅមិនបានរួសរាន់ (ទ្រង់ឈាន) នូវព្រះបាទខាងស្ដាំជាដំបូង នេះជាធម្មតានៃព្រះសម្ពុទ្ធទាំងឡាយ ។

## សត្តមំ ពុទ្ធុប្បាទកថាបទានំ

អសម្ភិតា ច តេ ពុទ្ធា    មិគរាជាវ កេសរី
នេវុក្កំសេន្តិ អត្តានំ    នោ ច វម្ភេន្តិ បាណិនំ ៗ
មានាតិមានតោ[១] មុត្តា    សមា សព្វេសុ បាណិសុ
អនត្តុក្កំសកា ពុទ្ធា    ពុទ្ធានំ ឯស ធម្មតា ៗ
ឧប្បជ្ជន្តា ច សម្ពុទ្ធា    អាលោកំ ទស្សយន្តិ តេ
ឆព្វិការំ[២] បកាសេន្តិ[៣] កេវលំ វសុធំ ឥមំ ៗ
បស្សន្តិ និរយញ្ចេតេ    និព្វាតិ និរយោ តទា
បវស្សតិ មហាមេឃោ    ពុទ្ធានំ ឯស ធម្មតា ៗ
ឦទិសា[៤] តេ មហានាគា    អតុលា តេ[៥] មហាយសា
វណ្ណតោ អនតិក្កន្តា    អប្បមេយ្យា តថាគតា ៗ

---

១ ឱ. មានាវិមានតោ ។ ២ ម. ឆព្វិការំ ។ ៣ ឱ.ម. បកម្បេន្តិ ។ ៤ ឱ. ឯទិសា ។
៥ ឱ. អតុល្យា ច ។





មួយទៀត ព្រះពុទ្ធទាំងនោះ ទ្រង់មិនតក់ស្លុត ប្រៀបដូចជា កេសររាជសីហ៍ ជាស្តេចនៃម្រឹគ ព្រះពុទ្ធទាំងឡាយទ្រង់មិនលើកតំកើងព្រះអង្គឯងផង ទាំងមិនបន្តុះបង្អាប់ពួកសត្វផង ។ ព្រះពុទ្ធទាំងឡាយ ទ្រង់ផុតស្រឡះចាកមានះនិងអតិមានះ ទ្រង់មានព្រះហឫទ័យស្មើចំពោះសត្វទាំងពួង ទ្រង់មិនលើកតំកើងព្រះអង្គឯង នេះជាធម្មតានៃព្រះសម្ពុទ្ធទាំង-ឡាយ ។ មួយវិញទៀត ព្រះសម្ពុទ្ធទាំងឡាយនោះ កាលកើតឡើង ទ្រង់សម្តែងនូវពន្លឺ ទ្រង់ប្រកាសនូវផែនដីទាំងអស់នេះ មានប្រការ ៦ ។ ក្នុងកាលនោះ ព្រះសម្ពុទ្ធទាំងឡាយនុ៎ះ ទ្រង់ទតឃើញនូវនរក នរកក៏រលត់ទៅវិញ មហាមេឃ បង្អុរភ្លៀងចុះមក នេះជាធម្មតានៃព្រះពុទ្ធទាំងឡាយ ។ ព្រះតថាគតទាំងនោះ ជាមហានាគប្រាកដដូច្នោះ ព្រះតថាគតទាំងនោះ ទ្រង់មានយសធំ គេមិនអាចថ្លឹងគុណបាន ព្រះតថាគតទាំងឡាយ ទ្រង់មិនប្រព្រឹត្តកន្លងពណ៌គុណ មានព្រះគុណគឺបុគ្គលមិនគប្បីកប់បាន ។

អនុមោទិំសុ មេ វាក្យំ    សព្វេ សិស្សា សគារវា
តថា(១) បដិបជ្ជិំសុ    យថាសត្តិ យថាពលំ ។
បដិប្វេជត្តិ បុញ្ញំ    តេ សកម្មាភិលាសិនោ
សទ្ទហន្តា មម វាក្យំ    ពុទ្ធគតមានសា(២) ។
តទា ចវិត្វា តុសិតា    ទេវបុត្តោ មហាយសោ
ឧប្បជ្ជិ មាតុកុច្ឆិស្មិំ    ទសសហស្សី កម្បថ ។
អស្សមស្សាវិទូរម្ហិ    ចង្កមូបគតោ(៣) អហំ
សព្វេ សិស្សា សមាគន្ត្វា    អាគច្ឆុំ មម សន្តិកេ ។
ឧសភោវ មហី នទតិ    មិគរាជាវ កុជ្ជតិ(៤)
សុំសុមារោវ សល្លតិ(៥)    កឹ វិបាកោ ភវិស្សតិ ។

១ ម. តថា ប ។ ២ ម. ពុទ្ធសក្កតមានសោ ។ ៣ ឱ. ម. ចង្កមម្ហិ បរិតោ ។ ៤ ឱ. កុញ្ជតិ ។ ម. កូជតិ ។ ៥ ឱ. សទ្ទតិ ។



ពួកសិស្សទាំងអស់ ជាអ្នកប្រកបដោយសេចក្តីគោរព បាន អនុមោទនាតាមពាក្យរបស់ខ្ញុំ សិស្សទាំងឡាយនោះ បាន នាំគ្នាប្រតិបត្តិ តាមសេចក្តីអង់អាច តាមកំឡាំង ដោយប្រការដូច្នោះ ។ សិស្សទាំងឡាយនោះ ជាអ្នកមិន ខ្ជិលច្រអូស ក្នុងការងាររបស់ខ្លួន នាំគ្នាបូជានូវព្រះចេតិយ ខ្ពស់ សិស្សទាំងឡាយនោះ ជាអ្នកជឿតាមពាក្យរបស់ខ្ញុំ ជាអ្នកមានចិត្តដល់នូវភាពជាព្រះពុទ្ធ ។

ក្នុងកាលនោះ មានទេវបុត្តមួយអង្គ មានយសធំ ច្យុតចុះ មកអំពីឋានតុសិត បានមកកើតក្នុងផ្ទៃមាតា លោកធាតុទាំង មួយម៉ឺន ក៏ញាប់ញ័រ ។ ខ្ញុំឋិតនៅក្នុងទីចង្រ្កម មិនឆ្ងាយអំពី អាស្រម ពួកសិស្សទាំងអស់ បានមកប្រជុំគ្នាក្នុងសំណាក់ របស់ខ្ញុំ ហើយសួរខ្ញុំថា ផែនដីបន្លឺ ដូចគោឧសភរាជ ស្រែកឡើងដូចស្តេចនៃម្រឹគ រោទ៍ឡើងដូចជាក្រពើ តើជា វិបាកអ្វីហ្ន៎ ។

### សត្តមំ បុប្ផច្ឆទនិយត្ថេរាបទានំ

យំ បតិត្តេមិ សត្ថុនំ   សិក្ខតា ថូបសន្តិកេ
សោណានំ កតកា សត្ថា   មាតុតុដ្ឋមុទាគមំ ។
តេសំ ជន្តុកថំ កត្វា   តិត្ថយិត្វា មហាមុនិ
ឧយ្យោជេត្វា សកេ សិស្សេ បល្លង្កំ អាភុជឹ អហំ ។
ពលញ្ច វត មេ ខីណំ   ព្យាធិតោ(១) បរមេន ហិ
ពុទ្ធសេដ្ឋំ សរិត្វាន   តត្ថ កាលំ កតោ អហំ ។
សព្វេ សិស្សា សមាគន្ត្វា   អកំសុ ចិតកំ តទា
កឡេវរញ្ច មេ គយ្ហ   ចិតកំ អភិរោបយុំ ។
ចិតកំ បរិវារេត្វា   សីសេ កត្វាន អញ្ជលី
សោកសល្លបរេតា តេ   វិកិណ្ណឹសុ សមាគតា ។

---

១ ឱ. វិប្បធិតោ ។ ម. ព្យធិតោ ។



### បុប្ផច្ឆទនិយត្ថេរាបទាន ទី ៧

ខ្ញុំកំពុងសរសើរនូវព្រះសម្ពុទ្ធអង្គណា ក្នុងទីជិតនៃព្រះស្តូបដែលធ្វើហើយដោយដីខ្សាច់ ក្នុងវេលានេះ ព្រះមានព្រះភាគអង្គនោះ ព្រះអង្គជាគ្រូ បានស្តេចចូលទៅកាន់ផ្លូវនៃទាក ។ ខ្ញុំបានធ្វើធម្មកថា ដល់សិស្សទាំងឡាយនោះ ហើយសរសើរនូវព្រះមហាមុនី រួចបញ្ជូនពួកសិស្សឲ្យត្រឡប់ទៅលំនៅជារបស់នៃខ្លួនវិញ ហើយខ្ញុំអង្គុយពែនភ្នែន ។ មួយទៀត ខ្ញុំអស់កំឡាំងណាស់ ព្រោះខ្ញុំមានរោគាព្យាធិជាទម្ងន់ ខ្ញុំរលឹកនូវព្រះសម្មាសម្ពុទ្ធដ៏ប្រសើរ ហើយក៏ធ្វើមរណៈកាល ក្នុងទីនោះ ។ ក្នុងកាលនោះ ពួកសិស្សទាំងអស់បានមកប្រជុំគ្នា ហើយធ្វើជើងថ្ករ រួចលើកសពរបស់ខ្ញុំដាក់លើជើងថ្ករ ។ សិស្សទាំងឡាយនោះ បានហោមរោមជើងថ្ករ ហើយធ្វើនូវអញ្ជលីលើសិរ្សៈ មានសរគឺសេចក្តីសោកត្រូវសង្កត់ បានមកប្រជុំគ្នាហើយ យំកន្ទក់កន្ទេញ ។

តេសំ លាលប្បមានានំ អគមំ ជិនសន្តិកំ(១)

អហំ អាចរិយោ តុយ្ហំ មា សោចិត្ថ សុមេធសា ។

សទត្ថេ វាយមេយ្យាថ រត្តិន្ទិវមតន្ទិតា

មា វោ បមត្តា អហុត្ថ ខណោ វោ បដិបាទិតោ ។

សកេ សិស្សេ ឧបាសិត្វា ទេវលោកំ ឧបាគមំ

អដ្ឋារស ច កប្បានិ(២) ទេវលោកេ អហោសហំ(៣) ។

សតានំ បញ្ចក្ខត្តុញ្ច ចក្កវត្តិ អហោសហំ

អនេកសតក្ខត្តុញ្ច ទេវរជ្ជំ អការយិំ ។

អវសេសេសុ កប្បេសុ វោកិណ្ណំ សំសរិំ អហំ

ទុគ្គតិំ នាភិជានាមិ ឧបដ្ឋានស្ស ឥទំ ផលំ ។

---

១ ឱ. អគមាសិំ ជិនន្តិកា ។ ម. អគមំ ជិនតំ តទា ។ ២ ឱ. អដ្ឋារសាហំ កប្បានិ ។
៣ ឱ. រមឹ អហំ ។ ម. រមេមហំ ។



កាលសិស្សទាំងឡាយនោះ កំពុងតែយំរៀបរាប់ ខ្ញុំក៏មកកាន់ជើងព្រៃ ហើយបានពោលថា ម្នាលអ្នកទាំងឡាយមានបញ្ញា យើងហ្នឹងហើយជាអាចារ្យរបស់អ្នក អ្នកទាំងឡាយកុំសោកស្តាយឡើយ ។ អ្នកទាំងឡាយកុំខ្ជិលច្រអូស ចូរនាំគ្នាព្យាយាម ក្នុងប្រយោជន៍របស់ខ្លួន ទាំងយប់ទាំងថ្ងៃចុះ អ្នកទាំងឡាយកុំមានសេចក្តីប្រមាទឡើយ ខណៈរបស់អ្នកទាំងឡាយ ដល់ព្រមហើយ ។ លុះខ្ញុំប្រៀនប្រដៅនូវពួកសិស្សរបស់ខ្លួនរួចហើយ ខ្ញុំក៏ត្រឡប់ទៅឯទេវលោកវិញ ខ្ញុំបានកើតក្នុងទេវលោក អស់ ១៨ កប្ប ខ្ញុំបានកើតជាស្តេចចក្រពត្តិ អស់ ៥០០ ដង ខ្ញុំបានទទួលសម្បត្តិជាទេវតាអស់ច្រើនរយដង ។ ក្នុងកប្បទាំងឡាយដ៏សេស ខ្ញុំបានអន្ទោលទៅកាន់គតិច្រឡូកច្រឡំ តែខ្ញុំមិនដែលស្គាល់ទុគ្គតិឡើយ នេះជាផលនៃការកសាងព្រះចេតិយខ្ជាប់ ។

យថា កោមុទិកេ មាសេ ពហូ បុប្ផន្តិ បាទបា
តថេវាហម្បិ សមយេ បុប្ផិតោម្ហិ មហេសិនា(១) ។
វីរិយំ មេ ធុរធោរយ្ហំ យោគក្ខេមាធិវាហនំ
នាគោវ ពន្ធនំ ឆេត្វា វិហរាមិ អនាសវោ ។
សតសហស្សេ ឥតោ កប្បេ យំ ពុទ្ធមភិត្ថវិំ
ទុគ្គតិំ នាភិជានាមិ កិត្តនាយ ឥទំ ផលំ ។
កិលេសា ឈាបិតា មយ្ហំ ភវា សព្វេ សមូហតា
នាគោវ ពន្ធនំ ឆេត្វា វិហរាមិ អនាសវោ ។
ស្វាគតំ វត មេ អាសិ មម ពុទ្ធស្ស សន្តិកេ
តិស្សោ វិជ្ជា អនុប្បត្តា កតំ ពុទ្ធស្ស សាសនំ ។

---

១ ឱ. មហេសិនោ ។





ឈើទាំងឡាយជាច្រើន រីកផ្កាក្នុងខែជាទីកើតផ្កាកោមុទ យ៉ាងណាមិញ ឯខ្ញុំក៏បានរីកហើយក្នុងសម័យ នៃព្រះសម្មាសម្ពុទ្ធ ដែលព្រះអង្គស្វែងរកនូវគុណដ៏ធំដូច្នោះដែរ ។ ខ្ញុំមានព្យាយាម ជាទីនាំទៅនូវធុរៈ ដល់ហើយនូវព្រះនិព្វាន ជាទីអស់ទៅនៃយោគៈ ជាអ្នកមិនមានអាសវៈ ព្រោះបានកាត់ចំណង ដូចជាដំរីកាត់ផ្តាច់នូវចំណង ។ ក្នុងកប្បទីមួយសែន អំពីកប្បនេះ ព្រោះហេតុដែលខ្ញុំសរសើរព្រះសម្ពុទ្ធក្នុងកាលនោះ ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃការសរសើរព្រះសម្ពុទ្ធ ។ កិលេសទាំងឡាយ ខ្ញុំដុតបំផ្លាញហើយ ភពទាំងពួង ខ្ញុំដកចោលចេញហើយ ខ្ញុំជាបុគ្គលមិនមានអាសវៈ ព្រោះបានកាត់ចំណង ដូចជាដំរីកាត់ផ្តាច់នូវចំណង ។ ឱ! ខ្ញុំមកល្អហើយ ក្នុងសំណាក់នៃព្រះពុទ្ធរបស់ខ្ញុំ វិជ្ជា ៣ ខ្ញុំបានដល់ហើយ សាសនា របស់ព្រះពុទ្ធ ខ្ញុំបានធ្វើហើយ ។

បដិសម្ភិទា ចតស្សោ   វិមោក្ខាបិ ច អដ្ឋិមេ
ឆឡភិញ្ញា សច្ឆិកតា   កតំ ពុទ្ធស្ស សាសនន្តិ ។

ឥត្ថំ សុទំ អាយស្មា បុឡិនុប្បាទកោ ថេរោ ឥមា គាថាយោ អភាសិត្ថាតិ ។

បុឡិនុប្បាទកត្ថេរស្ស អបទានំ សមត្តំ ។

## អដ្ឋមំ តរណិយត្ថេរាបទានំ

(៧៨) អត្ថទស្សី តុ ភគវា   សយម្ភូ លោកនាយកោ
វិនតានទិយា តីរេ   ឧបគច្ឆិ តថាគតោ ។
ឧទកា អភិនិក្ខម្ម   កច្ឆបោ វារិគោចរោ
ពុទ្ធំ តារេតុកាមោហំ   ឧបេសិំ លោកនាយកំ ។
អភិរូហតុ មំ ពុទ្ធោ   អត្ថទស្សី មហាមុនិ
អហំ តំ តារយិស្សាមិ   ទុក្ខស្សន្តករោ តុវំ ។



បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ពាក្យសាសនា របស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ។

បានឮថា ព្រះបុឡិនុប្បាទកត្ថេរ មានអាយុ បានសម្តែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

ចប់ បុឡិនុប្បាទកត្ថេរាបទាន ។

## តរណិយត្ថេរាបទាន ទី ៨

(៧៨) ព្រះតថាគត មានព្រះភាគ ព្រះនាមអត្ថទស្សី ជាព្រះសយម្ភូ ជាលោកនាយក ស្តេចបានចូលទៅជិតឆ្នេរស្ទឹងវិនតា ។ ខ្ញុំជាអណ្តើក ត្រាច់រកទឹក បានងើបអំពីទឹក មានប្រាថ្នានឹងចម្លងនូវព្រះពុទ្ធជាម្ចាស់ បានចូលទៅជិតព្រះលោកនាយក ហើយពោលថា បពិត្រព្រះមហាមុនី សូមព្រះពុទ្ធជាម្ចាស់ ព្រះនាមអត្ថទស្សី ទ្រង់ឡើងជិះលើខ្នងនៃខ្ញុំព្រះអង្គចុះ ខ្ញុំព្រះអង្គនឹងចម្លងព្រះអង្គ ព្រោះព្រះអង្គបានធ្វើនូវទីបំផុតនៃទុក្ខ ។

មម សង្កប្បមញ្ញាយ អត្ថទស្សី មហាយសោ
អភិរុហិត្វាន(១)មេ បិដ្ឋឹ អដ្ឋាសិ លោកនាយកោ ។
យទា សរាមិ អត្តានំ យតោ បត្តោស្មិ វិញ្ញុតំ
សុខំ មេ តាទិសំ នត្ថិ ផុដ្ឋេ បាទតលេ យថា(២) ។
ឧត្តរិត្វាន សម្ពុទ្ធោ អត្ថទស្សី មហាយសោ
នទីតីរម្ហិ ឋត្វាន ឥមា គាថា អភាសថ ។
យាវតា វត្តតេ ចិត្តំ កង្ខាសោតំ(៣) តរាមហំ
អយញ្ច(៤) កច្ឆបោ រាជា តារេតិ(៥) មម បុញ្ញវា ។
ឥមិនា ពុទ្ធតារេន(៦) មេត្តចិត្តវតាយ ច
អដ្ឋារស កប្បសតេ ទេវលោកេ រមិស្សតិ ។
ទេវលោកា ឥធាគន្ត្វា សុក្កមូលេន ចោទិតោ
ឯកាសនេ និសីទិត្វា កង្ខាសោតំ តរិស្សតិ ។

១ ឱ. អភិរុហិត្វា ។ ២ ឱ យថា បាទតលេ មុទិតំ ទិស្សន្តិ ។ ៣ ឱ.ម. គង្គាសោតំ ។ ៤ ឱ អយំ ហិ ។ ៥ ឱ. តារេសិ ។ ៦ ឱ. ពុទ្ធតេជេន ។



ព្រះអត្ថទស្សី មានយសធំ ជាលោកនាយក ទ្រង់ជ្រាបសេចក្តីត្រិះរិះរបស់ខ្ញុំហើយ ក៏ឡើងគង់លើខ្នងរបស់ខ្ញុំ ។ វេលាណា ខ្ញុំរលឹកឃើញនូវខ្លួន វេលាណា ខ្ញុំដល់នូវភាពដឹងក្តីហើយ វេលានោះ ខ្ញុំមិនមានសេចក្តីសុខដែលដូចនោះឡើយ ដូចជាផ្ទៃនៃបាតជើង (ដែលត្រូវបាទា) ប៉ះ ។ ព្រះសម្ពុទ្ធ ព្រះនាមអត្ថទស្សី មានយសធំ ទ្រង់ឆ្លងផុតត្រើយហើយ ព្រះអង្គឋិតនៅទៀបឆ្នេរស្ទឹង ហើយទ្រង់ត្រាស់នូវព្រះគាថានេះថា

ចិត្តប្រព្រឹត្តទៅ ដរាបណា តថាគតឆ្លងនូវខ្សែ នៃសេចក្តីសង្ស័យបាន ដរាបនោះ ចំណែកអណ្តើកនេះទើបបានកើតជាស្តេចមានបុណ្យ ព្រោះបានចម្លងនូវតថាគត ។ អណ្តើកនេះ នឹងត្រេកអរក្នុងទេវលោក អស់ ១.៨០០ កប្ប ដោយការចម្លងព្រះពុទ្ធនេះផង ដោយមេត្តាចិត្តដែលប្រព្រឹត្តទៅនេះផង ។ លុះច្យុតចាកទេវលោក មកកាន់លោកនេះ ត្រូវកុសលមូលដាស់តឿនហើយ នឹងអង្គុយនៅលើអាសនៈតែមួយ ហើយឆ្លងនូវខ្សែ នៃសេចក្តីសង្ស័យបាន ។

យថាបិ ភទ្ទកេ ខេត្តេ　ពីជំ អប្បម្បិ រោបិតំ
សម្មា ធារំ បវស្សន្តេ(១)　ផលំ តោសេតិ កស្សកោ ។
តថេវិទំ ពុទ្ធក្ខេត្តំ　សម្មាសម្ពុទ្ធទេសិតំ
សម្មា ធារំ បវច្ឆន្តេ(២)　ផលំ មំ តោសយិស្សតិ ។
បធានំ បហិតត្តោម្ហិ　ឧបសន្តោ និរូបធិ
សព្វាសវេ បរិញ្ញាយ　វិហរាមិ អនាសវោ ។
អដ្ឋារសេ កប្បសតេ　យំ កម្មមករិំ តទា
ទុគ្គតឹ នាភិជានាមិ　តារណាយ ឥទំ ផលំ ។
កិលេសា ឈាបិតា មយ្ហំ　ភវា សព្វេ សមូហតា
នាគោវ ពន្ធនំ ឆេត្វា　វិហរាមិ អនាសវោ ។
ស្វាគតំ វត មេ អាសិ　មម ពុទ្ធស្ស សន្តិកេ
តិស្សោ វិជ្ជា អនុប្បត្តា　កតំ ពុទ្ធស្ស សាសនំ ។

---

១ ម. បវេច្ឆន្តេ ។ ២ ម. បវេច្ឆន្តេ ។



ពូជសូម្បីមានប្រមាណតិច ដែលបុគ្គលព្រោះហើយក្នុងស្រែដ៏ល្អ កាលភ្លៀងញ៉ាំងធារទឹកឲ្យធ្លាក់ចុះដោយល្អ ផលរមែងញ៉ាំងអ្នកស្រែឲ្យត្រេកអរបាន ដូចម្តេចមិញ ។ ពុទ្ធខេត្រនេះ ដែលព្រះសម្មាសម្ពុទ្ធទ្រង់សម្តែងហើយ រមែងញ៉ាំងធារនៃផល ឲ្យធ្លាក់ចុះដោយប្រពៃ ផលនឹងញ៉ាំងខ្ញុំឲ្យត្រេកអរបាន ក៏យ៉ាងនោះដែរ ។ ខ្ញុំជាអ្នកមានចិត្តបញ្ជូនទៅកាន់សេចក្តីព្យាយាម ហើយជាអ្នកស្ងប់រម្ងាប់ មិនមានឧបធិក្កិលេស បានកំណត់ដឹងនូវអាសវៈទាំងពួង ជាអ្នកមិនមានអាសវៈ ។ ក្នុងកប្បទី ១.៨០០ ព្រោះហេតុដែលខ្ញុំធ្វើកុសលកម្មក្នុងកាលនោះ ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃការចម្លងព្រះសម្ពុទ្ធ ។ កិលេសទាំងឡាយ ខ្ញុំដុតបំផ្លាញហើយ ភពទាំងពួង ខ្ញុំដកចោលហើយ ខ្ញុំជាបុគ្គលមិនមានអាសវៈ ព្រោះបានកាត់បណ្តឹង ដូចជាដំរីកាត់ផ្តាច់នូវទន្លីង ។ ឱ ! ខ្ញុំមកល្អហើយ ក្នុងសំណាក់នៃព្រះពុទ្ធរបស់ខ្ញុំ វិជ្ជា ៣ ខ្ញុំបានដល់ហើយ សាសនារបស់ព្រះពុទ្ធ ខ្ញុំបានធ្វើហើយ ។

បដិសម្ភិទា ចតស្សោ វិមោក្ខាបិ ច អដ្ឋិមេ
ឆឡភិញ្ញា សច្ឆិកតា កតំ ពុទ្ធស្ស សាសនន្តិ ។

ឥត្ថំ សុទំ អាយស្មា ករណីយោ ថេរោ ឥមា
គាថាយោ អភាសិត្ថាតិ ។

ករណីយត្ថេរស្ស អបទានំ សមត្តំ ។

## នវមំ ធម្មរុចិត្ថេរាបទានំ

(៧៩) យទា ទីបង្ករោ ពុទ្ធោ សុមេធំ ព្យាករី ជិនោ
អបរិមេយ្យេ ឥតោ កប្បេ អយំ ពុទ្ធោ ភវិស្សតិ ។
ឥមស្ស ជនិកា មាតា មាយា នាម ភវិស្សតិ
បិតា សុទ្ធោទនោ នាម អយំ ហេស្សតិ គោតមោ ។



បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនា របស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ។

បានឮថា ព្រះករណីយត្ថេរ មានអាយុ បានសំដែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

ចប់ ករណីយត្ថេរាបទាន ។

## ធម្មរុចិត្ថេរាបទាន ទី ៩

(៧៩) កាលណា ព្រះជិនស្រីសម្ពុទ្ធជាម្ចាស់ ព្រះនាមទីបង្ករៈ ទ្រង់ព្យាករនូវព្រះសុមេធតាបសថា សុមេធតាបសនេះ នឹងបានត្រាស់ជាព្រះពុទ្ធ ក្នុងអបរិមេយ្យកប្ប (កប្បរាប់មិនបាន) អំពីកប្បនេះ ។ ព្រះមាតាបង្កើតនៃព្រះពុទ្ធនេះ ព្រះនាមមាយា ព្រះបិតា ព្រះនាមសុទ្ធោទនៈ សុមេធ-តាបសនេះ នឹងបានត្រាស់ជាព្រះពុទ្ធ ព្រះនាមគោតមៈ ។

បធានំ បទហិត្វាន  កត្វា ទុក្ករការិកំ
អស្សត្ថមូលេ សម្ពុទ្ធោ  ពុជ្ឈិស្សតិ មហាយសោ ។
ឧបតិស្សោ កោលិតោ ច  អគ្គា ហេស្សន្តិ សាវកា
អានន្ទោ នាមុបដ្ឋាកោ(១)  ឧបដ្ឋិស្សតិមំ ជិនំ ។
ខេមា ឧប្បលវណ្ណា ច  អគ្គា ហេស្សន្តិ សាវិកា
ចិត្តោ អាឡវកោ ចេវ  អគ្គា ហេស្សន្តុបាសកា
ខុជ្ជុត្តរា នន្ទមាតា  អគ្គា ហេស្សន្តុបាសិកា
ពោធិ ឥមស្ស ធីរស្ស(២)  អស្សត្ថោតិ បវុច្ចតិ ។
ឥទំ សុត្វាន វចនំ  អសមស្ស មហេសិនោ
អាមោទិតា នរមរូ  នមស្សន្តិ កតញ្ជលី ។
តទាហំ មាណវោ អាសឹ  មេឃោ នាម សុសិក្ខិតោ
សុត្វា ព្យាករណំ សេដ្ឋំ  សុមេធស្ស មហាមុនិ(៣) ។

១ ឱ. ម. អានន្ទោ នាម នាមេន ។ ២ ឱ. ម. វីរស្ស ។ ៣ ឱ. ម. មហាមុនេ ។





សុមេធតាបសនេះ តំកល់ទុកនូវសេចក្តីព្យាយាមហើយ ធ្វើនូវទុក្ករកិរិយា នឹងបានត្រាស់ដឹងជាព្រះសម្ពុទ្ធ មានយសធំ ក្រោមម្លប់នៃអស្សត្ថព្រឹក្ស ។ ភិក្ខុឈ្មោះឧបតិស្សៈ ១ ឈ្មោះកោលិតៈ ១ នឹងបានជាសាវកដ៏ប្រសើរ ភិក្ខុជាអ្នកឧបដ្ឋាក មាននាមថា អានន្ទ នឹងបំរើនូវព្រះជិនស្រីអង្គនេះ ។ ភិក្ខុនីឈ្មោះខេមា ១ ឈ្មោះឧប្បលវណ្ណា ១ នឹងបានជាសាវិកា ដ៏ប្រសើរ គហបតីឈ្មោះចិត្តៈ ១ ឈ្មោះអាឡវកៈ ១ នឹងបានជាឧបាសក ដ៏ប្រសើរ ។ នាងខុជ្ជុត្តរា ១ នាងនន្ទមាតា ១ នឹងបានជាឧបាសិកាដ៏ប្រសើរ ដើមឈើសម្រាប់ត្រាស់ដឹងនៃអ្នកប្រាជ្ញអង្គនេះ គេហៅថាអស្សត្ថព្រឹក្ស ។

ពួកមនុស្សនឹងទេវតា បានឮព្រះពុទ្ធដីកានេះ នៃព្រះពុទ្ធជាបុគ្គលស្វែងរកនូវគុណដ៏ធំ ឥតមានបុគ្គលណាស្មើ ក៏មានចិត្តរីករាយ នាំគ្នាធ្វើអញ្ជលីនមស្ការ ។ បពិត្រព្រះមហាមុនី កាលនោះ ខ្ញុំជាមាណព ឈ្មោះមេឃៈ អ្នកសិក្សាប្រពៃ បានឮពាក្យព្យាករណ៍ដ៏ប្រសើរ នៃសុមេធតាបស ។

សិរិវច្ឆោ កតិញាណ   សុមេធេ ករុណាលយេ(១)
បព្វជិត្វាន តំ វីរំ   សហា ច អនុបព្វជឹ ។
សំវុតោ បាតិមោក្ខស្មឹ   ឥន្ទ្រិយេសុ ច បញ្ចសុ
សុទ្ធាជីវោ សតោ ធីរោ(២)   ជិនសាសនការកោ ។
ឯវំ វិហរមានោហំ   បាបមិត្តេន កេនចិ
និយោជិតោ អនាចារេ   សុមគ្គា បរិធំសិតោ ។
វិតក្កវសិកោ(៣) ហុត្វា   សាសនតោ អបក្កមឹ
បច្ឆា តេន កុមិត្តេន   បយុត្តោ មាតុឃាតនំ ។
អការឹ នន្តរិយញ្ច(៤)   ឃាតយឹ ទុដ្ឋមានសោ
តតោ ចុតោ មហាវីចឹ   ឧបបន្នោ សុទារុណំ ។
វិនិបាតំ គតោ សន្តោ   សំសរឹ ទុក្ខិតោ ចិរំ
ន បុនោ អទ្ទសំ វីរំ   សុមេធំ នរបុង្គវំ ។

១ ឧ.ម. ករុណាសយេ ។ ២ ឧ.ម. វីរោ ។ ៣ ឧ. វិតក្កវសគោ ។ ៤ ឧ. អការិ-នន្តរិយញ្ច ។



ខ្ញុំស្និទ្ធស្នាលចំពោះសុមេធតាបស មានករុណាជាទីនៅ ខ្ញុំក៏បានបួសតាមតាបស ជាអ្នកមានព្យាយាម ដែលទ្រង់ផ្នួសនោះ ។ ខ្ញុំសង្រួមក្នុងបាដិមោក្ខផង ក្នុងឥន្ទ្រិយទាំង ៥ ផង មានអាជីវៈដ៏បរិសុទ្ធ មានស្មារតី ជាអ្នកប្រាជ្ញ ជាអ្នកធ្វើតាមពាក្យប្រដៅ នៃព្រះជិនស្រី ។ កាលខ្ញុំនៅជាមួយនឹងបាបមិត្តណាមួយ យ៉ាងនេះ ក៏បានប្រកបក្នុងអនាចារ ហើយឃ្លាតចាកផ្លូវដ៏ល្អ ។ ខ្ញុំជាអ្នកលុះក្នុងអំណាចវិតក្កៈ បានចៀសចេញអំពីសាសនា វេលាក្រោយមក ខ្ញុំបានប្រកបដោយបាបមិត្តអាក្រក់នោះទៀត ក៏ប្រព្រឹត្តធ្វើនូវមាតុឃាត ។ ខ្ញុំមានចិត្តប្រទូស្ត បានធ្វើអនន្តរិយកម្ម គឺសម្លាប់មាតា ខ្ញុំច្យុតអំពីអត្តភាពនោះ បានទៅកើតក្នុងមហាអវីចិនរក ដ៏អាក្រក់ក្រៃពេក ។ ខ្ញុំទៅកើតក្នុងអបាយ ដល់នូវសេចក្តីទុក្ខ អន្ទោលទៅអស់កាល ជាយូរអង្វែង លែងបានឃើញព្រះសុមេធតាបស ជាអ្នកប្រាជ្ញប្រសើរជាងជន ។

អស្មឹ កប្បេ សមុទ្ទស្មឹ  មជ្ឈោ អាសិ តិមិន្ទលោ(១)
ទិស្វាហំ សាគរេ នាវំ  គោចរត្ថុបាគមឹ ។
ទិស្វា មំ វាណិជា ភីតា  ពុទ្ធសេដ្ឋំ អនុស្សរុំ
គោតមោតិ មហាឃោសោ  សុត្វា តេហិ ឧទីរិតំ ។
បុព្វសញ្ញំ សរិត្វាន  តតោ កាលំ កតោ អហំ
សាវត្ថិយំ កុលេ ឥទ្ធេ(២)  ជាតោ ព្រាហ្មណជាតិយំ ។
អាសិំ ធម្មរុចិ នាម  សព្វបាបជិគុច្ឆកោ
ទិស្វាហំ លោកបជ្ជោតំ  ជាតិយា សត្តវស្សិកោ ។
មហាជេតវនំ គន្ត្វា  បព្វជឹ អនគារិយំ
ឧបេមិ ពុទ្ធំ តិក្ខត្តុំ  រត្តិយា ទិវសស្ស ច ។

១ ម. តិមិង្គលោ ។ ២ ម. ឥទ្ធេ ។



ក្នុងកប្បនេះ ខ្ញុំបានកើតជាត្រីសមុទ្រ ឈ្មោះតិមិន្ទលៈ បានឃើញសំពៅក្នុងសាគរ ក៏ចូលទៅជិតដើម្បីរកអាហារ ។ ពាណិជទាំងឡាយ បានឃើញខ្ញុំហើយ ក៏មានសេចក្ដីភិតភ័យ បានរំឭកគុណ នៃព្រះពុទ្ធដ៏ប្រសើរ ជាគោតមៈ ៗ ដូច្នេះ ខ្ញុំក៏បានឮសំឡេងគឹកកងខ្លាំង ដែលពួកពាណិជទាំងនោះពោលហើយ ។ ខ្ញុំរលឹកឃើញ នូវសញ្ញាអំពីដើម ក អំពីនោះមក ខ្ញុំធ្វើនូវមរណកាល បានទៅកើតក្នុងកំណើតនៃព្រាហ្មណ៍ ជាត្រកូលស្តុកស្តម្ភ ក្នុងក្រុងសាវត្ថី ។ ខ្ញុំមានឈ្មោះធម្មរុចិ ជាអ្នកខ្ពើមរអើមនូវបាបទាំងពួង មានអាយុ ៧ ឆ្នាំអំពីកំណើត បានឃើញព្រះពុទ្ធជាពន្លឺ ក្នុងលោក ។ ខ្ញុំបានទៅកាន់វត្តជេតពនដ៏ប្រសើរ ហើយចូលទៅកាន់ផ្នួស ចូលទៅជិតព្រះពុទ្ធ អស់វារៈ ៣ ដង រាល់យប់រាល់ថ្ងៃ ។

តទា ទិស្វា មុនិ អាហ សរ ធម្មុក្កិតំ មំ
អាតាបិ អវចិំ ពុទ្ធំ បុព្វកម្មំ វិការិតំ ។

សុចិរំ សតបុញ្ញលក្ខណំ
បតិបុព្វេន វិសុទ្ធបច្ចយា(១)
អហមជ្ជ សុបេក្ខំ តេ
តវ បស្សាមិ និរុបមំ វិគ្គហំ ។

សុចិរំ វិហិតំ នុ តេ មយា(២)
សុចិរត្តេន ទិវាសោសិតា(៣)
សុចិរំ អមលំ វិសោធិតំ
ហទយំ ញាណមយំ មហាមុនេ ។

ចិរកាលសមង្គិតោ(៤) តយា
អវិនដ្ឋា បុនប្បុនំ(៥) ចិរំ
បុនរជ្ជ សមាគតោ តយា
ន ហិ នស្សតិ កតំ គោតម ។

១ ឱ. ម. ឧ វិសុទ្ធបច្ចយំ ។ ២ ឱ. វិហតគតោ មយា ។ ម. វិហតត្តោ គយា ។ ៣ ឱ.ម. ឧទិវិសោសិកា ។ ៤ ឱ. ចិរកាលំ សមាគតោ ។ ម. ចិរកាលសមង្គិតោ ។ ៥ ឱ.ម. បុនប្បុនំ ។





កាលនោះ ព្រះមុនីបានទតឃើញខ្ញុំហើយ ក៏ត្រាស់ថា នែ ធម្មទេ អ្នកចូរលើកតម្កើងនោះទៅ ។ ខ្ញុំបានពោលនូវបុព្វកម្ម ដែលខ្លួនខ្ញុំបានសាងហើយ ថ្វាយព្រះពុទ្ធជាម្ចាស់ថា

ខ្ញុំមានបានឃើញព្រះពុទ្ធ មានបុញ្ញលក្ខណៈច្រើន មាន វិសុទ្ធិជាបច្ច័យក្នុងកាលមុន អស់កាលយូរហើយ ទើប តែក្នុងថ្ងៃនេះ ខ្ញុំបានឃើញព្រះកាយរបស់ព្រះអង្គ ដ៏គួរ រមិលមើលកេបុគ្គលប្រៀបពុំបាន ។ ខ្ញុំបានតាំងបុណ្យ ចំពោះព្រះអង្គអស់កាលយូរ កិលេសទាំងឡាយ ខ្ញុំបាន ឡើងសូត្រមិនមានសេសសល់ ដោយការក្រៀមដ៏ស្អាត បពិត្រព្រះមហាមុនី ក្នុងតិញាណមិនមានមន្ទិល ខ្ញុំបាន ជំរះហើយអស់កាលយូរ ។ ខ្ញុំព្រះអង្គប្រកបជាមួយនឹង ព្រះអង្គ អស់កាលដ៏យូរ មិនវិនាសក្នុងចន្លោះថ្ងៃទៀត អស់កាលដ៏យូរ ក្នុងថ្ងៃនេះ ខ្ញុំព្រះអង្គប្រកបព្រមជា មួយនឹងព្រះអង្គម្ដងទៀត បពិត្រព្រះគោតម: អំពើទាំង ឡាយដែលខ្ញុំបានធ្វើ មិនវិនាសទេឡើយ ។

កិលេសា ឈាបិតា មយ្ហំ ភវា សព្វេ សមូហតា
នាគោវ ពន្ធនំ ឆេត្វា វិហរាមិ អនាសវោ ។
ស្វាគតំ វត មេ អាសិ មម ពុទ្ធស្ស សន្តិកេ
តិស្សោ វិជ្ជា អនុប្បត្តា កតំ ពុទ្ធស្ស សាសនំ ។
បដិសម្ភិទា ចតស្សោ វិមោក្ខាបិច អដ្ឋិមេ
ឆឡភិញ្ញា សច្ឆិកតា កតំ ពុទ្ធស្ស សាសនន្តិ ។

ឥត្ថំ សុទំ អាយស្មា ធម្មរុចិ ថេរោ ឥមា គាថាយោ អភាសិត្ថាតិ ។

ធម្មរុចិត្ថេរស្ស អបទានំ សមត្តំ ។

## ទសមំ សាលមណ្ឌបិយត្ថេរាបទានំ

(៨០) អជ្ឈោគហេត្វា សាលវនំ សុកតោ អស្សមោ មម
សាលបុប្ផេហិ សញ្ឆន្នោ វសាមិ បវនេ តទា ។



កិលេសទាំងឡាយ ខ្ញុំដុតបំផ្លាញហើយ ភពទាំងពួង ខ្ញុំដកចោលហើយ ខ្ញុំជាបុគ្គលមិនមានអាសវៈ ព្រោះបានកាត់ចំណង ដូចជាដំរីកាត់ផ្តាច់នូវទន្លីង ។ ឱ ! ខ្ញុំមកល្អហើយ ក្នុងសំណាក់នៃព្រះពុទ្ធរបស់ខ្ញុំ វិជ្ជា ៣ ខ្ញុំបានដល់ហើយ សាសនា របស់ព្រះពុទ្ធ ខ្ញុំក៏បានធ្វើហើយ ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនា របស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ។

បានឮថា ព្រះធម្មរុចិត្ថេរ មានអាយុ បានសម្តែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

ចប់ ធម្មរុចិត្ថេរាបទាន ។

## សាលមណ្ឌបិយត្ថេរាបទាន ទី ១០

(៨០) អាស្រមដ៏ល្អរបស់ខ្ញុំ គេធ្វើលយចូលទៅក្នុងព្រៃរាំង សឹងដេរដាសដោយផ្ការាំង កាលនោះខ្ញុំនៅក្នុងព្រៃ ។

## ទសមំ សាលបុប្ផិយត្ថេរាបទានំ

ពិយទស្សី នាម ភគវា សយម្ភូ អគ្គបុគ្គលោ
វិវេកកាមោ សម្ពុទ្ធោ សាលវនមុបាគមិ ។
អរញ្ញា អភិនិក្ខម្ម បវនំ អគមាសហំ
មូលផលំ គវេសន្តោ អាហិណ្ឌាមិ វនេ តទា ។
តត្ថទ្ទសាសឹ សម្ពុទ្ធំ ពិយទស្សឹ មហាយសំ
សុនិសិន្នំ សមាបន្នំ វិរោចន្តំ មហាវនេ ។
ចតុទណ្ឌេ ឋបេត្វាន ពុទ្ធស្ស ឧបរី អហំ
មណ្ឌបំ សុកតំ កត្វា សាលបុប្ផេហិ ឆាទយឹ ។
សត្តាហំ ធារយិត្វាន មណ្ឌបំ សាលឆាទិតំ
តត្ថ ចិត្តំ បសាទេត្វា ពុទ្ធសេដ្ឋំ អវន្ទហំ (១) ។
ភគវា តម្ហិ សមយេ វុដ្ឋហិត្វា សមាធិតោ (២)
យុគមត្តំ បេក្ខមានោ និសីទិ បុរិសុត្តមោ ។

---

១ ម. អវន្ទិហំ ។ ២ ម. សមាធិតោ ។





ព្រះសម្ពុទ្ធ មានព្រះភាគ ព្រះនាមពិយទស្សី ជាព្រះសយម្ភូ ជាអគ្គបុគ្គល ទ្រង់ប្រាថ្នាវិវេក បានស្តេចចូលទៅក្នុងព្រៃរាំង ។ ខ្ញុំបានចេញអំពីអាស្រមទៅក្នុងព្រៃ ក្នុងកាលនោះ ខ្ញុំកាលនឹងស្វែងរក នូវមើមឈើនិងផ្លែឈើ បានត្រាច់ទៅក្នុងព្រៃ ។ ខ្ញុំបានឃើញនូវព្រះសម្ពុទ្ធ ព្រះនាមពិយទស្សី មានយសធំ ព្រះអង្គគង់ចូលនិរោធសមាបត្តិ ដ៏រុងរឿងក្នុងព្រៃធំនោះ ។ ខ្ញុំបានតំកល់ទុក នូវឈើ ៤ កំណាត់ ពីខាងលើនៃព្រះសម្ពុទ្ធ ហើយធ្វើមណ្ឌបយ៉ាងល្អ ប្រក់ដោយផ្ការាំងទាំងឡាយ ។ ខ្ញុំបានទ្រទ្រង់នូវមណ្ឌប ដែលប្រក់ដោយផ្ការាំង អស់ ៧ ថ្ងៃ ហើយញុំាងចិត្តឲ្យជ្រះថ្លា ក្នុងមណ្ឌបនោះ ទាំងបានថ្វាយបង្គំនូវព្រះពុទ្ធដ៏ប្រសើរ ។ សម័យនោះ ព្រះមានព្រះភាគ ជាបុរសដ៏ឧត្តម បានចេញអំពីសមាធិ ហើយគង់សំឡឹងមើលទី អំពីចម្ងាយប្រមាណមួយជួរនឹម ។

សាវកោ វរុណោ នាម    បិយទស្សិស្ស សត្ថុនោ
វសីសតសហស្សេហិ    ឧបេតញ្ញ វិចាយតិ ៗ
បិយទស្សី តុ ភគវា    លោកជេដ្ឋោ នរាសភោ
ភិក្ខុសង្ឃេ និសីទិត្វា    សិតំ បាតុករិ ជិនោ ៗ
អនុរុទ្ធោ ឧបដ្ឋាកោ    បិយទស្សិស្ស សត្ថុនោ
ឯកំសំ ចីវរំ កត្វា    អបុច្ឆិត្ថ មហាមុនិំ ៗ
កោ នុ ខោ ភគវា ហេតុ    សិតកម្មស្ស សត្ថុនោ
ការណេ វិជ្ជមានម្ហិ    សត្ថា បាតុករេ សិតំ ៗ
សត្តាហំ បុប្ផឆទំ    យោ មេ ធារេសិ មាណវោ
តស្ស កម្មំ សរិត្វាន    សិតំ បាតុករិំ អហំ ៗ
អនោកាសំ ន បស្សាមិ    យត្ថំ បុញ្ញំ វិបច្ចតិ
ទេវលោកេ មនុស្សេ វា    ឱកាសោវ ន សម្មតិ ៗ



សាវ័កឈ្មោះវរុណៈ របស់ព្រះសាស្តា ព្រះនាមបិយទស្សី បានចូលទៅគាល់ព្រះលោកនាយក ជាមួយនឹងពួកព្រះអរហន្ត មួយសែនអង្គ ជាអ្នកស្ទាត់ជំនាញ ។ ឯព្រះជិនស្រី មានព្រះភាគ ព្រះនាមបិយទស្សី ជាធំក្នុងលោក ប្រសើរជាងនរៈ គង់ក្នុងកណ្តាលភិក្ខុសង្ឃ ហើយទ្រង់ធ្វើនូវការញញឹមឲ្យប្រាកដ ។ ឧបដ្ឋាក ឈ្មោះអនុរុទ្ធៈ របស់ព្រះសាស្តា ព្រះនាមបិយទស្សី ធ្វើចីវរឆៀងស្មាម្ខាង ហើយទូលសួរព្រះមហាមុនីថា បពិត្រព្រះមានព្រះភាគ សភាវៈដូចម្តេចហ្ន៎ ជាហេតុនៃព្រះសាស្តា ទ្រង់ធ្វើនូវការញញឹម ប្រហែលជាមានហេតុ បានជាព្រះសាស្តា ទ្រង់ធ្វើនូវការញញឹម ។

មាណពណា ទ្រទ្រង់នូវម្លប់ដែលប្រក់ហើយដោយផ្កាក៏ ដល់តថាគត អស់ ៧ ថ្ងៃ តថាគតរលឹកឃើញកុសលកម្មរបស់មាណពនោះ ទើបធ្វើនូវការញញឹមឲ្យប្រាកដ ។ បុណ្យណា ឲ្យផលក្នុងទេវលោក ឬក្នុងមនុស្សលោក ឱកាសណា មិនសមល្មម តថាគតមិនឃើញនូវបុណ្យ ឱកាសនោះ ដែលមិនមានឱកាសឲ្យផល នោះឡើយ ។

ទេវលោកេ វសន្តស្ស    បុញ្ញកម្មសមង្គិនោ
យាវតា បរិសា តស្ស    សាលច្ឆន្នា ភវិស្សតិ ។
តត្ថ នច្ចេហិ គីតេហិ    តូរិយេហិ ភណេហិ ច
រមិស្សតិ សទា(១) សន្តោ    បុញ្ញកម្មសមាហិតោ ។
យាវតា បរិសា តស្ស    គន្ធគន្ធំ ភវិស្សតិ
សាលស្ស បុប្ផវស្សា ច    បវស្សិស្សតិ តាវទេ ។
តតោ ចុតោយំ មនុជោ    មានុសំ អាគមិស្សតិ
ឥធាបិ សាលឆទនំ    សព្វកាលំ ធរិស្សតិ(២) ។
ឥធ នច្ចញ្ច គីតញ្ច    សម្មតាឡសមាហិតំ
បរិវារេស្សន្តិមំ និច្ចំ    ពុទ្ធបូជាយិទំ ផលំ ។
ឧគ្គច្ឆន្តេ ច សូរិយេ    សាលវស្សំ បវស្សតិ
បុញ្ញកម្មេន សំយុត្តំ    វស្សតិ សព្វកាលិកំ ។

---

១ ម. តទា ។ ២ ម. ធារិយ្យតិ ។



កាលបុគ្គលនោះ ប្រកបដោយបុញ្ញកម្ម ហើយនៅក្នុងទេវលោក បរិសទ្យទាំងប៉ុន្មាន របស់បុគ្គលនោះ សឹងដេរដាសដូចជាផ្ការាំង ។ បុគ្គលប្រកបដោយបុញ្ញកម្មនោះ នឹងត្រេកត្រអាលដោយពួករាំ ពួកចំរៀង ពួកដេញដំប្រគំ ដ៏ជានិច្ច ក្នុងទេវលោក សព្វ ១ កាល ។ បរិសទ្យទាំងប៉ុន្មានរបស់បុគ្គលនោះ សឹងមានក្លិនក្រអូប ទាំងមានភ្លៀងជាវិការៈនៃផ្ការាំង នឹងធ្លាក់ចុះក្នុងខណៈនោះឯង ។ លុះបុគ្គលនេះច្យុតអំពីទេវលោកនោះ មកកើតជាមនុស្ស នឹងមកកាន់ត្រកូលមនុស្ស មណ្ឌបប្រក់ដោយផ្ការាំង ក្នុងមនុស្សលោកនេះ នឹងទ្រទ្រង់ (នូវបុគ្គលនេះ) សព្វ ១ កាល ។ របាំក្តី ចំរៀងក្តី ភ្លេងដេញដំប្រគំក្តី នឹងហោមរោមនូវបុគ្គលនេះ អស់កាលជានិច្ច ក្នុងមនុស្សលោកនេះ នេះជាផលនៃពុទ្ធបូជា ។ មួយទៀត កាលព្រះអាទិត្យរះឡើង ភ្លៀងជាវិការៈនៃផ្ការាំងនឹងធ្លាក់ចុះមក ឯភ្លៀងជាវិការៈនៃផ្ការាំង ដ៏ប្រកបដោយបុញ្ញកម្ម នឹងធ្លាក់ចុះមក សព្វ ១ កាល ។

អដ្ឋារសេ កប្បសតេ | ឱក្កាកកុលសម្ភវោ
គោតមោ នាម នាមេន | សត្ថា លោកេ ភវិស្សតិ ។
តស្ស ធម្មេសុ ទាយាទោ | ឱរសោ ធម្មនិម្មិតោ
សព្វាសវេ បរិញ្ញាយ | និព្វាយិស្សតិនាសវោ ។
ធម្មំ អភិសមេន្តស្ស | សាលបុប្ផំ ភវិស្សតិ
ឋិតកោ ឈាយមានស្ស | បុប្ផំ តត្ថ ហេស្សតិ ។
វិហារំ ភិក្ខុយិត្វាន | បិយទស្សី មហាមុនិ
បរិសាយ ធម្មំ ទេសេសិ | តប្បុត្តា ធម្មវុឌ្ឍិយោ ។
តឹសកប្បានិ ទេវេសុ | ទេវរជ្ជមការយឹ
សដ្ឋិ ច សត្តក្ខត្តុំ ច | ចក្កវត្តិ អហោសហំ ។
ទេវលោកា ឥធាគន្ត្វា | លភាមិ វិបុលំ សុខំ
ឥធាបិ សាលបុប្ផំ | មណ្ឌបស្ស ឥទំ ផលំ ។



ក្នុងកប្បទី ១.៨០០ ព្រះសាស្តា ព្រះនាមគោតម ប្រសូតកើតក្នុងត្រកូលឧក្កាកជ នឹងត្រាស់ដឹងក្នុងលោក ។ កុលបុត្រនេះ នឹងបានជាទាយាទដែលព្រះធម៌និម្មិត ជាអ្នកទទួលនូវមត៌កក្នុងធម៌ របស់ព្រះតថាគតនោះ កំណត់ដឹងអាសវៈទាំងពួង ជាអ្នកមិនមានអាសវៈ នឹងបរិនិព្វាន ។ កាលកុលបុត្រនោះ ត្រាស់ដឹងនូវធម៌ នឹងមានមណ្ឌបប្រក់ដោយផ្កាកំង កាលគេកំពុងប្ដូរលើជើងថ្ករ នឹងមានមណ្ឌបប្រក់ដោយផ្កាកំង ក្នុងទីនោះ ។ លុះព្រះមហាមុនី ព្រះនាមបិយទស្សី ទ្រង់ប្រកាសនូវវិបាកស្រួចហើយ ទើបសម្តែងនូវព្រះធម៌ដល់បរិ.ស័ទ ទ្រង់ញុំាងបរិស័ទឲ្យឆ្អែត ដោយភ្លៀងគឺព្រះធម៌ ។

ខ្ញុំបានសោយរាជ្យ ជាស្តេចទេវតា ក្នុងទេវលោក អស់ ៣០ កប្ប បានជាស្តេចចក្រពត្តិ អស់ ៦៧ ដង ។ លុះខ្ញុំច្យុតចាកទេវលោក មកកើតក្នុងមនុស្សលោកនេះ ក៏បាននូវសេចក្តីសុខ ដ៏ធំទូលាយ មានទាំងមណ្ឌបដែលប្រក់ទៅដោយផ្កាកំង នេះឯង ជាផលនៃមណ្ឌប ។

ទសមំ សកលវណ្ណិយត្ថេរាបទានំ

អយំ បច្ឆិមកោ មយ្ហំ ចរិមោ វត្តតេ ភវោ
ឥធាបិ សាលធជំ ហេស្សតិ សព្វកាលិកំ ។
មហាមុនឹ តោសយិត្វា គោតមំ សក្យបុង្គវំ
សន្តោម្ហិ អចលំ ឋានំ ហិត្វា ជយបរាជយំ ។
អដ្ឋារសេ កប្បសតេ យំ ពុទ្ធមភិបូជយឹ
ទុគ្គតឹ នាភិជានាមិ ពុទ្ធបូជាយិទំ ផលំ ។
កិលេសា ឈាបិតា មយ្ហំ ភវា សព្វេ សមូហតា
នាគោវ ពន្ធនំ ឆេត្វា វិហរាមិ អនាសវោ ។
ស្វាគតំ វត មេ អាសិ មម ពុទ្ធស្ស សន្តិកេ
តិស្សោ វិជ្ជា អនុប្បត្តា កតំ ពុទ្ធស្ស សាសនំ ។
បដិសម្ភិទា ចតស្សោ វិមោក្ខាបិ ច អដ្ឋិមេ
ឆឡភិញ្ញា សច្ឆិកតា កតំ ពុទ្ធស្ស សាសនន្តិ ។



សកលវណ្ណិយត្ថេរាបទាន ទី ១០

នេះកើតកាយជាទីបំផុត ភពជាទីបំផុតរបស់ខ្ញុំ កំពុងប្រព្រឹត្តទៅ មណ្ឌបប្រក់ដោយផ្កាកង់ តែងមាន សព្វ ។ កាល ក្នុងមនុស្សលោកនេះ ។ ខ្ញុំបានញុំាងព្រះមហាមុនី ព្រះនាមគោតម ព្រះអង្គប្រសើរ ក្នុងពួកសក្យៈ ឲ្យត្រេកអរហើយ បានដល់នូវអចលដ្ឋាន គឺព្រះនិព្វាន ខ្ញុំលះបង់នូវការឈ្នះនិងការចាញ់អស់ហើយ ។ ក្នុងកប្បទី ១.៨០០ ព្រោះហេតុដែលខ្ញុំ បានបូជានូវព្រះពុទ្ធ ក្នុងកាលនោះ ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃពុទ្ធបូជា ។ កិលេសទាំងឡាយ ខ្ញុំដុតបំផ្លាញហើយភព ទាំងពួង ខ្ញុំដកចោលអស់ហើយ ខ្ញុំជាបុគ្គលមិនមានអាសវៈ ព្រោះបានកាត់ចំណង ដូចជាដំរីកាត់ផ្តាច់នូវទន្លីង ។ ឱ! ខ្ញុំមកល្អហើយ ក្នុងសំណាក់នៃព្រះពុទ្ធរបស់ខ្ញុំ វិជ្ជា ៣ ខ្ញុំបានដល់ហើយ សាសនា របស់ព្រះពុទ្ធ ខ្ញុំបានធ្វើហើយ ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំធ្វើឲ្យជាក់ច្បាស់បានហើយ ទាំងសាសនា របស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ។

ឥត្ថំ សុទំ អាយស្មា សាលមណ្ឌបិយោ ថេរោ ឥមា គាថាយោ អភាសិត្ថាតិ ។

សាលមណ្ឌបិយត្ថេរស្ស អបទានំ សមត្តំ ។

## ឧទ្ទានំ

បំសុកូលំ ពុទ្ធសញ្ញី ភិសទោ ញាណកិត្តកោ
ចន្ទនី ធាតុបូជី ច បុឡិនុប្បាទកោបិ ច ។
តរណោ ធម្មរុចិកោ សាលមណ្ឌបិយោ តថា
គាថាសតានិ ទ្វេ ហោន្តិ ឧនវីសតិមេវ ច ។

បំសុកូលវគ្គោ ឯកូនបញ្ញាសមោ ។

---



បានឮថា ព្រះសាលមណ្ឌបិយត្ថេរ មានអាយុ បានសំដែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

ចប់ សាលមណ្ឌបិយត្ថេរាបទាន ។

## ឧទ្ទាន

បំសុកូលសញ្ញកត្ថេរាបទាន ១ ពុទ្ធសញ្ញកត្ថេរាបទាន ១ ភិសទាយកត្ថេរាបទាន ១ ញាណត្ថវិកត្ថេរាបទាន ១ ចន្ទនមាលិយត្ថេរាបទាន ១ ធាតុបូជកត្ថេរាបទាន ១ បុឡិនុប្បាទកត្ថេរាបទាន ១ តរណិយត្ថេរាបទាន ១ ធម្មរុចិត្ថេរាបទាន ១ សាលមណ្ឌបិយត្ថេរាបទាន ១ មានគាថា ២១៩ ។

ចប់ បំសុកូលវគ្គ ទី ៤៩ ។

---

## បឋមំ តីណិកឹកណិបុប្ផិយត្ថេរាបទានំ

[៨១] កណិការំ ជោតន្តំ(១) និសិន្នំ បព្វតន្តរេ
អទ្ទសំ វិរជំ ពុទ្ធំ វិបស្សឹ លោកនាយកំ ។
តីណិ កឹកណិបុប្ផានិ(២) បគ្គយ្ហ អភិរោបយឹ
សម្ពុទ្ធំ អភិបូជេត្វា គច្ឆាមិ ទក្ខិណាមុខោ ។
តេន កម្មេន សុកតេន ចេតនាបណិធីហិ ច
ជហិត្វា មានុសំ ទេហំ តាវតឹសំ អគច្ឆហំ ។
ឯកនវុតេ ឥតោ កប្បេ យំ ពុទ្ធមភិបូជយឹ
ទុគ្គតឹ នាភិជានាមិ ពុទ្ធបូជាយិទំ ផលំ ។
កិលេសា ឈាបិតា មយ្ហំ ភវា សព្វេ សមូហតា
នាគោវ ពន្ធនំ ឆេត្វា វិហរាមិ អនាសវោ ។

១ ម. ជោតេន្តំ ។ ២ ម. កិង្កិនិបុប្ផានិ ។ ប. កិង្កណិបុប្ផានិ ។



## តីណិកឹកណិបុប្ផិយត្ថេរាបទាន ទី ១

[៨១] ខ្ញុំបានឃើញព្រះពុទ្ធ ព្រះនាមវិបស្សី ទ្រង់មិនមានធូលី ជានាយកក្នុងលោក ព្រះអង្គគង់នៅចន្លោះភ្នំ ទ្រង់រុងរឿង ដូចជាផ្កាកណិការ ។ ខ្ញុំបានលើកយកនូវផ្កាកណ្ដឹង ៣ ទង ថ្វាយព្រះសម្ពុទ្ធ លុះបូជាព្រះសម្ពុទ្ធហើយ ខ្ញុំមានមុខបែរឆ្ពោះ ដើរទៅកាន់ទិសខាងត្បូង ។ ដោយកម្មដែលខ្ញុំបានធ្វើហើយ ដោយល្អនោះផង ដោយចេតនាដែលខ្ញុំបានតំកល់ទុកនោះផង ខ្ញុំលះបង់រាងកាយជារបស់មនុស្សហើយ ក៏បានទៅកើតឯឋានតាវត្តិង្ស ។ ក្នុងកប្បទី ៩១ អំពីកប្បនេះ ព្រោះហេតុដែលខ្ញុំបានបូជាព្រះសម្ពុទ្ធក្នុងកាលនោះ ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃពុទ្ធបូជា ។ កិលេសទាំងឡាយ ខ្ញុំដុតបំផ្លាញហើយ ភពទាំងពួង ខ្ញុំដកចោលអស់ហើយ ខ្ញុំជាបុគ្គលមិនមានអាសវៈ ព្រោះបានកាត់ចំណង ដូចជាដំរីកាត់ផ្ដាច់នូវទន្លីង ។

ស្វាគតំ វត មេ អាសិ មម ពុទ្ធស្ស សន្តិកេ
តិស្សោ វិជ្ជា អនុប្បត្តា កតំ ពុទ្ធស្ស សាសនំ ។
បដិសម្ភិទា ចតស្សោ វិមោក្ខាបិ ច អដ្ឋិមេ
ឆឡភិញ្ញា សច្ឆិកតា កតំ ពុទ្ធស្ស សាសនំ ។

ឥត្ថំ សុទំ អាយស្មា តីណិកិង្កណិបុប្ផិយោ ថេរោ ឥមា គាថាយោ អភាសិត្ថាតិ ។

តីណិកិង្កណិបុប្ផិយត្ថេរស្ស អបទានំ សមត្តំ ។

# ទុតិយំ បំសុកូលបូជកត្ថេរាបទានំ

(៤២) ហិមវន្តស្ស អវិទូរេ ឧទង្គណោ នាម(១) បព្វតោ
តត្ថទ្ទសំ បំសុកូលំ ទុមគ្គម្ហិ វិលគ្គិតំ ។
តីណិ កិង្កណិបុប្ផានិ ឱចិនិត្វាន ហំ តទា
ហដ្ឋោ ហដ្ឋេន ចិត្តេន បំសុកូលំ អបូជយិំ ។

១ ឱ. ឧទរោ នាម ។ ម. ឧទគ្គណោ នាម ។





។ ខ្ញុំមកល្អហើយ ក្នុងសំណាក់នៃព្រះពុទ្ធរបស់ខ្ញុំ វិជ្ជា ៣ ខ្ញុំបានដល់ហើយ សាសនា របស់ព្រះពុទ្ធ ខ្ញុំក៏បានធ្វើហើយ ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនា របស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ។

បានឮថា ព្រះតីណិកិង្កណិបុប្ផិយត្ថេរ មានអាយុ បានសម្ដែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

ចប់ តីណិកិង្កណិបុប្ផិយត្ថេរាបទាន ។

# បំសុកូលបូជកត្ថេរាបទាន ទី ២

(៤២) មានភ្នំមួយឈ្មោះឧទង្គណៈ នៅជិតភ្នំហិមពាន្ត ក្នុងទីនោះ ខ្ញុំបានឃើញសំពត់បង្សុកូល ដែលគេពាក់លើចុងឈើ ។ ក្នុងកាលនោះ ខ្ញុំមានចិត្តត្រេកអររីករាយ បានបេះផ្កាកណ្ដឹង ៣ ទង ហើយបូជាចំពោះសំពត់បង្សុកូលនោះ ។ ដោយអំពើដែលខ្ញុំបានធ្វើហើយ ដោយល្អនោះផង ដោយ

តេន កម្មេន សុកតេន ចេតនាបណិធីហិ ច
ជហិត្វា មានុសំ ទេហំ តាវតឹសំ អគច្ឆហំ ។
ឯកនវុតេ ឥតោ កប្បេ យំ កម្មមករឹ តទា
ទុគ្គតឹ នាភិជានាមិ បូជេត្វា អរហទ្ធជំ ។
កិលេសា ឈាបិតា មយ្ហំ ភវា សព្វេ សមូហតា
នាគោវ ពន្ធនំ ឆេត្វា វិហរាមិ អនាសវោ ។
ស្វាគតំ វត មេ អាសិ មម ពុទ្ធស្ស សន្តិកេ
តិស្សោ វិជ្ជា អនុប្បត្តា កតំ ពុទ្ធស្ស សាសនំ ។
បដិសម្ភិទា ចតស្សោ វិមោក្ខាបិច អដ្ឋិមេ
ឆឡភិញ្ញា សច្ឆិកតា កតំ ពុទ្ធស្ស សាសនំ ។

ឥត្ថំ សុទំ អាយស្មា បំសុកូលបូជកោ ថេរោ ឥមា គាថាយោ អភាសិត្ថាតិ ។

បំសុកូលបូជកត្ថេរស្ស អបទានំ សមត្តំ ។



ចេតនា ដែលខ្ញុំបានតំកល់ទុកហើយនោះផង ខ្ញុំលះបង់នូវកាយជារបស់មនុស្សហើយ ទៅកើតឯឋានតាវត្តិង្ស ។ ក្នុងកប្បទី ៩១ អំពីកប្បនេះ ព្រោះហេតុដែលខ្ញុំធ្វើនូវអំពើល្អ ក្នុងកាលនោះ ខ្ញុំមិនដែលស្គាល់ទុគ្គតិ ព្រោះបានបូជាទង់ជ័យព្រះអរហន្ត ។ កិលេសទាំងឡាយ ខ្ញុំដុតបំផ្លាញហើយ ភពទាំងពួង ខ្ញុំដកចោលហើយ ខ្ញុំជាបុគ្គលមិនមានអាសវៈ ព្រោះបានកាត់ចំណង ដូចជាដំរីកាត់ផ្តាច់នូវទន្លីង ។ ឱ! ខ្ញុំមកល្អហើយ ក្នុងសំណាក់នៃព្រះពុទ្ធរបស់ខ្ញុំ វិជ្ជា ៣ ខ្ញុំបានដល់ហើយ សាសនារបស់ព្រះពុទ្ធ ខ្ញុំបានធ្វើហើយ ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនា របស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ។

បានឮថា ព្រះបង្សុកូលបូជកត្ថេរ មានអាយុ បានសម្តែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

ចប់ បង្សុកូលបូជកត្ថេរាបទាន ។

## តតិយំ កោរណ្ឌបុប្ផិយត្ថេរាបទានំ

[៤៣] វនកម្មិកោ បុរេ អាសឹ បិតុបិតាមហេនហំ(១)
បសុមារេន(២) ជីវាមិ កុសលំ មេ ន វិជ្ជតិ ។
មម អាសយសាមន្តា តិស្សោ លោកគ្គនាយកោ
បទានិ តីណិ ទស្សេសិ អនុកម្បាយ ចក្ខុមា ។
អក្កន្តេ ច បទេ ទិស្វា តិស្សនាមស្ស សត្ថុនោ
ហដ្ឋោ ហដ្ឋេន ចិត្តេន បទេ ចិត្តំ បសាទយឹ ។
កោរណ្ឌំ បុប្ផិតំ ទិស្វា បាទបំ ធរណីរុហំ
ចង្កោដកំ(៣) គហេត្វាន បទសេដ្ឋំ អបូជយឹ ។
តេន កម្មេន សុកតេន ចេតនាបណិធីហិ ច
ជហិត្វា មានុសំ ទេហំ តាវត្តិំសំ អគច្ឆហំ ។

១ ម. បិតុមាតុមហេនហំ ។ ២ ឱ. បសុហិរេន ។ ៣ ឱ. បង្កោដកំ ។ ម. សកោដកំ ។



## កោរណ្ឌបុប្ផិយត្ថេរាបទាន ទី ៣

(៤៣) ក្នុងកាលមុន ខ្ញុំបានកើតជាអ្នកធ្វើការងារក្នុងព្រៃ ចិញ្ចឹមជីវិតដោយការសម្លាប់សត្វ តាមលំអាននៃជីតា កុសលរបស់ខ្ញុំមិនមាន ។ ព្រះចក្ខុមសម្ពុទ្ធ ជាព្រះលោកនាយក ព្រះនាមតិស្សៈ ទ្រង់មានព្រះអធ្យាស្រ័យសង្គ្រោះដល់ខ្ញុំ បានសម្តែងនូវស្នាមព្រះបាទ ៣ អន្លើ ។ ខ្ញុំបានឃើញនូវស្នាមព្រះបាទ នៃព្រះសាស្តា ព្រះនាមតិស្សៈ ដែលទ្រង់ជាន់ទុក មានចិត្តត្រេកអររីករាយ បានញុំាងចិត្តឲ្យជ្រះថ្លា ក្នុងស្នាមព្រះបាទ ។ ខ្ញុំបានឃើញនូវដើមកន្ទុយដំរី ដុះលើផែនដីមានផ្ការីក ហើយកាច់យកផ្កាកន្ទុយដំរីនោះ ទាំងចង្កោម ទៅបូជាស្នាមព្រះបាទដ៏ប្រសើរ ។ ដោយអំពើដែលខ្ញុំបានធ្វើហើយ ដោយល្អនោះផង ដោយចេតនាដែលខ្ញុំបានតាំងទុកហើយនោះផង ខ្ញុំលះបង់កាយជារបស់មនុស្សហើយ ក៏បានទៅកើតឯឋានតាវត្តិង្ស ។

តតិយំ កោរណ្ឌបុប្ផិយត្ថេរាបទានំ

យំ យំ យោនុបបជ្ជាមិ ទេវត្តំ អថ មានុសំ
កោរណ្ឌកឆវី ហោមិ សប្បភាសោ(១) ភវាមហំ ។
ទ្វេនវុតេ ឥតោ កប្បេ យំ កម្មមករឹ តទា
ទុគ្គតឹ នាភិជានាមិ បទព្ពជាយិទំ(២) ផលំ ។
កិលេសា ឈាបិតា មយ្ហំ ភវា សព្វេ សមូហតា
នាគោវ ពន្ធនំ ឆេត្វា វិហរាមិ អនាសវោ ។
ស្វាគតំ វត មេ អាសិ មម ពុទ្ធស្ស សន្តិកេ
តិស្សោ វិជ្ជា អនុប្បត្តា កតំ ពុទ្ធស្ស សាសនំ ។
បដិសម្ភិទា ចតស្សោ វិមោក្ខាបិច អដ្ឋិមេ
ឆឡភិញ្ញា សច្ឆិកតា កតំ ពុទ្ធស្ស សាសនំ ។

ឥត្ថំ សុទំ អាយស្មា កោរណ្ឌបុប្ផិយោ ថេរោ ឥមា គាថាយោ អភាសិត្ថាតិ ។

កោរណ្ឌបុប្ផិយត្ថេរស្ស អបទានំ សមត្តំ ។

---

១ ម. សុប្បភាសោ ។ ២ ម. បទព្វជាយិទំ ។



កោរណ្ឌបុប្ផិយត្ថេរាបទាន ទី ៣

ខ្ញុំចូលទៅកាន់កំណើតណា ៗ ទោះជាទេវតា ឬជាមនុស្ស ក៏មានពណ៌សម្បុរដូចផ្កាកន្ទួយដំរី មានពន្លឺស្មើល្អ ។ ក្នុងកប្បទី ៩២ អំពីកប្បនេះ ព្រោះហេតុដែលខ្ញុំធ្វើកុសលកម្មក្នុងកាលនោះ ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃការបូជាស្នាមព្រះបាទ ។ កិលេសទាំងឡាយ ខ្ញុំដុតបំផ្លាញហើយ ភពទាំងពួង ខ្ញុំដកចោលហើយ ខ្ញុំជាបុគ្គលមិនមានអាសវៈ ព្រោះបានកាត់ចំណង ដូចជាដំរីកាត់ផ្តាច់នូវទន្លីង ។ ឱ ! ខ្ញុំមកល្អហើយ ក្នុងសំណាក់នៃព្រះពុទ្ធរបស់ខ្ញុំ វិជ្ជា ៣ ខ្ញុំបានដល់ហើយ សាសនា របស់ព្រះពុទ្ធ ខ្ញុំបានធ្វើហើយ ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនា របស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ។

បានឮថា ព្រះកោរណ្ឌបុប្ផិយត្ថេរ មានអាយុ បានសម្តែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

ចប់ កោរណ្ឌបុប្ផិយត្ថេរាបទាន ។

# បញ្ចមំ កឹសុកបុប្ផិយត្ថេរាបទានំ

(៨៤) កឹសុកំ បុប្ផិតំ ទិស្វា បគ្គហេត្វាន អញ្ជលឹ
ពុទ្ធសេដ្ឋំ សរិត្វាន អាកាសេ អភិបូជយឹ ។
តេន កម្មេន សុកតេន ចេតនាបណិធីហិ ច
ជហិត្វា មានុសំ ទេហំ តាវតឹសំ អគច្ឆហំ ។
ឯកត្តឹសេ ឥតោ កប្បេ យំ កម្មមករឹ តទា
ទុគ្គតឹ នាភិជានាមិ ពុទ្ធបូជាយិទំ ផលំ ។
កិលេសា ឈាបិតា មយ្ហំ ភវា សព្វេ សមូហតា
នាគោវ ពន្ធនំ ឆេត្វា វិហរាមិ អនាសវោ ។
ស្វាគតំ វត មេ អាសិ មម ពុទ្ធស្ស សន្តិកេ
តិស្សោ វិជ្ជា អនុប្បត្តា កតំ ពុទ្ធស្ស សាសនំ ។



# កឹសុកបុប្ផិយត្ថេរាបទាន ទី ៥

(៨៤) ខ្ញុំបានឃើញផ្កាចារីក ហើយ (បេះផ្កានោះ) ប្រ ផ្គងអញ្ជលីប្រណម្យឡើង នឹកដល់ព្រះសម្មាសម្ពុទ្ធដ៏ប្រសើរ ហើយបានបូជាបោះផ្កានោះ ទៅក្នុងអាកាស ។ ដោយអំពើដែលខ្ញុំបានធ្វើដោយល្អនោះផង ដោយចេតនាដែលខ្ញុំបានតំកល់ទុកហើយនោះផង ខ្ញុំលះបង់កាយជារបស់មនុស្ស ទៅ ក៏បានទៅកើតឯឋានតាវត្តិង្ស ។ ក្នុងកប្បទី ៣១ អំពីកប្បនេះ ព្រោះហេតុដែលខ្ញុំបានធ្វើនូវកុសលកម្ម ក្នុងកាលនោះ ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃពុទ្ធបូជា ។ កិលេសទាំងឡាយ ខ្ញុំដុតបំផ្លាញហើយ ភពទាំងពួង ខ្ញុំដកចោលហើយ ខ្ញុំជាបុគ្គលមិនមានអាសវៈ ព្រោះបានកាត់ចំណាង ដូចជាដំរីកាត់ផ្តាច់នូវទន្លីង ។ ឱ ! ខ្ញុំមកល្អហើយ ក្នុងសំណាក់នៃព្រះពុទ្ធរបស់ខ្ញុំ វិជ្ជា ៣ ខ្ញុំបានដល់ហើយ សាសនា របស់ព្រះពុទ្ធ ខ្ញុំបានធ្វើហើយ ។

បដិសម្ភិទា ចតស្សោ វិមោក្ខាបិ ច អដ្ឋិមេ
ឆឡភិញ្ញា សច្ឆិកតា កតំ ពុទ្ធស្ស សាសនំ ។

ឥត្ថំ សុទំ អាយស្មា កឹសុកបុប្ផិយោ ថេរោ ឥមា គាថាយោ អភាសិត្ថាតិ ។

កឹសុកបុប្ផិយត្ថេរស្ស អបទានំ សមត្តំ ។

## បញ្ចមំ ឧបឌ្ឍទុស្សទាយកត្ថេរាបទានំ

(៤៥) បទុមុត្តរភគវតោ សុជាតោ នាម សាវកោ
បំសុកូលំ គវេសន្តោ សង្ការេ រថិយា(១) តទា ។
នគរេ ហំសវតិយា បរេសំ ភតកោ អហំ
ឧបឌ្ឍទុស្សំ ទត្វាន សិរសា អភិវាទយឹ ។
តេន កម្មេន សុកតេន ចេតនាបណិធីហិ ច
ជហិត្វា មានុសំ ទេហំ តាវតឹសំ អគច្ឆហំ ។

១ ឱ. ឈរតិ ។ ម. ចរតី ។



បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនា របស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ។

បានឮថា ព្រះកឹសុកបុប្ផិយត្ថេរ មានអាយុ បានសំដែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

ចប់ កឹសុកបុប្ផិយត្ថេរាបទាន ។

## ឧបឌ្ឍទុស្សទាយកត្ថេរាបទាន ទី ៥

(៤៥) ក្នុងកាលនោះ សាវ័កនាមសុជាតៈ របស់ព្រះមានព្រះភាគ ព្រះនាមបទុមុត្តរៈ លោកកំពុងស្វែងរកសំពត់បង្សុកូលលើគំនរសំរាមក្នុងច្រក ។ ខ្ញុំជាអ្នកស៊ីឈ្នួលនៃបុគ្គលដទៃ ក្នុងនគរហង្សវតី បានប្រគេនសំពត់ពាក់កណ្ដាលហើយថ្វាយបង្គំដោយសិរ្សៈ ។ ដោយអំពើដែលខ្ញុំបានធ្វើល្អនោះផង ដោយចេតនាដែលខ្ញុំបានតំកល់ទុកហើយនោះផង ខ្ញុំលះបង់កាយជារបស់មនុស្សទៅ ក៏បានទៅកើតឯឋានតាវត្តិង្ស ។

តេត្តឹសក្ខត្តុំ ទេវិន្ទោ ទេវរជ្ជមការយឹ
សត្តសត្តតិក្ខត្តុញ្ច ចក្កវត្តី អហោសហំ ។
បទេសរជ្ជំ វិបុលំ គណនាតោ អសង្ខិយំ
ឧបឌ្ឍទុស្សទានេន មោទាមិ អកុតោភយោ ។
ឥច្ឆមានោ អហំ(១) អជ្ជ សកាននំ សបព្វតំ
ខោមទុស្សេហិ ឆាទេយ្យំ អឌ្ឍទុស្សស្សិទំ ផលំ ។
សតសហស្សេ ឥតោ កប្បេ យំ ទានមទទឹ តទា
ទុគ្គតឹ នាភិជានាមិ អឌ្ឍទុស្សស្សិទំ ផលំ ។
កិលេសា ឈាបិតា មយ្ហំ ភវា សព្វេ សមូហតា
នាគោវ ពន្ធនំ ឆេត្វា វិហរាមិ អនាសវោ ។
ស្វាគតំ វត មេ អាសិ មម ពុទ្ធស្ស សន្តិកេ
តិស្សោ វិជ្ជា អនុប្បត្តា កតំ ពុទ្ធស្ស សាសនំ ។

១ ឱ. ម. បហំ ។





ខ្ញុំបានកើតជាព្រះឥន្ទ្រ សោយរាជ្យជាស្តេចនៃទេវតា អស់ ៣៣ ដង ខ្ញុំបានកើតជាស្តេចចក្រពត្តិ អស់ ៧៧ ដង ។ ខ្ញុំបានសោយប្រទេសរាជ្យដ៏ធំទូលាយ រាប់ជាតិមិនអស់ ខ្ញុំឥតមានភ័យអំពីទីណា តែងត្រេកអរ ព្រោះកិរិយាឲ្យទូលសំពត់ពាក់កណ្តាល ។ ក្នុងថ្ងៃនេះ បើខ្ញុំប្រាថ្នាយកសំពត់ដែលកើតអំពីសម្បកឈើ មកប្រក់ព្រៃនិងភ្នំក៏សឹងបាន នេះជាផលនៃការថ្វាយទូលសំពត់ពាក់កណ្តាល ។ ក្នុងកប្បទីមួយសែន អំពីកប្បនេះ ព្រោះហេតុដែលខ្ញុំបានឲ្យទាន ក្នុងកាលនោះ ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃសំពត់ពាក់កណ្តាល ។ កិលេសទាំងឡាយ ខ្ញុំដុតបំផ្លាញហើយ ភពទាំងពួង ខ្ញុំដកចោលហើយ ខ្ញុំជាបុគ្គលមិនមានអាសវៈ ព្រោះបានកាត់ចំណង ដូចជាដំរីកាត់ផ្តាច់ទន្លីង ។ ឱ! ខ្ញុំមកល្អហើយ ក្នុងសំណាក់នៃព្រះពុទ្ធរបស់ខ្ញុំ វិជ្ជា ៣ ខ្ញុំបានដល់ហើយ សាសនា របស់ព្រះពុទ្ធ ខ្ញុំបានធ្វើហើយ ។

បដិសម្ភិទា ចតស្សោ វិមោក្ខាបិច អដ្ឋិមេ

ឆឡភិញ្ញា សច្ឆិកតា កតំ ពុទ្ធស្ស សាសនំ ។

ឥត្ថំ សុទំ អាយស្មា ឧបឌ្ឍទុស្សទាយកោ

ថេរោ ឥមា គាថាយោ អភាសិត្ថាតិ ។

ឧបឌ្ឍទុស្សទាយកត្ថេរស្ស អបទានំ សមត្តំ ។

## ឆដ្ឋំ ឃតមណ្ឌទាយកត្ថេរាបទានំ

(៨៦) សុចិន្តិតំ ភគវន្តំ លោកជេដ្ឋំ នរាសភំ

ឧបវិដ្ឋំ មហារញ្ញំ វាតាពាធេន បីឡិតំ ។

ទិស្វា ចិត្តំ បសាទេត្វា ឃតមណ្ឌំ ឧបានយិំ

កតត្តា ឧបចិត្តតា[១] ច[២] គង្គា ភាគីរសី អយំ[៣] ។

---

១ ឱ. អាចិតត្តា ។ ២ ម. ចបទំ នត្ថិ ។ ៣ ឱ. បយំ ។



បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនា របស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ។

បានឮថា ព្រះឧបឌ្ឍទុស្សទាយកត្ថេរ មានអាយុ បានសម្តែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

ចប់ ឧបឌ្ឍទុស្សទាយកត្ថេរាបទាន ។

## ឃតមណ្ឌទាយកត្ថេរាបទាន ទី ៦

(៨៦) ខ្ញុំបានឃើញព្រះមានព្រះភាគ ព្រះអង្គមានព្រះតម្រិះល្អ ជាធំក្នុងលោក ប្រសើរជាងនរៈ ស្តេចចូលទៅគង់ក្នុងព្រៃធំ ត្រូវអាពាធកើតអំពីខ្យល់បៀតបៀនហើយ ខ្ញុំក៏ញុំាងចិត្តឲ្យជ្រះថ្លា បាននាំយកទឹកដោះថ្លា ចូលទៅថ្វាយព្រះអង្គ ។ ព្រោះតែកុសលដែលខ្ញុំបានធ្វើហើយ បានសន្សំហើយ ស្ទឹងគង្គាភាគីរសីនេះ

មហាសមុទ្ទា ចត្តារោ ឃតំ សម្បជ្ជរេ មម
អយញ្ច បឋវី ឃោរា អប្បមាណា អសង្ខិយា ។
មម សង្កប្បមញ្ញាយ ភវន្តិ(១) តេ(២) មធុសក្ករា
ចតុទ្ទិសា(៣) ឥមេ រុក្ខា បាទបា ធរណីរុហា ។
មម សង្កប្បមញ្ញាយ កប្បរុក្ខា ភវន្តិ តេ
បញ្ញាសក្ខត្តុំ ទេវិន្ទោ ទេវរជ្ជមការយិំ ។
ឯកបញ្ញាសក្ខត្តុញ្ច ចក្កវត្តី អហោសហំ
បទេសរជ្ជំ វិបុលំ គណនាតោ អសង្ខិយំ ។
ចតុន្នវុតេ ឥតោ កប្បេ យំ ទានមទទិំ តទា
ទុគ្គតឹ នាភិជានាមិ ឃតមណ្ឌស្សិទំ ផលំ ។
កិលេសា ឈាបិតា មយ្ហំ ភវា សព្វេ សមូហតា
នាគោវ ពន្ធនំ ឆេត្វា វិហរាមិ អនាសវោ ។

---

១ ឱ.ម. ភវតេ ។ ២ ឱ.ម. តេតិ ជាហេនត្តិ ។ ៣ ឱ.ម. ចតុទ្ទីបា ។



នឹងមហាសមុទ្រទាំង ៤ ប្រែទៅជាទឹកដោះថ្លាសម្រាប់ខ្ញុំ ។ ផែនដីនេះ ជាគ្រឿងធំ ឥតប្រមាណមិនបាន រាប់មិនបាន ផែនដីនោះទៅជាស្ករក្រាម មានរសផ្អែមឆ្ងាញ់ ព្រោះដឹងនូវសេចក្តីត្រិះរិះរបស់ខ្ញុំ ដើមឈើទាំងឡាយនេះ ដុះលើផែនដី ឋិតនៅក្នុងទិសទាំង ៤ ដើមឈើទាំងនោះ កើតទៅជាដើមកល្បព្រឹក្ស ព្រោះដឹងនូវសេចក្តីត្រិះរិះរបស់ខ្ញុំ ។ ខ្ញុំបានធំជាងទេវតា បានសោយរាជ្យជាស្តេចនៃទេវតា អស់ ៥០ ដង ។ ខ្ញុំបានជាស្តេចចក្រពត្តិ អស់ ៥១ ដង បានសោយប្រទេសរាជ្យ ដ៏ធំទូលាយ រាប់ជាគណនាមិនអស់ ។ ក្នុងកប្បទី ៩៤ អំពីកប្បនេះ ព្រោះហេតុដែលខ្ញុំបានថ្វាយទាន ក្នុងកាលនោះ ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃទឹកដោះថ្លា ។ កិលេសទាំងឡាយ ខ្ញុំដុតបំផ្លាញហើយ គ្រប់ភពទាំងពួង ខ្ញុំដកចោលអស់ហើយ ខ្ញុំជាអ្នកមិនមានអាសវៈ ព្រោះបានកាត់ចំណង ដូចជាដំរីកាត់ផ្តាច់នូវទន្លីង ។

ស្វាគតំ វត មេ អាសិ   មម ពុទ្ធស្ស សន្តិកេ
តិស្សោ វិជ្ជា អនុប្បត្តា   កតំ ពុទ្ធស្ស សាសនំ
បដិសម្ភិទា ចតស្សោ   វិមោក្ខាបិច អដ្ឋិមេ
ឆឡភិញ្ញា សច្ឆិកតា   កតំ ពុទ្ធស្ស សាសនន្តិ ។

ឥត្ថំ សុទំ អាយស្មា យគមណ្ឌាយកោ ថេរោ
ឥមា គាថាយោ អភាសិត្ថាតិ ។

យគមណ្ឌទាយកត្ថេរស្ស អបទានំ សមត្តំ ។

## សត្តមំ ឧទកទាយកត្ថេរាបទានំ

(៨៧) បទុមុត្តរពុទ្ធស្ស   ភិក្ខុសង្ឃេ អនុត្តរេ
បសន្នចិត្តោ សុមនោ   បានិយឃដំ(១) អបូរយឹ ។
បព្វតគ្គេ ទុមគ្គេ វា   អាកាសេ វាថ ភូមិយំ
យទា បានិយមិច្ឆាមិ   ខិប្បំ និព្វត្តតេ មមំ ។

១ ម. បានីយឃដំ ។





ឱ! ខ្ញុំមកល្អហើយ ក្នុងសំណាក់នៃព្រះពុទ្ធរបស់ខ្ញុំ វិជ្ជា ៣ ខ្ញុំបានដល់ហើយ សាសនារបស់ព្រះពុទ្ធ ខ្ញុំបានធ្វើហើយ ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនា របស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ។

បានឮថា ព្រះយគមណ្ឌទាយកត្ថេរ មានអាយុ បានសម្តែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

ចប់ យគមណ្ឌទាយកត្ថេរបទាន ។

## ឧទកទាយកត្ថេរបទាន ទី ៧

(៨៧) ខ្ញុំមានចិត្តជ្រះថ្លា មានចិត្តត្រេកអរ បានថ្វាយទឹកមួយក្អម ចំពោះភិក្ខុសង្ឃដ៏ប្រសើរ នៃព្រះបទុមុត្តរសម្ពុទ្ធ ។ (ដោយកុសលកម្មនេះ) បើខ្ញុំចង់បានទឹកសម្រាប់ផឹក លើកំពូលភ្នំ លើចុងឈើ ក្នុងអាកាស ឬក្នុងផែនដី ក្នុងកាលណា ទឹកក៏កើតឡើងយ៉ាងឆាប់ដល់ខ្ញុំ ក្នុងកាលនោះ ។

សតសហស្សេ ឥតោ កប្បេ យំ ទានមទទឹ តទា
ទុគ្គតឹ នាភិជានាមិ ឧទកទានស្សិទំ ផលំ ។
កិលេសា ឈាបិតា មយ្ហំ ភវា សព្វេ សមូហតា
នាគោវ ពន្ធនំ ឆេត្វា វិហរាមិ អនាសវោ ។
ស្វាគតំ វត មេ អាសិ មម ពុទ្ធស្ស សន្តិកេ
តិស្សោ វិជ្ជា អនុប្បត្តា កតំ ពុទ្ធស្ស សាសនំ ។
បដិសម្ភិទា ចតស្សោ វិមោក្ខាបិ ច អដ្ឋិមេ
ឆឡភិញ្ញា សច្ឆិកតា កតំ ពុទ្ធស្ស សាសនំ ។

ឥត្ថំ សុទំ អាយស្មា ឧទកទាយកោ ថេរោ ឥមា គាថាយោ អភាសិត្ថាតិ ។

ឧទកទាយកត្ថេរស្ស អបទានំ សមត្តំ ។



គិតកប្បមួយសែន អំពីកប្បនេះ ព្រោះហេតុដែលខ្ញុំបានឲ្យទាន ក្នុងកាលនោះ ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃទឹកទាន ។ កិលេសទាំងឡាយ ខ្ញុំដុតបំផ្លាញហើយ ភពទាំងពួង ខ្ញុំដកចោលអស់ហើយ ខ្ញុំជាអ្នកមិនមានអាសវៈ ព្រោះបានកាត់ចំណង ដូចជាដំរីកាត់ផ្តាច់នូវចំណង ។ ឱ ខ្ញុំមកល្អហើយ ក្នុងសំណាក់នៃព្រះពុទ្ធរបស់ខ្ញុំ វិជ្ជា ៣ ខ្ញុំបានដល់ហើយ សាសនារបស់ព្រះពុទ្ធ ខ្ញុំបានធ្វើហើយ ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ។

បានឮថា ព្រះឧទកទាយកត្ថេរ មានអាយុ បានសំដែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

ចប់ ឧទកទាយកត្ថេរាបទាន ។

# អដ្ឋមំ បុឡិនបុប្ផិយត្ថេរាបទានំ

(៨៨) ហិមវន្តស្សាវិទូរេ យមកោ នាម(១) បព្វតោ
អស្សមោ សុកតោ មយ្ហំ បណ្ណសាលា សុមាបិតា ។
នារទោ នាម នាមេន ជដិលោ ឧគ្គតាបនោ
ចតុទ្ទសសហស្សានិ សិស្សា បរិចរន្តិ មំ ។
បដិសល្លីនកោ សន្តោ ឯវំ ចិន្តេសហំ តទា
មហាជនា មំ បូជេន្តិ នាហំ បូជេមិ កិញ្ចនំ ។
ន មេ ឱវាទកោ អត្ថិ វត្តា កោចិ ន វិជ្ជតិ
អនាចរិយុបជ្ឈាយោ វនេ វសិំ តទាមហំ ។
ឧបាសមានោ យមហំ(២) គរុចិត្តំ ឧបដ្ឋហេ
សោ មេ អាចរិយោ នត្ថិ វនវាសោ និរត្ថកោ ។
អាយាគំ មេ គវេសិស្សំ គរុភាវនិយំ តថា
សាវស្សយោ(៣) វសិស្សាមិ ន កោចិ គរហិស្សតិ ។

---

១ ឱ. សមង្គោ នាម ។ ២ ម.ម. យមហំ ។ ៣ ឱ.ម. សាវស្សយោ ។

# បុឡិនបុប្ផិយត្ថេរាបទាន ទី ៨

(៨៨) ក្នុងទីជិតនៃព្រៃហិមពាន្ត មានភ្នំមួយ ឈ្មោះយមកៈ អាស្រមខ្ញុំបានធ្វើហើយ បណ្ណសាលា ក៏ខ្ញុំបានសាងល្អហើយក្បែរជើងភ្នំនោះ ។ ខ្ញុំជាជដិលឈ្មោះនារទៈ ជាអ្នកមានព្យាយាមខ្ពង់ខ្ពស់ សិស្ស ១៤.០០០ តែងបំរើខ្ញុំ សព្វវេលា ។ ខ្ញុំជាអ្នកចូលចិត្តសេចក្តីស្ងប់ស្ងាត់ មានចិត្តស្ងប់រម្ងាប់ ក្នុងកាលនោះ ខ្ញុំគិតយ៉ាងនេះថា មហាជនតែងបូជាអាត្មាអញ ។ មិនបានបូជាអ្នកណាមួយ ។ ជនអ្នកឲ្យទូន្មានដល់អាត្មាអញមិនមាន ជនអ្នកស្តីថាណាម្នាក់ ក៏មិនមាន អាត្មាអញមិនមានអាចារ្យនិងឧបជ្ឈាយ៍ អាត្មាអញសំរេចការនៅក្នុងព្រៃ ។ អាត្មាអញចូលទៅបំរើបុគ្គលណាដែលមានចិត្តធ្ងន់ បុគ្គលនោះ ជាអាចារ្យរបស់អាត្មាអញមិនមាន ការនៅក្នុងព្រៃ ឈ្មោះថាឥតប្រយោជន៍ ។ អាត្មាអញគប្បីស្វែងរកគ្រូដែលគួរបូជា និងគ្រូដែលគួរសរសើរ អាត្មាអញនឹងនៅជាមួយបុគ្គល គួរជាទីពឹងអាស្រ័យបាននោះ ទើបបុគ្គលណាមួយ នឹងមិនតិះដៀលអាត្មាអញឡើយ ។

ឧត្តានកូលា នទិកា សុបតិត្ថា មនោរមា
សុសុទ្ធបុលិនាកិណ្ណា អវិទូរេ មមស្សមំ ។
នទឹ អមរិកំ នាម ឧបកច្ឆា មហគ្គតា
សង្កឌ្ឍិត្វាន(១) បុលិនំ អកំ បុលិនចេតិយំ ។
យេ តេ អហេសុំ សម្ពុទ្ធា ភវន្តករណា មុនី
តេសំ ឯតាទិសោ ថូបោ តំ និមិត្តំ ករោមហំ ។
ករិត្វា បុលិនេ ថូបំ សោវណ្ណំ មាបយឹ អហំ
សោណ្ណកិង្កណិបច្ឆាទិ(២) សហស្សេ តីណិ បូជយឹ ។
សាយំ បាតំ នមស្សាមិ បីតិជាតោ(៣) កតញ្ជលិ
សម្មុខា វិយ សម្ពុទ្ធំ វន្ទិំ បុលិនចេតិយំ ។
យទា កិលេសា ជាយន្តិ វិតក្កា គេហនិស្សិតា
សរាមិ សុកតំ ថូបំ បច្ចវេក្ខាមិ តាវទេ ។

១ ឱ. ម. សំវឌ្ឍយិត្វា ។ ២ ឱ. សោវណ្ណកិង្ខិណិបច្ឆាទំ ។ ៣ ឱ. វិត្តិជាតោ ។ ម. វេទជាតោ ។



ស្ទឹងមានច្រាំងរាក់ មានកំពង់ល្អ ជាទីត្រេកអរនៃចិត្ត ដេរដាស ដោយផ្នែកខ្សាច់ស្អាត ជាន់ទៅជិតអាស្រមរបស់ខ្ញុំ ។ កាលនោះ ខ្ញុំបានដើរចូលទៅកាន់ស្ទឹងឈ្មោះអមរិកៈ ហើយប្រមូលយកផ្នែកខ្សាច់ មកធ្វើជាបុលិនចេតិយ (ចេតិយខ្សាច់) ។ ព្រះសម្ពុទ្ធទាំងឡាយអង្គណា ទ្រង់ធ្វើនូវទីបំផុតនៃភព ជាអ្នកប្រាជ្ញ ព្រះស្តូបនៃព្រះសម្ពុទ្ធទាំងឡាយនោះ ក៏ប្រាកដដូច្នោះ ខ្ញុំធ្វើនូវព្រះស្តូបនោះ ឲ្យជានិមិត្ត ។ លុះខ្ញុំធ្វើហើយ ខ្ញុំបានសាងនូវព្រះស្តូប ជាវិការៈនៃមាសលើផ្នែកខ្សាច់ ខ្ញុំបានបូជានូវផ្កាកណ្ដឹងមាស អស់ ៣ ពាន់ ។ ខ្ញុំមានបីតិកើតហើយ ធ្វើនូវអញ្ជលីនមស្ការ កាលល្ងាចព្រឹក ថ្វាយបង្គំចេតិយផ្នែកខ្សាច់ ហាក់ដូចជាថ្វាយបង្គំនូវព្រះសម្ពុទ្ធ ក្នុងទីចំពោះព្រះភក្ត្រ ។ កាលណា កិលេសទាំងឡាយកើតឡើង វិតក្កៈទាំងឡាយ ដែលអាស្រ័យនូវផ្ទះគឺកាមគុណ (កើតឡើង ក្នុងកាលនោះ) ខ្ញុំរលឹកដល់ព្រះស្តូប ដែលខ្ញុំធ្វើល្អហើយ ខ្ញុំពិចារណាឃើញច្បាស់ ក្នុងខណៈនោះឯង ។

ឧបនិស្សាយ វិហារំ  សន្តិកេ វិចាយេ តំ
កិលេសេ សំវេយ្យាសិ  ន យុត្តំ តវ មារិស ។
សហ អាវដ្ដេ ធុវេ  ការំ ហោតិ មេ គតា
ក្ខុរិតគ្គេ វិឆោទេសិ  ជាតោ ខុទ្ទិតោ(១) យថា ។
ឃរំ វិហារមាទំ មំ  មច្ចុកជាកិមន្ទុជ
តត្ថ កាលំ កតោ សន្តោ  ព្រហ្មលោកំ អគច្ឆហំ ។
យាវតាយុំ វសិត្វាន  តិទិវេ ឧបបជ្ជហំ
អសីតិក្ខត្តុំ ទេវិន្ទោ  ទេវរជ្ជមការយិំ ។
សតានំ តីណិក្ខត្តុញ្ច  ចក្កវត្តី អហោសហំ
បទេសរជ្ជំ វិបុលំ  គណនាតោ អសង្ខិយំ ។
តេសំ កឹកណិបុប្ផានំ(២) វិបាកំ អនុភោមហំ
ទ្វាវីសតិសហស្សានិ  បរិកេន្តិ មំ ភវេ ។

---

១ ឱ. ខុទ្ទិកោ ។ ម. ខុទ្ទកោ ។ ២ ម. សោណ្ណកិង្កណិបុប្ផានំ ។





ខ្ញុំបានចូលទៅកាន់ព្រះស្តូប នៃព្រះលោកនាយក ប្រសើរជាងសត្វ ដូចពួកឈ្មួញ ហើយខ្ញុំបានខ្ទួនថា នៃអ្នកនិរទុក្ខ បើអ្នកហ៊ានបំបាត់កិលេស ការដែលអ្នកបំបាត់កិលេសនេះ ជាអំពើមិនគួរដល់អ្នកទេ ។ កាលណា ខ្ញុំពឹងពាក់ព្រះស្តូប ឈ្មោះថាខ្ញុំមានសេចក្តីតោភ ក្នុងកាលនោះ ខ្ញុំបានបន្ទាបនូវកក្កុះអាក្រក់ ដូចដីដ៏ប្រសើរ ដែលត្រូវគេចាក់ដោយកន្ទេរ ។ មច្ចុកដៃតែងញាំញីខ្ញុំកាលនៅយ៉ាងនេះ លុះខ្ញុំធ្វើមរណកាលក្នុងទីនោះ បានទៅកើតឯព្រហ្មលោក ។ ខ្ញុំនៅក្នុងព្រហ្មលោក ដរាបដល់អស់អាយុ ហើយថយមកកើតក្នុងឋានត្រៃត្រិង្ស បានជាធំជាងទេវតា សោយរាជ្យក្នុងទេវលោក អស់ ៨០ ដង ។ ខ្ញុំបានជាស្តេចចក្រពត្តិ អស់ ៣០០ ដង បានសោយប្រទេសរាជ្យ ដ៏ធំទូលាយ រាប់ជាតិមិនអស់ ។ ខ្ញុំបានសោយនូវផល នៃផ្កាកណ្តឹងមាសទាំងនោះ ជន ២ ម៉ឺន ២ ពាន់ តែងចោមរោមខ្ញុំ ក្នុងភព ។

ថូបស្ស បរិចិណ្ណត្តា   រជោជល្លំ ន លិម្បតិ
កាយេ សេទា ន មុច្ចន្តិ   សប្បភាសោ ភវាមហំ ។
អហោ មេ សុកតោ ថូបោ   សុទិដ្ឋាមតិកា នទី
ថូបំ កត្វាន បុឡិនំ(១)   បត្តោម្ហិ អចលំ បទំ ។
កុសលំ កត្តុកាមេន   ជន្តុនា សារគាហិណា(២)
នត្ថិ ខេត្តំ អខេត្តំ វា   បដិបត្តិវ សារកា(៣) ។
យថាបិ ពលវា បោសោ   អណ្ណវំ តរិតុស្សហេ(៤)
បរិត្តំ កដ្ឋមាទាយ   បក្ខន្ទេយ្យ មហាសរំ ។
ឥមាហំ កដ្ឋំ និស្សាយ   តរិស្សាមិ មហោទធឹ
ឧស្សាហេន វីរិយេន   តរេយ្យ ឧទធឹ នរោ ។
តថេវ មេ កតំ កម្មំ   បរិត្តំ ថោកកញ្ច យំ
តំ កម្មំ(៥) ឧបនិស្សាយ   សំសារំ សមតិក្កមឹ ។

---

១ ឱ. បុលិនេ ។ ២ ឱ. ធារធារិណា ។ ៣ ម. សារតា ។ ៤ ឱ. ម. តរិតុស្សហោ ។
៥ ឱ. កតំ កម្មំ ។





ព្រោះខ្ញុំបានសាងព្រះស្តូប លំអងធូលីមិនប្រឡាក់កាយនៃខ្ញុំ ញើសទាំងឡាយក្នុងខ្លួនមិនហូរចេញ ខ្ញុំមានពន្លឺ ។ ឱ ! ព្រះស្តូបខ្ញុំបានធ្វើល្អហើយ ស្ទឹងឈ្មោះអមតៈ ខ្ញុំបានឃើញល្អហើយ ព្រោះខ្ញុំបានធ្វើព្រះស្តូបខ្ពស់ ទើបបានសម្រេចនូវព្រះនិព្វាន ជាធម្មជាតមិនកម្រើក ។ សត្វមានសេចក្តីប្រាថ្នាធ្វើកុសល ជាអ្នកប្រកាន់នូវខ្លឹម មិនទាំបាច់មានទីជាស្រែ ឬទីមិនជាស្រែឡើយ ស្រេចហើយត្រឹមតែសេចក្តីប្រតិបត្តិជាគុណមានខ្លឹម ។ បុរសមានកម្លាំង អាចឆ្លងសមុទ្រ ស្ទុះទៅក្នុងមហាសមុទ្របាន ព្រោះកាន់កំ-ណាត់ឈើតូច ។ ខ្ញុំឆ្លងសមុទ្រធំ ព្រោះអាស្រ័យកំណាត់ឈើនេះ នរជនគប្បីឆ្លងសមុទ្រ ដោយសេចក្តីព្យាយាមប្រឹងប្រែង មានឧបមាយ៉ាងណា ។ អំពើណា ទោះតិចតួចក្តី ថោកតាបក្តី ដែលខ្ញុំធ្វើហើយ ខ្ញុំបានឆ្លងសង្សារ ព្រោះអាស្រ័យអំពើនោះ ក៏មានឧបមេយ្យយ៉ាងនោះឯង ។

បច្ឆិមេ ភវសម្បត្តេ   សុក្កមូលេន ចោទិតោ
សាវត្ថិយំ បុរេ ជាតោ   មហាសាលេ សុអឌ្ឍកេ ។
សទ្ធា មាតាបិតា មយ្ហំ   ពុទ្ធស្ស សរណំ គតា
ឧភោ ទិដ្ឋសុតា(១) ឯតេ   អនុវត្តិំ សាសនំ ។
ពោធិបញ្ជរិកំ កត្វា   សោណ្ណថូបំ អការយុំ
សាយំ បាតំ នមស្សន្តិ   សក្យបុត្តស្ស សម្មុខា ។
ឧបោសថម្ហិ ទិវសេ   សោណ្ណថូបំ វិទំសយុំ
ពុទ្ធស្ស វណ្ណំ កិត្តេន្តា   តិយាមំ វីតិនាមយុំ ។
សហ ទិស្វានហំ(២) ថូបំ   សរឹ បុឡិនចេតិយំ
ឯកាសនេ និសីទិត្វា   អរហត្តំ អបាបុណឹ ។

ពាវីសតិមំ ភាណវារំ ។

គវេសមានោ តំ ធីរំ   ធម្មសេនាបតិទ្ទសំ
អគារា និក្ខមិត្វាន   បព្វជឹ តស្ស សន្តិកេ ។
ជាតិយា សត្តវស្សោហំ   អរហត្តំ អបាបុណឹ
ឧបសម្បាទយិ ពុទ្ធោ   គុណមញ្ញាយ ចក្ខុមា ។

---

១ ឱ. ម. ទិដ្ឋបទា ។ ២ ម. សោះទត្វានហំ ។



លុះដល់បច្ឆិមភព ខ្ញុំត្រូវកុសលមូលដាស់តឿន បានកើតក្នុងត្រកូលមហាសាល ដែលស្តុកស្តម្ភ ក្នុងក្រុងសាវត្ថី ។ មាតាបិតារបស់ខ្ញុំ មានសទ្ធាបានយកព្រះពុទ្ធជាទីពឹង ជនទាំងពីរនាក់នោះ ក៏អនុវត្តតាមពុទ្ធសាសនា ។ ពួកជនបានកាន់យកក្រមរពោធិ ទៅធ្វើព្រះស្តូបជាវិការៈនៃមាស តែងនមស្ការចំពោះព្រះភក្ត្រព្រះសក្យបុត្ត រាល់ល្ងាចព្រឹក ។ ក្នុងថ្ងៃឧបោសថ ពួកជននាំយកព្រះស្តូបមាស ហើយពោលសរសើរគុណព្រះពុទ្ធ ញុំាងកាលមានយាម ៣ ឲ្យកន្លងទៅ ។ លុះខ្ញុំបានឃើញព្រះស្តូបហើយ ក៏រលឹកឃើញនូវចេតិយផ្នូកខ្សាច់ អង្គុយលើអាសនៈមួយ ក៏បានដល់អរហត្ត ។

ចប់ ភាណវារៈ ទី ២២ ។

កាលខ្ញុំស្វែងរកអ្នកប្រាជ្ញ បានជួបព្រះធម្មសេនាបតីនោះ ក៏ចេញចាកផ្ទះ ទៅបួសក្នុងសំណាក់លោក ។ ខ្ញុំក៏បានសម្រេចអរហត្ត ក្នុងអាយុ ៧ ឆ្នាំ រាប់អំពីកំណើតមក ព្រះពុទ្ធមានចក្ខុទ្រង់ជ្រាបនូវគុណ បានឲ្យឧបសម្បទាដល់ខ្ញុំ ។

ទារកោវ សន្តោ កតកិច្ចោ មហាយសោ
កតំ មេ ករណីយជ្ជ សក្យបុត្តស្ស សាសនេ ។
សព្វវេរភយាតីតោ សព្វសង្គាតិគោ ឥសិ
សាវកោ តេ មហាវីរ សោណ្ណថូបស្សិទំ ផលំ ។
កិលេសា ឈាបិតា មយ្ហំ ភវា សព្វេ សមូហតា
នាគោវ ពន្ធនំ ឆេត្វា វិហរាមិ អនាសវោ ។
ស្វាគតំ វត មេ អាសិ មម ពុទ្ធស្ស សន្តិកេ
តិស្សោ វិជ្ជា អនុប្បត្តា កតំ ពុទ្ធស្ស សាសនំ ។
បដិសម្ភិទា ចតស្សោ វិមោក្ខាបិ ច អដ្ឋិមេ
ឆឡភិញ្ញា សច្ឆិកតា កតំ ពុទ្ធស្ស សាសនន្តិ ។

ឥត្ថំ សុទំ អាយស្មា បុឡិន្ទបិយោ ថេរោ ឥមា គាថាយោ អភាសិត្ថាតិ ។

បុឡិន្ទបិយត្ថេរស្ស អបទានំ សមត្តំ ។



កាលខ្ញុំនៅជាទារក បានសម្រេចកិច្ចហើយ សោឡសកិច្ច ក្នុងសាសនា នៃព្រះសក្យបុត្រ ខ្ញុំធ្វើរួចហើយក្នុងថ្ងៃនេះ ។ បពិត្រព្រះមហាវីរៈ ខ្ញុំកន្លងនូវពៀរនិងភ័យទាំងពួងហើយ កន្លងកិលេសជាគ្រឿងជំពាក់ទាំងពួងហើយ ជាអ្នកស្វែងរកគុណ ជាសាវ័ករបស់ព្រះអង្គ នេះជាផលនៃព្រះស្តូបមាស ។ កិលេសទាំងឡាយ ខ្ញុំដុតបំផ្លាញហើយ ភពទាំងអស់ ខ្ញុំដកចោលហើយ ខ្ញុំជាអ្នកមិនមានអាសវៈ ព្រោះបានកាត់ចំណង ដូចដំរីកាត់ផ្តាច់នូវខ្ទឹង ។ ឱ! ខ្ញុំមកល្អហើយ ក្នុងសំណាក់នៃព្រះពុទ្ធ របស់ខ្ញុំ វិជ្ជា ៣ ខ្ញុំបានដល់ហើយ សាសនារបស់ព្រះពុទ្ធ ខ្ញុំបានធ្វើហើយ ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនា របស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ។

បានឮថា ព្រះបុឡិន្ទបិយត្ថេរ មានអាយុ បានសម្តែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

ចប់ បុឡិន្ទបិយត្ថេរាបទាន ។

(៨៩) ហិមវន្តស្សាវិទូរេ ឃាតកោ នាម(១) បព្វតោ
សយម្ភូ នារទោ នាម រុក្ខមូលេ វសី តទា ។
នឡាគារំ ករិត្វាន តិណេន ឆាទយឹ អហំ
ចង្កមំ សោធយិត្វាន សយម្ភុស្ស អទាសហំ ។
តេន កម្មេន សុកតេន ចេតនាបណិធីហិ ច
ជហិត្វា មានុសំ ទេហំ តាវតឹសំ អគច្ឆហំ ។
តត្ថ មេ សុកតំ ព្យម្ហំ នឡកុដិកាយ និម្មិតំ(២)
សដ្ឋិយោជនមុព្វិទ្ធំ តឹសយោជនវិត្ថតំ ។
ចតុទ្ទសេសុ កប្បេសុ ទេវលោកេ រមឹ អហំ
ឯកសត្តតិក្ខត្តុញ្ច ទេវរជ្ជំ អការយឹ ។
ចតុត្តឹសតិក្ខត្តុញ្ច ចក្កវត្តី អហោសហំ
បទេសរជ្ជំ វិបុលំ គណនាតោ អសង្ខិយំ ។

១ ឱ. ភរិតោ ។ ម. ឃាតិតោ ។ ២ ម. នឡកុដិកនិម្មិតំ ។



(៨៩) ក្នុងទីមិនឆ្ងាយអំពីព្រៃហិមពាន្ត មានភ្នំមួយ ឈ្មោះឃាតកៈ កាលនោះ ព្រះសយម្ភូសម្ពុទ្ធ ព្រះនាម នារទៈ គង់នៅទៀបគល់ឈើ ជិតភ្នំនោះ ។ ខ្ញុំបានធ្វើផ្ទះ បបុស បិទបាំងដោយស្មៅ ជម្រះចង្ក្រមថ្វាយ ដល់ ព្រះសយម្ភូសម្ពុទ្ធ ។ ដោយអំពើដែលខ្ញុំធ្វើល្អហើយនោះផង ដោយការតាំងចេតនានោះផង ខ្ញុំលះបង់កាយ ជារបស់មនុស្សហើយ បានទៅកើតក្នុងឋានតាវត្តិង្ស ។ ប្រាសាទរបស់ខ្ញុំ ដែលកុសលកម្មធ្វើល្អហើយ ក្នុងឋានតាវត្តិង្សនោះ គឺកុសលកម្មនិម្មិតធ្វើជាខ្ទមបបុស មានកំពស់ ៦០ យោជន៍ ទទឹង ៣០ យោជន៍ ។ ខ្ញុំរីករាយក្នុងទេវលោក អស់ ១៤ កប្ប បានសោយរាជ្យ ក្នុងទេវលោក អស់ ៧១ ដង ។ ខ្ញុំបានជាស្តេចចក្រពត្តិ អស់ ៣៤ ដង បានសោយរាជ្យប្រទេសរាជ្យ ដ៏ធំទូលាយ រាប់ជាតិមិនអស់ ។

ធម្មបាសាទមារុយ្ហ សព្វញ្ញាការវ្ហូបតំ(១)
យជិច្ចកាហំ វិហារេ សក្យបុត្តស្ស សាសនេ ។
ឯកត្តិំសេ ឥតោ កប្បេ យំ កម្មមករឹ តទា
ទុគ្គតឹ នាភិជានាមិ ធម្មកុដិកាយិទំ ផលំ ។
កិលេសា ឈាបិតា មយ្ហំ ភវា សព្វេ សមូហតា
នាគោវ ពន្ធនំ ឆេត្វា វិហរាមិ អនាសវោ ។
ស្វាគតំ វត មេ អាសិ មម ពុទ្ធស្ស សន្តិកេ
តិស្សោ វិជ្ជា អនុប្បត្តា កតំ ពុទ្ធស្ស សាសនំ ។
បដិសម្ភិទា ចតស្សោ វិមោក្ខាបិ ច អដ្ឋិមេ
ឆឡភិញ្ញា សច្ឆិកតា កតំ ពុទ្ធស្ស សាសនំ ។

ឥត្ថំ សុទំ អាយស្មា ធម្មកុដិកទាយកោ ថេរោ ឥមា គាថាយោ អភាសិត្ថាតិ ។

ធម្មកុដិកទាយកត្ថេរស្ស អបទានំ សមត្តំ ។

---

១ ឱ. សញ្ញការវ្ហយំ ។ ម. សញ្ញកាវ្ហយំ ។



ខ្ញុំបានឡើងកាន់ធម្មប្រាសាទ ឧបមាដូចផ្ទះសព្វគ្រប់ប្រសើរ ហើយសម្រេចសម្រាន្តតាមសមគួរ ក្នុងសាសនានៃព្រះសក្យ-បុត្ត ។ ក្នុងកប្បទី ៣១ អំពីកប្បនេះ ព្រោះហេតុដែលខ្ញុំបានធ្វើកុសលកម្ម ក្នុងកាលនោះ ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃខ្ទមបបុស ។ កិលេសទាំងឡាយ ខ្ញុំដុតបំផ្លាញហើយ ភពទាំងអស់ ខ្ញុំដកចោលហើយ ខ្ញុំជាអ្នកមិនមានអាសវៈ ព្រោះបានកាត់ចំណង ដូចដំរីកាត់ផ្តាច់ទន្លីង ។ ឱ! ខ្ញុំមកល្អហើយ ក្នុងសំណាក់នៃព្រះពុទ្ធរបស់ខ្ញុំ វិជ្ជា ៣ ខ្ញុំបានដល់ហើយ សាសនារបស់ព្រះពុទ្ធ ខ្ញុំបានធ្វើហើយ ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនា របស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ។

បានឮថា ព្រះធម្មកុដិកទាយកត្ថេរ មានអាយុ បានសម្តែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

ចប់ ធម្មកុដិកទាយកត្ថេរាបទាន ។

## ទសមំ បិយាលផលទាយកត្ថេរាបទានំ

(៩០) មិគលុទ្ទោ បុរេ អាសឹ វិបិនេ(១) វិចរំ តទា

អទ្ទសិំ វិរជំ ពុទ្ធំ សព្វធម្មាន បារគុំ ។

បិយាលផលមាទាយ ពុទ្ធសេដ្ឋស្សទាសហំ

បុញ្ញក្ខេត្តស្ស វីរស្ស បសន្នោ សេហិ បាណិភិ ។

ឯកត្តឹសេ ឥតោ កប្បេ យំ ផលំ អទទឹ តទា

ទុគ្គតឹ នាភិជានាមិ ផលទានស្សិទំ ផលំ ។

កិលេសា ឈាបិតា មយ្ហំ ភវា សព្វេ សមូហតា

នាគោវ ពន្ធនំ ឆេត្វា វិហរាមិ អនាសវោ ។

ស្វាគតំ វត មេ អាសិ មម ពុទ្ធស្ស សន្តិកេ

តិស្សោ វិជ្ជា អនុប្បត្តា កតំ ពុទ្ធស្ស សាសនំ ។

បដិសម្ភិទា ចតស្សោ វិមោក្ខាបិ ច អដ្ឋិមេ

ឆឡភិញ្ញា សច្ឆិកតា កតំ ពុទ្ធស្ស សាសនំ ។

---

១ ឱ. វិចិនេ ។ ម. វិបិនេ ។

## បិយាលផលទាយកត្ថេរាបទាន ទី ១១

(៩០) ក្នុងកាលមុន ខ្ញុំកើតជាព្រានព្រៃ កាលនោះ ខ្ញុំបានត្រាច់ទៅក្នុងព្រៃធំ បានឃើញព្រះសម្ពុទ្ធ ព្រះអង្គមិនមានធូលីគឺកិលេស ទ្រង់ដល់នូវត្រើយនៃធម៌ទាំងពួង ។ ខ្ញុំមានចិត្តជ្រះថ្លា បានយកផ្លែទ្រយឹង មកថ្វាយព្រះពុទ្ធដ៏ប្រសើរ ជាបុញ្ញក្ខេត្ត ព្រះអង្គមានព្យាយាម ដោយដៃរបស់ខ្ញុំ ។ ក្នុងកប្បទី ៣១ អំពីកប្បនេះ ព្រោះហេតុដែលខ្ញុំបានថ្វាយផ្លែទ្រយឹង ក្នុងកាលនោះ ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃផលទាន ។ កិលេសទាំងឡាយ ខ្ញុំដុតបំផ្លាញហើយ ភពទាំងពួង ខ្ញុំដកចោលអស់ហើយ ខ្ញុំជាអ្នកមិនមានអាសវៈ ព្រោះបានកាត់ចំណង ដូចជាដំរីកាត់ផ្តាច់នូវចំណង ។ ឱ! ខ្ញុំមកល្អហើយ ក្នុងសំណាក់នៃព្រះពុទ្ធរបស់ខ្ញុំ វិជ្ជា ៣ ខ្ញុំបានដល់ហើយ សាសនា របស់ព្រះពុទ្ធ ខ្ញុំបានធ្វើហើយ ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនា របស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ។

ឥត្ថំ សុទំ អាយស្មា បិយាលផលទាយកោ ថេរោ
ឥមា គាថាយោ អភាសិត្ថាតិ ។

បិយាលផលទាយកត្ថេរស្ស អបទានំ សមត្តំ ។

ឧទ្ទានំ

កិង្កណិ(១) បំសុកូលញ្ច កោរណ្ឌកឹសុកា(២)
ឧបឌ្ឍទុស្សី ឃដទោ ឧទកំ ថូបការកោ ។
នឡាគារី ច ចង្កមោ បិយាលផលទាយកោ
សតមេកញ្ច គាថានំ ចតស្សោ ច តទុត្តរិ ។

កិង្កណិបុប្ផវគ្គោ បញ្ញាសមោ ។

---

១ ម. កិង្កិណិ ។ ២ ឱ. កោរណ្ឌបុប្ផកឹសុកំ ។ ម. កោរណ្ឌផលកឹសុកំ ។



បានឮថា ព្រះបិយាលផលទាយកត្ថេរដ៏មានអាយុ បានសំដែង
នូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

ចប់ បិយាលផលទាយកត្ថេរាបទាន ។

ឧទ្ទាន

កិង្កណិបុប្ផិយត្ថេរាបទាន ១ បំសុកូលបូជកត្ថេរាបទាន ១ កោរណ្ឌបុប្ផិយត្ថេរាបទាន ១ កឹសុកបុប្ផិយត្ថេរាបទាន ១ ឧបឌ្ឍទុស្សទាយកត្ថេរាបទាន ១ ឃដមណ្ឌទាយកត្ថេរាបទាន ១ ឧទកទាយកត្ថេរាបទាន ១ ថូបនិច្ចបុប្ផិយត្ថេរាបទាន ១ នឡាគារិកទាយកត្ថេរាបទាន ផងតប់ ៤ បិយាលផលទាយកត្ថេរាបទាន ១ ឯគាថាមានចំនួន ១០១ និងលើសពីនោះ ៤ គាថាទៀត ។

ចប់ កិង្កណិបុប្ផវគ្គ ទី ៥០ ។

## ៣៥ វគ្គុទ្ទានំ

មេត្តេយ្យវគ្គោ ភទ្ទាលិ សកិំសម្មជ្ជកោបិច

ឯកវិហារី វិភេទកោ(១) ជគតិ សាលបុប្ផិយោ ។

នឡមាលិ(២) បំសុកូលិ កិំកណិបុប្ផិកោ(៣) តថា

អសីតិ ទ្វេ ច គាថាយោ ចតុទ្ទស(៤) សតានិ ច ។

មេត្តេយ្យវគ្គទសកំ បញ្ចមំ សមត្តំ ។

---

១ ឱ. ឯកោ វិហារកិវគ្គោ ។ ម. ឯកវិហារី វិភេទកិ ។ ២ ឱ. នឡមាលិ ។ ម. នឡការី ។

៣ ឱ. ម. កិង្កណិបុប្ផិយោ ។ ៤ ឱ. ម. ចតុទ្ទស ។

## មួយទៀត ឧទ្ទាននៃវគ្គ

មេត្តេយ្យវគ្គ ១ ភទ្ទាលិវគ្គ ១ សកិំសម្មជ្ជកវគ្គ ១ ឯកវិហារិ-វគ្គ ១ វិភេទកវគ្គ ១ ជគតិវគ្គ ១ សាលបុប្ផិយវគ្គ ១ ។ នឡមាលិវគ្គ ១ បំសុកូលវគ្គ ១ កិំកណិបុប្ផវគ្គ ១ ឯគាថា មានចំនួន ១.៤៨៤ គាថា ។

ចប់ មេត្តេយ្យវគ្គទសកៈ ប្រមាណជាគម្រប់ ទី ៥ ។

## ឯកបញ្ញាសោ កណិការវគ្គោ

## បឋមំ តីណិកណិការបុប្ផិយត្ថេរាបទានំ

(៥១) សុមេធោ នាម សម្ពុទ្ធោ ទ្វត្តឹសវរលក្ខណោ
វិវេកកាមោ សម្ពុទ្ធោ ហិមវន្តំ ឧបាគមិ ។
អជ្ឈោគាហេត្វា ហិមវន្តំ អគ្គោ ការុណិកោ មុនិ
បល្លង្កំ អាភុជិត្វាន និសីទិ បុរិសុត្តមោ ។
វិជ្ជាធរោ តទា អាសឹ អន្តលិក្ខចរោ អហំ
តិសូលំ សុកតំ គយ្ហ គច្ឆាមិ អម្ពរេ តទា ។
បព្វតគ្គេ យថា អគ្គិ បុណ្ណមាយេវ(១) ចន្ទិមា
វនេ ឱភាសតេ ពុទ្ធោ សាលរាជាវ ផុល្លិតោ ។
វនគ្គា(២) និក្ខមិត្វាន ពុទ្ធរំសាភិធាវរេ
នឡគ្គិវណ្ណសង្កាសា ទិស្វា ចិត្តំ បសាទយឹ ។

១ ម. អគ្គិ បុណ្ណមាសេវ ។ ២ ម.ឱ. វនគ្គា ។

## កណិការវគ្គ ទី ៥១

## តីណិកណិការបុប្ផិយត្ថេរាបទាន ទី ១

(៥១) ព្រះសម្ពុទ្ធ ព្រះនាមសុមេធៈ មានព្រះលក្ខណៈ ៣២ ដ៏ប្រសើរ មានសេចក្តីប្រាថ្នានូវការស្ងប់ស្ងាត់ ទ្រង់ត្រាស់ដឹងដោយប្រពៃ បានស្តេចចូលទៅកាន់ព្រៃហិមពាន្ត ។ ព្រះមហាមុនី ទ្រង់ជាចំបង ជាបុរសខ្ពង់ខ្ពស់ ប្រកបដោយសេចក្តីករុណា ស្តេចចុះកាន់ព្រៃហិមពាន្ត ហើយទ្រង់គង់ផ្គត់ព្រះភ្លែន ។ កាលនោះ ខ្ញុំកើតជាពិទ្យាធរ ជាអ្នកត្រាច់ទៅក្នុងអាកាស កាន់ត្បូងដែលធ្វើល្អហើយ បានហោះទៅឰដ៏អាកាស ក្នុងកាលនោះ ។ ព្រះសម្ពុទ្ធព្រះអង្គរុងរឿងក្នុងព្រៃ ដូចភ្លើងលើកំពូលភ្នំ ឬដូចព្រះចន្ទពេញបូណ៌មី ពុំនោះសោត ដូចស្តេចឈើដែលមានផ្ការីកស្គុះស្គាយ ។ ខ្ញុំចេញអំពីព្រៃ បានឃើញរស្មីព្រះពុទ្ធដែលផ្សាយចេញ ដូចពណ៌ភ្លើងដែលឆេះបបុស ហើយក៏ញុំាងចិត្តឲ្យជ្រះថ្លា ។

វិចិនំ អទ្ទសំ បុប្ផំ(១)　កណិការំ ទេវគន្ធិកំ
តីណិ បុប្ផានិ អាហាយ　ពុទ្ធសេដ្ឋំ អបូជយិំ ។
ពុទ្ធស្ស អានុភាវេន　តីណិ បុប្ផានិ មេ តទា
ឧទ្ធំវណ្ដា(២) អធោបត្តា　ឆាយំ កុព្វន្តិ សត្ថុនោ ។
តេន កម្មេន សុកតេន　ចេតនាបណិធីហិ ច
ជហិត្វា មានុសំ ទេហំ　តាវតិំសំ អគច្ឆហំ ។
តត្ថ មេ សុកតំ ព្យម្ហំ　កណិការីតិ ញាយតិ
សដ្ឋិយោជនមុព្វិទ្ធំ　តិំសយោជនវិត្ថតំ ។
សហស្សកណ្ឌា សតភេណ្ឌុ　ធជាលុ ហរិតាមយោ
សតសហស្សនិយ្យូហា　ព្យម្ហេ បាតុរហំសុ មេ ។
សោណ្ណមយា មណិមយា　លោហិតង្គមយាបិ ច
ផលិកាបិ ច បល្លង្កា　យេនិច្ឆកា យទិច្ឆកំ(៣) ។

១ ឱ. ពុទ្ធំ ។ ២ ម. ឧទ្ធំវណ្ណា ។ ៣ ម. យទិច្ឆកា យទិច្ឆកា ។



ខ្ញុំកំពុងតែជ្រើសរើសផ្កា ក៏បានឃើញផ្កាកណិការ មានក្លិនក្រអូបដូចក្លិនទិព្វ ហើយបាននាំយកផ្កា ៣ ទងទៅបូជាព្រះសម្ពុទ្ធដ៏ប្រសើរ ។ ដោយអានុភាពនៃព្រះពុទ្ធ ផ្កាទាំង ៣ ទងរបស់ខ្ញុំ ក្នុងកាលនោះ មានទងឡើងលើ មានក្របកចុះក្រោម ធ្វើជាម្លប់បាំងថ្វាយព្រះសាស្ដា ។ ដោយអំពើដែលធ្វើល្អនោះផង ដោយការតំកល់ចេតនានោះផង ខ្ញុំលះបង់កងកាយជារបស់មនុស្សហើយ បានទៅកើត ក្នុងឋានតាវត្តិង្ស ។ វិមានដែលកុសលសាងសម្រាប់ខ្ញុំ ក្នុងទីនោះ មានកំពស់ ៦០ យោជន៍ ទទឹង ៣០ យោជន៍ ពួកទេវតាតែងស្គាល់ថា កណិការវិមាន ។ ប្រាសាទមានកំពស់មួយពាន់សន្ទុះព្រួញ មានជាន់ ៧ បរិបូណ៌ដោយទង់ ជាវិការៈនៃកែវមណីមានពណ៌ខៀវ ផ្ទះមានកំពូលមួយសែន មានប្រាកដក្នុងវិមានរបស់ខ្ញុំ ។ បល្ល័ង្កជាវិការៈនៃមាសក៏មាន ជាវិការៈនៃកែវមណីក៏មាន ជាវិការៈនៃកែវទទឹមក៏មាន ជាវិការៈនៃកែវផលិកក៏មាន គួរតាមប្រាថ្នា គួរតាមបំណង ។

មហារហញ្ច សយនំ　　តុលិកំ វិកតិសុត្តំ(១)
ឧទ្ធលោមិកឯកន្តិំ　　ពិម្ពោហនសមាយុតំ(២) ។
ភវា និក្ខមិត្វាន　　ចរន្តោ ទេវចារិកំ
យទា ឥច្ឆាមិ គមនំ　　ទេវសង្ឃបុរក្ខតោ ។
បុប្ផស្ស ហេដ្ឋា តិដ្ឋាមិ　　ឧបរិ ឆទនំ មម
សមន្តា យោជនសតំ　　ករណិការេហិ ឆាទិតំ ។
សដ្ឋី តុរិយសហស្សានិ　　សាយំ បាតំ ឧបដ្ឋហុំ
បរិវារេន្តិ មំ និច្ចំ　　រត្តិន្ទិវមតន្ទិតា ។
តត្ថ នច្ចេហិ គីតេហិ　　តាឡេហិ វាទិតេហិ ច
រមាមិ ខិឌ្ឌារតិយា(៣)　　មោទាមិ កាមកាមិហំ ។
តត្ថ ភុត្វា បិវិត្វា ច　　មោទាមិ តិទសេ តទា
នារីគណេហិ សហិតោ　　មោទាមិ ព្យម្ហមុត្តមេ ។

១ ឱ. តូលិកា វិកតីយុត្តំ ។ ម. តូលិកា វិកតំ យុតំ ។ ២ ឱ.ម. ពិម្ពោហនសមាយុតំ ។ ៣ ម. ខិឌ្ឌារតិយា ។



មួយទៀត ទីដេកបានដ៏ប្រសើរ ដែលញាត់ដោយនុន ធ្វើដោយកោមសត្វ វិចិត្រដោយកោមសត្វ មានកោមសត្វសំពោះទិនខ្ចាត់ជាដើម ធ្វើដោយកោមសត្វមានកោមព្រាងឡើងតែម្ខាង ជាកម្រាលសមគួរដល់ខ្ញុំ ។ កាលណា ខ្ញុំចេញអំពីលំនៅ ហើយត្រេកអរទៅកាន់ទេវចារិកប្រាថ្នានឹងទៅ តែងមានពួកទេវតាហែហមកោម ។ ខ្ញុំឋិតនៅខាងក្រោមផ្កា ផ្កាប្រក់ខាងលើខ្ញុំ ទីមួយរយយោជន៍ជុំវិញ សុទ្ធសឹងបិទបាំងដោយផ្កាកណិការ ។ តូរ្យតន្ត្រី ៦ ម៉ឺន មកបម្រើខ្ញុំរាល់ល្ងាចព្រឹក ជាអ្នកមិនខ្ជិលច្រអូសទាំងយប់ទាំងថ្ងៃ តែងចោមរោមខ្ញុំជានិច្ច ។ ខ្ញុំត្រេកអរដោយរបាំ ចំរៀង គ្រឿងដេញ ដំ និងគ្រឿងប្រគំ ក្នុងវិមាននោះ ខ្ញុំមានសេចក្តីប្រាថ្នាក្នុងកាម តែងរីករាយក្នុងតម្រេកនៃល្បែង ។ ខ្ញុំបរិភោគក្តី ផឹកក្តី ក្នុងទីនោះ តែងរីករាយក្នុងឋានត្រៃត្រិង្ស ក្នុងកាលនោះ ខ្ញុំប្រកបដោយពួកនារី រីករាយក្នុងវិមានដ៏ឧត្តម ។

សតាហំ បញ្ញុក្ខត្តុញ្ញ   នេវជ្ជមកាសយឹ
សតាហំ ពីណាក្ខត្តុញ្ញ   ចក្កវត្តិ អហោសហំ ។
ឋានេសរជ្ជំ វិបុលំ   គណនាតោ អសង្ខិយំ
ភវាភវេ សំសរិត្វា   មហាភោគំ លភាមហំ ។
ភោគេ មេ ឩនតា នត្ថិ   ពុទ្ធបូជាយិទំ ផលំ
ទុវេ ភវេ សំសរាមិ   ទេវត្តេ អថ មានុសេ ។
អញ្ញំ គតឹ ន ជានាមិ   ពុទ្ធបូជាយិទំ ផលំ
ទុវេ កុលេ បជាយាមិ   ខត្តិយេ ចាបិ ព្រាហ្មណេ ។
នីចេ កុលេ ន ជាយាមិ   ពុទ្ធបូជាយិទំ ផលំ
ហត្ថិយានំ អស្សយានំ   សិវិកំ សន្ទមានិកំ ។
លភាមិ សព្វមេវេតំ   ពុទ្ធបូជាយិទំ ផលំ
ទាសីគណំ ទាសគណំ   នារិយោ សមលង្កតា ។
លភាមិ សព្វមេវេតំ   ពុទ្ធបូជាយិទំ ផលំ
កោសេយ្យកម្ពលិយានិ[១] ខោមកប្បាសិកានិ ច ។

១ ឱ·ម. កោសេយ្យកម្ពលីយានិ ។



ខ្ញុំសោយរាជ្យក្នុងទេវលោក អស់ ៥០០ ដង បានជាស្តេចចក្រពត្តិ អស់ ៣០០ ដង ។ សោយប្រទេសរាជ្យដ៏ធំទូលាយ រាប់ជាតិមិនអស់ ខ្ញុំកាលអន្ទោលទៅក្នុងភពតូចភពធំ តែងបាននូវភោគសម្បត្តិច្រើន ។ ខ្ញុំមិនមានសេចក្តីខ្វះខាតដោយភោគសម្បត្តិ នេះជាផលនៃពុទ្ធបូជា ខ្ញុំតែងអន្ទោលទៅក្នុងភពពីរ គឺទេវតានិងមនុស្ស ។ ខ្ញុំមិនដែលស្គាល់គតិដទៃទេ នេះជាផលនៃពុទ្ធបូជា ខ្ញុំតែងកើតក្នុងត្រកូល ២ គឺត្រកូលក្សត្រ និងត្រកូលព្រាហ្មណ៍ ។ ខ្ញុំមិនកើតក្នុងត្រកូលទាប នេះជាផលនៃពុទ្ធបូជា ខ្ញុំតែងបាននូវយានទាំងអស់នេះ គឺយានដំរី យានសេះ ព្រះសាលឿន ថេទ្រន៍គ្រឿង នេះជាផលនៃពុទ្ធបូជា ។ ខ្ញុំតែងបាននូវរបស់ទាំងអស់នេះ គឺខ្ញុំស្រី ខ្ញុំប្រុស នារីដែលមានគ្រឿងតាក់តែងសមរម្យ នេះជាផលនៃពុទ្ធបូជា ។ ខ្ញុំតែងបាននូវសំពត់ទាំងអស់នេះ គឺសំពត់កោសេយ្យពស្ត្រ សំពត់កម្ពល សំពត់ខោមពស្ត្រ និងសំពត់កប្បាសិកពស្ត្រ នេះជាផលនៃពុទ្ធបូជា ។

លភាមិ សព្វមេវេតំ ពុទ្ធបូជាយិទំ ផលំ
នវំ វត្ថំ នវំ ផលំ នវគ្គរសភោជនំ ។
លភាមិ សព្វមេវេតំ ពុទ្ធបូជាយិទំ ផលំ
ឥមេ ខាទ ឥមេ ភុញ្ជ ឥមម្ហិ សយនេ សយ ។
លភាមិ សព្វមេវេតំ ពុទ្ធបូជាយិទំ ផលំ
សព្វត្ថ បូជិតោ ហោមិ យសោ អព្ភុគ្គតោ(១) មម ។
មហាបក្ខោ(២) សទា ហោមិ អភេជ្ជបរិសោ សទា
ញាតីនំ ឧត្តមោ ហោមិ ពុទ្ធបូជាយិទំ ផលំ ។
សីតំ ឧណ្ហំ ន ជានាមិ បរិឡាហោ ន វិជ្ជតិ ។
អថោ ចេតសិកំ ទុក្ខំ ហទយេ មេ ន វិជ្ជតិ ។
សុវណ្ណវណ្ណោ ហុត្វាន សំសរាមិ ភវាភវេ
វេវណ្ណិយំ(៣) ន ជានាមិ ពុទ្ធបូជាយិទំ ផលំ ។
ទេវលោកា ចវិត្វាន សុក្កមូលេន ចោទិតោ
សាវត្ថិយំ បុរេ ជាតោ មហាសាលេ សុអឌ្ឍកេ ។

១ ឱ. អព្ភុគ្គតោ ។ ២ ឱ, ម. មហាបក្ខោ ។ ៣ ឱ. វេវណ្ណិ ។



ខ្ញុំតែងបាននូវវត្ថុទាំងអស់នេះគឺ សំពត់ថ្មី ផ្លែឈើថ្មី ភោជន មានរសដ៏ប្រសើរប្រសើរ នេះជាផលនៃពុទ្ធបូជា ។ ខ្ញុំតែងបាននូវពាក្យពោលទាំងអស់នេះថា សូមលោកពិសានូវភោជនទាំងនេះ សូមបរិភោគភោជនទាំងនេះ សូមសម្រាន្តលើដំណេកនេះ នេះជាផលនៃពុទ្ធបូជា ។ ខ្ញុំមានគេបូជាក្នុងទីទាំងពួង យស (កេរ្តិ៍ឈ្មោះ) របស់ខ្ញុំ ខ្ពស់ខ្ពាយទៅក្នុងទិសទាំងពួង ។ ខ្ញុំមានសក្តិធំសព្វកាល មានបរិស័ទមិនបែកបាក់សព្វកាល ខ្ញុំជាបុរសឧត្តមជាងពួកញាតិ នេះជាផលនៃពុទ្ធបូជា ។ ខ្ញុំមិនដែលស្គាល់ត្រជាក់និងក្តៅ ឯសេចក្តីក្តៅក្រហាយក៏មិនមាន ទាំងសេចក្តីទុក្ខព្រួយក្នុងចិត្តក៏មិនមាន ក្នុងហឫទ័យរបស់ខ្ញុំ ។ ខ្ញុំជាអ្នកមានសម្បុរដូចមាស តែងអន្ទោលទៅក្នុងភពតូចភពធំ ខ្ញុំមិនដែលស្គាល់ភាពពណ៌អាក្រក់ នេះជាផលនៃពុទ្ធបូជា ។ ខ្ញុំច្យុតចាកទេវលោក ត្រូវកុសលមូលដាស់តឿន បានមកកើតក្នុងបុរីសាវត្ថី ក្នុងត្រកូលមហាសាល ជាត្រកូលស្តុកស្តម្ភមាំមួន ។

បញ្ចកាមគុណេ ហិត្វា បព្វជឹ អនគារិយំ
ជាតិយា សត្តវស្សោហំ អរហត្តំ អបាបុណឹ ។
ឧបសម្បាទយី ពុទ្ធោ គុណមញ្ញាយ ចក្ខុមា
តរុណោ បូជនីយោហំ ពុទ្ធបូជាយិទំ ផលំ ។
ទិព្វចក្ខុំ វិសុទ្ធំ មេ សមាធិកុសលោ អហំ
អភិញ្ញាបារមិប្បត្តោ ពុទ្ធបូជាយិទំ ផលំ ។
បដិសម្ភិទា អនុប្បត្តោ ឥទ្ធិបាទេសុ កោវិទោ
សទ្ធម្មេ បារមិប្បត្តោ ពុទ្ធបូជាយិទំ ផលំ ។
តិំសកប្បសហស្សម្ហិ យំ ពុទ្ធមភិបូជយឹ
ទុគ្គតឹ នាភិជានាមិ ពុទ្ធបូជាយិទំ ផលំ ។
កិលេសា ឈាបិតា មយ្ហំ ភវា សព្វេ សមូហតា
នាគោវ ពន្ធនំ ឆេត្វា វិហរាមិ អនាសវោ ។



ខ្ញុំលះបង់កាមគុណទាំង៥ ហើយចូលទៅកាន់ផ្នួស ខ្ញុំមានអាយុ ៧ ឆ្នាំ រាប់អំពីកំណើតមក បានដល់អរហត្ត ។ ព្រះសម្ពុទ្ធទ្រង់មានចក្ខុ ជ្រាបច្បាស់នូវគុណរបស់ខ្ញុំ បានឲ្យឧប-សម្បទាដល់ខ្ញុំ ខ្ញុំជាមនុស្សក្មេង គួរដល់ការបូជា នេះជាផលនៃពុទ្ធបូជា ។ ចក្ខុរបស់ខ្ញុំដ៏បរិសុទ្ធដូចជាទិព្វ ខ្ញុំជាអ្នកឈ្លាសវៃក្នុងសមាធិ ដល់នូវត្រើយនៃអភិញ្ញា នេះជាផលនៃពុទ្ធបូជា ។ បដិសម្ភិទា ខ្ញុំបានសម្រេចដោយលំដាប់ ខ្ញុំជាអ្នកឈ្លាសវៃក្នុងឥទ្ធិបាទ បានដល់ត្រើយក្នុងព្រះសទ្ធម្ម នេះជាផលនៃពុទ្ធបូជា ។ ក្នុងកប្បទី៣ម៉ឺន អំពីកប្បនេះ ព្រោះហេតុដែលខ្ញុំបានបូជាព្រះសម្ពុទ្ធ ក្នុងកាលនោះ ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃពុទ្ធបូជា ។ កិលេសទាំងឡាយ ខ្ញុំដុតបំ-ផ្លាញហើយ ភពទាំងអស់ ខ្ញុំដកចោលហើយ ខ្ញុំជាអ្នកមិនមានអាសវៈ ព្រោះបានកាត់ចំណង ដូចជាដំរីកាត់ផ្តាច់នូវទន្លីង ។

ស្វាគតំ វត មេ អាសិ មម ពុទ្ធស្ស សន្តិកេ
តិស្សោ វិជ្ជា អនុប្បត្តា កតំ ពុទ្ធស្ស សាសនំ ។
បដិសម្ភិទា ចតស្សោ វិមោក្ខាបិ ច អដ្ឋិមេ
ឆឡភិញ្ញា សច្ឆិកតា កតំ ពុទ្ធស្ស សាសនន្តិ ។

ឥត្ថំ សុទំ អាយស្មា កិណិកណិការបុប្ផិយោ
ថេរោ ឥមា គាថាយោ អភាសិត្ថាតិ ។

កិណិកណិការបុប្ផិយត្ថេរស្ស អបទានំ សមត្តំ ។

## ទុតិយំ ឯកបត្តទាយកត្ថេរាបទានំ

(៩២) នគរេ ហំសវតិយា កុម្ភការោ អហោសហំ
អទ្ទសំ វិរជំ ពុទ្ធំ ឱឃតិណ្ណមនាសវំ ។
សុកតំ មត្តិកាបត្តំ(១) ពុទ្ធសេដ្ឋស្សទាសហំ
បត្តំ ទត្វា ភគវតោ ឧជុភូតស្ស តាទិនោ ។

១ ម. បត្តំ មត្តំ ។



ឱ ! ខ្ញុំមកល្អហើយ ក្នុងសំណាក់ព្រះពុទ្ធរបស់ខ្ញុំ វិជ្ជា ៣ ខ្ញុំបានដល់ហើយ សាសនា របស់ព្រះពុទ្ធ ខ្ញុំបានធ្វើហើយ ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនា របស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ។

បានឮថា ព្រះកិណិកណិការបុប្ផិយត្ថេរ មានអាយុ បានសម្តែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

ចប់ កិណិកណិការបុប្ផិយត្ថេរាបទាន ។

## ឯកបត្តទាយកត្ថេរាបទាន ទី ២

(៩២) ខ្ញុំកើតជាស្មូនឆ្នាំង ក្នុងនគរហង្សវតី ខ្ញុំបានឃើញព្រះពុទ្ធ ទ្រង់ប្រាសចាកធូលីគឺកិលេស ទ្រង់ឆ្លងផុតនូវអន្លង់គឺកិលេស មិនមានអាសវៈ ។ ខ្ញុំបានថ្វាយបាត្រដី ដែលខ្ញុំធ្វើល្អហើយ ដល់ព្រះពុទ្ធដ៏ប្រសើរ ខ្ញុំថ្វាយបាត្រដល់ព្រះមានបុណ្យ មានព្រះហឫទ័យទៀងត្រង់ ទ្រង់មិនញាប់ញ័រដោយលោកធម៌ ។

ភវេ និព្វត្តមានោហំ    សោវណ្ណថាលេ លភាមហំ
រូបិមយេ ច សោវណ្ណេ    ថាលកេ ច មណីមយេ ។
បាតិយា បរិភុញ្ជាមិ    បុញ្ញកម្មស្សិទំ ផលំ
យសសា ជលាចញ្ញ[១]    អគ្គតោ ច ហោមហំ[២] ។
យថាបិ ភទ្ទកេ ខេត្តេ    ពីជំ អប្បម្បិ រោបិតំ
សម្មា ធារំ បវេច្ឆន្តេ[៣]    ផលំ តោសេតិ កស្សកំ ។
តថេវិទំ បត្តទានំ    ពុទ្ធក្ខេត្តម្ហិ រោបិតំ
បីតិធារេ បវស្សន្តេ    ផលំ មេ តោសយិស្សតិ ។
យាវតា ខេត្តា វិជ្ជន្តិ    សង្ឃាបិច គណាបិច
ពុទ្ធក្ខេត្តសមោ នត្ថិ    សុខទោ សព្វបាណិនំ ។
នមោ តេ បុរិសាជញ្ញ    នមោ តេ បុរិសុត្តម
ឯកបត្តំ ទទិត្វាន    បត្តោម្ហិ អចលំ បទំ ។

---

១ ឱ.ម. យសោឥញ្ញ ឧតាឥញ្ញ ។ ២ ឱ. បក្ខកោ ច ហោមហំ ។ ម. សក្ខកោ ច ហោមហំ ។ ៣ ឱ. បវេច្ឆន្តេ ។ ម. បវច្ឆន្តេ ។





ខ្ញុំកាលកើតក្នុងភព តែងបានថាសមាសផង ថាសមាស-
ក្រឡៃប្រាក់ផង បានជាវិការនៃកែវមណីផង ។ ខ្ញុំតែង
បរិភោគដោយភាជន៍ នេះជាផលនៃបុញ្ញកម្ម ខ្ញុំជាអ្នកប្រ-
សើរដោយយសបរិវារជាជនទាំងឡាយ ។ ពូជសូម្បីបន្តិច
បន្តួចដែលគេសាបព្រោះក្នុងស្រែដ៏ល្អ កាលបើមេឃបង្អុរ
ធារទឹកដោយប្រពៃ ផ្លែស្រូវរមែងញ៉ាំងអ្នកស្រែ ឲ្យត្រេកអរ
យ៉ាងណាមិញ ។ បត្តទាននេះដែលខ្ញុំសាបព្រោះក្នុងស្រែគឺ
ព្រះពុទ្ធ ធារទឹកគឺបីតិបង្អុរចុះមក ផលរមែងធ្វើឲ្យខ្ញុំត្រេកអរ
ក៏យ៉ាងនោះដែរ ។ ស្រែទាំងប៉ុន្មានណា គឺព្រះសង្ឃក្តី គណៈ
ក្តី ស្រែទាំងនោះ ស្មើដោយស្រែគឺព្រះពុទ្ធ មិនមានឡើយ
ព្រោះស្រែគឺព្រះពុទ្ធ អាចឲ្យសេចក្តីសុខដល់សត្វទាំងពួង ។
បពិត្របុរសអាជានេយ្យ ខ្ញុំសូមថ្វាយបង្គំព្រះអង្គ បពិត្រ
បុរសដ៏ឧត្តម ខ្ញុំសូមថ្វាយបង្គំព្រះអង្គ ខ្ញុំបានថ្វាយបាត្រមួយ
ហើយបានសម្រេចព្រះនិព្វាន ជាគុណជាតមិនកម្រើក ។

ឯកនវុតេ ឥតោ កប្បេ យំ បត្តមទទឹ តទា
ទុគ្គតឹ នាភិជានាមិ បត្តទានស្សិទំ ផលំ ។
កិលេសា ឈាបិតា មយ្ហំ ភវា សព្វេ សមូហតា
នាគោវ ពន្ធនំ ឆេត្វា វិហរាមិ អនាសវោ ។
ស្វាគតំ វត មេ អាសិ មម ពុទ្ធស្ស សន្តិកេ
តិស្សោ វិជ្ជា អនុប្បត្តា កតំ ពុទ្ធស្ស សាសនំ ។
បដិសម្ភិទា ចតស្សោ វិមោក្ខាបិ ច អដ្ឋិមេ
ឆឡភិញ្ញា សច្ឆិកតា កតំ ពុទ្ធស្ស សាសនន្តិ ។

ឥត្ថំ សុទំ អាយស្មា ឯកបត្តទាយកោ ថេរោ ឥមា គាថាយោ អភាសិត្ថាតិ ។

ឯកបត្តទាយកត្ថេរស្ស អបទានំ សមត្តំ ។



ក្នុងកប្បទី ៩១ អំពីកប្បនេះ ព្រោះហេតុដែលខ្ញុំបានថ្វាយបាត្រ ក្នុងកាលនោះ ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃបត្តទាន ។ កិលេសទាំងឡាយ ខ្ញុំដុតបំផ្លាញហើយ ភពទាំងអស់ ខ្ញុំដកចោលហើយ ខ្ញុំជាអ្នកមិនមានអាសវៈ ព្រោះបានកាត់ចំណង ដូចជាដំរីកាត់ផ្តាច់នូវខ្នឹង ។ ឱ! ខ្ញុំមកល្អហើយ ក្នុងសំណាក់ព្រះពុទ្ធរបស់ខ្ញុំ វិជ្ជា ៣ ខ្ញុំបានសម្រេចហើយ ទាំងសាសនា របស់ព្រះពុទ្ធ ខ្ញុំបានធ្វើហើយ ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនា របស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ។

បានឮថា ព្រះឯកបត្តទាយកត្ថេរ មានអាយុ បានសំដែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

ចប់ ឯកបត្តទាយកត្ថេរាបទាន ។

## តតិយំ កាសុមារិកផលទាយកត្ថេរាបទានំ

(៤៣) កណិការំវ ជោតន្តំ និសិន្នំ បព្វតន្តរេ

អទ្ទសំ វិរជំ ពុទ្ធំ លោកជេដ្ឋំ នរាសភំ ។

បសន្នចិត្តោ សុមនោ សិរេ កត្វាន អញ្ជលឹ

កាសុមារិកមាទាយ ពុទ្ធសេដ្ឋស្សទាសហំ ។

ឯកត្តឹសេ ឥតោ កប្បេ យំ ផលំ អទទឹ តទា

ទុគ្គតឹ នាភិជានាមិ ផលទានស្សិទំ ផលំ ។

កិលេសា ឈាបិតា មយ្ហំ ភវា សព្វេ សមូហតា

នាគោវ ពន្ធនំ ឆេត្វា វិហរាមិ អនាសវោ ។

ស្វាគតំ វត មេ អាសិ មម ពុទ្ធស្ស សន្តិកេ

តិស្សោ វិជ្ជា អនុប្បត្តា កតំ ពុទ្ធស្ស សាសនំ ។

បដិសម្ភិទា ចតស្សោ វិមោក្ខាបិច អដ្ឋិមេ

ឆឡភិញ្ញា សច្ឆិកតា កតំ ពុទ្ធស្ស សាសនំ ។

## កាសុមារិកផលទាយកត្ថេរាបទាន ទី ៣

(៤៣) ខ្ញុំបានឃើញព្រះពុទ្ធ ទ្រង់ប្រាសចាកធូលី ជាច្បងក្នុងលោក ប្រសើរជាងនរៈ រុងរឿងដូចផ្កាកណិការ ទ្រង់គង់នៅក្នុងចន្លោះភ្នំ ។ ខ្ញុំមានចិត្តជ្រះថ្លា មានចិត្តរីករាយ ផ្គងអញ្ជលីលើក្បាល បានយកផ្លែស្លាទុំទៅថ្វាយព្រះពុទ្ធដ៏ប្រសើរ ។ ក្នុងកប្បទី ៣១ អំពីកប្បនេះ ព្រោះហេតុដែលខ្ញុំបានថ្វាយផ្លែស្លា ក្នុងកាលនោះ ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃផលទាន ។ កិលេសទាំងឡាយ ខ្ញុំដុតបំផ្លាញហើយ ភពទាំងអស់ ខ្ញុំដកចោលហើយ ខ្ញុំជាអ្នកមិនមានអាសវៈ ព្រោះបានកាត់ចំណង ដូចជាដំរីកាត់ផ្តាច់ទន្លីង ។ ឱ ! ខ្ញុំមកល្អហើយ ក្នុងសំណាក់ព្រះពុទ្ធរបស់ខ្ញុំ វិជ្ជា ៣ ខ្ញុំបានដល់ហើយ សាសនារបស់ព្រះពុទ្ធ ខ្ញុំបានធ្វើហើយ ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ។

ឥត្ថំ សុទំ អាយស្មា កាសុមារិកផលទាយកោ ថេរោ ឥមា គាថាយោ អភាសិត្ថាតិ ។

កាសុមារិកផលទាយកត្ថេរស្ស អបទានំ សមត្តំ ។

## ឆដ្ឋំ អវដផលិយត្ថេរាបទានំ

(៩៦) សហស្សរំសី ភគវា សយម្ភូ អបរាជិតោ
វិវេកា វុដ្ឋហិត្វាន គោចរាយាភិនិក្ខមិ ។
ផលហត្ថោ អហំ ទិស្វា ឧបគច្ឆឹ នរាសភំ
បសន្នចិត្តោ សុមនោ អវដំ អទទឹ ផលំ ។
ឆន្នវុតេ ឥតោ កប្បេ យំ ផលំ អទទឹ តទា
ទុគ្គតឹ នាភិជានាមិ ផលទានស្សិទំ ផលំ ។
កិលេសា ឈាបិតា មយ្ហំ ភវា សព្វេ សមូហតា
នាគោវ ពន្ធនំ ឆេត្វា វិហរាមិ អនាសវោ ។



បានឮថា ព្រះកាសុមារិកផលទាយកត្ថេរ មានអាយុ បានសម្តែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

ចប់ កាសុមារិកផលទាយកត្ថេរាបទាន ។

## អវដផលិយត្ថេរាបទាន ទី ៦

(៩៦) ព្រះមានព្រះភាគ ទ្រង់មានរស្មីច្រើន ត្រាស់ដឹងដោយព្រះអង្គឯង ទ្រង់ឈ្នះមារ ក្រោកចាកទីស្ងប់ស្ងាត់ ស្តេចចេញទៅដើម្បីគោចរ ។ ខ្ញុំមានដៃកាន់ផ្លែឈើ ឃើញព្រះនរាសភៈ ក៏ចូលទៅជិត ខ្ញុំមានចិត្តជ្រះថ្លា មានចិត្តរីករាយ បានថ្វាយអវដផល (ផ្លែឈើ) ដល់ព្រះអង្គ ។ ក្នុងកប្បទី ៩៦ អំពីកប្បនេះ ព្រោះហេតុដែលខ្ញុំបានថ្វាយផ្លែឈើ ក្នុងកាលនោះ ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃផលទាន ។ កិលេសទាំងឡាយ ខ្ញុំដុតបំផ្លាញហើយ ភពទាំងអស់ ខ្ញុំដកចោលហើយ ខ្ញុំជាអ្នកមិនមានអាសវៈ ព្រោះបានកាត់ចំណង ដូចជាដំរីកាត់ផ្តាច់ នូវចំណង ។

ស្វាគតំ វត មេ អាសិ មម ពុទ្ធស្ស សន្តិកេ
តិស្សោ វិជ្ជា អនុប្បត្តា កតំ ពុទ្ធស្ស សាសនំ ។
បដិសម្ភិទា ចតស្សោ វិមោក្ខាបិ ច អដ្ឋិមេ
ឆឡភិញ្ញា សច្ឆិកតា កតំ ពុទ្ធស្ស សាសនំ ។

ឥត្ថំ សុទំ អាយស្មា អវដផលិយោ ថេរោ ឥមា គាថាយោ អភាសិត្ថាតិ ។

អវដផលិយត្ថេរស្ស អបទានំ សមត្តំ ។

## បញ្ចមំ ផារុផលិយត្ថេរាបទានំ

(៩៥) សុវណ្ណវណ្ណំ សម្ពុទ្ធំ អាហុតីនំ បដិគ្គហំ
វិបិនំ បដិបជ្ជន្តំ ផារុផលមទាសហំ(១) ។
ឯកនវុតេ ឥតោ កប្បេ យំ ផលំ អទទឹ តទា
ទុគ្គតឹ នាភិជានាមិ ផលទានស្សិទំ ផលំ ។

១ ឱ. ផារុផលមទាសហំ ។ ម. ផារុផល... ។





ឱ ! ខ្ញុំមកល្អហើយ ក្នុងសំណាក់ព្រះពុទ្ធរបស់ខ្ញុំ វិជ្ជា ៣ ខ្ញុំបានដល់ហើយ សាសនា របស់ព្រះពុទ្ធ ខ្ញុំបានធ្វើហើយ ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនា របស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ។

បានឮថា ព្រះអវដផលិយត្ថេរ មានអាយុ បានសម្តែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

ចប់ អវដផលិយត្ថេរាបទាន ។

## ផារុផលិយត្ថេរាបទាន ទី ៥

(៩៥) ខ្ញុំបានឃើញព្រះសម្ពុទ្ធ ទ្រង់មានវណ្ណៈដូចមាស គួរទទួលនូវគ្រឿងបូជា កំពុងស្តេចពុទ្ធដំណើរទៅតាមព្រៃ ហើយបានប្រគេនផារុផល (ផ្លែឈើ) ។ ក្នុងកប្បទី ៩១ អំពីកប្បនេះ ព្រោះហេតុដែលខ្ញុំបានថ្វាយផ្លែឈើ ក្នុងកាលនោះ ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃផលទាន ។

កិលេសា ឈាបិតា មយ្ហំ ភវា សព្វេ សមូហតា
នាគោវ ពន្ធនំ ឆេត្វា វិហរាមិ អនាសវោ ។
ស្វាគតំ វត មេ អាសិ មម ពុទ្ធស្ស សន្តិកេ
តិស្សោ វិជ្ជា អនុប្បត្តា កតំ ពុទ្ធស្ស សាសនំ ។
បដិសម្ភិទា ចតស្សោ វិមោក្ខាបិ ច អដ្ឋិមេ
ឆឡភិញ្ញា សច្ឆិកតា កតំ ពុទ្ធស្ស សាសនន្តិ ។

ឥត្ថំ សុទំ អាយស្មា ចារផលិយោ ថេរោ ឥមា គាថាយោ អភាសិត្ថាតិ ។

ចារផលិយត្ថេរស្ស អបទានំ សមត្តំ ។

## ឆដ្ឋំ មាតុលុង្គផលទាយកត្ថេរាបទានំ

(៩៦) កណិការំ វ ជលិតំ បុណ្ណមាយេវ ចន្ទិមំ
ជលន្តំ ទីបរុក្ខំវ អទ្ទសំ លោកនាយកំ ។
មាតុលុង្គផលំ គយ្ហ អទាសិំ សត្ថុនោ អហំ
ទក្ខិណេយ្យស្ស វីរស្ស បសន្នោ សេហិ បាណិភិ ។



កិលេសទាំងឡាយ ខ្ញុំដុតបំផ្លាញហើយ ភពទាំងអស់ ខ្ញុំដកចោលហើយ ខ្ញុំជាអ្នកមិនមានអាសវៈ ព្រោះបានកាត់ចំណង ដូចជាដំរីកាត់ផ្តាច់នូវទន្លីង ។ ឱ ! ខ្ញុំមកល្អហើយ ក្នុងសំណាក់ព្រះពុទ្ធរបស់ខ្ញុំ វិជ្ជា ៣ ខ្ញុំបានដល់ហើយ សាសនា របស់ព្រះពុទ្ធ ខ្ញុំបានធ្វើហើយ ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនា របស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ។

បានឮថា ព្រះចារផលិយត្ថេរ មានអាយុ បានសម្តែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

ចប់ ចារផលិយត្ថេរាបទាន ។

## មាតុលុង្គផលទាយកត្ថេរាបទាន ទី ៦

[៩៦] ខ្ញុំបានឃើញនូវព្រះលោកនាយក ទ្រង់រុងរឿងដូចផ្កាកណិការ ឬដូចព្រះចន្ទពេញបូណ៌មី ឬក៏ដូចឈើប្រទីប ដ៏រុងរឿង ។ ខ្ញុំមានចិត្តជ្រះថ្លា បានយកផ្លែក្រូចត្លុង ទៅថ្វាយព្រះសាស្តា ជាទក្ខិណេយ្យបុគ្គល ទ្រង់មានព្យាយាម ដោយដៃរបស់ខ្លួន ។

ផ្ដើម មាតុលុង្គផលទាយកត្ថេរាបទានំ

ឯកត្តឹសេ ឥតោ កប្បេ យំ ផលំ អទទឹ តទា
ទុគ្គតឹ នាភិជានាមិ ផលទានស្សិទំ ផលំ ។
កិលេសា ឈាបិតា មយ្ហំ ភវា សព្វេ សមូហតា
នាគោវ ពន្ធនំ ឆេត្វា វិហរាមិ អនាសវោ ។
ស្វាគតំ វត មេ អាសិ មម ពុទ្ធស្ស សន្តិកេ
តិស្សោ វិជ្ជា អនុប្បត្តា កតំ ពុទ្ធស្ស សាសនំ ។
បដិសម្ភិទា ចតស្សោ វិមោក្ខាបិច អដ្ឋិមេ
ឆឡភិញ្ញា សច្ឆិកតា កតំ ពុទ្ធស្ស សាសនន្តិ ។

ឥត្ថំ សុទំ អាយស្មា មាតុលុង្គផលទាយកោ ថេរោ ឥមា គាថាយោ អភាសិត្ថាតិ ។

មាតុលុង្គផលទាយកត្ថេរស្ស អបទានំ សមត្តំ ។



មាតុលុង្គផលទាយកត្ថេរាបទាន ទី ៦

ក្នុងកប្បទី ៣១ អំពីកប្បនេះ ព្រោះហេតុដែលខ្ញុំបានថ្វាយ
ផ្លែឈើ ក្នុងកាលនោះ ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផល
នៃផលទាន ។ កិលេសទាំងឡាយ ខ្ញុំដុតបំផ្លាញហើយ
ភពទាំងអស់ ខ្ញុំដកចោលហើយ ខ្ញុំជាអ្នកមិនមានអាសវៈ
ព្រោះបានកាត់ចំណង ដូចជាដំរីកាត់ផ្ដាច់នូវទន្លីង ។ ឱ !
ខ្ញុំមកល្អហើយ ក្នុងសំណាក់ព្រះពុទ្ធរបស់ខ្ញុំ វិជ្ជា ៣ ខ្ញុំបាន
ដល់ហើយ សាសនា របស់ព្រះពុទ្ធ ខ្ញុំបានធ្វើហើយ ។
បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យ
ជាក់ច្បាស់ហើយ ទាំងសាសនា របស់ព្រះពុទ្ធ ខ្ញុំក៏បាន
ប្រតិបត្តិហើយ ។

បានឮថា ព្រះមាតុលុង្គផលទាយកត្ថេរ មានអាយុ បានសំដែង
នូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

ចប់ មាតុលុង្គផលទាយកត្ថេរាបទាន ។

# សត្តមំ អជ្ជេលផលទាយកត្ថេរាបទានំ

[៩៧] អជិតោ នាម សម្ពុទ្ធោ ហិមវន្តេ វសី តទា
ចរណេន ច សម្បន្នោ សមាធិកុសលោ មុនិ ។
កុម្ភមត្តំ គហេត្វាន អញ្ជលី ជីវជីវកំ(១)
ឆត្តបណ្ណំ គហេត្វាន អទាសិ សត្ថុនោ អហំ ។
ចតុន្នវុតេ ឥតោ កប្បេ យំ ផលំ អទទឹ តទា
ទុគ្គតឹ នាភិជានាមិ ផលទានស្សិទំ ផលំ ។
កិលេសា ឈាបិតា មយ្ហំ ភវា សព្វេ សមូហតា
នាគោវ ពន្ធនំ ឆេត្វា វិហរាមិ អនាសវោ ។
ស្វាគតំ វត មេ អាសិ មម ពុទ្ធស្ស សន្តិកេ
តិស្សោ វិជ្ជា អនុប្បត្តា កតំ ពុទ្ធស្ស សាសនំ ។
បដិសម្ភិទា ចតស្សោ វិមោក្ខាបិ ច អដ្ឋិមេ
ឆឡភិញ្ញា សច្ឆិកតា កតំ ពុទ្ធស្ស សាសនំ ។

១ អ. ផលំ ជីវជីវកំ ។





# អជ្ជេលផលទាយកត្ថេរាបទាន ទី ៧

[៩៧] កាលនោះ ព្រះបច្ចេកសម្ពុទ្ធ ព្រះនាមអជិតៈ ទ្រង់បរិបូណ៌ដោយចរណៈ ឈ្លាសវៃក្នុងសមាធិ ជាអ្នកប្រាជ្ញ គង់នៅក្នុងព្រៃហិមពាន្ត ។ ខ្ញុំបានយកផ្លែអញ្ជលិព្រឹក្សស្រស់ៗ ប្រមាណប៉ុនក្អម កាន់យកឆត្រស្លឹក ប្រគេនដល់ព្រះសាស្តា ។ ក្នុងកប្ប ទី ៩៤ អំពីកប្បនេះ ព្រោះហេតុដែលខ្ញុំបានថ្វាយផ្លែឈើ ក្នុងកាលនោះ ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃផលទាន ។ កិលេសទាំងឡាយ ខ្ញុំដុតបំផ្លាញហើយ ភពទាំងអស់ ខ្ញុំដកចោលហើយ ខ្ញុំជាអ្នកមិនមានអាសវៈ ព្រោះបានកាត់ចំណង ដូចជាដំរីកាត់ផ្តាច់នូវទន្លីង ។ ឱ ! ខ្ញុំមកល្អហើយ ក្នុងសំណាក់ព្រះពុទ្ធរបស់ខ្ញុំ វិជ្ជា ៣ ខ្ញុំបានដល់ហើយ សាសនារបស់ព្រះពុទ្ធ ខ្ញុំបានធ្វើហើយ ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនា របស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ។

ឥត្ថំ សុទំ អាយស្មា អម្ពផលទាយកោ ថេរោ ឥមា គាថាយោ អភាសិត្ថាតិ ។

អម្ពផលទាយកត្ថេរស្ស អបទានំ សមត្តំ ។

# អដ្ឋមំ អមោរផលិយត្ថេរាបទានំ

(៩៨) សុវណ្ណវណ្ណំ សម្ពុទ្ធំ   អាហុតីនំ បដិគ្គហំ
រថិយំ បដិបជ្ជន្តំ   អមោរំ(១) អទទឹ ផលំ ។
ឯកនវុតេ ឥតោ កប្បេ   យំ ផលំ អទទឹ តទា
ទុគ្គតឹ នាភិជានាមិ   ផលទានស្សិទំ ផលំ ។
កិលេសា ឈាបិតា មយ្ហំ   ភវា សព្វេ សមូហតា
នាគោវ ពន្ធនំ ឆេត្វា   វិហរាមិ អនាសវោ ។
ស្វាគតំ វត មេ អាសិ   មម ពុទ្ធស្ស សន្តិកេ
តិស្សោ វិជ្ជា អនុប្បត្តា   កតំ ពុទ្ធស្ស សាសនំ ។

---

១ ម. អមោទំ ។





បានឮថា ព្រះអម្ពផលទាយកត្ថេរ មានអាយុ បានសម្ដែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

ចប់ អម្ពផលទាយកត្ថេរាបទាន ។

# អមោរផលិយត្ថេរាបទាន ទី ៨

(៩៨) ខ្ញុំបានឃើញនូវព្រះសម្ពុទ្ធ ទ្រង់មានវណ្ណៈដូចមាស គួរទទួលនូវគ្រឿងបូជា ដែលទ្រង់កំពុងតែស្ដេចទៅតាមច្រក ហើយប្រគេនផ្លែអមោរព្រឹក្ស ។ ក្នុងកប្បទី ៩១ អំពីកប្បនេះ ព្រោះហេតុដែលខ្ញុំបានថ្វាយផ្លែឈើ ក្នុងកាលនោះ ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃផលទាន ។ កិលេសទាំងឡាយ ខ្ញុំដុតបំផ្លាញហើយ ភពទាំងអស់ ខ្ញុំដកចោលហើយ ខ្ញុំជាអ្នកមិនមានអាសវៈ ព្រោះបានកាត់ចំណង ដូចជាដំរីកាត់ផ្ដាច់នូវទន្លីង ។ ឱ! ខ្ញុំមកល្អហើយ ក្នុងសំណាក់ព្រះពុទ្ធរបស់ខ្ញុំ វិជ្ជា ៣ ខ្ញុំបានដល់ហើយ សាសនា របស់ព្រះពុទ្ធ ខ្ញុំបានធ្វើហើយ ។

បដិសម្ភិទា ចតស្សោ វិមោក្ខាបិ ច អដ្ឋិមេ
ឆឡភិញ្ញា សច្ឆិកតា កតំ ពុទ្ធស្ស សាសនំ ។

ឥត្ថំ សុទំ អាយស្មា អម្ពផលិយោ ថេរោ ឥមា គាថាយោ អភាសិត្ថាតិ ។

អម្ពផលិយត្ថេរស្ស អបទានំ សមត្តំ ។

## នវមំ តាលផលិយត្ថេរាបទានំ

(៤៩) សតរំសី នាម ភគវា សយម្ភូ អបរាជិតោ
វុដ្ឋហិត្វាន គោចរាយាភិនិក្ខមិ ។
ផលហត្ថោ អហំ ទិស្វា ឧបគច្ឆិំ នរាសភំ
បសន្នចិត្តោ សុមនោ តាលផលមទាសហំ ។
ចតុន្នវុតេ ឥតោ កប្បេ យំ ផលំ អទទឹ តទា
ទុគ្គតឹ នាភិជានាមិ ផលទានស្សិទំ ផលំ ។



បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនា របស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ។

បានឮថា ព្រះអម្ពផលិយត្ថេរ មានអាយុ បានសំដែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

ចប់ អម្ពផលិយត្ថេរាបទាន ។

## តាលផលិយត្ថេរាបទាន ទី ៩

(៤៩) ព្រះមានព្រះភាគ ទ្រង់ព្រះនាមសតរង្សី ត្រាស់ដឹងដោយព្រះអង្គឯង ទ្រង់ឈ្នះមារ ក្រោកចេញចាកទីស្ងាត់ ហើយស្តេចទៅដើម្បីគោចរ ។ ខ្ញុំមានដៃកាន់ផ្លែឈើ ឃើញព្រះនរាសភៈ ក៏ចូលទៅជិត ខ្ញុំមានចិត្តជ្រះថ្លា មានចិត្តរីករាយ បានថ្វាយផ្លែត្នោត ។ ក្នុងកប្បទី ៩៤ អំពីកប្បនេះ ព្រោះហេតុដែលខ្ញុំបានថ្វាយផ្លែ ក្នុងកាលនោះ ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃផលទាន ។

កិលេសា ឈាបិតា មយ្ហំ ភវា សព្វេ សមូហតា

នាគោវ ពន្ធនំ ឆេត្វា វិហរាមិ អនាសវោ ។

ស្វាគតំ វត មេ អាសិ មម ពុទ្ធស្ស សន្តិកេ

តិស្សោ វិជ្ជា អនុប្បត្តា កតំ ពុទ្ធស្ស សាសនំ ។

បដិសម្ភិទា ចតស្សោ វិមោក្ខាបិ ច អដ្ឋិមេ

ឆឡភិញ្ញា សច្ឆិកតា កតំ ពុទ្ធស្ស សាសនំ ។

ឥត្ថំ សុទំ អាយស្មា តាលផលិយោ(១) ថេរោ ឥមា

គាថាយោ អភាសិត្ថាតិ ។

តាលផលិយត្ថេរស្ស អបទានំ សមត្តំ ។

## ទសមំ នាឡិកេរផលទាយកត្ថេរាបទានំ

(១០០) នគរេ ពន្ធុមតិយា អារាមិកោ អហំ តទា

អទ្ទសំ វិរជំ ពុទ្ធំ គច្ឆន្តំ អនិលញ្ជសេ ។

នាឡិកេរផលំ(២) គយ្ហ ពុទ្ធសេដ្ឋស្សទាសហំ

អាកាសេ ឋិតកោ សន្តោ បដិគ្គណ្ហិ មហាយសោ ។

១ ម. តាលផលទាយកោ ។ ២ ឱ. នាឡិកេរំ ។



កិលេសទាំងឡាយ ខ្ញុំដុតបំផ្លាញហើយ ភពទាំងអស់ ខ្ញុំដកចោលហើយ ខ្ញុំជាអ្នកមិនមានអាសវៈ ព្រោះបានកាត់ចំណង ដូចជាដំរីកាត់ផ្តាច់នូវចំណង ។ ឱ ! ខ្ញុំមកល្អហើយ ក្នុងសំណាក់ព្រះពុទ្ធរបស់ខ្ញុំ វិជ្ជា ៣ ខ្ញុំបានដល់ហើយ សាសនា របស់ព្រះពុទ្ធ ខ្ញុំបានធ្វើហើយ ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនា របស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ។

បានឮថា ព្រះតាលផលិយត្ថេរ មានអាយុ បានសម្តែងនូវគាថា ទាំងនេះ ដោយប្រការដូច្នេះ ។

ចប់ តាលផលិយត្ថេរាបទាន ។

## នាឡិកេរផលទាយកត្ថេរាបទាន ទី ១០

(១០០) កាលនោះ ខ្ញុំជាញោមវត្តក្នុងនគរពន្ធុមតី បានឃើញព្រះពុទ្ធ ទ្រង់ប្រាសចាកធូលី កំពុងស្តេចទៅឯអាកាស ខ្ញុំ បានយកផ្លែដូងទៅថ្វាយដល់ព្រះពុទ្ធដ៏ប្រសើរ ព្រះពុទ្ធទ្រង់ មានយសធំ ឋិតនៅក្នុងអាកាស ទ្រង់ទទួល (ផ្លែដូងនោះ) ។

បីតិសញ្ជននោ(១) មយ្ហំ   ទិដ្ឋធម្មសុខាវហោ

ផលំ ពុទ្ធស្ស ទត្វាន   វិប្បសន្នេន ចេតសា ។

អធិគញ្ឆឹ តទា បីតឹ   វិបុលញ្ច សុខុត្តមំ

ឧប្បជ្ជតេវ រតនំ   និព្វត្តស្ស តហឹ(២) តហឹ ។

ឯកនវុតេ ឥតោ កប្បេ   យំ ផលំ អទទឹ តទា

ទុគ្គតឹ នាភិជានាមិ   ផលទានស្សិទំ ផលំ ។

ទិព្វចក្ខុំ វិសុទ្ធំ មេ   សមាធិកុសលោ អហំ

អភិញ្ញាបារមិប្បត្តោ   ផលទានស្សិទំ ផលំ ។

កិលេសា ឈាបិតា មយ្ហំ   ភវា សព្វេ សមូហតា

នាគោវ ពន្ធនំ ឆេត្វា   វិហរាមិ អនាសវោ ។

ស្វាគតំ វត មេ អាសិ   មម ពុទ្ធស្ស សន្តិកេ

តិស្សោ វិជ្ជា អនុប្បត្តា   កតំ ពុទ្ធស្ស សាសនំ ។

---

១ ឱ ម. វិត្តិសញ្ជននោ ។ ២ ឱ. យហឹ ។



ខ្ញុំមានការកើតបីតិ ជាទីនាំមកនូវសេចក្តីសុខ ក្នុងបច្ចុប្បន្ន ព្រោះថ្វាយនូវផ្លែឈើ ដល់ព្រះពុទ្ធ ដោយចិត្តជ្រះថ្លា ។ កាលនោះ ខ្ញុំបាននូវបីតិដ៏ធំទូលាយផង នូវសេចក្តីសុខដ៏ឧត្តមផង រតនៈតែងកើតឡើងដល់ខ្ញុំ ដែលកើតក្នុងភពនោះ ៗ ។ ក្នុងកប្បទី ៩១ អំពីកប្បនេះ ព្រោះហេតុដែលខ្ញុំបានថ្វាយផ្លែ ក្នុងកាលនោះ ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃផលទាន ។ ចក្ខុរបស់ខ្ញុំដ៏បរិសុទ្ធដូចជាទិព្វ ខ្ញុំជាអ្នកឈ្លាសវៃក្នុងសមាធិ ដល់នូវអភិញ្ញាបារមី នេះជាផលនៃផលទាន ។ កិលេសទាំងឡាយ ខ្ញុំដុតបំផ្លាញហើយ ភពទាំងអស់ ខ្ញុំដកចោលហើយ ខ្ញុំជាអ្នកមិនមានអាសវៈ ព្រោះបានកាត់ចំណង ដូចជាដំរីកាត់ផ្តាច់នូវទន្លីង ។ ឱ! ខ្ញុំមកល្អហើយ ក្នុងសំណាក់ព្រះពុទ្ធរបស់ខ្ញុំ វិជ្ជា ៣ ខ្ញុំបានដល់ហើយ សាសនា របស់ព្រះពុទ្ធ ខ្ញុំបានធ្វើហើយ ។

ទសមំ នាលិកេរផលទាយកត្ថេរាបទានំ

បដិសម្ភិទា ចតស្សោ វិមោក្ខាបិ ច អដ្ឋិមេ
ឆឡភិញ្ញា សច្ឆិកតា កតំ ពុទ្ធស្ស សាសនន្តិ ។

ឥត្ថំ សុទំ អាយស្មា នាលិកេរផលទាយកោ ថេរោ
ឥមា គាថាយោ អភាសិត្ថាតិ ។

នាលិកេរផលទាយកត្ថេរស្ស អបទានំ សមត្តំ ។

## ឧទ្ទានំ

កណិការេកបត្តញ្ច[១] កាសុមារិ តថាវដោ[២]
ចារផលំ មាតុលុង្គំ[៣] អជ្ជេលាមោរមេវ ច[៤] ។
តាលំ តថា នាលិកេរំ គាថាយោ គណិតាឥហ[៥]
ឯកំ គាថាសតំ ហោតិ ឩនាធិកាវិវជ្ជិតំ ។

កណិការវគ្គោ ឯកបញ្ញាសោ ។

---

១ ឱ. កណិការេកបត្តំ ច ។ ២ ឱ. តថាវិធិ ។ ម. តថាវដា ។ ៣ ឱ. ជារញ្ច មា-តុលុង្គញ្ច ។ ម. ជាទញ្ច... ។ ៤ ម. អជ្ជេលីមោរមេវ ច ។ ៥ ឱ.ម. គណិតាវិហ ។





បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនា របស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ។

បានឮថា ព្រះនាលិកេរផលទាយកត្ថេរ មានអាយុ បានសម្ដែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

ចប់ នាលិកេរផលទាយកត្ថេរាបទាន ។

## ឧទ្ទាន

គឺកណិការបុប្ផិយត្ថេរាបទាន ១ ឯកបត្តទាយកត្ថេរាបទាន ១ កាសុមារិកផលទាយកត្ថេរាបទាន ១ អវដផលិយត្ថេរាបទាន ១ ចារផលិយត្ថេរាបទាន ១ មាតុលុង្គផលទាយកត្ថេរាបទាន ១ អជ្ជេលផលទាយកត្ថេរាបទាន ១ អមោរផលិយត្ថេរាបទាន ១ តាលផលិយត្ថេរាបទាន ១ នាលិកេរផលទាយកត្ថេរាបទាន ១ គាថាតាមដែលលោករាប់ទៅឃើញមានចំនួន ១០១ គាថា មិនមានការខ្វះនិងការលើស ។

ចប់ កណិការវគ្គ ទី ៥១ ។

## បឋមំ កុរញ្ជិយផលទាយកត្ថេរាបទានំ

[១០១] មិគលុទ្ធោ(១) បុរេ អាសឹ វិបិនេ វិចរំ អហំ

អទ្ទសំ វិរជំ ពុទ្ធំ សព្វធម្មាន បារគុំ ។

កុរញ្ជិយផលំ(២) គយ្ហ ពុទ្ធសេដ្ឋស្សទាសហំ

បុញ្ញក្ខេត្តស្ស វីរស្ស(៣) បសន្នោ សេហិ បាណិភិ ។

ឯកត្តឹសេ ឥតោ កប្បេ យំ ផលំ អទទឹ តទា

ទុគ្គតឹ នាភិជានាមិ ផលទានស្សិទំ ផលំ ។

កិលេសា ឈាបិតា មយ្ហំ ភវា សព្វេ សមូហតា

នាគោវ ពន្ធនំ ឆេត្វា វិហរាមិ អនាសវោ ។

ស្វាគតំ វត មេ អាសិ មម ពុទ្ធស្ស សន្តិកេ

តិស្សោ វិជ្ជា អនុប្បត្តា កតំ ពុទ្ធស្ស សាសនំ ។

បដិសម្ភិទា ចតស្សោ វិមោក្ខាបិ ច អដ្ឋិមេ

ឆឡភិញ្ញា សច្ឆិកតា កតំ ពុទ្ធស្ស សាសនន្តិ ។

---

១ ឱ.ម. មិគលុទ្ទោ ។ ២ ឱ. កុបញ្ញិយផលំ ។ ម. កុរញ្ជិយផលំ ។ ៣ ឱ. វីរស្ស ។ ម. តាទិនោ ។

# ផលទាយកវគ្គ ទី ៥២

## កុរញ្ជិយផលទាយកត្ថេរាបទាន ទី ១

[១០១] ក្នុងកាលមុន ខ្ញុំកើតជាព្រានព្រៃ ត្រេចទៅក្នុងព្រៃធំ បានឃើញព្រះសម្ពុទ្ធ ទ្រង់ប្រាសចាកធូលី ដល់នូវត្រើយនៃធម៌ទាំងពួង ។ ខ្ញុំមានចិត្តជ្រះថ្លា បានកាន់យកផ្លែកុរញ្ជិយព្រឹក្ស ថ្វាយព្រះពុទ្ធដ៏ប្រសើរ ជាបុញ្ញក្ខេត្ត ជាអ្នកប្រាជ្ញ ដោយដៃរបស់ខ្លួន ។ ក្នុងកប្បទី ៣១ អំពីកប្បនេះ ព្រោះហេតុដែលខ្ញុំបានថ្វាយផ្លែ ក្នុងកាលនោះ ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃផលទាន ។ កិលេសទាំងឡាយ ខ្ញុំដុតបំផ្លាញហើយ ភពទាំងអស់ ខ្ញុំដកចោលហើយ ខ្ញុំជាអ្នកមិនមានអាសវៈ ព្រោះបានកាត់ចំណង ដូចជាដំរីកាត់ផ្តាច់នូវចំណង ។ ឱ ខ្ញុំមកល្អហើយ ក្នុងសំណាក់ព្រះពុទ្ធរបស់ខ្ញុំ វិជ្ជា ៣ ខ្ញុំបានដល់ហើយ សាសនារបស់ព្រះពុទ្ធ ខ្ញុំបានធ្វើហើយ ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ។

ឥត្ថំ សុទំ អាយស្មា កុរញ្ជិយផលទាយកោ ថេរោ ឥមា គាថាយោ អភាសិត្ថាតិ ។

កុរញ្ជិយផលទាយកត្ថេរស្ស អបទានំ សមត្តំ ។

## ទុតិយំ កបិដ្ឋផលទាយកត្ថេរាបទានំ

(១០២) សុវណ្ណវណ្ណំ សម្ពុទ្ធំ អាហុតីនំ បដិគ្គហំ
រថិយំ បដិបជ្ជន្តំ កបិដ្ឋំ អទទឹ ផលំ ។
ឯកនវុតេ ឥតោ កប្បេ យំ ផលំ អទទឹ តទា
ទុគ្គតឹ នាភិជានាមិ ផលទានស្សិទំ ផលំ ។
កិលេសា ឈាបិតា មយ្ហំ ភវា សព្វេ សមូហតា
នាគោវ ពន្ធនំ ឆេត្វា វិហរាមិ អនាសវោ ។
ស្វាគតំ វត មេ អាសិ មម ពុទ្ធស្ស សន្តិកេ
តិស្សោ វិជ្ជា អនុប្បត្តា កតំ ពុទ្ធស្ស សាសនំ ។



បានឮថា ព្រះកុរញ្ជិយផលទាយកត្ថេរ មានអាយុ បានសម្តែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

ចប់ កុរញ្ជិយផលទាយកត្ថេរាបទាន ។

## កបិដ្ឋផលទាយកត្ថេរាបទាន ទី ២

(១០២) ខ្ញុំបានឃើញព្រះសម្ពុទ្ធ ទ្រង់មានវណ្ណៈដូចមាស គួរទទួលគ្រឿងបូជា កំពុងស្តេចទៅតាមច្រក ហើយថ្វាយផ្លែខ្វិត ។ ក្នុងកប្បទី ៩១ អំពីកប្បនេះ ព្រោះហេតុដែលខ្ញុំបានថ្វាយផ្លែឈើ ក្នុងកាលនោះ ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃផលទាន ។ កិលេសទាំងឡាយ ខ្ញុំដុតបំផ្លាញហើយ ភពទាំងអស់ ខ្ញុំដកចោលហើយ ខ្ញុំជាអ្នកមិនមានអាសវៈ ព្រោះបានកាត់ចំណង ដូចជាដំរីកាត់ផ្តាច់នូវទន្លីង ។ ឱ! ខ្ញុំមកល្អហើយ ក្នុងសំណាក់ព្រះពុទ្ធរបស់ខ្ញុំ វិជ្ជា ៣ ខ្ញុំបានដល់ហើយ សាសនារបស់ព្រះពុទ្ធ ខ្ញុំបានធ្វើហើយ ។

បដិសម្ភិទា ចតស្សោ   វិមោក្ខាបិច អដ្ឋិមេ
ឆឡភិញ្ញា សច្ឆិកតា   កតំ ពុទ្ធស្ស សាសនន្តិ ។

ឥត្ថំ សុទំ អាយស្មា កបិដ្ឋផលទាយកោ ថេរោ ឥមា គាថាយោ អភាសិត្ថាតិ ។

កបិដ្ឋផលទាយកត្ថេរស្ស អបទានំ សមត្តំ ។

## តតិយំ កោសុម្ពផលិយត្ថេរាបទានំ

(១០៣) កកុធំ វិលសន្តំវ(១)   ទេវទេវំ នរាសភំ
រថិយំ បដិបជ្ជន្តំ   កោសុម្ពមទទិន្ទហំ(២) ។
ឯកត្តឹសេ ឥតោ កប្បេ   យំ ផលំ អទទឹ តទា
ទុគ្គតឹ នាភិជានាមិ   ផលទានស្សិទំ ផលំ ។
កិលេសា ឈាបិតា មយ្ហំ   ភវា សព្វេ សមូហតា
នាគោវ ពន្ធនំ ឆេត្វា   វិហរាមិ អនាសវោ ។

១ ម. វិលម្ពន្តំ ។ ២ ម. កោសម្ពមទទឹ តទា ។ កោសម្ពន្តិ យុត្តតរំ ។





បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនា របស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ។

បានឮថា ព្រះកបិដ្ឋផលទាយកត្ថេរ មានអាយុ បានសំដែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

ចប់ កបិដ្ឋផលទាយកត្ថេរាបទាន ។

## កោសុម្ពផលិយត្ថេរាបទាន ទី ៣

(១០៣) កាលនោះ ខ្ញុំបានឃើញព្រះសម្ពុទ្ធ ទ្រង់មានដំណើរល្អស្លូនដូចលំពង់ថ្ងន់ត្រូវខ្យល់ ជាទេវតាក្នុងទេវតាប្រសើរជាងនរៈ កំពុងស្តេចទៅតាមច្រក ហើយបានថ្វាយផ្លែសង្ក្រ ។ ក្នុងកប្បទី ៣១ អំពីកប្បនេះ ព្រោះហេតុដែលខ្ញុំបានថ្វាយផ្លែ ក្នុងកាលនោះ ខ្ញុំមិនដែលស្គាល់ទុគ្គតិនេះជាផលនៃផលទាន ។ កិលេសទាំងឡាយ ខ្ញុំដុតបំផ្លាញហើយ ភពទាំងអស់ ខ្ញុំដកចោលហើយ ខ្ញុំជាអ្នកមិនមានអាសវៈ ព្រោះបានកាត់ចំណង ដូចជាដំរីកាត់ផ្តាច់នូវទន្លីង ។

ស្វាគតំ វត មេ អាសិ   មម ពុទ្ធស្ស សន្តិកេ
តិស្សោ វិជ្ជា អនុប្បត្តា   កតំ ពុទ្ធស្ស សាសនំ ។
បដិសម្ភិទា ចតស្សោ   វិមោក្ខាបិ ច អដ្ឋិមេ
ឆឡភិញ្ញា សច្ឆិកតា   កតំ ពុទ្ធស្ស សាសនន្តិ ។

ឥត្ថំ សុទំ អាយស្មា កោសុម្ភផលិយោ ថេរោ ឥមា គាថាយោ អភាសិត្ថាតិ ។

កោសុម្ភផលិយត្ថេរស្ស អបទានំ សមត្តំ ។

## ចតុត្ថំ កេតកបុប្ផិយត្ថេរាបទានំ

(១០៤) វិនតានទិយា(១) តីរេ   វិហាសិ បុរិសុត្តមោ
អទ្ទសំ វិរជំ ពុទ្ធំ   ឯកគ្គំ សុសមាហិតំ ។
មធុកន្តស្ស បុប្ផេន   កេតកស្ស អហំ តទា
បសន្នចិត្តោ សុមនោ   ពុទ្ធសេដ្ឋស្ស បូជយឹ(២) ។

---

១ ឧ. វិត្តាយ នទិយា ។ ម. ចិត្តាយ នទិយា ។ ២ ម. ពុទ្ធសេដ្ឋំ អបូជយឹ ។



ឱ ! ខ្ញុំមកល្អហើយ ក្នុងសំណាក់ព្រះពុទ្ធរបស់ខ្ញុំ វិជ្ជា ៣ ខ្ញុំបានដល់ហើយ សាសនា របស់ព្រះពុទ្ធ ខ្ញុំបានធ្វើហើយ ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនា របស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ។

បានឮថា ព្រះកោសុម្ភផលិយត្ថេរ មានអាយុ បានសំដែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

ចប់ កោសុម្ភផលិយត្ថេរាបទាន ។

## កេតកបុប្ផិយត្ថេរាបទាន ទី ៤

(១០៤) ព្រះសម្ពុទ្ធជាបុរសខ្ពង់ខ្ពស់ ទ្រង់គង់នៅទៀបឆ្នេរស្ទឹងវិនតា ខ្ញុំបានឃើញព្រះពុទ្ធ ទ្រង់ប្រាសចាកធូលីគឺកិលេស មានព្រះហឫទ័យមូលក្នុងអារម្មណ៍តែមួយ មានព្រះហឫទ័យតំកល់មាំ ។ កាលនោះ ខ្ញុំមានចិត្តជ្រះថ្លា មានចិត្តរីករាយបានបូជាផ្កាកេត ដែលមានក្លិនក្រអូបចំពោះព្រះសម្ពុទ្ធដ៏ប្រសើរ ។

ឯកនវុតេ ឥតោ កប្បេ យំ បុប្ផំ អភិបូជយឹ
ទុគ្គតឹ នាភិជានាមិ ពុទ្ធបូជាយិទំ ផលំ ។
កិលេសា ឈាបិតា មយ្ហំ ភវា សព្វេ សមូហតា
នាគោវ ពន្ធនំ ឆេត្វា វិហរាមិ អនាសវោ ។
ស្វាគតំ វត មេ អាសិ មម ពុទ្ធស្ស សន្តិកេ
តិស្សោ វិជ្ជា អនុប្បត្តា កតំ ពុទ្ធស្ស សាសនំ ។
បដិសម្ភិទា ចតស្សោ វិមោក្ខាបិច អដ្ឋិមេ
ឆឡភិញ្ញា សច្ឆិកតា កតំ ពុទ្ធស្ស សាសនំ ។

ឥត្ថំ សុទំ អាយស្មា កេតកបុប្ផិយោ ថេរោ ឥមា គាថាយោ អភាសិត្ថាតិ ។

កេតកបុប្ផិយត្ថេរស្ស អបទានំ សមត្តំ ។



ក្នុងកប្បទី ៩១ អំពីកប្បនេះ ព្រោះហេតុដែលខ្ញុំបានបូជាផ្កាក្នុងកាលនោះ ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃពុទ្ធបូជា ។ កិលេសទាំងឡាយ ខ្ញុំដុតបំផ្លាញហើយ ភពទាំងអស់ ខ្ញុំដកចោលហើយ ខ្ញុំជាអ្នកមិនមានអាសវៈ ព្រោះបានកាត់ចំណង ដូចជាដំរីកាត់ផ្តាច់នូវទន្លីង ។ ឱ! ខ្ញុំមកល្អហើយ ក្នុងសំណាក់ព្រះពុទ្ធរបស់ខ្ញុំ វិជ្ជា ៣ ខ្ញុំបានដល់ហើយ សាសនា របស់ព្រះពុទ្ធ ខ្ញុំបានធ្វើហើយ ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនា របស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ។

បានឮថា ព្រះកេតកបុប្ផិយត្ថេរ មានអាយុ បានសំដែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

ចប់ កេតកបុប្ផិយត្ថេរាបទាន ។

# បញ្ចមំ នាគបុប្ផិយត្ថេរាបទានំ

[១០៨] សុវណ្ណវណ្ណំ សម្ពុទ្ធំ អាហុតីនំ បដិគ្គហំ
រថិយំ បដិបជ្ជន្តំ នាគបុប្ផំ អបូជយឹ ។
ឯកនវុតេ ឥតោ កប្បេ យំ បុប្ផមភិបូជយឹ
ទុគ្គតឹ នាភិជានាមិ ពុទ្ធបូជាយិទំ ផលំ ។
កិលេសា ឈាបិតា មយ្ហំ ភវា សព្វេ សមូហតា
នាគោវ ពន្ធនំ ឆេត្វា វិហរាមិ អនាសវោ ។
ស្វាគតំ វត មេ អាសិ មម ពុទ្ធស្ស សន្តិកេ
តិស្សោ វិជ្ជា អនុប្បត្តា កតំ ពុទ្ធស្ស សាសនំ ។
បដិសម្ភិទា ចតស្សោ វិមោក្ខាបិ ច អដ្ឋិមេ
ឆឡភិញ្ញា សច្ឆិកតា កតំ ពុទ្ធស្ស សាសនំ ។

ឥត្ថំ សុទំ អាយស្មា នាគបុប្ផិយោ ថេរោ ឥមា គាថាយោ អភាសិត្ថាតិ ។

នាគបុប្ផិយត្ថេរស្ស អបទានំ សមត្តំ ។

# នាគបុប្ផិយត្ថេរាបទាន ទី ៥

[១០៨] ខ្ញុំបានបូជាផ្កាខ្ទឹង ចំពោះព្រះសម្ពុទ្ធ ទ្រង់មានវណ្ណៈដូចមាស គួរទទួលនូវគ្រឿងបូជា កំពុងស្តេចទៅតាមច្រក ។ ក្នុងកប្បទី ៩១ អំពីកប្បនេះ ព្រោះហេតុដែលខ្ញុំបានបូជាផ្កា ក្នុងកាលនោះ ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃពុទ្ធបូជា ។ កិលេសទាំងឡាយ ខ្ញុំដុតបំផ្លាញហើយ ភពទាំងអស់ ខ្ញុំដកចោលហើយ ខ្ញុំជាអ្នកមិនមានអាសវៈ ព្រោះបានកាត់ចំណង ដូចជាដំរីកាត់ផ្តាច់ទន្លប់ខ្ទឹង ។ ឱ! ខ្ញុំមកល្អហើយ ក្នុងសំណាក់ព្រះពុទ្ធរបស់ខ្ញុំ វិជ្ជា ៣ ខ្ញុំបានដល់ហើយ សាសនា របស់ព្រះពុទ្ធ ខ្ញុំបានធ្វើហើយ ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនា របស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ។

បានឮថា ព្រះនាគបុប្ផិយត្ថេរ មានអាយុ បានសម្តែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

ចប់ នាគបុប្ផិយត្ថេរាបទាន ។

## ឆដ្ឋំ អជ្ជុនបុប្ផិយត្ថេរាបទានំ

(១០៦) ចន្ទភាគានទីតីរេ អហោសឹ កិន្នរោ តទា
អទ្ទសំ វិរជំ ពុទ្ធំ សយម្ភុំ អបរាជិតំ ។
បសន្នចិត្តោ សុមនោ វេទជាតោ កតញ្ជលី
គហេត្វា អជ្ជុនបុប្ផំ សយម្ភុំ អភិបូជយឹ ។
តេន កម្មេន សុកតេន ចេតនាបណិធីហិ ច
ជហិត្វា កិន្នរំ ទេហំ តាវត្តឹសំ អគញ្ឆហំ ។
ឆត្តឹសក្ខត្តុំ ទេវិន្ទោ ទេវរជ្ជមការយឹ
ទសក្ខត្តុំ ចក្កវត្តិ មហារជ្ជមការយឹ ។
បទេសរជ្ជំ វិបុលំ គណនាតោ អសង្ខិយំ
សុខេត្តេ វប្បិតំ(១) ពីជំ សយម្ភុស្មឹ អហោសិ មេ(២) ។
កុសលំ វិជ្ជតេ មយ្ហំ បព្វជឹ អនគារិយំ
បូជារហោ អហំ អជ្ជ សក្យបុត្តស្ស សាសនេ ។

---

១ ឱ. វីជិតំ ។ ២ ឱ. អហោ មមំ ។ ម. អហោ មម ។



## អជ្ជុនបុប្ផិយត្ថេរាបទាន ទី ៦

(១០៦) កាលនោះ ខ្ញុំកើតជាកិន្នរ នៅទៀបនទីស្ទឹងចន្ទភាគា បានឃើញព្រះពុទ្ធ ទ្រង់ប្រាសចាកធូលីគឺកិលេស ត្រាស់ដឹងដោយព្រះអង្គឯង ទ្រង់ឈ្នះមារ ។ ខ្ញុំមានចិត្តជ្រះថ្លា មានចិត្តរីករាយ កើតអរ ធ្វើនូវអញ្ជលីកម្ម បានយកផ្កាអជ្ជុន ទៅបូជាព្រះសយម្ភូ ។ ព្រោះអំពើដែលខ្ញុំធ្វើល្អនោះផង ព្រោះការតាំងចេតនានោះផង លុះខ្ញុំលះបង់នូវរាងកាយជាកិន្នរហើយ ក៏បានទៅកើត ក្នុងឋានតាវត្តិង្ស ។ ខ្ញុំជាធំជាងទេវតា បានសោយរាជ្យ ក្នុងទេវលោក អស់ ៣៦ ដង បានសោយរាជ្យ ជាស្តេចចក្រពត្តិមហារាជអស់ ១០ ដង ។ បានសោយប្រទេសរាជ្យ ដ៏ធំទូលាយ រាប់ជាតិមិនអស់ (ព្រោះ) ពូជ បានព្រោះក្នុងព្រះសយម្ភូ ជាស្រែដ៏ល្អ ។ ខ្ញុំមានកុសល ខ្ញុំបានបួសទៅកាន់ផ្នួស ខ្ញុំជាបុគ្គលគួរគេបូជា ក្នុងសាសនា នៃព្រះសក្យបុត្ត ក្នុងថ្ងៃនេះ ។

កិលេសា ឈាបិតា មយ្ហំ ភវា សព្វេ សមូហតា

នាគោវ ពន្ធនំ ឆេត្វា វិហរាមិ អនាសវោ ។

ស្វាគតំ វត មេ អាសិ មម ពុទ្ធស្ស សន្តិកេ

តិស្សោ វិជ្ជា អនុប្បត្តា កតំ ពុទ្ធស្ស សាសនំ ។

បដិសម្ភិទា ចតស្សោ វិមោក្ខាបិ ច អដ្ឋិមេ

ឆឡភិញ្ញា សច្ឆិកតា កតំ ពុទ្ធស្ស សាសនំ ។

ឥត្ថំ សុទំ អាយស្មា អជ្ជុនបុប្ផិយោ ថេរោ ឥមា គាថាយោ អភាសិត្ថាតិ ។

អជ្ជុនបុប្ផិយត្ថេរស្ស អបទានំ សមត្តំ ។

## សត្តមំ កុដិធូបបិយត្ថេរាបទានំ

(១០៧) ហិមវន្តស្សាវិទូរេ អច្ចុតោ(១) នាម បព្វតោ

ពុទ្ធោ សុទស្សនោ នាម វសតេ បព្វតន្តរេ ។

បុប្ផំ ហេមវន្តំ(២) គយ្ហ វេហាសំ អគមាសហំ

តត្ថទ្ទសាសឹ សម្ពុទ្ធំ ឱឃតិណ្ណមនាសវំ ។

---

១ ឱ. ជាវិណោ ។ ម. វិសណ្ណោ ។ ២ ឱ. ហេមវិកំ ។



កិលេសទាំងឡាយ ខ្ញុំដុតបំផ្លាញហើយ ភពទាំងអស់ ខ្ញុំដកចោលហើយ ខ្ញុំជាអ្នកមិនមានអាសវៈ ព្រោះបានកាត់ចំណង ដូចដំរីកាត់ផ្តាច់នូវចំណង ។ ឱ ! ខ្ញុំមកល្អហើយ ក្នុងសំណាក់ព្រះពុទ្ធរបស់ខ្ញុំ វិជ្ជា ៣ ខ្ញុំបានដល់ហើយ សាសនា របស់ព្រះពុទ្ធ ខ្ញុំបានធ្វើហើយ ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនា របស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ។

បានឮថា ព្រះអជ្ជុនបុប្ផិយត្ថេរ មានអាយុ បានសំដែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

ចប់ អជ្ជុនបុប្ផិយត្ថេរាបទាន ។

## កុដិធូបបិយត្ថេរាបទាន ទី ៧

(១០៧) ក្នុងទីជិតនៃព្រៃហិមពាន្ត មានភ្នំមួយឈ្មោះអច្ចុតៈ ព្រះសម្ពុទ្ធព្រះនាមសុទស្សនៈ គង់នៅក្នុងចន្លោះភ្នំនោះ ។ ខ្ញុំបានយកផ្កា អំពីព្រៃហិមពាន្ត ហើយទៅកាន់អាកាស បានឃើញព្រះសម្ពុទ្ធទ្រង់ឆ្លងឱឃៈ មិនមានអាសវៈ ក្នុងទីនោះ ។

បុប្ផំ កុដជមាទាយ   សិរេ កត្វាឧបាគ្គតា
ពុទ្ធស្ស អភិរោបេសឹ   សយម្ភុស្ស មហេសិនោ ។
ឯកត្តឹសេ ឥតោ កប្បេ   យំ បុប្ផមភិបូជយឹ
ទុគ្គតឹ នាភិជានាមិ   ពុទ្ធបូជាយិទំ ផលំ ។
កិលេសា ឈាបិតា មយ្ហំ   ភវា សព្វេ សមូហតា
នាគោវ ពន្ធនំ ឆេត្វា   វិហរាមិ អនាសវោ ។
ស្វាគតំ វត មេ អាសិ   មម ពុទ្ធស្ស សន្តិកេ
តិស្សោ វិជ្ជា អនុប្បត្តា   កតំ ពុទ្ធស្ស សាសនំ ។
បដិសម្ភិទា ចតស្សោ   វិមោក្ខាបិច អដ្ឋិមេ
ឆឡភិញ្ញា សច្ឆិកតា   កតំ ពុទ្ធស្ស សាសនំ ។

ឥត្ថំ សុទំ អាយស្មា កុដជបុប្ផិយោ ថេរោ ឥមា គាថាយោ អភាសិត្ថាតិ ។

កុដជបុប្ផិយត្ថេរស្ស អបទានំ សមត្តំ ។



កាលនោះ ខ្ញុំយកផ្កាអញ្ចាញខៀវ មកតំកល់លើក្បាល ហើយបូជាព្រះពុទ្ធ ទ្រង់ត្រាស់ដឹងឯង ទ្រង់ស្វែងរកនូវគុណដ៏ធំ ។ ក្នុងកប្បទី ៣១ អំពីកប្បនេះ ព្រោះហេតុដែលខ្ញុំបានបូជាផ្កាក្នុងកាលនោះ ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃពុទ្ធបូជា ។ កិលេសទាំងឡាយ ខ្ញុំដុតបំផ្លាញហើយ ភពទាំងអស់ ខ្ញុំដកចោលហើយ ខ្ញុំជាអ្នកមិនមានអាសវៈ ព្រោះបានកាត់បំណង ដូចជាដំរីកាត់ផ្តាច់នូវទន្លីង ។ ឱ ! ខ្ញុំមកល្អហើយក្នុងសំណាក់ព្រះពុទ្ធរបស់ខ្ញុំ វិជ្ជា ៣ ខ្ញុំបានដល់ហើយ សាសនា របស់ព្រះពុទ្ធ ខ្ញុំបានធ្វើហើយ ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនា របស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ។

បានឮថា ព្រះកុដជបុប្ផិយត្ថេរ មានអាយុ បានសំដែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

ចប់ កុដជបុប្ផិយត្ថេរាបទាន ។

## អដ្ឋមំ ឃោសសញ្ញកត្ថេរាបទានំ

[១០៨] មិគលុទ្ទោ បុរេ អាសឹ អរញ្ញេ វិបិនេ អហំ

អទ្ទសឹ វិរជំ ពុទ្ធំ ទេវសង្ឃបុរក្ខតំ ។

ចតុសច្ចំ បកាសេន្តំ ទេសេន្តំ អមតំ បទំ

អស្សោសឹ មធុរំ ធម្មំ សិខិនោ លោកពន្ធុនោ ។

ឃោសេ ចិត្តំ បសាទេសឹ អសមប្បដិបុគ្គលេ

តត្ថ ចិត្តំ បសាទេត្វា ឧត្តរឹ ទុត្តរំ ភវំ ។

ឯកត្តឹសេ ឥតោ កប្បេ យំ សញ្ញមលភឹ តទា

ទុគ្គតឹ នាភិជានាមិ ឃោសសញ្ញាយិទំ ផលំ ។

កិលេសា ឈាបិតា មយ្ហំ ភវា សព្វេ សមូហតា

នាគោវ ពន្ធនំ ឆេត្វា វិហរាមិ អនាសវោ ។

ស្វាគតំ វត មេ អាសិ មម ពុទ្ធស្ស សន្តិកេ

តិស្សោ វិជ្ជា អនុប្បត្តា កតំ ពុទ្ធស្ស សាសនំ ។

## ឃោសសញ្ញកត្ថេរាបទាន ទី ៨

[១០៨] ក្នុងកាលមុន ខ្ញុំកើតជាព្រានម្រឹគ នៅក្នុងព្រៃធំ ខ្ញុំបានឃើញព្រះពុទ្ធ ទ្រង់ប្រាសចាកធូលី មានពួកទេវតាចោមរោមហើយ កំពុងប្រកាសនូវសច្ច ៤ សំដែងនូវអមតបទ ។ ខ្ញុំបានស្តាប់ធម៌ដ៏ពីរោះ របស់ព្រះពុទ្ធ ព្រះនាមសិខី ជាផៅពង្សនៃសត្វលោក ។ ខ្ញុំធ្វើចិត្តឲ្យជ្រះថ្លាក្នុងឃោសសព្ទ របស់ព្រះសិខីសម្ពុទ្ធ ដែលរកបុគ្គលប្រៀបស្មើមិនមាន ខ្ញុំញុំាងចិត្តឲ្យជ្រះថ្លាក្នុងព្រះអង្គ ហើយបានឆ្លងនូវភព ដែលសត្វហែលឆ្លងបានដោយកម្រ ។ ក្នុងកប្បទី ៣១ អំពីកប្បនេះ ព្រោះហេតុដែលខ្ញុំបាននូវសញ្ញា ក្នុងកាលនោះ ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃឃោសសញ្ញា ។ កិលេសទាំងឡាយ ខ្ញុំដុតបំផ្លាញហើយ ភពទាំងអស់ ខ្ញុំដកចោលហើយ ខ្ញុំជាអ្នកមិនមានអាសវៈ ព្រោះបានកាត់ចំណង ដូចជាដំរីកាត់ផ្តាច់នូវចំណង ។ ឱ! ខ្ញុំមកល្អហើយ ក្នុងសំណាក់ព្រះពុទ្ធរបស់ខ្ញុំ វិជ្ជា ៣ ខ្ញុំបានដល់ហើយ សាសនារបស់ព្រះពុទ្ធ ខ្ញុំបានធ្វើហើយ ។

បដិសម្ភិទា ចតស្សោ វិមោក្ខាបិច អដ្ឋិមេ
ឆឡភិញ្ញា សច្ឆិកតា កតំ ពុទ្ធស្ស សាសនំ ។

ឥត្ថំ សុទំ អាយស្មា ឃោសសញ្ញកោ ថេរោ ឥមា គាថាយោ អភាសិត្ថាតិ ។

ឃោសសញ្ញកត្ថេរស្ស អបទានំ សមត្តំ ។

## នវមំ សព្វផលទាយកត្ថេរាបទានំ

(១០៩) វរុណោ នាម នាមេន ព្រាហ្មណោ មន្តបារគូ
ឆឌ្ឌេត្វា ទស បុត្តានិ វនមជ្ឈោគហឹ តទា ។
អស្សមំ សុកតំ កត្វា សុវិភត្តំ មនោរមំ
បណ្ណសាលំ ករិត្វាន វសាមិ បវនេ អហំ ។
បទុមុត្តរោ លោកវិទូ អាហុតីនំ បដិគ្គហោ
មមុទ្ធរិតុកាមោ សោ អាគញ្ឆិ មម អស្សមំ ។



បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនា របស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ។

បានឮថា ព្រះឃោសសញ្ញកត្ថេរ មានអាយុ បានសម្តែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

ចប់ ឃោសសញ្ញកត្ថេរាបទាន ។

## សព្វផលទាយកត្ថេរាបទាន ទី ៩

(១០៩) កាលនោះ ខ្ញុំកើតជាព្រាហ្មណ៍ ឈ្មោះវរុណៈ ជាអ្នកដល់ត្រើយនៃមន្ត បានលះបង់បុត្ត ១០ នាក់ ហើយដើរចូលទៅកាន់ព្រៃ ។ ខ្ញុំបានធ្វើអាស្រមដ៏ល្អ បានធ្វើបណ្ណសាលា ជាទីរីករាយនៃចិត្ត ដែលគេចាត់ចែងជាក់យ៉ាងល្អ នៅក្នុងព្រៃធំ ។ កាលនោះ ព្រះបទុមុត្តរសម្ពុទ្ធ ទ្រង់ជ្រាបច្បាស់នូវត្រៃលោក គួរទទួលគ្រឿងបូជា ព្រះអង្គមានសេចក្តីប្រាថ្នាដើម្បីស្រោចស្រង់ខ្ញុំ បានស្តេចមកកាន់អាស្រមរបស់ខ្ញុំ ។

យាវតា វនសណ្ឌម្ហិ ឱភាសោ វិបុលោ អហុ
ពុទ្ធស្ស អានុភាវេន បជ្ជលិ បវនំ តទា ។
ទិស្វាន បាដិហីរំ(១) ពុទ្ធសេដ្ឋស្ស តាទិនោ
បត្តបុដំ គហេត្វាន ឱលោនំ បូរយឹ(២) អហំ ។
ឧបគន្ត្វាន សម្ពុទ្ធំ សហ ទារិយតាសហំ
អនុកម្បាយ មេ ពុទ្ធោ ឥទំ វចនមព្រវិ ។
ទារិការំ គហេត្វាន បច្ឆតោ ឋបេ មេ តុវំ
បរិភុត្តេ សង្ឃម្ហិ បុញ្ញំ តវ ភវិស្សតិ ។
បុដកន្តំ គហេត្វាន ភិក្ខុសង្ឃស្សទាសហំ
តេន ចិត្តប្បសាទេន តុសិតំ ឧបបជ្ជហំ ។
តត្ថ ទិព្វេហិ នច្ចេហិ គីតេហិ វាទិតេហិ ច
បញ្ចកាមេហិ សំយុត្តា អនុភោមិ យសំ អហំ(៣) ។
យំ យំ យោនុបបជ្ជាមិ ទេវត្តំ អថ មានុសំ
ភោគេ មេ ឩនតា នត្ថិ ផលទានស្សិទំ ផលំ ។

---

១ ឱ. ទិស្វានហំ បាដិហីរំ ។ ម. ទិស្វាន តំ បាដិហីរំ ។ ២ ម. បូជយឹ ។ ៣ ឱ. សតា អហំ ។ ម. សតាសុខំ ។



ពន្លឺដ៏ទូលាយ ក្នុងដងព្រៃទាំងប៉ុន្មាន ក៏កើតមានឡើង កាលនោះព្រៃធំ ក៏ភ្លឺច្រាលដោយអានុភាព របស់ព្រះពុទ្ធ ។ ខ្ញុំឃើញបាដិហារ្យ របស់ព្រះពុទ្ធដ៏ប្រសើរ ព្រះអង្គមិនញាប់ញ័រដោយលោកធម៌ ខ្ញុំយកស្លឹកខ្ចប់ផ្លែឈើ ហើយកែកដេរមក ។ ខ្ញុំបានចូលទៅគាល់ព្រះសម្ពុទ្ធ ហើយថ្វាយផ្លែនោះទាំងអម្រែក ព្រះសម្ពុទ្ធទ្រង់អនុគ្រោះដល់ខ្ញុំ ទ្រង់ត្រាស់ព្រះពុទ្ធដីកានេះថា អ្នកចូរកែកនូវអម្រែក តាមក្រោយតថាគតមក កាលបើសង្ឃឆាន់ហើយ បុណ្យនឹងមានដល់អ្នក ។ ខ្ញុំយកកញ្ចប់នោះប្រគេនភិក្ខុសង្ឃ ខ្ញុំញុំាងចិត្តឲ្យជ្រះថ្លា ក្នុងព្រះសង្ឃនោះហើយ ក៏បានទៅកើតឯតុសិត ។ ខ្ញុំប្រកបដោយរបាំទិព្វ ចម្រៀងទិព្វ គ្រឿងប្រគំទិព្វ ក្នុងឋានសួគ៌នោះ ហើយសោយយសបរិវារ ដោយបញ្ចកាមនោះ ។ ខ្ញុំចូលទៅយកកំណើតណា ១ ទោះជាទេវតា ឬជាមនុស្ស ការខ្វះខាតភោគសម្បត្តិរបស់ខ្ញុំ មិនមាន នេះជាផលនៃផលទាន ។

យាវតា ចតុកេ ទីបា សសមុទ្ទា សបព្វតា
ផលំ ពុទ្ធស្ស ទត្វាន ឥស្សរំ ការយឹ អហំ(១) ។
យាវតា យេ(២) បក្ខិគណា អាកាសេ ឧប្បតន្តិ តេ
តេបិ មំ វសមន្វេន្តិ ផលទានស្សិទំ ផលំ ។
យាវតា វនសណ្ឌម្ហិ យក្ខា ភូតា ច រក្ខសា
កុម្ភណ្ឌា គរុឡា ចាបិ បាចរិយំ(៣) ឧបេន្តិ មេ ។
កុម្ភា សោណា(៤) មធុការ ឌំសា ច មកសា ឧភោ
តេបិ មំ វសមន្វេន្តិ ផលទានស្សិទំ ផលំ ។
សុបណ្ណា នាម សកុណា បក្ខិជាតា មហព្វលា
តេបិ មំ សរណំ យន្តិ ផលទានស្សិទំ ផលំ ។
យេបិ ទីឃាយុកា នាគា ឥទ្ធិមន្តោ មហាយសា
តេបិ មំ វសមន្វេន្តិ ផលទានស្សិទំ ផលំ ។
សីហា ព្យគ្ឃា ច ទីបី ច អច្ឆកោកតរច្ឆកា(៥)
តេបិ មំ វសមន្វេន្តិ ផលទានស្សិទំ ផលំ ។

---

១ ឱ.ម. ការយាមហំ ។ ២ ម. យេ ។ ៣ ឱ. ពារិយំ ។ ម. បារិយំ ។ ៤ ឱ. កុម្ភសោណា ។ ម. កុម្មសោណា ។ ៥ ឱ. អច្ឆកោកតរច្ឆយោ ។





ទ្វីបទាំង ៤ ព្រមទាំងសមុទ្រនិងភ្នំមានត្រឹមណា ខ្ញុំសោយឥស្សរភាព កំណត់ត្រឹមនោះ ព្រោះថ្វាយនូវផ្លែឈើ ចំពោះព្រះពុទ្ធ ។ ពួកបក្សី ទាំងប៉ុន្មានណា ហើរក្នុងអាកាស បក្សីទាំងនោះ តែងលុះក្នុងអំណាចរបស់ខ្ញុំ នេះជាផលនៃផលទាន ។ ពួកយក្ស ភូត រាក្សស កុម្ភណ្ឌ គ្រុឌ ទាំងប៉ុន្មាន ដែលនៅក្នុងដងព្រៃ តែងមកបម្រើខ្ញុំ ។ ពួកអណ្តើក ក្អែក ឃ្មុំ រំពាម មូស សត្វទាំងពួកនេះ តែងលុះក្នុងអំណាចរបស់ខ្ញុំ នេះជាផលនៃផលទាន ។ ពួកសត្វស្លាបឈ្មោះសុបណ្ណៈ ជាបក្សីមានកម្លាំងច្រើន សត្វទាំងនោះ តែងយកខ្ញុំជាទីពឹង នេះជាផលនៃផលទាន ។ ពួកនាគណា មានអាយុវែង មានឫទ្ធិ មានយសធំ នាគទាំងនោះឯងតែងលុះក្នុងអំណាចរបស់ខ្ញុំ នេះជាផលនៃផលទាន ។ ពួកសត្វសីហៈ ខ្លាធំ ខ្លាដំបង ខ្លាឃ្មុំ ឆ្កែស្រុក ឆ្កែព្រៃ សត្វទាំងនោះឯង តែងលុះក្នុងអំណាចរបស់ខ្ញុំ នេះជាផលនៃផលទាន ។

ឱសធិតិណវាសី ច យេ ច អាកាសវាសិនោ
សព្វេ មំ សរណំ យន្តិ ផលទានស្សិទំ ផលំ ។
សុទុទ្ទសំ សុនិបុណំ គម្ភីរំ សុប្បកាសិតំ
ផុសយិត្វា(១) វិហរាមិ ផលទានស្សិទំ ផលំ ។
វិមោក្ខេ អដ្ឋ ផុសិត្វា(២) វិហរាមិ អនាសវោ
អាតាបី និបកោ ចាបិ(៣) ផលទានស្សិទំ ផលំ ។
យេ ផលដ្ឋា ពុទ្ធបុត្តា ខីណទោសា មហាយសា
អហំ អញ្ញតរោ តេសំ ផលទានស្សិទំ ផលំ ។
អភិញ្ញាបារមី គតា សុក្កមូលេន ចោទិតោ
សព្វាសវេ បរិញ្ញាយ វិហរាមិ អនាសវោ ។
តេវិជ្ជា ឥទ្ធិបត្តា ច ពុទ្ធបុត្តា មហាយសា
ទិព្វសោតសមាបន្នា តេសំ អញ្ញតរោ អហំ ។

១ ឱ. ផស្សិត្វាន ។ ២ ម. ផស្សិត្វា ។ ៣ ឱ.ម. ចាហំ ។



ពួកទេវតាណា ដែលឋិតនៅលើដើមឈើនិងស្មៅក្តី ឋិតនៅក្នុងអាកាសក្តី ទេវតាទាំងអស់នោះឯង តែងយកខ្ញុំជាទីពឹង នេះជាផលនៃផលទាន ។ ខ្ញុំបានសម្រេចធម៌ដែលគេឃើញបានដោយកម្រ ជាធម៌ល្អិតជ្រាលជ្រៅ ដែលព្រះពុទ្ធទ្រង់ប្រកាសល្អហើយ នេះជាផលនៃផលទាន ។ ខ្ញុំបានវិមោក្ខ ៨ ជាអ្នកមិនមានអាសវៈ មានព្យាយាមដុតកំដៅកិលេស មានប្រាជ្ញាចាស់ នេះជាផលនៃផលទាន ។ ពួកពុទ្ធបុត្តណា ដែលឋិតនៅក្នុងផល អស់ទោសៈហើយ មានយសច្រើន បណ្តាពុទ្ធបុត្តទាំងនោះ ខ្ញុំក៏ជាពុទ្ធបុត្តមួយដែរ នេះជាផលនៃផលទាន ។ ខ្ញុំបានសម្រេចអភិញ្ញាបារមី ត្រូវកុសលមូល ដាស់តឿនហើយ ក៏បានកំណត់ដឹងនូវអាសវៈទាំងអស់ ជាអ្នកមិនមានអាសវៈ ។ ពុទ្ធបុត្តណា មានវិជ្ជា ៣ សម្រេចនូវឫទ្ធិ មានយសច្រើន សម្រេចនូវទិព្វសោត បណ្តាពុទ្ធបុត្តទាំងនោះ ខ្ញុំក៏ជាពុទ្ធបុត្តមួយដែរ ។

សតសហស្សេ ឥតោ កប្បេ យំ ផលំ អទទឹ តទា
ទុគ្គតឹ នាភិជានាមិ ផលទានស្សិទំ ផលំ ។
កិលេសា ឈាបិតា មយ្ហំ ភវា សព្វេ សមូហតា
នាគោវ ពន្ធនំ ឆេត្វា វិហរាមិ អនាសវោ ។
ស្វាគតំ វត មេ អាសិ មម ពុទ្ធស្ស សន្តិកេ
តិស្សោ វិជ្ជា អនុប្បត្តា កតំ ពុទ្ធស្ស សាសនំ ។
បដិសម្ភិទា ចតស្សោ វិមោក្ខាបិច អដ្ឋិមេ
ឆឡភិញ្ញា សច្ឆិកតា កតំ ពុទ្ធស្ស សាសនន្តិ ។

ឥត្ថំ សុទំ អាយស្មា សព្វផលទាយកោ ថេរោ ឥមា គាថាយោ អភាសិត្ថាតិ ។

សព្វផលទាយកត្ថេរស្ស អបទានំ សមត្តំ ។



ក្នុងកប្បទីមួយសែន អំពីកប្បនេះ ព្រោះហេតុដែលខ្ញុំបានថ្វាយផ្លែឈើ ក្នុងកាលនោះ ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃផលទាន ។ កិលេសទាំងឡាយ ខ្ញុំដុតបំផ្លាញហើយ ភពទាំងអស់ ខ្ញុំដកចោលហើយ ខ្ញុំជាអ្នកមិនមានអាសវៈ ព្រោះបានកាត់ចំណង ដូចជាដំរីកាត់ផ្តាច់នូវចំណង ។ ឱ! ខ្ញុំមកល្អហើយ ក្នុងសំណាក់ព្រះពុទ្ធរបស់ខ្ញុំ វិជ្ជា ៣ ខ្ញុំបានដល់ហើយ សាសនា របស់ព្រះពុទ្ធ ខ្ញុំបានធ្វើហើយ ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនា របស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ។

បានឮថា ព្រះសព្វផលទាយកត្ថេរ មានអាយុ បានសំដែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

ចប់ សព្វផលទាយកត្ថេរបទាន ។

## ទសមំ បទុមធារិយត្ថេរាបទានំ

(១១០) ហិមវន្តស្ស អវិទូរេ រោមសោ នាម បព្វតោ
ពុទ្ធោភិសម្ភវោ នាម(១) អព្ភោកាសេ វសី តទា ។
ភវនា និក្ខមិត្វាន បទុមំ ធារយឹ អហំ
ឯកាហំ ធារយិត្វាន ឃរំ បុនាគមឹ ។
ឯកត្តឹសេ ឥតោ កប្បេ យំ ពុទ្ធមភិបូជយឹ
ទុគ្គតឹ នាភិជានាមិ ពុទ្ធបូជាយិទំ ផលំ ។
កិលេសា ឈាបិតា មយ្ហំ ភវា សព្វេ សមូហតា
នាគោវ ពន្ធនំ ឆេត្វា វិហរាមិ អនាសវោ ។
ស្វាគតំ វត មេ អាសិ មម ពុទ្ធស្ស សន្តិកេ
តិស្សោ វិជ្ជា អនុប្បត្តា កតំ ពុទ្ធស្ស សាសនំ ។
បដិសម្ភិទា ចតស្សោ វិមោក្ខាបិច អដ្ឋិមេ
ឆឡភិញ្ញា សច្ឆិកតា កតំ ពុទ្ធស្ស សាសនន្តិ ។

១ ម.ម. ពុទ្ធោបិសម្ភវោ នាម ។

## បទុមធារិយត្ថេរាបទាន ទី ១០

(១១០) ក្បែរទីជិតព្រៃហិមពាន្ត មានភ្នំមួយឈ្មោះ រោមសៈ កាលនោះ ព្រះសម្ពុទ្ធព្រះនាមអភិសម្ភវៈ ទ្រង់គង់ក្នុងទីវាលជិតភ្នំនោះ ។ ខ្ញុំចេញអំពីលំនៅ បានយកផ្កាឈូកបាំងថ្វាយព្រះអង្គ លុះខ្ញុំយកផ្កាឈូកមួយបាំងថ្វាយអស់មួយថ្ងៃហើយ ខ្ញុំត្រឡប់មកកាន់លំនៅវិញ ។ ក្នុងកប្បទី ៣១ អំពីកប្បនេះ ព្រោះហេតុដែលខ្ញុំបានបូជាព្រះពុទ្ធ ក្នុងកាលនោះ ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃពុទ្ធបូជា ។ កិលេសទាំងឡាយ ខ្ញុំដុតបំផ្លាញហើយ ភពទាំងអស់ ខ្ញុំដកចោលហើយ ខ្ញុំជាអ្នកមិនមានអាសវៈ ព្រោះបានកាត់ចំណង ដូចជាដំរីកាត់ផ្តាច់នូវចំណង ។ ឱ! ខ្ញុំមកល្អហើយ ក្នុងសំណាក់ព្រះពុទ្ធរបស់ខ្ញុំ វិជ្ជា ៣ ខ្ញុំបានដល់ហើយ សាសនា របស់ព្រះពុទ្ធ ខ្ញុំបានធ្វើហើយ ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនា របស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ។

ឥត្ថំ សុទំ អាយស្មា បទុមច្ឆទនិយោ(១) ថេរោ ឥមា គាថាយោ អភាសិត្ថាតិ ។

បទុមច្ឆទនិយត្ថេរស្ស អបទានំ សមត្តំ ។

## ឧទ្ទានំ

កុរញ្ជិយ(២) កបិដ្ឋញ្ច  កោសុម្ពំ អថ កេតកី(៣)
នាគបុប្ផជ្ជុនញ្ចេវ  កុដជី ឃោសសញ្ញកោ ។
ថេរោ ច សព្វផលទោ  តថា បទុមធារិយោ(៤)
អសីតិ ចេត្ថ គាថាយោ  តិស្សោ គាថា តទុត្តរិ ។

ផលទាយកវគ្គោ ទ្វេបញ្ញាសោ

១ ឱ. បទុមធារិកោ ។ ២ ឱ. កុរញ្ជិយំ ។ ម. កុរញ្ជិយំ ។ ៣ ម. កោសម្ពមថ កេតកំ ។
៤ ឱ. បទុមធារិកោ ។





បានឮថា ព្រះបទុមច្ឆាទិយត្ថេរ មានអាយុ បានសម្តែងនូវគាថា ទាំងនេះ ដោយប្រការដូច្នេះ ។

ចប់ បទុមច្ឆាទិយត្ថេរបទាន ។

## ឧទ្ទាន

កុរញ្ជិយផលទាយកត្ថេរបទាន ១ កបិដ្ឋផលទាយកត្ថេរបទាន ១ កោសុម្ពផលិយត្ថេរបទាន ១ កេតកបុប្ផិយត្ថេរបទាន ១ នាគបុប្ផិយត្ថេរបទាន ១ អជ្ជុនបុប្ផិយត្ថេរបទាន ១ កុដជបុប្ផិយត្ថេរបទាន ១ ឃោសសញ្ញកត្ថេរបទាន ១ សព្វផលទាយកត្ថេរបទាន ១ បទុមច្ឆាទិយត្ថេរបទាន ១ រួមគាថាក្នុងវគ្គនេះ មាន ៨៣ គាថា ។

ចប់ ផលទាយកវគ្គ ទី ៥២ ។

# តេបញ្ញាសោ តិណទាយវគ្គោ

## បឋមំ តិណមុដ្ឋិទាយកត្ថេរាបទានំ

(១១១) ហិមវន្តស្ស អវិទូរេ លម្ពកោ នាម បព្វតោ
តត្ថេវ តិស្សោ[១] សម្ពុទ្ធោ អព្ភោកាសម្ហិ ចង្កមិ ។
មិគលុទ្ទោ បុរេ អាសិំ អរញ្ញេ កាននេ អហំ
ទិស្វាន តំ ទេវទេវំ តិណមុដ្ឋិមទាសហំ
និសីទនត្ថំ ពុទ្ធស្ស ទត្វា ចិត្តំ បសាទយិំ
សម្ពុទ្ធំ អភិវាទេត្វា[២] បក្កាមិំ ឧត្តរាមុខោ ។
អចិរំ គតមត្តំ មំ[៣] មិគរាជា អបោថយិ
សីហេន បោថិតោ[៤] សន្តោ តត្ថ កាលំ កតោ អហំ ។
អាសន្នេ មេ កតំ កម្មំ ពុទ្ធសេដ្ឋេ អនាសវេ
សុមុត្តោ សរវេគោវ ទេវលោកំ អគញ្ឆហំ ។

---

១ ឱ. ម. កក្ខុបតិស្សោ ។ ២ ឱ.ម. អភិវន្ទិត្វា ។ ៣ ឱ អចិរំគតមត្តស្ស អចិរំ គត. មត្តស្ស ។ ៤ ឱ. បេថិតោ ។ ម. មថិតោ ។

# តិណទាយកវគ្គទី ៥៣

## តិណមុដ្ឋិទាយកត្ថេរាបទាន ទី ១

(១១១) នៅជិតភ្នំហិមពាន្ត មានភ្នំមួយឈ្មោះលម្ពកៈ ព្រះតិស្សសម្ពុទ្ធ ស្ដេចចង្ក្រមនាទីកំលវាលភ្នំនោះ ។ ក្នុងកាលមុន ខ្ញុំកើតជាព្រានម្រឹគនៅក្នុងព្រៃធំ ខ្ញុំបានឃើញព្រះសម្ពុទ្ធ ជាទេវតាក្រៃលែងជាងទេវតា ខ្ញុំបានថ្វាយស្មៅមួយក្ដាប់ ។ លុះខ្ញុំបានថ្វាយស្មៅដល់ព្រះសម្ពុទ្ធ ដើម្បីគង់ ហើយញុំាងចិត្តឲ្យជ្រះថ្លា បានថ្វាយបង្គំព្រះសម្ពុទ្ធ រួចបែរមុខទៅកាន់ឧត្តរទិស ដើរចេញទៅ ។ ស្រាប់តែមានស្ដេចម្រឹគមកបៀតបៀនខ្ញុំ ដែលទើបនឹងដើរទៅភ្លាម ខ្ញុំត្រូវសត្វសីហៈ បៀតបៀនហើយ ក៏ធ្វើមរណកាល ក្នុងទីនោះ ។ អាសន្នកម្មដែលខ្ញុំធ្វើហើយ ចំពោះព្រះសម្ពុទ្ធដ៏ប្រសើរ ព្រះអង្គមិនមានអាសវៈ ខ្ញុំក៏បានទៅកើតក្នុងទេវលោក ដូចកំឡាំងកូនសរដែលផុតស្រឡះ (ចាកបំពង់ព្រួញ) ។

យូបោ តត្ថ សុកោ អាសិ បុញ្ញកម្មាភិនិម្មិតោ
សហស្សកណ្ឌោ សតភេណ្ឌូ ធជាលុ ហរិតាមយោ ។
បភានិទ្ធាវតេ តស្ស សតរំសីវ ឧគ្គតោ
អាកិណ្ណោ ទេវកញ្ញាហិ អាមោទិំ កាមកាមហំ ។
ទេវលោកា ចវិត្វាន សុក្កមូលេន ចោទិតោ
អាគន្ត្វាន មនុស្សត្តំ បត្តោម្ហិ អាសវក្ខយំ ។
ចតុន្នវុតេ ឥតោ កប្បេ និសីធនមកាសហំ(១)
ទុគ្គតឹ នាភិជានាមិ តិណមុដ្ឋេ ឥទំ ផលំ ។
កិលេសា ឈាបិតា មយ្ហំ ភវា សព្វេ សមូហតា
នាគោវ ពន្ធនំ ឆេត្វា វិហរាមិ អនាសវោ ។
ស្វាគតំ វត មេ អាសិ មម ពុទ្ធស្ស សន្តិកេ
តិស្សោ វិជ្ជា អនុប្បត្តា កតំ ពុទ្ធស្ស សាសនំ ។

១ ឱ. ម. និសីទនមកាសហំ ។



ប្រាសាទដ៏ល្អ ដែលបុញ្ញកម្មនិម្មិតហើយ ក្នុងទេវលោកនោះ មានកំពស់មួយពាន់សន្ទុះព្រួញ មានជាន់ ៧ បរិបូណ៌ដោយទង់ បិទបាំងដោយកែវមណីខៀវ ។ ពន្លឺរបស់ប្រាសាទនោះ តែងផ្សាយចេញ ដូចព្រះអាទិត្យដែលរះឡើង ប្រាសាទនោះ កុះករដោយទេវកញ្ញា ខ្ញុំពេញចិត្តត្រេកអរក្នុងកាម ។ ខ្ញុំច្យុតចាកទេវលោក ត្រូវកុសលមូលដាស់តឿន បានមកកាន់អត្តភាពជាមនុស្ស ក៏បានដល់នូវការអស់ទៅនៃអាសវៈ ។ ក្នុងកប្បទី ៩៤ អំពីកប្បនេះ ព្រោះហេតុដែលខ្ញុំបានធ្វើកម្រាលអង្គុយ ក្នុងកាលនោះ ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃស្មៅមួយក្តាប់ ។ កិលេសទាំងឡាយ ខ្ញុំដុតបំផ្លាញហើយ ភពទាំងពួង ខ្ញុំដកចោលអស់ហើយ ខ្ញុំជាអ្នកមិនមានអាសវៈ ព្រោះបានកាត់បំណង់ ដូចជាដំរីកាត់ផ្តាច់នូវទន្ទឹង ។ ឱ ! ខ្ញុំមកល្អហើយ ក្នុងសំណាក់ព្រះពុទ្ធរបស់ខ្ញុំ វិជ្ជា ៣ ខ្ញុំបានដល់ហើយ សាសនារបស់ព្រះពុទ្ធ ខ្ញុំបានធ្វើហើយ ។

បដិសម្ភិទា ចតស្សោ វិមោក្ខាបិ ច អដ្ឋិមេ

ឆឡភិញ្ញា សច្ឆិកតា កតំ ពុទ្ធស្ស សាសនំ ។

ឥត្ថំ សុទំ អាយស្មា តិណមុដ្ឋិទាយកោ ថេរោ ឥមា

គាថាយោ អភាសិត្ថាតិ ។

តិណមុដ្ឋិទាយកត្ថេរស្ស អបទានំ សមត្តំ ។

## ទុតិយំ វច្ចកទាយកត្ថេរាបទានំ

(១១៤) វិបស្សិនោ ភគវតោ លោកជេដ្ឋស្ស តាទិនោ

ឯកំ វច្ចំ(១) មយា ទិន្នំ បសន្នេន សបាណិនា ។

ហត្ថិយានំ អស្សយានំ ទិព្វយានំ សមជ្ឈគំ

តេន វច្ចកទានេន(២) បត្តោម្ហិ អាសវក្ខយំ ។

ឯកនវុតេ ឥតោ កប្បេ យំ វច្ចមទទឹ(៣) តទា

ទុគ្គតឹ នាភិជានាមិ វច្ចទានស្សិទំ ផលំ ។

១ ឱ. ឯកបេច្ចំ ។ ម. ឯកមញ្ចំ ។ ២ ឱ. បេច្ចកទានេន ។ ម. មញ្ចកទានេន ។ ៣ ឱ. បេច្ចមទទឹ ។ ម. មញ្ចមទទឹ ។



បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនា របស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ។

បានឮថា ព្រះតិណមុដ្ឋិទាយកត្ថេរ មានអាយុ បានសំដែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

ចប់ តិណមុដ្ឋិទាយកត្ថេរាបទាន ។

## វច្ចកទាយកត្ថេរាបទាន ទី ២

(១១៤) ខ្ញុំមានចិត្តជ្រះថ្លា បានថ្វាយបង្គន់មួយដោយដៃរបស់ខ្លួន ចំពោះព្រះមានព្រះភាគ ព្រះនាមវិបស្សី ជាច្បងក្នុងលោក ជាតាទិបុគ្គល ។ ខ្ញុំបានយានដំរី យានសេះ យានទិព្វ ហើយបានដល់នូវធម៌ជាទីក្ស័យនៃអាសវៈ ដោយសារការថ្វាយនូវបង្គន់នោះ ។ ក្នុងកប្បទី ៩១ អំពីកប្បនេះ ព្រោះហេតុ ដែលខ្ញុំបានថ្វាយបង្គន់ ក្នុងកាលនោះ ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផល នៃការថ្វាយបង្គន់ ។

កិលេសា ឈាបិតា មយ្ហំ ភវា សព្វេ សមូហតា
នាគោវ ពន្ធនំ ឆេត្វា វិហរាមិ អនាសវោ ។
ស្វាគតំ វត មេ អាសិ មម ពុទ្ធស្ស សន្តិកេ
តិស្សោ វិជ្ជា អនុប្បត្តា កតំ ពុទ្ធស្ស សាសនំ ។
បដិសម្ភិទា ចតស្សោ វិមោក្ខាបិ ច អដ្ឋិមេ
ឆឡភិញ្ញា សច្ឆិកតា កតំ ពុទ្ធស្ស សាសនំ ។

ឥត្ថំ សុទំ អាយស្មា វច្ឆកាយនោ(១) ថេរោ
ឥមា គាថាយោ អភាសិត្ថាតិ ។

វច្ឆកាយនត្ថេរស្ស(២) អបទានំ សមត្តំ ។

## តតិយំ សរណគមនិយត្ថេរាបទានំ

(១១៣) អារុយ្ហិម្ហ(៣) តទា នាវំ ភិក្ខុ ចាជីវកោ ចហំ(៤)
នាវាយ ភិជ្ជមានាយ ភិក្ខុ មេ សរណំ អទា ។

---

១ ឱ. វច្ឆាយនោ ។ ម. បញ្ចាយនោ ។ ២ ឱ. វច្ឆាយនត្ថេរស្ស ។ ម. បញ្ចាយនត្ថេរស្ស ។ ៣ ឱ. អារុហិម្ហ ។ ម. អារុហិម្ហិ ។ ៤ ឱ. ម. ចហំ ។



កិលេសទាំងឡាយ ខ្ញុំដុតបំផ្លាញហើយ ភពទាំងអស់ ខ្ញុំដកចោលហើយ ខ្ញុំជាអ្នកមិនមានអាសវៈ ព្រោះបានកាត់ចំណង ដូចជាដំរីកាត់ផ្តាច់ខ្នោះចេញ ។ ឱ ! ខ្ញុំមកល្អហើយ ក្នុងសំណាក់ព្រះពុទ្ធរបស់ខ្ញុំ វិជ្ជា ៣ ខ្ញុំបានដល់ហើយ សាសនា របស់ព្រះពុទ្ធ ខ្ញុំបានធ្វើហើយ ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនា របស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ។

បានឮថា ព្រះវច្ឆកាយនត្ថេរ មានអាយុ បានសម្តែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

ចប់ វច្ឆកាយនត្ថេរាបទាន ។

## សរណគមនិយត្ថេរាបទាន ទី ៣

(១១៣) ក្នុងកាលនោះ ភិក្ខុនិងខ្ញុំជាអ្នកប្រកបការចិញ្ចឹមជីវិត បានឡើងជិះសំពៅទៅជាមួយគ្នា កាលដែលសំពៅធ្លាយហើយ ភិក្ខុបានឲ្យសរណគមន៍ដល់ខ្ញុំ ។

ឯកត្តឹសេ ឥតោ កប្បេ យំ សោ មេ សរណំ គតោ

ទុគ្គតឹ នាភិជានាមិ សរណាគមនេ(១) ផលំ ។

កិលេសា ឈាបិតា មយ្ហំ ភវា សព្វេ សមូហតា

នាគោវ ពន្ធនំ ឆេត្វា វិហរាមិ អនាសវោ ។

ស្វាគតំ វត មេ អាសិ មម ពុទ្ធស្ស សន្តិកេ

តិស្សោ វិជ្ជា អនុប្បត្តា កតំ ពុទ្ធស្ស សាសនំ ។

បដិសម្ភិទា ចតស្សោ វិមោក្ខាបិច អដ្ឋិមេ

ឆឡភិញ្ញា សច្ឆិកតា កតំ ពុទ្ធស្ស សាសនំ ។

ឥត្ថំ សុទំ អាយស្មា សរណាគមនិយោ ថេរោ ឥមា គាថាយោ អភាសិត្ថាតិ ។

សរណាគមនិយត្ថេរស្ស អបទានំ សមត្តំ ។

---

១ ឱ. សរណគមនេ ។



ក្នុងកប្បទី ៣១ អំពីកប្បនេះ ព្រោះហេតុដែលភិក្ខុនោះបាន ឲ្យសរណគមន៍ដល់ខ្ញុំក្នុងកាលនោះ ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃសរណគមន៍ ។ កិលេសទាំងឡាយ ខ្ញុំដុត បំផ្លាញហើយ ភពទាំងអស់ ខ្ញុំដកហូតហើយ ខ្ញុំជាអ្នក មិនមានអាសវៈ ព្រោះបានកាត់ចំណង ដូចជាដំរីកាត់ផ្តាច់ នូវទន្លីង ។ ឱ ! ខ្ញុំមកល្អហើយ ក្នុងសំណាក់ព្រះពុទ្ធរបស់ ខ្ញុំ វិជ្ជា ៣ ខ្ញុំបានដល់ហើយ សាសនា របស់ព្រះពុទ្ធ ខ្ញុំ បានធ្វើហើយ ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនា របស់ ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ។

បានឮថា ព្រះសរណគមនិយត្ថេរ មានអាយុ បានសម្តែងនូវ គាថាទាំងនេះ ដោយប្រការដូច្នេះ ។

ចប់ សរណគមនិយត្ថេរាបទាន ។

# ចតុត្ថំ អព្ភញ្ជនទាយកត្ថេរាបទានំ

(១១៤) នគរេ ពន្ធុមតិយា រាជុយ្យានេ វសាមហំ
ចម្មវាសី(១)តទា អាសឹ កមណ្ឌលុធរោ អហំ ។
អទ្ទសំ វិរជំ ពុទ្ធំ សយម្ភុំ អបរាជិតំ
អាតាបឹ បហិតត្តំ(២) ឈាយឹ ឈានរតំ ឥសឹ(៣) ។
សព្វកាមសមិទ្ធិញ្ច ឱឃតិណ្ណមនាសវំ
ទិស្វា បសន្នសុមនោ អព្ភញ្ជនមទាសហំ ។
ឯកនវុតេ ឥតោ កប្បេ យំ ទានមទទឹ តទា
ទុគ្គតឹ នាភិជានាមិ អព្ភញ្ជនស្សិទំ ផលំ ។
កិលេសា ឈាបិតា មយ្ហំ ភវា សព្វេ សមូហតា ។
នាគោវ ពន្ធនំ ឆេត្វា វិហរាមិ អនាសវោ ។

១ ឱ. ចម្មវាសី ។ ២ ឱ. បធានបហិតត្តំ ។ ម. បធានំ បហិតត្តំ ។ ៣ ឱ.ម. វសឹ ។



# អព្ភញ្ជនទាយកត្ថេរាបទាន ទី ៤

[១១៤] ខ្ញុំនៅក្នុងព្រះរាជឧទ្យាន ក្បែរក្រុងពន្ធុមតី កាលនោះ ខ្ញុំស្លៀកសំពត់ស្បែក ទ្រទ្រង់ល័ក្តពាន់ ។ ខ្ញុំបានឃើញព្រះសម្ពុទ្ធ ទ្រង់ប្រាសចាកធូលីគឺកិលេស ជាព្រះសយម្ភូ ទ្រង់ឈ្នះកិលេស មានព្យាយាមជាគ្រឿងដុតកំដៅនូវកិលេស មានព្រះហឫទ័យបញ្ជូនទៅកាន់ព្រះនិព្វាន ទ្រង់ជាឥសី ទ្រង់មានឈាន ត្រេកអរក្នុងឈាន ។ លុះខ្ញុំឃើញព្រះសម្ពុទ្ធ ទ្រង់សម្រេចសេចក្តីប្រាថ្នាទាំងពួងផង ទ្រង់ឆ្លងនូវអន្លង់ ទាំងមិនមានអាសវៈផង ក៏មានចិត្តជ្រះថ្លា មានចិត្តរីករាយ បានថ្វាយថ្នាំបន្តក់ភ្នែក ។ ក្នុងកប្បទី ៩១ អំពីកប្បនេះ ព្រោះហេតុដែលខ្ញុំ បានឲ្យទានក្នុងកាលនោះ ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃថ្នាំបន្តក់ភ្នែក ។ កិលេសទាំងឡាយ ខ្ញុំដុតបំផ្លាញហើយ ភពទាំងអស់ ខ្ញុំដកចោលហើយ ខ្ញុំជាអ្នកមិនមានអាសវៈ ព្រោះបានកាត់ចំណង ដូចដំរីកាត់ផ្តាច់នូវចំណង ។

ស្វាគតំ វត មេ អាសិ    មម ពុទ្ធស្ស សន្តិកេ

តិស្សោ វិជ្ជា អនុប្បត្តា    កតំ ពុទ្ធស្ស សាសនំ ។

បដិសម្ភិទា ចតស្សោ    វិមោក្ខាបិ ច អដ្ឋិមេ

ឆឡភិញ្ញា សច្ឆិកតា    កតំ ពុទ្ធស្ស សាសនំ ។

ឥត្ថំ សុទំ អាយស្មា អគ្គញ្ញទាយកោ ថេរោ

ឥមា គាថាយោ អភាសិត្ថាតិ ។

អគ្គញ្ញទាយកត្ថេរស្ស អបទានំ សមត្តំ ។

## បញ្ចមំ សុបដិទាយកត្ថេរាបទានំ

(១១៩) ទិវាវិហារា និក្ខន្តោ វិបស្សី លោកនាយកោ

លហុំ សុបដិកំ ទត្វា[១]    កប្បំ សគ្គម្ហិ មោទហំ ។

ឯកនវុតេ ឥតោ កប្បេ    យំ សុបដិកមទាសហំ[២]

ទុគ្គតឹ នាភិជានាមិ    សុបដស្ស ឥទំ ផលំ ។

---

១ ម. លហុំ សុបដំ ទត្វា ។ ២ ម. សុបដំ អទាសហំ ។



១ ខ្ញុំមកល្អហើយ ក្នុងសំណាក់ព្រះពុទ្ធរបស់ខ្ញុំ វិជ្ជា ៣ ខ្ញុំបានដល់ហើយ សាសនា របស់ព្រះពុទ្ធ ខ្ញុំបានធ្វើហើយ ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនា របស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ។

បានឮថា ព្រះអគ្គញ្ញទាយកត្ថេរ មានអាយុ បានសម្តែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

ចប់ អគ្គញ្ញទាយកត្ថេរាបទាន ។

## សុបដិទាយកត្ថេរាបទាន ទី ៥

(១១៩) ព្រះលោកនាយក ព្រះនាមវិបស្សី ចេញអំពីកន្លែងសម្រាកក្នុងវេលាថ្ងៃ ខ្ញុំបានថ្វាយសំពត់មានសាច់ស្តើង ហើយបានរីករាយក្នុងឋានសួគ៌ អស់មួយកប្ប ។ ក្នុងកប្បទី ៩១ អំពីកប្បនេះ ព្រោះហេតុដែលខ្ញុំបានថ្វាយសំពត់ដ៏ល្អ ក្នុងកាលនោះ ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃសំពត់ ។

កិលេសា ឈាបិតា មយ្ហំ ភវា សព្វេ សមូហតា
នាគោវ ពន្ធនំ ឆេត្វា វិហរាមិ អនាសវោ ។
ស្វាគតំ វត មេ អាសិ ពុទ្ធសេដ្ឋស្ស សន្តិកេ
តិស្សោ វិជ្ជា អនុប្បត្តា កតំ ពុទ្ធស្ស សាសនំ ។
បដិសម្ភិទា ចតស្សោ វិមោក្ខាបិច អដ្ឋិមេ
ឆឡភិញ្ញា សច្ឆិកតា កតំ ពុទ្ធស្ស សាសនន្តិ ។

ឥត្ថំ សុទំ អាយស្មា សុបដាយកោ(១) ថេរោ ឥមា គាថាយោ អភាសិត្ថាតិ ។

សុបដាយកត្ថេរស្ស អបទានំ សមត្តំ ។

## ឆដ្ឋំ ទណ្ឌទាយកត្ថេរាបទានំ

(១១៦) កាននំ វនមោគយ្ហ វេឡុំ ឆេត្វានហំ តទា
អាលម្ពនំ ករិត្វាន(២) សង្ឃស្ស អទទឹ អហំ(៣) ។

១ ឱ. សូបប្បទាយកោ ។ ២ ឱ. ករោត្វាន ។ ៣ ម. ពទុំ ។



កិលេសទាំងឡាយ ខ្ញុំដុតបំផ្លាញហើយ ភពទាំងអស់ ខ្ញុំដកចោលហើយ ខ្ញុំជាអ្នកមិនមានអាសវៈ ព្រោះបានកាត់បំណង ដូចជាដំរីកាត់ផ្តាច់ខ្សែទន្លីង ។ ឱ! ខ្ញុំមកល្អហើយ ក្នុងសំណាក់ព្រះពុទ្ធដ៏ប្រសើរ របស់ខ្ញុំ វិជ្ជា ៣ ខ្ញុំបានដល់ហើយ សាសនា របស់ព្រះពុទ្ធ ខ្ញុំបានធ្វើហើយ ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនា របស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ។

បានឮថា ព្រះសុបដាយកត្ថេរ មានអាយុ បានសម្តែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

ចប់ សុបដាយកត្ថេរាបទាន ។

## ទណ្ឌទាយកត្ថេរាបទាន ទី ៦

(១១៦) កាលនោះ ខ្ញុំចូលទៅ ក្នុងព្រៃធំ បានកាប់ឫស្សីធ្វើជាបង្កាន់ដៃ ប្រគេនដល់ព្រះសង្ឃ ។

## ឆដ្ឋំ ទណ្ឌទាយកត្ថេរាបទានំ

តេន ចិត្តប្បសាទេន សុព្វតេ អភិវាទយឹ(១)
អាលម្ពនទណ្ឌំ ទត្វាន បក្កាមឹ ឧត្តរាមុខោ ។
ចតុន្នវុតេ ឥតោ កប្បេ យំ ទណ្ឌមទទឹ តទា
ទុគ្គតឹ នាភិជានាមិ ទណ្ឌទានស្សិទំ ផលំ ។
កិលេសា ឈាបិតា មយ្ហំ ភវា សព្វេ សមូហតា
នាគោវ ពន្ធនំ ឆេត្វា វិហរាមិ អនាសវោ ។
ស្វាគតំ វត មេ អាសិ មម ពុទ្ធស្ស សន្តិកេ
តិស្សោ វិជ្ជា អនុប្បត្តា កតំ ពុទ្ធស្ស សាសនំ ។
បដិសម្ភិទា ចតស្សោ វិមោក្ខាបិ ច អដ្ឋិមេ
ឆឡភិញ្ញា សច្ឆិកតា កតំ ពុទ្ធស្ស សាសនំ ។

ឥត្ថំ សុទំ អាយស្មា ទណ្ឌទាយកោ ថេរោ ឥមា គាថាយោ អភាសិត្ថាតិ ។

ទណ្ឌទាយកត្ថេរស្ស អបទានំ សមត្តំ ។

តេវីសតិមំ ភាណវារំ ។

---

១ ម. អភិវាទិយ ។



## ទណ្ឌទាយកត្ថេរាបទាន ទី ៦

ខ្ញុំថ្វាយបង្គំនូវព្រះសង្ឃមានវត្តល្អ ដោយចិត្តជ្រះថ្លានោះ ហើយ ខ្ញុំប្រគេនកំណាត់ឫស្សីបង្អែកដៃរួចហើយ ក៏បែរមុខឆ្ពោះទៅកាន់ទិសឧត្តរ ដើរចេញទៅ ។ ក្នុងកប្បទី ៩៤ អំពីកប្បនេះ ព្រោះហេតុដែលខ្ញុំបានថ្វាយកំណាត់ឫស្សី ក្នុងកាលនោះ ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃការឲ្យកំណាត់ឫស្សី ។ កិលេសទាំងឡាយ ខ្ញុំដុតបំផ្លាញហើយ ភពទាំងអស់ ខ្ញុំដកចោលហើយ ខ្ញុំជាអ្នកមិនមានអាសវៈ ព្រោះបានកាត់ចំណង ដូចជាដំរីកាត់ផ្តាច់នូវទន្ទឹង ។ ឱ ! ខ្ញុំមកល្អហើយ ក្នុងសំណាក់ព្រះពុទ្ធរបស់ខ្ញុំ វិជ្ជា ៣ ខ្ញុំបានដល់ហើយ សាសនា របស់ព្រះពុទ្ធ ខ្ញុំបានធ្វើហើយ ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនា របស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ។

បានឮថា ព្រះទណ្ឌទាយកត្ថេរ មានអាយុ បានសម្ដែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

ចប់ ទណ្ឌទាយកត្ថេរាបទាន ។

ចប់ ភាណវារៈ ទី ២៣ ។

# សត្តមំ គិរិនេលបូជកត្ថេរាបទានំ

(១១៧) មិគលុទ្ទោ បុរេ អាសឹ វិវនេ(១) វិចរំ អហំ

អទ្ទសំ វិរជំ ពុទ្ធំ សព្វធម្មាន បារគុំ ។

តស្មឹ មហាការុណិកេ សព្វសត្តហិតេ រតេ

បសន្នចិត្តោ សុមនោ នេលបុប្ផំ អបូជយឹ ។

ឯកត្តឹសេ ឥតោ កប្បេ យំ បុប្ផមភិបូជយឹ

ទុគ្គតឹ នាភិជានាមិ បុប្ផបូជាយិទំ ផលំ ។

កិលេសា ឈាបិតា មយ្ហំ ភវា សព្វេ សមូហតា

នាគោវ ពន្ធនំ ឆេត្វា វិហរាមិ អនាសវោ ។

ស្វាគតំ វត មេ អាសិ មម ពុទ្ធស្ស សន្តិកេ

តិស្សោ វិជ្ជា អនុប្បត្តា កតំ ពុទ្ធស្ស សាសនំ ។

---

១ ឱ. វិបិនេ ។ ម. វិបិនេ ។



# គិរិនេលបូជកត្ថេរាបទាន ទី ៧

(១១៧) ក្នុងកាលមុន ខ្ញុំកើតជាព្រានម្រឹគ ត្រាច់ទៅក្នុងព្រៃ បានឃើញព្រះសម្ពុទ្ធ ទ្រង់ប្រាសចាកធូលី ដល់នូវត្រើយនៃធម៌ទាំងពួង ។ ខ្ញុំមានចិត្តជ្រះថ្លា មានចិត្តរីករាយ ចំពោះព្រះសម្ពុទ្ធ ព្រះអង្គប្រកបដោយសេចក្តីករុណា ត្រេកអរចំពោះប្រយោជន៍របស់សព្វសត្វ ហើយបានបូជាផ្កាអញ្ចាន ទៀត ។ ក្នុងកប្បទី ៣១ អំពីកប្បនេះ ព្រោះហេតុដែលខ្ញុំបានបូជាផ្កា ក្នុងកាលនោះ ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃពុទ្ធបូជា ។ កិលេសទាំងឡាយ ខ្ញុំដុតបំផ្លាញហើយ ភពទាំងអស់ ខ្ញុំដកចោលហើយ ខ្ញុំជាអ្នកមិនមានអាសវៈ ព្រោះបានកាត់បំណង់ ដូចជាដំរីកាត់ផ្តាច់នូវទន្លឹង ។ ឱ! ខ្ញុំមកល្អហើយ ក្នុងសំណាក់នៃព្រះពុទ្ធរបស់ខ្ញុំ វិជ្ជា ៣ ខ្ញុំបានដល់ហើយ សាសនា របស់ព្រះពុទ្ធ ខ្ញុំបានធ្វើហើយ ។

បដិសម្ភិទា ចតស្សោ វិមោក្ខាបិ ច អដ្ឋិមេ
ឆឡភិញ្ញា សច្ឆិកតា កតំ ពុទ្ធស្ស សាសនន្តិ ។

ឥត្ថំ សុទំ អាយស្មា តិណលបូជកោ ថេរោ ឥមា គាថាយោ អភាសិត្ថាតិ ។

តិណលបូជកត្ថេរស្ស អបទានំ សមត្តំ ។

## អដ្ឋមំ ពោធិសម្មជ្ជកត្ថេរាបទានំ

(១១៨) អហំ បុរេ ពោធិបត្តំ ឧជ្ឈិតំ ចេតិយង្គណេ
តំ គហេត្វាន ឆឌ្ឌេសឹ អលភឹ វីសតិ(១) គុណេ ។
តស្ស កម្មស្ស តេជេន សំសរន្តោ ភវាភវេ
ទុវេ ភវេ សំសរាមិ ទេវត្តេ ចាបិ មានុសេ ។
ទេវលោកា ចវិត្វាន អាគន្ត្វា មានុសំ ភវំ
ទុវេ កុលេ បជាយាមិ ខត្តិយេ ចាបិ ព្រាហ្មណេ ។

១ ឱ. វីសតិ ។ ម. វីសតិំ ។



បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនា របស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ។

បានឮថា ព្រះតិណលបូជកត្ថេរ មានអាយុ បានសម្ដែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

ចប់ តិណលបូជកត្ថេរាបទាន ។

## ពោធិសម្មជ្ជកត្ថេរាបទាន ទី ៨

(១១៨) ក្នុងកាលមុន ខ្ញុំបានរើសស្លឹកពោធិ៍ ដែលជ្រុះក្នុងលានព្រះចេតិយ ហើយយកទៅចោល ខ្ញុំបាននូវគុណ ២០ ។ ខ្ញុំអន្ទោលទៅក្នុងភពតូចភពធំ តែងអន្ទោលទៅក្នុងភពពីរ គឺទេវតានិងមនុស្ស ដោយតេជះនៃកម្មនោះ ។ លុះខ្ញុំច្យុតចាកទេវលោក មកកាន់ភពរបស់មនុស្ស តែងកើតក្នុងត្រកូលពីរ គឺក្សត្រនិងព្រាហ្មណ៍ ។ ខ្ញុំបរិបូណ៌ដោយអវយវៈតូចធំ មានកំពស់និងទំហំសមរម្យ មានរូបល្អ មានសម្បុរល្អ មានកាយពេញលេញមិនខ្វះខាត ។

អដ្ឋបដ្ឋំ សម្បន្នា អារោហបរិណាហកំ
អភិរូបា សុចិ ហោមិ · សម្បុណ្ណាគា(១) អនូនកា ។
ទេវលោកេ មនុស្សេ វា ជាតា វា យត្ថ តត្ថចិ
ភវេ សុវណ្ណវណ្ណា ច ឧត្តត្តកនកូបមា ។
មុទុ(២) មទ្ទវា សិនិទ្ធា(៣) សុខុមា សុកុមារិកា(៤)
ឆវិ មេ សព្វទា ហោតិ ពោធិបត្តេ សុដ្ឋិតេ ។
យតោ កុតោចិ គតីសុ សរីរេ សមុទាគតេ
ន លិម្បតិ រជោជល្លំ វិបាកោ បត្តត្ថវិកេ ។
ឧណ្ហេ វាតាតបេ តស្ស អគ្គិតាបេន វា បន
គត្តេ សេទោ ន មុញ្ចតិ វិបាកោ បត្តត្ថវិកេ ។
កុដ្ឋំ គណ្ឌោ កិលាសោ ច តិលកា បិឡកា តថា
ន ហោន្តិ កាយេ ទទ្ទុ ច វិបាកោ បត្តត្ថវិកេ ។
អបរម្បិ គុណន្តស្ស និព្វត្តតិ ភវាភវេ
រោគា ន ហោន្តិ កាយស្មឹ វិបាកោ បត្តត្ថវិកេ ។

---

១ ឱ. ម. សម្បុណ្ណង្គា ។ ២ ឱ ម មុទុកា ។ ៣ ឱ. និទ្ធា ។ ប. និទ្ធា ។ ៤ ឱ. សុកុមារកា ។ ម. សុកុមារិកា ។



ខ្ញុំកើតក្នុងទេវលោក ឬក្នុងមនុស្សលោក ឬក៏ក្នុងកុលណាមួយ តែងមានសម្បុរដូចមាស ឬប្រៀបដូចមាសដុត ។ សម្បុររបស់ខ្ញុំ ទន់ ល្អល្អាស ជិតស្និទ្ធ ល្អិត ផូរផង់ សព្វៗកាល ព្រោះបានយកស្បោងបាត្រទៅថ្វាយ ។ ចំណែកដែលប្រឡាក់ដោយធូលី មិនដែលប្រឡាក់ក្នុងស្រីរៈ (របស់ខ្ញុំ) ក្នុងកាលណាមួយឡើយ នេះជាផល ក្នុងការយកស្បោងបាត្រទៅថ្វាយ ។ ខ្លួនរបស់ខ្ញុំនោះ (បិតនៅ) ក្នុងទីមានខ្យល់និងកំដៅថ្ងៃដ៏ក្ដៅក្ដី ឬត្រូវកំដៅភ្លើងក្ដី ញើសតាំងឡើងក៏មិនដែលហូរចេញ នេះជាផលក្នុងការយកស្បោងបាត្រទៅថ្វាយ ។ រោគឃ្លង់ ពក ស្រែង ប្រជ្រុយ បូស ដំបៅពិស មិនដែលមានក្នុងកាយ (របស់ខ្ញុំឡើយ) នេះជាផលក្នុងការយកស្បោងបាត្រទៅថ្វាយ ។ គុណដទៃទៀត តែងកើតដល់ខ្ញុំនោះ ក្នុងភពតូចនិងភពធំ គឺរោគទាំងឡាយ មិនដែលកើតក្នុងកាយរបស់ខ្ញុំឡើយ នេះជាផលក្នុងការយកស្បោងបាត្រទៅថ្វាយ ។

អបរម្បិ គុណាន្តស្ស ចិត្តតិ ភវាភវេ

ន ហោន្តិ ចិត្តជា ព្យាធិ វិបាកោ ចិត្តកម្មុនោ ។

អបរម្បិ គុណាន្តស្ស ចិត្តតិ ភវាភវេ

អមិត្តា ច ភវន្តស្ស វិបាកោ ចិត្តកម្មុនោ ។

អបរម្បិ គុណាន្តស្ស ចិត្តតិ ភវាភវេ

អង្គុនកោតោ ភវតិ វិបាកោ ចិត្តកម្មុនោ ។

អបរម្បិ គុណាន្តស្ស ចិត្តតិ ភវាភវេ

អត្តកដ្ឋហិ ចោរេហិ ន ហោតិ ឧទកា ភយំ ។

អបរម្បិ គុណាន្តស្ស ចិត្តតិ ភវាភវេ

ទាសី ទាសា អនុចរ ហោន្តិ ចិត្តានុវត្តកា ។

យម្ហិ អាយុប្បមាណម្ហិ ជាយតេ មានុសេ ភវេ

តតោ ន ហាយតេ អាយុ តិដ្ឋតេ យាវតាយុកំ ។



គុណណាដទៃទៀត តែងកើតដល់ខ្ញុំនោះ គឺមិនកើតតួចទិនតពជំ គឺពុកការណ៍ជាក្រៀមរៀតបៀន ដែលកើតអំពីចិត្ត មិនដែលមានឡើយ នេះជាផល គឺមិនការយកស្លឹកពោធិទៅបោល ។ គុណដទៃទៀត តែងកើតដល់ខ្ញុំនោះ គឺមិនកើតតួចទិនតពជំ គឺពួកសត្រូវ មិនដែលមានដល់ខ្ញុំនោះ នេះជាផល គឺមិនការយកស្លឹកពោធិទៅបោល ។ គុណដទៃទៀត តែងកើតដល់ខ្ញុំនោះ គឺមិនកើតតួចទិនតពជំ គឺរោគៈមិនដែលខូចខាតឡើយ នេះជាផល គឺមិនការយកស្លឹកពោធិទៅបោល ។ គុណដទៃទៀត តែងកើតដល់ខ្ញុំនោះ គឺមិនកើតតួចទិនតពជំ គឺភ័យ អំពីភ្លើងនិងស្តេច អំពីចោរនិងទឹក មិនដែលមានឡើយ ។ មានគុណដទៃទៀត តែងកើតដល់ខ្ញុំនោះ គឺមិនកើតតួចទិនតពជំ គឺពួកខ្ញុំស្រីខ្ញុំប្រុស ជាអ្នកប្រព្រឹត្តតាម ជាអ្នកលុះអំណាចចិត្តរបស់ខ្ញុំ ។ បុគ្គលកើតក្នុងភព ជារបស់មនុស្ស មានកំណត់អាយុត្រឹមណា អាយុរបស់ខ្ញុំមិនថយចុះអំពីកំណត់ត្រឹមនោះ តែងឋិតនៅដរាបដល់អស់អាយុ ។

អត្ថកា ច ពាហិកា(១) ទេវមា ច សរដ្ឋកា
អនុយុត្តា ហោន្តិ សព្វេបិ វុឌ្ឍិកាមា សុខិច្ឆកា ។
ភោគវា យសវា ហោមិ សិរិមា ញាតិបក្ខវា
អរោគោ គតសន្តាសោ(២) ភវេហំ សព្វទា ភវេ(៣) ។
ទេវា មនុស្សា អសុរា គន្ធព្វា យក្ខរក្ខសា
សព្វេ តេ បរិរក្ខន្តិ ភវេ សំសរតោ សទា ។
ទេវលោកេ មនុស្សេ ច អនុភោត្វា ឧភោ យសេ
អវសានេ ច និព្វានំ សិវំ បត្តោ អនុត្តរំ ។
សម្ពុទ្ធមុទ្ទិសិត្វាន ពោធឹ វា តស្ស សត្ថុនោ
យោ បុញ្ញំ បសវេ បោសោ តស្ស កឹ នាម ទុល្លភំ ។
មគ្គេ ផលេ ច អាគមេ ឈានាភិញ្ញាគុណេសុ ច
អញ្ញេសំ អធិកោ ហុត្វា និព្វាយតិ(៤) អនាសវោ ។

---

១ ឱ.ម. អត្ថកា ពាហិកា ។ ២ ឱ. ម. អបេតភយសន្តាសោ ។ ៣ ឱ. ភវេសំ សព្វទា ភវេ ។ ម. ភវេហំ សព្វទា ភវេ ។ ៤ ឱ.ម. និព្វាយតិ ។





ពួកជនទាំងអស់ អ្នកប្រាជ្ញជាសេចក្តីច្រើន ប្រាថ្នាសេចក្តីសុខ ទោះនៅខាងក្នុងក្តី ខាងក្រៅក្តី អ្នកនិគមក្តី អ្នកដែនក្តី សុទ្ធតែជាអ្នកប្រកបគាប់ខ្ញុំ ។ ខ្ញុំជាអ្នកមានភោគៈ មានយសមានសិរី មានពួកញាតិ ជាអ្នកឥតមានរោគ ប្រាសចាកសេចក្តីតក់ស្លុត តែងមានក្នុងភព សព្វៗ កាល ។ ពួកទេវតា មនុស្ស អសុរ គន្ធព្វ យក្ខ រាក្សស អ្នកទាំងអស់នោះ តែងគ្រប់ខ្ញុំ ដែលអន្ទោលទៅក្នុងភព សព្វៗ កាល ។ ខ្ញុំទទួលយសទាំងពីរក្នុងទេវលោកផង ក្នុងមនុស្សលោកផង រួចខ្ញុំបានដល់នូវព្រះនិព្វាន ជាសុខដ៏ប្រសើរក្នុងកាលជាទីបំផុត ។ បុរសណា ទទួលចំពោះព្រះសម្ពុទ្ធ ឬចំពោះដើមពោធិរបស់ព្រះសាស្តានោះ គប្បីទទួលនូវផលបុណ្យ (ផលទាំងអស់) ឈ្មោះថាបុរសនោះបានដោយក្រដុច ល្អចបាន ។ បុគ្គល (ដែលឋិតនៅ) ក្នុងមគ្គ ក្នុងផល ក្នុងបរិយត្តិ ក្នុងគុណគឺឈានទាំងអភិញ្ញា ជាបុគ្គលប្រសើរក្រៃលែងជាងពួកជនដទៃ ជាអ្នកមិនមានអាសវៈ តែងបរិនិព្វាន ។

បុរេហំ ពោធិយា បត្តំ ករេត្វា ហដ្ឋមានសោ
ឥមេហិ វីសកត្ថេហិ សមត្តិ ហោមិ សព្វទា ។
កិលេសា ឈាបិតា មយ្ហំ ភវា សព្វេ សមូហតា
នាគោវ ពន្ធនំ ឆេត្វា វិហរាមិ អនាសវោ ។
ស្វាគតំ វត មេ អាសិ មម ពុទ្ធស្ស សន្តិកេ
តិស្សោ វិជ្ជា អនុប្បត្តា កតំ ពុទ្ធស្ស សាសនំ
បដិសម្ភិទា ចតស្សោ វិមោក្ខាបិ ច អដ្ឋិមេ
ឆឡភិញ្ញា សច្ឆិកតា កតំ ពុទ្ធស្ស សាសនន្តិ ។

ឥត្ថំ សុទំ អាយស្មា ពោធិសម្មជ្ជកោ ថេរោ ឥមា គាថាយោ អភាសិត្ថាតិ ។

ពោធិសម្មជ្ជកត្ថេរស្ស អបទានំ សមត្តំ ។



ក្នុងកាលមុន ខ្ញុំមានចិត្តរីករាយ បានយកស្លឹក[illegible] ទើបជាអ្នកបរិបូណ៌ដោយវត្ថុ ២០ នេះ សព្វ ៗ កាល ។ កិលេសទាំងឡាយ ខ្ញុំដុតបំផ្លាញហើយ ភពទាំងអស់ ខ្ញុំដកចោលហើយ ខ្ញុំជាអ្នកមិនមានអាសវៈ ព្រោះបានកាត់បំណង ដូចជាដំរីកាត់ផ្តាច់នូវចំណង ។ ឱ ! ខ្ញុំមកល្អហើយ ក្នុងសំណាក់ព្រះពុទ្ធរបស់ខ្ញុំ វិជ្ជា ៣ ខ្ញុំបានដល់ហើយ សាសនា របស់ព្រះពុទ្ធ ខ្ញុំបានធ្វើហើយ ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនា របស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ។

បានឮថា ព្រះពោធិសម្មជ្ជកត្ថេរ មានអាយុ បានសម្ដែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

ចប់ ពោធិសម្មជ្ជកត្ថេរាបទាន ។

# នវមំ អាមណ្ឌផលទាយកត្ថេរាបទានំ

(១១៩) បទុមុត្តរោ នាម ជិនោ សព្វធម្មាន បារគូ
វុដ្ឋហិត្វា សមាធិម្ហា ចង្កមិ លោកនាយកោ ។
ខារិភារំ គហេត្វាន អាហរន្តោ ផលំ តទា
អទ្ទសិំ វិរជំ ពុទ្ធំ ចង្កមន្តំ មហាមុនិំ ។
បសន្នចិត្តោ សុមនោ សិរេ កត្វាន អញ្ជលិំ
សម្ពុទ្ធំ អភិវាទេត្វា អាមណ្ឌមទទិំ ផលំ ។
សតសហស្សេវិតោ កប្បេ យំ ផលំ អទទិំ តទា
ទុគ្គតិំ នាភិជានាមិ អាមណ្ឌស្ស ឥទំ ផលំ ។
កិលេសា ឈាបិតា មយ្ហំ ភវា សព្វេ សមូហតា
នាគោវ ពន្ធនំ ឆេត្វា វិហរាមិ អនាសវោ ។
ស្វាគតំ វត មេ អាសិ មម ពុទ្ធស្ស សន្តិកេ
តិស្សោ វិជ្ជា អនុប្បត្តា កតំ ពុទ្ធស្ស សាសនំ ។



# អាមណ្ឌផលទាយកត្ថេរាបទាន ទី ៩

(១១៩) ព្រះជិនស្រី ព្រះនាមបទុមុត្តរៈ ទ្រង់ដល់នូវត្រើយនៃធម៌ទាំងពួង ជាលោកនាយក ទ្រង់ចេញចាកសមាធិហើយចង្ក្រម ។ កាលនោះ ខ្ញុំកាន់នូវស្រែកដែលពេញដោយផ្លែឈើ បានឃើញព្រះសម្ពុទ្ធ ជាមហាមុនី ទ្រង់ប្រាសចាកកិលេស កំពុងចង្ក្រម ។ ខ្ញុំមានចិត្តជ្រះថ្លា មានចិត្តរីករាយ ធ្វើនូវអញ្ជលីលើសិរសៈ ថ្វាយបង្គំព្រះសម្ពុទ្ធ ហើយថ្វាយផ្លែល្ហុង ។ ក្នុងកប្បទីមួយសែន អំពីកប្បនេះ ព្រោះហេតុដែលខ្ញុំបានថ្វាយផ្លែឈើ ក្នុងកាលនោះ ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃផ្លែល្ហុង ។ កិលេសទាំងឡាយ ខ្ញុំដុតបំផ្លាញហើយ ភពទាំងអស់ ខ្ញុំដកចោលហើយ ខ្ញុំជាអ្នកមិនមានអាសវៈ ព្រោះបានកាត់ចំណង ដូចដំរីកាត់ផ្តាច់នូវចំណង ។ ឱ ! ខ្ញុំមកល្អហើយ ក្នុងសំណាក់ព្រះពុទ្ធរបស់ខ្ញុំ វិជ្ជា ៣ ខ្ញុំបានដល់ហើយ សាសនា របស់ព្រះពុទ្ធ ខ្ញុំបានធ្វើហើយ ។

បដិសម្ភិទា ចតស្សោ វិមោក្ខាបិ ច អដ្ឋិមេ
ឆឡភិញ្ញា សច្ឆិកតា កតំ ពុទ្ធស្ស សាសនំ ។

ឥត្ថំ សុទំ អាយស្មា អាមណ្ឌផលទាយកោ ថេរោ
ឥមា គាថាយោ អភាសិត្ថាតិ ។

អាមណ្ឌផលទាយកត្ថេរស្ស អបទានំ សមត្តំ ។

## ទសមំ សុគន្ធត្ថេរាបទានំ

(១៦០) ឥមម្ហិ ភទ្ទកេ កប្បេ ព្រហ្មពន្ធុ មហាយសោ
កស្សបោ នាម នាមេន ឧប្បជ្ជិ វទតំ វរោ ។
អនុព្យញ្ជនសម្បន្នោ ទ្វត្តឹសវរលក្ខណោ
ព្យាមប្បភាបរិវុតោ រំសិជាលសមុត្ថតោ[១] ។
អស្សាសេតា យថា ចន្ទោ សុរិយោវ[២] បភង្ករោ
និព្វាបេតា យថា មេឃោ សាគរោវ គុណាករោ ។

១ ឱ. រំសិជាលសមោសដោ ។ ឧ. រំសិជាលសមោហតោ ។ ២ ឱ.ម. សុរិយោ ចិស្សតិ ។



បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនា របស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ។

បានឮថា ព្រះអាមណ្ឌផលទាយកត្ថេរ មានអាយុ បានសម្ដែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

ចប់ អាមណ្ឌផលទាយកត្ថេរាបទាន ។

## សុគន្ធត្ថេរាបទាន ទី ១០

(១៦០) ក្នុងភទ្ទកប្បនេះ ព្រះពុទ្ធព្រះនាមកស្សបៈ ទ្រង់មានផៅពង្សដ៏ប្រសើរ មានយសធំ ព្រះអង្គប្រសើរជាងពួកអ្នកប្រាជ្ញ ទ្រង់កើតឡើងហើយ ។ ព្រះអង្គបរិបូណ៌ដោយអនុព្យញ្ជនៈ មានលក្ខណៈ ៣២ ដ៏ប្រសើរ មានពន្លឺមួយព្យាមជុំវិញ មានបណ្ដាញរស្មីតាំងឡើង ។ ព្រះអង្គទ្រង់ញុំាងពួកជនឲ្យត្រេកអរដូចព្រះចន្ទ មានរស្មីដូចព្រះអាទិត្យ ទ្រង់ញុំាងសត្វឲ្យរលត់ទុក្ខដូចមហាមេឃ ទ្រង់ធ្វើនូវគុណដូចសាគរ ។

ធរណីវ សីលេន ហិមវំ សមាធិនា
អាកាសោវិយ បញ្ញាយ អសង្គំ អនិលោ យថា ។
អន្តោ យថាវិហារេ(១) បរិសាសុ វិសារទោ
សច្ចានិ សម្បកាសេន្តំ ឧទ្ធរន្តំ មហាជនំ ។
តទាហំ(២) ពារាណសិយំ សេដ្ឋិបុត្តោ មហាយសោ
អាសឹ(៣) ធនធញ្ញស្ស បហូតស្ស ពហូ មម ។
ជង្ឃាវិហារំ(៤) វិចរំ មិគទាយំ ឧបេច្ចហំ(៥)
អទ្ទសឹ ជាជសត្ថារំ(៦) ទេសេន្តំ អមតំ បទំ ។
វិសដ្ឋកន្តវចនំ ករវិកសមស្សរំ
ហំសទុន្ទុភិនិគ្ឃោសំ(៧) វិញ្ញាបេន្តំ មហាជនំ ។
ទិស្វា ទេវាតិទេវន្តំ សុត្វា ច មធុរំ សរំ(៨)
បហាយានប្បកេ ភោគេ បព្វជឹ អនគារិយំ ។

---

១ ឱ.ម. សកទាចិ ឧបារីសេ ។ ២ ឱ. តទាហិ ។ ៣ ឱ. អាសហំ ។ ម. អនន្ត... ។ ៤ ឱ. ជង្ឃាវិហារំ ។ ៥ ឱ. មិគទាយមុបេច្ចហំ ។ ម. មិគទាយមុបេសហំ ។ ៦ ឱ. តាទិសំ គុរុំ ។ ម. វិរជំ គុរុំ ។ ៧ ម. ហំសរុតហំសនិគ្ឃោសំ ។ ៨ ឱ.ម. គិរំ ។



ព្រះអង្គមានសីលដូចផែនដី មានសមាធិដូចភ្នំហិមពាន្ត មានបញ្ញាដូចអាកាស មិនជាប់ចំពាក់ដូចខ្យល់ ។ ព្រះអង្គមានគុណមិនខ្វះខាត មានធម៌ជាគ្រឿងអប់រំ ទ្រង់ក្លៀវក្លាក្នុងពួកបរិស័ទ ទ្រង់ស្រង់ឡើងនូវមហាជន ហើយប្រកាសនូវសច្ចធម៌ ។ កាលនោះ ខ្ញុំកើតជាសេដ្ឋីបុត្ត ក្នុងក្រុងពារាណសី មានយសធំ ជាអ្នកប្រសើរ ដោយទ្រព្យនិងស្រូវច្រើនក្រៃលែង ។ ខ្ញុំកាលត្រាច់ទៅកាន់ទីសម្រាកស្ងួន ក៏ចូលទៅក្នុងព្រៃមិគទាយ បានឃើញព្រះសាស្តាជាទីពឹង កំពុងសម្តែងអមតបទ មានព្រះពុទ្ធដីកាជ្រះស្រឡះ មានសំឡេងស្មើដោយសត្វករវិក មានសន្ធឹកគឹកកងដូចសត្វហង្ស ឬដូចស្គរ ទ្រង់ញុំាងមហាជនឲ្យដឹងច្បាស់ ។ លុះខ្ញុំឃើញព្រះសម្ពុទ្ធនោះជាទេវតាដ៏ក្រៃលែងជាងទេវតា ទាំងបានស្តាប់សំឡេងដ៏ពីរោះ ទើបលះភោគៈដ៏ច្រើន ហើយចូលទៅកាន់ផ្នួស ។

ឯវំ បព្វជិតោ ចាហំ ន ចិរេន ពហុស្សុតោ

អហោសិំ ធម្មកថិកោ វិចិត្តបដិភាណកោ ។

មហាបរិសមជ្ឈេហំ តុដ្ឋចិត្តោ(១) បុនប្បុនំ

វណ្ណយិំ ហេមវណ្ណស្ស វណ្ណំ វណ្ណវិសារទោ ។

ឯស ខីណាសវោ ពុទ្ធោ អនីឃោ ឆិន្នសំសយោ

សព្វកម្មក្ខយំ បត្តោ វិមុត្តោ ឧបធិក្ខយេ (២) ។

ឯស សោ ភគវា ពុទ្ធោ ឯស សីហោ អនុត្តរោ

សទេវកស្ស លោកស្ស ព្រហ្មចក្កំ បវត្តកោ ។

ទន្តោ ទមេតា សន្តោ ច សមេតា និព្វុតោ ឥសិ

និព្វាបេតា ច អស្សត្ថោ អស្សាសេតា មហាជនំ ។

---

១ ឱ.ម. ហដ្ឋចិត្តោ ។ ២ ឱ. សតិសង្ខយេ ។ ម. វិមុត្តោ បធិសង្ខយេ ។



លុះខ្ញុំបួសយ៉ាងនេះហើយ មិនយូរប៉ុន្មានក៏បានជាពហុស្សូត ជាធម្មកថិក មានប្រាជ្ញាដ៏វិចិត្រ ។ ខ្ញុំជាអ្នកក្លៀវក្លាដោយគុណ បានពណ៌នាគុណរបស់ព្រះសាស្តា ដែលមានវណ្ណៈដូចមាស ក្នុងកណ្តាលបរិស័ទច្រើន ជារឿយ ៗ ។ ព្រះពុទ្ធនុ៎ះ ជាព្រះខីណាស្រព ទ្រង់មិនមានទុក្ខ កាត់បង់នូវសេចក្តីសង្ស័យ ទ្រង់ដល់នូវការអស់នៃកម្មទាំងពួង មានព្រះហឫទ័យផុតស្រឡះ ក្នុងព្រះនិព្វាន ជាទីអស់ទៅនៃឧបធិ ។ ព្រះមានព្រះភាគអង្គនុ៎ះ ទ្រង់ត្រាស់ដឹងនូវសច្ចធម៌ ព្រះមានព្រះភាគអង្គនុ៎ះ ទ្រង់ប្រសើរដូចសីហៈ ព្រះអង្គញ៉ាំងព្រហ្មចក្រឲ្យប្រព្រឹត្តទៅដល់មនុស្សលោក ព្រមទាំងទេវលោក ។ ទ្រង់ជាឥសី មានឥន្ទ្រិយទូន្មានហើយ ទ្រង់ទូន្មាននូវមហាជន ព្រះអង្គស្ងប់រម្ងាប់ហើយ ញ៉ាំងមហាជនឲ្យស្ងប់រម្ងាប់ ទ្រង់រលត់កិលេសហើយ ញ៉ាំងមហាជនឲ្យរលត់កិលេសផង ព្រះអង្គត្រេកអរហើយ ញ៉ាំងមហាជនឲ្យត្រេកអរផង ។

វីរោ សូរោ ច វិក្កន្តោ(១) បញ្ញោ ការុណិកោ វសី

វិជិតាវី វិជិតោ ច(២) អប្បគព្ភោ អនាលយោ ។

អនេជោ អចលោ ធីរោ(៣) អមោហោ អសមោ មុនិ

ធោរយ្ហោ ឧសភោ នាគោ សីហោ សក្កោ គរូសុ ច ។

វិរាគោ វិមលោ ព្រហ្មា វាទីសូរោ រណញ្ជហោ

អខិលោ ច វិសល្លោ ច អសមោ វុសភោ(៤) សុចិ ។

ព្រាហ្មណោ សមណោ នាថោ ភិសក្កោ សល្លកត្តោ(៥)

យោធោ ពុទ្ធោ សុតាសុតោ(៦) អចលោ មុទិតោ សិតោ ។

---

១ ឱ. ធីរោ ច ។ ២ ឱ. ម. វិជិតាវី ច សណ្ឋិតោ ។ ៣ ឱ. ម. ធីមា ។ ៤ ឱ. បយតោ ។ ម. សំយតោ ។ ៥ ឱ. ម. សល្លកត្តោ ។ ៦ ឱ. សុតាសុតោ ។



ព្រះអង្គមានព្យាយាម អង់អាច ក្លាហាន មានប្រាជ្ញា ប្រកបដោយសេចក្តីករុណា ទ្រង់ស្ទាត់ជំនាញ ទ្រង់ឈ្នះហើយ ទ្រង់ឈ្នះមិនចាញ់វិញ ទ្រង់មិនឃ្លេសឃ្លង មិនមានអាល័យ ។ ព្រះមុនីទ្រង់មិនញាប់ញ័រ មិនឃ្លេងឃ្លោង ជាអ្នកប្រាជ្ញ មិនមានមោហៈ ឥតមានបុគ្គលស្មើ នាំទៅនូវធុរៈ ជាឧសភៈ ជានាគ ជាសីហៈ ទ្រង់អង់អាចក្នុងពួកគ្រូទាំងឡាយ ។ ព្រះអង្គប្រាសចាករាគៈ មិនមានមន្ទិល ជាព្រហ្ម មានវោហារដ៏ក្លៀវក្លា ទ្រង់លះបង់នូវសត្រូវគឺកិលេស ទ្រង់មិនរឹងត្អឹង ប្រាសចាកកូនសរគឺសេចក្តីសោក ឥតមានបុគ្គលស្មើ ជាឧសភៈ ជាអ្នកស្អាត ។ ព្រះអង្គជាព្រាហ្មណ៍ ជាសមណៈ ជាទីពឹង ជាពេទ្យ ទ្រង់កំចាត់បង់នូវសរ គឺសេចក្តីសោក ជាយោធា ត្រាស់ដឹងនូវសច្ចៈ ភ្ញាក់រលឹកចាកការដេកលក់ មិនញាប់ញ័រ មានព្រះហឫទ័យមាំ ត្រជាក់ ។

កតកិច្ចា វហន្តា ច(១) កត្តា នេតា បកាសិតា

សម្បហំសិតា ឆេត្តា(២) ច ជេត្តា សោតា(៣) បសំសិតា ។

អខិលោ(៤) ច វិសល្លោ ច អនីឃោ អកថំកថី

អនេជោ វិរជោ ខត្តា គន្តា វត្តា បកាសិតា ។

តារេតា អត្ថការេតា ការេតា សម្បទារិតា(៥)

បាបេតា សហិតា ហន្តា តាបិតា ច វិសោសិតា(៦) ។

សច្ចដ្ឋិតោ(៧) សមសមោ អសហាយោ ទយាសយោ(៨)

អច្ឆេរមន្តោ(៩) អក្ខោភោ កតាវី ឥសិ សត្តមោ(១០) ។

---

១ ឱ. ពាលគត្តា ច ហន្តារ ។ ម. គបាគោ ច សន្ទិត ។ ២ ម. ចោតា ច ។ ៣ ឱ. ម. សោតា ។ ៤ ឱ. អខិលោ ។ ៥ ឱ. សម្បទាលេតា ។ ៦ ឱ. ហន្តា តាបិតា តាបសោ ។ ម. ហន្តា តាបិតា តាបសោ ។ ៧ ឱ.ម. សមចិត្តោ ។ ៨ ឱ. ទយាសយោ ។ ម ទយាសយោ ។ ៩ ឱ អច្ឆេរសន្តោ ។ ម អច្ឆេរមន្តោ ។ ១០ ឱ ម. សត្តមោ ។





ព្រះអង្គមានកិច្ចធ្វើហើយ ទ្រង់នាំទៅ ទ្រង់ធ្វើ ទ្រង់ណែនាំ ទ្រង់ប្រកាស ទ្រង់រីករាយ ទ្រង់លាងជម្រះ ទ្រង់កាត់ (កិលេស) ទ្រង់ស្រោចស្រង់ គួរគេសរសើរ ។ ព្រះអង្គមិនគម្រើក (មិនរឹករាំ) ព្រួសចាកសរទៅសេចក្តីសោក មិនមានទុក្ខ មិនមានសេចក្តីសង្ស័យ មិនញាប់ញ័រ ទ្រង់ប្រាសចាកធូលី ទ្រង់គាស់រំលើង (កិលេស) ទ្រង់ចងក្រង ទ្រង់ពោលប្រដៅ ទ្រង់ប្រកាស ។ ព្រះអង្គទ្រង់ចម្លង ទ្រង់ធ្វើប្រយោជន៍ ញុំាងជនឲ្យធ្វើ (ប្រយោជន៍) ទ្រង់លោយកិលេស ទ្រង់ញុំាងជនឲ្យដល់ ទ្រង់អត់ធន់ ទ្រង់សម្លាប់កិលេស ទ្រង់មានព្យាយាមដុតកិលេស ទ្រង់ញុំាងកិលេសឲ្យរីងស្ងួត ។ ព្រះអង្គទ្រង់ឋិតនៅក្នុងសច្ចៈ ទ្រង់ស្មើដោយបុគ្គលស្មើគឺអ-សទិសបុគ្គល មិនមានសំឡាញ់ ទ្រង់អាស្រ័យក្នុងសេចក្តីអាណិត មានសេចក្តីអស្ចារ្យ ទ្រង់មិនកក្រើក ទ្រង់ធ្វើជាឥសីទី ៧ ។

ឆិន្នតណ្ហាគតេថ្វំ ជិម្ហាលោ  អប្បមេយ្យោ អតុបមោ
សព្វវាក្យបថាតីតោ  សព្វនេយ្យន្តគោ[១] ជិនោ ។
សត្ថរិសីវរេ[២] តស្មិំ  បសាទោ អមតាវហោ[៣]
តស្មា ពុទ្ធេ ច ធម្មេ ច  សង្ឃេ សទ្ធា មហត្ថិកា[៤] ។
គុណេហិ ឯវមាទីហិ  តិលោកសរណុត្តមំ
វណ្ណេន្តោ បរិសមជ្ឈេ  កាថី[៥] ធម្មកថំ អហំ ។
តតោ ចុតាហំ តុសិតេ  អនុភោត្វា មហាសុខំ
តតោ ចុតោ មនុស្សេសុ  ជាតោ ហោមិ សុគន្ធិកោ ។
និស្សាសោ មុខគន្ធោ ច  ទេហគន្ធោ តថេវ មេ
សេទគន្ធោ ច សតតំ  សព្វគន្ធោវ ហោតិ មេ ។

---

១ ឱ. សព្វនេយ្យន្តិកោ ។ ម. សព្វនេយ្យន្តគូ ។ ២ ឱ. សត្ថិសាវរេ ។ ម. សត្ថុសាវបរេ ។ ៣ ម. អមតាវហោ ។ ៤ ឱ. ប មហិទ្ធិកា ។ ៥ ឱ. ម. អកិំ ។



ព្រះជិនស្រីទ្រង់ផុតសេចក្តីសង្ស័យ មិនមានមានះ មាន
គុណប្រមាណមិនបាន មិនមានឧបមា ទ្រង់កន្លងនូវគន្លង
ពាក្យទាំងពួង ដល់នូវទីបំផុតនៃនេយ្យធម៌ទាំងពួង ។ សេចក្តី
ជ្រះថ្លា ក្នុងព្រះជិនស្រីដ៏ប្រសើរដូចព្រះអាទិត្យនោះ ជាគុណ
នាំមកនូវព្រះនិព្វានឈ្មោះអមតៈ ព្រោះហេតុនោះ សេចក្តី
ជឿស៊ប់ក្នុងព្រះពុទ្ធក្តី ព្រះធម៌ក្តី ព្រះសង្ឃក្តី មានប្រយោជន៍
ច្រើន ។ ខ្ញុំក៏បានពណ៌នាគុណនៃព្រះសម្ពុទ្ធដ៏ប្រសើរ ជាទី-
ពឹងនៃសត្វក្នុងត្រៃលោក ដោយគុណទាំងឡាយ មានយ៉ាង
នេះជាដើម ហើយសំដែងធម្មកថា ក្នុងកណ្តាលបរិស័ទ ។ ខ្ញុំ
ច្យុតចាកអត្តភាពនោះហើយ ទទួលសេចក្តីសុខច្រើនក្នុងភព
តុសិត លុះច្យុតចាកតុសិតនោះ មកកើតក្នុងពួកមនុស្ស ជា
អ្នកមានក្លិនក្រអូប ។ ខ្យល់ដង្ហើមចេញរបស់ខ្ញុំក្តី ក្លិនមាត់ក្តី
ក្លិនកាយក្តី ដូចគ្នា ក្លិនរបស់ខ្ញុំនោះ ក្រអូបសព្វ ជានិច្ច ។

មុខតោ សទា មយ្ហំ   បទុមុប្បលគន្ធគោ

អតិក្កន្តោ(១) សទា ភាតិ   សរីរេ ច តថេវ មេ ។

គុណត្ថវស្ស សព្វត្ថំ(២)   ផលត្ថំ(៣) បរមត្ថិ

ឯកគ្គមនសា សព្វេ   ភាសិតស្ស(៤) សុណាថ មេ ។

គុណំ ពុទ្ធស្ស វត្វាន   ហិតាយជំ សុខាវហំ(៥)

សុចិន្តោ(៦) ហោមិ សព្វត្ថ   សង្ឃោ វីរសមាសុតោ(៧) ។

យសស្សី សុខិតោ កន្តោ   ជុតិមា បិយទស្សនោ

វត្តា អបរិក្ខតោ ច   និទ្ទោសោ បញ្ញវា តថា ។

ខីណេ អាយុសិ និព្វានំ   សុលភំ ពុទ្ធភត្តិនំ(៨)

តេសំ ហេតុំ បវក្ខាមិ   តំ សុណាថ យថាតថំ ។

---

១ ឱ. អតិសេដ្ឋោ ។ ម. បរិសេដ្ឋោ ។ ២ ឱ. ឥទ្ធំ ។ ៣ ឱ. ផលទ្ធំ ។ ម. ផលត្ថំ ។ ៤ ឱ. ម. វណ្ណយិស្សំ ។ ៥ ឱ. ហិតាយ ជិនសត្ថុនោ ។ ម. ហិតាយ ចេ ន សត្ថុនោ ។ ៦ ឱ.ម. សុចិត្តោ ។ ៧ ឱ. សេដ្ឋវិសមាយុតោ ។ ៨ ម. ពុទ្ធភត្តិនោ ។



ក្លិនមាត់របស់ខ្ញុំ ដូចក្លិនផ្កាឈូក ឬផ្កាឧប្បលដ៏ប្រពៃ សព្វៗកាល ទាំងសរីរៈរបស់ខ្ញុំ ប្រសើរផុតគេ តែងផ្សាយទៅ សព្វៗកាល ដូច្នោះដែរ ។ សេចក្តីសប្បាយដ៏ក្រៃលែង ទាំងអស់នោះ ជាផលនៃសេចក្តីសរសើរនូវគុណ អ្នកទាំងអស់គ្នា ចូរស្តាប់នូវភាសិតរបស់ខ្ញុំ ដោយចិត្តនឹងធួនចុះ ។ លុះខ្ញុំសរសើរព្រះពុទ្ធគុណ ជាទីមកនៃប្រយោជន៍ ទាំងនាំមកនូវសេចក្តីសុខ ខ្ញុំមានចិត្តស្អាត ជាសង្ឃខ្វល់ខ្វាយតែនឹងសេចក្តីព្យាយាម ក្នុងធម៌ទាំងពួង ។ ព្រះសម្ពុទ្ធ ខ្ញុំមានយស ខ្ញុំមានសេចក្តីសុខ ខ្ញុំគួរគាប់ ខ្ញុំរុងរឿង ជាទីស្រឡាញ់ ទាំងគួររមិលមើល ខ្ញុំពោលប្រពៃ មិនមានបុគ្គលមើលងាយ មិនមានទោស មានប្រាជ្ញ ។ កាលបើព្រះជន្មាយុអស់ហើយ បុគ្គលអ្នកគប់រកនូវព្រះពុទ្ធ តែងបានព្រះនិព្វានដោយងាយ ខ្ញុំនឹងសម្តែងនូវហេតុ នៃគុណទាំងឡាយនោះ អ្នកទាំងឡាយ ចូរស្តាប់ហេតុនោះ ដោយពិតចុះ ។

សទ្ធំ យសំ ភគវតោ    វិកិណា(១) អភិកង្ខិយំ
យត្ថ យត្ថូបបជ្ជាមិ(២)    យសស្សី តេន ហោមហំ ។
ទុក្ខស្សន្តករំ ពុទ្ធំ    ធម្មំ សន្តំ អសង្ខតំ
វណ្ណយំ សុខិតោ អាសិំ    សត្តានំ សុខទោ(៣) តតោ ។
គុណំ វទន្តោ ពុទ្ធស្ស    ពុទ្ធបីតិសមាយុតោ
សកត្តំ បរកត្តំ ច(៤)    អាសិំ(៥) តេន ច(៦) កន្តិមា ។
ជិនោ យោ(៧) តិត្ថិកាតិណ្ណោ    អភិភុយ្យ កុតិត្ថិយេ
គុណំ វទន្តោ ជោតេសិំ(៨)    នាយកំ ជុតិមា តតោ ។

---

១ ឱ.ម. វិធិតា ។ ២ ឱ. យត្ថ តត្ថុបបជ្ជាមិ ។ ម. តត្ថ តត្ថូបបជ្ជាមិ ។ ៣ ម. សុខិតោ ។ ៤ ឱ. សកត្តិម្ហរកត្តិញ្ច ។ ៥ ឱ. អាសឹ ។ ៦ ឱ. ចេសទ្ធា ខន្តិ ។ ៧ ឱ. ជិនោ យេ ។ ម. ជិនតេ ។ ៨ ឱ. ម. ជោតេសឹ ។



ខ្ញុំថ្វាយបង្គំនូវយស របស់ព្រះមានព្រះភាគ ដោយការត្រិះរិះ សូម្បីខ្ញុំទៅកើត ក្នុងភពណា ៗ ក៏ជាអ្នកមានយស ក្នុងភពនោះ ៗ ដោយការត្រិះរិះនោះ ។ ខ្ញុំកាលសរសើរនូវព្រះសម្ពុទ្ធ ទ្រង់ធ្វើនូវព្រះនិព្វាន ជាទីបំផុតនៃកងទុក្ខ ព្រះធម៌ជាគុណស្ងប់ស្ងាប់ ជាអសង្ខតធម៌ ហើយជាអ្នកដល់នូវសេចក្តីសុខ ជាអ្នកឲ្យនូវសេចក្តីសុខ ដល់ពួកសត្វ ក្នុងកាលនោះ ។ មួយទៀត ខ្ញុំកាលពោលសរសើរ នូវគុណរបស់ព្រះពុទ្ធ ប្រកបដោយបីតិក្នុងព្រះពុទ្ធ បានញុំាងសេចក្តីត្រេកអររបស់ខ្លួន និងសេចក្តីត្រេកអរ របស់បុគ្គលដទៃឲ្យកើត ជាអ្នកមានសេចក្តីត្រេកអរ ដោយសារហេតុនោះ ។ ព្រះជិនស្រីអង្គណា កន្លងផុតនូវពួកតិរ្ថិយ គ្របសង្កត់នូវពួកតិរ្ថិយដ៏អាក្រក់ ខ្ញុំពោលនូវគុណ សរសើរនូវព្រះនាយកអង្គនោះ ខ្ញុំមានសេចក្តីរុងរឿង ដោយសារហេតុនោះ ។

ទសមំ សុគន្ធត្ថេរាបទានំ

បិយព្ភាណី ជនស្សាបិ   សម្ពុទ្ធស្ស គុណំ វទិំ[១]
សរទេ[២] សសង្កោហំ   តោជាសឹ បិយទស្សនោ ៗ
យថាសត្តិវសេនាហំ   ស្តុត្វាភិជាហំ សុគតំ
សុកតិំ តេន វគ្គីសោ   វិចិត្តបដិភាណកោ ៗ
យេ ពាលា វិមតី បត្តា   បរិភោន្តិ មហាមុនិំ
និគ្គហឹ តេ សធម្មេន   បរិក្ខេន[៣] តេនហំ ៗ
ពុទ្ធវណ្ណោហិ សត្តានំ   កិលេសេ អបនេសហំ
និក្កិលេសមនោ ហោមិ   តស្ស កម្មស្ស វាហសា ៗ
សោតូនំ ពុទ្ធិមជនិំ   ពុទ្ធានុស្សតិទេសកោ
តេណាបិតាសឹ[៤] សបញ្ញោ   និបុណត្ថវិបស្សកោ ៗ

១ ឱ. វទិ ។ ២ ឱ. សរទេ ។ ម. សរទោ ។ ៣ ឱ. ម. បរក្ខោ ន តេនហំ ។ ៤ ឱ. តេណាហោសឹ ។ ម. តេណាបិ មាសឹ ។



សុគន្ធត្ថេរាបទាន ទី ១០

ខ្ញុំធ្វើសេចក្ដីស្រឡាញ់ដល់ពួកជន ខ្ញុំពោលសរសើរគុណព្រះសម្ពុទ្ធ ខ្ញុំប្រាកដដូចព្រះចន្ទក្នុងសរទកាល ខ្ញុំជាទីស្រឡាញ់ គួរមើលមើល ដោយសារហេតុនោះ ។ ខ្ញុំសរសើរព្រះសុគត ដោយពាក្យគ្រប់ ដោយអំណាចនៃសេចក្ដីអង់អាច ព្រោះហេតុនោះ ទើបខ្ញុំមាននាមថា វគ្គីសៈ ជាអ្នកមានប្រាជ្ញាដ៏វិចិត្រ ។ បពិត្រព្រះមហាមុនី ពួកជនពាលណា ដល់នូវសេចក្ដីសង្ស័យ ហើយមើលងាយ ខ្ញុំសង្កត់សង្កិនជនពាលទាំងនោះ ដោយការគ្រប់សង្កត់ តាមធម៌របស់ខ្លួននោះ ។ ខ្ញុំនាំចេញនូវកិលេសទាំងឡាយ របស់សត្វ ដោយការសរសើរនូវព្រះពុទ្ធ ទើបខ្ញុំមានចិត្តមិនប្រឡូកកិលេស ដោយកម្លាំងនៃកម្មនោះ ។ ខ្ញុំញុំាងប្រាជ្ញាឲ្យកើត ដល់ជនជាអ្នកស្តាប់ ជាអ្នកសម្ដែងនូវពុទ្ធានុស្សតិ ព្រោះហេតុនោះ ទើបខ្ញុំជាអ្នកមានប្រាជ្ញា ជាអ្នកពិចារណាឃើញនូវអត្ថដ៏ល្អិត ។

សព្វាសវបរិក្ខីណោ   តិណ្ណសំសារសាគរោ
សេ ច(១) អនុធារេតោ   ធាតុណ្ហិស្សាមិ និព្វុតោ ៗ
ឥមស្មិំយេវ កប្បស្មឹ   យមហំ សត្ថុំ ផលិំ
ទុគ្គតឹ នាភិជានាមិ   ពុទ្ធបូជាយិទំ ផលំ ៗ
កិលេសា ឈាបិតា មយ្ហំ   ភវា សព្វេ សមូហតា
នាគោវ ពន្ធនំ ឆេត្វា   វិហរាមិ អនាសវោ ៗ
ស្វាគតំ វត មេ អាសិ   មម ពុទ្ធស្ស សន្តិកេ
តិស្សោ វិជ្ជា អនុប្បត្តា   កតំ ពុទ្ធស្ស សាសនំ ៗ
បដិសម្ភិទា ចតស្សោ   វិមោក្ខាបិ ច អដ្ឋិមេ
ឆឡភិញ្ញា សច្ឆិកតា   កតំ ពុទ្ធស្ស សាសនន្តិ ៗ

ឥត្ថំ សុទំ អាយស្មា សុគន្ធោ ថេរោ ឥមា គាថា-យោ អភាសិត្ថាតិ ៗ

សុគន្ធត្ថេរស្ស អបទានំ សមត្តំ ៗ

---

១ ម. ឆ. សិរី ៗ





ខ្ញុំអស់អាសវៈទាំងពួងហើយ ឆ្លងសមុទ្រគឺសង្សារហើយ ខ្ញុំជាអ្នកស្គាត់ជំនាញ មិនមានឧបាទាន ទាំងដល់នូវព្រះនិព្វាន ៗ ក្នុងកប្បនេះឯង ព្រោះហេតុដែលខ្ញុំសរសើរព្រះជិនស្រី ក្នុងកាលនោះ ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃពុទ្ធបូជា ៗ កិលេសទាំងឡាយ ខ្ញុំដុតបំផ្លាញហើយ ភពទាំងអស់ ខ្ញុំដកចោលហើយ ខ្ញុំជាអ្នកមិនមានអាសវៈ ព្រោះបានកាត់ចំណង ដូចជាដំរីកាត់ផ្តាច់ខ្សែទន្លីង ៗ ឱ! ខ្ញុំមកល្អហើយ ក្នុងសំណាក់ព្រះពុទ្ធរបស់ខ្ញុំ វិជ្ជា ៣ ខ្ញុំបានដល់ហើយ សាសនា របស់ព្រះពុទ្ធ ខ្ញុំបានធ្វើហើយ ៗ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនា របស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ៗ

បានឮថា ព្រះសុគន្ធត្ថេរ មានអាយុ បានសម្តែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ៗ

ចប់ សុគន្ធត្ថេរាបទាន ៗ

ឧទ្ទានំ

កិលេសោ វត្ថុតោ(១) ទេវ សរណាគ្គញ្ញមជ្ឈេតោ(២)
សុមនោ(៣) ចណ្ឌាលយ៍ ច ថេលប្បទី តបេ(៤) ច ។
តោធិសមុជ្ជតោ មណ្ណោ សុខេទ្តោ ចសេរោ ធិជោ
កាលាសតិ សតេវីសំ តណ្ហាំ តេគុ សត្តហោ ។

ចំណាយកវគ្គោ ទេបញ្ញាសោ ។

---

១ ឱ. វត្ថុតោ ។ ម. មញ្ញតោ ។ ២ ឱ.ម. សរណាគ្គញ្ញមជ្ឈេតោ ។ ៣ ឱ. សុមនី ។ ៤ ម. តបេវ ។



ឧទ្ទានំ

កិលេសប្បហានយកវគ្គមាន ១ វត្ថុកថាយកវគ្គមាន ១ សរណគមនយកវគ្គមាន ១ អគ្គញ្ញទាយកវគ្គមាន ១ សុមនាយកវគ្គមាន ១ ចណ្ឌាយកវគ្គមាន ១ គិ-លេបប្បទកវគ្គមាន ១ ពោធិសមុជ្ជកវគ្គមាន ១ កា-មណ្ឌលតាយកវគ្គមាន ១ សុគន្ធវគ្គមាន ជាទី ១០ ឯកាទសកនិបាតនេះ មាន ៦៤០ គោតកប៉ះហើយ ដោយ សព្វគ្រប់ ។

ចប់ និបាតយកវគ្គ ទី ៥៣ ។

---

## ចតុបណ្ណាសមោ កច្ចាយនវគ្គោ

## បឋមំ មហាកច្ចាយនត្ថេរាបទានំ

(១៦១) បទុមុត្តរោ នាម ជិនោ អនេជោ អជិតញ្ជយោ(១)
សតសហស្សេ កប្បានំ ឥតោ ឧប្បជ្ជិ នាយកោ ។
វីរោ កមលបត្តក្ខោ សសង្កវិមលាននោ
កនកាចលសង្កាសោ(២) រវិទិត្តិសមប្បភោ(៣) ។
សត្តនេត្តមនោហារី វរលក្ខណភូសិតោ
សព្វវាក្យបថាតីតោ មនុជាមរសក្កតោ ។
សម្ពុទ្ធោ ពោធយំ សត្តេ វាគីសោ(៤) មធុរស្សរោ
ករុណានិពន្ធសន្តានោ(៥) បរិសាសុ វិសារទោ ។
ទេសេតិ មធុរំ ធម្មំ ចតុសច្ចូបសំហិតំ
និមុគ្គេ មោហបង្កម្ហិ សមុទ្ធរតិ បាណិនោ(៦) ។

---

១ ឱ.ម. អជិតញ្ជយោ ។ ឌ. អជិតំជយោ ។ ២ ឱ.ម. កនកាចលសង្កាសោ ។ ៣ ម. រវិទិត្តិហរិប្បភោ ។ ៤ ឱ.ម. វាគីសោ ។ ៥ ឱ. ករុណានិព្ពុសន្តានោ ។ ម. ករុណានិពទ្ធសន្តានោ ។ ៦ ម. បាណិនេ ។

## កច្ចាយនវគ្គ ទី ៥៤

## មហាកច្ចាយនត្ថេរាបទាន ទី ១

(១៦១) ព្រះជិនស្រីព្រះនាមបទុមុត្តរៈ ទ្រង់មិនញាប់ញ័រ ឥតមានបុគ្គលផ្ចាញ់បាន ជានាយក ទ្រង់ត្រាស់ឡើង ក្នុងកប្បទីមួយសែន អំពីកប្បនេះ ។ ព្រះវីរសម្ពុទ្ធ ទ្រង់មានស្របកព្រះនេត្រ ដូចផ្កាឈូក មានព្រះភក្ត្រផុតចាកមន្ទិលដូចព្រះចន្ទ មានព្រះកាយដូចមាស មានរស្មីរុងរឿងដូចព្រះអាទិត្យ ទ្រង់ជាទីត្រេកអរនៃចិត្តរបស់សត្វ ប្រដាប់ដោយលក្ខណៈដ៏ប្រសើរ ទ្រង់កន្លងផុតគន្លងពាក្យទាំងពួង ត្រូវមនុស្សនិងទេវតា ធ្វើសក្ការៈហើយ ។ ព្រះសម្ពុទ្ធទ្រង់ញុំាងពួកសត្វឲ្យត្រាស់ដឹង ទ្រង់មានសម្លេងពីរោះផ្សាយទៅ ទ្រង់មានសន្តានជាប់ដោយសេចក្តីករុណា ទ្រង់ក្លៀវក្លាក្នុងពួកបរិស័ទ ។ ព្រះសម្ពុទ្ធទ្រង់សម្តែងធម៌ពីរោះ ប្រកបដោយសច្ចៈ ៤ ទ្រង់ស្រង់ពួកសត្វដែលលិចចុះ ក្នុងភក់គឺមោហៈ ។

តទា ឯកកោ ហុត្វា តាបសោ ហិមវាលយេ
នភសា មានុសំ លោកំ គច្ឆេ ជិនបក្ខិយំ ។
ឧបេច្ច សត្ថុកំ តស្ស អស្សោសឹ ធម្មទេសនំ
វណ្ណយន្តស្ស វីរស្ស សាវកស្ស មហាគុណំ ។
សង្ខិត្តេន មយា វុត្តំ វិត្ថារេន បកាសយំ
បរិសំ មញ្ញុ តោសេតិ យថា កច្ចាយនោ អយំ[១] ។
នាហំ ឯវំ ជោតកំ[២] អញ្ញំ បស្សាមិ សាវកំ
តស្មា តទគ្គេ ឯសគ្គោ ឯវំ ធារេថ ភិក្ខវោ ។
តទាហំ វិម្ហិតោ ហុត្វា វាក្យំ សុត្វា មនោរមំ
ហិមវន្តំ គមិត្វាន អាហិត្វា បុប្ផសញ្ចយំ ។
បូជេត្វា លោកសរណំ តំ ឋានំ អភិបត្ថយឹ

---

១ ឱ. ម អយំ ។ ២ ឱ. វិវរិតកត្ថុំ ។ ម. វិវរិតកត្ថុំ ។





ក្នុងកាលនោះ ខ្ញុំកើតជាតាបស មានលំនៅក្នុងព្រៃហិមពាន្ត [illegible] ហោះទៅកាន់មនុស្សលោក តាមអាកាស បានឃើញព្រះជិនស្រី ។ ខ្ញុំចូលទៅកាន់សំណាក់ព្រះជិនស្រីនោះ បានស្តាប់ធម្មទេសនា របស់ព្រះសម្ពុទ្ធជាអ្នកប្រាជ្ញ ដែលកំពុងពណ៌នានូវគុណដ៏ធំរបស់សាវកថា ភាសិតដែលតថាគតពោល ដោយបំព្រួញ សាវកនេះ ប្រកាសដោយពិស្តារបាន ញុំាងបរិស័ទឲ្យត្រេកអរដូចកច្ចាយនភិក្ខុ ។ តថាគតមិនឃើញមានសាវកដទៃណាមួយក្នុងសាសនានេះ យ៉ាងនេះឡើយ ព្រោះហេតុនោះ សាវកនេះជាអ្នកប្រសើរ (ឋិតនៅ) ក្នុងទីជាឯតទគ្គៈ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយចូរចាំទុកយ៉ាងនេះចុះ ។ កាលនោះខ្ញុំមានសេចក្តីស្ញប់ស្ញែង ព្រោះស្តាប់ពាក្យជាទីគាប់ចិត្តនោះហើយ ទៅកាន់ព្រៃហិមពាន្ត ដើរសន្សំរបស់ផ្កាឈើ ។ ខ្ញុំបូជាចំពោះព្រះសម្ពុទ្ធជាទីពឹងនៃលោក ហើយប្រាថ្នានូវតំណែងនោះ ។

តទា មហាសយំ ញត្វា  ព្យាកាសិ សរណាគមោ(១) ។

បស្សថេតំ ឥសិវរំ  និទ្ធន្តកនកត្តចំ

ឧទគ្គលោមមានសំ(២)  អចលំ បញ្ជលិំ(៣) ឋិតំ ។

ហាសំ សុបុណ្ណនយនំ  ពុទ្ធវណ្ណគតាសយំ

ធម្មជំ ឧគ្គហទយំ(៤)  អមតាសិត្តសន្និភំ ។

កច្ចានស្ស គុណំ សុត្វា  តំ ឋានំ បត្ថយំ ឋិតោ

អនាគតម្ហិ អទ្ធានេ  គោតមស្ស មហាមុនេ ។

តស្ស ធម្មេសុ ទាយាទោ  ឱរសោ ធម្មនិម្មិតោ

កច្ចានោ នាម នាមេន  ហេស្សតិ សត្ថុសាវកោ ។

ពហុស្សុតោ មហាញាណី  អធិប្បាយវិទូ មុនិ

បាបុណិស្សតិ តំ ឋានំ  យថាយំ ព្យាកតោ មយា ។

---

១ ឱ. ព្យាកាសិ សរណញ្ជលោ ។ ២ ឱ. ឧទ្ធគ្គលោមំ បីនំសំ ។ ៣ ឱ. អញ្ជលិំ ។ ៤ ឱ. ធម្មជំ ឧគ្គហទំ ។



កាលនោះ ព្រះសរណាគមនសម្ពុទ្ធ ទ្រង់ជ្រាបអធ្យាស្រ័យដ៏ធំរបស់ខ្ញុំ ទ្រង់ព្យាករថា អ្នកទាំងឡាយ ចូរមើលនូវឥសីដ៏ប្រសើរនេះ មានស្បែកដូចមាស មិនមានមន្ទិល មានរោមខ្ពស់ និងសាច់ពេញលេញ ឈរផ្គងអញ្ជលីមិនកម្រើក មានសេចក្តីរីករាយ មានភ្នែកពេញល្អ មានអធ្យាស្រ័យស្ទុះ ក្នុងការពណ៌នានូវព្រះគុណ ជាអ្នកកើតអំពីធម៌ មានហឫទ័យខ្ពស់ ហាក់ដូចជាស្រោចស្រពដោយទឹកអម្រឹត ។

បពិត្រព្រះមហាមុនី លុះខ្ញុំឈរស្តាប់នូវគុណរបស់ព្រះកច្ចានត្ថេរហើយ ក៏ប្រាថ្នានូវតំណែងនោះ ក្នុងសាសនានៃព្រះគោតម ក្នុងកាលជាអនាគត ។ (ព្រះបទុមុត្តរៈទ្រង់ព្យាករថា) តាបសនេះ នឹងបានជាធម្មទាយាទ ជាឱរសរបស់ព្រះគោតមនោះ ជាធម្មនិម្មិត មាននាមថាកច្ចានត្ថេរ ជាសាវ័ករបស់ព្រះសាស្តា ។ កច្ចានត្ថេរនោះ នឹងបានជាពហុស្សូត មានញាណដ៏ប្រសើរ ជាអ្នកប្រាជ្ញ ដឹងនូវសេចក្តីអធិប្បាយ នឹងដល់នូវតំណែងនោះ ដូចជាតថាគតព្យាករហើយនេះ ។

សតសហស្សេ ឥតោ កប្បេ យំ កម្មមករឹ តទា
ទុគ្គតឹ នាភិជានាមិ ពុទ្ធបូជាយិទំ ផលំ ។
ទុវេ ភវេ សំសរាមិ ទេវត្តេ អថ មានុសេ
អញ្ញំ គតឹ ន ជានាមិ(១) ពុទ្ធបូជាយិទំ ផលំ ។
ទុវេ កុលេ បជាយាមិ(២) ខត្តិយេ ចាបិ(៣) ព្រាហ្មណេ
នីចេ កុលេ ន ជាយាមិ ពុទ្ធបូជាយិទំ ផលំ ។
បច្ឆិមេ ច ភវេ ទានិ ឧជ្ជេនិយំ បុរេ វរេ(៤)
បជ្ជោតស្ស សចណ្ឌស្ស បុរោហិតទុជាតិនោ(៥) ។
បុត្តោ តិរិដិវច្ឆស្ស(៦) និបុណោ វេទបារគូ
មាតា ច ចន្ទបទុមា(៧) កច្ចានោហំ វរត្តចោ(៨) ។
វីមំសនត្ថំ ពុទ្ធស្ស ភូមិបាលេន បេសិតោ
ទិស្វា មោក្ខបុរទ្វារំ នាយកំ គុណសញ្ចយំ ។
សុត្វាន វិមលំ វាក្យំ គតិបង្កវិសោធនំ(៩)
បាបុណឹ អមតំ សន្តំ សេសេហិ សហ សត្តហិ(១០) ។

---

១ ឱ. ម. ន ជានាមិ ។ ២ ឱ. ម. បជាយាមិ ។ ៣ ឱ. ម. អថ ។ ៤ ឱ. ម. បច្ឆិមេ ច ភវេ- ទានិ ជាតោ ឧជ្ជេនិយេ បុរេ ។ ៥ ឱ. អចណ្ឌស្ស បុរោហិតទិជាតិនោ ។ ម. សចណ្ឌស្ស បុរោហិតទិជាធិនោ ។ ៦ ឱ. ម. តិរីដិវច្ឆស្ស ។ ៧ ឱ. ចន្ទបទុមា ។ ម. ចន្ទិមា នាម ។ ៨ ឱ. ម. វរត្តចោ ។ ៩ ឱ. ម. គតិបង្កវិសោធនំ ។ ១០ ឱ. បញ្ចហិ ។



ក្នុងកប្បទីមួយសែន អំពីកប្បនេះ ព្រោះហេតុដែលខ្ញុំ បានធ្វើកុសលកម្ម ក្នុងកាលនោះ ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃពុទ្ធបូជា ។ ខ្ញុំតែងអន្ទោលទៅក្នុងភពពីរ គឺ ទេវតានិងមនុស្ស មិនដែលស្គាល់គតិដទៃឡើយ នេះជាផល នៃពុទ្ធបូជា ។ ខ្ញុំតែងកើតក្នុងត្រកូលពីរ គឺត្រកូលក្សត្រ ឬ ព្រាហ្មណ៍ មិនដែលកើតក្នុងត្រកូលថោកឡើយ នេះជាផល នៃពុទ្ធបូជា ។ ក្នុងបច្ឆិមភព ខ្ញុំកើតជាបុត្រនៃបុរោហិត របស់ ស្ដេចព្រះនាមចណ្ឌបជ្ជោត ក្នុងបុរីឧជ្ជេនី ជាទីរីករាយ ។ ខ្ញុំ ជាបុត្ររបស់តិរិដិវច្ឆព្រាហ្មណ៍ ជាអ្នកមានប្រាជ្ញាល្អិត ដល់ នូវត្រើយនៃវេទ ឯមាតាខ្ញុំ ឈ្មោះនាងចន្ទបទុមា ខ្ញុំឈ្មោះ កច្ចានៈ មានសម្បុរល្អ ។ ខ្ញុំដែលព្រះភូមិបាលបញ្ជូនទៅ ដើម្បីល្បងមើលព្រះសម្ពុទ្ធ ក៏បានឃើញព្រះនាយក ជាទ្វារ នៃមោក្ខបុរី ជាទីសន្សំនូវគុណ ។ ខ្ញុំស្ដាប់ពាក្យមិន មានមន្ទិល ជាពាក្យជម្រះនូវភក់គឺគតិ ក៏បានដល់នូវអមត- ធម៌ ជាទីរម្ងាប់ ជាមួយនឹងពួកបុរោហិតដ៏សេស ៧ នាក់ ។

អធិប្បាយវិទូ ជាតោ សុគតស្ស មហាមតេ
ឋបិតោ ឯតទគ្គេ ច សុសមិទ្ធមនោរថោ ។

កិលេសា ឈាបិតា មយ្ហំ ភវា សព្វេ សមូហតា
នាគោវ ពន្ធនំ ឆេត្វា វិហរាមិ អនាសវោ ។

ស្វាគតំ វត មេ អាសិ មម ពុទ្ធស្ស សន្តិកេ
តិស្សោ វិជ្ជា អនុប្បត្តា កតំ ពុទ្ធស្ស សាសនំ ។

បដិសម្ភិទា ចតស្សោ វិមោក្ខាបិច អដ្ឋិមេ
ឆឡភិញ្ញា សច្ឆិកតា កតំ ពុទ្ធស្ស សាសនន្តិ ។

ឥត្ថំ សុទំ អាយស្មា មហាកច្ចាយនោ ថេរោ
ឥមា គាថាយោ អភាសិត្ថាតិ ។

មហាកច្ចាយនត្ថេរស្ស អបទានំ សមត្តំ ។



ខ្ញុំជាអ្នកដឹងនូវសេចក្តីអធិប្បាយ ក្នុងបំណងធំ នៃព្រះសុគត ព្រះអង្គទ្រង់តាំងខ្ញុំទុក ក្នុងទីជាឯតទគ្គៈ ខ្ញុំមានសេចក្តីប្រាថ្នាសម្រេចល្អហើយ ។ កិលេសទាំងឡាយ ខ្ញុំដុតបំផ្លាញហើយ ភពទាំងអស់ ខ្ញុំដកចោលហើយ ខ្ញុំជាអ្នកមិនមានអាសវៈ ព្រោះបានកាត់ចំណង ដូចដំរីកាត់ផ្តាច់នូវទន្លីង ។ ឱ ! ខ្ញុំមកល្អហើយ ក្នុងសំណាក់ព្រះពុទ្ធរបស់ខ្ញុំ វិជ្ជា ៣ ខ្ញុំបានដល់ហើយ សាសនា របស់ព្រះពុទ្ធ ខ្ញុំបានធ្វើហើយ ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនា របស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ។

បានឮថា ព្រះមហាកច្ចាយនត្ថេរ មានអាយុ បានសម្តែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

ចប់ មហាកច្ចាយនត្ថេរាបទាន ។

## ទុតិយំ វក្កលិត្ថេរាបទានំ

(១៦៦) ឯកោ សតសហស្សម្ហិ កប្បេ ឧប្បជ្ជិ នាយកោ
អនោមនាមោ អមិតោ នាមេន បទុមុត្តរោ ។
បទុមាការវទនោ បទុមាមលសុច្ឆវី
លោកេនានុបលិត្តោ ច តោយេន បទុមំ យថា ។
វីរោ បទុមបត្តក្ខោ កន្តោ ច បទុមំ យថា
បទុមុត្តរគន្ធោ ច តស្មា សោ បទុមុត្តរោ ។
លោកជេដ្ឋោ ច និម្មានោ អន្ធានំ នយនូបមោ
សន្តវេសោ គុណនិធិ ករុណាមតិសាគរោ ។
ស កទាចិ(១) មហាវីរោ ព្រហ្មាសុរសុរច្ចិតោ(២)
សទេវមនុជាកិណ្ណេ(៣) ជនមជ្ឈេ ជិនុត្តមោ(៤) ។

---

១ ឱ. ម. កកាចិ ។ ២ ឱ. ព្រហ្មាសុរច្ចិតោ ។ ៣ ឱ. ម. សទេវមនុជាកិណ្ណោ ។ ៤ ម. អនុត្តមោ ។

## វក្កលិត្ថេរាបទាន ទី ២

[១៦៦] ក្នុងកប្បមួយសែន អំពីកប្បនេះ ព្រះនាយក ព្រះនាមបទុមុត្តរៈ មានព្រះនាមខ្ពង់ខ្ពស់ មានគុណកប់មិនបាន ត្រាស់ឡើងហើយ ក្នុងលោក ។ ព្រះអង្គមានអាការនៃព្រះភក្ត្រដូចផ្កាឈូក មានព្រះឆវីវណ្ណល្អមិនមានមន្ទិលដូចផ្កាឈូក មិនជាប់ចំពាក់ដោយលោក ដូចផ្កាឈូកមិនប្រឡាក់ដោយទឹក ។ ព្រះអង្គជាអ្នកប្រាជ្ញ មានព្រះនេត្រដូចត្របកឈូក ជាទីត្រេកអរដូចផ្កាឈូក ទ្រង់មានក្លិនវិសេសដូចផ្កាឈូក ព្រោះហេតុនោះឯង ទើបព្រះអង្គទ្រង់ព្រះនាមជា បទុមុត្តរៈ ។ ព្រះអង្គជាច្បងក្នុងលោក ទ្រង់មិនមានមានះ មានឧបមាដូចភ្នែកនៃពួកជនខ្វាក់ ទ្រង់មានភេទស្ងប់រម្ងាប់ ជាកំណប់នៃគុណ ទ្រង់មានករុណាគុណនិងបញ្ញាគុណដូចសាគរ ។ ជួនកាល ព្រះមហាវីរៈនោះ មានពួកព្រហ្ម ទេវតា និងអសុរបូជា ព្រះអង្គឧត្តមជាងពួកជន ក្នុងកណ្ដាលប្រជុំជន ដែលកុះករដោយទេវតានិងមនុស្ស ។

វទនេន សុគន្ធេន  មធុរេន រុតេន(១) ច

រញ្ជយំ បរិសំ សព្វំ  សន្ថវិ(២) សាវកំ សកំ ៕

សទ្ធាធិមុត្តោ សុមតិ  មម ទស្សនលាលយោ(៣)

នត្ថិ ឯតាទិសោ អញ្ញោ  យថាយំ ភិក្ខុ វក្កលិ ៕

តទាហំ ហំសវតិយា  ជនេ ព្រាហ្មណសត្រជោ(៤)

ហុត្វា សុត្វា ជិតំ(៥) វាក្យំ  តណ្ហានំ អភិរោចយិំ ៕

សសាវកំ តំ វិមលំ  និមន្តេត្វា តថាគតំ

សត្តាហំ ភោជយិត្វាន  ទុស្សេហិ ឆាទយិំ តទា ៕

និបច្ច សិរសា តស្ស  អនន្តគុណសាគរេ

និមុត្តោ បីតិសម្បុណ្ណោ  ឥទំ វចនមព្រវី ៕

យោ សោ តយា សន្ថវិតោ  ឥធ សទ្ធាធិមុត្តោ ឥសិ(៦)

ភិក្ខុ សទ្ធាវតំ អគ្គោ  តាទិសោ ហំ មហាមុនិ(៧) ៕

---

១ ឱ. ម. រុតេន ។ ២ ឱ. សន្ថវី ។ ម. សន្ថវិ ។ ៣ ឱ. ម. ទស្សនលាលសោ ។ ៤ ឱ. ម. ព្រាហ្មណត្រជោ ។ ៥ ឱ. សុត្វា ឯតំ ។ ៦ ឱ. ឥតោ សត្តមកេ ឥសិ ។ ម. ឥតោ សត្តមកេ មុនិ ។ ៧ ឱ. ម. តាទិសោ ហោមហំ មុនេ ។



ព្រះមហាវីរៈ ទ្រង់ញ៉ាំងបរិស័ទទាំងពួងឲ្យត្រេកអរ ដោយព្រះឱស្ឋមានក្លិនក្រអូបផង ដោយព្រះសូរសៀងពីរោះផង ទ្រង់សរសើរសាវ័ករបស់ព្រះអង្គថា សាវ័កនេះ ជាសទ្ធាធិមុត្ត មានប្រាជ្ញាល្អ មានអាល័យ ក្នុងការឃើញតថាគត បុគ្គលដទៃបែបនេះ មិនមានដូចវក្កលិភិក្ខុនេះឡើយ ។ កាលនោះ ខ្ញុំកើតជាកូនរបស់ព្រាហ្មណ៍ នៅក្នុងក្រុងហង្សវតី លុះបានស្តាប់ព្រះពុទ្ធដីកានោះហើយ ក៏ប្រាថ្នានូវតំណែងនោះ ។ កាលនោះខ្ញុំនិមន្តព្រះតថាគត ទ្រង់មិនមានមន្ទិលនោះ ព្រមទាំងសាវ័ក ឲ្យគង់ឆាន់អស់ ៧ ថ្ងៃ ក្រោយបាក់សំពត់ ។ ខ្ញុំក្រាបចុះដោយសិរ្សៈ មុជចុះក្នុងសាគរគឺអនន្តគុណរបស់ព្រះអង្គ មានបីតិពេញលេញ ទើបពោលពាក្យនេះថា បពិត្រព្រះមហាមុនី ឥសីគឺភិក្ខុអង្គណា ជាសទ្ធាធិមុត្ត ក្នុងសាសនានេះ ដែលព្រះអង្គសរសើរហើយថា ជាបុគ្គលជាន់ខ្ពស់ក្នុងភិក្ខុអ្នកមានសទ្ធា ខ្ញុំព្រះអង្គសូមបានដូចភិក្ខុនោះ ក្នុងកាលអនាគត ។

ឯវំ វុត្តេ មហាវីរោ អនាវរណទស្សនោ
ឥមំ វាក្យំ ឧទីរយិ(១) បរិសាយ មហាមុនិ ។
បស្សថេតំ មាណវកំ បីតមដ្ឋនិវាសនំ
ហេមយញ្ញោបចិតង្គំ ជននេត្តមនោហរំ ។
ឯសោ អនាគតទ្ធានេ គោតមស្ស មហេសិនោ
អគ្គោ សទ្ធាធិមុត្តានំ សាវកោយំ ភវិស្សតិ ។
ទេវភូតោ មនុស្សោ វា សព្វសន្តាបវជ្ជិតោ
សព្វភោគបរិព្យូឡ្ហោ សុខិតោ សំសរិស្សតិ ។
សតសហស្សេតោ កប្បេ ឱក្កាកកុលសម្ភវោ
គោតមោ នាម នាមេន សត្ថា លោកេ ភវិស្សតិ ។
តស្ស ធម្មេសុ ទាយាទោ ឱរសោ ធម្មនិម្មិតោ
វក្កលិ នាម នាមេន ហេស្សតិ សត្ថុសាវកោ ។

---

១ ឱ.ម. ឧទីរេសិ ។



លុះខ្ញុំពោលយ៉ាងនេះហើយ ទើបព្រះមហាមុនីទ្រង់ព្យាយាមធំ មានការឃើញមិនខកំបាំង ទ្រង់បន្លឺឡើងនូវព្រះពុទ្ធដីកានេះ ក្នុងកណ្តាលបរិស័ទថា

អ្នកទាំងឡាយ ចូរមើលមាណពនេះ ដែលស្លៀកសំពត់សាច់មដ្ឋមានសម្បុរលឿង ជាអ្នកមានអវយវៈដូចគ្រឿងបូជា ដែលបិទដោយមាស ជាទីត្រេកអរគ្រប់ចិត្តរបស់ជន ។ មាណពនេះ នឹងបានជាសាវ័ក របស់ព្រះគោតមមហេសី ប្រសើរលើសជាងពួកភិក្ខុ ដែលជាសទ្ធាធិមុត្ត ក្នុងកាលជាអនាគត ។ មាណពនេះ ទោះកើតជាទេវតា ឬជាមនុស្ស ជាអ្នកវៀរចាកសេចក្តីក្តៅក្រហាយទាំងពួង បរិបូណ៌ដោយភោគៈទាំងពួង ជាអ្នកអន្ទោលទៅនឹងមានសេចក្តីសុខ ។ ក្នុងកប្បទីមួយសែន អំពីកប្បនេះ ព្រះសាស្តា ព្រះនាមគោតម ទ្រង់កើតក្នុងត្រកូលឧក្កាកៈ នឹងត្រាស់ឡើងក្នុងលោក ។ មាណពនេះ នឹងបានជាធម្មទាយាទរបស់ព្រះអង្គ ជាឱរស ជាធម្មនិម្មិត មាននាមវក្កលិ ជាសាវ័ករបស់ព្រះសាស្តា ។

តេន កម្មវិសេសេន  ចេតនាបណិធីហិ ច

ជហិត្វា មានុសំ ទេហំ  តាវតិំសំ អគច្ឆហំ ។

សព្វត្ថ សុខិតោ ហុត្វា  សំសរិត្វា ភវាភវេ

សាវត្ថិយំ បុរេ ជាតោ  កុលេ អឌ្ឍកេ អហំ ។

នោនីតំ សុខុមាលំ មំ  ហិតំ បល្លវកោមលំ

មាតា(១) ឧត្តានសយនំ  បិសាចភយតជ្ជិតា ។

បាទមូលេ មហេសិស្ស  សាយាបេសិ(២) ទីនមានសា

ឥមំ ទទាមិ តេ នាថ  សរណំ ហោតុ នាយក ។

តទា បដិគ្គហិ សោ មំ  ភីតំ សរណោ មុនិ

ជាលិនា ចក្កង្កិតេន(៣)  មុទុកោមលបាណិនា ។

១ ឱ. ម. មន្តុ ។ ២ ឱ. សាយេយ្យំ ។ ម. សាយេសុំ ។ ៣ ឱ. សង្ខលង្កេន ។ ម. សង្ខាលកេន ។



ខ្ញុំលះបង់កាយជារបស់មនុស្សហើយ ក៏បានទៅកើតក្នុងឋានតាវត្តិង្ស ដោយវិសេសនៃកម្មនោះផង ដោយការតាំងទុកនូវចេតនានោះផង ។ ខ្ញុំអន្ទោលទៅក្នុងភពតូចភពធំ ជាអ្នកមានសេចក្តីសុខ ក្នុងភពទាំងពួង ខ្ញុំមកកើតក្នុងត្រកូលមួយ ក្នុងក្រុងសាវត្ថី ។ មាតាមានភ័យអំពីបិសាចបៀតបៀន នូវខ្ញុំ ដែលនៅល្អិតទន់ដូចទឹកដោះខាប់ កំពុងនៅផ្តេកផ្ងារល្អិតទន់ដូចត្រួយឈើ ។ មាតាផ្តេកខ្ញុំទៀបបាទមូលរបស់ព្រះមហេ-ស៊ី លុះគាត់មានចិត្តចង់ថ្វាយ (ទើបពោលថា) បពិត្រព្រះលោកនាថ ខ្ញុំព្រះអង្គថ្វាយទារកនេះចំពោះព្រះអង្គ បពិត្រព្រះនាយក ខ្ញុំព្រះអង្គសូមដល់នូវព្រះអង្គ ជាទីពឹងទីរលឹក ។ គ្រានោះ ព្រះមហាមុនីនោះ ដែលជាទីពឹងនៃពួកសត្វអ្នកខ្លាច ទ្រង់ទទួលនូវខ្ញុំដោយព្រះហស្តដ៏ទន់ដូចផ្កា មានក្រ-ឡាប្រទាក់ដូចសំណាញ់ មានផ្ចិតស្នាមរាវដ៏ដូចចក្រ ។

តទា បភុតិ ជាតោហំ(១) អរក្ខេយ្យេន រក្ខិតោ

សព្វព្យាធិវិមុត្តោ(២) សុខេន បរិវុទ្ធិតោ(៣) ។

សុគតេន វិនាភូតោ ឧក្កណ្ឋាមិ មុហុត្តកំ

ជាតិយា សត្តវស្សាហំ បព្វជឹ អនគារិយំ ។

សព្វបារមិសម្ភូតំ នីលក្ខិនយនំ វរំ(៤)

រូបំ សព្វំ សុភាកិណ្ណំ អតិត្តោ វិហរាមហំ ។

ពុទ្ធរូបរតឹ ញត្វា តទា ឱវទិ មំ ជិនោ

អលំ វក្កលិ កឹ រូបេ រមសេ ពាលនន្ទិតេ ។

យោ ហិ បស្សតិ សទ្ធម្មំ សោ មំ បស្សតិ បណ្ឌិតោ

អបស្សមានោ សទ្ធម្មំ មំ បស្សេបិ ន បស្សតិ ។

---

១ ឱ. ម. តេនាហំ ។ ២ ឱ. សព្វុបទ្ទវនិម្មុត្តោ ។ ម. សព្វីតិវិនិមុត្តោ ។ ៣ ឱ. បរិវឌ្ឍិ-តោ ។ ម. បរិវុទ្ធិតោ ។ ៤ ឱ. បរំ ។





ចាប់ដើមតាំងពីកាលនោះ ខ្ញុំបានព្រះសម្ពុទ្ធរក្សាហើយ ដោយអំពើមិនគួរគេរក្សាបាន ខ្ញុំរួចស្រឡះចាកព្យាធិទាំងពួង ចំរើនដោយសេចក្តីសុខ ។ បើខ្ញុំវៀរចាកព្រះសុគតហើយ ក៏កើតអផ្សុកមួយរំពេច លុះខ្ញុំអាយុ៧ឆ្នាំ ចាប់អំពីកំណើត ក៏បានចូលទៅកាន់ផ្នួស ។ ខ្ញុំមិនឆ្អែតចិត្តនឹងព្រះសុគត ទ្រង់ពេញលេញដោយបារមីទាំងពួង មានព្រះនេត្រខៀវស្រស់ មានព្រះរូបល្អពេញដោយរបស់ល្អគ្រប់ទាំងអស់ ។ កាលនោះ ព្រះជិនស្រីទ្រង់ជ្រាបថាខ្ញុំមានសេចក្តីត្រេកអរ ក្នុងរូបរបស់ព្រះពុទ្ធហើយ ក៏ទ្រង់ទូន្មានខ្ញុំថា នែវក្កលិ កុំឡើយ អ្នកត្រេកអរក្នុងរូបដែលជនពាលត្រេកអរហើយ នឹងមានប្រយោជន៍អ្វី ព្រោះថាបុគ្គលណាជាបណ្ឌិត បានឃើញព្រះសទ្ធម្ម បុគ្គលនោះឈ្មោះថាឃើញតថាគត បុគ្គលណា កាលមិនឃើញព្រះសទ្ធម្ម សូម្បីឃើញតថាគត បុគ្គលនោះក៏ឈ្មោះថាមិនឃើញដែរ ។

អច្ចន្តាទីនវោ កាយោ វិសរុក្ខសមូបមោ

អាវាសោ សព្វរោគានំ បុញ្ជោ ទុក្ខស្ស កេវលោ ។

និព្វិន្ទិយ តតោ រូបេ ខន្ធានំ ឧទយព្វយំ

បស្សំ សព្វគ្គិលេសានំ(១) សុខេនន្តំ គមិស្សសិ ។

ឯវំ តេនានុសិដ្ឋាហំ នាយកេន ហិតេសិនា

តិដ្ឋគ្គំ សមាហិតា ឈាយាមិ តិកគ្គបេ ។

បិតោ បព្វតគព្ភម្ហិ អស្សាសយិ(២) មហាមុនិ

វិក្កលីតិ និរាភេន(៣) តំ សុត្វា ឱរុតោ(៤) អហំ ។

បក្កន្តិ(៥) សេលបព្ភារេ អនេកសតកោដិសេ

តទា ពុទ្ធានុភាវេន សុខេនេវ មហិំ គតោ ។

បុនាបិ(៦) ធម្មំ ទេសេតិ ខន្ធានំ ឧទយព្វយំ

តមហំ ធម្មមញ្ញាយ អរហត្តំ អបាបុណិំ ។

១ ម. ឧបក្កិលេសានំ ។ ២ ឱ. មហាហស ។ ម. អស្សាសយិ ។ ៣ ឱ.ម. និរោភិបំ ។
៤ ម. ឱរុទិតោ ។ ៥ ម. វិក្កលិ ។ ៦ ឱ. បុនាបិ ។ ម. ធុនិ មំ ។





កាយជារបស់មានទោស ក្រៃលែងបំផុត ដូចមេមហាប៉ុក ដើមឈើមានពិស ជាលំនៅនៃរោគទាំងពួង ជាគំនរនៃកងទុក្ខទាំងអស់ ។ អ្នកចូរនឿយណាយ ចាកកាយនោះ ចូរឃើញនូវការកើតឡើងនិងការសូន្យ នៃខន្ធទាំងឡាយ ក្នុងប្រយោជន៍ អ្នកនឹងដល់នូវព្រះនិព្វានជាទីបំផុត នៃកិលេសទាំងពួង ដោយសេចក្តីសុខ ។ លុះព្រះនាយក ទ្រង់សំដែងនូវប្រយោជន៍នោះ ប្រៀនប្រដៅខ្ញុំយ៉ាងនេះរួចហើយ ខ្ញុំក៏ឡើងនិគ្គិតឲ្យកូន នៅសណ្ដាប់សណ្ដាំង ត្រង់ប្រកត្ត ។ ព្រះជិនស្រីមហាមុនី ទ្រង់បិតនៅខាងលើភ្នំ ញ៉ាំងខ្ញុំឲ្យត្រេកអរ ទ្រង់ត្រាស់ហៅខ្ញុំថា ម្នាលវក្កលិ ខ្ញុំបានឮព្រះពុទ្ធដីកានោះហើយ ក៏មានចិត្តត្រេកអរ ។ កាលនោះ ខ្ញុំស្ទុះទៅត្រង់ជ្រោះភ្នំ មានជម្រៅច្រើនយោជន៍រយ ដើរទៅកាន់ផែនដី ដោយស្រួលដោយពុទ្ធានុភាព ។ ព្រះមហាមុនីទ្រង់សំដែងធម៌ គឺការកើតឡើងនិងការសូន្យនៃខន្ធទាំងឡាយ ឬទៀត ខ្ញុំបានដឹងនូវធម៌នោះហើយ ក៏បានដល់នូវអរហត្តផល ។

ខុទ្ទកំ វក្កលិត្ថេរាបទានំ

សុមហាបរិសមជ្ឈេ(១) តទា មំ ចរណុត្តមោ(២)
អគ្គំ សទ្ធាធិមុត្តានំ បញ្ញាបេតិ(៣) មហាមតិ ។
សតសហស្សេ ឥតោ កប្បេ យំ កម្មមករឹ តទា
ទុគ្គតឹ នាភិជានាមិ ពុទ្ធបូជាយិទំ ផលំ ។
កិលេសា ឈាបិតា មយ្ហំ ភវា សព្វេ សមូហតា
នាគោវ ពន្ធនំ ឆេត្វា វិហរាមិ អនាសវោ ។
ស្វាគតំ វត មេ អាសិ មម ពុទ្ធស្ស សន្តិកេ
តិស្សោ វិជ្ជា អនុប្បត្តា កតំ ពុទ្ធស្ស សាសនំ ។
បដិសម្ភិទា ចតស្សោ វិមោក្ខាបិ ច អដ្ឋិមេ
ឆឡភិញ្ញា សច្ឆិកតា កតំ ពុទ្ធស្ស សាសនំ ។

ឥត្ថំ សុទំ អាយស្មា វក្កលិ ថេរោ ឥមា គាថាយោ អភាសិត្ថាតិ ។

វក្កលិត្ថេរស្ស អបទានំ សមត្តំ ។

---

១ ឱ. សុមហាបរិសាមជ្ឈេ ។ ២ ឱ. មរណុត្តមោ ។ ម. ចរណុត្តមោ ។ ៣ ឱ. បញ្ញាបេសិ ។ ម. បញ្ញបេសិ ។



វក្កលិត្ថេរាបទាន ទី ៨

គ្រានោះ ព្រះសម្ពុទ្ធមានប្រាជ្ញាច្រើន ទ្រង់ដល់នូវបំផុតនៃចរណៈ ទ្រង់តាំងខ្ញុំជាកំពូលនៃពួកភិក្ខុ ដែលជាសទ្ធាធិមុត្ត ក្នុងកណ្តាលបរិស័ទច្រើន ។ ក្នុងកប្បទីមួយសែន អំពីកប្បនេះ ព្រោះហេតុដែលខ្ញុំបានធ្វើកុសលកម្ម ក្នុងកាលនោះ ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃពុទ្ធបូជា ។ កិលេសទាំងឡាយ ខ្ញុំដុតបំផ្លាញហើយ ភពទាំងអស់ ខ្ញុំដកចោលហើយ ខ្ញុំជាអ្នកមិនមានអាសវៈ ព្រោះបានកាត់ចំណង ដូចដំរីកាត់ផ្តាច់នូវទន្លីង ។ ឱ ខ្ញុំមកល្អហើយ ក្នុងសំណាក់ព្រះពុទ្ធរបស់ខ្ញុំ វិជ្ជា ៣ ខ្ញុំបានដល់ហើយ សាសនា របស់ព្រះពុទ្ធ ខ្ញុំបានធ្វើហើយ ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ។

បានឮថា ព្រះវក្កលិត្ថេរ មានអាយុ បានសំដែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

ចប់ វក្កលិត្ថេរាបទាន ។

# តតិយំ មហាកប្បិនត្ថេរាបទានំ

(១២៣) បទុមុត្តរោ នាម ជិនោ សព្វធម្មាន បារគូ
ឧទិតោ អជដាកាសេ(១) រវីវ សរទម្ពរេ ។
វចនាភាយ ពោធេតិ វេនេយ្យបទុមានិ សោ
កិលេសបង្កេ សោសេតិ មតិរំសីហិ នាយកោ ។
តិត្ថិយានំ យសេ(២) ហន្តិ ខជ្ជោតេ(៣) យថា រវិ
សច្ចត្ថំ សម្បកាសេតិ រតនំវ(៤) ទិវាករោ ។
គុណានំ អាយតីភូតោ រតនានំវ សាគរោ
បជ្ជុន្នោរិវ ភូតានំ(៥) ធម្មមេឃេន វស្សតិ ។
អក្ខទស្សោ តទា អាសឹ នគរេ ហំសសវ្ហយេ
ឧបេច្ច ធម្មមស្សោសឹ ជលជុត្តមនាមិនោ ។
ឱវាទកស្ស ភិក្ខូនំ សាវកស្ស សតាវិនោ(៦)
គុណំ បកាសយន្តស្ស ហាសយន្តស្ស(៧) មេ មនំ ។

---

១ ឱ. ម. ជលតាកាសេ ។ ២ ឱ. យសោ ។ ៣ ឱ. ម. ខជ្ជោតកា ។ ៤ ម. សច្ចត្ថាភំ បកាសេតិ រតនំវ ។ ៥ ម. បជ្ជុន្នោរិវ ភូតានិ ។ ៦ ឱ. ម. កតាវិនោ ។ ៧ ឱ. សសយន្តស្ស ។ ម. តប្បយន្តស្ស ។



# មហាកប្បិនត្ថេរាបទាន ទី ៣

(១២៣) ព្រះជិនស្រីព្រះនាមបទុមុត្តរៈ ទ្រង់ដល់នូវត្រើយនៃធម៌ទាំងពួង ទ្រង់រុងរឿងដូចព្រះអាទិត្យរះឡើងក្នុងអាកាស ក្នុងសរទកាល ។ ព្រះអង្គទ្រង់ញុំាងផ្កាឈូកគឺពួកវេនេយ្យសត្វឲ្យរីក ដោយពន្លឺគឺព្រះពុទ្ធដីកា ព្រះនាយកទ្រង់ញុំាងភក់គឺកិលេសឲ្យរីងស្ងួត ដោយរស្មីគឺប្រាជ្ញា ។ ព្រះនាយកទ្រង់សម្លាប់យសរបស់ពួកតិរ្ថិយ ដោយប្រាជ្ញាដូចកៅរើ ព្រះអង្គប្រកាសធម៌ក្នុងទីទាំងពួង ដូចព្រះអាទិត្យញុំាងយប់និងថ្ងៃឲ្យភ្លឺសព្វ ។ ព្រះអង្គជាទីកើតនៃគុណទាំង-ឡាយ ដូចជាសាគរជាទីកើតនៃរតនៈទាំងឡាយ ទ្រង់តែងបង្អុរភ្លៀងគឺធម៌ ឲ្យដល់ពួកសត្វ ដូចមេឃបង្អុរភ្លៀង ។ កាលនោះ ខ្ញុំជាចៅក្រម (អ្នកកាត់ក្តី) ក្នុងនគរឈ្មោះហង្ស-វតី បានចូលទៅស្តាប់ធម៌ របស់ព្រះមុនី ព្រះនាមបទុមុត្តរៈ ដែលកំពុងប្រទានឱវាទ ដល់ពួកភិក្ខុ កំពុងប្រកាសនូវគុណនៃសាវ័ក អ្នកមានសតិ ទ្រង់ញុំាងចិត្តរបស់ខ្ញុំឲ្យរីករាយ ។

សុត្វា បីតិសុមនោ និមន្តេត្វា តថាគតំ(១)

សសិស្សំ ភោជយិត្វាន តណ្ឋានំ អភិបត្ថយិំ ។

តទា ហំសសមភាគោ ហំសទុន្ទុភិនិស្សនោ(២)

បស្សថេតំ មហាមត្តំ វិនិច្ឆយវិសារទំ ។

មម(៣) បាទមូលេ បតិតំ សមុគ្គតតនូរុហំ(៤)

ជីមុត្តវណ្ណំ បីនំសំ(៥) បសន្ននយនាននំ ។

បរិវារេន មហតា រាជយុត្តំ មហាយសំ

ឯសោ តថាវិនោ ឋានំ បត្ថេតិ មុទិតាយ សោ ។

ឥមិនា បិណ្ឌបាតេន(៦) ចាគេន បណិធីហិ(៧) ច

កប្បសតសហស្សានិ នុបបជ្ជតិ ទុគ្គតឹ ។

---

១ ម. និមន្តេត្វា តថាគតំ សសិស្សំ លោកនាយកំ ឥតិ បាឋោ ទិស្សតិ ។ ២ ឱ. ហំសទុន្ទុភិនិស្សនោ ។ ម. ហំសទុន្ទុភិនិស្សនោ ។ ៣ ម. មំ ។ ៤ ឱ. សមុគ្គតតនូរុហំ ។ ម. សមុគ្គតតនូរុហំ ។ ៥ ឱ.ម. ជីមូតវណ្ណំ បីនំសំ ។ ៦ ឱ. បណិធានេន ។ ម. បណិធា-នេន ។ ៧ ឱ ម. បណិធាយ ។



ខ្ញុំបានស្តាប់ហើយ ក៏មានបីតិ មានចិត្តរីករាយ និមន្តព្រះតថាគត ព្រមទាំងភិក្ខុជាសិស្សឲ្យឆាន់ ហើយប្រាថ្នានូវតំណែងនោះ ។ កាលនោះ ព្រះនាយក ទ្រង់មានចំណែកប្រៀបស្មើដោយសត្វហង្ស ទ្រង់បញ្ចេញព្រះរាជដូចជាស្គរមានសំឡេងដូចសត្វហង្ស ដូច្នេះថា

អ្នកទាំងឡាយ ចូរមើលមហាមាត្យនុ៎ះ ជាអ្នកក្លៀវក្លាក្នុងការកាត់ក្តី ជាអ្នកមានរោមរៀវឆានចុងង មានកែវភ្នែកនិងមុខស្រស់បស់ល្អ ទ្រង់ព្រៀងដូចសម្បុរកៃផ្មួត កំពុងក្រាបទៀបបាទមូលនៃតថាគត ជាអ្នកមានយសធំ ដោយបរិវារច្រើន ដែលស្តេចទ្រង់ប្រទានឲ្យ ឯមហាមាត្យនុ៎ះ ប្រាថ្នានូវតំណែងរបស់ភិក្ខុ ដែលជាអ្នកឈ្លាសក្នុងពាក្យ ដោយចិត្តរីករាយ មហាមាត្យនុ៎ះ នឹងមិនទៅកាន់ទុគ្គតិ អស់មួយសែនកប្ប ដោយចង្ហាន់បិណ្ឌបាតនេះផង ដោយការបរិច្ចាគនេះផង ដោយការតាំងសេចក្តីប្រាថ្នានេះផង ។

ទេវេសុ ទេវសោភាគ្យំ មនុស្សេសុ មហត្តំ(១)
អនុភោត្វាន សេសេន(២) និព្វានំ បាបុណិស្សតិ ។
សតសហស្សេ ឥតោ កប្បេ ឱក្កាកកុលសម្ភវោ
គោតមោ នាម នាមេន សត្ថា លោកេ ភវិស្សតិ ។
តស្ស ធម្មេសុ ទាយាទោ ឱរសោ ធម្មនិម្មិតោ
កប្បិនោ នាម នាមេន ហេស្សតិ សត្ថុសាវកោ ។
តតោហំ សុកតំ ការំ កត្វាន ជិនសាសនេ
ជហិត្វា មានុសំ ទេហំ តុសិតំ អគមាសហំ ។
ទេវមនុស្សរជ្ជានិ សត្តសោ អនុសាសិយ
ពារាណសិសមាសន្នេ(៣) ជាតោ កេណិយជាតិយា ។
សតសហស្សបរិវារោ(៤) សបជាបតិកោ អហំ
បញ្ចបច្ចេកពុទ្ធានំ សតានិ សមុបដ្ឋហឹ ។

---

១ ឱ.ម. មហន្តតំ ។ ២ ឱ ម. អនុភុត្វានសេសេន ។ ៣ ឱ. ពារាណសិយំ អាសន្នេ ។
៤ ឱ.ម. សតសហស្សបរិវារេន ។



មហាមាត្យនុ៎ះ នឹងទទួលនូវសិរីរបស់ទេវតា ក្នុងទេវលោក នូវភាពជាធំក្នុងមនុស្ស នឹងបានដល់នូវព្រះនិព្វាន ដោយសេសសល់នៃផល ។ ក្នុងកប្បទីមួយសែន អំពីកប្បនេះ ព្រះសាស្ដាព្រះនាមគោតម ទ្រង់កើតក្នុងត្រកូលក្សត្រឱក្កាកៈ នឹងត្រាស់ឡើងក្នុងលោក ។ ឯមហាមាត្យនេះ នឹងបានជាធម្មទាយាទ របស់ព្រះគោតមនោះ ជាឱរស ជាធម្មនិម្មិត មាននាមថា កប្បិនៈ ជាសាវករបស់ព្រះសាស្ដានោះ ។

លំដាប់នោះ ខ្ញុំធ្វើសក្ការៈដ៏ល្អ ក្នុងសាសនារបស់ព្រះជិនស្រី លុះខ្ញុំលះកន្លែងកាយជារបស់មនុស្សហើយ ទៅកើតក្នុងឋានតុសិត ។ ខ្ញុំបានគ្រប់គ្រងនូវទេវរាជសម្បត្តិ និងមនុស្សរាជសម្បត្តិ ដោយស្ដប់ស្ដល់ហើយ ទើបខ្ញុំមកកើតក្នុងកំណើតកេណិយៈ ជិតក្រុងពារាណសី ។ ខ្ញុំមានបរិវារមួយសែន មានភរិយា បានចូលទៅបម្រើព្រះបច្ចេកពុទ្ធ ៥០០ អង្គ ។

តេមាសំ ភោជយិត្វាន  អទម្ហ(១) តិចីវរំ
តតោ ចុតា មយំ សព្វេ  អហុម្ហ តិទសូបគា ។
បុនោ សព្វេ មនុស្សត្តំ  អាគតម្ហា(២) តតោ ចុតា(៣)
កុក្កុដម្ហិ បុរេ ជាតា  ហិមវន្តស្ស បស្សតោ ។
កប្បិនោ នាមហំ អាសិំ  រាជបុត្តោ មហាយសោ
សេសាមច្ចកុលេ ជាតា  មមេវ បរិវារយុំ ។
មហារជ្ជសុខំ បត្តា  សព្វកាមសមិទ្ធិនោ(៤)
វាណិជេហិ សមក្ខាតំ  ពុទ្ធុប្បាទមហំ សុណិំ(៥) ។
ពុទ្ធោ លោកេ សមុប្បន្នោ  អសមោ ឯកបុគ្គលោ
សោ បកាសេតិ សទ្ធម្មំ  អមតំ សុខមុត្តមំ ។
សុយុត្តា តស្ស សិស្សា ច  សុមុត្តា ច អនាសវា
សុត្វា នេសំ វចនំ  សក្ការិត្វាន វាណិជេ ។

---

១ ទ.ម. បច្ចាទម្ហ ។ ២ ទ. អាគមម្ហ ។ ម. អគមិម្ហ ។ ៣ ម. ចុតោ ។ ៤ ទ. ម. សព្វកាមសមិទ្ធិហ ។ ៥ ទ. ពុទ្ធុប្បាទមហាបុណ្ណំ ។





យើងខ្ញុំទាំងនេះ ញុំាងព្រះបច្ចេកពុទ្ធឲ្យឆាន់ផង ឲ្យស្លៀកពាក់ត្រៃចីវរផង អស់៣ខែ រួចច្យុតចាកអត្តភាពនោះ ទៅកើតក្នុងឋានតាវត្តិង្ស ។ យើងទាំងអស់ច្យុតចាកទេវតានោះ មកកាន់អត្តភាពរបស់មនុស្ស កើតក្នុងកុក្កុដវតី ជិតព្រៃហិមពាន្ត ។ ខ្ញុំជារាជបុត្រ មាននាមថា កប្បិនៈ មានយសធំ ឯទេវតាដ៏សេស មកកើតក្នុងត្រកូលអាមាត្យ ហែហមខ្ញុំ ។ ខ្ញុំដល់នូវសេចក្ដីសុខ ដោយរាជសម្បត្តិដ៏ធំ សម្រេចសេចក្ដីប្រាថ្នាទាំងពួង ខ្ញុំបានឮនូវការកើតឡើងនៃព្រះពុទ្ធ ដោយពួកពាណិជប្រាប់ថា ព្រះពុទ្ធត្រាស់ឡើងហើយ ក្នុងលោក ទ្រង់ជាបុគ្គលឯក ឥតមានបុគ្គលស្មើ ព្រះអង្គនោះទ្រង់ប្រកាសនូវព្រះសទ្ធម្មគឺអមតៈ ជាសុខដ៏ឧត្តម ។ ឯពួកសិស្សរបស់ព្រះសម្ពុទ្ធអង្គនោះ ប្រកបព្យាយាមល្អ រួចស្រឡះចាកកិលេស ជាអ្នកមិនមានអាសវៈ លុះខ្ញុំស្ដាប់ពាក្យរបស់ពាណិជទាំងនោះហើយ ក៏ធ្វើសក្ការៈចំពោះពួកពាណិជនោះ ។

បហាយ(១) រជ្ជំ សាមញ្ញោ និក្ខមឹ ពុទ្ធមាមកោ

នទឹ ទិស្វា មហានទឹ បូរិតំ សមតិត្តិកំ ។

អប្បតិត្ថំ អនាលម្ពំ ទុត្តរំ សីឃវាហិនឹ

គុណំ សរិត្វា ពុទ្ធស្ស សោត្ថិនា សមតិក្កមឹ ។

ភវសោតំ សចេ ពុទ្ធោ តិណ្ណោ លោកន្តគូ វិទូ(២)

ឯតេន សច្ចវជ្ជេន គមនំ មេ សមិជ្ឈតុ ។

យទិ សន្តិគមោ មគ្គោ មោក្ខញ្ចំ សន្តិកំ(៣) សុខំ

ឯតេន សច្ចវជ្ជេន គមនំ មេ សមិជ្ឈតុ ។

សង្ឃោ ចេ តិណ្ណកន្តារោ បុញ្ញក្ខេត្តោ អនុត្តរោ

ឯតេន សច្ចវជ្ជេន គមនំ មេ សមិជ្ឈតុ ។

១ ម. វិហាយ ។ ២ ម. វិទូ ។ ៣ ឱ. មោក្ខញ្ច សន្តិកំ ។ ម. មោក្ខញ្ចច្ចន្តិកំ ។



ខ្ញុំព្រមទាំងភរិយា ជាអ្នកកាន់តាមព្រះពុទ្ធ ស៊ូលះរាជ្យចេញ ដើរទៅ បានឃើញស្ទឹងមហាចន្ទា មានទឹកពេញប្រៀប ៗ ជាស្ទឹងមិនមានកំពង់ មិនមានឈើស្ព ( ស្ពាន ) គេឆ្លងបានដោយក្រ ជាស្ទឹងមានខ្សែទឹកហ័ស ខ្ញុំរលឹកគុណព្រះសម្ពុទ្ធហើយ ក៏ឆ្លងបានដោយសួស្តី ដោយគិតថា ប្រសិនបើ ព្រះសម្ពុទ្ធទ្រង់ឆ្លងនូវខ្សែទឹក គឺភពហើយ ដល់នូវព្រះនិព្វានជាទីបំផុតនៃលោក ទ្រង់ជ្រាបច្បាស់ (ត្រាស់ទៀងពិតមែន) ដំណើររបស់ខ្ញុំ សូមឲ្យសម្រេច ដោយពាក្យសច្ចៈនេះ ៗ ប្រសិនបើ មគ្គជាដំណើរទៅកាន់ទីស្ងប់រម្ងាប់ ជាទីឲ្យនូវការរួចស្រឡះកិលេស ជាទីស្ងប់រម្ងាប់ ជាទីសុខ ( មានពិតមែន ) ដំណើររបស់ខ្ញុំ សូមឲ្យសម្រេច ដោយពាក្យសច្ចៈនេះ ៗ ប្រសិនបើ ព្រះសង្ឃជាអ្នកឆ្លងផុតចាកភពហើយ ជាបុញ្ញក្ខេត្តដ៏ប្រសើរ (មានពិតមែន) ដំណើររបស់ខ្ញុំ សូមឲ្យសម្រេច ដោយពាក្យសច្ចៈនេះ ៗ

## តតិយំ មហាកប្បិនត្ថេរាបទានំ

សហ កាលេ សត្ថុរេ មត្តា អនេកានំ(១) ផលំ
គតោ សុវេទន ឧត្តិណ្ណោ ចជិតេ មនោរមេ ។
ឆសិទ្ធិំ អត្ថសិ តុដ្ឋិំ ឧបេត្តិ បកត្តិំ
ផលន្តិ ហេមសេលិវ ធីបត្តិំ ជោតិតំ ។
សសីវ តារកសហិតំ សារកោហំ បុត្តាតិ
អាសិ រិយ(២) វស្សត្តិំ ធេវេន ផលខន្ធិ(៣) ។
វត្ថិត្វាន សហាមត្តោ ឯកាបត្តិ ឧតារិសិ
គតោ អជ្ឈាសយំ(៤)ញត្វា តុត្ថោ ធម្មមទេសយំ ។
សុត្វាន ធម្មំ វិមលំ អកេតុម្ហ មយំ ជិនំ
បញ្ញាវេហិ មហាវីរ ខិតិណ្ណម្ហ(៥) ករ មយំ ។
ស្វាគតោ ភិក្ខវេ ធម្មោ ទុក្ខន្តស្ស ការកយ(៦) រាក
ចរថ ព្រហ្មចរិយំ ឥច្ចាហ មុនិ សត្តមោ ។

---

១ ឱ. ចរេតតំ ។ ២ ឱ. ម. ភាសរិ វិយ ។ ៣ ឱ. ទេសនា ផលខន្ធំ ។ ម. ទេសនា ផលបន្ធំ ។ ៤ ឱ. ម. គោ អាសយំ ។ ៥ ឱ. និត្ថិណ្ណម្ហ ។ ម. និត្តិន្នម្ហ ។ ៦ ឱ. ម. ទុក្ខន្តការកាយ ។



## មហាកប្បិនត្ថេរាបទាន ទី ៣

លុះខ្ញុំឮព្រះពុទ្ធដីកាហើយ ចិត្តស្ងប់ក៏កើតឡើងដល់ខ្ញុំ លំដាប់នោះ ខ្ញុំក៏កើតត្រេកអរស្ងប់ ជាវិបាកនៃទានដោយ សទ្ធាភាព ។ ខ្ញុំបានឃើញព្រះពុទ្ធទ្រង់គង់នៅ មានរស្មីដូចព្រះអាទិត្យដែលរះឡើង ទ្រង់រុងរឿងដូចភ្លើងមាស មានពន្លឺដូចដើមឈើប្រចាំទ្វីប ។ មានពួកសាវ័កហែហមក្រោម ដូចព្រះចន្ទដែលប្រកបដោយពួកផ្កាយ ឬដូចជាទឹកហូរដែលទៅ-តាមដងស្ទឹងមក ទ្រង់ជាទីពឹងរបស់ពួកជន ។ ខ្ញុំព្រមទាំងអាមាត្យ លុះថ្វាយបង្គំហើយ ចូលទៅគាល់ព្រះសម្ពុទ្ធ ។ លំ-ដាប់នោះ ព្រះសម្ពុទ្ធទ្រង់ជ្រាបអធ្យាស្រ័យ ហើយបានសំដែងធម៌ ។ លុះយើងខ្ញុំស្តាប់ធម៌ស្អាត មិនមានមន្ទិល ទើបក្រាបទូលព្រះជិនស្រីថា បពិត្រព្រះអង្គដ៏ទ្រង់ព្យាយាមធំ សូមព្រះអង្គបំបួស យើងខ្ញុំនឹងឆ្លងកត់ភពទាំងឡាយ ។ ព្រះសម្ពុទ្ធ ជាព្រះមុនីទី ៧ ទ្រង់ត្រាស់ដូច្នេះថា ម្នាលភិក្ខុទាំងឡាយ ធម៌ដែលតថាគតពោលល្អហើយ ដល់អ្នកទាំងឡាយ ជាធម៌ប្រព្រឹត្តទៅ ដើម្បីធ្វើនូវព្រះនិព្វាន ជាទីបំផុតនៃកងទុក្ខ អ្នកទាំងឡាយ ចូរប្រព្រឹត្តព្រហ្មចរិយៈចុះ ។

សហ ភរិយាយ សទ្ធិំ ភិក្ខុបេសនក មយំ
អហុម្ហា(១) ឧបសម្បន្នា សោតាបន្នា សាសនេ ។
តតោ ជេតវនំ គន្ត្វា អនុសាសិ វិនាយកោ
អនុសិដ្ឋា ជិនេនាហំ អរហត្តំ អបាបុណឹ ។
តតោ ភិក្ខុសហស្សានិ អនុសាសិមហំ តទា
មមានុសាសនករា តេបិ អាសុំ អនាសវា ។
ជិនោ តស្មិំ គុណេ តុដ្ឋោ ឯតទគ្គេ ឋបេសិ មំ
ភិក្ខុឱវាទកានគ្គោ កប្បិនោតិ មហាជនេ(២) ។
សតសហស្សេ កតំ កម្មំ ផលំ ទស្សេសិ មេ ឥធ
សុមុត្តោ សរវេគោវ កិលេសេ ឈាបយឹ មម ។

១ ម. អហុម្ហ ។ ២ ម. មហាជិនេ ។



ពួកយើងខ្ញុំទាំងអស់ ទ្រទ្រង់ភេទជាភិក្ខុក្នុងកាលនៃព្រះពុទ្ធ-ដីកា លុះបានឧបសម្បទាហើយ ក៏បានជាសោតាបន្នបុគ្គលក្នុងសាសនា ។ លំដាប់នោះ ព្រះនាយកទ្រង់ស្ដេចទៅកាន់វត្តជេតពន ទ្រង់ប្រៀនប្រដៅខ្ញុំ ឯខ្ញុំដែលព្រះជិនស្រីទ្រង់ប្រៀនប្រដៅហើយ ក៏បានដល់នូវព្រះអរហត្ត ។ លំ-ដាប់នោះ ខ្ញុំប្រដៅពួកភិក្ខុមួយពាន់រូប ពួកភិក្ខុទាំងមួយពាន់នោះ ធ្វើតាមពាក្យប្រៀនប្រដៅរបស់ខ្ញុំ ក៏នៅជាអ្នកមិនមានអាសវៈ ក្នុងកាលនោះ ។ ព្រះជិនស្រីទ្រង់ត្រេកអរ ក្នុងគុណនោះ ទ្រង់តាំងខ្ញុំក្នុងទីជាឯតទគ្គៈ ក្នុងកណ្ដាលមហា-ជនថា កប្បិនភិក្ខុ ជាកំពូលនៃពួកសាវ័កអ្នកឲ្យឱវាទភិក្ខុ ។ ព្រះជិនស្រីទ្រង់សំដែងផលកម្ម ដែលខ្ញុំធ្វើហើយ ក្នុងកប្បទីមួយសែន ក្នុងសាសនានេះ ខ្ញុំមានចិត្តរួចស្រឡះហើយ ដូចជាសន្ទុះនៃកូនសរ ខ្ញុំដុតកិលេសទាំងឡាយរបស់ខ្ញុំហើយ ។

កិលេសា ឈាបិតា មយ្ហំ ភវា សព្វេ សមូហតា
នាគោវ ពន្ធនំ ឆេត្វា វិហរាមិ អនាសវោ ។
ស្វាគតំ វត មេ អាសិ មម ពុទ្ធស្ស សន្តិកេ
តិស្សោ វិជ្ជា អនុប្បត្តា កតំ ពុទ្ធស្ស សាសនំ ។
បដិសម្ភិទា ចតស្សោ វិមោក្ខាបិ ច អដ្ឋិមេ
ឆឡភិញ្ញា សច្ឆិកតា កតំ ពុទ្ធស្ស សាសនំ ។

ឥត្ថំ សុទំ អាយស្មា មហាកប្បិនោ ថេរោ ឥមា គាថាយោ អភាសិត្ថាតិ ។

មហាកប្បិនត្ថេរស្ស អបទានំ សមត្តំ ។

## ចតុត្ថំ ទព្វមល្លបុត្តត្ថេរាបទានំ

(១៦៤) បទុមុត្តរោ នាម ជិនោ សព្វលោកវិទូ មុនិ
ឥតោ សតសហស្សម្ហិ កប្បេ ឧប្បជ្ជិ ចក្ខុមា ។





កិលេសទាំងឡាយ ខ្ញុំដុតបំផ្លាញហើយ ភពទាំងអស់ ខ្ញុំដកចោលហើយ ខ្ញុំជាអ្នកមិនមានអាសវៈ ព្រោះបានកាត់ចំណង ដូចជាដំរីកាត់ផ្តាច់នូវទម្លីង ។ ឱ ! ខ្ញុំមកល្អហើយ ក្នុងសំណាក់ព្រះពុទ្ធរបស់ខ្ញុំ វិជ្ជា ៣ ខ្ញុំបានដល់ហើយ សាសនា របស់ព្រះពុទ្ធ ខ្ញុំបានធ្វើហើយ ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនា របស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ។

បានឮថា ព្រះមហាកប្បិនត្ថេរ មានអាយុ បានសម្តែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

ចប់ មហាកប្បិនត្ថេរាបទាន ។

## ទព្វមល្លបុត្តត្ថេរាបទាន ទី ៤

(១៦៤) ក្នុងកប្បទីមួយសែន អំពីកប្បនេះ ព្រះជិនស្រី ព្រះនាមបទុមុត្តរៈ ជាអ្នកប្រាជ្ញ ទ្រង់ជ្រាបនូវលោកទាំងពួង ព្រះអង្គមានចក្ខុ ទ្រង់កើតឡើងហើយ ។

ឱភធរោ វិញ្ញាបកោ តារកោ សព្វបាណិនំ

ទេសនាកុសលោ ពុទ្ធោ តារេសិ ជនតំ ពហុំ ។

អនុកម្បកោ ការុណិកោ ហិតេសី សព្វបាណិនំ

សម្បត្តេ តិត្ថិយេ សព្វេ បញ្ចសីលេ បតិដ្ឋហិ ។

ឯវំ និរាកុលំ អាសិ សុញ្ញតំ តិត្ថិយេហិ ច

វិចិត្តំ អរហន្តេហិ វសីភូតេហិ តាទិភិ ។

រតនដ្ឋបញ្ញាសំ ឧច្ចត្តោ សោ មហាមុនិ

កញ្ចនគ្ឃិយសង្កាសោ ពត្តឹសវរលក្ខណោ ។

វស្សសតសហស្សានិ អាយុ វិជ្ជតិ តាវទេ

តាវតា តិដ្ឋមានោ សោ តារេសិ ជនតំ ពហុំ ។

តទាហំ ហំសវតិយំ សេដ្ឋិបុត្តោ មហាយសោ

ឧបេត្វា លោកបជ្ជោតំ អស្សោសឹ ធម្មទេសនំ ។



ព្រះពុទ្ធទ្រង់ប្រកាន់ទុកហេង ទ្រង់ប៉ុន្តិ ទ្រង់ចម្លងពួកសត្វទាំងពួង ទ្រង់ឈ្លាសក្នុងទេសនា ចម្លងប្រជុំជនដ៏ច្រើន ។ ព្រះអង្គមានសេចក្ដីអនុគ្រោះ មានសេចក្ដីករុណា ទ្រង់ស្វែងរកប្រយោជន៍ដល់សត្វទាំងពួង តែងញ៉ាំងពួកតិរ្ថិយទាំងពួងដែលជួបប្រទះឲ្យតាំងនៅក្នុងសីល ៥ ។ កាលយ៉ាំងនេះ សាសនារបស់ព្រះអង្គមិនរើករ ជាសាសនាសូន្យចាកពួកតិរ្ថិយ ជាសាសនាវិចិត្រដោយពួកព្រះអរហន្ត ដែលស្ទាត់ជំនាញ ជាតាទិបុគ្គល ។ ព្រះមហាមុនីអង្គនោះ មានកំពស់ ៥៨ ហត្ថ ប្រាកដស្មើដោយគ្រឿងបូជា ជាការៈនៃមាស មានលក្ខណៈដ៏ប្រសើរ ៣២ ប្រការ ។ មានព្រះជន្មាយុមួយសែនឆ្នាំ ព្រះបទុមុត្តរៈអង្គនោះ កាលប្រតិស្ឋាននៅ ទ្រង់ចម្លងប្រជុំជនច្រើន កំណត់ត្រឹមនោះ ។ កាលនោះ ខ្ញុំកើតជាសេដ្ឋបុត្ត មានយសធំ ក្នុងក្រុងហង្សវតី បានចូលទៅជិតព្រះសម្ពុទ្ធ ជាប្រទីបក្នុងលោក បានស្ដាប់ធម្មទេសនា ។

សេនាសនានិ ភិក្ខូនំ    បញ្ញាបេត្វា សសាវកំ
កិត្តយន្តស្ស វចនំ    សុណិត្វា មុនិនោ អហំ ។

អធិការំ សសង្ឃស្ស    កត្វា តស្ស មហេសិនោ
និបច្ច សិរសា បាទេ    តំ ឋានំ អភិបត្ថយិំ ។

តទា ហិ សោ(១) មហាវីរោ    មម កម្មំ បកិត្តយិ(២)
យោ យំ សសង្ឃំ ភោជេសិ    សត្តាហំ លោកនាយកំ ។

សោយំ កមលបត្តក្ខោ    សីហំសោ កនកត្តចោ
មម(៣) ឋានមុបេច្ច និបតិ(៤)    បត្ថយិ(៥) ឋានមុត្តមំ ។

សតសហស្សេ ឥតោ កប្បេ    ឱក្កាកកុលសម្ភវោ
គោតមោ នាម នាមេន    សត្ថា លោកេ ភវិស្សតិ ។

សាវកោ តស្ស ពុទ្ធស្ស    ឧគ្គោ នាមេន វិស្សុតោ
សេនាសនបញ្ញាបកោ    អគ្គោ ហេស្សតិយំ តទា(៦) ។

---

១ ឱ. តទាហំ សោ ។ ២ ឱ. បកិត្តយិ ។ ៣ ឱ. មំ ។ ៤ ឱ. បតិតោ ។ ៥ ឱ. បត្ថយិ ។ ៦ ឱ. ហេស្សតយំ តទា ។





ខ្ញុំបានស្តាប់ព្រះពុទ្ធដីកា របស់ព្រះមុនី ទ្រង់សរសើរអំពើ នៃសាវ័ករបស់ព្រះអង្គ ជាអ្នកក្រាលសេនាសនៈដល់ពួកភិក្ខុ ក៏មានចិត្តរីករាយ ។ ខ្ញុំធ្វើការគោរពចំពោះសង្ឃ ហើយក្រាបចុះទៀបព្រះបាទា របស់ព្រះមហេសីអង្គនោះ ដោយសិរ្ស: ប្រាថ្នានូវតំណែងនោះ ។ កាលនោះ ព្រះមហាវីរៈអង្គនោះ ទ្រង់សរសើរនូវកម្មរបស់ខ្ញុំថា

កុលបុត្តណា ញុំាងតថាគតជាលោកនាយក ព្រមទាំងភិក្ខុសង្ឃឲ្យឆាន់ អស់ ៧ ថ្ងៃ ។ កុលបុត្រនោះ មានភ្នែកដូចត្របកឈូក មានស្មាដូចសត្វសីហៈ មានសម្បុរដូចមាស ក្រាបចុះទៀបបាទមូលនៃតថាគត ហើយប្រាថ្នានូវទីដ៏ប្រសើរ ។ ក្នុងកប្បទីមួយសែន អំពីកប្បនេះ ព្រះសាស្តាព្រះនាមគោតម ទ្រង់កើតក្នុងត្រកូលឱក្កាកៈ នឹងបានត្រាស់ក្នុងលោក ។ កុលបុត្តនេះ នឹងបានជាសាវ័ករបស់ព្រះពុទ្ធអង្គនោះ ប្រាកដនាមថាឧគ្គៈ ជាអ្នកក្រាលអាសនៈជាកំពូល (នៃសាវ័កទាំងពួង) ។

តេន កម្មេន សុកតេន ចេតនាបណិធីហិ ច
ជហិត្វា មានុសំ ទេហំ តាវតឹសំ អគញ្ឆហំ ។
សតានំ តីណិក្ខត្តុញ្ច ទេវរជ្ជមការយឹ
តថា បញ្ចសតក្ខត្តុំ ចក្កវត្តី អហោសហំ ។
បទេសរជ្ជំ វិបុលំ គណនាតោ អសង្ខិយំ
សព្វត្ថ សុខិតោ អាសឹ តស្ស កម្មស្ស វាហសា ។
ឯកនវុតេ ឥតោ កប្បេ វិបស្សី នាម នាយកោ
ឧប្បជ្ជិ ចារុនយនោ(១) សព្វធម្មវិបស្សកោ ។
ទុដ្ឋចិត្តោ ឧបវទឹ សាវកំ តស្ស តាទិនោ
សព្វាសវបរិក្ខីណំ សុទ្ធោតិ ច វិជានិយ ។
តស្សេវ នរវីរស្ស សាវកានំ មហេសិនំ
សលាកញ្ច គហេត្វាន ខីរោទនមទាសហំ ។

១ ម. ចារុទស្សនោ ។





ខ្ញុំលះបង់កាយ ជារបស់មនុស្សហើយ បានទៅកើតឯឋានតាវត្តិង្ស ដោយកម្មដែលខ្ញុំធ្វើល្អនោះផង ដោយការតាំងសេចក្តីប្រាថ្នានោះផង ។ ខ្ញុំបានទទួលទេវរាជសម្បត្តិអស់ ៣០០ ដង បានជាស្តេចចក្រពត្តិ អស់ ៥០០ ដង ។ ខ្ញុំបានគ្រប់គ្រងប្រទេសរាជ្យដ៏ធំទូលាយ រាប់ជាតិមិនអស់ ខ្ញុំដល់នូវសេចក្តីសុខ ក្នុងភពទាំងពួង ដោយអំណាចនៃកុសលកម្មនោះ ។ ក្នុងកប្បទី ៩១ អំពីកប្បនេះ ព្រះនាយកព្រះនាមវិបស្សី ទ្រង់មានព្រះនេត្រដ៏ល្អ ទ្រង់ឃើញច្បាស់នូវធម៌ទាំងពួង ទ្រង់ត្រាស់ឡើង ។ ខ្ញុំមានចិត្តប្រទូស្ត តិះដៀលសាវ័កអ្នកមិនមានអាសវៈទាំងពួង របស់ព្រះអង្គ ជាតាទិបុគ្គល ហើយប្តេជ្ញាថា អាត្មាអញស្អាត ។ (លុះមកខាងក្រោយ) ខ្ញុំកាន់យកស្លាកហើយ ប្រគេនបាយលាយដោយទឹកដោះស្រស់ ដល់ពួកសាវ័កអ្នកស្វែងរកសីលគុណរបស់ព្រះវិបស្សីអង្គនោះ ទ្រង់មានព្យាយាមជាងពួកនរៈ ។

ឥមម្ហិ ភទ្ទកេ កប្បេ ព្រហ្មពន្ធុ មហាយសោ
កស្សបោ នាម នាមេន ឧប្បជ្ជិ វទតំ វរោ ។
សាសនំ ជោតយិត្វាន អភិភុយ្យ កុតិត្ថិយេ
វិនេយ្យេ វិនយិត្វាន និព្វុតោ សោ សសាវកោ ។
សសិស្សេ និព្វុតេ នាថេ អត្ថមេន្តម្ហិ សាសនេ
ទេវា កន្ទឹសុ សំវិគ្គា មុត្តកេសា រុទម្មុខា
និព្វាយិស្សតិ ធម្មក្ខោ ន បស្សិស្សាម សុព្វតេ
ន សុណិស្សាម សទ្ធម្មំ អហោ នោ អប្បបុញ្ញតា ។
ចលាយំ បថវី សព្វា អចលា សា ពុលាពុលី (១)
សាគរោ ច សសោកោវ(២) វិនទី ករុណំ គិរំ ។

១ ទុ.ម ចលាចលា ។ ២ ទុ.ម. សសោកោវ ។



ក្នុងកប្បនេះ ព្រះសម្ពុទ្ធព្រះនាមកស្សបៈ មានផៅពង្សដ៏ប្រសើរ ទ្រង់មានយសធំ ប្រសើរជាងពួកអ្នកប្រាជ្ញ ទ្រង់ត្រាស់ឡើង ។ ព្រះសម្ពុទ្ធអង្គនោះ ព្រមទាំងសាវ័ក ទ្រង់ញុំាងសាសនាឲ្យរុងរឿង ទ្រង់គ្របសង្កត់ពួកតិរ្ថិយអាក្រក់ ទ្រង់ណែនាំវេនេយ្យសត្វ ហើយបរិនិព្វាន ។ កាលព្រះលោកនាថ ព្រមទាំងសិស្សបរិនិព្វានហើយ កាលសាសនាសាបសូន្យហើយ ពួកទេវតាមានសេចក្តីតក់ស្លុត រំសាយសក់ មានមុខទទឹកដោយទឹកភ្នែក កន្ទក់កន្ទេញថា ព្រះសម្ពុទ្ធទ្រង់ប្រាប់ធម៌ នឹងបរិនិព្វាន ពួកយើងនឹងមិនឃើញព្រះអង្គដែលមានវត្តល្អ នឹងមិនបានស្តាប់ព្រះសទ្ធម្ម ឱហ្ន៎ ពួកយើងចំជាអ្នកឥតបុណ្យមែន ។ កាលនោះឯង ផែនដីទាំងមូលនេះ ដែលជារបស់មិនញាប់ញ័រ ផែនដីនោះធំទូលាយផង សាគរព្រមទាំងសោកផង ក៏បន្លឺសំរែកករុណា ។

ចតុទ្ទិសា នទ្ទុតិយោ(១) ណាទយឹសុ អមានុសា(២)
សមន្តតោ អសនិយោ ផលឹសុ ច ភយាវហា ។
ឧក្កា បតឹសុ នភសា ធូមកេតុ បទិស្សថ(៣)
សធូមា ជាលវដ្ដា ច(៤) រវឹសុ ការុណំ មិគា ។
ឧប្បាតេ ទារុណេ ទិស្វា សាសនន្តគ្គសូចកេ(៥)
សំវិគ្គា ភិក្ខុកេ សត្ត(៦) ចិន្តយិម្ហ មយំ តទា ។
សាសនេន វិនាម្ហាកំ(៧) ជីវិតេន អលំ មយំ
បវិសិត្វា មហារញ្ញំ យុញ្ជាម ជិនសាសនំ ។
អនុសម្ហ តតារញ្ញេ ឧទ្ទិទ្ធិ សេលបព្វតំ(៨)
និស្សេណិយា គមារុយ្ហ និស្សេណី ចាតយិម្ហសេ(៩) ។
តទា ឋិវិធំ ពោ ថេរេ ពុទ្ធុប្បាទោ សុទុល្លភោ
សទ្ធា ច ទុល្លភា(១០) លទ្ធា ពោធិតំ សេសញ្ច សាសនំ ។

១ ម. ទុន្ទុភិយោ ។ ២ ឱ. សមានុសា ។ ៣ ម. ច ទិស្សតិ ។ ៤ ឱ. សធូម ល-លិសត្តា ច ។ ៥ ឱ. សាសនន្តញ្ញ សូចកេ ។ ៦ ឱ. តត្ថ ។ ៧ ឱ. វិនាសម្ហ ។ ៨ ឱ. ម. សេលមុទ្ធំ ។ ៩ ឱ. ចាតយម្ហសេ ។ ១០ សព្វា ហិ សុលភា ។ ម. សទ្ធាតិ ទុល្លភា ។



ស្គរទាំងឡាយក្នុងទិសទាំង ៤ ដែលមិនមែនជារបស់មនុស្ស ក៏បន្លឺឡើង ផ្គរទាំងឡាយជារបស់នាំមកនូវភ័យ ក៏ធ្លាក់ចុះជុំទិស ។ ភ្លើងគប់ទាំងឡាយ ក៏ធ្លាក់មកអំពីអាកាស ផ្កាយដុះកន្ទុយ អណ្ដាតភ្លើង ព្រមទាំងផ្សែង ក៏ប្រាកដឡើង ពួកម្រឹគ ស្រែកនូវសំរែកករុណា ។ កាលនោះ យើងជាភិក្ខុនី ៧ រូប ឃើញហេតុអាក្រក់ ជាចម្រូងឲ្យវិនាសសាសនាកើតឡើង ក៏មានសេចក្ដីសង្វេគ គិតគ្នាថា ពួកយើងបើវៀរចាកសាសនាហើយ មិនគួររស់នៅឡើយ យើងទាំងឡាយគួរចូលទៅក្នុងព្រៃធំ ហើយប្រកបនូវសាសនារបស់ព្រះជិនស្រី ។ កាលនោះ ពួកខ្ញុំបានឃើញភ្នំខ្ពស់ក្នុងព្រៃ ដើរឡើងភ្នំនោះតាមជណ្ដើរ ហើយច្រានជណ្ដើរចោល ។ គ្រានោះ ព្រះថេរៈទូន្មាននូវពួកយើងថា ការកើតឡើងនៃព្រះពុទ្ធ ជាការកម្រណាស់ សទ្ធាសោតក៏កើតបានដោយកម្រដែរ ឯសាសនាដែលសេសសល់នៅ ក៏ស្ដួចស្ដើង ។

វិបត្តិ ចណាតីតា អចរេត្ត ធុត្វាសាគរេ

តស្មា បយោគោ កត្តព្វោ យាវ តិដ្ឋតិ(១) សាសនំ ។

អរហា អាសិ សោ ថេរោ អនាគាមិ តទានុគោ

សុសីលា ឥតរេ យុត្តា ទេវលោកំ អគម្ហសេ ។

និព្វុតោ តិណ្ណសំសារោ សុទ្ធាវាសេ ច ឯកកោ

អហញ្ច បុក្កុសាតិ ច សភិយោ ពាហិយោ តថា ។

កុមារកស្សបោ ចេវ តត្ថ តត្ថូបគា មយំ

សំសារពន្ធា មុត្តា គោតមេនានុកម្បិតា ។

មល្លេសុ កុសិនារាយំ ជាតោ គព្ភេ ច មេ សតោ

មាតា មតា(២) ចិតការូឡ្ហា តតោ និបតិតោ អហំ ។

---

១ ទ. យាវ ឋាតិ ។ ម. យាវ ឋាតិ ។ ២ ទ. បិតា ។



សត្វទាំងឡាយក៏មានខណៈកន្លងហើយ រមែងធ្លាក់ចុះក្នុងសាគរគឺសេចក្តីទុក្ខ មិនមានទីបំផុត ព្រោះហេតុនោះ សាសនាប្រតិស្ឋាននៅ ដរាបណា ពួកយើងគប្បីធ្វើព្យាយាមដរាបនោះ ។ ព្រះថេរៈនោះជាព្រះអរហន្ត អនុត្ថេរជាលំដាប់នឹងមហាថេរៈនោះ ជាអនាគាមី ភិក្ខុទាំងឡាយក្រៅអំពីនេះ មានសីលល្អប្រកបព្យាយាម បានទៅកើតក្នុងទេវលោក ។ (ព្រះថេរៈ ១ រូប) មានសង្សារវដ្តឆ្លងហើយបរិនិព្វាន ព្រះថេរៈមួយរូបទៀតទៅកើតក្នុងសុទ្ធាវាសព្រហ្មលោក (ឯពួកយើង) គឺខ្ញុំ ១ បុក្កុសាតិ ១ សភិយៈ ១ ពាហិយៈ ១ និងព្រះកុមារកស្សបៈ ១ (នៅជាបុថុជ្ជន) ដូចគ្នា ពួកយើងក៏ចូលទៅកើតហើយក្នុងភពនោះ ៗ បានព្រះសម្ពុទ្ធ ព្រះនាមគោតមអនុគ្រោះ ក៏រួចស្រឡះចាកចំណងសង្សារ ។ ខ្ញុំកើតក្នុងត្រកូលមល្លៈ ក្នុងក្រុងកុសិនារា កាលខ្ញុំនៅក្នុងគភ៌ មាតារបស់ខ្ញុំស្លាប់ លុះគេលើកឡើងកាន់ជើងថ្ករ ខ្ញុំក៏ប្រូតចាកគភ៌នោះ

បតិតោ ទព្វបុញ្ជម្ហិ តតោ ទព្វោ វិស្សុតោ
ព្រហ្មចារីផលេនាហំ(១) វិមុត្តោ សត្តវស្សិកោ ។
ខីរោទនផលេនាហំ បញ្ចង្គេហិ ឧបាគតោ
ខីណាសវោបដ្ឋានេន ថោមេហិ ពហុ ថោមិតោ ។
ឧភោ បុញ្ញញ្ច បាបញ្ច វីតិវត្តោម្ហិ ទានហំ
បត្វាន បរមំ សន្តឹ វិហរាមិ អនាសវោ ។
សេនាសនំ បញ្ញាបយឹ ហាសយិត្វាន សុព្វតេ
ជិនោ តស្មឹ គុណេ តុដ្ឋោ ឯតគ្គេ ឋបេសិ មំ ។
កិលេសា ឈាបិតា មយ្ហំ ភវា សព្វេ សមូហតា
នាគោវ ពន្ធនំ ឆេត្វា វិហរាមិ អនាសវោ ។
ស្វាគតំ វត មេ អាសិ មម ពុទ្ធស្ស សន្តិកេ
តិស្សោ វិជ្ជា អនុប្បត្តា កតំ ពុទ្ធស្ស សាសនំ ។

---

១ ឱ. ព្រហ្មចរិផលេនាហំ ។



ធ្លាក់ទៅលើគំនរឈើដណ្ដកទាំងឡាយ ព្រោះហេតុនោះ ទើបខ្ញុំមានឈ្មោះប្រាកដថា ទព្វៈ ខ្ញុំមានអាយុ ៧ ឆ្នាំ មានចិត្តផុតស្រឡះចាកកិលេស ដោយផលនៃព្រហ្មចរិយៈ ។ ខ្ញុំប្រកបដោយអង្គៈ ៥ ដោយផលនៃបាយ ដែលលាយទឹកដោះស្រស់ ត្រូវបានគេសរសើរហើយដោយច្រើន ដោយការគោរពព្រះខីណាស្រព ។ ឥឡូវនេះ ខ្ញុំកន្លងបុណ្យនិងបាបទាំងពីរ បានដល់នូវសេចក្តីស្ងប់រម្ងាប់ក្រៃលែង ជាអ្នកមិនមានអាសវៈ ។ ខ្ញុំក្រាលសេនាសនៈ ញុំាងពួកលោកអ្នកមានវត្តល្អឲ្យរីករាយ ព្រះជិនស្រី ទ្រង់ត្រេកអរនឹងគុណនោះ ទើបតាំងខ្ញុំក្នុងទីជាឯតទគ្គៈ ។ កិលេសទាំងឡាយ ខ្ញុំដុតបំផ្លាញហើយ ភពទាំងពួង ខ្ញុំដកចោលហើយ ខ្ញុំជាអ្នកមិនមានអាសវៈ ព្រោះបានកាត់ចំណង ដូចជាដំរីកាត់ផ្តាច់នូវទន្លីង ។ ឱ ! ខ្ញុំមកល្អហើយ ក្នុងសំណាក់ព្រះពុទ្ធរបស់ខ្ញុំ វិជ្ជា ៣ ខ្ញុំបានដល់ហើយ សាសនា របស់ព្រះពុទ្ធ ខ្ញុំបានធ្វើហើយ ។

បដិសម្ភិទា ចតស្សោ វិមោក្ខាបិ ច អដ្ឋិមេ
ឆឡភិញ្ញា សច្ឆិកតា កតំ ពុទ្ធស្ស សាសនំ ។

ឥត្ថំ សុទំ អាយស្មា ទព្វោ មល្លបុត្តោ ថេរោ ឥមា
គាថាយោ អភាសិត្ថាតិ ។

ទព្វមល្លបុត្តត្ថេរស្ស អបទានំ សមត្តំ ។

## បញ្ចមំ កុមារកស្សបត្ថេរាបទានំ

(១៦៨) ឥតោ សតសហស្សម្ហិ កប្បេ ឧប្បជ្ជិ នាយកោ
សព្វលោកហិតោ ធីរោ បទុមុត្តរនាមកោ ។
តទាហំ ព្រាហ្មណោ ហុត្វា វិស្សុតោ វេទបារគូ
ទិវាវិហារំ វិចរំ អទ្ទសំ លោកនាយកំ ។
ចតុសច្ចំ បកាសេន្តំ ពោធយន្តំ សទេវកំ
សសាវកំ ចិត្តកថិកំ(១) វណ្ណយន្តំ មហាជនេ ។

១ ឱ.ម. វិចិត្តកថិកន្តំ ។





បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យ
ជាក់ច្បាស់ហើយ ទាំងសាសនា របស់ព្រះពុទ្ធ ខ្ញុំក៏បាន
ប្រតិបត្តិហើយ ។

បានឮថា ព្រះទព្វមល្លបុត្តត្ថេរ មានអាយុ បានសម្តែងនូវ
គាថាទាំងនេះ ដោយប្រការដូច្នេះ ។

ចប់ ទព្វមល្លបុត្តត្ថេរាបទាន ។

## កុមារកស្សបត្ថេរាបទាន ទី ៥

(១៦៨) ក្នុងកប្បទីមួយសែន អំពីកប្បនេះ ព្រះពុទ្ធ
ព្រះនាមបទុមុត្តរៈ ជានាយក ទ្រង់ទំនុកបម្រុងសត្វលោក
ទាំងពួង ជាអ្នកប្រាជ្ញ ទ្រង់កើតឡើង (ក្នុងលោក) ។ កាល
នោះ ខ្ញុំកើតជាព្រាហ្មណ៍ មានល្បីល្បាញ ជាអ្នកដល់នូវ
ត្រើយនៃត្រៃវេទ កាលដើរទៅដើម្បីសម្រាក ក្នុងវេលាថ្ងៃ
ក៏បានជួបប្រទះព្រះលោកនាយក ព្រះអង្គជាធម្មកថិកដ៏ត្រ-
កាល ទ្រង់កំពុងប្រកាសសម្តែងនូវសច្ចៈ ៤ កំពុងញ៉ាំង
មហាជន ព្រមទាំងទេវតា និងសាវ័ក ឲ្យត្រាស់ដឹង ។

តទា មុទិតចិត្តោហំ និមន្តេត្វា តថាគតំ
នានារត្តេហិ វត្ថេហិ អលង្ករិត្វាន មណ្ឌបំ ។
នានាគន្ធបវាសិតំ សសង្ឃំ ភោជយឹ តហិំ
ភោជយិត្វាន សត្តាហំ នានគ្គរសភោជនំ ។
នានាចិត្តេហិ បុប្ផេហិ បូជយិត្វា សសាវកំ(១)
និបច្ច បាទមូលម្ហិ តំ ឋានំ បត្ថយឹ អហំ ។
តទា មុនិវរោ អាហ ការុណោ ការុណាលយោ(២)
បស្សថេតំ ទិជវរំ បទុមាននលោចនំ ។
បីតិបាមុជ្ជពហុលំ សមុគ្គតនុរុហំ(៣)
ហាសាវហំ(៤) វិសាលក្ខំ មម សាសនសាលយំ(៥) ។
មម(៦) បាទមូលេ បតិតំ ឯកាវត្តិ(៧) សុមានសំ
ឯស បត្ថេតិ តំ ឋានំ វិចិត្តកាបិកាត្តិំ(៨) ។

---

១ ម. មហាវីរំ ។ ២ ឱ. ម. ករុណោ ករុណាលយោ ។ ៣ ឱ. សមុគ្គតនុរុហំ ។ ម. សមុគ្គតតនុរុហំ ។ ៤ ឱ. ហាសាធិកំ ។ ម. ហាសម្ពុតំ ។ ៥ ឱ.ម. សាសនលាលសំ ។ ៦ ឱ. មំ ។ ម. មេ ។ ៧ ឱ. ឯកាវត្តំ ។ ម. ឯកវត្តំ ។ ៨ ឱ. វិចិត្តកបិកត្តំ ។



គ្រានោះ ខ្ញុំមានចិត្តរីករាយ បាននិមន្តព្រះតថាគត រួចរាក់តែងមណ្ឌបដោយសំពត់ មានពណ៌ក្រហមផ្សេងៗ ហើយនិមន្តព្រះពុទ្ធ ព្រមទាំងព្រះសង្ឃ ដែលមានស្មៅព្រាល ទ្រោលដូចគេទះផ្សេងៗ ឲ្យឆាន់ក្នុងមណ្ឌបនោះ លុះឆាន់ចង្ហាន់មានរសដ៏ប្រសើរផ្សេងៗ គ្រប់ ៧ ថ្ងៃហើយ ទើបខ្ញុំបូជាព្រះតថាគត ព្រមទាំងសាវ័ក ដោយផ្កាដ៏វិចិត្រផ្សេងៗ ហើយក្រាបទៀបព្រះបាទ ប្រាថ្នានូវតំណែងនោះ ។

គ្រានោះ ព្រះមុនីដ៏ប្រសើរ ព្រះអង្គមានករុណា មានករុណាជាលំនៅ ទ្រង់ត្រាស់ថា អ្នកទាំងឡាយ ចូរមើលព្រាហ្មណ៍ដ៏ប្រសើរនុ៎ះ ដែលមានមុខនិងភ្នែកដូចផ្កាឈូក ជាអ្នកច្រើន ដោយបីតិនិងបាមុជ្ជៈ មានរោមផង់ឡើង ជាអ្នកនាំមក នូវសេចក្តីរីករាយ មានភ្នែកស្រឡះ មានសេចក្តីអាល័យ ក្នុងសាសនា នៃតថាគត មានវត្តប្រតិបត្តិតែមួយ មានចិត្តល្អ បានក្រាបទៀបបាទានៃតថាគត ព្រាហ្មណ៍នុ៎ះ ប្រាថ្នានូវតំណែងនោះ គឺភាពជាអ្នកសម្តែងធម៌ដ៏វិចិត្រ ។

សតសហស្សេ ឥតោ កប្បេ  ឱក្កាកកុលសម្ភវោ

គោតមោ នាម នាមេន  សត្ថា លោកេ ភវិស្សតិ ។

តស្ស ធម្មេសុ ទាយាទោ  ឱរសោ ធម្មនិម្មិតោ

កុមារកស្សបោ នាម  ហេស្សតិ សត្ថុសាវកោ ។

វិចិត្តបុប្ផទុស្សានំ  រតនានញ្ច វាហសា

វិចិត្តកថិកានំ សោ  អគ្គត្តំ បាបុណិស្សតិ ។

តេន កម្មេន សុកតេន  ចេតនាបណិធីហិ ច

ជហិត្វា មានុសំ ទេហំ  តាវត្តិំសំ អគច្ឆហំ ។

បរិព្ភមិំ ភវាភវេ  រង្គមជ្ឈេ យថា នដោ

សាខាមិគត្រជោ ហុត្វា  មិគិយា កុច្ឆិមោក្កមិំ ។





ក្នុងកប្បទីមួយសែន អំពីកប្បនេះ មានមហាបុរសម្នាក់ក្នុងត្រកូលស្តេចឧក្កាកៈ ទើបបានជាព្រះសាស្តាក្នុងលោក ព្រះនាមគោតម ។ ឯព្រាហ្មណ៍នុ៎ះ ទើបបានជាឱរស ដែលព្រះធម៌និម្មិត ជាអ្នកទទួលមត៌កក្នុងធម៌ របស់ព្រះសាស្តានោះហើយ ទើបបានជាសាវ័កនៃព្រះសាស្តា ឈ្មោះថាកុមារកស្សបៈ ។ ដោយអានិសង្សនៃផ្កានិងសំពត់ដ៏វិចិត្រ និងរតនៈទាំងឡាយ កុមារកស្សបៈនោះ នឹងបានដល់នូវភាពនៃខ្លួនប្រសើរលើសលុប ជាងអ្នកថិកត្រកាលទាំងឡាយ ។

ដោយអំពើដែលខ្ញុំធ្វើល្អនោះផង ដោយការតំកល់នូវសេចក្តីប្រាថ្នានោះផង ខ្ញុំលុះលះបង់កាយ ជារបស់មនុស្សហើយ ក៏បានទៅកើត ក្នុងឋានតាវត្តិង្ស ។ ខ្ញុំវិលចុះវិលឡើង ក្នុងភពតូចនិងភពធំ ហាក់ដូចជាអ្នករបាំ ( ដែលវិលចុះឡើង ) ក្នុងកណ្តាលរឿនរង្គ ខ្ញុំជាសត្វត្រូវកើតដោយសាខាម្រឹគ បានចូលទៅចាប់ផ្ទៃក្នុងមេម្រឹគ ។

តទា មយិ គរុចិត្តោ វជ្ឈកោ ឧបដ្ឋិតោ
សាខេន ចត្តា មេ មាតា និគ្រោធំ សរណំ គតា ។
តេនសោ មិគរាជេន មរណា បរិមោចិតា
បរិច្ចជិត្វាន សប្បាណំ មមេវំ ឱវទី តទា ។
និគ្រោធមេវ សេវេយ្យ ន សាខមុបសំវសេ
និគ្រោធស្មឹ មតំ សេយ្យោ យញ្ចេ សាខស្មិ ជីវិតំ ។

តេនានុសិដ្ឋា មិគយូថបេន(១)
អហញ្ច មាតា ចតរេ(២) ច តស្សោភិនំ(៣)
អាគម្ម រម្មំ ឱសិតាធិវាសំ
គតា បវាសំ សឃរំ យថេវ ។

---

១ ឱ. មិគយោធិទេន ។ ២ ឱ. អយំ បាឋោ នត្ថិ ។ ម. ជិតរេ ។ ៣ ឱ. តស្សោភិទេន ។



កាលខ្ញុំកំពុងទៅក្នុងគតិ កាលនោះ វេនដែលគេសម្លាប់ក៏មកដល់ ឯមាតារបស់ខ្ញុំ ត្រូវសាខម្រឹគលះបង់ចោល គាត់ក៏ទៅយកនិគ្រោធម្រឹគជាទីពឹងវិញ ។ កាលនោះ មាតារបស់ខ្ញុំនោះ ត្រូវស្ដេចម្រឹគនោះជួយដោះអំពីមរណៈ ដែលមាតាខ្ញុំ ស៊ូលះជីវិតរបស់ខ្លួន ក៏ទូន្មានខ្ញុំ យ៉ាងនេះថា ( ហៃបា បើបា ចង់បានសេចក្ដីចំរើន ) ត្រូវសេពគប់នឹងនិគ្រោធម្រឹគ កុំទៅសេពគប់ នឹងសាខម្រឹគឡើយ ការស្លាប់ក្នុងសំណាក់និគ្រោធម្រឹគ ទើបប្រសើរ ការរស់ក្នុងសំណាក់សាខម្រឹគ កុំប្រសើរឡើយ ។

ខ្ញុំ មាតា និងម្រឹគដទៃ ត្រូវស្ដេចម្រឹគនោះ ប្រៀនប្រដៅហើយ ក៏ទទួលធ្វើតាមឱវាទ របស់ស្ដេចម្រឹគនោះ ហើយបានទៅកើត ក្នុងពិមាននៅឋានតុសិត ជាទីត្រេកអរ ហាក់ដូចជាបុគ្គល ទៅកាន់ទីព្រាត់ប្រាស ហើយបានត្រឡប់មកផ្ទះខ្លួនវិញ ។

## បញ្ចមំ កុមារកស្សបត្ថេរាបទានំ

បុរោ កស្សបវីរស្ស   អន្តរហិតេ សាសនេ
អារុយ្ហ សេលសិខរំ   យុញ្ជិត្វា ជិនសាសនំ ។
ឥទានាហំ[១] រាជគហេ   ជាតោ សេដ្ឋិកុលេ អហំ[២]
អាបន្នសត្តា[៣] មេ មាតា   បព្វជិ អនគារិយំ ។
សគព្ភិំ តំ វិទិត្វាន   ទេវទត្តមុបានយុំ
សោ អវោច វិនាសេថ   បាបិកំ ភិក្ខុនឹ ឥមំ ។
ឥទានិបិ[៤] មុនិន្ទេន   ជិនេន អនុកម្បិតា
សុខិនី ជននី មយ្ហំ   អាសិ ភិក្ខុនុបស្សយេ ។
តំ ទិស្វា មហីបាលោ   កោសលោ មំ អបោសយិ
កុមារបរិហារេន   នាមេនាហញ្ច កស្សបោ ។
មហាកស្សបមាគម្ម   អហំ កោមារកស្សបោ
វម្មិកស្សូបមំ តាយិ   សុត្វា ពុទ្ធេន ទេសិតំ ។

---

១ ឱ. ឥទានិហំ ។ ម. ឥទានាហំ ។ ២ ឱ. អហុំ ។ ម. អហុ ។ ៣ ម. អាបន្នសត្តា ។
៤ ម. ឥទានិបិ ។





កាលសាសនានៃព្រះពុទ្ធកស្សបៈ ជាអ្នកប្រាជ្ញ សាបសូន្យទៅ ខ្ញុំបានឡើងទៅលើកំពូលភ្នំ ហើយប្រកបតាមសាសនានៃព្រះជិនស្រីទៀត ។ ក្នុងវេលានេះ ខ្ញុំទៅចាប់ផ្ទៃក្នុងត្រកូលសេដ្ឋី ក្នុងក្រុងរាជគ្រឹះ ឯមាតារបស់ខ្ញុំ បានចូលទៅកាន់ផ្នួសទាំងមានគភ៌ ។ ពួកភិក្ខុនី លុះបានដឹងថា មាតាខ្ញុំនោះមានគភ៌ហើយ ក៏នាំគ្នាចូលទៅក្រាបទេវទត្ត ទេវទត្តនោះ បាននិយាយថា នាងទាំងឡាយ ចូរញ៉ាំងភិក្ខុនីដ៏លាមកនេះ ឲ្យវិនាស ។ ក្នុងវេលានេះ មាតាជាព្រះជននីរបស់ខ្ញុំ មានសេចក្តីសុខ ក្នុងសំណាក់ភិក្ខុនី ដោយសារព្រះមុនិន្ទជិនស្រីទ្រង់អនុគ្រោះ ។ ព្រះបាទកោសលរក្សាផែនដី ទ្រង់ជ្រាបហេតុនោះហើយ ក៏បានចិញ្ចឹមខ្ញុំ ដោយគ្រឿងក្មេងកុមារ ខ្ញុំមានឈ្មោះថាកស្សបៈ ។ ខ្ញុំក៏ដឹងពាក់អាស្រ័យនឹងព្រះមហាកស្សបៈ ទើបបានឈ្មោះថា កុមារកស្សបៈវិញ ខ្ញុំបានស្តាប់ធម៌ដែលព្រះពុទ្ធទ្រង់សម្តែងថា កំណាយប្រាកដដូចជាដំបូក ។

តតោ ចិត្តំ វិមុច្ចិ មេ អនុបាទាយ សព្វសោ
ធាយាសិ ឧបយ័ត្វាហំ ឯកគត្តំ អនាបុណឹ ។
កិលេសា ឈាបិតា មយ្ហំ ភវា សព្វេ សមូហតា
នាគោវ ពន្ធនំ ឆេត្វា វិហរាមិ អនាសវោ ។
ស្វាគតំ វត មេ អាសិ មម ពុទ្ធស្ស សន្តិកេ
តិស្សោ វិជ្ជា អនុប្បត្តា កតំ ពុទ្ធស្ស សាសនំ ។
បដិសម្ភិទា ចតស្សោ វិមោក្ខាបិ ច អដ្ឋិមេ
ឆឡភិញ្ញា សច្ឆិកតា កតំ ពុទ្ធស្ស សាសនំ ។

ឥត្ថំ សុទំ អាយស្មា កុមារកស្សបោ ថេរោ ឥមា គាថាយោ អភាសិត្ថាតិ ។

កុមារកស្សបត្ថេរស្ស អបទានំ សមត្តំ ។

បញ្ចវីសតិមំ ភាណវារំ ។



លំដាប់នោះ ចិត្តរបស់ខ្ញុំ ក៏រួចស្រឡះចាកអាសវៈ ព្រោះមិនមានការប្រកាន់ សព្វគ្រប់ ខ្ញុំខ្ជាប់ខ្ជួនឲ្យបានបែបបទហើយ ក៏បានដល់នូវទីជាឯកទគ្គៈ ។ កិលេសទាំងឡាយ ខ្ញុំដុតបំផ្លាញហើយ ភពទាំងពួង ខ្ញុំដកចោលហើយ ខ្ញុំជាអ្នកមិនមានអាសវៈ ព្រោះបានកាត់ចំណង ដូចជាដំរីកាត់ផ្តាច់នូវទន្លីង ។ ឱ ! ខ្ញុំមកល្អហើយ ក្នុងសំណាក់ព្រះពុទ្ធរបស់ខ្ញុំ វិជ្ជា ៣ ខ្ញុំបានដល់ហើយ សាសនា របស់ព្រះពុទ្ធ ខ្ញុំបានធ្វើហើយ ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនា របស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ។

បានឮថា ព្រះកុមារកស្សបត្ថេរ មានអាយុ បានសំដែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

ចប់ កុមារកស្សបត្ថេរាបទាន ។

ចប់ ភាណវារៈ ទី ២៤ ។

# ៤ ពាហិយត្ថេរាបទានំ

(១៦៦) ឥតោ សតសហស្សម្ហិ កប្បេ ឧប្បជ្ជិ នាយកោ

មហប្បភោ តិលោកគ្គោ នាមេន បទុមុត្តរោ ។

ទិព្វាភិញ្ញស្ស ភិក្ខុស្ស គុណំ កិត្តយតោ មុនេ

សុត្វា ឧទគ្គចិត្តោហំ ការំ កត្វា មហេសិនោ ។

ទត្វា សត្តាហិកំ ទានំ សសិស្សស្ស មុនេ អហំ

អភិវាទិយ សម្ពុទ្ធំ តំ ឋានំ បត្ថយឹ តទា ។

តតោ មំ ព្យាករិ ពុទ្ធោ ឯតំ បស្សថ ព្រាហ្មណំ

បតិតំ បាទមូលេ មេ បីនសម្ពន្ធវគ្គណំ(១) ។

ហេមយញ្ញោបចិតង្គំ អវទាតំ តនុត្តចំ

បលម្ពពិម្ពតម្ពោដ្ឋំ សេតតិណ្ហសមទ្វិជំ(២) ។

១ ឱ. បីនំសំ បច្ចវគ្គណំ ។ ២ ឱ. សេតតិណ្ហំ សមំ ទ្វិជំ ។ ម. សេតតិណ្ហសមំ ទ្វិជំ ។

# ពាហិយត្ថេរាបទាន ទី ៤

[១៦៦] ក្នុងកប្បទីមួយសែន អំពីកប្បនេះ ព្រះពុទ្ធជានាយក ព្រះនាមបទុមុត្តរៈ ព្រះអង្គមានរស្មីច្រើន ជាកំពូលនៃត្រៃលោក ស្តេចកើតឡើង (ក្នុងលោក) ។ ខ្ញុំបានឮព្រះមុនី ទ្រង់សរសើរគុណ នៃភិក្ខុអ្នកត្រាស់ដឹងឆាប់ ក៏មានចិត្តរីករាយឡើង ហើយបានធ្វើគ្រឿងសក្ការៈ ថ្វាយព្រះមហេសី ។ ក្នុងកាលនោះ ខ្ញុំបានថ្វាយទានដល់ព្រះមុនី ព្រមទាំងសិស្ស អស់ ៧ ថ្ងៃ ហើយថ្វាយបង្គំព្រះសម្ពុទ្ធ ប្រាថ្នានូវតំណែងនោះ ។

លំដាប់នោះ ព្រះពុទ្ធទ្រង់ព្យាករខ្ញុំថា អ្នកទាំងឡាយចូរមើលព្រាហ្មណ៍នុ៎ះ ដែលក្រាបទៀបបាទមូលនៃតថាគត ជាអ្នកមានប្រាជ្ញាជាគ្រឿងពិចារណាពេញបរិបូណ៌ មានអវយវៈដូចជាគ្រឿងបូជាដែលគេធ្វើពីមាស មានសម្បុរស មានស្បែកស្តើង មានបបូរមាត់ក្រហម ដូចផ្លែបាស៊ុំ ដែលសំយុងចុះយោងយោន ជាព្រាហ្មណ៍ស្មើដោយក្នុងក្រស់ជាកំពុត ។

គុណាជាមិ(១) ពហុតរំ សមុទ្ទក្ខន្ធរាហំ
គុណោ យាយតនិក្ខន្តំ បតិសម្ពុលិតាជិនំ ។
ឯសោ បត្ថយតេ ឋានំ ទិព្យាភិញ្ញស្ស ភិក្ខុនោ
អនាគតេ មហាវីរោ គោតមោ នាម ហេស្សតិ ។
តស្ស ធម្មេសុ ទាយាទោ ឱរសោ ធម្មនិម្មិតោ
ពាហិយោ នាម នាមេន ហេស្សតិ សត្ថុសាវកោ ។
តទា តុដ្ឋោ ច វុដ្ឋាយ យាវជីវំ មហាមុនិ
ការំ កត្វា ចុតោ សគ្គំ អគា(២)សកវំ យថា ។
ទេវភូតោ មនុស្សោ វា សុខិតោ តស្ស កម្មុនោ
ភវាភវេ សំសរិត្វាន សម្បត្តិមនុភោសហំ ។
ចុតោ កស្សបវីរស្ស អត្ថង្គតម្ហិ(៣) សាសនេ
អារុយ្ហ សេលសិខរំ យុញ្ជិត្វា ជិនសាសនំ(៤) ។

---

១ ឱ. គុណបត្ត... ។ ២ ឱ. អគំ ។ ម. អគ្គំ ។ ៣ ឱ. ចុតោ កស្សបវីរស្ស អត្ថង្គតម្ហិ ។ ម. ចុតោកស្សបវីរស្ស អត្ថមេតម្ហិ ។ ៤ ឱ. ជិនសាសនេ ។





មានកំឡាំង គឺគុណដ៏ច្រើន មានកេរ្តិ៍ដ៏ល្បីល្បាញ មាន អណ្ដូងជាទីទៅនៃគុណកើតហើយ មានមុខរីកដោយបីតិ ។ ព្រាហ្មណ៍នេះ ប្រាថ្នាតំណែងនៃភិក្ខុអ្នកត្រាស់ដឹងឆាប់ ព្រះពុទ្ធជាមហាវីរបុរស ព្រះនាមគោតម នឹងមានក្នុងអនាគត-កាល ។ (ព្រាហ្មណ៍នេះ) នឹងជាអ្នកទទួលនូវមត៌កក្នុងធម៌ព្រះគោតមនោះ ជាឱរសដែលធម៌និម្មិតហើយ នឹងបានជាសាវ័កនៃព្រះសាស្តា ឈ្មោះជា ពាហិយៈ ។

គ្រានោះ ខ្ញុំត្រេកអរ បានក្រោកឡើង ធ្វើសក្ការៈចំពោះព្រះមហាមុនី ដរាបដល់អស់ជីវិត លុះច្យុត (អំពីមនុស្ស) បានទៅកើតក្នុងឋានសួគ៌ ត្រង់ទីលំនៅជារបស់ខ្លួន ។ ខ្ញុំអន្ទោលទៅកើតជាទេវតា ឬជាមនុស្ស តែងដល់នូវសេចក្តីសុខ ហើយបានទទួលសម្បត្តិ ដោយកំរិតនៃកុសល-កម្មនោះ ។ កាលសាសនាព្រះពុទ្ធកស្សបៈ ជាអ្នកប្រាជ្ញ ដល់នូវសេចក្តីរលាយ ខ្ញុំបានឡើងទៅលើកំពូលភ្នំ ហើយប្រកបព្យាយាម ក្នុងសាសនា នៃព្រះជិនស្រីទៀត ។

### ផ្ទៃ ពាហិយត្ថេរាបទានំ

ពិសុទ្ធសីលោ សប្បញ្ញោ ជិនសាសនការកោ
តតោ ចុតា បញ្ច ជនា ទេវលោកំ អគម្ហសេ ។
តត្ថាហំ ពាហិយោ[១] ជាតោ ភារុកច្ឆេ បុរុត្តមេ
តតោ នាវាយ បក្ខន្ទោ[២] សាគរំ អប្បសិទ្ធិកំ[៣] ។
តតោ នាវា អភិជ្ជិត្ថ គច្ឆន្តី កតិបាហកំ
តទា ភីសនកេ ឃោរេ បតិតោ មករាលយេ[៤] ។
តទាហំ វាយមិត្វាន សន្តរិត្វា មហោទធឹ
សុប្បារកំ បត្តនវរំ[៥] សម្បត្តោ មន្ទវេធិតោ[៦] ។
ទារុចីរំ និវាសេត្វា គាមំ បិណ្ឌាយ បាវិសឹ
តទាហ សោ ជនោ តុដ្ឋោ អរហាយំ ឥធាគតោ ។

---

១ ឧ. ម. តតោហំ ពាហិកោ ។ ២ ឧ. បក្ខន្តោ ។ ម. បក្ខន្ទោ ។ ៣ ឧ. អប្បសិទ្ធិយំ ។ ម. អត្ថសិទ្ធិយំ ។ ៤ ឧ. ម. មករាករេ ។ ៥ ឧ. សុប្បារបត្តនវរំ ។ ម. សុប្បារកបត្តនវរំ ។ ៦ ឧ. មន្ទវេធិតោ ។ ម. ឧទ្ធវេធិតំ ។



### ពាហិយត្ថេរាបទាន ទី ៦

ខ្ញុំជាអ្នកមានសីលបរិសុទ្ធ ប្រកបដោយប្រាជ្ញា ជាអ្នកធ្វើតាមសាសនានៃព្រះជិនស្រី ពួកជន ៥ នាក់ (ដែលប្រកបព្យាយាមជាមួយនឹងខ្ញុំ) លុះច្យុតអំពីមនុស្សលោកទៅ បានទៅកើតក្នុងទេវលោក ។ បណ្តាជនទាំង ៥ នាក់នោះ ខ្ញុំឈ្មោះពាហិយៈ កើតក្នុងក្រុងភារុកច្ឆៈ ជាបុរីខ្ពង់ខ្ពស់ លំដាប់នោះឯង ខ្ញុំទៅកាន់សាគរ ឈ្មោះអប្បសិទ្ធិកៈ ដោយសំពៅ ។ ឯសំពៅនោះបានបែកធ្លាយក្នុងសាគរ ខ្ញុំហែលទៅបានតែបីថ្ងៃ ក៏ធ្លាក់ទៅក្នុងលំនៅនៃសត្វមករ ជាទីគួរខ្លាចដ៏ពន្លឹក ។ គ្រានោះ ខ្ញុំប្រឹងប្រែងឆ្លងមហាសមុទ្រ ក៏បានដល់កំពង់ផែដ៏ប្រសើរ ឈ្មោះសុប្បារកៈ ទាំងកំពុងមានសេចក្តីញាប់ញ័រដើមទ្រូង ។ ខ្ញុំស្លៀកសម្បកឈើ ដើរចូលទៅក្នុងស្រុកដើម្បីដុំបាយ គ្រានោះ មានជនម្នាក់ ត្រេកអរហើយនិយាយថា នេះជាព្រះអរហន្ត បាននិមន្តមកក្នុងទីនេះ ។

ឥមំ អន្នេន បានេន  វត្ថេន សយនេន ច

តោសេត្វាន ច សក្កត្វា  ហេស្សាម សុចិតា មយំ ។

បត្ថយានំ តទា លាភី  តេហិ សក្កតបូជិតោ[1]

អរហាហត្តំ[2] សក្កប្បំ  ឧបព្ភេសឹ អយោនិសោ ។

តតោ មេ ចិត្តមញ្ញាយ  ចោទយំ បុព្វទេវតា

ន ត្វំ ឧបាយមគ្គញ្ញូ  កុតោ ហិ អរហា ភវេ ។

ចោទិតោ តាយ សំវិគ្គោ  តទាហំ បរិបុច្ឆិសំ

កេ វា ឯតេ កុហឹ លោកេ  អរហន្តោ នរុត្តមា ។

១ ឱ. ម. សក្កតបូជិតំ ។ ២ ឱ. អរហាយត្តំ ។



ពួកយើងនឹងធ្វើសក្ការៈ ចំពោះព្រះអរហន្តនេះ ដោយបាយ ទឹក សំពត់ ទីដេក និងគេសជ្ជៈ ហើយនឹងបានសេចក្តីសុខ ៗ គ្រានោះ ខ្ញុំជាអ្នកបានបច្ច័យទាំងឡាយ ក្រៅជនទាំងនោះ ធ្វើសក្ការបូជា ក៏ញុំាងសេចក្តីត្រិះរិះ ឲ្យកើតឡើង ដោយខុសឧបាយនៃប្រាជ្ញាថា អាត្មាអញជាព្រះអរហន្ត ។ លំដាប់នោះ បុព្វទេវតាមួយអង្គ (ទេវតាជាមិត្រដែលធ្លាប់ធ្វើកុសលជាមួយគ្នាក្នុងជាតិមុន) បានដឹងចិត្តខ្ញុំ ក៏មកដាស់តឿនខ្ញុំថា អ្នកមិនទាន់ដឹងផ្លូវជាឧបាយនៃព្រះនិព្វានទេ តើនឹងជាព្រះអរហន្ត ដូចម្តេចកើត ។ គ្រានោះ ខ្ញុំត្រូវទេវតានោះដាស់តឿនហើយ ក៏តក់ស្លុត បានសួរទេវតានោះថា បុគ្គលដូចម្តេច ដែលជាព្រះអរហន្តក្នុងលោក ជាអ្នកខ្ពង់ខ្ពស់ជាងពួកមនុស្ស ហើយអរហន្តទាំងនោះ នៅឯណា ។

### ឆដ្ឋំ ពាហិយត្ថេរាបទានំ

សាវត្ថិយំ កោសលមន្ទិរេ ជិនោ

បហូតបញ្ញោ វរភូរិមេធសោ

សោ សក្យបុត្តោ អរហា អនាសវោ

ទេសេតិ ធម្មំ អរហត្តបត្តិយា ។

តទស្ស សុត្វា វចនំ សុបីណិតោ

និធឹវ លទ្ធា កបណោ សុវិម្ហិតោ[១]

ឧទគ្គចិត្តោ អរហន្តមុត្តមំ

សុទស្សនំ ទដ្ឋុមនន្តគោចរំ ។

តទា តតោ[២] និក្ខមិត្វាន សត្ថុនោ

សទា ជិនំ[៣] បស្សាមិ វិមលាននំ[៤]

ឧបេច្ច រម្មំ វិជិតវ្ហយំ តំ

ទិជេ អបុច្ឆិ កុហឹ លោកនន្ទនោ ។

---

១ ឱ. កបណោ វិម្ហិតោ ។ ម. កបណោតិ វិម្ហិតោ ។ ២ ឱ. ឥតោ ។ ៣ ម. ឫភាជិនំ ។ ៤ ម. កមលាននំ ។



### ពាហិយត្ថេរាបទាន ទី ៦

(ទេវតាតបថា) ព្រះជិនស្រី ព្រះអង្គមានប្រាជ្ញាច្រើន មានប្រាជ្ញាដូចផែនដីដ៏ប្រសើរ ស្តេចទៅកាន់កោសលៈមន្ទិរ ទៀបក្រុងសាវត្ថី ព្រះអង្គជាសក្យបុត្រ ជាព្រះអរហន្ត មិនមានអាសវៈ ទ្រង់សម្តែងធម៌ ដើម្បីដល់នូវព្រះអរហត្ត ។ ខ្ញុំគ្រាន់តែឮពាក្យទេវតានោះហើយ ក៏ឆ្អែតកាយ ឆ្អែតចិត្ត អស្ចារ្យក្នុងចិត្ត មានចិត្តត្រេកអរ ដូចជាមនុស្សកំព្រា បានកំណប់ទ្រព្យ (ដោយខ្ញុំគិតឃើញថា) ការឃើញព្រះអរហន្ត ដ៏ខ្ពង់ខ្ពស់ មានអារម្មណ៍ជាទីបំផុត ជាការឃើញប្រពៃ ។ គ្រានោះខ្ញុំចេញពីស្រុកនោះ ដើរទៅកាន់សំណាក់ព្រះសាស្តា ប្រាថ្នាឲ្យបានឃើញព្រះជិនស្រី ព្រះអង្គមានព្រះភក្ត្រប្រាសចាកមន្ទិលសព្វកាល ខ្ញុំចូលទៅកាន់ស្រុកឈ្មោះវិជិតៈ ជាទីត្រេកអរ បានសួរពួកព្រាហ្មណ៍ថា ព្រះពុទ្ធជាទីត្រេកអរនៃសត្វលោក គង់នៅក្នុងទីណា ។

តតោ អាហំសុ ធរណេវន្តិតោ

បុរំ បវិដ្ឋោ អសេសជាយ សោ

បច្ចយំ(១) ឥច្ឆំ មុនិនស្ស ពុទ្ធស្ស ភោ

ឧបេច្ច វន្ទាហិ តមគ្គបុគ្គលំ ។

តតោហំ តុរិតំ គន្ត្វា សាវត្ថិំ បុរមុត្តមំ

វិចរន្តំ តមទ្ទក្ខិំ បិណ្ឌត្ថំ អបិហាគិធំ ។

បត្តហត្ថំ អលោលក្ខំ ជោតយន្តំ ឥវាមតំ(២)

សិរីនិលយសង្កាសំ រវិទិត្តហរាននំ ។

តំ សមេច្ច និបច្ចាហំ ឥទំ(៣) វចនមព្រវិំ

កុបថេ វិប្បនដ្ឋស្ស សរណំ ហោហិ គោតម ។

---

១ ឱ. សហាយំ ។ ២ ឱ. ភាវយន្តំ... ។ ម. ជោតយន្តំ បីតាការំ ។ ៣ ឱ. ឥមំ ។



លំដាប់នោះ ពួកព្រាហ្មណ៍ ប្រាប់ថា ព្រះពុទ្ធដែលមនុស្សនិងទេវតា តែងបូជាយញ្ញ ស្តេចចូលទៅកាន់បុរី ដើម្បីស្វែងរកបច្ច័យ បើអ្នកឯង ជាអ្នកខ្វល់ខ្វាយចង់ជួបនឹងព្រះជិនស្រី ចូរទៅបូជាយញ្ញ នូវព្រះពុទ្ធ ជាអគ្គបុគ្គល ក្នុងទីនោះ ឲ្យឆាប់ចុះ ។

លំដាប់នោះ ខ្ញុំបានទៅឯក្រុងសាវត្ថី ជាបុរីដ៏ឧត្តមយ៉ាងឆាប់ បានឃើញព្រះអង្គ កំពុងស្តេចទៅដើម្បីបិណ្ឌបាត ព្រះអង្គឥតមានជាប់ព្រះហឫទ័យក្នុងអាហារ មានបាត្រនៅក្នុងព្រះហស្ត មានព្រះនេត្រមិនលើមលោម ទ្រង់សម្តែងបំភ្លឺនូវអមតនិព្វាន ក្នុងទីនេះ ព្រះអង្គប្រាកដស្មើដោយលំនៅដ៏មានសិរី មានព្រះភក្ត្រភ្លឺដូចព្រះអាទិត្យដ៏រុងរឿង ។ លុះខ្ញុំបានជួបនឹងព្រះសាស្តានោះហើយ ក៏ក្រាបចុះ ហើយពោលពាក្យនេះថា បពិត្រព្រះគោតម សូមព្រះអង្គជាទីពឹងរបស់ខ្ញុំព្រះអង្គ ដែលជាអ្នកវង្វេងវិលវល់ក្នុងផ្លូវខុស ។

ទាណាសន្តានេណត្តាយ បិណ្ឌាយ វិចរិំហំ
ឧ តេ ជន្តុកជាកាលេ ឥន្ទ្រាហ មុនិ សន្តមោ ។
តតោ បុនប្បុនំ ពុទ្ធំ អាយាចិំ ឧច្ចាលាសោ
សោ មេ ធម្មមទេសេសិ កម្ពុំ សុញ្ញតំ បរំ ។
តស្ស ធម្មំ សុណិត្វាន បាបុណិំ អាសវក្ខយំ
បរិក្ខីណាយុកោ សត្ថា អហោសត្ថានុកម្បកោ(១) ។
កិលេសា ឈាបិតា មយ្ហំ ភវា សព្វេ សមូហតា
នាគោវ ពន្ធនំ ឆេត្វា វិហរាមិ អនាសវា ។
ស្វាគតំ វត មេ អាសិ មម ពុទ្ធស្ស សន្តិកេ
តិស្សោ វិជ្ជា អនុប្បត្តា កតំ ពុទ្ធស្ស សាសនំ ។
បដិសម្ភិទា ចតស្សោ វិមោក្ខាបិ ច អដ្ឋិមេ
ឆឡភិញ្ញា សច្ឆិកតា កតំ ពុទ្ធស្ស សាសនន្តិ ។

១ ម. អហោ សត្ថានុកម្បកោ ។



ព្រះមុនីទី ៧ ទ្រង់ត្រាស់ថា តថាគត កំពុងត្រាច់ទៅបិណ្ឌបាត ដើម្បីបម្រើសត្វ កាលនេះ ជាកាលមិនគួរនឹងសម្ដែងធម៌ដល់អ្នកទេ ។ គ្រានោះ ខ្ញុំជាអ្នកប្រាថ្នាក្នុងធម៌ បានអារាធនាព្រះពុទ្ធ ព្រះអង្គបានត្រាស់សម្ដែងធម៌ ជាបទជ្រាលជ្រៅ ជាធម៌សូន្យចាកកិលេស ដល់ខ្ញុំ ។ ខ្ញុំលុះស្ដាប់ធម៌របស់ព្រះអង្គហើយ ក៏បានដល់នូវកិរិយាអស់អាសវៈ ខ្ញុំមានអាយុអស់ហើយ ឱ! ព្រះសាស្ដាទ្រង់មានសេចក្ដីអនុគ្រោះអ្វីម្ល៉េះ ។ កិលេសទាំងឡាយ ខ្ញុំដុតបំផ្លាញហើយ ភពទាំងពួងខ្ញុំដកចោលហើយ ខ្ញុំជាអ្នកមិនមានអាសវៈ ព្រោះបានកាត់ចំណង ដូចជាដំរីកាត់ផ្ដាច់នូវទន្លីង ។ ឱ! ខ្ញុំមកល្អហើយក្នុងសាសនាព្រះពុទ្ធ របស់ខ្ញុំ វិជ្ជា ៣ ខ្ញុំបានដល់ហើយ សាសនា របស់ព្រះពុទ្ធ ខ្ញុំបានធ្វើហើយ ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនា របស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ។

ឃរំ ទេព វិហតាសិ  ពាហិយោ ទារុចីរិយោ
សុប្បារកញ្ច បតិតោ  កូតាធិប្បាយ តារិយា ។
អត្តនោ បុត្តចរិតំ(១)  តិត្ថិយិត្វា មហាមតិ
បរិទិត្វាយិ សោក ជិនេក(២)  សាវត្ថិយំ បុរុត្តមេ ។
ឧគត ឧក្កមត្តោ តំ  ទិស្វាន ឥសិ សត្តមោ
ទារុចីរធរំ ធីរំ  ពាហិយំ ពាហិតាគមំ(៣) ។
ក្ខមិយំ បតិតំ ឥណ្ហំ(៤)  ឥន្ទគោត្តំ ជាតិតំ
គតាយុំ សុក្ខតាលេសិ(៥)  ជិនសាសនការកំ ។
ឆតោ អាបត្តិយំ សត្ថា  សាវកោ សាសនេ រតេ
គណ្ហថ ហត្វា ឈាបេថ  ឥត្ថំ សព្រហ្មចារិនោ ។
ថូបំ ករោថ បូជេថ  និព្វុតោ សោ មហាមតិ
ទិព្វាភិញ្ញានមេសគ្គោ  សាវកោ មេ វចោករោ ។

---

១ ម. បុត្តចរិយំ ។ ២ ឱ. រិកេ ។ ម. ចេវកេ ។ ៣ ឱ.ម. ពាហិតាគមំ ។ ៤ ឱ.ម. ទន្តំ ។
៥ ឱ. គតាយុំ សង្គហលេសំ ។ ម. គតាយុំ លង្គិតលេសំ ។



ព្រះថេរៈឈ្មោះពាហិយទារុចីរិយៈ បានឡូកហ៊ើងនេះ ហើយ ក៏ដួលលើគំនរសម្រាម ព្រោះមេគោដែលយក្ខនិក-វៃណានមកដល់ ។ លុះព្រះពាហិយត្ថេរ ជាអ្នកប្រាជ្ញ មានប្រាជ្ញាច្រើននោះ ពោលសរសើរបុព្វចរិតរបស់ខ្លួនហើយ ក៏បរិនិព្វានក្នុងក្រុងសាវត្ថី ជាបុរីដ៏ឧត្តម ។ ព្រះពុទ្ធជាឥសីទី ៧ ចេញអំពីនគរ បានឃើញព្រះពាហិយៈ ជាអ្នកប្រាជ្ញនោះ ស្លៀកសំពត់សម្បកឈើ មានការផុតកំដៅកិលេស បង្ក្រាក់ចង់ហើយ ។ ដួលលើផែនដី ដូចជាកំណាត់ឈើឬដងទង់ធំ ដែលគេផ្តួលចុះ មានអាយុអស់ហើយ មានកិលេសស្ងួតហើយ ជាអ្នកធ្វើតាមសាសនាព្រះជិនស្រី ។ លំដាប់នោះ ព្រះសាស្តាទ្រង់ត្រាស់ហៅពួកសាវ័ក អ្នកត្រេកអរក្នុងសាសនាថា អ្នកទាំងឡាយ ចូរយកសព របស់សព្រហ្មចារីទៅបូជាចុះ ។ ចូរធ្វើស្តូប ចូរបូជា ដ្បិតពាហិយៈជាអ្នកប្រាជ្ញធំនោះ ជាអ្នកធ្វើតាមពាក្យរបស់តថាគត ជាសាវ័កប្រសើរជាងសាវ័កដែលជាទិព្វាភិញ្ញា បរិនិព្វានហើយ ។

ផង្គ ពាហិយត្ថេរបទានំ

សហស្សមបិ ចេ គាថា អនត្ថបទសញ្ហិតា

ឯកំ គាថាបទំ សេយ្យោ យំ សុត្វា ឧបសម្មតិ ។

យត្ថ អាបោ ច បឋវី តេជោ វាយោ ន គាធតិ

ន តត្ថ សុក្កា ជោតន្តិ អាទិច្ចោ នប្បកាសតិ ។

ន តត្ថ ចន្ទិមា ភាតិ តមោ តត្ថ ន វិជ្ជតិ

យទា ច អត្តនាវេទិ មុនិ មោនេន ព្រាហ្មណោ ។

អថ រូបា អរូបា ច សុខទុក្ខា បមុច្ចតិ

ឥត្ថុំ អគណិ ធាជោ តិលោកស្សរណោ មុនីតិ ។

ឥត្ថំ សុតំ អាយស្មា ពាហិយោ ថេរោ ឥមា គាថាយោ អភាសិត្ថាតិ ។

ពាហិយត្ថេរស្ស អបទានំ សមត្តំ ។



ពាហិយត្ថេរបទាន ទី ៦

បើគាថាសូម្បីមួយពាន់ តែប្រកបដោយបទមិនជាប្រយោជន៍ មិនប្រសើរស្មើនឹងគាថាមួយបទ ដែលគេស្តាប់ហើយទេ ។ ទឹក ដី ភ្លើង ខ្យល់ មិនតាំងនៅក្នុងព្រះនិព្វានណា កុសល ទាំងឡាយ មិនរុងរឿងក្នុងព្រះនិព្វាននោះ ព្រះអាទិត្យ ក៏មិនប្រាកដ ( ក្នុងព្រះនិព្វាននោះ ) ។ ព្រះចន្ទ ក៏មិនភ្លឺក្នុងព្រះនិព្វាននោះ ងងឹតក៏មិនមាន ក្នុងព្រះនិព្វាននោះដែរ វេលាណា ព្រាហ្មណ៍ ជាមុនិ ដោយញាណ ត្រាស់ដឹងដោយខ្លួនឯង ក្នុងកាលណា ក៏រួចចាករូបនិងអរូប សុខនិងទុក្ខ ក្នុងកាលនោះ ។ ព្រះមុនីនាថ ជាទីពឹងនៃសត្វក្នុងត្រៃលោក បានសម្តែងយ៉ាងនេះឯង ។

បានឮថា ព្រះពាហិយត្ថេរ មានអាយុ បានសម្តែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

ចប់ ពាហិយត្ថេរបទាន ។

# សត្តមំ មហាកោដ្ឋិកត្ថេរាបទានំ

(១៦៧) បទុមុត្តរោ នាម ជិនោ សព្វលោកវិទូ មុនិ
ឥតោ សតសហស្សម្ហិ កប្បេ ឧប្បជ្ជិ ចក្ខុមា ។
ឱវាទកោ វិញ្ញាបកោ តារកោ សព្វបាណិនំ
ទេសនាកុសលោ ពុទ្ធោ តារេសិ ជនតំ ពហុំ ។
អនុកម្បកោ ការុណិកោ ហិតេសី សព្វបាណិនំ
សម្បត្តេ តិត្ថិយេ សព្វេ បញ្ចសីលេ បតិដ្ឋហិ(១) ។
ឯវំ និរាកុលំ អាសិ សុញ្ញតំ តិត្ថិយេហិ ច
វិចិត្តំ អរហន្តេហិ វសីភូតេហិ តាទិភិ ។
រតនានដ្ឋបញ្ញាសំ ឧគ្គតោ សោ មហាមុនិ
កញ្ចនគ្ឃិយសង្កាសោ ពត្តឹសវរលក្ខណោ ។
វស្សសតសហស្សានិ(២) អាយុ វិជ្ជតិ តាវទេ
តាវតា តិដ្ឋមានោ សោ(៣) តារេសិ ជនតំ ពហុំ ។

---

១ ឱ. តិដ្ឋបិ ។ ២ ម. វស្សសតសហស្សានិ ។ ៣ ឱ. តិដ្ឋមានសោ ។



# មហាកោដ្ឋិកត្ថេរាបទាន ទី ៧

(១៦៧) ព្រះជិនស្រី ព្រះនាមបទុមុត្តរៈ ជាអ្នកប្រាជ្ញ ទ្រង់ជ្រាបច្បាស់នូវលោកទាំងអស់ មានចក្ខុ កើតឡើង ក្នុងកប្បទីមួយសែន អំពីកប្បនេះ ។ ព្រះពុទ្ធទ្រង់ឈ្លាសក្នុងទេសនា ទ្រង់ប្រទានឱវាទ ញ៉ាំងសត្វឲ្យដឹង ចម្លងសត្វ ញ៉ាំងពួកជនច្រើនឲ្យឆ្លង ទ្រង់អនុគ្រោះ មានសេចក្តីករុណា ស្វែងរកប្រយោជន៍ដល់សត្វទាំងពួង បានញ៉ាំងពួកតិរ្ថិយទាំងអស់ ដែលមកប្រជុំគ្នា ឲ្យតាំងនៅស៊ប់ក្នុងសីល ៥ ។ សាសនានេះឯង មិនរឹករៃ សូន្យចាកពួកតិរ្ថិយ វិចិត្រដោយព្រះអរហន្តទាំងឡាយ ជាបុគ្គលស្ទាត់ជំនាញ ប្រកបដោយតាទិគុណ ។ ព្រះមហាមុនីនោះ មានកំពស់ ៥៨ ហត្ថ ប្រាកដស្មើដោយគ្រឿងបូជា ជាវិការៈនៃមាស មានលក្ខណៈដ៏ប្រសើរ ៣២ ប្រការ ។ មានព្រះជន្មមួយសែនឆ្នាំ កាលព្រះអង្គគង់ព្រះជន្មនៅ បានញ៉ាំងពួកជនច្រើនឲ្យឆ្លង (ពកលោក) ។

តទាហំ ហំសវតិយា ព្រាហ្មណោ វេទបារគូ
ឧបេត្វា(១) សព្វលោកគ្គំ(២) អស្សោសឹ ធម្មទេសនំ ។
តទា សោ សាវកំ ធីរោ បភិន្នបដិសម្ភិទំ(៣)
អត្ថេ ធម្មេ និរុត្តេ ច បដិភាណេ ច កោវិទំ ។
ឋបេសិ ឯតទគ្គម្ហិ តំ សុត្វា មុទិតោ អហំ
សសាវកំ ជិនវរំ សត្តាហំ ភោជយឹ តទា ។
ទុស្សេហិ ច្ឆាទយិត្វាន សសិស្សំ ពុទ្ធសាគរំ
និបច្ច បាទមូលម្ហិ តំ ឋានំ បត្ថយឹ អហំ ។
តតោ អវោច លោកគ្គោ បស្សថេតំ ទិជុត្តមំ
និបន្នំ បាទមូលម្ហិ(៤) កមលោទរសប្បភំ ។
សេដ្ឋី ពុទ្ធស្ស(៥) ភិក្ខុស្ស ឋានំ បត្ថយតេ អយំ
តាយ សទ្ធាយ ចាគេន សទ្ធម្មស្សវណេន ច(៦) ។

---

១ ម. ឧបេច្ច ។ ២ ឱ. សត្ថុបារគ្គំ ។ ៣ ម. បភិន្នមតិគោចរំ ។ ៤ ឱ. ម. បាទមូលេ ទេ ។ ៥ ឱ. ពុទ្ធសេដ្ឋស្ស ។ ៦ ឱ.ម. តេន ធម្មស្សវនេន ច ។





កាលនោះ ខ្ញុំកើតជាព្រាហ្មណ៍ ក្នុងក្រុងហង្សវតី ជាអ្នកដល់នូវត្រើយនៃវេទ បានចូលទៅជិតព្រះពុទ្ធជាកំពូល នៃសព្វលោកទាំងពួង ហើយស្តាប់ធម្មទេសនា ។ គ្រានោះ ព្រះពុទ្ធជាអ្នកប្រាជ្ញ ទ្រង់តាំងសាវ័ក (មួយអង្គ) ដែលបែកធ្លាយបដិសម្ភិទា ជាអ្នកឈ្លាសវៃក្នុងអត្ថ ធម៌ និរុត្តិ និងបដិភាណ ក្នុងទីជាឯតទគ្គៈ កាលនោះ ខ្ញុំបានឮនូវតំណែងនោះហើយ ក៏មានចិត្តរីករាយ បាននិមន្តព្រះជិនស្រីដ៏ប្រសើរ ព្រមទាំងសាវ័កឲ្យឆាន់ អស់ ៧ ថ្ងៃ ។ ខ្ញុំញុំាងព្រះពុទ្ធដូចជាសាគរ ព្រមទាំងសិស្សឲ្យស្លៀកសំពត់ រួចខ្ញុំក្រាបទៀបព្រះបាទមូល ប្រាថ្នានូវតំណែងនោះ ។

លំដាប់នោះ ព្រះពុទ្ធជាកំពូលលោក ទ្រង់ត្រាស់ថា អ្នកទាំងឡាយ ចូរមើលព្រាហ្មណ៍ដ៏ខ្ពង់ខ្ពស់នុ៎ះ ក្រាបទៀបបាទមូល មានរស្មីដ៏ពោះ ដូចផ្កាឈូក ព្រាហ្មណ៍នេះ (បរិបូណ៌) ដោយសទ្ធា ចាគៈ និងសទ្ធម្មស្សវនៈនោះ ប្រាថ្នានូវតំណែងនៃភិក្ខុ របស់ព្រះពុទ្ធដ៏ប្រសើរ ។

សព្វត្ថ សុខិតោ ហុត្វា សំសរិត្វា ភវាភវេ

អនាគតម្ហិ អទ្ធានេ លច្ឆសេតំ[១] មនោរថំ ។

សតសហស្សិតោ កប្បេ ឱក្កាកកុលសម្ភវោ

គោតមោ នាម នាមេន សត្ថា លោកេ ភវិស្សតិ ។

តស្ស ធម្មេសុ ទាយាទោ ឱរសោ ធម្មនិម្មិតោ

កោដ្ឋិតោ នាម នាមេន ហេស្សតិ សត្ថុសាវកោ ។

តំ សុត្វា មុទិតោ ហុត្វា យាវជីវំ តទា ជិនំ

មេត្តចិត្តោ បរិចរឹ[២] យតោ[៣] បញ្ញាសមាហិតោ ។

តេន កម្មវិបាកេន ចេតនាបណិធីហិ ច

ជហិត្វា មានុសំ ទេហំ តាវតឹសំ អគញ្ឆហំ ។

សតានំ តីណិក្ខត្តុញ្ច ទេវរជ្ជមការយឹ

សតានំ បញ្ចក្ខត្តុញ្ច ចក្កវត្តី អហោសហំ ។

---

១ ឱ. លច្ឆសេតំ ។ ២ ម. ជិនំ តំ ។ ៣ ឱ.ម. សតោ ។





ព្រាហ្មណ៍នេះ ជាអ្នកដល់នូវសេចក្តីសុខ ក្នុងទីតាំងក្នុង អន្ទោលទៅក្នុងភពតូចភពធំ រមែងបាននូវតំណែងនុ៎ះ ដូចបំណង ក្នុងកាលជាអនាគត ។ ក្នុងកប្បទីមួយសែន អំពីកប្បនេះ មានមហាបុរស សម្ភពក្នុងត្រកូលស្តេចឱក្កាកៈ នឹងបានជាព្រះសាស្តា ក្នុងលោក ព្រះនាមគោតម ។ ព្រាហ្មណ៍នេះ នឹងបានជាធម្មទាយាទ ជាឱរស ជាធម្មនិម្មិត របស់ព្រះគោតមនោះ នឹងបានជាសាវ័ក នៃព្រះសាស្តា មាននាមថា កោដ្ឋិកៈ ។

កាលនោះ ខ្ញុំឮពុទ្ធព្យាករណ៍នោះហើយ ក៏មានចិត្តរីករាយ មានចិត្តប្រកបដោយមេត្តា មានប្រាជ្ញាខ្ជាប់ខ្ជួនបានបម្រើព្រះជិនស្រី ដរាបដល់អស់ជីវិត ។ ដោយផលនៃកុសលកម្មនោះផង ដោយការតាំងទុក នូវសេចក្តីប្រាថ្នានោះផង ខ្ញុំលះបង់កាយ ជារបស់មនុស្សហើយ បានទៅកើតក្នុងឋានតាវត្តិង្ស ។ ខ្ញុំបានសោយរាជ្យ ជាស្តេចទេវតា អស់ ៣០០ ដង បានជាស្តេចចក្រពត្តិ អស់ ៥០០ ដង ។

បទេសរជ្ជំ វិបុលំ គណនាតោ អសង្ខិយំ
សត្តត្ត សុចិតោ កាសី តស្ស កម្មស្ស វាហសា ។
ទុវេ ភវេ សំសរាមិ ទេវត្តេ អថ មានុសេ
អញ្ញំ គតឹ ន ជានាមិ(១) សុចិណ្ណស្ស ឥទំ ផលំ ។
ទុវេ កុលេ បជាយាមិ ខត្តិយេ ចាបិ ព្រាហ្មណេ
នីចេ កុលេ ន ជាយាមិ សុចិណ្ណស្ស ឥទំ ផលំ ។
បច្ឆិមេ ភវសម្បត្តេ ព្រហ្មពន្ធុ អហោសហំ
សាវត្ថិយំ វិប្បកុលេ បច្ចាជាតោ មហទ្ធនេ ។
មាតា ចន្ទវតី នាម បិតា មេ អស្សលាយនោ
យទា មេ បិតរំ ពុទ្ធោ វិនយិ(២) សព្វសុទ្ធិយា(៣) ។
តទា បសន្នោ សុគតំ បព្វជឹ អនគារិយំ
មោគ្គល្លានោ អាចរិយោ ឧបជ្ឈា សារិសម្ភវោ ។

---

១ ឱ.ម. ន គច្ឆាមិ ។ ២ ឱ.ម. វិនយី ។ ៣ ឱ. សព្វសុទ្ធិយា ។



បានសោយប្រទេសរាជ្យដ៏ធំទូលាយ រាប់ជាគណនាមិនអស់ ខ្ញុំបានសេចក្តីសុខ ក្នុងទីទាំងពួង ដោយអានិសង្សនៃកុសលកម្មនោះ ។ ខ្ញុំតែងអន្ទោលទៅក្នុងភព ២ គឺទេវតា ឬមនុស្ស ខ្ញុំមិនដែលស្គាល់គតិដទៃ នេះជាផលនៃកុសលកម្ម ដែលខ្ញុំសន្សំល្អហើយ ។ ខ្ញុំតែងកើតក្នុងត្រកូល ២ គឺក្សត្រ ឬព្រាហ្មណ៍ មិនដែលកើត ក្នុងត្រកូលទាបថោកទេ នេះជាផលនៃកុសលកម្ម ដែលខ្ញុំសន្សំល្អហើយ ។ លុះដល់បច្ឆិមភព ខ្ញុំជាអ្នកមានផៅពង្សប្រសើរ ខាងក្រោយមក ខ្ញុំកើតក្នុងត្រកូលព្រាហ្មណ៍ មានធនធានច្រើន ក្នុងក្រុងសាវត្ថី ។ មាតារបស់ខ្ញុំ ឈ្មោះចន្ទវតី បិតារបស់ខ្ញុំ ឈ្មោះអស្សលាយនៈ ព្រះពុទ្ធទ្រង់ទូន្មានបិតារបស់ខ្ញុំ ដើម្បីសេចក្តីស្អាតគ្រប់យ៉ាង ក្នុងកាលណា ។ កាលនោះ ខ្ញុំជ្រះថ្លា ចំពោះព្រះសុគត ហើយចូលទៅកាន់ផ្នួស ព្រះមោគ្គល្លានជាអាចារ្យ ព្រះសារីបុត្តជាឧបជ្ឈាយ៍ (របស់ខ្ញុំ) ។

កេសេសុ ឆិជ្ជមានេសុ ទិដ្ឋិ ឆិន្នា សមូលិកា
និវាសេន្តោ ច កាសាវំ អរហត្តំ អបាបុណឹ ។
អត្ថធម្មនិរុត្តីសុ បដិភាណេ ច មេ មតិ
បភិន្នា តេន លោកគ្គោ ឯតទគ្គេ ឋបេសិ មំ ។
អសន្ទិដ្ឋំ វិយាកាសិ ឧបតិស្សេន បុច្ឆិតោ
បដិសម្ភិទាសុ តេនាហំ អគ្គោ សត្ថុសាសនេ ។
កិលេសា ឈាបិតា មយ្ហំ ភវា សព្វេ សមូហតា
នាគោវ ពន្ធនំ ឆេត្វា វិហរាមិ អនាសវោ ។
ស្វាគតំ វត មេ អាសិ ពុទ្ធសេដ្ឋស្ស សន្តិកេ
តិស្សោ វិជ្ជា អនុប្បត្តា កតំ ពុទ្ធស្ស សាសនំ ។
បដិសម្ភិទា ចតស្សោ វិមោក្ខាបិ ច អដ្ឋិមេ
ឆឡភិញ្ញា សច្ឆិកតា កតំ ពុទ្ធស្ស សាសនន្តិ ។





កាលសក់ទាំងឡាយដាច់ចុះ ទិដ្ឋិព្រមទាំងឫសក៏ដាច់ចុះដែរ ខ្ញុំកំពុងតែស្លៀកសំពត់កាសាវៈ ក៏បានសម្រេចអរហត្ត ។ ប្រាជ្ញារបស់ខ្ញុំបែកធ្លាយ ក្នុងអត្ថ ធម៌ និរុត្តិ និងបដិភាណ ហេតុនេះ បានជាព្រះពុទ្ធ ជាកំពូលនៃលោក ទ្រង់តាំងខ្ញុំ ក្នុងទីជាឯតទគ្គៈ ។ ខ្ញុំត្រូវឧបតិស្សៈ សាកសួរក្នុងបដិសម្ភិទា ក៏បានដោះស្រាយនូវធម៌ ដែលខ្លួនមិនដែលបានឃើញ ហេតុនោះហើយបានជាខ្ញុំជាអ្នកប្រសើរ ក្នុងសាសនានៃព្រះសម្ពុទ្ធ ។ កិលេសទាំងឡាយ ខ្ញុំដុតបំផ្លាញហើយ ភពទាំងពួង ខ្ញុំដកចោលហើយ ខ្ញុំជាអ្នកមិនមានអាសវៈ ព្រោះបានកាត់ចំណង ដូចជាដំរីកាត់ផ្ដាច់នូវចំណង ។ ឱ! ខ្ញុំមកល្អហើយ ក្នុងសំណាក់ព្រះពុទ្ធដ៏ប្រសើរ របស់ខ្ញុំ វិជ្ជា ៣ ខ្ញុំបានដល់ហើយ សាសនា របស់ព្រះពុទ្ធ ខ្ញុំបានធ្វើហើយ ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនា របស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ។

ឥត្ថំ សុទំ អាយស្មា មហាកោដ្ឋិកោ ថេរោ ឥមា
គាថាយោ អភាសិត្ថាតិ ។

មហាកោដ្ឋិកត្ថេរស្ស អបទានំ សមត្តំ ។

## អដ្ឋមំ ឧរុវេលកស្សបត្ថេរាបទានំ

(១៤៨) បទុមុត្តរោ នាម ជិនោ សព្វលោកវិទូ មុនិ
ឥតោ សតសហស្សម្ហិ កប្បេ ឧប្បជ្ជិ ចក្ខុមា ។
ឱវាទកោ វិញ្ញាបកោ តារកោ សព្វបាណិនំ
ទេសនាកុសលោ ពុទ្ធោ តារេសិ ជនតំ ពហុំ ។
អនុកម្បកោ ការុណិកោ ហិតេសី សព្វបាណិនំ
សម្បត្តេ តិត្ថិយេ សព្វេ បញ្ចសីលេ បតិដ្ឋហិ ។
ឯវំ និរាកុលំ អាសិ សុញ្ញតំ តិត្ថិយេហិ ច
វិចិត្តំ អរហន្តេហិ វសីភូតេហិ តាទិភិ ។



បានឮថា ព្រះមហាកោដ្ឋិកត្ថេរ មានអាយុ បានសំដែងនូវគាថា
ទាំងនេះ ដោយប្រការដូច្នេះ ។

ចប់ មហាកោដ្ឋិកត្ថេរាបទាន ។

## ឧរុវេលកស្សបត្ថេរាបទាន ទី ៨

(១៤៨) ព្រះជិនស្រីព្រះនាមបទុមុត្តរៈ ជាអ្នកប្រាជ្ញ ទ្រង់
ជ្រាបច្បាស់នូវលោកទាំងមូល មានបញ្ញាចក្ខុ ទ្រង់ឧប្បត្តិឡើង
ក្នុងកប្បទីមួយសែន អំពីកប្បនេះ ។ ព្រះពុទ្ធជាម្ចាស់ ទ្រង់
ប្រទានឱវាទ ញុំាងសត្វឲ្យត្រាស់ដឹង ចម្លងសត្វទាំងពួង
ទ្រង់ឈ្លាសក្នុងទេសនា ស្តេចញុំាងប្រជុំជនច្រើនឲ្យឆ្លង(ចាក
លោក) ព្រះអង្គមានសេចក្តីអនុគ្រោះ មានសេចក្តីករុណា
ស្វះស្វែងរកនូវប្រយោជន៍ដល់សត្វទាំងពួង បានញុំាងពួក
តិរ្ថិយទាំងពួង ដែលមកប្រជុំគ្នាឲ្យតាំងនៅស៊ប់ក្នុងសីល៥ ។
សាសនានេះមិនរើករវល់ សូន្យចាកពួកតិរ្ថិយ វិចិត្រដោយពួក
ព្រះអរហន្ត ជាអ្នកស្ទាត់ជំនាញ ប្រកបដោយតាទិគុណ ។

រតនានដ្ឋបញ្ញាសំ ឧគ្គតោ សោ មហាមុនិ
កញ្ចនគ្ឃិយសង្កាសោ ទ្វត្តឹសវរលក្ខណោ ។
វស្សសតសហស្សានិ អាយុ វិជ្ជតិ តាវទេ
តាវតា តិដ្ឋមានោ សោ តារេសិ ជនតំ ពហុំ ។
តទាហំ ហំសវតិយា ព្រាហ្មណោ សាធុសម្មតោ
ឧបេច្ច លោកបជ្ជោតំ អស្សោសឹ ធម្មទេសនំ ។
តទា មហាបរិសតិ មហាបុរិសសាវកំ
ឋបេន្តំ ឯតទគ្គម្ហិ សុត្វាន មុទិតោ អហំ ។
មហតា បរិវារេន និមន្តេត្វា មហាជិនំ
ព្រាហ្មណានំ សហស្សេន សហ ទានមទាសហំ ។
មហាទានំ ទទិត្វាន អភិវាទិយ នាយកំ
ឯកមន្តំ ឋិតោ ហដ្ឋោ ឥទំ វចនមព្រវឹ ។



ព្រះមហាមុនីនោះ មានកំពស់ ៥៨ ហត្ថ ប្រាកដស្មើដោយគ្រឿងប្រដាប់ ជាវិការៈនៃមាស មានលក្ខណៈដ៏ប្រសើរ ៣២ ប្រការ ។ មានព្រះជន្មមួយសែនឆ្នាំ កាលព្រះអង្គគង់ព្រះជន្មនៅឡើយ បានញុំាងពួកជនច្រើនឲ្យឆ្លង (ចាកលោក) កាលនោះ ខ្ញុំកើតជាព្រាហ្មណ៍ ដែលលោកសន្មតថាជាសប្បុរស នៅក្នុងក្រុងហង្សវតី បានចូលទៅគាល់ព្រះពុទ្ធជាពន្លឺនៃលោក ហើយស្តាប់ធម្មទេសនា ។ ក្នុងកាលនោះ ខ្ញុំបានឃើញព្រះមានបុណ្យ កំពុងតាំងមហាបុរិសសាវក ក្នុងទីជាឯតទគ្គៈ ក្នុងកណ្តាលមហាបរិស័ទ ខ្ញុំបានឮហើយក៏ត្រេកអរ ។ ខ្ញុំនិមន្តព្រះមហាជិនស្រី ព្រមទាំងបរិវារជាច្រើន បានថ្វាយទានជាមួយនឹងពួកព្រាហ្មណ៍ មួយពាន់នាក់ ។ លុះថ្វាយមហាទានហើយ ក៏ក្រាបថ្វាយបង្គំព្រះនាយក ឋិតនៅក្នុងទីដ៏សមគួរ ត្រេកអរហើយ ក៏ពោលពាក្យនេះថា

តយិ សទ្ធាយ មេ វីរ អធិការោតុលោ ច ព

បរិសា មហតី ហោតុ ជិតត្តស្ស តវំ តវំ ។

តទា អនេក បរិសំ ឧទគ្គិតសុស្សុក

ការិការុណោ សត្ថា ឥមំ បស្សថ ព្រាហ្មណំ ។

ហេមវណ្ណំ មហាពាហុំ កមលាននលោចនំ

ឧទគ្គតនុជំ ហដ្ឋំ សទ្ធាវន្តំ គុណេ មម ។

ឯស បត្ថយតិ(១) ឋានំ សីហសរស្ស(២) ភិក្ខុនោ

អនាគតម្ហិ អទ្ធានេ លច្ឆសេតំ មនោរថំ ។

សតសហស្សេ ឥតោ កប្បេ ឱក្កាកកុលសម្ភវោ

គោតមោ នាម នាមេន សត្ថា លោកេ ភវិស្សតិ ។

---

១ ឱ. បត្ថយេ ។ ម. បត្ថេសេ ។ ២ ឱ.ម. សីហឃោសស្ស ។



បពិត្រព្រះអង្គមានព្យាយាម ដោយសេចក្ដីជឿចំពោះព្រះអង្គផង ដោយគុណាធិការដ៏ក្រៃលែងផង បរិស័ទច្រើន សូមសម្រេចដល់ខ្ញុំព្រះអង្គ ដែលកើតក្នុងទីនោះ ។ ។

គ្រានោះ ព្រះសាស្ដា មានព្រះសូរសៀងក្បោះក្បាយ ដូចផាក់ខនៃដំរី ពីរោះដូចសត្វករវិក បានត្រាស់ចំពោះបរិស័ទថា អ្នកទាំងឡាយ ចូរមើលព្រាហ្មណ៍នុ៎ះ មានសម្បុរដូចមាស មានកំភួនដៃធំ មានមុខនិងភ្នែកដូចផ្កាឈូក មានរោមដ៏ខៀវផែលឡើង ជាអ្នកត្រេកអរ មានសេចក្ដីជឿក្នុងគុណរបស់តថាគត ។ ព្រាហ្មណ៍នេះ ប្រាថ្នានូវតំណែងនៃភិក្ខុ ដែលមានសំឡេង ដូចជាសីហៈនោះ នឹងបាននូវតំណែងនុ៎ះដូចបំណង ក្នុងកាលជាអនាគត ។ ក្នុងកប្បទីមួយសែនអំពីកប្បនេះ មានព្រះមហាបុរស សម្ភពក្នុងត្រកូលស្ដេចឧក្កាកៈ នឹងបានជាព្រះសាស្ដាក្នុងលោក ព្រះនាមគោតម ។

តស្ស ធម្មស្ស ទាយាទោ   ឱរសោ ធម្មនិម្មិតោ

កស្សបោ នាម នាមេន   ហេស្សតិ សត្ថុ សាវកោ ។

ឥតោ ទ្វេនវុតេ កប្បេ   អហុ សត្ថា អនុត្តរោ

អប្បដិមោ អសទិសោ   ផុស្សោ លោកគ្គនាយកោ ។

សោ ច សព្វតមំ ហន្ត្វា   វិជដេត្វា មហាជដំ

វស្សេតិ អមតំ វុដ្ឋិំ   តប្បយន្តោ សទេវកំ ។

តទា វយំ(១) ពារាណសិយំ   រាជាមច្ចា អហុម្ហសេ

ភាតរេម្ហ តយោ សព្វេ   សំវិស្សដ្ឋា រាជិនោ(២) ។

វីរង្គរូបា ពលិនោ   សង្គាមេ អបរាជិតា

តទា កុបិតបច្ចន្តេ   អម្ហេ រាជា មហីបតិ ។

១ ម. តទាហំ ។ ឱ. តទា ហិ ។ ២ ម. សំវិស្សត្ថា បករិនោ ។



ព្រាហ្មណ៍នេះ ជាឱរសដែលធម៌និម្មិត ជាអ្នកទទួលមត៌កនូវធម៌ របស់ព្រះគោតមនោះ នឹងបានជាសាវ័កនៃព្រះសាស្តា មាននាមថា កស្សបៈ ។ កន្លងកប្បទី ៩២ អំពីកប្បនេះ ទើបមានព្រះសាស្តាព្រះនាមផុស្សៈ ព្រះអង្គប្រសើរ រកបុគ្គលប្រៀបផ្ទឹមមិនបាន ឥតមានបុគ្គលស្មើ ជានាយក ជាកំពូលនៃលោក ។ ព្រះអង្គកំចាត់បង់នូវងងឹតទាំងពួង ទ្រង់ស្រ-ដោះនូវបណ្តាញធំ គឺតណ្ហា ស្តេចបង្អុរចុះនូវភ្លៀង គឺអមតៈ ហើយញុំាងមនុស្សលោក ព្រមទាំងទេវលោក ឲ្យឆ្អែតស្កប់ស្កល់ (ដោយទឹកអម្រឹតនោះ) ។ កាលនោះ យើងទាំងអស់គ្នា ៣ នាក់ ជាបងប្អូន ជាអាមាត្យរបស់ស្តេចពារាណ-សី ជាទីទុកព្រះទ័យ នៃព្រះរាជា ។ ជាអ្នកមានព្យាយាមដ៏អាច មានកម្លាំង ឈ្នះក្នុងសង្គ្រាម គ្រានោះ ស្រុកបច្ចន្តគ្រាមកើតបះបោរ ម្ចាស់ផែនដី ក៏ត្រាស់បង្គាប់យើង

## អដ្ឋមំ ឧរោលកសប្បុរេត្តកបាឋំ

ធជ កត្វាន បត្តិំ   សាធេត្វា អវធិពលិ(១)

ខេមិ មេ វិជិតំ កត្វា   បុណ្ណជាតិ សាសជ(២) ។

តតោ មយំ អកេទុម្ហា   យធ ខេយ្យាសិ ជាយតំ

ឧបដ្ឋាជាយ អម្ហាកំ   សាធយិស្សាម(៣) តេ តតោ ។

តតោ មយំ លទ្ធិក   ក្ខមិតាលេន បេសិតា

ធិក្ខិត្តសត្តំ បត្តិំ   កត្វា បុញ្ញុបេក្ខ តំ ។

យាចិត្វា សត្តុបដ្ឋាធំ   ភជាធំ លោកយតំ

អុធិវំ លកិត្វាន   យាវជីវំ យធិម្ហ(៤) តំ ។

---

១ ឱ. សោធេត្វា អវិនីតល់ ។ ម. សោធេត្វា អវិនិតល់ ។ ២ ឱ.ម. ភាសចំ ។ ៣ ឱ. សោធយិស្សាម ។ ៤ ឱ. អធិម្ហ ។



## ឧរោលកសប្បុរេត្តកបេត ទី ៨

ប្រៀនប្រដៅយើងថា អ្នកទាំងឡាយ មកអាយ ចូរទៅ កាន់បច្ចន្តគ្រាម បង្ក្រាបភាសាវែងដី ធ្វើដែនរបស់អញ ឲ្យ បានក្សេមក្សាន្ត ហើយត្រឡប់មកវិញចុះ ។ លំដាប់នោះ ពួកយើងក្រាបទូលសូមភាថា បើព្រះអង្គប្រទាន ទូលព្រះពុទ្ធ ជានាយក ដល់យើងដើម្បីបានបំរើ យើងទាំងឡាយ នឹង បង្ក្រាបសត្រូវទាំងនោះ ក្នុងបច្ចន្តគ្រាមនោះ ឲ្យខានតែ បាន ។ គ្រានោះ ពួកយើងបានទទួលហើយ ទើបស្តេច បញ្ជូនទៅដើម្បីក្សេមស្រុក ពួកយើងក៏ធ្វើបច្ចន្តគ្រាម ឲ្យ មានគ្រឿងសស្ត្រាដាក់ទុះ រួចហើយត្រឡប់មកកាន់ក្រុង តក្កសិលានោះវិញ ។ បានសូមភាបេប្រើព្រះសាស្តា ជា លោកនាយក នឹងព្រះកជា សុំបានព្រះមុនីដ៏ប្រសើរមក ហើយ ទើបនាំគ្នាបូជាព្រះអង្គនោះ ដរាបដល់អស់ជីវិត ។

មហគ្ឃានិ ច វត្ថានិ   បណីតានិ រសានិ ច
សេនាសនានិ រម្មានិ   ភេសជ្ជានិ ហិតានិ ច ។
ទត្វា សសង្ឃមុនិនោ   ធម្មេនុប្បាទិតានិ នោ[1]
សីលវន្តោ ការុណិកា   ចាគយុត្តមានសា ។
សទា បរិចរិត្វាន   មេត្តចិត្តេន នាយកំ
និព្វុតេ តម្ហិ លោកគ្គេ   បូជំ កត្វា យថាពលំ ។
តតោ ចុតា តាវតឹសំ[2]   គតា តត្ថ មហាសុខំ
អនុភូតា មយំ សព្វេ   ពុទ្ធបូជាយិទំ ផលំ ។
មាលាការោ យថាលទ្ធា   ទស្សេតិ វិកតី ពហុំ
តថា ភវេ ភវេត្តហំ   វិមានាធិបតី អហុំ ។

១ ម.ឆ. ធម្មេនុប្បាទិតានិ តេ ។ ២ ឱ. ម. សន្តុសិតំ ។



ពួកយើងជាអ្នកមានសីល មានសេចក្តីករុណា មានចិត្តប្រកបដោយការឲ្យ បានប្រគេន នូវសំពត់មានតម្លៃផង នូវភោជនមានសេចក្តីថ្លៃថ្លាផង នូវសេនាសនៈជាទីត្រេកអរផង នូវភេសជ្ជៈជាប្រយោជន៍ផង ដែលកើតឡើងដោយធម៌ ដល់ព្រះមុនី ព្រមទាំងព្រះសង្ឃ ហើយបម្រើព្រះនាយកដោយមេត្តាចិត្តសព្វកាល ។ កាលដែលព្រះអង្គជាកំពូលនៃលោកទ្រង់បរិនិព្វានទៅ ពួកយើងក៏នាំគ្នាធ្វើការបូជា សមគួរតាមកម្លាំងធនធាន ។ ពួកយើងទាំងអស់គ្នា ច្យុតអំពីមនុស្សលោកនោះ បានទៅកើតក្នុងឋានតាវត្តិង្ស សោយមហាសុខក្នុងឋានតាវត្តិង្សនោះ នេះជាផលនៃពុទ្ធបូជា ។ ជាងក្រងផ្កា បាននូវផ្កា តែងសម្តែងនូវការធ្វើលេចផ្សេង ៗ ច្រើនយ៉ាង យ៉ាងណាមិញ ចំណែកខាងខ្ញុំ កាលកើតក្នុងភព បានជាធំក្នុងវិមានទាំងឡាយ ក៏យ៉ាងនោះដែរ ។

គុណាចេលស្ស ភត្តេន  មិច្ឆាទិដ្ឋិគតាសយោ
ឧរកាមត្តមាស្សេត្វា  រុចាយ(១) មម ធីតុយា ។
ទិវាទិ ឋានយិត្វាន  ព្រហ្មុនា នារទេនហំ
ពហុធា(២) សាសិតោ សន្តោ  ទិដ្ឋិំ ហិត្វាន បាបិកំ ។
បូរយិត្វា វិសេសេន  ទសកម្មបថេ អហំ
ហិត្វាន ទេហមត្តិមំ  សគ្គំ សកឃរំ យថា ។
បច្ឆិមេ ភវសម្បត្តេ  ព្រហ្មពន្ធុ អហោសហំ
ពារាណសិយំ ជីតាយ(៣)  ជាតោ វិប្បកុលេ អហំ(៤) ។
មច្ចុព្យាធិជរាភីតោ  ឱគាហេត្វា មហាវនំ(៥)
បព្វាជិំ បនមេសន្តោ  ជដិលេសុ អវត្ថិជី ។
តទា ទ្វេ ភាតរោ មយ្ហំ  បព្វជឹសុ មយា សហ
ឧរវេលាយ នាមេត្វា  អស្សមិំ មេសិំ រហិ ។

១ ឱ. ខេវា មត្តិមាទេហ្គ រូជាយ ។ ២ ឱ. ពហុវ ។ ៣ ឱ. ពារាណសិយំ ជាយំ ។
៤ ឱ. វិប្បមហាកុលេ ។ ៥ ឱ. ហិត្វាន ប មហាវនំ ។



ខ្ញុំមានការសង្ឃឹម ត្រូវមិច្ឆាទិដ្ឋិកំចាត់បង់ (ព្រោះជឿ) តាមពាក្យអាចេលឈ្មោះគុណៈ ក៏ឡើងកាន់ផ្លូវខុស មិនបានកាន់យកនូវពាក្យរបស់នាងរុចា ជាធីតានៃខ្ញុំ លុះបាននារទព្រហ្មមកប្រៀនប្រដៅ ដោយវិធីច្រើនយ៉ាង ក៏បានស្ញប់ស្ញាប់ ហើយលះបង់ទិដ្ឋិអាក្រក់ចោលចេញ ។ ខ្ញុំបានបំពេញកម្មបថទាំង ១០ ដោយវិសេស លុះលះបង់កាយរបស់មនុស្សហើយ ក៏បានទៅកើតក្នុងឋានសួគ៌ ដូចជាទៅកាន់លំនៅរបស់ខ្លួន ។ លុះដល់បច្ឆិមភព ខ្ញុំជាអ្នកមានជាតិដ៏ប្រសើរ គឺកើតក្នុងត្រកូលព្រាហ្មណ៍ ក្នុងក្រុងពារាណសី ជាក្រុងទូលាយ ។ ខ្ញុំត្រូវមច្ចុ ព្យាធិ និងជរាគ្របសង្កត់ហើយ បានចូលទៅក្នុងព្រៃមហាវ័ន ស្វែងរកផ្លូវព្រះនិព្វាន ហើយក៏ចូលបួសក្នុងពួកជដិល ។ គ្រានោះ ប្អូនរបស់ខ្ញុំទាំង ២ នាក់ ក៏បួសជាមួយនឹងខ្ញុំដែរ ខ្ញុំបានកសាងអាស្រម នៅក្នុងឧរុវេលប្រទេស ។

កស្សបោ នាម គោត្តេន ឧរុវេលាយ ជ៏វសី(១)
តតោ មេ អាសិ បញ្ញត្តិ ឧរុវេលាសុ កស្សបោ ។
នទីសកាសេ ភាតា មេ នទីកស្សបសវ្ហយោ
អាសិប្បកាសោ គាមេន(២) គយាយំ គយកស្សបោ ។
ទ្វេ សតានិ កនិដ្ឋស្ស តីណិ មជ្ឈស្ស ភាតុនោ
មម បញ្ចសតា ឩនា សិស្សា សព្វេ មមានុគា ។
តទា ឧបេច្ច មំ(៣) ពុទ្ធោ កត្វាន វិវិធានិ មេ
បាដិហីរានិ លោកគ្គោ វិនេសិ នរសារថិ ។
សហស្សបរិវារេន អហោសិំ ឯហិភិក្ខុកោ(៤)
តេហេវ សហ សព្វេហិ អរហត្តំ អបាបុណឹ ។

---

១ ឱ. ឧរុវេលា ខិវសិកា ។ ម. ឧរុវេឡនិវសិតោ ។ ២ ឱ. អាសិ សកាសេ គាមេន ។ ម. អាសិសកាសគាមេន ។ ៣ ឱ. មេ ។ ៤ ឱ. ភិក្ខុកោ ។



ខ្ញុំឈ្មោះកស្សប តាមគោត្រ នៅក្នុងឧរុវេលប្រទេស ព្រោះនៅក្នុងឧរុវេលប្រទេសនោះ បានជានាមបញ្ញត្តិ របស់ខ្ញុំថា ឧរុវេលកស្សប ។ ប្អូនរបស់ខ្ញុំម្នាក់ នៅក្បែរស្ទឹង មាននាមថា នទីកស្សប (ប្អូនម្នាក់ទៀត) នៅក្នុងប្រទេសគយា ក៏មាននាមប្រាកដថា គយាកស្សប ។ ប្អូនពៅមានសិស្ស ២០០ ប្អូនកណ្តាល មានសិស្ស ៣០០ ខ្ញុំឯងមានសិស្ស ៥០០ ឥតខ្វះ សិស្សទាំងអស់នោះ ប្រព្រឹត្តតាមខ្ញុំ ។ គ្រានោះ ព្រះពុទ្ធជាកំពូលនៃលោក ជានរសារថី ទ្រង់ចូលទៅរកខ្ញុំ បានធ្វើបាដិហារ្យផ្សេងៗ ទូន្មានខ្ញុំ ។ ខ្ញុំបានបួសជាឯហិភិក្ខុ ព្រមដោយបរិវារមួយពាន់ ហើយបានសម្រេចអរហត្ត មួយអន្លើដោយជនទាំងនោះគ្រប់គ្នា ។

តេ ច អញ្ញេ ពហូ ភេ    យសសា(១) មំ បរិវារយុំ
សាសិតុញ្ច សមត្ថោហំ    តតោ មំ ឥសិ សត្តមោ ។
មហាបរិសការីស្មឹ    ឯតទគ្គេ ឋបេសិ មំ
អហោ ពុទ្ធេ កតំ ការំ    សផលំ មេ អជាយថ ។
កិលេសា ឈាបិតា មយ្ហំ ភវា សព្វេ សមូហតា
នាគោវ ពន្ធនំ ឆេត្វា    វិហរាមិ អនាសវោ ។
ស្វាគតំ វត មេ អាសិ    មម ពុទ្ធស្ស សន្តិកេ
តិស្សោ វិជ្ជា អនុប្បត្តា    កតំ ពុទ្ធស្ស សាសនំ ។
បដិសម្ភិទា ចតស្សោ    វិមោក្ខាបិ ច អដ្ឋិមេ
ឆឡភិញ្ញា សច្ឆិកតា    កតំ ពុទ្ធស្ស សាសនន្តិ ។

ឥត្ថំ សុទំ អាយស្មា ឧរុវេលកស្សបោ ថេរោ ឥមា គាថាយោ អភាសិត្ថាតិ ។

ឧរុវេលកស្សបត្ថេរស្ស អបទានំ សមត្តំ ។

---

១ ឱ. សិស្សា ។ ម. យេស្សា ។





មិនមែនត្រឹមតែពួកជន ទាំងនោះទេ មានទាំងពួកជនដទៃជាច្រើន ហោមរោមខ្ញុំដោយយស ខ្ញុំក៏អាចប្រៀនប្រដៅ (ជនទាំងនោះ) បាន លំដាប់ពីនោះមក ព្រះពុទ្ធជាឥសីទី ៧ ទ្រង់តាំងខ្ញុំក្នុងទីជាឯតទគ្គៈ ខាងមានបរិស័ទច្រើន ។ ឱហ្ន៎! ការបូជាដែលខ្ញុំបានធ្វើចំពោះព្រះពុទ្ធ កើតផលដល់ខ្ញុំវិញ ។ កិលេសទាំងឡាយ ខ្ញុំដុតបំផ្លាញហើយ ភពទាំងពួងខ្ញុំដកចោលហើយ ខ្ញុំជាអ្នកមិនមានអាសវៈ ព្រោះបានកាត់ចំណង ដូចដំរីកាត់ផ្តាច់នូវទន្ទឹង ។ ឱ! ខ្ញុំមកល្អហើយក្នុងសំណាក់ព្រះពុទ្ធរបស់ខ្ញុំ វិជ្ជា ៣ ខ្ញុំបានដល់ហើយ សា-សនា របស់ព្រះពុទ្ធ ខ្ញុំបានធ្វើហើយ ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនា របស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ។

បានឮថា ព្រះឧរុវេលកស្សបត្ថេរ មានអាយុ បានសម្តែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

ចប់ ឧរុវេលកស្សបត្ថេរាបទាន ។

## នវមំ ភទ្ទត្ថេរាបទានំ

(១៦៨) បទុមុត្តរោ នាម ជិនោ សព្វលោកវិទូ មុនិ
ឥតោ សតសហស្សម្ហិ កប្បេ ឧប្បជ្ជិ ចក្ខុមា ។
ឱវាទកោ វិញ្ញាបកោ តារកោ សព្វបាណិនំ
ទេសនាកុសលោ ពុទ្ធោ តារេសិ ជនតំ ពហុំ ។
អនុកម្បកោ ការុណិកោ ហិតេសី សព្វបាណិនំ
សម្បត្តេ តិត្ថិយេ សព្វេ បញ្ចសីលេ បតិដ្ឋហិ ។
ឯវំ និរាកុលំ អាសិ សុញ្ញតំ តិត្ថិយេហិ ច
វិចិត្តំ អរហន្តេហិ វសីភូតេហិ តាទិហិ ។
រតនានដ្ឋបញ្ញាសំ ឧគ្គតោ សោ មហាមុនិ
កញ្ចនគ្ឃិយសង្កាសោ ទ្វត្តឹសវរលក្ខណោ ។



## ភទ្ទត្ថេរាបទាន ទី៩

( ១៦៨ ) ព្រះជិនស្រី ព្រះនាមបទុមុត្តរៈ មានបញ្ញាចក្ខុ ជាអ្នកប្រាជ្ញ ជ្រាបច្បាស់នូវលោកទាំងពួង ស្តេចកើតឡើងក្នុងកប្បទីមួយសែន អំពីកប្បនេះ ។ ព្រះពុទ្ធទ្រង់ឈ្លាសក្នុងការទេសនា ទ្រង់ប្រទានឱវាទ ញុំាងសត្វឲ្យត្រាស់ដឹង បម្លងសត្វទាំងពួង ទ្រង់ញុំាងប្រជុំជនច្រើនឲ្យឆ្លង (ពីលោក) ។ ព្រះអង្គមានសេចក្តីអនុគ្រោះ មានសេចក្តីអាណិតអាសូរ ស្វែងរកប្រយោជន៍ដល់សព្វសត្វ ទ្រង់ញុំាងពួកតិរ្ថិយទាំងពួងដែលមកប្រជុំគ្នាឲ្យតាំងនៅក្នុងសីល៥ ។ កាលយ៉ាងនេះសាសនានេះមិនវឹកវរ សូន្យចាកពួកតិរ្ថិយ វិចិត្រដោយពួកព្រះអរហន្តជាបុគ្គលស្ទាត់ជំនាញ ប្រកបដោយតាទិគុណ ។ ព្រះមហាមុនីនោះ មានកំពស់៥៨ហត្ថ ប្រាកដស្មើដោយគ្រឿងបូជាជាវិការៈនៃមាស មានលក្ខណៈដ៏ប្រសើរ៣២ប្រការ ។

វស្សសតសហស្សានិ អាយុ វិជ្ជតិ តាវទេ
តាវតា តិដ្ឋមានោ សោ តារេសិ ជនតំ ពហុំ ។
តទាហំ ហំសវតិយា ព្រាហ្មណោ មន្តបារគូ
ឧបេច្ច តំ នរវរំ អស្សោសិំ ធម្មទេសនំ ។
បញ្ញាបេត្វា មហាវីរំ បរិសាសុ វិសារទំ
បដិការេណយ្យតំ ភិក្ខុំ ឯតទគ្គេ វិនយេ តំ ។
តទាហំ ការំ កត្វាន សសង្ឃេ លោកនាយកេ
និបច្ច សិរសា បាទេ តដ្ឋានំ អភិបត្ថយិំ ។
តតោ មំ ភគវា អាហ សិង្គីនិក្ខសមប្បភោ
សរេន រជនីយេន កិលេសមលហារិនា ។
សុខី ភវស្សុ ទីឃាយុ សិជ្ឈតុ(១) បណិធី តវ
សសង្ឃេ មេ កតំ ការំ អតីវ វិបុលំ តយា ។

---
១ ម. សមិជ្ឈតុ ។





មានព្រះជិនមួយអង្គ កាលព្រះអង្គគង់ព្រះជន្មនៅឡើយ ស្ដេចញ៉ាំងប្រជុំជនច្រើនឲ្យឆ្លង (ពាក់លោក) ។ គ្រានោះ ខ្ញុំកើតជាព្រាហ្មណ៍ នៅក្រុងហង្សវតី ជាអ្នកដល់ត្រើយនៃមន្ត បានចូលទៅគាល់ព្រះអង្គជានរៈដ៏ប្រសើរ ហើយស្ដាប់ធម៌ទេសនា ។ ខ្ញុំបានឃើញនូវព្រះនាយក មានព្យាយាមធំ កំពុងតាំងភិក្ខុអ្នកមានប្រាជ្ញាក្លៀវក្លា ក្នុងទីជាឯតទគ្គៈ ក្នុងកណ្ដាលបរិស័ទ ។ គ្រានោះ ខ្ញុំធ្វើសក្ការៈចំពោះព្រះលោក-នាយក ព្រមទាំងព្រះភិក្ខុសង្ឃ ហើយក្រាបថ្វាយបង្គំព្រះបាទាដោយសិរ្បៈ ប្រាថ្នានូវតំណែងនោះ ។ លំដាប់នោះ ព្រះមានព្រះភាគ ព្រះអង្គមានរស្មីដូចជាមាសត្រា ទ្រង់ត្រាស់នឹងខ្ញុំ ដោយព្រះសូរសៀងគួរត្រេកអរ អាចកំចាត់បង់នូវកិលេសជាមន្ទិល ដូច្នេះថា

អ្នកចូរបានសេចក្ដីសុខ មានអាយុវែង សេចក្ដីប្រាថ្នាចូរសម្រេចដល់អ្នក ព្រោះគ្រឿងសក្ការៈ អ្នកបានធ្វើដល់តថាគត ព្រមទាំងព្រះសង្ឃ ហៅពេញជាអធិកមហិមា ។

សតសហស្សេ ឥតោ កប្បេ ឱក្កាកកុលសម្ភវោ
គោតមោ នាម នាមេន សត្ថា លោកេ ភវិស្សតិ ។
តស្ស ធម្មេសុ ទាយាទោ ឱរសោ ធម្មនិម្មិតោ
កណោតិ នាមធេយ្យេន ហេស្សតិ សត្ថុ សាវកោ(១) ។
បដិភាណេយ្យកានគ្គំ បញ្ញាបេស្សតិ នាយកោ
តំ សុត្វា មុទិតោ ហុត្វា យាវជីវំ តទា ជិនំ ។
មេត្តចិត្តោ បរិចរឹ យតោ(២) បញ្ញាសមាហិតោ
តេន កម្មេន សុកតេន ចេតនាបណិធីហិ ច ។
ជហិត្វា មានុសំ ទេហំ តាវតឹសំ អគញ្ឆហំ
សតានំ តីណិក្ខត្តុញ្ច ទេវរជ្ជមការយឹ ។

---

១ ឱម. ឥតោ បរំ សកេ ហេតុ គុណេ គុត្តិ បរិបុណ្ណា ឧភយគាថា ទិស្សន្តិ ។
២ ឱម. សតោ ។





ក្នុងកប្បទីមួយសែន អំពីកប្បនេះ មានមហាបុរស សម្តេចក្នុងត្រកូលស្តេចឧក្កាកៈ នឹងបានជាសាស្តា ព្រះនាមគោតម ត្រាស់ឡើងក្នុងលោក ។ បុរសនេះនឹងបានជាទាយាទ ដែលព្រះធម៌និម្មិត ជាអ្នកទទួលនូវមត៌ក ក្នុងធម៌របស់ព្រះគោតមនោះ ជាសាវ័ករបស់ព្រះសាស្តា មានឈ្មោះថា កណៈ ។ ព្រះនាយក នឹងតាំងបុរសនេះ ជាបុគ្គលប្រសើរ ជាងសាវ័កអ្នកមានប្រាជ្ញាទាំងឡាយ ។

គ្រានោះ ខ្ញុំឮព្រះពុទ្ធដីកានោះហើយ ក៏ត្រេកអរ មានចិត្តប្រកបដោយមេត្តា មានប្រាជ្ញាខ្ជាប់ខ្ជួន បានបម្រើព្រះជិនស្រី ដរាបដល់អស់ជីវិត ។ ដោយអំពើដែលខ្ញុំធ្វើដោយល្អនោះផង ដោយការតាំងទុកនូវសេចក្តីប្រាថ្នានោះផង ខ្ញុំលះបង់កាយរបស់មនុស្សហើយ ក៏បានទៅកើតក្នុងឋានតាវត្តិង្ស បានសោយរាជ្យជាស្តេចទេវតា អស់ ៣០០ ដង ។

សតានិ បញ្ចក្ខត្តុញ្ច ចក្កវត្តិ អហោសហំ
បទេសរជ្ជំ វិបុលំ គណនាតោ អសង្ខិយំ ។
សព្វត្ថ សុខិតោ អាសឹ តស្ស កម្មស្ស វាហសា
បច្ឆិមេ ភវសម្បត្តេ គិរិព្ពជបុរុត្តមេ ។
ជាតោ វិប្បកុលេ និទ្ធេ វិកលច្ឆាទនភោជនេ
កដច្ឆុភិក្ខំ អទាសឹ សារីបុត្តស្ស តាទិនោ ។
យទា ជិណ្ណោ ច វុឌ្ឍោ ច តទារាមមុបាគមឹ
បព្វាជេន្តិ ន មំ កោចិ[១] ជិណ្ណំ ទុព្វលថាមកំ ។
តេន ទីនោ វិវណ្ណង្គោ[២] សោកោ ចាសឹ តទា អហំ
ទិស្វា មហាការុណិកោ មមមាហ មហាមុនិ ។

---

១ ម. បព្វជេតិ ន មំ កោចិ ។ ២ ឱ. ទិណ្ណោ វិវណ្ណង្គោ ។ ម. ទីនោ វិវណ្ណកោ ។



បានជាស្តេចចក្រពត្តិ អស់ ៥០០ ដង បានសោយប្រទេស-រាជ្យដ៏ទូលាយ រាប់ជាគិតមិនអស់ ។ ខ្ញុំជាអ្នកបានសេចក្តីសុខក្នុងទីទាំងពួង ដោយការសន្សំនៃកម្មនោះ លុះដល់បច្ឆិមភព ខ្ញុំកើតក្នុងត្រកូលព្រាហ្មណ៍ ទ័លក្រ ខ្វះខាតគ្រឿងស្លៀកពាក់និងគ្រឿងបរិភោគ នៅក្នុងក្រុងគិរិព្វជៈ ជាក្រុងខ្ពង់ខ្ពស់ បានប្រគេនបង្អែមមួយវែក ដល់ព្រះសារីបុត្ត ជាតាទិបុគ្គល ។ កាលដែលខ្ញុំមានវ័យចាស់ចម្រើនឡើង បានចូលទៅកាន់អារាម ក្នុងកាលនោះ ឥតមានភិក្ខុណាបានបំបួសខ្ញុំ ដែលចាស់គ្រាំគ្រា មានកម្លាំងថមថយទេ ។ ព្រោះហេតុនោះ បានជាខ្ញុំកើតទុក្ខ មានសម្បុរខ្លួនអាប់អន់ មានសេចក្តីសោកកាលនោះ ព្រះមហាមុនី មានសេចក្តីករុណាធំ លុះឃើញហើយត្រាស់សួរខ្ញុំថា

តិមន្តំ បុត្ត សោកាវេត្ថា ព្រូហិ មេ ចិត្តជំ រុជំ
បព្វជ្ជំ ន លភេ ហំ ស្វាក្ខាតេ តវ សាសនេ ។
តេន សោកេន ឈាយាម្ហិ តាណំ ហោហិ នាយក
តតោ ភិក្ខូ សមានេត្វា អបុច្ឆិ មុនិ សត្ថុនោ ។
ឥមស្ស អធិការីយេ(១) សរន្តា ព្យាហរន្តុ តេ
សារីបុត្តោ តទាវោច ការមស្ស សរាមហំ ។
កដច្ឆុភិក្ខំ ទាបេសិ បិណ្ឌាយ ចរតោ មមំ
សាធុ សាធុ កតញ្ញូសិ សារីបុត្ត ឥមំ ទុវំ ។
បព្វាជេហិ(២) ឥទំ វុឌ្ឍំ ហេស្សតិ បូជនិយោ(៣) អយំ
តតោ អលត្ថ បព្វជ្ជំ កម្មវាចោបសម្បទំ ។

---

១ ម. អធិការំ ។ ២ ឱ. បព្វាជេសិ ។ ៣ ឱ ម. ហេស្សតិ ភាជនិយោ ។





ម្នាលកូន អ្នកត្រូវសេចក្ដីសោកគ្របសង្កត់ដូចម្ដេច ចូរប្រាប់សេចក្ដីឈឺចិត្តរបស់អ្នកមក ។ បពិត្រព្រះអង្គមានព្យាយាម ខ្ញុំព្រះអង្គមិនបានបព្វជ្ជា ក្នុងសាសនា ដែលព្រះអង្គសម្ដែងដោយល្អទេ ខ្ញុំព្រះអង្គកើតទុក្ខ ព្រោះសេចក្ដីស្ដាយនោះ បពិត្រព្រះនាយក សូមព្រះអង្គជាទីពឹងរបស់ខ្ញុំ ។ គ្រានោះ ព្រះមុនី ទី ៧ ប្រមូលភិក្ខុទាំងឡាយមកហើយត្រាស់សួរថា ពួកភិក្ខុណា នឹកឃើញគុណរបស់ព្រាហ្មណ៍នេះ ពួកភិក្ខុនោះ ចូរពោលមក ។ គ្រានោះ ព្រះសារីបុត្តបានពោលថា ខ្ញុំព្រះករុណានឹកឃើញគុណរបស់ព្រាហ្មណ៍នេះ ដ្បិតព្រាហ្មណ៍នេះ បានប្រើគេឲ្យប្រគេនចង្ហាន់មួយវែក ដល់ខ្ញុំព្រះអង្គ កាលត្រាច់ទៅបិណ្ឌបាត ។ ម្នាលសារីបុត្រ ប្រពៃហើយ ៗ អ្នកជាមនុស្សកតញ្ញូនឹងព្រាហ្មណ៍នេះ អ្នកចូរបំបួសព្រាហ្មណ៍ចាស់នេះចុះ ព្រោះព្រាហ្មណ៍នេះនឹងជាបុគ្គលគួរគេបូជា ។ លំដាប់នោះ ខ្ញុំក៏បានបព្វជ្ជា ព្រមទាំងឧបសម្បទាដោយកម្មវាចា ។

ឥមំ ភគ្គេរាបទានំ

៦ ធីរេនេវ កាលេន ធាតុលំ អាសវក្ខយំ
សត្ថារំ បុនចេ ភគ្គុំ សុណាមិ បុនចេ យតោ[1]
បដិភានេយ្យកាឌត្តំ ឥតោ មំ ឋបយិ ជិនោ ។
កិលេសា ឈាបិតា មយ្ហំ ភវា សព្វេ សមូហតា
នាគោវ ពន្ធនំ ឆេត្វា វិហរាមិ អនាសវោ ។
ស្វាគតំ វត មេ អាសិ មម ពុទ្ធស្ស សន្តិកេ
តិស្សោ វិជ្ជា អនុប្បត្តា កតំ ពុទ្ធស្ស សាសនំ ។
បដិសម្ភិទា ចតស្សោ វិមោក្ខាបិ ច អដ្ឋិមេ
ឆឡភិញ្ញា សច្ឆិកតា កតំ ពុទ្ធស្ស សាសនំ ។

ឥត្ថំ សុទំ អាយស្មា ភគោ ថេរោ ឥមា គាថា-
យោ អភាសិត្ថាតិ ។

ភគ្គុត្ថេរស្ស អបទានំ សមត្តំ ។

---

១ ម. សតោ ។



ភគ្គេរាបទាន ទី ៤

អស់កាលមិនយូរប៉ុន្មាន ខ្ញុំក៏បានដល់នូវធម៌ជាគ្រឿងអស់ទៅ
នៃអាសវៈ តាំងពីខ្ញុំមានចិត្តរីករាយ ស្តាប់ព្រះពុទ្ធដីការបស់
ព្រះមុនី ដោយគោរព ក្នុងកាលណា ព្រះជិនស្រី ក៏តាំង
ខ្ញុំថាជាអ្នកប្រសើរខាងប្រាជ្ញា ជាងពួកសាវ័កអ្នកមានប្រាជ្ញា
ក្នុងកាលនោះ ។ កិលេសទាំងឡាយ ខ្ញុំដុតបំផ្លាញហើយ
ភពទាំងពួង ខ្ញុំផ្តាច់ចោលហើយ ខ្ញុំជាអ្នកមិនមានអាសវៈ
ព្រោះបានកាត់ចំណង ដូចជាដំរីកាត់ផ្តាច់នូវទន្លីង ។ ឱ ! ខ្ញុំ
មកល្អហើយ ក្នុងសំណាក់ព្រះពុទ្ធរបស់ខ្ញុំ វិជ្ជា ៣ ខ្ញុំបាន
ដល់ហើយ សាសនា របស់ព្រះពុទ្ធ ខ្ញុំបានធ្វើហើយ ។
បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យ
ជាក់ច្បាស់ហើយ ទាំងសាសនា របស់ព្រះពុទ្ធ ខ្ញុំក៏បាន
ប្រតិបត្តិហើយ ។

បានឮថា ព្រះភគុត្ថេរ មានអាយុ បានសំដែងនូវគាថាទាំង
នេះ ដោយប្រការដូច្នេះ ។

ចប់ ភគ្គេរាបទាន ។

## ទសមំ មោឃរាជត្ថេរាបទានំ

[១៣០] បទុមុត្តរោ លោកវិទូ(១) សព្វលោកហិតោ មុនិ
ឥតោ សតសហស្សម្ហិ កប្បេ ឧប្បជ្ជិ ចក្ខុមា ។
ឱវាទកោ វិញ្ញាបកោ តារកោ សព្វបាណិនំ
ទេសនាកុសលោ ពុទ្ធោ តារេសិ ជនតំ ពហុំ ។
អនុកម្បកោ ការុណិកោ ហិតេសី សព្វបាណិនំ
សម្បត្តេ តិត្ថិយេ សព្វេ បញ្ចសីលេ បតិដ្ឋហិ ។
ឯវំ និរាកុលំ អាសិ សុញ្ញតំ តិត្ថិយេហិ ច
វិចិត្តំ អរហន្តេហិ វសីភូតេហិ តាទិភិ ។
រតនានដ្ឋបញ្ញាសំ ឧគ្គតោ សោ មហាមុនិ
កញ្ចនគ្ឃិយសង្កាសោ ពត្តឹសវរលក្ខណោ ។

---
១ ឱ.ម. បទុមុត្តរោ នាម ជិនោ ។



## មោឃរាជត្ថេរាបទាន ទី ១០

(១៣០) ព្រះមុនីព្រះនាមបទុមុត្តរៈ មានបញ្ញាចក្ខុ ទ្រង់ជ្រាបច្បាស់នូវលោក ទ្រង់ជាប្រយោជន៍ដល់សត្វលោកទាំងពួង ទ្រង់កើតឡើងក្នុងកប្បទីមួយសែន អំពីកប្បនេះ ។ ព្រះពុទ្ធទ្រង់ឈ្លាសក្នុងទេសនា ទ្រង់ប្រទានឱវាទ ញុំាងសត្វឲ្យត្រាស់ដឹង ចម្លងសត្វទាំងពួង ទ្រង់ញុំាងពួកជនច្រើនឲ្យឆ្លង (កាត់លោក) ទ្រង់មានសេចក្តីអនុគ្រោះ មានករុណា ស្វែងរកប្រយោជន៍ដល់សត្វទាំងពួង ទ្រង់ញុំាងពួកតិរ្ថិយទាំងពួង ដែលមកប្រជុំគ្នា ឲ្យតាំងនៅក្នុងសីល ៥ ។ កាលយ៉ាងនេះ សាសនានោះឯង មិនរំកិល សូន្យចាកពួកតិរ្ថិយ វិចិត្រដោយពួកព្រះអរហន្ត ជាអ្នកស្ទាត់ជំនាញ ប្រកបដោយតាទិគុណ ។ ព្រះមហាមុនីនោះ មានកំពស់ ៥៨ហត្ថ ប្រាកដស្មើដោយគ្រឿងបូជាជាវិការនៃមាស មានលក្ខណៈប្រសើរ ៣២ប្រការ ។

វេស្សភុស្ស ភគវតោ អាសុំ ឧបដ្ឋិតា តទា
តទា តិដ្ឋមានោ សោ តារេសិ ជនតំ ពហុំ ។
តទាហំ ហំសវតិយា កុលេ អញ្ញតរេ អហុំ
បរកម្មាយនេ យុត្តោ នត្ថិ មេ កិញ្ចិ សទ្ធនំ ។
បដិក្កមនសាលាយំ វសេន្តោ កតភូមិយំ
អគ្គិ ឧដ្ឋាលយី តត្ថ ឌយ្ហា កណ្ហា សិលាមហិ(១) ។
តទា បរិសតិ ជាតោ ចតុសច្ចំ បកាសតោ
សាវកំ សម្បកិត្តេសិ លូខចីវរធារកំ ។
តស្ស តម្ហិ គុណេ តុដ្ឋោ បដិបជ្ជ(២) តថាគតំ
លូខចីវរធារត្តំ បត្ថយឹ ឋានមុត្តមំ ។
តទា អហុច គតវា សាវកោ បទុមុត្តរេ
បស្សេតំ បុរិសកំ កុចេលំ តនុនេហកំ ។

១ ឱ. សិលាមហិ ។ ម. សិលាមយំ ។ ២ ឱ. បតិបជ្ជ ។ ម. បតិបជ្ជ ។



មានព្រះនាមវេស្សភូ [illegible] កាលព្រះអង្គទ្រង់គង់នៅហើយ
ទ្រង់ញុំាងពួកជនច្រើនឲ្យឆ្លង (ភពលោក) ។ កាលនោះ ខ្ញុំ
កើតក្នុងត្រកូលមួយ នៅក្នុងក្រុងហង្សវតី ជាអ្នកប្រកបការ-
ងារ របស់បុគ្គលដទៃ ខ្ញុំអត់មានគ្រឿងតិចតួចជាទ្រព្យរបស់ខ្លួន
ឡើយ ។ កាលខ្ញុំនៅក្នុងបដិក្កមនសាលា ដែលគេធ្វើជាថ្នាក់
ក៏អុជភ្លើង ក្នុងបដិក្កមនសាលានោះ ផែនដីដែលក្រាលដោយ
ថ្ម ត្រូវភ្លើងឆេះខ្លោចខ្មៅ ។ កាលនោះ ព្រះលោកនាថ កំពុង
ប្រកាសសច្ចៈ ៤ ក្នុងកណ្ដាលបរិស័ទ ទ្រង់សរសើរសាវ័ក
ដែលទ្រទ្រង់ចីវរសៅហ្មង ។ ខ្ញុំត្រេកអរក្នុងគុណ របស់សាវ័ក
នោះ បានប្រតិបត្តិព្រះតថាគត ហើយប្រាថ្នាតំណែងដ៏ខ្ពង់
ខ្ពស់ ជាកំពូលនៃការទ្រទ្រង់ចីវរសៅហ្មង ។ គ្រានោះ ព្រះប-
ទុមុត្តរៈ មានជោគ ស្ដេចទ្រង់ត្រាស់នឹងពួកសាវ័កថា អ្នកទាំង
ឡាយ ចូរមើលបុរសនុ៎ះ ដែលមានសំពត់ក្រខ្វក់ មានខ្លួនស្ដើងៗ

បីតិប្បសន្នវទនំ សក្កានេ សមប្បិតំ(១)
ឧបគន្ត្វា ហដ្ឋា អកាសិំ សាសនេ កិច្ចំ ។
ឯសោ បន្តិតំ តំ ហំ បិ សត្ថុសេនស្ស(២) ភិក្ខុនោ
លូខិតវិនាកិស្ស គស្ស វណ្ណកតាសយោ(៣) ។
តំ សុត្វា មុទិតោ ហុត្វា និបច្ច សិរសា ជិនំ
យាវជីវំ សុភំ កម្មំ ការេត្វា ជិនសាសនេ ។
តេន កម្មេន សុកតេន ចេតនាបណិធីហិ ច
ជហិត្វា មានុសំ ទេហំ តាវតឹសំ អគញ្ឆហំ(៤) ។
បដិក្កមនសាលាយំ ភូមិដាហកកម្មុនា(៥)
សតសហស្សំ(៦) និរយេ អឌយ្ហឹ វេទនាដ្ដិតោ ។
តេន កម្មាវសេសេន បញ្ច ជាតិសតានិហំ
មនុស្សេ កុលេជា ហុត្វា ជាតិយា លក្ខណង្កិតា ។

---

១ ម. សព្វាស្វេហសមប្បិតំ ។ ២ ម. បេស្ស សេនស្ស ។ ៣ ម. វណ្ណសិតាសយោ ។ ៤ ឱ.ម. តាវតឹសូបគា អហំ ។ ៥ ឱ. ភូមិដាហកកម្មុនា ។ ម. ភូមិទាយកកម្មុនា ។ ៦ ម. សម ហស្សំ ។



មានមុខស្រស់ថ្លាដោយបីតិ តាំងមានទ្រព្យប្រសើរលើសខ្ញុំផង តាមហើយ មានកេមង់រៀវរឿនឡើង កែកយ ឥតកំរែកដូចជាដុំឈើ ។ បុរសខ្ញុំ ព្រាជ្ញជូនតែណែនៃកិច្ចកមានសច្ចៈជារបស់ខ្លួន ទ្រទ្រង់ទូរវ៉ៃរសៅហ្មងនោះ មានអញ្ញស្រើយតាំងនៅ ក្នុងគុណនៃកិច្ចនោះ ។ លុះខ្ញុំស្លាប់ព្រះភាគម្រាស់នោះហើយ កំកើតសេចក្តីកែកយ ព្រោះទៀបព្រះជិនស្រីដោយសិរ្ស: ធ្វើទូរអំពើល្អ ក្នុងសាសនាព្រះជិនស្រី ដកបផល់អស់ដីកែ ។ ដោយអំពើដែលខ្ញុំធ្វើល្អនោះផង ដោយការតែកល់ទុកទូរសេចក្តីព្រាជ្ញានោះផង លុះខ្ញុំលះបង់កន្ទកាយជារបស់មនុស្សហើយ កំបានទៅកើត ក្នុងឋានតាវត្តិង្ស ។ ដោយអំពើដែលខ្ញុំបានដុតថ្នាក់ ក្នុងបដិក្កមនសាលា ខ្ញុំត្រូវរេចនាត្រួបសត្វ នេះនៅក្នុងនរក អស់មួយពាន់ឆ្នាំគត់ ។ ដោយសំណល់កម្មនោះ ខ្ញុំបានកើតក្នុងត្រកូលមនុស្ស មានលក្ខណៈគេស្គាល់បាន តាមលំដាប់ អស់៥០០ជាតិ ។

ទសមំ មោឃរាជត្ថេរាបទានំ

បញ្ច ជាតិសតានេវ | កុដ្ឋរោគសមប្បិតោ
មហាទុក្ខំ អនុភវី | តស្ស កម្មស្ស វាហសា ។
ឥមម្ហិ ភទ្ទកេ កប្បេ | ឧបរិដ្ឋំ(១) យសស្សិនំ
បិណ្ឌបាតេន តប្បេសិំ | បសន្នមានសោ អហំ ។
តេន កម្មវិសេសេន | ចេតនាបណិធីហិ ច
ជហិត្វា មានុសំ ទេហំ | តាវតិំសំ អគញ្ឆហំ ។
បច្ឆិមេ ភវសម្បត្តេ | អជាយឹ ខត្តិយេ កុលេ
បិតុនោ អច្ចយេនាហំ | មហារជ្ជសមប្បិតោ ។
កុដ្ឋរោគាភិភូតោហំ | រត្តិយំ ន សុខំ(២) លភេ
មោឃំ រជ្ជសុខំ យស្មា | មោឃោ ភោគោ តតោ អហំ ។
កាយស្ស ទោសំ ទិស្វាន | បព្វជឹ អនគារិយំ
ពាវរិស្ស ទិជស្ស | សិស្សត្តំ អជ្ឈុបាគមឹ ។

---

១ ម. ឧបដ្ឋិតំ ។ ២ ម. ន រត្តិយំ សុខំ ។ ម. ន រត្តិំ ន សុខំ ។



មោឃរាជត្ថេរាបទាន ទី ១០

ពេញព្រៀបដោយរោគឃ្លង់ គ្រប់ ៥០០ ជាតិ ដើររងទុក្ខធំ ដោយផលនៃកម្មនោះ ។ ក្នុងកប្បនេះ ខ្ញុំមានចិត្តជ្រះថ្លា បានញុំាងព្រះបច្ចេកពុទ្ធព្រះនាមឧបរិដ្ឋៈ មានយស ឲ្យឆ្អែតស្កប់ស្កល់ដោយចង្ហាន់បិណ្ឌបាត ។ ដោយកម្មវិសេសនោះផង ដោយការតាំងទុកនូវចេតនានោះផង លុះខ្ញុំលះបង់កាយរបស់មនុស្សហើយ ក៏បានទៅកើតក្នុងឋានតាវត្តិង្ស ។ លុះដល់បច្ឆិមភព ខ្ញុំបានកើតក្នុងត្រកូលក្សត្រ អំណើរតពីព្រះបិតាទៅ ខ្ញុំក៏បានឆ្អែតស្កប់ស្កល់ដោយរាជសម្បត្តិធំ ។ ខ្ញុំត្រូវរោគឃ្លង់គ្របសង្កត់ ឥតបានសុខក្នុងរាត្រីឡើយ សេចក្តីសុខក្នុងរាជសម្បត្តិ ជារបស់សោះសូន្យទទេ ព្រោះហេតុណា ព្រោះហេតុនោះ បានជាខ្ញុំមានឈ្មោះថាមោឃរាជ ។ ខ្ញុំឃើញទោសរបស់កាយហើយ ក៏ចូលទៅកាន់ផ្នួស បានចូលទៅធ្វើជាសិស្សរបស់តាពាវរីព្រាហ្មណ៍ ដែលជាកំពូលព្រាហ្មណ៍ ។

មហេសា បរិវារេន ឧបេច្ច វរនាយកំ

អបុច្ឆិំ និបុណំ បញ្ហំ ភកិសំ វាទិសូទនំ ។

អយំ លោកោ បរោ លោកោ ព្រហ្មលោកោ សទេវកោ

ទិដ្ឋិំ តេ[1] នាភិជានាតិ គោតមស្ស យសស្សិនោ ។

ឯវំ អភិក្កន្តទស្សាវឹ អត្ថិ[2] បញ្ហេន អាគមឹ

កថំ លោកំ អវេក្ខន្តំ មច្ចុរាជា ន បស្សតិ ។

សុញ្ញតោ លោកំ អវេក្ខស្សុ មោឃរាជ សទា សតោ

អត្តានុទិដ្ឋិំ ឩហច្ច ឯវំ មច្ចុតរោ សិយា ។

ឯវំ លោកំ អវេក្ខន្តំ មច្ចុរាជា ន បស្សតិ

ឥតិ មំ អភណី ពុទ្ធោ សព្វកង្ខច្ឆិទោ ។

---

១ ឱ. ទិដ្ឋិ តោ ។ ម. ទិដ្ឋី តេ ។ ២ ឱ.ម. អត្ថិ ។



ខ្ញុំមានបរិវារច្រើន ចូលទៅគាល់ព្រះពុទ្ធ ជានាយកដ៏ប្រសើរ ហើយសួរនូវប្រស្នាដ៏ល្អិតល្អន់ ជាប្រស្នានៃបុគ្គលមានថ្វីមាត់ ជាទីហូមកនៃវាទៈថា លោកនេះ បរលោក ព្រហ្មលោក ព្រមទាំងទេវលោក ( មានដែបប្តូវ ) ខ្ញុំព្រះអង្គមិនដឹងទិដ្ឋិ របស់ព្រះអង្គ ជាគោតម ដ៏មានយសទេ ។ ដែលខ្ញុំព្រះអង្គមកនេះ ដើម្បីសួរប្រស្នា ចំពោះព្រះអង្គ ទ្រង់ឃើញវិសេសយ៉ាងនេះ ចុះមច្ចុរាជ មិនឃើញបុគ្គលដែលពិចារណាឃើញច្បាស់នូវលោក តើយ៉ាងណា ។ ព្រះពុទ្ធទ្រង់ព្យាបាលកេតគ្រប់មុខ បានត្រាស់ឆ្លើយនឹងខ្ញុំវិញថា ម្នាលមោឃរាជ អ្នកចូរមានស្មារតីសព្វកាល ពិចារណានូវលោកថាសូន្យចុះ បុគ្គលដែលបានដក នូវអត្តានុទិដ្ឋិចេញហើយ រមែងឆ្លងផុតមច្ចុរាជបាន ។ មច្ចុរាជ រមែងមិនឃើញនូវបុគ្គល អ្នកពិចារណាឃើញច្បាស់នូវលោក យ៉ាងនេះ ។

សហេ តាជាវសានេន · កេសមស្សុវិវជ្ជិតោ
កាសាវវត្ថវសនោ · អភសិ ភិក្ខុ តទាហំ(១) ។
សង្ឃំគេស្សុ វិហារេសុ · ច វសឹ ភេកបិញ្ជិតោ
អា វិហារេ បទុស្សិតំ · ភយាភិសុបិញ្ជិតោ(២) ។
សង្ការកូដា អាហេត្វា(៣) · សុសានា រថិកាហិ ច
តតោ សង្ឃាដឹ កត្វាន · ធារយឹ លូខចីវរំ ។
មហាភិសក្កោ តស្ស មេ · គុណេ តុដ្ឋោ វិនាយកោ
លូខចីវរធារីនំ · ឯតទគ្គេ ឋបេសិ មំ ។
បុញ្ញាបាបបរិក្ខីណោ · សព្វភេតវិវជ្ជិតោ
សិខីវ អនុបាទានោ · និព្វាយិស្សមនាសវោ ។
កិលេសា ឈាបិតា មយ្ហំ · ភវា សព្វេ សមូហតា
នាគោវ ពន្ធនំ ឆេត្វា · វិហរាមិ អនាសវោ ។
ស្វាគតំ វត មេ អាសិ · មម ពុទ្ធស្ស សន្តិកេ
តិស្សោ វិជ្ជា អនុប្បត្តា · កតំ ពុទ្ធស្ស សាសនំ ។

១ ម. តទាហុតោ ។ ២ ម. ភិក្ខុភោគីសុបិញ្ញិតោ ។ ៣ ម. អាហិត្វា ។



គ្រាន់តែចប់គាថា ខ្ញុំវៀរស្រឡះចាកសក់និងពុកមាត់ ស្លៀកសំពត់កាសាវៈ បានក្លាយទៅជាឯហិភិក្ខុភ្លាម ។ ខ្ញុំត្រូវរោគបៀតបៀនហើយ មិនហ៊ានទៅក្នុងវិហាររបស់សង្ឃ ក្រែងគេរករឿងដោយសំដីថា អ្នកកុំប្រទូស្តវិហារ ។ លំដាប់នោះ ខ្ញុំបាននាំយកសំពត់ អំពីគំនរសំរាមខ្លះ ព្រៃស្មសានខ្លះ ច្រកខ្លះ មកធ្វើជាសង្ឃាដី ហើយប្រើប្រាស់តែចីវរសៅហ្មង ។ ព្រះពុទ្ធ ជាមហាពេទ្យ ដឹកនាំសត្វ ទ្រង់ត្រេកអរក្នុងគុណរបស់ខ្ញុំនោះហើយ ក៏តាំងខ្ញុំក្នុងទីជាឯតទគ្គៈ ជាងពួកភិក្ខុទ្រទ្រង់នូវចីវរសៅហ្មង ។ ខ្ញុំជាបុគ្គលអស់បុណ្យនិងបាប វៀរស្រឡះចាកហេតុគ្រប់យ៉ាង ឥតមានអាសវៈ ដូចជាភ្លើងឥតកំញម នឹងបរិនិព្វាន ។ កិលេសទាំងឡាយ ខ្ញុំដុតបំផ្លាញហើយ ភពទាំងពួង ខ្ញុំដកចោលហើយ ខ្ញុំជាអ្នកមិនមានអាសវៈ ព្រោះបានកាត់ចំណង ដូចជាដំរីកាត់ផ្តាច់នូវចំណង ។ ។ ខ្ញុំមកល្អហើយ ក្នុងសំណាក់ព្រះពុទ្ធរបស់ខ្ញុំ វិជ្ជា ៣ ខ្ញុំបានដល់ហើយ សាសនារបស់ព្រះពុទ្ធ ខ្ញុំបានធ្វើហើយ ។

បដិសម្ភិទា ចតស្សោ វិមោក្ខាបិ ច អដ្ឋិមេ

ឆឡភិញ្ញា សច្ឆិកតា កតំ ពុទ្ធស្ស សាសនន្តិ ។

ឥត្ថំ សុទំ អាយស្មា មោឃរាជា ថេរោ ឥមា

គាថាយោ អភាសិត្ថាតិ ។

មោឃរាជត្ថេរស្ស អបទានំ សមត្តំ ។

ឧទ្ទានំ

កច្ចានោ វក្កលី ថេរោ មហាកប្បិនសវ្ហយោ

ទព្វោ កុមារនាមោ ច ពាហិយោ កោដ្ឋិកោ វសី ។

ឧរុវេលកស្សបោ រាធោ មោឃរាជា ច បណ្ឌិតោ

តីណិ គាថាសតានេត្ថ ទ្វាសដ្ឋិ ចេវ បិណ្ឌិតា ។

កច្ចាយនវគ្គោ ចតុបញ្ញាសោ ។

---



បដិសម្ភិទា ៤ វិមោក្ខ ៨ អភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យ

ជាក់ច្បាស់ហើយ ទាំងសាសនា របស់ព្រះពុទ្ធ ខ្ញុំបាន

ប្រតិបត្តិហើយ ។

បានឮថា ព្រះមោឃរាជត្ថេរ មានអាយុ បានសម្តែងនូវគាថា

ទាំងនេះ ដោយប្រការដូច្នេះ ។

ចប់ មោឃរាជត្ថេរាបទាន ។

ឧទ្ទាន

មហាកច្ចាយនត្ថេរាបទាន ១ វក្កលិត្ថេរាបទាន ១ មហាកប្បិ-

នត្ថេរាបទាន ១ ទព្វមល្លបុត្តត្ថេរាបទាន ១ កុមារកស្សបត្ថេ-

រាបទាន ១ ពាហិយត្ថេរាបទាន ១ មហាកោដ្ឋិតត្ថេរាបទាន ១

ឧរុវេលកស្សបត្ថេរាបទាន ១ រាធត្ថេរាបទាន ១ មោឃរាជ-

បណ្ឌិតត្ថេរាបទាន ១ មានគាថា ៣៦២ ដែលព្រះសង្គីតិ-

កាចារ្យ បានប្រមូលទុកហើយ ។

ចប់ កច្ចាយនវគ្គ ទី ៥៤ ។

## បញ្ចបញ្ញាសោ ភទ្ទិយវគ្គោ

### បឋមំ លកុណ្ដកភទ្ទិយត្ថេរាបទានំ

(១៣១) បទុមុត្តរោ នាម ជិនោ សព្វធម្មាន បារគូ(១)

ឥតោ សតសហស្សម្ហិ លោកេ(២) ឧប្បជ្ជិ នាយកោ ។

នគរំ ហំសវតិយា សេដ្ឋិបុត្តោ មហទ្ធនោ

ជង្ឃាវិហារំ វិចរំ សង្ឃារាមំ អគច្ឆហំ ។

តទា សោ លោកបជ្ជោតោ ធម្មំ ទេសេសិ នាយកោ

មញ្ជុស្សរកំ(៣) បវរំ សាវកំ អភិកិត្តយិ ។

តំ សុត្វា មុទិតោ ហុត្វា ការំ កត្វា មហេសិនោ

វន្ទិត្វា សត្ថុនោ បាទេ តំ ឋានំ អភិបត្ថយិំ ។

---

១. ម. សព្វធម្មេសុ ចក្ខុមា ។ ២ ម. កប្បេ ។ ៣ ម មញ្ជុស្សរានំ ។

## ភទ្ទិយវគ្គ ទី ៥៥

### លកុណ្ឌកភទ្ទិយត្ថេរាបទាន ទី ១

(១៣១) ព្រះជិនស្រី ព្រះនាមបទុមុត្តរៈ ទ្រង់ដល់នូវត្រើយនៃធម៌ទាំងពួង ព្រះអង្គជានាយក ទ្រង់កើតឡើងក្នុងលោក ក្នុងកប្បជាមួយសែន អំពីកប្បនេះ ។ កាលនោះ ខ្ញុំកើតជាសេដ្ឋីបុត្រ ក្នុងនគរហង្សវតី ជាអ្នកមានទ្រព្យច្រើន បានដើរទៅកាន់ទីសង្ឃារាម ក៏ធៀនចូលទៅកាន់អារាមរបស់សង្ឃ ។ គ្រានោះ ព្រះអង្គជាប្រទីបនៃលោក ជានាយក ក៏ទ្រង់សម្ដែងធម៌ ទ្រង់សរសើរសាវ័កដ៏ប្រសើរដែលមានសំឡេងពីរោះ ជាធំពួកសាវ័ក ដែលមានសំឡេងពីរោះទាំងឡាយ ។ ខ្ញុំឮព្រះពុទ្ធដីកានោះហើយ ក៏ត្រេកអរ បានធ្វើគ្រឿងសក្ការៈ ចំពោះព្រះមហេសី ហើយថ្វាយបង្គំបាទនៃព្រះសាស្ដា រួចប្រាថ្នានូវតំណែងនោះ ។

តទា តុដ្ឋោ វិយាកាសិ សង្ឃមជ្ឈេ វិនាយកោ
អនាគតម្ហិ អទ្ធានេ លច្ឆសេតំ មនោរថំ ។
សតសហស្សេ ឥតោ កប្បេ ឱក្កាកកុលសម្ភវោ
គោតមោ នាម នាមេន សត្ថា លោកេ ភវិស្សតិ ។
តស្ស ធម្មេសុ ទាយាទោ ឱរសោ ធម្មនិម្មិតោ
កង្ខិយោ នាម នាមេន ហេស្សតិ សត្ថុសាវកោ ។
តេន កម្មេន សុកតេន ចេតនាបណិធីហិ ច
ជហិត្វា មានុសំ ទេហំ តាវតឹសំ អគញ្ឆហំ ។
ទ្វេនវុតេ ឥតោ កប្បេ ផុស្សោ ឧប្បជ្ជិ នាយកោ
ទុរាសទោ ទុប្បសហោ សព្វលោកុត្តមោ ជិនោ ។



គ្រានោះ ព្រះពុទ្ធជានាយក ទ្រង់ព្យាករក្នុងកណ្ដាលជំនុំសង្ឃថា អ្នកនឹងបាននូវតំណែងនុ៎ះ ដូចចិត្តប៉ុនប៉ង ក្នុងកាលអនាគត ។ ក្នុងកប្បទីមួយសែន អំពីកប្បនេះ មានមហាបុរស សម្ភពក្នុងត្រកូលស្តេចឱក្កាកៈ នឹងបានជាសាស្តាព្រះនាមគោតម ត្រាស់ក្នុងលោក ។ សេដ្ឋិបុត្រនេះ នឹងបានជាឱរសដែលព្រះធម៌និម្មិត ជាអ្នកទទួលមត៌ក ក្នុងធម៌របស់ព្រះគោតម ជាសាវ័កនៃព្រះសាស្ដា មាននាមថាកង្ខិយៈ ។

ដោយអំពើដែលខ្ញុំធ្វើល្អនោះផង ដោយការតំកល់ទុកនូវចេតនានោះផង លុះខ្ញុំលះបង់នូវកាយរបស់មនុស្សហើយ ក៏បានទៅកើតក្នុងឋានតាវត្តិង្ស ។ ព្រះជិនស្រី ព្រះនាមផុស្សៈ ជានាយក ដែលគេចូលទៅគាល់បានដោយក្រ គេគ្របសង្កត់បានដោយក្រ ព្រះអង្គខ្ពង់ខ្ពស់ ជាងលោកទាំងពួង ទ្រង់កើតឡើង ក្នុងកប្បទី ៩២ អំពីកប្បនេះ ។

បឋមំ លកុណ្ឌកភទ្ទិយត្ថេរាបទានំ

ចរណេន ច សម្បន្នោ ព្រហ្មា(១) ឧជុ បតាបវា
ហិតេសី សព្វសត្តានំ ពាហុំ មោចេសិ ចក្ខុមា ។
ឧត្តរាបថេ(២) តស្ស អហោសិំ ផុស្សកោកិលោ(៣)
គន្ធកុដិសមាសន្នេ អម្ពរុក្ខេ វសាមហំ ។
តទា បិណ្ឌាយ គច្ឆន្តំ ទក្ខិណេយ្យំ ជិនុត្តមំ
ទិស្វា ចិត្តំ បសាទេត្វា មញ្ជុនា អភិកូជហំ ។
រាជុយ្យានំ តទា គត្វា សុបក្កំ កាឡកាត្តំ
អម្ពបិណ្ឌំ គហេត្វាន សម្ពុទ្ធស្សោបនាមយិំ ។
តទា មេ ចិត្តមញ្ញាយ មហាការុណិកោ ជិនោ
ឧបដ្ឋាកស្ស ហត្ថតោ បត្តំ បគ្គណ្ហិ នាយកោ ។

---

១ ឱ. ព្រហ្មា ។ ២ ម. ឧត្តរាបថេ ។ ៣ ឱ. ម. ផុស្សកោកិលោ ។



លកុណ្ឌកភទ្ទិយត្ថេរាបទាន ទី ១

ទ្រង់បរិបូណ៌ដោយចរណៈ ជាបុគ្គលប្រសើរ មានព្រះទ័យត្រង់ មានតេជះ ស្វែងរកប្រយោជន៍ដល់សព្វសត្វ ទ្រង់ញ៉ាំងសត្វជាច្រើនឲ្យរួចចាកចំណង ។ ខ្ញុំកើតជាសត្វតាវ៉ៅ នៅលើដើមស្វាយក្បែរគន្ធកុដិ ក្នុងអារាម របស់ព្រះសាស្តានោះ ។ គ្រានោះ ខ្ញុំបានឃើញព្រះជិនស្រី ជាទក្ខិណេយ្យ-បុគ្គលដ៏ខ្ពង់ខ្ពស់ ស្តេចកំពុងទៅបិណ្ឌបាត ហើយញ៉ាំងចិត្តឲ្យជ្រះថ្លា ក៏ស្រែករងំ ដោយសំឡេងដ៏ពីរោះ ។ ខ្ញុំបានហើរទៅកាន់ឧទ្យានស្តេច ហើយពាំយកផ្លែស្វាយទុំ មានសម្បុរនៃសម្បកដូចមាស បង្អោនទៅជិតព្រះសម្ពុទ្ធ ។ ព្រះជិនស្រី ទ្រង់ប្រកបដោយមហាករុណា ជានាយក ទ្រង់ជ្រាបច្បាស់នូវចិត្តរបស់ខ្ញុំហើយ ក៏យកបាត្រអំពីដៃភិក្ខុ ជាឧប-ដ្ឋាក (ហើយបង្អោនបាត្រទៅរកខ្ញុំជាសត្វតាវ៉ៅនោះ) ។

អនាសី(១) ហដ្ឋចិត្តោហំ   អម្ពបិណ្ឌំ មហាមុនេ
បត្តេ បក្ខិប្ប បក្ខេហិ   បញ្ជលី កត្វាន មញ្ជុនា ។
សរេន រជនីយេន   សវនីយេន មញ្ជុនា(២)
វិស្សដ្ឋោ ពុទ្ធបូជត្ថំ   និឌ្ឌំ គន្ត្វា និបជ្ជហំ ។
តទា មុទិតចិត្តំ មំ   ពុទ្ធបេមគតាសយំ
សកុណគ្ឃិ ឧបាគន្ត្វា   ឃាតយិ ទុដ្ឋមានសោ ។
តតោ ចុតាហំ តុសិតេ   អនុភោត្វា មហាសុខំ
មនុស្សយោនិមាគញ្ឆិំ   តស្ស កម្មស្ស វាហសា ។
ឥមម្ហិ ភទ្ទកេ កប្បេ   ព្រហ្មពន្ធុ មហាយសោ
កស្សបោ នាម គោត្តេន   ឧប្បជ្ជិ វទតំ វរោ ។
សាសនំ ជោតយិត្វា សោ   អភិភុយ្យ កុតិត្ថិយេ
វិនយិត្វាន វេនេយ្យេ   និព្វុតោ សោ សសាវកោ ។

១ ម. ទក្ខុំ ។ ២ ម. និស្សា ។



ខ្ញុំមានចិត្តរីករាយ បានដាក់ផ្លែស្វាយក្នុងបាត្រ ថ្វាយព្រះមហាមុនី រួចធ្វើអញ្ជលីដោយស្លាបទាំងពីរ ស្រែកដោយសំឡេងដ៏ពីរោះ កាលស្រែកដោយសំឡេង គួរត្រេកអរ គួរស្តាប់ ដ៏ទន់ពីរោះ ដើម្បីពុទ្ធបូជាហើយ ក៏ហើរទៅកាន់ទ្រនំ ហើយដេកលក់ ។ គ្រានោះ សត្វខ្លែង ជាសត្វចិត្តអាក្រក់ ហើរមកឆាបយកខ្ញុំ ដែលកំពុងមានចិត្តរីករាយ មានអធ្យាស្រ័យស្រឡាញ់ចំពោះព្រះពុទ្ធ ។ ខ្ញុំច្យុតចាកអត្តភាពនោះ ក៏បានទទួលមហាសុខ ក្នុងឋានតុសិត (លុះច្យុតចាកឋានតុសិត) ក៏បានមកកាន់កំណើតមនុស្ស ព្រោះអានិសង្សនៃកុសលកម្មនោះឯង ។ ក្នុងកប្បនេះ ព្រះពុទ្ធព្រះនាមកស្សបៈ ដោយគោត្រ មានផៅពង្សប្រសើរ មានយសធំ ព្រះអង្គប្រសើរជាងពួកអ្នកប្រាជ្ញ ស្តេចកើតឡើង ។ ព្រះអង្គបំភ្លឺសាសនា គ្របសង្កត់តិរ្ថិយអាក្រក់ ទ្រង់ទូន្មានពួកវេនេយ្យសត្វ រួចហើយព្រះអង្គព្រមទាំងពួកសាវ័ក បរិនិព្វានទៅ ។

និព្វុតេ តម្ហិ លោកគ្គេ បសន្នា ជនតា ពហូ
បូជនត្ថាយ ពុទ្ធស្ស ថូបំ ករោន្តិ សត្ថុនោ ។
សត្តយោជនិកំ ថូបំ សត្តរតនភូសិតំ
ការេស្សាម មហេសិស្ស ឥច្ចេវំ មន្តយន្តិ តេ ។
កិកិនោ កាសិរាជស្ស តទា សេនាយ នាយកោ
ហុត្វាហំ អប្បមាណស្ស បមាណំ ចេតិយេ វទិំ ។
តទា តេ មម វាក្យេន ចេតិយំ យោជនុគ្គតំ
អកំសុ នរវីរស្ស នានារតនភូសិតំ ។
តេន កម្មេន សុកតេន ចេតនាបណិធីហិ ច
ជហិត្វា មានុសំ ទេហំ តាវត្តិំសំ អគច្ឆហំ ។
បច្ឆិមេ ច ភវេ ទានិ ជាតោ សេដ្ឋិកុលេ អហំ
សាវត្ថិយំ បុរវរេ ឥទ្ធេ ផីតេ មហទ្ធនេ ។





កាលព្រះអង្គ ជាបុគ្គលប្រសើរជាងសត្វលោក បរិនិព្វានហើយ ពួកជនច្រើនគ្នា កើតសេចក្តីជ្រះថ្លា នាំគ្នាធ្វើព្រះស្តូប ដើម្បីជាគ្រឿងបូជាចំពោះព្រះសាស្តា ។ ពួកជនទាំងនោះប្រឹក្សាគ្នាយ៉ាងនេះថា យើងទាំងឡាយ នឹងឲ្យពួកជាងធ្វើព្រះស្តូបកំពស់ ៧ យោជន៍ វិចិត្រស្អាតដោយកែវ ៧ ប្រការ ថ្វាយព្រះពុទ្ធជាមហេសី ។ កាលនោះ ខ្ញុំជានាយកនៃសេនារបស់ព្រះបាទកិកីនៃដែនកាសី បានបង្គាប់ឲ្យគេធ្វើចេតិយដែលត្រូវមានទំហំ ឲ្យមកជាតូចវិញ ។ គ្រានោះ ពួកជនទាំងនោះ ក៏នាំគ្នាធ្វើចេតិយតាមពាក្យខ្ញុំ កំពស់មួយយោជន៍ សឹងវិចិត្រស្អាតដោយកែវផ្សេងៗ ថ្វាយព្រះពុទ្ធ ជាអ្នកប្រាជ្ញប្រសើរជាងជន ។ ដោយអំពើដែលខ្ញុំធ្វើដោយល្អមានផង ដោយការតំកល់ទុកនូវចេតនានោះផង លុះខ្ញុំលះបង់កាយជារបស់មនុស្សហើយ បានទៅកើតក្នុងឋានតាវត្តិង្ស ។ ក្នុងបច្ឆិមភព ឥឡូវនេះ ខ្ញុំកើតក្នុងត្រកូលសេដ្ឋី ក្រុងសាវត្ថី ជាក្រុងដ៏ប្រសើរ ស្តុកស្តម្ភ ទូលាយ មានទ្រព្យច្រើន ។

កុរញ្ជិយវេស សុគតំ ទិស្វា វិម្ហិតមានសោ
បក្ខជិត្វាន ន តីរំ អវេហត្ថំ អបាបុណឹ ៗ
ចេតិយស្ស បមាណំ យំ អកាសឹ តេន កម្មុនា
លកុណ្ឌកសរីរោហំ ជាតោ បរិភវោហោ ៗ
សរេន មនុវេតាហំ បូជេត្វា ឥសិសត្តមំ
មញ្ជុស្សរេន ភិក្ខូនំ អគ្គត្តំ អនុបាបុណឹ ៗ
ផលទានេន ពុទ្ធស្ស គុណានុស្សរណេន ច
សាមញ្ញផលសម្បន្នោ វិហរាមិ អនាសវោ ៗ
កិលេសា ឈាបិតា មយ្ហំ ភវា សព្វេ សមូហតា
នាគោវ ពន្ធនំ ឆេត្វា វិហរាមិ អនាសវោ ៗ
ស្វាគតំ វត មេ អាសិ មម ពុទ្ធស្ស សន្តិកេ(១)
តិស្សោ វិជ្ជា អនុប្បត្តា កតំ ពុទ្ធស្ស សាសនំ ៗ

១ ម. ពុទ្ធសេដ្ឋស្ស សន្តិកេ ។



ខ្ញុំឃើញព្រះសុគត ក៏ក្ដីទូលទៅក្នុងបុរី ក៏មានចិត្តស្ញប់ស្ញែង បានចូលទៅបួស មិនយូរប៉ុន្មាន ខ្ញុំក៏បានសម្រេចព្រះអរហត្ត ។ ខ្ញុំបានធ្វើចេតិយឲ្យមានទំហំតូចណា ព្រោះអំពើនោះឯង បានជាខ្ញុំកើតមកមានសរីរៈតឿ គួរដល់ការមើលងាយ (នៃអ្នកដទៃ) ។ ខ្ញុំបានដល់នូវលាភជាបុគ្គលប្រសើរ (ខាងមានសំឡេងពីរោះ) ជាងពួកភិក្ខុដែលមានសំ-ឡេងពីរោះ ព្រោះបានបូជាព្រះពុទ្ធ ជាឥសីទី ៧ ដោយសំឡេងដ៏ពីរោះ ។ ខ្ញុំបានសម្រេចនូវសាមញ្ញផល ឥតមានអាសវៈ ព្រោះបានថ្វាយផ្លែស្វាយដល់ព្រះពុទ្ធ និងការនឹករលឹកគុណនៃព្រះពុទ្ធ ។ កិលេសទាំងឡាយ ខ្ញុំដុតបំផ្លាញហើយ ភពទាំងពួង ខ្ញុំដកចោលហើយ ខ្ញុំជាអ្នកមិនមានអា-សវៈ ព្រោះបានកាត់ចំណង ដូចជាដំរីកាត់ផ្ដាច់នូវទន្លីង ។ ឱ ! ខ្ញុំមកល្អហើយ ក្នុងសំណាក់ព្រះពុទ្ធរបស់ខ្ញុំ វិជ្ជា ៣ ខ្ញុំបានដល់ហើយ សាសនារបស់ព្រះពុទ្ធ ខ្ញុំបានធ្វើហើយ ។

បដិសម្ភិទា ចតស្សោ វិមោក្ខាបិ ច អដ្ឋិមេ
ឆឡភិញ្ញា សច្ឆិកតា កតំ ពុទ្ធស្ស សាសនន្តិ ។

ឥត្ថំ សុទំ អាយស្មា លកុណ្ឋកភទ្ទិយោ ថេរោ
ឥមា គាថាយោ អភាសិត្ថាតិ ។

លកុណ្ឋកភទ្ទិយត្ថេរស្ស អបទានំ សមត្តំ ។

## ទុតិយំ កង្ខារេវតត្ថេរាបទានំ

(១៣២) បទុមុត្តរោ នាម ជិនោ សព្វធម្មេសុ ចក្ខុមា
ឥតោ សតសហស្សម្ហិ កប្បេ ឧប្បជ្ជិ នាយកោ ។
សីហហនុ ព្រហ្មគិរោ ហំសទុន្ទុភិសារោ
នាគវិក្កន្តគមនោ ចន្ទសូរិយប្បភោ ។



បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនា របស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ។

បានឮថា ព្រះលកុណ្ឋកភទ្ទិយត្ថេរ មានអាយុ បានសម្តែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

ចប់ លកុណ្ឋកភទ្ទិយត្ថេរាបទាន ។

## កង្ខារេវតត្ថេរាបទាន ទី ២

[ ១៣២ ] ព្រះជិនស្រី ព្រះនាមបទុមុត្តរៈ ទ្រង់មានបញ្ញាចក្ខុក្នុងធម៌ទាំងពួង ព្រះអង្គជានាយក ទ្រង់កើតឡើងក្នុងកប្បទីមួយសែន អំពីកប្បនេះ ។ ព្រះសម្ពុទ្ធទ្រង់មានចង្កាដូចចង្កាសីហៈ មានព្រះសូរសេង ដូចសំឡេងព្រហ្ម មានសូរសព្ទដូចហង្សនិងស្គរ មានពុទ្ធដំណើរ ដូចដំរីដែលក្លៀវក្លា មានរស្មីដូចព្រះចន្ទ្រ និងព្រះអាទិត្យជាដើម ។

មហាយតិ មហាវីរោ មហាឈាយី មហាគតិ(១)
មហាការុណិកោ នាថោ មហាតមវិសោធនោ(២) ។
ស កទាចិ តិលោកគ្គោ វេនេយ្យំ វិនយំ ពហុំ
ធម្មំ ទេសេតិ សម្ពុទ្ធោ សត្តចិត្តវិទូ មុនិ ។
ឈាយី ឈានរតោ ធីរោ ឧបសន្តោ អនាវិលោ
វណ្ណយន្តោ បរិសតិ តោសេតិ ជនតំ ជិនោ ។
តទាហំ ហំសវតិយា ព្រាហ្មណោ វេទបារគូ
ធម្មំ សុត្វាន មុទិតោ តំ ឋានំ អភិបត្ថយិំ ។
តទា ជិនោ វិយាកាសិ សង្ឃមជ្ឈេ វិនាយកោ
មុទិតោ ហោហិ ត្វំ ព្រហ្មេ លច្ឆសេតំ មនោរថំ ។

---

១ ឱ. មហាហិតោ ។ ម. មហាគណោ ។ ២ ឱ. មហាតមនិស្សូទនោ ។ ម. មហាតមបនូ-ទនោ ។



មានប្រាជ្ញាច្រើន មានព្យាយាមធំ មានឈានធំ មានគតិធំ ប្រកបដោយមហាករុណា ជាទីពឹងនៃសត្វលោក ទ្រង់កំចាត់បង់នូវងងឹតធំ គឺមោហៈ ។ ព្រះអង្គជាកំពូលនៃត្រៃលោក ទ្រង់ជ្រាបច្បាស់នូវចិត្តសត្វ ជាអ្នកប្រាជ្ញ កាលទូន្មាននូវវេនេយ្យសត្វ ហើយទ្រង់សម្តែងធម៌ច្រើន ។ ព្រះជិនស្រី ទ្រង់សរសើរនូវបុគ្គលអ្នកមានឈាន ត្រេកអរក្នុងឈាន មានព្យាយាម មានចិត្តស្ងប់រម្ងាប់ មិនល្អក់ ទ្រង់ញ៉ាំងពួកជនឲ្យត្រេកអរ ក្នុងកណ្តាលបរិស័ទ ។ កាលនោះ ខ្ញុំជាព្រាហ្មណ៍ ដល់នូវត្រើយនៃវេទ នៅក្នុងក្រុងហង្សវតី លុះស្តាប់ធម៌ហើយ មានចិត្តរីករាយ ទើបប្រាថ្នានូវតំណែងនោះ ។

គ្រានោះ ព្រះជិនស្រី ជានាយក ទ្រង់ព្យាករ ក្នុងកណ្តាលនៃជំនុំសង្ឃថា ម្នាលព្រាហ្មណ៍ អ្នកចូរត្រេកអរចុះ អ្នកនឹងបាននូវតំណែងនុ៎ះ ដូចចិត្តប៉ុនប៉ងពុំខាន ។

ទុតិយំ កង្ខារេវតត្ថេរាបទានំ

សតសហស្សេ ឥតោ កប្បេ ឱក្កាកកុលសម្ភវោ
គោតមោ នាម នាមេន សត្ថា លោកេ ភវិស្សតិ ។
តស្ស ធម្មេសុ ទាយាទោ ឱរសោ ធម្មនិម្មិតោ
រេវតោ នាម នាមេន ហេស្សតិ សត្ថុសាវកោ ។
តេន កម្មេន សុកតេន ចេតនាបណិធីហិ ច
ជហិត្វា មានុសំ ទេហំ តាវតិំសំ អគច្ឆហំ ។
បច្ឆិមេ ច ភវេ ទានិ ជាតោហំ កោលិយេ បុរេ
ខត្តិយេ កុលសម្បន្នេ ឥទ្ធេ ផីតេ មហទ្ធនេ ។
យទា កបិលវត្ថុស្មិំ ពុទ្ធោ ធម្មំ អទេសយិ
តទា បសន្នោ សុគតេ បព្វជឹ អនគារិយំ ។
កង្ខា មេ ពហុលា(១) អាសិ កប្បាកប្បេ តហឹ តហឹ
តំ សព្វំ វិនយិ ពុទ្ធោ ទេសេត្វា ធម្មមុត្តមំ ។

១ ម. ពហុសោ ។



កង្ខារេវតត្ថេរាបទាន ទី ២

ក្នុងកប្បទីមួយសែន អំពីកប្បនេះ មានមហាបុរស កើត ក្នុងត្រកូលស្ដេចឱក្កាកៈ នឹងបានជាសាស្ដា ក្នុងលោក ព្រះនាមគោតម ។ ព្រាហ្មណ៍នេះ នឹងបានជាឱរសដែលព្រះធម៌និម្មិត ជាអ្នកទទួលមត៌ក ក្នុងធម៌របស់ព្រះគោតមនោះ ជាសាវករបស់ព្រះសាស្ដា មាននាមថា រេវតៈ ។

ដោយអំពើដែលខ្ញុំធ្វើល្អនោះផង ដោយការតំកល់ទុកចេ-តនានោះផង លុះខ្ញុំលះបង់កាយរបស់មនុស្សហើយ បានទៅកើតក្នុងឋានតាវត្តិង្ស ។ ក្នុងបច្ឆិមភព ឥឡូវនេះ ខ្ញុំកើតក្នុងត្រកូលក្សត្រ ជាត្រកូលសម្បូណ៌ ស្ដុកស្ដម្ភ ទូលាយ មានទ្រព្យច្រើន នៅក្នុងក្រុងកោលិយៈ ។ កាលណា ព្រះពុទ្ធទ្រង់សំដែងធម៌ ក្នុងក្រុងកបិលវត្ថុ កាលនោះ ខ្ញុំជ្រះថ្លាចំពោះព្រះសុគត ហើយចូលទៅកាន់ផ្នួស ។ ខ្ញុំមានសេចក្ដីសង្ស័យច្រើន ក្នុងហេតុគួរនិងមិនគួរនោះ ៗ ព្រះពុទ្ធសំដែងធម៌ដ៏ឧត្តម ក៏កាត់បង់នូវសេចក្ដីសង្ស័យទាំងអស់នោះបាន ។

តតោហំ តិណ្ណសំសារោ តទា ឈានសុខេ រតោ
វិហរាមិ តទា ពុទ្ធោ មំ ទិស្វា ឯតទព្រវិ ។
យា កាចិ កង្ខា ឥធ វា ហុរំ វា
សកវេទិយា វា បរវេទិយា វា
យេ ឈាយិនោ តា បជហន្តិ សព្វា
អាតាបិនោ ព្រហ្មចរិយំ ចរន្តា ។
សតសហស្សេ កតំ កម្មំ ផលំ ទស្សេសិ មេ ឥធ
សុមុត្តោ សរវេគោវ កិលេសេ ឈាបយឹ មម ។
តតោ មំ(១) ឈាននិរតំ ទិស្វា លោកន្តគូ មុនិ
ឈាយីនំ ភិក្ខូនំ អគ្គោ បញ្ញបេសិ មហាមតិ(២) ។
កិលេសា ឈាបិតា មយ្ហំ ភវា សព្វេ សមូហតា
នាគោវ ពន្ធនំ ឆេត្វា វិហរាមិ អនាសវោ ។

១ ម. មំ រតិ សន្តុដ្ឋិ ។ ២ ឱ. មហាមុនិ ។





ហេតុនោះ ខ្ញុំឈ្មោះថា ជាអ្នកមានសង្សារឆ្លងផុតហើយ ត្រេកអរចំពោះសេចក្តីសុខក្នុងឈាន ។ គ្រានោះ ព្រះពុទ្ធទ្រង់ឃើញខ្ញុំ ហើយទ្រង់ប្រកាសពាក្យនេះថា
សេចក្តីសង្ស័យណាមួយ ក្នុងលោកនេះ ឬក្នុងលោក
ខាងមុខ ពួកបុគ្គលមានឈាន មានព្យាយាម ជាអ្នក
ប្រព្រឹត្តព្រហ្មចរិយៈ តែងលះបង់នូវសេចក្តីសង្ស័យនោះ
បាន ដោយប្រាជ្ញានៃខ្លួន ឬដោយប្រាជ្ញានៃអ្នកដទៃ ។

អំពើដែលខ្ញុំបានធ្វើ ក្នុងកប្បទីមួយសែន គឺបង្ហាញផលដល់ខ្ញុំ ក្នុងជាតិនេះ ខ្ញុំបានដុតបំផ្លាញកិលេសទាំងឡាយហើយ ដូចសទ្ទុះសរដែលរបូតផុតចេញ (ពីធ្នូ) ។ ព្រះមុនី ទ្រង់ដល់នូវទីបំផុតនៃលោក មានប្រាជ្ញាច្រើនទ្រង់ឃើញខ្ញុំ ជាអ្នកត្រេកអរ ក្នុងឈានដូច្នោះ ក៏តាំងខ្ញុំជាអ្នកប្រសើរ ជាងពួកភិក្ខុអ្នកមានឈាន ។ កិលេសទាំងឡាយ ខ្ញុំដុតបំផ្លាញហើយ ភពទាំងពួង ខ្ញុំដកចោលហើយ ខ្ញុំជាអ្នកមិនមានអាសវៈ ព្រោះបានកាត់ចំណង ដូចដំរីកាត់ផ្តាច់នូវទន្លីង ។

ស្វាគតំ វត មេ អាសិ មម ពុទ្ធស្ស សន្តិកេ
តិស្សោ វិជ្ជា អនុប្បត្តា កតំ ពុទ្ធស្ស សាសនំ ។
បដិសម្ភិទា ចតស្សោ វិមោក្ខាបិ ច អដ្ឋិមេ
ឆឡភិញ្ញា សច្ឆិកតា កតំ ពុទ្ធស្ស សាសនន្តិ ។

ឥត្ថំ សុទំ អាយស្មា កង្ខារេវតោ ថេរោ ឥមា
គាថាយោ អភាសិត្ថាតិ ។

កង្ខារេវតត្ថេរស្ស អបទានំ សមត្តំ ។

## តតិយំ សីវលិត្ថេរាបទានំ

(១៣៣) បទុមុត្តរោ នាម ជិនោ សព្វធម្មេសុ ចក្ខុមា
ឥតោ សតសហស្សម្ហិ កប្បេ ឧប្បជ្ជិ នាយកោ ។
សីលន្តស្ស អសង្ខេយ្យំ សមាធិ វជិរូបមោ
អសង្ខេយ្យំ ញាណវរំ វិមុត្តិ ច អនោបមា ។



ឱ ! ខ្ញុំមកល្អហើយ ក្នុងសំណាក់ព្រះពុទ្ធរបស់ខ្ញុំ វិជ្ជា ៣ ខ្ញុំបានដល់ហើយ សាសនា របស់ព្រះពុទ្ធ ខ្ញុំបានធ្វើហើយ ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនា របស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ។

បានឮថា ព្រះកង្ខារេវតត្ថេរ មានអាយុ បានសំដែងនូវគាថា ទាំងនេះ ដោយប្រការដូច្នេះ ។

ចប់ កង្ខារេវតត្ថេរាបទាន ។

## សីវលិត្ថេរាបទាន ទី ៣

(១៣៣) ព្រះជិនស្រី ព្រះនាមបទុមុត្តរៈ មានបញ្ញាចក្ខុ ក្នុងធម៌ទាំងពួង ព្រះអង្គជានាយក ទ្រង់កើតឡើង ក្នុងកប្បទីមួយសែន អំពីកប្បនេះ ។ សីលរបស់ព្រះអង្គ រាប់មិនបាន សមាធិឧបមាដូចកែវវជិរ ញាណដ៏ប្រសើរ ក៏រាប់មិនអស់ ទាំងវិមុត្តិ ក៏រកអ្វីប្រៀបផ្ទឹមគ្មាន ។

មនុជាមរនាគានំ ព្រហ្មានញ្ច សទេវកេ
សមណព្រាហ្មណាកិណ្ណេ(១) ធម្មំ ទេសេសិ នាយកោ ។
សសាវកំ ពហុលាភំ បុញ្ញវន្តំ ជុតិន្ធរំ
ឋបេសិ ឯតទគ្គម្ហិ បរិសាសុ វិសារទោ ។
តទាហំ ខត្តិយោ អាសិំ នគរេ ហំសសវ្ហយេ
សុត្វា ជិនស្ស តំ វាក្យំ សាវកស្ស គុណំ ពហុំ ។
និមន្តយិត្វា សត្តាហំ ភោជយិត្វា សសាវកំ
មហាទានំ ទទិត្វាន តំ ឋានំ អភិបត្ថយិំ ។
តទា មំ វិនតំ បាទេ ទិស្វាន បុរិសាសភោ
សរេន មហតា ធីរោ(២) ឥមំ វចនមព្រវិ ។
តតោ ជិនស្ស វចនំ សោតុកាមា មហាជនា
ទេវតា អថ គន្ធព្វា(៣) ព្រហ្មានោ ច មហិទ្ធិកា ។

---

១ ម. សមណព្រាហ្មណាកិណ្ណេ ។ ២ ម. សុស្សរេន មហាវីរោ ។ ៣ ម. ទេវ-
ទានវ គន្ធព្វា ។



ព្រះនាយក ទ្រង់សម្តែងនូវធម៌ក្នុងទីប្រជុំ ដ៏កុះករ ដោយសមណៈនិងព្រាហ្មណ៍ ដល់ពួកមនុស្ស ទេវតា នាគ និងព្រហ្ម ។ ព្រះពុទ្ធទ្រង់ក្លៀវក្លា ក្នុងពួកបរិស័ទ ស្តេចតាំងសាវ័ករបស់ព្រះអង្គ ដែលជាអ្នកសម្បូណ៌លាភ មានបុណ្យ ទ្រទ្រង់នូវសេចក្តីរុងរឿង ក្នុងទីជាឯតទគ្គៈ ។ កាលនោះ ខ្ញុំកើតជាក្សត្រ ក្នុងនគរឈ្មោះហំសវៈ បានឮព្រះពុទ្ធដីកានៃព្រះជិនស្រីផង នូវគុណនៃសាវ័កច្រើនផង ។ ខ្ញុំបាននិមន្តព្រះសាស្តា ព្រមទាំងសាវ័កឲ្យឆាន់ចង្ហាន់ អស់ ៧ ថ្ងៃ លុះថ្វាយមហាទានរួចហើយ ទើបប្រាថ្នានូវតំណែងនោះ ។ គ្រានោះ ព្រះពុទ្ធជាបុរសប្រសើរ ជាអ្នកប្រាជ្ញ ទ្រង់ឃើញខ្ញុំក្រាបទៀបព្រះបាទ ក៏ទ្រង់ត្រាស់ពាក្យនេះ ដោយព្រះសូរសៀងដ៏ពីរោះ ។ លំដាប់នោះ ពួកមហាជន គឺពួកទេវតា គន្ធព្វ ពួកព្រហ្មមានឫទ្ធិច្រើន និងពួកសមណព្រាហ្មណ៍ មានប្រាថ្នាដើម្បីស្តាប់ នូវព្រះពុទ្ធដីកា នៃព្រះជិនស្រីហើយ

សមណាព្រាហ្មណា ចេវ ធម្មស្សវុ គារវាលី

នមោ តេ បុរិសាជញ្ញ នមោ តេ បុរិសុត្តម ។

ទត្តិយេន មហាទានំ និដ្ឋំ សត្តាហកាលិកំ[1]

សោតុកាមា ផលំ តស្ស ព្យាករោហិ មហាមុនេ ។

តតោ អវោច ភគវា សុណាថ មម ភាសិតំ

អប្បមេយ្យម្ហិ ពុទ្ធម្ហិ សសង្ឃម្ហិ បតិដ្ឋិតា ។

ទក្ខិណាទាយ កោវត្តា[2] អប្បមេយ្យផលា ហិ សា

អបិ ចេស មហាកោកោ ហាចំ បត្តិ ឧត្តមំ ។

---

១ ឱ. សត្តាហិកំ វិការ ។ ម. សត្តាហិកំ វិជា ។ ២ ឱ. ទោវត្តោ ។





ក៏នាំគ្នាធ្វើអញ្ជលីនមស្ការថា បពិត្រព្រះអង្គជាបុរសអាជា-នេយ្យ ខ្ញុំសូមនមស្ការ ចំពោះព្រះអង្គ បពិត្រព្រះអង្គជាបុរសឧត្តមខ្ពង់ខ្ពស់ ខ្ញុំសូមនមស្ការចំពោះព្រះអង្គ ។ បពិត្រព្រះមហាមុនី ខ្ញុំព្រះអង្គទាំងឡាយ ចង់ស្តាប់ផលានិសង្សនៃមហាទាន ដែលព្រះមហាក្សត្រទ្រង់បានថ្វាយ អស់ ៧ ថ្ងៃ សូមព្រះអង្គទ្រង់ព្យាករ នូវផលនៃមហាទាននោះ ។

លំដាប់នោះ ព្រះមានព្រះភាគ ទ្រង់ត្រាស់ថា អ្នកទាំងឡាយ ចូរចាំស្តាប់ភាសិតរបស់តថាគតដូចតទៅនេះចុះ ទក្ខិណា-ទាន ដែលព្រះមហាក្សត្រ បានតំកល់ទុកក្នុងព្រះពុទ្ធ ព្រមទាំងព្រះសង្ឃ ដែលជាអ្នកមានគុណសម្បត្តិ ប្រមាណមិនបាន ទក្ខិណាទាននោះ នឹងគេអ្នកណាពោលថា មានអា-និសង្សប៉ុណ្ណេះ ឬប៉ុណ្ណោះបានឡើយ ព្រោះទក្ខិណាទាននោះមានផលប្រមាណមិនបានទេ មួយទៀត ព្រះមហាក្សត្រដែលមានគេកោតុះប្រើនេះ ទ្រង់ជានូវតំណែងដ៏ខ្ពង់ខ្ពស់ថា

លាភី វិបុលលាភានំ យថា ភិក្ខុ សុទស្សនោ

តថាហម្បិ ភវេយ្យន្តិ បត្ថេសិំ អនាគតេ ។

សតសហស្សេ ឥតោ កប្បេ ឱក្កាកកុលសម្ភវោ

គោតមោ នាម នាមេន សត្ថា លោកេ ភវិស្សតិ ។

តស្ស ធម្មេសុ ទាយាទោ ឱរសោ ធម្មនិម្មិតោ

សីវលី នាម នាមេន ហេស្សតិ សត្ថុសាវកោ ។

តេន កម្មេន សុកតេន ចេតនាបណិធីហិ ច

ជហិត្វា មានុសំ ទេហំ តាវតិំសំ អគញ្ឆហិ[១] ។

ឯកនវុតេ ឥតោ កប្បេ វិបស្សី លោកនាយកោ

ឧប្បជ្ជិ ចារុនយនោ សព្វធម្មវិបស្សកោ ។

១ ឱ. ម. តាវតិំសុបគោ អហំ ។



សុទស្សនភិក្ខុ ជាអ្នកបានលាភដ៏ច្រើនយ៉ាងឆ្ងាយ យ៉ាងណា អាត្មាអញ សូមឲ្យបានទូលលាភ យ៉ាងនោះ ព្រះមហាក្សត្រនេះ នឹងបានទូលនូវលាភនេះ ក្នុងកាលអនាគតជាប្រាកដ ។ ក្នុងកប្បទីមួយសែន អំពីកប្បនេះ មានមហាបុរសសម្ភពក្នុងត្រកូលស្តេចឱក្កាកៈ នឹងបានជាសាស្តាព្រះនាមគោតម នឹងត្រាស់ឡើងក្នុងលោក ។ ព្រះមហាក្សត្រនេះ នឹងបានជាឱរសដែលព្រះធម៌និម្មិត ជាអ្នកទទួលមត៌កក្នុងធម៌នៃព្រះគោតមនោះ ជាសាវកនៃព្រះសាស្តា មាននាមថា សីវលី ។ ដោយអំពើដែលខ្ញុំធ្វើល្អនោះផង ដោយការតំកល់ទុកនូវចេតនានោះផង លុះខ្ញុំលះបង់កាយជារបស់មនុស្សហើយ ក៏បានទៅកើតក្នុងឋានតាវត្តិង្ស ។ ព្រះលោកនាយក ព្រះនាមវិបស្សី មានព្រះនេត្រដូចមាស ឃើញនូវធម៌ទាំងពួង ស្តេចកើតឡើង ក្នុងកប្បទី ៩១ អំពីកប្បនេះ ។

នគរំ ពន្ធុមតិយា  កុលស្សញ្ញស្ស ច
ធុយិតោ វុឌ្ឍិតោ ចេវ  អាសិំ កម្មន្តយាចកោ ។
តទា អញ្ញាតកេ បុត្តោ(១)  វិបស្សិស្ស មហេសិនោ
បរិវេណំ អការេសិ  មហន្តមិតំ វិស្សុតំ ។
និដ្ឋិតេ ច មហាទានំ  ទទុំ(២) ខជ្ជកសញ្ញិតំ
នវំ ទធិំ មធុញ្ចេវ  វិចិនំ នេវ អទ្ទសំ(៣) ។
តទាហន្តំ គហេត្វាន  នវទធិំ មធុម្បិ ច
កម្មសាមិឃរំ គច្ឆិំ  តមេសន្តា មមទ្ទសុំ ។
សហស្សម្បិ ទត្វាន  នាលភិត្ត សតទ្ទុយំ(៤)
តតោហមេវំ(៥) ចិន្តេសិំ  នេតំ ហេស្សតិ ឱរកំ ។
យថា ឥមេ ជនា សព្វេ  សក្ការេន្តិ តថាគតំ
អហម្បិ ការំ កាស្សាមិ សសង្ឃេ លោកនាយកេ ។

១ ឱ.ម. បុត្តោ ។ ២ ឱ. ទទុំ ។ ៣ ឱ. អទ្ទសំ ។ ស. អទ្ទសុំ ។ ៤ ឱ. សតទ្ទុយំ ។ ម. សតទ្វយំ ។ ៥ ឱ. ម. តតោហំ ឯវំ ។





កាលនោះ ខ្ញុំជាអ្នកនេះថែរក្សា រកស៊ីនិងការធ្វើក្នុង ការងារ របស់ត្រកូលមួយ នៅក្នុងនគរពន្ធុមតី ។ គ្រានោះ ពួកជនមួយក្រុម បានឲ្យជាងកសាងបរិវេណ ដែលប្រាកដជាបរិវេណធំ ថ្វាយព្រះពុទ្ធ ព្រះនាមវិបស្សី ទ្រង់ស្វែងរកគុណដ៏ធំ ។ លុះធ្វើបរិវេណរួចស្រេច ពួកជនទាំងនោះ នាំគ្នាថ្វាយមហាទាន ប្រកបដោយបន្ថែម ខ្ញុំពិនិត្យមើល (ក្នុងមហាទាននោះ) មិនឃើញមានទឹកដោះជូរថ្មីនិងទឹកឃ្មុំសោះ ។ គ្រានោះ ខ្ញុំក៏បានកាន់ទឹកដោះជូរថ្មី និងទឹកឃ្មុំ ដើរទៅផ្ទះនៃម្ចាស់ការងារ ស្រាប់តែពួកអ្នកស្វែងរកនោះ បានជួបនឹងខ្ញុំ ។ គេបានឲ្យថ្លៃ ៦០០ រហូតដល់ ១ ពាន់ ក៏នៅតែមិនបាន លំដាប់នោះ ខ្ញុំគិតថា វត្ថុនេះ មិនមែនជារបស់ថោកទាប ។ ពួកជនទាំងនេះ គ្រប់គ្នាធ្វើសក្ការៈចំពោះព្រះតថាគត យ៉ាងណា អាត្មាអញនឹងធ្វើសក្ការៈ ចំពោះព្រះលោកនាយក ព្រមទាំងព្រះសង្ឃ យ៉ាងនោះដែរ ។

តទាភោគេហិ ចេត្វាន(1) ទធឹ មធុញ្ច ឯកតោ
មន្ថិត្វា លោកនាថស្ស សសង្ឃស្ស អទាសហំ ។
តេន កម្មេន សុកតេន ចេតនាបណិធីហិ ច
ជហិត្វា មានុសំ ទេហំ តាវត្តឹសំ(2) អគច្ឆហំ ។
បុនាហំ ពារាណសិយំ រាជា ហុត្វា មហាយសោ
សត្តុកស្ស(3) តទា ទូតោ(4) ទ្វារំ រុន្ធឹ អហំ តទា ។
តទា តបស្សិនោ រុទ្ធា ឯកាហំ រក្ខិតា(5) មយា
តតោ តស្ស វិបាកេន បាបុណឹ(6) និរយំ ភុសំ ។
បច្ឆិមេ ច ភវេ ទានិ ជាតោហំ កោលិយេ បុរេ
សុប្បវាសា មេ មាតា មហាលិច្ឆវី មេ បិតា ។
ខត្តិយេ បុញ្ញកម្មេន ទ្វាររោធស្ស វាហសា
សត្តវស្សានិ និវសឹ(7) មាតុកុច្ឆិម្ហិ ទុក្ខិតោ ។

---

១ ឱ.ម. ចិន្តេត្វា ។ ២ ម. ទេវលោកំ ។ ៣ ម. សត្តុកស្ស ។ ៤ ឱ. ពុទ្ធោ ។ ម. វុទ្ធោ ។
៥ ម. ទុក្ខិតោ ។ ៦ ឱ. ម. ពាឡ្ហំ ។ ៧ ឱ. វសឹ ។



គ្រានោះ ខ្ញុំបាននាំយកទឹកដោះជូរនិងទឹកឃ្មុំ ចាក់លាយឡំ ហើយ ថ្វាយដល់ព្រះលោកនាថ ព្រមទាំងព្រះសង្ឃ ក្នុងកាលនោះ ។ ដោយអំពើដែលខ្ញុំធ្វើល្អនោះផង ដោយការតំកល់ទុកនូវចេតនានោះផង លុះខ្ញុំលះបង់កាយ ជារបស់មនុស្សហើយ បានទៅកើតក្នុងឋានតាវត្តិង្ស ។ តពីនោះមក ខ្ញុំកើតជាស្ដេចមានយសធំ ក្នុងក្រុងពារាណសី ជាអ្នកប្រទូស្ត ចំពោះសត្រូវ បានបិទទ្វារនគរ ។ គ្រានោះ ពួកអ្នកនគរ ដែលត្រូវខ្ញុំបិទទ្វារ គេក្ខុតអស់មួយថ្ងៃ កើតសេចក្ដីក្ដៅក្រហាយ លំដាប់អំពីនោះមក ខ្ញុំទៅកើតក្នុងនរកដ៏លាមកខ្លាំងក្លា ព្រោះផលនៃអំពើនោះឯង ។ ក្នុងបច្ឆិមភព ឥឡូវនេះ ខ្ញុំកើតក្នុងកោលិយបុរ មាតារបស់ខ្ញុំ ឈ្មោះសុប្បវាសា បិតាខ្ញុំ ឈ្មោះមហាលិច្ឆវី ។ ខ្ញុំនៅជាទុក្ខក្នុងផ្ទៃមាតា អស់ ៧ ឆ្នាំ ខ្ញុំនៅទ្វារយោនី អស់ ៧ ថ្ងៃ ពេញពោរដោយមហាទុក្ខ

សត្តាហំ ទ្វារមូឡ្ហោហំ  មហាទុក្ខសមប្បិតោ
មាតា មេ ឆន្ទទានេន  ឯវំ អាសិ សុទុក្ខិតា ។
សុវត្ថិតោហំ និក្ខន្តោ  ពុទ្ធេន អនុកម្បិតោ
និក្ខន្តទិវសេយេវ  បព្វជឹ អនគារិយំ ។
ឧបជ្ឈាយោ សារីបុត្តោ មេ  មោគ្គល្លានោ មហិទ្ធិកោ
កេសេ ឱរោបយន្តោ មេ  អនុសាសិ មហាមតិ ។
កេសេសុ ឆិជ្ជមានេសុ  អរហត្តំ អបាបុណិំ
ទេវា នាគា មនុស្សា ច  បច្ចយេ ឧបេន្តិ(១) មេ ។
បទុមុត្តរនាមញ្ញុំ(២)  វិបស្សិំ វិនាយកំ
យំ បូជយិំ បមុទិតោ  បច្ចយេហិ វិសេសតោ ។
តតោ តេសំ វិសេសេន  កម្មានំ វិបុលុត្តមំ
លាភំ លភាមិ សព្វត្ថ  វនេ គាមេ ជលេ ថលេ ។
រេវតំ ទស្សនត្ថាយ  យទា យាតិ វិនាយកោ
តិំសភិក្ខុសហស្សេហិ  សហ លោកគ្គនាយកោ ។

---

១ ឱ. បច្ចយានុបនេន្តិ ។ ម. បច្ចយេ ឧបនេន្តិ ។ ២ ម. បទុមុត្តរនាមជិនំ ។





ព្រោះហេតុតែបិទទ្វារនោះ ដោយគាំងបុញ្ញ ឯខ្ញុំជាកូនស្រុក មាតារបស់ខ្ញុំកើតទុក្ខយ៉ាងនោះដែរ ព្រោះឲ្យឆន្ទៈដល់ខ្ញុំ ។ ក្នុងថ្ងៃដែលប្រសូតចេញមក ខ្ញុំប្រសូតចេញមកដោយសួស្តីភាព ត្រូវព្រះពុទ្ធអនុគ្រោះ ក៏បានចូលទៅកាន់ផ្នួស ។ ព្រះសារីបុត្រជាឧបជ្ឈាយ៍របស់ខ្ញុំ ព្រះមោគ្គល្លានមានឫទ្ធិច្រើន មានប្រាជ្ញាច្រើន បានកោរសក់ ហើយប្រៀនប្រដៅខ្ញុំ ។ កាលដែលសក់ដាច់ចុះ ខ្ញុំក៏បានសម្រេចអរហត្ត ពួកទេវតា នាគ និងពួកមនុស្ស តែងបង្អោនបច្ច័យទាំងឡាយ មកឲ្យខ្ញុំ ។ ខ្ញុំមានចិត្តរីករាយបានបូជាព្រះពុទ្ធ ព្រះនាមបទុមុត្តរៈ និងព្រះនាយក ព្រះនាមវិបស្សី ដោយបច្ច័យទាំងឡាយដ៏វិសេស ។ ព្រោះហេតុនោះ ទើបខ្ញុំបាននូវលាភ ដ៏ទូលាយ ខ្ពង់ខ្ពស់ ក្នុងទីសព្វអន្លើ គឺព្រៃ ស្រុក ទីទឹក ទីគោក ដោយផលដ៏វិសេសនៃកម្មទាំងនោះ ។ កាលណា ព្រះសម្ពុទ្ធ ជានាយក ព្រះអគ្គជាកំពូលនៃលោក និងដឹកនាំសត្វ ស្តេចទៅជួបនឹងព្រះថេរៈឈ្មោះរេវតៈ មួយអន្លើដោយភិក្ខុ ៣ ម៉ឺនរូប ។

តទា ទេវោបនីតេហិ មមត្ថាយ មហាមុនិ
បច្ចយេហិ ឧបាសិតោ សសង្ឃោ លោកនាយកោ ។
ឧបដ្ឋិតោ មយា ពុទ្ធោ គន្ត្វា រេវតមទ្ទសំ(១)
តតោ ជេតវនំ គន្ត្វា ឯតទគ្គេ ឋបេសិ មំ ។
លាភីនំ សីវលី អគ្គោ មម សិស្សេសុ ភិក្ខវោ
សព្វលោកហិតោ សត្ថា កិត្តយី បរិសាសុ មំ ។
កិលេសា ឈាបិតា មយ្ហំ ភវា សព្វេ សមូហតា
នាគោវ ពន្ធនំ ឆេត្វា វិហរាមិ អនាសវោ ។
ស្វាគតំ វត មេ អាសិ មម ពុទ្ធស្ស សន្តិកេ
តិស្សោ វិជ្ជា អនុប្បត្តា កតំ ពុទ្ធស្ស សាសនំ ។

---

១ ម. រេវតមទ្ទសិំ ។



កាលនោះ ព្រះពុទ្ធ ទ្រង់មានយោបល់ដ៏ មានព្យាយាមធំ ជានាយកនៃលោក ព្រមទាំងព្រះសង្ឃ ត្រូវខ្ញុំបំរើដោយ បច្ច័យទាំងឡាយ ដែលពួកទេវតាបង្អោនចូលមក ដើម្បីប្រយោជន៍ដល់ខ្ញុំ ហើយទ្រង់ជួបនឹងព្រះថេរៈ ឈ្មោះរេវតៈ លំដាប់នោះ ទ្រង់យាងទៅកាន់វត្តជេតពនវិញ ក៏តាំងខ្ញុំក្នុង ទីជាឯតទគ្គៈ ។ ព្រះសាស្តា ទ្រង់ទំនុកបំរុងសត្វលោកទាំងពួង ស្តេចសរសើរខ្ញុំ ក្នុងកណ្តាលពួកបរិស័ទថា ម្នាលភិក្ខុទាំងឡាយ បណ្តាសិស្សទាំងឡាយ របស់តថាគត មានតែភិក្ខុសីវលីមួយទេ ជាអ្នកប្រសើរជាងពួកភិក្ខុអ្នកស្វាក់លាភ ។ កិលេសទាំងឡាយ ខ្ញុំដុតបំផ្លាញហើយ ភពទាំងពួង ខ្ញុំដកចោលហើយ ខ្ញុំជាអ្នកមិនមានអាសវៈ ព្រោះបានកាត់ចំណង ដូចជាដំរីកាត់ផ្តាច់ខ្សែទន្លីង ។ ឱ ! ខ្ញុំមកល្អហើយ ក្នុងសំណាក់ព្រះពុទ្ធ របស់ខ្ញុំ វិជ្ជា ៣ ខ្ញុំបានដល់ហើយ សាសនា របស់ព្រះពុទ្ធ ខ្ញុំបានធ្វើហើយ ។

បដិសម្ភិទា ចតស្សោ វិមោក្ខាបិ ច អដ្ឋិមេ
ឆឡភិញ្ញា សច្ឆិកតា កតំ ពុទ្ធស្ស សាសនន្តិ ។

ឥត្ថំ សុទំ អាយស្មា សីវលិ ថេរោ ឥមា គាថាយោ
អភាសិត្ថាតិ ។

សីវលិត្ថេរស្ស អបទានំ សមត្តំ ។

## បញ្ចមំ វគ្គសត្តោបមានំ

[១៣៥] បទុមុត្តរោ នាម ជិនោ សព្វធម្មេសុ ចក្ខុមា
ឥតោ សតសហស្សម្ហិ កប្បេ ឧប្បជ្ជិ នាយកោ ។
យថាបិ សាគរេ ឩម្មិ[១] គគនេ វិយ តារកា
ឯវំ បាវចនំ តស្ស អរហន្តេហិ ចិត្តិតំ[២] ។
សទេវាសុរនាគេហិ មនុជេហិ បុរក្ខតោ
សមណព្រាហ្មណាកិណ្ណោ ជនមជ្ឈេ ជិនុត្តមោ ។

១ ឱ. ម. ឩមិ ។ ២ ឱ. ចិត្តិតំ ។





បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនា របស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ។

បានឮថា ព្រះសីវលិត្ថេរ មានអាយុ បានសំដែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

ចប់ សីវលិត្ថេរាបទាន ។

## វគ្គសត្តោបមាន ទី ៥

(១៣៥) ព្រះជិនស្រី ព្រះនាមបទុមុត្តរៈ ព្រះអង្គមានបញ្ញាចក្ខុក្នុងធម៌ទាំងពួង ជានាយក ទ្រង់កើតឡើងហើយ ក្នុងកប្បទីមួយសែន អំពីកប្បនេះ ។ រលកក្នុងសាគរ និងពួកផ្កាយ ក្នុងអាកាស យ៉ាងណាមិញ សាសនារបស់ព្រះពុទ្ធអង្គនោះ ដ៏វិចិត្រហើយ ដោយពួកព្រះអរហន្ត ក៏យ៉ាងនោះដែរ ។ ព្រះជិនស្រីដ៏ឧត្តមនោះ មានពួកមនុស្ស ព្រមទាំងទេវតា អសុរ នាគ ចោមរោមក្នុងកណ្ដាលប្រជុំជន កុះករដោយសមណៈនិងព្រាហ្មណ៍ ។

នរាសភោ អនុប្បត្តោ      លោកេ លោកគ្គុ ជិនោ
វតេនេ វិរោចេត្តា      ជនេយ្យ បមុទាតិ សោ ។
វេសារជ្ជេហិ សម្បន្នោ      ពន្ធហិ ពុទ្ធសុត្តមោ
បកើឆតយសារជ្ជោ      ខេមប្បត្តោ វិសារទោ ។
អាសភំ បវរំ ឋានំ      ពុទ្ធភូមិញ្ច កេវលំ
បដិជានាតិ លោកគ្គោ      នត្ថិ សញ្ចោទកោ តហិំ ។
សីហនាទមសម្ភីតំ      នទតោ តស្ស តាទិនោ
នេវ ឆតេក ព្រហ្មា វា      បដិវត្តា ច វិជ្ជតិ ។
ទេសេត្តា បវរំ ធម្មំ      សន្តារេត្តា សទេវកំ
ធម្មចក្កំ បវត្តេតិ      បរិសាសុ វិសារទោ ។
បដិកាណាវតិំ អត្ថំ      សាវកំ សាធុសម្មតំ
គុណំ ពហុំ បកាសេត្វា      ឋគខេត្តេ ឋបេសិ តំ ។



ព្រះជិនស្រីនោះ ព្រះអង្គដល់នូវទីបំផុតនៃលោក ក្នុងលោក ទ្រង់ញ៉ាំងពួកវេនេយ្យសត្វ ឲ្យពេញចិត្ត ដោយស្តែងផ្លូវ ឲ្យត្រាស់ដឹងដោយពាក្យ (របស់ព្រះអង្គ) ។ ព្រះអង្គបរិបូណ៌ដោយវេសារជ្ជធម៌ទាំង ៤ ជាបុរសដ៏ឧត្តម មានភ័យនិងសេចក្តីកោតញញើតលះបង់ហើយ ទ្រង់ដល់នូវទីដ៏ក្សេម ជាអ្នកក្លៀវក្លា ។ ព្រះអង្គជាបុគ្គលប្រសើរក្នុងលោក ទ្រង់ប្តេជ្ញានូវពុទ្ធភូមិ ដែលជាទីដ៏ប្រសើរថ្លៃថ្លាទាំងអស់ ព្រះអង្គគ្មានបុគ្គលណាមួយជាស់តឿនឡើយ ។ កាលព្រះអង្គជាតាទិបុគ្គល បន្លឺនូវសីហនាទ ឥតមានញញើត មិនមានទេវតា និងនរជន ឬព្រហ្មពោលតបតបានឡើយ ។ ព្រះអង្គកាលសំដែងនូវធម៌ដ៏ប្រសើរ ញ៉ាំងមនុស្សព្រមទាំងទេវតាឲ្យឆ្លង (ខ្ទ វដ្តៈទាំង ៣) ញ៉ាំងធម្មចក្រឲ្យប្រព្រឹត្តទៅ ទ្រង់ជាអ្នកក្លៀវក្លា ក្នុងបរិស័ទ ។ ព្រះអង្គប្រកាសនូវគុណដ៏ច្រើន នៃសាវ័កមួយរូប ដ៏ប្រសើរជាងពួកលោកមានបដិភាណ ដែលគេសន្មតថាជាសប្បុរស ហើយតាំងសាវ័កនោះ ក្នុងទីជាឯតទគ្គៈ ។

## ចតុត្ថំ វង្គីសត្ថេរាបទានំ

នគរេ ហំសវតិយា ព្រាហ្មណោ សាធុសម្មតោ

សព្វវេទវិទូ ជាតោ វង្គីសោ វាទិសូទនោ ។

ឧបេច្ច តំ មហាវីរំ សុត្វា តំ(១) ធម្មទេសនំ

បីតិវរំ បដិលភឹ សាវកស្ស គុណេ រតោ(២) ។

និមន្តយិត្វា សុគតំ សសង្ឃំ លោកនន្ទនំ

សត្តាហំ ភោជយិត្វាហំ ទុស្សេហិ ឆាទយឹ តទា ។

និបច្ច សិរសា បាទេ កតោកាសោ កតញ្ជលី

ឯកមន្តេ ឋិតោ ហដ្ឋោ សន្ថវឹ ជិនមុត្តមំ ។

នមោ តេ វាទិសូទន(៣) នមោ តេ ឥសិសត្តម(៤)

នមោ តេ សព្វលោកគ្គ នមោ តេ អភយង្ករ ។

---

១ ម. សុត្វាហំ ។ ២ ម. គុណេន រតោ ។ ៣ ឧ. វាទិមទ្ទល ។ ម. វាទិមទ្ទន ។
៤ ឧ. បុរិសុត្តម ។



## វង្គីសត្ថេរាបទាន ទី ៤

កាលនោះ ខ្ញុំកើតជាព្រាហ្មណ៍ឈ្មោះវង្គីសៈ នៅក្នុងនគរហង្សវតី ចេះចប់នូវវេទសព្វគ្រប់ គេសន្មតថាជាសប្បុរស ជាអ្នកបង្ក្រាបនូវពាក្យប្រៀបប្រដៅ ។ ខ្ញុំបានចូលទៅជិតព្រះអង្គមានព្យាយាមធំ ហើយស្តាប់ធម្មទេសនា បាននូវបីតិដ៏ប្រសើរ ក៏ត្រេកអរក្នុងគុណនៃសាវ័ក ។ កាលនោះ ខ្ញុំនិមន្តព្រះសុគត ព្រមទាំងព្រះសង្ឃ ដែលជាអ្នកញ៉ាំងសត្វលោកឲ្យត្រេកអរ មកបានអស់ ៧ ថ្ងៃ ហើយឲ្យគេបិទបាំងដោយសំពត់ទាំងឡាយ ។ ខ្ញុំបានក្រាបក្បាលទៀបព្រះបាទា (នៃព្រះអង្គ) លុះព្រះអង្គបើកឱកាសឲ្យខ្ញុំហើយ ខ្ញុំបានធ្វើនូវអញ្ជលី ឋិតនៅក្នុងទីដ៏សមគួរ មានចិត្តត្រេកអរ សរសើរនូវព្រះជិនស្រីដ៏ឧត្តមថា បពិត្រព្រះអង្គទ្រង់បង្ក្រាបនូវពាក្យប្រៀនប្រដៅ ខ្ញុំសូមថ្វាយបង្គំព្រះអង្គ បពិត្រព្រះអង្គជាឥសីទី ៧ ខ្ញុំសូមថ្វាយបង្គំព្រះអង្គ បពិត្រព្រះអង្គជាបុគ្គលប្រសើរជាងសត្វលោកទាំងអស់ ខ្ញុំសូមក្រាបថ្វាយបង្គំព្រះអង្គ បពិត្រព្រះអង្គទ្រង់ធ្វើនូវអភ័យ ខ្ញុំសូមក្រាបថ្វាយបង្គំព្រះអង្គ ។

នមោ តេ មារមថន  នមោ តេ ទិដ្ឋិសូទន

នមោ តេ សព្វសុខទ  នមោ តេ សរណង្ករ ។

អនាថានំ ភវំ នាថោ  ភីតានំ អភយប្បទោ

វិស្សាសំ ភូមិសន្តានំ  សរណំ សរណេសិនំ ។

ឯវមាទីហិ សម្ពុទ្ធំ  សន្ថវិត្វា មហាគុណំ

អវោចំ ភិន្នស្សរស្ស[១]  គតឹ បប្បោមិ ភិក្ខុតោ ។

តទា អវោច ភគវា  អនន្តបដិភាណវា

យោ សោ ពុទ្ធំ អភោជេសិ  សត្តាហំ សហសាវកំ ។

គុណញ្ច មេ បកិត្តេសិ  បសន្នោ សេហិ បាណិភិ

ឯសោ បត្ថយតេ ឋានំ  ភិន្នស្សរស្ស[២] ភិក្ខុតោ ។

១-២ ឱ. ភិន្ទសុខស្ស ។





បពិត្រព្រះអង្គទ្រង់ញាំញីនូវមារ ខ្ញុំសូមក្រាបថ្វាយបង្គំព្រះអង្គ បពិត្រព្រះអង្គទ្រង់បង្ខូរនូវទិដ្ឋិ ខ្ញុំសូមក្រាបថ្វាយបង្គំព្រះអង្គ បពិត្រព្រះអង្គទ្រង់ឲ្យនូវសន្តិសុខ ខ្ញុំសូមក្រាបថ្វាយបង្គំព្រះអង្គ បពិត្រព្រះអង្គទ្រង់ធ្វើនូវទីពឹង ខ្ញុំសូមក្រាបថ្វាយបង្គំព្រះអង្គ ។ ព្រះអង្គដ៏ចំរើន ជាទីពឹងនៃសត្វ ដែលពុំមានទីពឹង ទ្រង់ប្រទាននូវអភ័យដល់សត្វដែលមានភ័យ ទ្រង់ស្និទ្ធស្នាលរបស់សត្វទាំងឡាយ ដែលមានភូមិដ៏ស្ងប់ ជាទីពឹងរបស់ពួកជនអ្នកស្វែងរកនូវទីពឹង ។ លុះខ្ញុំសរសើរព្រះសម្ពុទ្ធមានគុណធំ ដោយពាក្យទាំងឡាយ មានយ៉ាងនេះជាដើម រួចបានពោលថា ខ្ញុំសូមដល់នូវគតិរបស់ភិក្ខុ ដែលជាអ្នកឿរគ្នា ជាធំភិក្ខុអ្នកមានវាទៈឿរគ្នា ។

កាលនោះ ព្រះមានព្រះភាគ ព្រះអង្គមានបដិភាណគ្មានទីបំផុត បានត្រាស់ថា បុគ្គលណា បានញុំាងព្រះពុទ្ធព្រមទាំងសាវ័ក ឲ្យឆាន់អស់ ៧ ថ្ងៃ ជ្រះថ្លា (ប្រណម្យ) ដោយដៃរបស់ខ្លួន សរសើរនូវគុណនៃតថាគត បុគ្គលនុ៎ះ ប្រាថ្នានូវតំណែងរបស់ភិក្ខុ អ្នកឿរគ្នាគង់ ។

បន្ត វង្គីសត្ថេរាបទាន

អនាគតម្ហិ អទ្ធានេ លច្ឆសេតំ(១) មនោរថំ
ទេវមនុស្សសម្បត្តិំ អនុភោត្វា អនប្បកំ ។
សតសហស្សិតោ កប្បេ ឱក្កាកកុលសម្ភវោ
គោតមោ នាម នាមេន សត្ថា លោកេ ភវិស្សតិ ។
តស្ស ធម្មេសុ ទាយាទោ ឱរសោ ធម្មនិម្មិតោ
វង្គីសោ នាម នាមេន ហេស្សតិ សត្ថុសាវកោ ។
តំ សុត្វា មុទិតោ ហុត្វា យាវជីវំ តទា ជិនំ
បច្ចយេហិ ឧបដ្ឋាសិំ មេត្តចិត្តោ តថាគតំ ។
តេន កម្មេន សុកតេន ចេតនាបណិធីហិ ច
ជហិត្វា មានុសំ ទេហំ តាវតិំសំ អគច្ឆហំ(២) ។
បច្ឆិមេ ច ភវេ ទានិ បរិព្វាជកុលេ(៣) អហំ
បច្ចាជាតោ(៤) យទា អាសិំ ជាតិយា សត្តវស្សិកោ ។

---

១ ឱ. លច្ឆេតំ ៖ ២ ឱ.ម. តុសិតំ អគមាសហំ ។ ៣ ម. ជាតោ វិប្បកុលេ ។ ៤ ម. សម្ភូតោ ច ។



វង្គីសត្ថេរាបទាន ទី ៤

បុគ្គលទាំងឡាយសោយសម្បត្តិទេវតា និងសម្បត្តិមនុស្សដ៏ច្រើន ហើយបាននូវតំណែងជាទីពេញចិត្តនោះ ក្នុងអនាគតកាល ។ ក្នុងកប្បមួយសែន អំពីកប្បនេះ មានមហាបុរសទ្រង់កើតក្នុងឱក្កាកត្រកូល ដ៏បានជាព្រះសាស្តា ទ្រង់ព្រះនាមគោតម ត្រាស់ឡើងក្នុងលោក ។ បុរសនោះ ជាទាយាទក្នុងធម៌ទាំងឡាយ របស់ព្រះអង្គ ជាឱរស ជាធម្មនិម្មិត ជាសាវ័ក នៃព្រះសាស្តាអង្គនោះ មានឈ្មោះថាវង្គីសៈ ។

កាលនោះ ខ្ញុំបានស្តាប់ពាក្យព្យាករណ៍នោះហើយ ក៏ជាបុគ្គលមានចិត្តខ្ជាប់ មានចិត្តមេត្តា បានបម្រើនូវព្រះតថាគតជិនស្រី ដោយបច្ច័យទាំងឡាយ ដរាបដល់អស់ជីវិត ។ ដោយកុសលកម្មដែលខ្ញុំធ្វើល្អនោះផង ដោយការតាំងចិត្តទុកនោះផង លុះខ្ញុំលះបង់កាយជារបស់មនុស្សហើយ បានទៅកើតក្នុងឋានតាវត្តិង្ស ។ ដល់មកក្នុងបច្ឆិមភព ក្នុងភពនេះ ខ្ញុំបានមកកើតក្នុងត្រកូលបរិព្វាជក មានអាយុ ៧ ឆ្នាំ កាលអំពីកំណើត

សព្វវេទវិទូ ជាតោ　　វាទសត្ថវិសារទោ
វាទិស្សរោ(១) ចិត្តកថី　　បរវាទប្បមទ្ទនោ ។
វង្គេ(២) ជាតោតិ(៣) វង្គីសោ　　វចនេ ឥស្សរោតិ វា
វង្គីសោ ឥតិ មេ នាមំ　　អគ្គស្សុ(៤) លោកសម្មតំ ។
យទាហំ វិញ្ញុតំ បត្តោ　　ឋិតោ បឋមយោព្វនេ
តទា រាជគហេ រម្មេ　　សារីបុត្តមហទ្ទសំ(៥) ។

បញ្ចវីសតិមំ ភាណវារំ ។

បិណ្ឌាយ វិចរន្តំ តំ　　បត្តបាណឹ សុសំវុតំ
អលោលក្ខុំ មិតភាណឹ　　យុគមត្តំ ឧទិក្ខតំ(៦) ។
តំ ទិស្វា វិម្ហិតោ ហុត្វា　　អកេបមធុប្បរំ
កណិការំវ ចិចិតំ　　ចិត្តំ គាថាបធិ អហំ ។

១ ម. វាទិស្សរោ ។ ២ ឱ. ឯត្តន្តរេ ហើ សត្វោ ទិស្សតិ ។ ៣ ឱ.ម. ធតំ សត្វោ ទត្ថុ ។ ៤ ឱ.ម. អគ្គ ។ ៥ ឱ. សារីបុត្តមបទ្ទសំ ។ ម. សារីបុត្តមហទ្ទសំ ។ ៦ ឱ. និរិក្ខតំ ម. និខក្ខិតំ ។



ក៏ចេះចប់នូវត្រៃវេទទាំងអស់ ត្រៀមត្រៃដោយគេវសាស្ត្រ មាន សំឡេងដ៏ពីរោះ មានសំដីវិចិត្រ ជាអ្នកញាំញីនូវពួកនៃ បុគ្គលដទៃ ។ ឯនាមដ៏ប្រសើររបស់ខ្ញុំ ដែលលោកសន្មត ហើយថា វង្គីសៈ ព្រោះកើតក្នុងវង្គជនបទ ម្យ៉ាងថា វង្គីសៈ ព្រោះជាឥស្សរៈក្នុងពាក្យ ។ កាលណា ខ្ញុំបានដឹងក្តី ឋិត នៅក្នុងបឋមវ័យ កាលនោះ ខ្ញុំបានជួបនឹងព្រះសារីបុត្ត ក្នុង ក្រុងរាជគ្រឹះ ដែលជាទីគាប់ ។

ចប់ភាណវារៈ ទី ២៥ ។

ខ្ញុំឃើញព្រះសារីបុត្តនោះ កំពុងត្រាច់ទៅបិណ្ឌបាត មាន បាត្រក្នុងដៃ លោកសង្រួមល្អ មានភ្នែកមិនរវើរវាយ និ-យាយល្មមកំណត់ ក្រឡេកមើលត្រឹមមួយជួរទឹម លុះឃើញ លោកហើយ មានសេចក្តីអស្ចារ្យ បាននិយាយពាក្យគួរសម ជាបទគាថាវិចិត្រ ដូចផ្កាកណិការដែលគេវិចិត្រហើយ ។

## ចតុត្ថំ វង្គីសត្ថេរាបទានំ

អាចិក្ខិ សោ មេ សត្ថារំ   សម្ពុទ្ធំ លោកនាយកំ
តទា សោ បណ្ឌិតោ ធីរោ   ឧត្តរឹ សមទេសយិ ៗ
វិរាគសហិតំ កត្វា   កថំ ឧត្តមសម្បទំ
វិចិត្តបដិភានេហិ   តោសិតោ តេន តាទិនា ៗ
និបច្ច សិរសា បាទេ   បព្វាជេហីតិ អព្រវី(១)
តតោ មំ ស មហាបញ្ញោ   ពុទ្ធសេដ្ឋមុបានយិ ៗ
និបច្ច សិរសា បាទេ   និសីទឹ សត្ថុ សន្តិកេ
មមាហ វទតំ សេដ្ឋោ   សន្តិ វង្គីស កច្ចិ តេ(២) ៗ(៣)
មតំ សីសំ វិធិតំ   សុគតិទុគ្គតិគតំ(៤)
តុយ្ហំ(៥) វិជ្ជាវិសេសេន   សចេ សក្កោសិ ភណយ(៦) ៗ

---

១ ឱ. បព្វាជេហីតិ ចព្រវី ។ ម. បព្វាជេហីតិ មំ ព្រវី ។ ២ ម. កច្ចិ វង្គីស ជានាសិក ទិស្សន្តិ ។ ៣ ម. ឥតោ បរំ កិញ្ចិ សិប្បន្តិ តស្សាហំ ជានាមីតិ ច អព្រវី ឥតិ ទិស្សន្តិ ។ ៤ ឱ.ម. មតសីសំ វនច្ឆុទ្ធំ អបិ ពារសវស្សិកន្តិ ទិស្សន្តិ ។ ៥ ឱ. ម. តយា ។ ៦ ឱ. ភាសយ ។



## វង្គីសត្ថេរាបទាន ទី ៤

លោកក៏ប្រាប់ខ្ញុំ នូវព្រះសម្ពុទ្ធទ្រង់ជាសាស្តា ជាលោកនាយក កាលនោះ លោកជាបណ្ឌិតមានប្រាជ្ញា បានប្រាប់ខ្ញុំតទៅទៀត ៗ ខ្ញុំត្រូវលោកជាតាទិបុគ្គលធ្វើពាក្យប្រកបដោយវិរាគៈដ៏ឧត្តម ដែលគេឃើញបានដោយកម្រ ឲ្យត្រេកអរដោយបដិភាណដ៏វិចិត្រទាំងឡាយ ៗ ខ្ញុំក៏ឱនក្បាលទៀបព្រះបាទ ហើយពោលថា សូមលោកម្ចាស់បំបួសខ្ញុំ លំដាប់នោះ ព្រះសារីបុត្ត មានប្រាជ្ញាច្រើននោះ នាំខ្ញុំចូលទៅគាល់ព្រះពុទ្ធដ៏ប្រសើរ ៗ ខ្ញុំឱនក្បាលទៀបព្រះបាទ អង្គុយក្នុងសំណាក់នៃព្រះសាស្តា ព្រះសាស្តា ប្រសើរជាងអ្នកប្រាជ្ញទាំងឡាយ ទ្រង់មានព្រះពុទ្ធដីកានឹងខ្ញុំថា ម្នាលវង្គីសៈ សិល្បៈណាមួយរបស់អ្នក មានពិតឬ ៗ ក្បាលមនុស្ស ដែលស្លាប់ហើយ បើអ្នកអាច (ដឹងក្បាលមនុស្ស) ដែលស្លាប់ទៅកាន់សុគតិ ឬទុគ្គតិ ដោយវិជ្ជាវិសេសរបស់អ្នក អ្នកចូរប្រាប់មកចុះ ៗ

ភាវេហិ(១) មេ បដិញ្ញាតេ ឆវសីសានិ ទស្សយិ

អហំ និរយទេវេសុ ឧបបន្នេ អភាសយិំ ។

តទា ខីណាសវស្សាបិ(២) សីសំ ទស្សេសិ នាយកោ

តតោហំ វិហតារម្ភោ បព្វជ្ជំ សមយាចិសិំ(៣) ។

បព្វជិត្វាន សុគតំ សន្ថវិំ យហឹ តហឹ

តតោ មំ កាវិចិត្តោតិ(៤) ឧជ្ឈាយន្តិ ហិ ភិក្ខវោ ។

តតោ វីមំសនត្ថំ មេ អាហ ពុទ្ធោ វិនាយកោ

តក្កិកា យំ ឥមា(៥) គាថា ឋានសោ បដិភន្តិ តេ(៦) ។

ន កាព្យចិត្តោហំ វីរ ឋានសោ បដិភន្តិ មេ

តេនហិ ទានិ វង្គីស ឋានសោ សន្ថវាហិ មំ ។

---

១ ម. ភាមាភិ ។ ២ ម.ម បវត្តកត្ថុស្ស ។ ៣ ម. សមយាចិហំ ។ ៤ ម. កវ្យចិត្តោតិ ។ ម. កបវិជ្ជោសិ ។ ៥ ម. តក្កិកាបដិមា ។ ៦ ម. តំ ។



ខ្ញុំបានទទួលពាក្យប្តេជ្ញាថា ព្រះករុណាព្រះអង្គ ព្រះពុទ្ធទ្រង់បញ្ចេញនូវក្បាល ៗ ខ្ញុំក៏ក្រាបទូលចំពោះក្បាល (មនុស្ស) ដែលទៅកើត ក្នុងនរកនិងទេវតា ។

កាលនោះ ព្រះលោកនាយក បញ្ចេញនូវក្បាលរបស់ព្រះខីណាស្រព លំដាប់នោះ ខ្ញុំពាល់គំនិត ក៏សូមបព្វជ្ជា ។ លុះខ្ញុំបព្វជ្ជាហើយ ក៏សរសើរព្រះសុគត តាមតែក្នុងទីណា ៗ ក៏បាន លំដាប់នោះ ភិក្ខុទាំងឡាយលើកទោស ថាជាអ្នកកែកាយ ក្នុងកាព្យ ។ លំដាប់នោះ ព្រះពុទ្ធជានាយក ទ្រង់ត្រាស់ដើម្បីល្បងមើល ចំពោះខ្ញុំថា លុះតែបុគ្គលទាំងឡាយ ជាអ្នកត្រិះរិះ ទើបពោលគាថាទាំងឡាយ តាមដំណើរឋាន មែនឬទេ ។ បពិត្រព្រះអង្គមានព្យាយាម ខ្ញុំព្រះអង្គមិនមែនជាអ្នកយកចិត្តគិតគូក្នុងកាព្យទេ តែខ្ញុំព្រះអង្គពោលនូវគាថាទាំងឡាយតាមដំណើរឋាន ៗ ម្នាលវង្គីសៈ បើដូច្នោះ ឥឡូវនេះ អ្នកចូរសរសើរតថាគតតាមហេតុ ជាគាថាមកមើល ។

ឥធាគំ សក្កីរ ធីរំ | គាថាហិ ឥសិសត្តមំ
សោ ហាសសោ ឥធា នុដ្ឋោ | ធីរោ អក្ខុធរេសិ មំ ។
បដិភាណេន ភិក្ខូន | អញ្ញោ សមនុស្សាមហំ
បេសលោ តេន សិក្ខោ | អរហន្តំ អនាមុណី ។
បដិភាណវា អក្ខោ | អញ្ញោ គោចរ ឧវិដ្ឋិត
យថាយំ ភិក្ខុ វត្តីសោ | ឯវំ ធារេថ ភិក្ខវោ ។
សតសហស្សេ កតំ កម្មំ | ផលំ ទស្សេសិ មេ ឥធ
សុមុត្តោ សរវេគោវ | កិលេសា ឈាបិតា មយា ។
កិលេសា ឈាបិតា មយ្ហំ | ភវា សព្វេ សមូហតា
នាគោវ ពន្ធនំ ឆេត្វា | វិហរាមិ អនាសវោ ។





កាលនោះ ខ្ញុំបានសរសើរព្រះអង្គជាអ្នកប្រាជ្ញ ជាឥសី ទី ៧ ដោយគាថាទាំងឡាយ ។ ព្រះជិនស្រីអង្គនោះ មានព្រះហឫទ័យត្រេកអរមួយរំពេច ក៏ត្រាស់នឹងខ្ញុំ ក្នុងទីឯកទេស ។ ខ្ញុំក្នុងទីបង់ នូវបុគ្គលដទៃ ដោយចិត្តដ៏ល្អស្រួលបាន ខ្ញុំជាបុគ្គលមានសីលជាទីស្រឡាញ់ មានសេចក្តីសន្តោស ដោយបដិភាណចិត្ត ក៏បានដល់នូវអរហត្ត ។

ភិក្ខុដទៃណាមួយ ជាបុគ្គលប្រសើរជាងភិក្ខុ អ្នកមានបដិភាណ ដូចជាថេរភិក្ខុនេះ មិនមានទេ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ ចូរចាំទុកយ៉ាងនេះចុះ ។

កម្មដែលខ្ញុំធ្វើហើយ ក្នុងកប្បទីមួយសែន អំពីកប្បនេះ ក៏ឲ្យផលដល់ខ្ញុំ ក្នុងលោកនេះ ខ្ញុំផុតផុតចាកកិលេសហើយ ដូចជាសន្ទុះសរ ប្រុតផុតចាកបំពង់ព្រួញ កិលេសទាំងឡាយ ខ្ញុំដុតបំផ្លាញហើយ ។ កិលេសទាំងឡាយ ខ្ញុំដុតបំផ្លាញហើយ ភពទាំងអស់ ខ្ញុំដកចោលហើយ ខ្ញុំជាអ្នកមិនមានអាសវៈ ព្រោះបានកាត់ចំណង ដូចជាដំរីកាត់ផ្តាច់នូវទន្លីង ។

សាគតំ វត មេ អាសិ    មម ពុទ្ធស្ស សន្តិកេ

តិស្សោ វិជ្ជា អនុប្បត្តា    កតំ ពុទ្ធស្ស សាសនំ ។

បដិសម្ភិទា ចតស្សោ    វិមោក្ខាបិ ច អដ្ឋិមេ

ឆឡភិញ្ញា សច្ឆិកតា    កតំ ពុទ្ធស្ស សាសនន្តិ ។

ឥត្ថំ សុទំ អាយស្មា វត្ថិសេដ្ឋោ ថេរោ ឥមា គាថា-យោ អភាសិត្ថាតិ ។

វត្ថិសេដ្ឋស្ស អបទានំ សមត្តំ ។

## បញ្ចមំ ឆន្នកត្ថេរាបទានំ

(១៣៥) បទុមុត្តរោ នាម ជិនោ    សព្វធម្មេសុ ចក្ខុមា

ឥតោ សតសហស្សម្ហិ    កប្បេ ឧប្បជ្ជិ នាយកោ ។

ហិតាយ សព្វសត្តានំ    សុខាយ វទតី ជិនោ

អត្ថាយ បុរិសាជញ្ញោ    បដិបន្នោ សទេវកេ ។



ន ។ ខ្ញុំមកល្អហើយ ក្នុងសំណាក់ព្រះពុទ្ធរបស់ខ្ញុំ វិជ្ជា ៣ ខ្ញុំបានសម្រេចហើយ សាសនា របស់ព្រះពុទ្ធ ខ្ញុំបានធ្វើហើយ ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនា របស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ។

បានឮថា ព្រះវត្ថិសេដ្ឋ មានអាយុ បានសម្ដែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

ចប់ វត្ថិសេដ្ឋកៈ ។

## ឆន្នកត្ថេរាបទាន ទី ៥

(១៣៥) ព្រះជិនស្រី ព្រះនាមបទុមុត្តរៈ ទ្រង់មានបញ្ញាចក្ខុក្នុងធម៌ទាំងពួង ព្រះអង្គជានាយក ទ្រង់កើតឡើងក្នុងកប្បមួយសែន អំពីកប្បនេះ ។ ព្រះអង្គជាបុរសអាជានេយ្យ ប្រសើរជាងអ្នកប្រាជ្ញទាំងឡាយ ទ្រង់ស្ដេចទៅក្នុងមនុស្សលោកនិងទេវលោក ដើម្បីប្រយោជន៍ ដើម្បីសេចក្ដីសុខ ដើម្បីសេចក្ដីចំរើន ដល់សព្វសត្វទាំងឡាយ ។

បញ្ចមំ ឧទ្ទេសភាណំ

យសគ្គប្បត្តោ សិរីមា  កិត្តិវណ្ណភតោ ជិនោ
បូជិតោ សព្វលោកស្ស  ជិនោ សត្ថា សុវិស្សុតោ ។
ឧត្តិណ្ណវិចិកិច្ឆោ សោ  វីតិវត្តកថំកថោ
បរិបុណ្ណមនសង្កប្បោ  បត្តោ សម្ពោធិមុត្តមំ ។
អនុប្បន្នស្ស មគ្គស្ស  ឧប្បាទេតា នរុត្តមោ
អនក្ខាតញ្ច អក្ខាសិ  អសញ្ជាតញ្ច សញ្ជយិ ។
មគ្គញ្ញូ(១) មគ្គវិទូ ច(២)  មគ្គក្ខាយី នរាសភោ
មគ្គស្ស កុសលោ សត្ថា  សារថីនំ វរុត្តមោ(៣) ។
ឥតិ មហាការុណិកោ  ធម្មំ ទេសេសិ នាយកោ
និមុគ្គេ មោហបង្កម្ហា(៤)  សមុទ្ធរតិ បាណិនោ ។

១ ឱ. ឯកត្តុម សោលសេតូ វិសុទ្ធិ ។ ២ ឱ. ច សទ្ទោ នត្ថិ ។ ៣ ឱ. ម. វរុត្តមោ ។ ៤ ម. កាមបង្កម្ហា ។



ឧទ្ទេសភាណៈ ទី ៥

ព្រះជិនស្រី ព្រះអង្គដល់នូវយសដ៏ប្រសើរ មានសិរី ពេញប្រៀបដោយកិត្តិគុណ ដែលសត្វលោកតាំងទុក បូជាហើយ ល្បីខ្ចរខ្ចាយសព្វទិស ។ ព្រះជិនស្រីនោះ មានវិចិកិច្ឆាទួនផុតហើយ មានសេចក្ដីសង្ស័យកន្លងហើយ មានសេចក្ដីត្រិះរិះក្នុងព្រះចិន្តាពេញបរិបូណ៌ ទ្រង់ដល់នូវសម្ពោធិញ្ញាណដ៏ឧត្តម ។ ព្រះអង្គជានរៈដ៏ឧត្តម ទ្រង់ញ៉ាំងមគ្គដែលមិនទាន់កើតឲ្យកើតឡើង ទ្រង់ប្រាប់នូវពាក្យដែលគេមិនទាន់និយាយ ទ្រង់បង្កើតនូវធម្មជាតដែលមិនទាន់កើត ។ ព្រះអង្គជាអ្នកស្គាល់នូវផ្លូវ ជ្រាបច្បាស់នូវផ្លូវ ជាអ្នកប្រាប់នូវផ្លូវ ជាអ្នកអង់អាចជាងនរៈ ជាសាស្ដាឈ្លាសវៃក្នុងផ្លូវ ជានរៈដ៏ឧត្តម ជាងសារថីទាំងឡាយ ។ ក្នុងកាលនោះ ព្រះលោកនាយក ទ្រង់ប្រកបដោយមហាករុណា ទ្រង់សម្ដែងនូវធម៌ ហើយស្រង់ពួកសត្វដែលមុជចុះ ក្នុងភក់គឺមោហៈ ។

ភិក្ខុំ ទិវាឋានេ សហាវំ ធេនុស្សតំ
វណ្ណយិ បគ្គហគ្គម្ពិ ឋបេសិ មហាមុនិ ។
តំ សុត្វា បមុទិតោ និមន្តេត្វា តថាគតំ
ភោជយិត្វា សសង្ឃន្តំ បត្ថយឹ ឋានមុត្តមំ ។
តទា បមុទិតោ ធីរោ មំ អវោច មហាឥសិ
សុខី ភវស្សុ ទីឃាយុ លច្ឆសេតំ មនោរថំ ។
សតសហស្សិតោ កប្បេ ឱក្កាកកុលសម្ភវោ
គោតមោ នាម នាមេន សត្ថា លោកេ ភវិស្សតិ ។
តស្ស ធម្មេសុ ទាយាទោ ឱរសោ ធម្មនិម្មិតោ
ឧទាយី នាម នាមេន ហេស្សតិ សត្ថុ សាវកោ ។
តេន កម្មេន សុកតេន ចេតនាបណិធីហិ ច
ជហិត្វា មានុសំ ទេហំ តាវតឹសំ អគច្ឆហំ(១) ។

១ ឱ. តាវតឹសូបគោ អហំ ។



ព្រះមហាមុនី ទ្រង់សរសើរភិក្ខុ ដែលញុំាងត្រកូលឲ្យជ្រះថ្លា ក្នុងកណ្តាលពួកភិក្ខុ បានតែងតាំងក្នុងឋានៈ ជាឯតទគ្គៈ ។ ខ្ញុំបានស្តាប់ព្រះពុទ្ធដីកានោះហើយ ក៏មានចិត្តរីករាយ និមន្តព្រះតថាគត ព្រមទាំងព្រះសង្ឃ ឲ្យឆាន់ ហើយប្រាថ្នានូវតំណែង ដ៏ឧត្តមនោះ ។

ក្នុងកាលនោះ ព្រះមហាឥសី ជាធីរៈ ទ្រង់មានព្រះទ័យរីករាយ បានត្រាស់នឹងខ្ញុំថា អ្នកចូរបានសេចក្តីសុខ មានអាយុវែង អ្នកនឹងបាននូវតំណែង ជាទីពេញចិត្តនុ៎ះ ។ ក្នុងកប្បមួយសែន អំពីកប្បនេះ ព្រះសាស្តាទ្រង់ព្រះនាម គោតម ទ្រង់សម្ភពក្នុងឧក្កាកត្រកូល នឹងត្រាស់ឡើងក្នុងលោក ។ បុរសនេះនឹងបានជាទាយាទ ក្នុងធម៌របស់ព្រះសាស្តា ជាឱរសដែលធម៌និម្មិត ឈ្មោះឧទាយី ជាសាវ័ក របស់ព្រះសាស្តានោះ ។ ដោយកុសលកម្មដែលខ្ញុំធ្វើល្អនោះផង ដោយការតាំងចេតនានោះផង លុះខ្ញុំលះបង់កាយ ជារបស់មនុស្សហើយ ក៏បានទៅកើត ក្នុងឋានតាវត្តិង្ស ។

បញ្ចមំ ...

បច្ឆិមេ ច ភវេ ទានិ ជាតោ សេដ្ឋិកុលេ អហំ
សាវត្ថិយំ បុរវរេ ឥទ្ធេ ផីតេ មហទ្ធនេ ។
បុរប្បវេសេ សុគតំ ទិស្វា វិម្ហិតមានសោ
ជេតារាមបដិគ្គាហេ បព្វជឹ អនគារិយំ ។
ន ចិរេនេវ កាលេន អរហត្តំ អបាបុណឹ
តតោហំ តិណ្ណសំសារោ សាសិតោ សព្វទស្សិនា ។
ភិក្ខុនីនំ ធម្មកថំ បរិបុច្ឆាការី អហំ
សាសិតា តា មយា សព្វា អហេសុំ អនាសវា ។
សតានិ បញ្ចមត្តានិ តតោ តុដ្ឋោ មហាហិតោ
ភិក្ខុនីឱវាទកំ អគ្គដ្ឋានេ ឋបេសិ មំ ។



បញ្ចមវគ្គ ទី ៥

ក្នុងភពនេះ ជាទីបំផុតនេះឯង ខ្ញុំកើតក្នុងត្រកូលសេដ្ឋី ក្នុងក្រុងសាវត្ថី ជាបុរីប្រសើរ ស្តុកស្តម្ភ ដូចកាយ មានទ្រព្យច្រើន ។ ខ្ញុំបានឃើញព្រះសុគត ទៀបមាត់ទ្វារនៃបុរី ក៏មានចិត្តរន្ធត់ កាលព្រះសុគតទ្រង់ទទួលជេតពន ខ្ញុំចូលទៅកាន់ផ្នួស ។ លំដាប់នោះ ខ្ញុំត្រូវព្រះសម្ពុទ្ធ ទ្រង់ឃើញសព្វ ប្រៀនប្រដៅហើយ មានសង្សារឆ្លងហើយ ក៏បានដល់អរហត្ត ដោយកាលមិនយូរប៉ុន្មាន ។ ខ្ញុំបានធ្វើនូវធម្មកថានិងបរិបុច្ឆា ចំពោះនាងភិក្ខុនីទាំងឡាយ ភិក្ខុនីទាំងអស់នោះ ចំនួន ៥០០ រូបឯណោះ ដែលខ្ញុំទូន្មានហើយ ក៏បានទៅជាភិក្ខុនីមិនមានអាសវៈ ។ កាលនោះ ព្រះមានព្រះភាគមានព្រះហឫទ័យត្រេកអរ ទ្រង់ធ្វើប្រយោជន៍ធំ ទ្រង់តាំងខ្ញុំក្នុងតំណែងដ៏ប្រសើរ ជាងពួកសាវ័កអ្នកឲ្យឱវាទពួកភិក្ខុនី ។

សតសហស្សេ កតំ កម្មំ ផលំ ទស្សេសិ មេ ឥធ

សុមុត្តោ សរវេគោវ កិលេសេ ឈាបយិំ មម ។

កិលេសា ឈាបិតា មយ្ហំ ភវា សព្វេ សមូហតា

នាគោវ ពន្ធនំ ឆេត្វា វិហរាមិ អនាសវោ ។

ស្វាគតំ វត មេ អាសិ មម ពុទ្ធស្ស សន្តិកេ

តិស្សោ វិជ្ជា អនុប្បត្តា កតំ ពុទ្ធស្ស សាសនំ ។

បដិសម្ភិទា ចតស្សោ វិមោក្ខាបិ ច អដ្ឋិមេ

ឆឡភិញ្ញា សច្ឆិកតា កតំ ពុទ្ធស្ស សាសនន្តិ ។

ឥត្ថំ សុទំ អាយស្មា នន្ទកោ ថេរោ ឥមា គា-

ថាយោ អភាសិត្ថាតិ ។

នន្ទកត្ថេរស្ស អបទានំ សមត្តំ ។



កុសលកម្មដែលខ្ញុំធ្វើហើយ ក្នុងកប្បទីមួយសែន អំពីកប្បនេះ ក៏ឲ្យផលដល់ខ្ញុំ ក្នុងលោកនេះ កិលេសទាំងឡាយ ខ្ញុំដុតបំផ្លាញហើយ ដូចកៀនខ្សែព្រួញ ដែលរបូតផុតទៅ ។ កិលេសទាំងឡាយ ខ្ញុំដុតកំលោចហើយ ភពទាំងអស់ ខ្ញុំដកចោលចេញហើយ ខ្ញុំជាអ្នកមិនមានអាសវៈ ព្រោះបានកាត់បំណង ដូចជាដំរីកាត់ផ្តាច់ខ្សែទន្លីង ។ ឱ! ខ្ញុំមកល្អហើយ ក្នុងសំណាក់ព្រះពុទ្ធរបស់ខ្ញុំ វិជ្ជា ៣ ខ្ញុំបានសម្រេចហើយ សាសនា របស់ព្រះពុទ្ធ ខ្ញុំបានធ្វើហើយ ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនា របស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ។

បានឮថា ព្រះនន្ទកត្ថេរ មានអាយុ បានសម្តែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

ចប់ នន្ទកត្ថេរាបទាន ។

# ឆដ្ឋំ កាឡុទាយិត្ថេរាបទានំ

(១៣៦) បទុមុត្តរោ នាម ជិនោ សព្ពធម្មេសុ ចក្ខុមា
ឥតោ សតសហស្សម្ហិ កប្បេ ឧប្បជ្ជិ នាយកោ ។
នាយកានំ វរោ សត្ថា គុណាគុណវិទូ ជិនោ
កតញ្ញូ កតវេទី ច តិត្ថេ យោជេសិ បាណិនោ ។
សព្ពញ្ញុតេន ញាណេន តុលយិត្វា ទយាសយោ
ទេសេសិ បវរំ ធម្មំ អនន្តគុណសញ្ចយោ ។
ស កទាចិ មហាវីរោ អនន្តជនតំ មុនិ(១)
ទេសេសិ មធុរំ ធម្មំ ចតុសច្ចូបសញ្ហិតំ ។
សុត្វាន តំ ធម្មវរំ អាទិមជ្ឈន្តសោភណំ
បាណា សតសហស្សានិ ធម្មាភិសមយោ អហុ ។

១ ម. អនន្តជនតំ សរិ ។ ឱ. អនន្តជនសំសរិ ។



# កាឡុទាយិត្ថេរាបទាន ទី ៦

(១៣៦) ព្រះជិនស្រីព្រះនាមបទុមុត្តរៈ ទ្រង់មានព្រះចក្ខុក្នុងធម៌ទាំងពួង ព្រះអង្គជានាយក កើតឡើង ក្នុងកប្បទីមួយសែន អំពីកប្បនេះ ។ ព្រះសាស្ដាទ្រង់ប្រសើរជាងពួកអ្នកនាំមុខ ទ្រង់ជ្រាបនូវគុណនិងទោស ព្រះអង្គឈ្នះមារ ជាកតញ្ញូកតវេទីបុគ្គល ទ្រង់ញុំាងពួកសត្វឲ្យប្រកប ក្នុងកំពង់គឺធម្មវិន័យ ។ ព្រះអង្គជាសព្វញ្ញូ មានសេចក្ដីករុណាដល់សត្វជាទីអាស្រ័យ ទ្រង់សន្សំនូវគុណរកទីបំផុតគ្មាន ទ្រង់ថ្លឹងមើលដោយញាណនោះ ហើយសំដែងនូវធម៌ ដ៏ប្រសើរ ។ ក្នុងកាលណា ។ ក៏ដោយ ព្រះសាស្ដាមានព្យាយាមខ្លាំង មានការបរិសុទ្ធស្អាតជាងប្រជុំជនជាអនន្ត ទ្រង់សំដែងធម៌ដ៏ពីរោះ ប្រកបដោយសច្ចៈ ៤ ។ ពួកសត្វចំនួនមួយសែន បានត្រាស់ដឹងមគ្គផល ព្រោះបានស្ដាប់នូវធម៌ដ៏ប្រសើរ មានលំអខាងដើម កណ្ដាល និងខាងចុង ។

កម្បិតា ធរណី តត្ថ គជ្ជិំសុ ច បយោធរា
សាធុការំ បវត្តេសុំ ទេវព្រហ្មនរាសុរា ។
អហោ ការុណិកោ សត្ថា អហោ សទ្ធម្មទេសនា
អហោ ភវសមុទ្ទស្មឹ និមុគ្គេ ឧទ្ធរី ជិនោ ។
ឯវំ សំវេគជាតេសុ[1] សនរាមរព្រហ្មេសុ
កុលប្បសាទកានគ្គំ សាវកំ វណ្ណយី ជិនោ ។
តទាហំ ហំសវតិយា ជាតោមច្ចកុលេ អហុំ
បាសាទិកោ ទស្សនីយោ បហូតធនធញ្ញវា ។
ហំសារាមមុបេច្ចាហំ វន្ទិត្វា តំ តថាគតំ
សុណិត្វា មធុរំ ធម្មំ ការំ កត្វា ច តាទិនោ ។
និបច្ច បាទមូលេហំ ឥទំ វចនមព្រវី
កុលប្បសាទកានគ្គោ យោ តវ សាសនេ[2] មុនេ ។

១ ម. ឯវំ សំវេគជាតេសុ ។ ២ ឱ. ម. យោ តយាសន្តោ ។



ក្នុងកាលនោះ ដែនដីក៏លាន់ឮ មេឃក៏គ្រហឹម ពួកទេវតា ព្រហ្ម មនុស្ស អសុរ ក៏ញ៉ាំងសាធុការឲ្យប្រព្រឹត្តទៅថា ១ ព្រះសាស្តាទ្រង់ប្រកបដោយករុណា ១ ព្រះសទ្ធម្មទេសនា ១ ព្រះជិនស្រី ទ្រង់ស្រង់ទេវតា មនុស្សសត្វ ដែលមុជចុះក្នុងសមុទ្រគឺភព ឡើងផុត ។ (កាលបើសត្វទាំងឡាយ) ព្រមទាំងមនុស្ស ទេវតា ព្រហ្ម កើតសេចក្តីសង្វេគយ៉ាងនេះហើយ ព្រះជិនស្រីទ្រង់សរសើរនូវសាវ័ក ដែលប្រសើរជាងបុគ្គលជ្រះថ្លា ក្នុងត្រកូលទាំងឡាយ ។ កាលនោះ ខ្ញុំកើតក្នុងត្រកូលអាមាត្យ ក្នុងហង្សវតីនគរ ជាបុគ្គលប្រកបដោយសេចក្តីជ្រះថ្លា គួរឲ្យរមិលមើល មានទ្រព្យនិងស្រូវច្រើន ។ ខ្ញុំចូលទៅក្នុងហង្សារាម ថ្វាយបង្គំព្រះតថាគតនោះ ស្តាប់នូវធម៌ដ៏ពីរោះ ហើយធ្វើនូវគ្រឿងសក្ការៈ ដល់ព្រះតថាគត ជាតាទិបុគ្គល ។ ខ្ញុំក្រាបទៀបព្រះបាទ ពោលពាក្យនេះថា បពិត្រព្រះមុនី បុគ្គលណា ប្រសើរជាងបុគ្គលអ្នកជ្រះថ្លា ក្នុងត្រកូល ក្នុងសាសនា នៃព្រះអង្គ ។

## ផ្ទុំ កាព្យកាយវិភាគវាទ

តាវិហេសកំ ឧបាវិ(១)   ពុទ្ធសេដ្ឋស្ស សាសនេ

គតោ មហាការុណិកោ   សិញ្ចាគ្គោកមតេន មំ ។

អាហ មំ បុត្ត ទុត្តិដ្ឋ(២)   លទ្ធសតិ នយោជិ

ការឹ យាម ជិនេ ការំ   កតញ្ញូ វិជលោ សិយា ។

សតសហស្សេ ឥតោ កប្បេ   ឱក្កាកកុលសម្ភវោ

គោតមោ នាម នាមេន   សត្ថា លោកេ ភវិស្សតិ ។

តស្ស ធម្មេសុ ទាយាទោ   ឱរសោ ធម្មនិម្មិតោ

ឧបាលិ នាម នាមេន   ហេស្សតិ សត្ថុសាវកោ ។

តំ សុត្វា មុទិតោ ហុត្វា   យាវជីវំ តទា ជិនំ

មេត្តចិត្តោ បរិចរឹ   បច្ចយេហិ វិនាយកំ ។

---

១ ឱ. តាវិសោ ឧបាវិ រឺ ។ ២ ឱ. អាហាំ បុត្ត វុត្តិដ្ឋ ។ ម. អស្សាស បុត្ត ឧត្តិដ្ឋ ។



## កាព្យកាយវិភាគបកាន ទី ៦

បពិត្រព្រះអង្គមានព្យាយាមធំ ខ្ញុំព្រះអង្គ សូមឲ្យបានជាបុគ្គលប្រាកដដូចបុគ្គលនោះ ក្នុងសាសនា នៃព្រះពុទ្ធដ៏ប្រសើរ ។

កាលនោះ ព្រះពុទ្ធ ទ្រង់ប្រកបដោយមហាករុណា ក៏ស្រោចខ្ញុំ ដោយអម្រឹតធម៌ ។ ព្រះពុទ្ធទ្រង់ត្រាស់នឹងខ្ញុំថា ម្នាលបុត្រ ចូរអ្នកក្រោកឡើង អ្នកនឹងបាននូវតំណែងសមដូចបំណងនុ៎ះ បុគ្គលធ្វើនូវការបូជាចំពោះព្រះជិនស្រី នឹងប្រាសចាកផល ដូចម្ដេចកើត ។ ក្នុងកប្បទីមួយសែន អំពីកប្បនេះ ព្រះសាស្ដា ទ្រង់ព្រះនាមគោតម ព្រះអង្គសម្ភពក្នុងឱក្កាកត្រកូល នឹងត្រាស់ឡើងក្នុងលោក ។ បុរសនេះ នឹងបានជាទាយាទក្នុងធម៌តំណពូជ របស់ព្រះសាស្ដានោះ ជាឱរស ដែលធម៌និម្មិតហើយ ឈ្មោះឧបាលិ ជាសាវករបស់ព្រះសាស្ដានោះ ។ កាលនោះ ខ្ញុំបានស្ដាប់ នូវព្រះពុទ្ធដីកានោះហើយ ក៏មានចិត្តរីករាយ មានចិត្តប្រកបដោយមេត្តា បានបម្រើនូវព្រះជិនស្រី ព្រះអង្គជាអ្នកដឹកនាំសត្វ ដោយការបរិក្ខារគឺបច្ច័យទាំងឡាយ ហូតដល់អស់ជីវិត ។

តេន កម្មវិបាកេន   ចេតោបណិធិហេតុ ច
ជហិត្វា មានុសំ ទេហំ   តាវតិំសំ អគច្ឆហំ ។
បច្ឆិមេ ច ភវេ ទានិ   រម្មេ កាបិលវត្ថវេ
ជាតោ មហាមច្ចកុលេ   សុទ្ធោទនេ មហីបតិ ។
យទា អជាយិ សិទ្ធត្ថោ   រម្មេ លុម្ពិនិកាននេ
ហិតាយ សព្វលោកស្ស   សុខាយ ច នរាសភោ ។
តទហេវ អហំ ជាតោ   សហ តេនេវ វឌ្ឍិតោ
បិយោ សហាយោ ទយិតោ   វិស្សដ្ឋោ នីតិកោវិទោ ។
ឯកូនតឹសោ វយសា   និក្ខន្តោ បព្វជី សោ(១)
ឆព្វស្សានិ វីរាយេត្វា   អាសិ ពុទ្ធោ វិនាយកោ ។

---

១ ម. និក្ខមិត្វា អគារតោ ។



ដោយវិបាកនៃកុសលកម្មនោះផង ដោយការតំកល់ទុកចេត-នានោះផង លុះខ្ញុំលះបង់នូវកាយជារបស់មនុស្ស ក៏បានទៅកើត ក្នុងឋានតាវត្តិង្ស ។ ក្នុងភពនេះ ដល់មកបច្ចិមភព ខ្ញុំបានកើតក្នុងត្រកូលអាមាត្យធំ ក្នុងកបិលវត្ថុ ជាទីរីក-រាយ មានព្រះបាទសុទ្ធោទនៈជាម្ចាស់ផែនដី ។ កាលនោះ ព្រះសិទ្ធត្ថកុមារ ជាអ្នកអង់អាចជាងនរជន បានកើតឡើងក្នុងព្រៃលុម្ពិនីជាទីរីករាយ ដើម្បីប្រយោជន៍ ដើម្បីសេចក្ដីសុខ ដល់សព្វសត្វលោក ។ ខ្ញុំកើតក្នុងថ្ងៃនោះដែរ មានវ័យចម្រើនឡើងជាមួយនឹងព្រះសិទ្ធត្ថកុមារនោះ ជាសម្លាញ់ ជាទីស្រឡាញ់ ប្រកបដោយសេចក្ដីអាណិត ជាអ្នកស្និទ្ធស្នាល ឈ្លាសវៃក្នុងនីតិសាស្ត្រ ។ ព្រះសិទ្ធត្ថកុមារនោះ មានវ័យ ២៩ ឆ្នាំ ក៏ចេញទៅបួស ញ៉ាំងកាលឲ្យកន្លងទៅ អស់ ៦ ឆ្នាំ បានត្រាស់ជាព្រះពុទ្ធ ដឹកនាំ (សត្វលោក) ។

ជេត្វា សសេនកំ មារំ   ខេបយិត្វាន អាសវេ
ភវណ្ណវំ តរិត្វាន   ពុទ្ធោ អាសិ សទេវកេ ។
ឥសិបតនំ គន្ត្វា(១)   វិនេត្វា បញ្ចវគ្គិយេ
តតោ វិនេសិ ជនតំ   គន្ត្វា គន្ត្វា តហឹ តហឹ ។
វេនេយ្យេ វិនយន្តោ សោ   សង្គណ្ហន្តោ សទេវកំ
ឧបេច្ច មគធេ គិរឹ   វិហាសិ តទា ជិនោ ។
តទា សុទ្ធោទនេនាហំ   ភូមិបាលេន បេសិតោ
គន្ត្វា ទិស្វា ទសពលំ   បព្វជិត្វារហា អហំ(២) ។
តទា មហេសឹ យាចិត្វា   បាបយឹ កបិលវ្ហយំ
តតោ បុរហំ(៣) គន្ត្វាន   បសាទេសឹ មហាកុលំ ។
ជិនោ តស្មឹ គុណេ តុដ្ឋោ   មមាហ បុរិសាសភោ
កុលប្បសាទកានគ្គំ   បញ្ញាបេសិ វិនាយកោ ។

១ ឱ.ប. គមិត្វាន ។ ២ ឱ.ម. អហុំ ។ ៣ ឱ. បុតាហំ ។





ព្រះអង្គឈ្នះមារព្រមទាំងសេនា ហើយញុំាងអាសវៈឲ្យអស់ ទ្រង់ឆ្លងអន្លង់គឺភព បានជាព្រះពុទ្ធក្នុងមនុស្សលោកនិងទេវលោក ។ ទ្រង់ស្តេចទៅកាន់ព្រៃ ឈ្មោះឥសិបតនៈ ទូន្មានបញ្ចវគ្គិយភិក្ខុ តពីនោះមក ព្រះមានព្រះភាគ ក៏ស្តេចទៅក្នុងទីនោះ ៗ ហើយទូន្មាន (សត្វ) ។ ព្រះមានព្រះភាគនោះ កាលទូន្មានពួកសត្វ ដែលគួរទូន្មាន សង្គ្រោះទាំងមនុស្សនិងទេវតា ស្តេចចូលទៅកាន់ភ្នំក្នុងដែនមគធៈ កាលនោះ ព្រះជិនស្រី ទ្រង់គង់ (លើភ្នំនោះ) ។ ពេលនោះ ខ្ញុំត្រូវព្រះបាទសុទ្ធោទនៈ ជាភូមិបាលបញ្ជូនទៅហើយ ខ្ញុំក៏ទៅ លុះខ្ញុំបានឃើញព្រះទសពលហើយ ក៏បួសបានជាអរហន្ត ។ ខ្ញុំបានអារាធនាព្រះពុទ្ធ ព្រះអង្គស្វែងរកនូវគុណដ៏ធំ ឲ្យចូលទៅកាន់ក្រុងកបិលពស្តុ លំដាប់នោះ ខ្ញុំទៅមុនទៀត បានញុំាងមហាត្រកូលឲ្យជ្រះថ្លា ។ ព្រះជិនស្រីត្រេកអរក្នុងគុណនោះ ព្រះអង្គជាបុរសប្រសើរ ជានាយកដ៏វិសេស បានតាំងខ្ញុំទុកជាអ្នកប្រសើរជាងពួកសាវ័ក អ្នកញុំាងត្រកូលឲ្យជ្រះថ្លា ។

កិលេសា ឈាបិតា មយ្ហំ ភវា សព្វេ សមូហតា
នាគោវ ពន្ធនំ ឆេត្វា វិហរាមិ អនាសវោ ។
ស្វាគតំ វត មេ អាសិ មម ពុទ្ធស្ស សន្តិកេ
តិស្សោ វិជ្ជា អនុប្បត្តា កតំ ពុទ្ធស្ស សាសនំ ។
បដិសម្ភិទា ចតស្សោ វិមោក្ខាបិ ច អដ្ឋិមេ
ឆឡភិញ្ញា សច្ឆិកតា កតំ ពុទ្ធស្ស សាសនន្តិ ។

ឥត្ថំ សុទំ អាយស្មា កាឡុទាយី ថេរោ ឥមា គាថាយោ អភាសិត្ថាតិ ។

កាឡុទាយិត្ថេរស្ស អបទានំ សមត្តំ ។

## សត្តមំ អភយត្ថេរាបទានំ

(១៣៧) បទុមុត្តរោ នាម ជិនោ សព្វធម្មេសុ ចក្ខុមា(១)
ឥតោ សតសហស្សម្ហិ កប្បេ ឧប្បជ្ជិ នាយកោ ។
សរណាគមនេ កោចិ(២) និវេសេសិ តថាគតោ
កោចិ(៣) សីលេ និវេសេសិ ទសកម្មបថុត្តមេ ។

១ ឱ. ម. បក្ខុមា ។ ២ ឱ. កញ្ចិ ។ ឱ. កិញ្ចិ ។ ៣ ឱ. សមាបត្តិកស្ស បន្តិ ។



កិលេសទាំងឡាយ ខ្ញុំដុតបំផ្លាញហើយ ភពទាំងអស់ ខ្ញុំផ្តាច់ចោលហើយ ខ្ញុំជាអ្នកមិនមានអាសវៈ ព្រោះឲ្យកាត់ចំណង ដូចជាដំរីកាត់ផ្តាច់នូវចំណង ។ ឱ ! ខ្ញុំមកល្អហើយ ក្នុងសំណាក់ព្រះពុទ្ធ របស់ខ្ញុំ ។ វិជ្ជា ៣ ខ្ញុំបានសម្រេចហើយ សាសនា របស់ព្រះពុទ្ធ ខ្ញុំបានធ្វើហើយ ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនា របស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ។

បានឮថា ព្រះកាឡុទាយិត្ថេរ មានអាយុ បានសម្តែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

ចប់ កាឡុទាយិត្ថេរាបទាន ។

## អភយត្ថេរាបទាន ទី ៧

(១៣៧) ព្រះជិនស្រី ព្រះនាមបទុមុត្តរៈ ព្រះអង្គដល់នូវត្រើយ នៃធម៌ទាំងពួង ជានាយក ទ្រង់កើតឡើង ក្នុងកប្បទីមួយសែន អំពីកប្បនេះ ។ ព្រះតថាគត ទ្រង់ញុំាងពួកសត្វខ្លះ ឲ្យតាំងនៅក្នុងសរណគមន៍ ញុំាងពួកសត្វខ្លះ ឲ្យតាំងនៅក្នុងសីល និងកម្មបថ ១០ ដ៏ឧត្តម ។

ទេតិ កស្សចិ សោ វីរោ សាមញ្ញផលមុត្តមំ

សមាបត្តី តថា អដ្ឋ(១) តិស្សោ វិជ្ជា បវេច្ឆតិ ។

ឆឡភិញ្ញាសុ យោជេតិ កញ្ចិ សត្តេ នរុត្តមោ

ទេតិ កស្សចិ សោ នាថោ ចតស្សោ បដិសម្ភិទា ។

ពោធនេយ្យំ បជំ ទិស្វា អសង្ខេយ្យេបិ យោជនេ

ខណេន ឧបគន្ត្វាន វិនេតិ នរសារថិ ។

តទាហំ ហំសវតិយំ អហោសិំ ព្រាហ្មណត្រជោ

បារគូ សព្វវេទានំ វេយ្យាករណសម្មតោ ។

និរុត្តិយា ច កុសលោ និឃណ្ឌុ ច(២) វិសារទោ

បទកោ កេដុភវិទូ ឆន្ទោវិចិតិកោវិទោ ។

ជង្ឃាវិហារំ វិចរំ ហំសារាមំ ឧបេច្ចហំ

អទ្ទសំ វរទំ សេដ្ឋំ មហាជនបុរក្ខតំ ។

---

១ ម. សមាបត្តិស្ស ចត្ថ ។ ២ ឧ. និឃណ្ឌុ ច ។ ម. និឃណ្ឌុម្ហិ ។



ព្រះអង្គជាអ្នកប្រាជ្ញ ទ្រង់ប្រទាននូវសាមញ្ញផលដ៏ឧត្តម ដល់ពួកសត្វខ្លះ ម្យ៉ាងទៀត ទ្រង់ញ៉ាំងសត្វខ្លះឲ្យត្រាស់ដឹង នូវសមាបត្តិ ៨ វិជ្ជា ៣ ។ ព្រះឧត្តម ទ្រង់ញ៉ាំងសត្វពួកខ្លះ ឲ្យប្រកបក្នុងអភិញ្ញា ៦ ព្រះលោកនាថនោះ ទ្រង់ប្រទាននូវ បដិសម្ភិទា ៤ ដល់ពួកសត្វខ្លះ ។ ព្រះឧសភៈ ទ្រង់ឃើញ នូវពួកសត្វ ដែលគួរទូន្មានឲ្យត្រាស់ដឹងបាន សូម្បីនៅក្នុង ចម្ងាយមួយអសង្ខេយ្យយោជន៍ ក៏ស្តេចទៅទូន្មានដោយ មួយរំពេចបាន ។ កាលនោះ ខ្ញុំកើតជាព្រាហ្មណ៍ ក្នុង ក្រុងហង្សវតី បានដល់នូវត្រើយនៃវេទទាំងពួង ចេះចប់នូវ វេយ្យាករណ៍ ។ ជាអ្នកឈ្លាសក្នុងនិរុត្តិផង ក្លៀវក្លាក្នុងគម្ពីរ ឈ្មោះនិឃណ្ឌុផង រៀនទ្រូបទផង ចេះនូវគម្ពីរឈ្មោះកេ- ដុភៈផង ឈ្លាសវៃដ៏វិចិត្រក្នុងឆន្ទសាស្ត្រផង ។ ខ្ញុំកាល ត្រាច់ទៅកាន់ទីសម្រាកស្ងួន ក៏ចូលទៅក្នុងហង្សារាម បាន ឃើញព្រះសម្ពុទ្ធប្រសើរថ្លៃថ្លា មានមហាជនចោមរោម ។

ទេសេន្តំ វិវិធំ ធម្មំ  បញ្ហំ ការយតី អហំ

ឧបេត្វា តស្ស ភាស្យានំ(១)  សុត្វាន វិមលាននំ ។

ព្យាហតំ បុនរុត្តិ ច  អបត្ថំ ច(២) និរត្ថកំ

នាទ្ទសំ តស្ស មុនិនោ  អតោ បត្ថិតោ អហំ ។

ន ចិរេនេវ កាលេន  សត្ថុត្វាបិ(៣) វិសារទោ

និបុណោ ពុទ្ធវចនេ  អហោសិ គណិសម្មតោ ។

តតោ ចតស្សោ គាថាយោ  គន្ថយិត្វា សុព្យញ្ជនា

សន្ថវិត្វា តិលោកគ្គំ  ទេសយិស្សំ ទិនេ ទិនេ ។

វិរត្តោសិ មហាវីរ  សំសារេ សភយេ វសិ

ការុញ្ញាយ ន និព្ពាយិ  តតោ ការុណិកោ មុនិ ។

---

១ ម. កល្យាណំ ។ ២ ម. អសត្ថំ ច ។ ៣ ឱ. សន្ថុត្វា ។ ម. សត្ថុត្វា ។





ខ្ញុំជាអ្នកដឹងនូវបដ្ឋិកធម៌ បានចូលទៅគាល់ព្រះមានព្រះភាគ ព្រះអង្គកំពុងសំដែងធម៌ ដែលប្រាសចាកធូលី ខ្ញុំបានស្តាប់ព្រះពុទ្ធដីការបស់ព្រះអង្គ ដែលជាពាក្យមិនមានមន្ទិល ។ ខ្ញុំមិនឃើញនូវការគាំងគ្នាក់ ដែលលម្អៀងបៀតបៀនបាន ឬនូវហេតុមិនជាទីប្រាថ្នា ឬក៏នូវអំពើមិនមានប្រយោជន៍ របស់ព្រះមុនីនោះសោះ លំដាប់នោះ ខ្ញុំក៏បួស (ក្នុងសំណាក់នៃព្រះអង្គ) ។ អស់កាលមិនយូរប៉ុន្មាន ខ្ញុំជាបុគ្គលក្លៀវក្លា ក្នុងទីតាំងក្នុង គេសន្មតថាជាអ្នកមានគណៈ ក្នុងពុទ្ធវចនៈដ៏ល្អិតល្អន់ ។ កាលនោះ ខ្ញុំបានក្រងនូវគាថា ៤ មានព្យញ្ជនៈដ៏ល្អ ហើយសរសើរព្រះពុទ្ធ ជាកំពូលនៃត្រៃលោក ហើយសំដែងធម៌រាល់ៗថ្ងៃ ។ ព្រះមហាវីរៈ ព្រះអង្គនៅក្នុងសង្សារដែលប្រកបដោយភ័យ ទ្រង់មានព្រះទ័យនឿយណាយ តែទ្រង់មិនទាន់និព្វាន ព្រោះមានសេចក្តីករុណា ហេតុនោះ ព្រះមុនី ឈ្មោះថាមានសេចក្តីករុណា ។

បជ្ជោតោ យោ សន្តោ ច កិលេសសោ អប្បុ

សម្បជានោ សតិយុត្តោ តស្មា បិសោ អចិន្តិយោ ។

ឧព្វលានំ កិលេសានំ យស្សាសយគតានំ មេ

ញាណគ្គិបរិដ្ឋានំ ន ចយិស្សុ ឧនត្តកិំ ។

យោ សព្វលោកស្ស គរុ លោកោ យស្ស គតោ គរុ

តថាបិ លោកាចរិយោ លោកោ តស្សានុវត្តតោ ។

ឯវមាទីហិ សន្ថុតី កិត្តយិំ ធម្មទេសនំ

យាវជីវំ ករិត្វាន គតោ សគ្គំ ឥតោ ចុតោ ។

សតសហស្សេតោ កប្បេ យំ ពុទ្ធមភិកិត្តយិំ

ទុគ្គតិំ នាភិជានាមិ កិត្តនាយ ឥទំ ផលំ ។





សត្វណាដែលជាប្រចង្កៀង ដែលមិនលុះក្នុងអំណាចកិលេស ជាអ្នកមានការដឹងខ្លួន ប្រកបដោយសតិ ហេតុនោះ សត្វនុះព្រះអង្គមិនគួរគិត ។ ពួកកិលេសរបស់ខ្ញុំណា ដែលមានកម្លាំងខ្សោយ តាំងនៅតាមគន្ធ ដែលភ្លើងគឺមគ្គញាណដុតកំដៅហើយ មិនតាំងអស់លើងនៅឡើយ (កិលេសទាំងឡាយ) របស់ខ្ញុំនោះ មិនកើតឡើងទៀតទេ ។ បុគ្គលណា ជាគ្រូនៃលោកទាំងពួង ម្យ៉ាងទៀត គ្រូនៃបុគ្គលណា គឺលោក ឬជាគោរពក្នុងលោក លោកប្រព្រឹត្តទៅតាមបុគ្គលនោះដោយពិត ។ ខ្ញុំសរសើរព្រះសម្ពុទ្ធ និងធម្មទេសនា (នៃព្រះអង្គ) ដោយពាក្យទាំងឡាយ មានយ៉ាងនេះជាដើម ហើយធ្វើ (សេចក្តីគោរព) ដរាបដល់អស់ជីវិត លុះខ្ញុំច្យុតអំពីអត្តភាពនោះ ក៏បានទៅកើតក្នុងឋានសួគ៌ ។ ក្នុងកប្បទីមួយសែនអំពីកប្បនេះ ព្រោះហេតុដែលខ្ញុំសរសើរព្រះពុទ្ធ ក្នុងកាលនោះ ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃការសរសើរ ។

ទេវលោកេ(១) មហារជ្ជំ ទិព្វំ ការេសិំ ភាគសោ(២)
ចក្កវត្តិមហារជ្ជំ ពហុសោ ការយឹ អហំ ។
ទុវេ ភវេ សំសរាមិ ទេវត្តេ អថ មានុសេ
អញ្ញំ គតឹ ន ជានាមិ កិត្តនាយ ឥទំ ផលំ ។
ទុវេ កុលេ បជាយាមិ ខត្តិយេ អថ ព្រាហ្មណេ
នីចេ កុលេ ន ជានាមិ កិត្តនាយ ឥទំ ផលំ ។
បច្ឆិមេ ច ភវេ ទានិ គិរិព្វជបុរុត្តមេ
រញ្ញោហំ ពិម្ពិសារស្ស បុត្តោ នាមេន អភយោ ។
បាបមិត្តវសំ គន្ត្វា និគណ្ឋេន វិមោហិតោ(៣)
បេសិតោ នាដបុត្តេន ពុទ្ធសេដ្ឋំ ឧបេច្ចហំ ។
បុច្ឆិត្វា និបុណំ បញ្ហំ សុត្វា ព្យាករណុត្តមំ
បព្វជិត្វាន ន ចិរំ អរហត្តំ អបាបុណឹ ។
កិត្តយិត្វា ជិនវរំ កិត្តិតោ ហោមិ សព្វទា
សុគន្ធទេហវទនោ អាសឹ សុខសមប្បិតោ ។

---

១ ម. ទេវរជ្ជំ ។ ២ ឱ. រជ្ជំ ទេវសិកញ្ញយំ ។ ម. ពាទេសំ កញ្ញាសត្ថយំ ។ ៣ ឱ. ម. វិមោហិតោ ។



កាលនោះ ខ្ញុំសោយរាជ្យជាស្តេចធំ ក្នុងទេវលោកដ៏ជាទិព្វ ហើយខ្ញុំសោយរាជ្យ ជាស្តេចមហាចក្រពត្តិ ជាច្រើនជាតិ ។ ខ្ញុំកើតតែក្នុងគតិពីរ គឺទេវតានិងមនុស្ស ខ្ញុំមិនស្គាល់គតិដទៃទេ នេះជាផលនៃការសរសើរ ។ ខ្ញុំកើតតែក្នុងត្រកូលពីរ គឺត្រកូលក្សត្រនិងត្រកូលព្រាហ្មណ៍ ខ្ញុំមិនស្គាល់ត្រកូលទាបឡើយ នេះជាផលនៃការសរសើរ ។ ក្នុងភពនេះ ដល់មកក្នុងបច្ឆិមភព ខ្ញុំមានឈ្មោះថាអភ័យ ជាបុត្ររបស់ព្រះបាទពិម្ពិសារ ក្នុងគិរិព្វជបុរីដ៏ឧត្តម ។ ខ្ញុំលុះអំណាចនៃបាបមិត្ត ត្រូវពួកនិគ្រន្ថបញ្ឆោតហើយ ដែលត្រូវឈ្មោះនាដបុត្តប្រើទៅ ខ្ញុំក៏ចូលទៅគាល់ព្រះពុទ្ធដ៏ប្រសើរ ។ ខ្ញុំសួរនូវប្រស្នាដ៏ល្អិត ស្តាប់នូវព្យាករណ៍ដ៏ឧត្តម ហើយក៏បព្វជ្ជា អស់កាលមិនយូរប៉ុន្មាន ក៏បាននូវព្រះអរហត្ត ។ ខ្ញុំសរសើរព្រះជិនស្រីដ៏ប្រសើរ ត្រូវគេសរសើរសព្វកាល ជាបុគ្គលមានកាយនិងមាត់មានក្លិនក្រអូបល្អ ផ្អែតស្កប់ស្កល់ដោយសេចក្តីសុខ ។

## សត្តមំ ភាណវារំ

តិក្ខហាសលហុប្បញ្ញោ មហាបញ្ញោ តថេវហំ
វិចិត្តបដិភានោ ច តស្ស កម្មស្ស វាហសា ។

អភិត្ថវិត្វា បទុមុត្តរាហំ
បសន្នចិត្តោ អសមំ សយម្ភុំ
ហេតន្ធិ កាព្យានំ អមោយគ្គុំ
សតំសហស្សានិ ផលេន តស្ស ។

កិលេសា ឈាបិតា មយ្ហំ ភវា សព្វេ សមូហតា
នាគោវ ពន្ធនំ ឆេត្វា វិហរាមិ អនាសវោ ។
ស្វាគតំ វត មេ អាសិ ពុទ្ធសេដ្ឋស្ស សន្តិកេ
តិស្សោ វិជ្ជា អនុប្បត្តា កតំ ពុទ្ធស្ស សាសនំ ។
បដិសម្ភិទា ចតស្សោ វិមោក្ខាបិ ច អដ្ឋិមេ
ឆឡភិញ្ញា សច្ឆិកតា កតំ ពុទ្ធស្ស សាសនន្តិ ។



## ភាណវារៈ ទី ៧

ខ្ញុំជាបុគ្គលមានប្រាជ្ញាមុត មានប្រាជ្ញាដ៏រីករាយ និងរហ័ស មានប្រាជ្ញាច្រើន មានបដិភាណដ៏វិចិត្រ ព្រោះអានិសង្ស នៃកុសលកម្មនោះ ។

ខ្ញុំមានចិត្តជ្រះថ្លា បានសរសើរព្រះសយម្ភូ ព្រះនាម បទុមុត្តរៈ ឥតមានបុគ្គលស្មើ ខ្ញុំមិនទៅកាន់អបាយ-

ភូមិ អស់មួយសែនកប្ប ដោយផលនៃកម្មនោះ ។

កិលេសទាំងឡាយ ខ្ញុំដុតបំផ្លាញហើយ ភពទាំងអស់ ខ្ញុំដកចោលហើយ ខ្ញុំជាអ្នកមិនមានអាសវៈ ព្រោះបានកាត់ចំ-ណង ដូចជាដំរីកាត់ផ្ដាច់នូវទន្លីង ។ ឱ ! ខ្ញុំមកល្អហើយ ក្នុងសំណាក់ព្រះពុទ្ធដ៏ប្រសើរ វិជ្ជា ៣ ខ្ញុំបានសម្រេចហើយ សាសនា របស់ព្រះពុទ្ធ ខ្ញុំបានធ្វើហើយ ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនា របស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ។

ឥត្ថំ សុទំ អាយស្មា អភយោ ថេរោ ឥមា គាថា-យោ អភាសិត្ថាតិ ។

អភយត្ថេរស្ស អបទានំ សមត្តំ ។

## អដ្ឋមំ លោមសកិយត្ថេរាបទានំ

(១៣៨) ឥមម្ហិ ភទ្ទកេ កប្បេ ព្រហ្មពន្ធុ មហាយសោ
កស្សបោ នាម នាមេន ឧប្បជ្ជិ វទតំ វរោ ។
តទាហំ ចន្ទនោ ចេវ បព្វជិត្វាន សាសនេ
អាបាណកោដិយំ ធម្មំ(១) បូរយិត្វាន សាសនេ ។
តតោ ចុតា សន្តុសិតំ ឧបបន្នា ឧភោ មយំ
តត្ថ ទិព្វេហិ នច្ចេហិ គីតេហិ វាទិតេហិ ច ។
រូបាទិទសហង្គេហិ អភិភោត្វាន សេសកេ
យាវតាយុំ វសិត្វាន អនុភោត្វា មហាសុខំ ។
តតោ ចវិត្វា តិទសំ ចន្ទនោ ឧបបជ្ជថ(២)
អហំ កបិលវត្ថុស្មឹ អជាយឹ(៣) សាកិយត្រជោ ។

១ ឱ.ម. អាបាណកោដិកំ ធម្មំ ។ ២ ម. ឧបបជ្ជិ ។ ៣ ឱ. អជាយិ ។



បានឮថា ព្រះអភយត្ថេរ មានអាយុ បានសំដែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

ចប់ អភយត្ថេរាបទាន ។

## លោមសកិយត្ថេរាបទាន ទី ៨

(១៣៨) ក្នុងភទ្ទកប្បនេះ ព្រះពុទ្ធទ្រង់ព្រះនាមកស្សប មានផៅពង្សដ៏ប្រសើរ មានយសធំ ប្រសើរជាងអ្នកពោលទាំងឡាយ ទ្រង់កើតឡើង ។ កាលនោះ ខ្ញុំនិងចន្ទនបុរស បានបួសក្នុងសាសនា បានបំពេញកុសលកម្ម ក្នុងសាសនា ក្នុងទីបំផុតនៃជីវិត ។ យើងទាំងពីរនាក់ ច្យុតអំពីអត្តភាពនោះ ហើយបានទៅកើត ក្នុងឋានតុសិត បរិបូណ៌ដោយការរាំ ច្រៀង និងប្រគំជាទិព្វ ក្នុងទីនោះ ។ គ្របសង្កត់ទេវតាដ៏សេសទាំងឡាយ ដោយអង្គទាំង ១០ មានរូបជាដើម នៅទទួលសេចក្តីសុខ ដរាបដល់អស់ជីវិត ។ លុះច្យុតអំពីនោះមក ចន្ទនបុរសទៅកើតក្នុងឋានត្រៃត្រិង្ស ចំណែកខ្ញុំ បានកើតក្នុងក្រុងកបិលពស្តុ ជាកូននៃសាក្យៈ ។

## អដ្ឋមំ ញាតិសមាគមកថំ

យទា ឧទាយិថេរេន អជ្ឈិដ្ឋោ លោកនាយកោ
អនុកម្បិយ សក្យានំ ឧបេសិ កបិលវ្ហយំ ។
តទាតិមានិនោ សក្យា ន ពុទ្ធស្ស គុណញ្ញោ
បណាមន្តិ ន សម្មុខំ ជាតិថទ្ធា អជានកា ។
តេសំ សត្ថាបមញ្ញាយ អាកាសេ ចង្កមិ ជិនោ
បជ្ជោតយ រស្មិហិ បជ្ជលិត្ត យថា សិខី ។
ទស្សេត្វា រូបមតុលំ ទេន អត្តនាយថ
ឯកោបិ ហុត្វា ពហុធា អហោសិ បុនរេកកោ ។
អន្ធការំ បកាសញ្ច ទស្សយិត្វា អនេកធា
បាដិហារិំ ករិត្វាន វិនយិ ញាតកេ មុនិ ។
ចាតុទ្ទីបោ មហាមេឃោ តាវទេ បវស្សថ
តទា ហិ ជាតកំ ពុទ្ធោ វេស្សន្តរមទេសយិ ។
តទា តេ ខត្តិយា សព្វេ និហត្វា ជាតិជំ មទំ
ឧបេសុំ សរណំ ពុទ្ធំ [illegible] តទា ។



## ញាតិសមាគមកថា ទី ៨

ព្រះលោកនាយក កាលឧទាយិត្ថេរអារាធនាហើយ ទ្រង់អនុ-គ្រោះដល់ពួកសាក្យៈ បានស្តេចទៅកាន់ក្រុងកបិលពស្តុ ។ កាលនោះ ពួកសាក្យៈមានសេចក្តីមើលងាយ មិនស្គាល់គុណរបស់ព្រះពុទ្ធ ជាអ្នករឹងត្អឹងប្រកាន់ជាតិ មិនអើពើ មិនថ្វាយបង្គំព្រះសម្ពុទ្ធ ព្រះជិនស្រីទ្រង់ជ្រាបនូវការត្រិះរិះរបស់សាក្យៈទាំងនោះហើយ ក៏ចង្ក្រមក្នុងអាកាស បំភ្លឺដូចជាមេឃ ក៏ព្រោលដូចជាអណ្តាតភ្លើង ។ ព្រះអង្គបង្ហាញនូវរូបឥតមានទីប្រៀប ហើយបាត់ទៅវិញ ធ្វើព្រះអង្គតែមួយអង្គ ឲ្យជាច្រើនអង្គ ធ្វើច្រើនអង្គឲ្យជាមួយព្រះអង្គវិញ ។ ព្រះអង្គជាអ្នកប្រាជ្ញ ទ្រង់សំដែងនូវងងឹតផង ពន្លឺផង ដោយច្រើន ហើយធ្វើនូវបាដិហារ្យ ទូន្មានពួកញាតិ ។ ខណៈនោះ ទ្វីបទាំង ៤ មានភ្លៀងធំបង្អុរចុះ កាលនោះ ព្រះពុទ្ធទ្រង់សំដែងវេស្សន្តរជាតក ។ ពួកក្សត្រទាំងអស់នោះ ក៏កំចាត់នូវសេចក្តីស្រវឹង ដែលកើតអំពីជាតិ យកព្រះពុទ្ធជាទីពឹង ឯព្រះគោតមសុគតនោះ ទ្រង់ពោលថា

ឥទំ តតិយំ តវ ភូរិបញ្ញ
បាទានិ វន្ទាមិ សមន្តចក្ខុ
យទា ហិ ជាតោ បថវី បកម្បយិ(១)
យទា ច តំ ឧជ្ជហិ ជម្ពុឆាយា ។

តទា ពុទ្ធានុភាវំ ទិស្វា វិម្ហិតមានសោ
បព្វជិត្វាន តស្សេវ និវសឹ មាតុបូជកោ ។
ចន្ទនោ ទេវបុត្តោ មំ ឧបគន្ត្វា អបុច្ឆថ
ភទ្ទេករត្តស្ស តទា សង្ខេបវិត្ថារំ នយំ(២) ។
ចោទិតោហំ តទា តេន ឧបេត្វ នរនាយកំ
ភទ្ទេករត្តំ សុត្វាន សំវិគ្គោ វនមាគមោ ។
តទា មាតរមាបុច្ឆិ វនេ វច្ឆាមិ ឯកកោ
សុខុមាលោសិ មេ មាតា ភាសយំ មេ តទា វចំ ។

១ ឱ. បកម្បសិ ។ ២ ឱ. សង្ខេបវិត្ថារយំ នយំ ។



បពិត្រព្រះអង្គមានបញ្ញា ដូចជាផែនដី មានចក្ខុជុំវិញ ខ្ញុំថ្វាយបង្គំព្រះបាទា របស់ព្រះអង្គ ជាគំរប់ ៣ ដងនឹង នេះហើយ គឺកាលព្រះអង្គកើត ផែនដីញាប់ញ័រ (ខ្ញុំថ្វាយបង្គំម្តង) កាលម្លប់ព្រីងមិនលះបង់ព្រះអង្គ (ខ្ញុំថ្វាយបង្គំម្តង ឥឡូវនេះ ខ្ញុំថ្វាយបង្គំម្តងទៀត) ។

កាលនោះ ខ្ញុំឃើញនូវអានុភាព របស់ព្រះពុទ្ធនោះ ក៏មានចិត្តទន់ បានចូលបួស ជាអ្នកបូជាមាតា នៅក្នុងសំណាក់របស់ព្រះអង្គនោះ ។ កាលនោះ ចន្ទនទេវបុត្តចូលទៅរកខ្ញុំ សួរនូវន័យដ៏សង្ខេបនិងពិស្តារ នៃភទ្ទេករត្តសូត្រ ។ ខ្ញុំត្រូវចន្ទនទេវបុត្តនោះដាស់តឿនហើយ ក៏ចូលទៅគាល់ព្រះនរនាយក ស្តាប់នូវភទ្ទេករត្តសូត្រ មានចិត្តតក់ស្លុត ក៏ពេញចិត្តនឹងទៅក្នុងព្រៃ ។ កាលនោះ ខ្ញុំលាមាតា ជាបុគ្គលម្នាក់ឯងទៅក្នុងព្រៃ មាតាខ្ញុំឃាត់ថា អ្នកជាបុគ្គលធ្លាប់បម្រើដោយសេចក្តីសុខ កាលនោះ ខ្ញុំបាននិយាយនឹងមាតាបិតាតាំងនោះ ។

ទព្វំ(១) កុសំ បោដកិលំ ឧសីរំ មុញ្ជបព្វជំ

ឧរសា បនុទិស្សាមិ(២) វិវេកមនុព្រូហយំ ។

តតោ វនំ បវិដ្ឋាហំ សរិត្វា ជិនសាសនំ

ភទ្ទេករត្តោវាទំ អរហត្តំ អបាបុណិំ ។

អតីតំ នាន្វាគមេយ្យ នប្បដិកង្ខេ អនាគតំ

យទតីតម្បហីនន្តំ(៣) អប្បត្តញ្ច អនាគតំ ។

បច្ចុប្បន្នញ្ច យោ ធម្មំ តត្ថ តត្ថ វិបស្សតិ

អសំហីរំ អសង្កុប្បំ តំ វិទ្វា មនុព្រូហយេ(៤) ។

អជ្ជេវ កិច្ចមាតប្បំ កោ ជញ្ញា មរណំ សុវេ

ន ហិ នោ សង្គរន្តេន មហាសេនេន មច្ចុនា ។

---

១ ឱ. ទព្ពំ ។ ឱ. កាសំ ។ ២ ឱ. បនុទហិស្សាមិ ។ ៣ ឱ. យទតីតំ បហីនន្តំ ។ ៤ ឱ. សំវិទ្ធមនុព្រូហយេ ។





ខ្ញុំបានចុះការទៅស្មៀវត្រង់ ចាស់ ស្បែកស្ពោស ស្មៀយោ-ប្រង់ ស្មៀវដំណាក់ទន្ទ្រាយតាំងអស់ ដោយទ្រូង ហើយចម្រើននូវវិវេក ។ កាលនោះ ខ្ញុំចូលទៅក្នុងព្រៃ រឭកនូវភទ្ទេករត្តសូត្រ ដែលជាពាក្យប្រៀនប្រដៅព្រះជិនស្រី ហើយបានដល់អរហត្ត ។ បុគ្គលមិនត្រូវអាឡោះអាល័យនូវបញ្ចក្ខន្ធដែលកន្លងទៅហើយទេ មិនត្រូវប្រាថ្នាបញ្ចក្ខន្ធដែលជាអនាគតទេ ព្រោះបញ្ចក្ខន្ធណា ជាអតីត បញ្ចក្ខន្ធនោះ កន្លងផុតទៅហើយ បញ្ចក្ខន្ធណា ជាអនាគត បញ្ចក្ខន្ធនោះ ក៏មិនទាន់មកដល់ ។ បុគ្គលណាពិចារណាឃើញច្បាស់ នូវធម៌ជាបច្ចុប្បន្ន ក្នុងទីនោះៗ បុគ្គលនោះ លុះដឹងច្បាស់នូវព្រះនិព្វាន ដែលមិនញាប់ញ័រ មិនបានកម្រើកនោះ គប្បីចម្រើនឲ្យរឿយៗ ។ ការព្យាយាមជាគ្រឿងដុតកិលេស បុគ្គលគួរតែធ្វើក្នុងថ្ងៃនេះឯង អ្នកណាដឹងថា សេចក្តីស្លាប់នឹងមាន ក្នុងថ្ងៃស្អែកបាន ព្រោះថា យើងតទល់នឹងមច្ចុ ដែលមានសេនាច្រើននោះ មិនបានសោះឡើយ ។

ឯវំវិហារិមាតាបឹ អហោរត្តមតន្ទិតំ
តំ វេ ភទ្ទេករត្តោតិ សន្តោ អាចិក្ខតេ មុនិ ។
កិលេសា ឈាបិតា មយ្ហំ ភវា សព្វេ សមូហតា
នាគោវ ពន្ធនំ ឆេត្វា វិហរាមិ អនាសវោ ។
ស្វាគតំ វត មេ អាសិ មម ពុទ្ធស្ស សន្តិកេ
តិស្សោ វិជ្ជា អនុប្បត្តា កតំ ពុទ្ធស្ស សាសនំ ។
បដិសម្ភិទា ចតស្សោ វិមោក្ខាបិ ច អដ្ឋិមេ
ឆឡភិញ្ញា សច្ឆិកតា កតំ ពុទ្ធស្ស សាសនំ ។

ឥត្ថំ សុទំ អាយស្មា លោមសកង្គិយោ ថេរោ ឥមា គាថាយោ អភាសិត្ថាតិ ។

លោមសកង្គិយត្ថេរស្ស អបទានំ សមត្តំ ។



អ្នកប្រាជ្ញស្ងប់រម្ងាប់ តែងហៅបុគ្គល ដែលមានវិហារធម៌យ៉ាងនេះ មានព្យាយាមដុតកំដៅកិលេស មិនខ្ជិលច្រអូស អស់ថ្ងៃនិងយប់នោះឯង ថាជាអ្នកមានរាត្រីមួយដ៏ចំរើន ។ កិលេសទាំងឡាយ ខ្ញុំដុតបំផ្លាញហើយ ភពទាំងអស់ ខ្ញុំដកចោលហើយ ខ្ញុំជាអ្នកមិនមានអាសវៈ ព្រោះបានកាត់ចំណង ដូចជាដំរីកាត់ផ្តាច់នូវទន្លីង ។ ឱ! ខ្ញុំមកល្អហើយ ក្នុងសំណាក់ព្រះពុទ្ធរបស់ខ្ញុំ វិជ្ជា ៣ ខ្ញុំបានសម្រេចហើយ សាសនារបស់ព្រះពុទ្ធ ខ្ញុំបានធ្វើហើយ ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនា របស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ។

បានឮថា ព្រះលោមសកង្គិយត្ថេរ មានអាយុ បានសំដែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

ចប់ លោមសកង្គិយត្ថេរាបទាន ។

## នវមំ វិបុឡោរាបទានំ

(១៣៩) ឥមម្ហិ ភទ្ទកេ កប្បេ ព្រហ្មពន្ធុ មហាយសោ
កស្សបោ នាម នាមេន ឧប្បជ្ជិ វទតំ វរោ ។
តទាហំ បព្វជិត្វាន តស្ស ពុទ្ធស្ស សាសនេ
យាវជីវំ ចរិត្វាន ព្រហ្មចរិយំ(១) ឥតោ ចុតោ ។
តេន កម្មេន សុកតេន ចេតនាបណិធីហិ ច
ជហិត្វា មានុសំ ទេហំ តាវតឹសំ អគច្ឆហំ ។
ឥតោ ចុតោ អរញ្ញម្ហិ កបោតោ អាសហំ ឥហំ
វសតេ គុណសម្បន្នោ ភិក្ខុ ឈានរតោ សទា ។
មេត្តចិត្តោ ការុណិកោ សទា បមុទិតាននោ
ឧបេក្ខកោ មហាវីរោ អប្បមញ្ញាសុ កោវិទោ ។

១ ម. ព្រហ្មចារី ។



## វិបុឡោរាបទាន ទី ៩

(១៣៩) ក្នុងភទ្ទកប្បនេះ ព្រះសម្ពុទ្ធព្រះនាមកស្សបៈ មានផៅពង្សប្រសើរ មានយសធំ ទ្រង់ប្រសើរជាងអ្នកប្រាជ្ញទាំងឡាយ ទ្រង់កើតឡើងហើយ ។ កាលនោះ ខ្ញុំបួសក្នុងសាសនានៃព្រះពុទ្ធនោះ ប្រព្រឹត្តព្រហ្មចារ្យ ដរាបអស់ជីវិត ហើយច្យុតចាកអត្តភាពនោះ ។ ដោយកុសលកម្មដែលខ្ញុំធ្វើល្អនោះផង ដោយការតំកល់ចេតនានោះផង លុះខ្ញុំលះបង់រាងកាយជារបស់មនុស្សហើយ ក៏បានទៅកើតក្នុងឋានតាវ-ត្តិង្ស ។ ខ្ញុំច្យុតចាកឋានតាវត្តិង្សនោះ មកកើតជាព្រាបនៅក្នុងព្រៃ មានភិក្ខុមួយរូបបរិបូណ៌ដោយគុណ ត្រេកអរក្នុងឈាន នៅក្នុងទីនោះ សព្វកាល ។ (ភិក្ខុនោះ) មានមេត្តាចិត្ត មានសេចក្តីករុណា មានមុខរីករាយសព្វកាល ប្រកបដោយឧ-បេក្ខា មានព្យាយាមធំ ឈ្លាសក្នុងអប្បមញ្ញាទាំងឡាយ ។

វិជីវណសន្តិព្យោ សត្ថុ បត្តហិតាសយោ(១)
វិស្សដ្ឋោ ន ចិរេនាសិំ(២) តស្មិំ សុគតសាវកេ ។
ឧបេច្ច បាទមូលម្ហិ និសិន្នស្ស គតាស្សមេ
កទាចិ អាមិសំ ទេតិ ធម្មំ ទេសេសិ ចេកទា ។
តទា វិបុលបេមេន ឧបាសិត្វា ជិនត្រជំ
តតោ ចុតោ គតោ សគ្គំ បវាសោ សឃរំ យថា ។
សគ្គា ចុតោ មនុស្សេសុ និព្វត្តោ បុញ្ញកម្មុនា
អគារំ ឆឌ្ឌយិត្វាន បព្វជឹ ពហុសោ អហំ ។
សមណោ តាបសោ ទិជោ(៣) បរិព្វាជោ តថេវហំ
ហុត្វា វសឹ អរញ្ញម្ហិ អនេកសតសោ អហំ ។

១ ម. សព្វសត្តហិតាសយេ ។ ២ ខ. ន ចិរេនស្មិំ ។ ៣ ម.ម. វិប្បោ ។



ខ្ញុំមានសេចក្តីត្រេកអរ ព្រោះសាសនាគម្ពីរណៈ មានអត្ថប្រយោជន៍ដល់សព្វសត្វ មិនយូរប៉ុន្មាន ក៏ស្និទ្ធស្នាលចំពោះសាវ័កនៃព្រះសុគតនោះ ។ កាលនោះ ខ្ញុំចូលទៅទៀបបាទនៃភិក្ខុនោះ ដែលគង់នៅក្នុងអាស្រម ជូនកាលលោកឲ្យអាមិសៈ ជូនកាលលោកសម្តែងធម៌ឲ្យខ្ញុំស្តាប់ ។ កាលនោះ ខ្ញុំចូលទៅរកសាវ័ក ជាបុត្រនៃព្រះជិនស្រី ដោយសេចក្តីស្រឡាញ់យ៉ាងខ្លាំង លុះខ្ញុំច្យុតចាកអត្តភាពនោះហើយ ក៏បានទៅកើតក្នុងឋានសួគ៌ ដូចជាការនៅគ្រប់គ្រងផ្ទះរបស់ខ្លួន ។ ខ្ញុំច្យុតចាកឋានសួគ៌ មកកើតក្នុងមនុស្សលោក ដោយបុញ្ញកម្ម ហើយលះបង់ផ្ទះចេញទៅបួសច្រើនលើក ។ គឺខ្ញុំបួសជាសមណៈ ជាតាបស ជាព្រាហ្មណ៍ ជាបរិព្វាជក ដោយប្រការផ្សេងៗ ព្រោះខ្ញុំនៅក្នុងព្រៃ អស់រយនៃឆ្នាំដ៏ច្រើន ។

## ចប់ វេស្សន្តរជាតក

បច្ឆិមេ ច ភវេ ទានិ     រម្មេ កបិលវត្ថវេ
វិញ្ញុ ពោត្ត ធនេ តស្ស     ជាយាយ អហមោក្កមិំ ។
មាតុ មេ ទោហឡោ អាសិ     កុច្ឆិគតស្ស មេ
ជាយមានស្ស ទីបម្ហិ     វសិតាយ ចិត្តលោ ។
តតោ មេ អជនី មាតា     រមណីយេ វនន្តរេ
គព្ភតោ និក្ខមន្តំ មំ     កាសាយេន បដិគ្គហុំ ។
តតោ កុមារោ សិទ្ធត្ថោ     ជាតោ សក្យកុលទ្ធជោ
តស្ស មិត្តោ បិយោ អាសិ     សំវិសដ្ឋោ សុខាធិយោ(១) ។
សត្តសារេ ហ៊ិ(២)និក្ខន្តេ     ឱហាយ វិបុលំ យសំ
អហំ បព្វជិត្វាន     ហិមវន្តំ ឧបាគមិំ ។
វិធាលយិំ ការវិយិំ     កស្សបំ ធុតកនកំ
និស្សា សុត្វា ជិនុប្បាទំ     ឧបេសិំ នរសារថិំ ។

---

១ ឱ. សុមាធិកោ ។ ២ ម. សត្តសាយ ហ៊ិត្តរុទ្ទ ។ ឧ. សត្តសារេហិ និក្ខន្តេ ។



## វេស្សន្តរជាតក ទី ៩

ឥឡូវនេះ មកដល់ភពជាទីបំផុត ព្រាហ្មណ៍ណា ជាវិញ្ញូតាត្រូ នៅក្នុងក្រុងកបិលពស្តុ ជាទីរីករាយ ខ្ញុំចុះចាប់បដិសន្ធិ ក្នុងផ្ទៃភរិយារបស់ព្រាហ្មណ៍នោះ ។ កាលខ្ញុំនឹងប្រសូតចាកផ្ទៃមកខាងក្រៅ មាតារបស់ខ្ញុំមានសេចក្ដីប្រាថ្នា គឺមានប្រាថ្នាដើម្បីនៅក្នុងព្រៃជិតទីដែលខ្ញុំនឹងកើត ។ លំដាប់នោះ មាតាបានបង្កើតខ្ញុំ ត្រង់ចន្លោះព្រៃគួរជាទីរីករាយ ជនទាំងឡាយបានទទួលខ្ញុំ កាលចេញមកអំពីគភ៌ ដោយសំពត់កាសាយៈ ។ លំដាប់នោះ សិទ្ធត្ថកុមារទ្រង់កើតហើយ ជាទង់ជ័យនៃសាក្យត្រកូល ខ្ញុំជាមិត្តរបស់សិទ្ធត្ថកុមារនោះ ជាទីស្រឡាញ់ ស្និទ្ធស្នាល រាប់អានគ្នាជាប់ផុត ។ កាលព្រះសិទ្ធត្ថៈជាខ្ញុំរបស់សត្វ ទ្រង់ចេញបួស ខ្ញុំក៏លះបង់យសដ៏ធំហើយបួស ចូលទៅក្នុងព្រៃហិមពាន្តដែរ ។ ខ្ញុំឃើញព្រះកស្សបៈដែលមានព្រៃជាលំនៅគួរសេពសេរ មានកាយៈកំចាត់កិលេស ឮឱ្យការកើតឡើងនៃព្រះជិនស្រី ក៏ចូលទៅគាល់ព្រះអង្គ ជាសារថីនៃនរៈ ។

សោ មេ ធម្មំ អទេសេសិ   សព្វត្ថំ សព្វញ្ញាសយិ
តតោហំ បព្វជិត្វាន   វិហាសិំ ឧបនាគ្គមំ ។
តត្ថប្បមត្តោ វិហរំ   ឆឡភិញ្ញា អបស្សយិំ
អហោ សុលទ្ធលាភោម្ហិ   សុមិត្តេនានុកម្បិតោ ។
កិលេសា ឈាបិតា មយ្ហំ   ភវា សព្វេ សមូហតា
នាគោវ ពន្ធនំ ឆេត្វា   វិហរាមិ អនាសវោ ។
ស្វាគតំ វត មេ អាសិ   ពុទ្ធសេដ្ឋស្ស សន្តិកេ
តិស្សោ វិជ្ជា អនុប្បត្តា   កតំ ពុទ្ធស្ស សាសនំ ។
បដិសម្ភិទា ចតស្សោ   វិមោក្ខាបិ ច អដ្ឋិមេ
ឆឡភិញ្ញា សច្ឆិកតា   កតំ ពុទ្ធស្ស សាសនន្តិ ។

ឥត្ថំ សុទំ អាយស្មា វិធុរោ ថេរោ ឥមា គាថាយោ អភាសិត្ថាតិ ។

វិធុរត្ថេរស្ស អបទានំ សមត្តំ ។



ព្រះអង្គសម្ដែងនូវធម៌ដល់ខ្ញុំ ប្រកាសនូវអត្ថទាំងពួង ជាប់ចប់នោះ ខ្ញុំក៏បួសចូលទៅកាន់ព្រៃវិញទៀត ។ ខ្ញុំជាបុគ្គលមិនប្រមាទ នៅក្នុងទីនោះ ក៏បានឃើញអភិញ្ញា ៦ ឱ ! អញត្រូវមិត្តល្អអនុគ្រោះហើយ ក៏មានលាភបានហើយណាស់ ។ កិលេសទាំងឡាយ ខ្ញុំដុតបំផ្លាញហើយ ភពទាំងអស់ ខ្ញុំដកចោលហើយ ខ្ញុំជាអ្នកមិនមានអាសវៈ ព្រោះបានកាត់ចំណង ដូចជាដំរីកាត់ផ្ដាច់នូវទន្ទឹង ។ ឱ ! ខ្ញុំមកល្អហើយ ក្នុងសំណាក់ព្រះពុទ្ធដ៏ប្រសើរ វិជ្ជា ៣ ខ្ញុំបានសម្រេចហើយ សាសនា របស់ព្រះពុទ្ធ ខ្ញុំបានធ្វើហើយ ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនា របស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ។

បានឮថា ព្រះវិធុរត្ថេរ មានអាយុ បានសម្ដែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

ចប់ វិធុរត្ថេរាបទាន ៦ ។

## ទសមំ ចូឡសុគន្ធត្ថេរាបទានំ

[១៤០] ឥមម្ហិ ភទ្ទកេ កប្បេ ព្រហ្មពន្ធុ មហាយសោ
កស្សបោ នាម នាមេន ឧប្បជ្ជិ វទតំ វរោ ។
អនុព្យញ្ជនសម្បន្នោ ទ្វត្តឹសវរលក្ខណោ
ព្យាមប្បភាបរិវុតោ រំសិជាលសមោត្ថតោ ។
អស្សាសេតា យថា ចន្ទោ សុរិយោវ បភង្ករោ
និព្វាបេតា យថា មេឃោ សាគរោវ គុណាករោ ។
ធរណីរិវ សីលេន ហិមវាវ សមាធិនា
អាកាសោ វិយ បញ្ញាយ អសង្គោ អនិលោ យថា ។
តទាហំ(១) ពារាណសិយំ ឧប្បន្នោ មហាកុលេ
បហូតធនធញ្ញស្មឹ នានារតនសញ្ចយេ ។
មហតា បរិវារេន និសិន្នំ លោកនាយកំ
ឧបេច្ច ធម្មមស្សោសឹ អមតំ មធោហំ ។

---

១ ម. តទា ហំ ។



## ចូឡសុគន្ធត្ថេរាបទាន ទី ១០

[១៤០] ក្នុងភទ្ទកប្បនេះ ព្រះសម្ពុទ្ធព្រះនាមកស្សបៈ មានផៅពង្សដ៏ប្រសើរ មានយសធំ ទ្រង់ប្រសើរជាងពួកព្រាហ្មណ៍ទាំងឡាយ ទ្រង់កើតឡើងហើយ ។ ព្រះអង្គប្រកបដោយអនុព្យញ្ជនៈ មានលក្ខណៈដ៏ប្រសើរ ៣២ ប្រការ មានពន្លឺមួយព្យាមជុំវិញ ព្រោងព្រាតដោយបណ្តាញ គឺរស្មី ។ ព្រះអង្គញុំាងលោកឲ្យត្រេកអរ ដូចជាព្រះចន្ទ្រ ទ្រង់ធ្វើនូវពន្លឺដូចជាព្រះអាទិត្យ ទ្រង់រំលត់ទុក្ខ ដូចជាភ្លៀង ទ្រង់ជាអណ្តូងនៃគុណដូចជាសាគរ ។ ព្រះអង្គមានសីលដូចជាផែនដី មានសមាធិ ដូចជាភ្នំហិមពាន្ត មានបញ្ញាដូចជាអាកាស មិនមានគ្រឿងទើសដូចខ្យល់ ។ កាលនោះ ខ្ញុំកើតក្នុងមហាត្រកូល មានទ្រព្យនិងស្រូវច្រើន សន្សំរតនៈផ្សេងៗ ក្នុងក្រុងពារាណសី ។ ខ្ញុំចូលទៅគាល់ព្រះលោកនាយក ដែលគង់នៅដោយបរិវារច្រើន បានស្តាប់អមតធម៌គួរដល់ចិត្ត ។

ទ្វត្តឹសលក្ខណធរោ សុនក្ខត្តោវ ចន្ទិមា
អនុព្យញ្ជនសម្បុណ្ណោ សាលរាជាវ ផុល្លិតោ ។
រំសិជាលបរិក្ខិត្តោ ទិត្តោវ កនកាចលោ
ព្យាមប្បភាបរិវុតោ សតរំសី(១) ទិវាករោ ។
សោណ្ណាននោ ជិនវរោ រម្មណីវ សិលុច្ចយោ
ករុណាបុណ្ណហទយោ គុណេន វិយ(២) សាគរោ ។
លោកវិស្សុតកិត្តិ ច សិនេរុ នគុត្តមោ
យសសា វិតតោ ធីរោ អាកាសសទិសោ មុនិ ។
អសង្គចិត្តោ សព្វត្ថ អនិលោ វិយ នាយកោ
បតិដ្ឋា សព្វភូតានំ មហីវ មុនិសត្តមោ ។
អនុបលិត្តោ លោកេន តោយេន បទុមំ យថា
កុវាទគច្ឆទហនោ(៣) អគ្គិក្ខន្ធោវ សោ វិភូ(៤) ។

១ ឱ. សរស្មិំ ។ ម. សតរំសី ។ ២ ឱ. វិត្ថារ វិយ ។ ៣ ឱ. កុបាទគច្ឆទហនោ ។
៤ ឱ. សោភសិ ។ ម. សោ ឥសី ។



ព្រះអង្គទ្រទ្រង់លក្ខណៈ ៣២ ប្រការ ដូចជាព្រះចន្ទ្រមាន នក្ខត្តឫក្សល្អ ទ្រង់បរិបូណ៌ដោយអនុព្យញ្ជនៈ ដូចជាដើមសាលរាជមានផ្ការីក ។ ទ្រង់មានបណ្ដាញនៃរស្មីបិទបាំង ដូចជាមាសមិនប្រែពណ៌ ដែលជាងមាសដុតហើយ មានពន្លឺមួយព្យាមផ្សាយជុំវិញ ដូចជាព្រះអាទិត្យមានរស្មីដ៏ច្រើន ។ ព្រះជិនស្រីប្រសើរ មានព្រះភក្ត្រដូចមាស ឬដូចជាភ្នំជាទីរីករាយ មានព្រះហឫទ័យពេញដោយករុណា (ប្រកប) ដោយគុណដូចជាសាគរ ។ មានកេរ្តិ៍ឈ្មោះល្បីល្បាញក្នុងលោក ដូចជាភ្នំដ៏ឧត្តមឈ្មោះសិនេរុ ទ្រង់ជាអ្នកប្រាជ្ញ ផ្សាយចេញទៅដោយយស ជាមុនីដូចជាអាកាស ។ ព្រះលោកនាយក មានព្រះហឫទ័យមិនជាប់ចំពាក់ ក្នុងទីទាំងពួង ដូចជាខ្យល់ ជាមុនីទី ៧ ជាទីពឹងរបស់ពួកសត្វទាំងអស់ ដូចជាផែនដី ។ ព្រះអង្គមិនប្រឡាក់ ដោយលោក ដូចជាផ្កាឈូក មិនទទឹកដោយទឹក ទ្រង់ដុតរឿង ដូចជាគំនរភ្លើងឆេះគុម្ពគច្ឆៈ ។

ទសមំ ពុទ្ធប្បវត្តិស្ដេចយាង

អគ្គោ វិយ សព្វត្ថ  កិលេសវិសោសនតោ(១)
គន្ធមាទនសេលោវ  គុណគន្ធវិភូសិតោ
គុណានំ អាករោ ធីរោ  រតនានំវ សាគរោ
សិន្ធុវ ច វនជាតានំ  កិលេសមលហារកោ ។
វិជយីវ មហាយោធោ  មារសេនប្បមទ្ទនោ
ចក្កវត្តីវ សោ រាជា  ពោជ្ឈង្គរតនិស្សរោ ។
មហាភិសក្កសង្កាសោ  ទោសព្យាធិតិកិច្ឆកោ
សល្លកត្តោ យថា វេជ្ជោ  ទិដ្ឋិគណ្ឌវិផាលកោ ។
សោ តទា លោកបជ្ជោតោ  សនរាមរសក្កតោ
បរិសាសុ ជនិន្ទោ  ធម្មំ ទេសយតេ ជិនោ ។
ទានំ ទត្វា មហាភោគោ  សីលេន សុគតូបគោ
ភាវនាយ ច និព្វាតិ  ឥច្ចេវមនុសាសថ ។

១ ម. កិលេសវិបនាយតោ ។



ពុទ្ធប្បវត្តិស្ដេចយាង ទី ១០

ទ្រង់ញុំាងពិសគឺកិលេសឲ្យវិនាសក្ស័យទាំងពួង ដូចជាឱសថ ទ្រង់ស្អិតស្អាងគ្រឿងក្រអូបគឺគុណ ដូចជាភ្នំគន្ធមាទនៈ ។ ព្រះអង្គជាអ្នកប្រាជ្ញ ជាអណ្ដូងនៃគុណទាំងឡាយ ដូចជាសាគរជាទីកើតនៃរតនៈទាំងឡាយ ព្រះអង្គជាអាជានេយ្យនៃនរជន ទ្រង់នាំចេញនូវមន្ទិលគឺកិលេស ដូចជាស្ទឹងសិន្ធុ ។ ព្រះអង្គ ញុំាញីនូវមារទ័ពសេនានៃមារ ដូចជាមហាយោធាធំ ឈ្នះ (នូវបច្ចាមិត្ត) ជាឥស្សរៈដោយរតនៈគឺពោជ្ឈង្គ ដូចជាស្ដេចចក្រពត្តិ ។ ព្រះអង្គជាពេទ្យរក្សានូវព្យាធិគឺទោសៈ ដូចជាគ្រូពេទ្យធំ ព្រះអង្គវះនូវពកគឺទិដ្ឋិ ដូចជាពេទ្យវះដ៏ប្រសើរ ។ កាលនោះឯង ព្រះជិនស្រី ព្រះអង្គជាពន្លឺរបស់លោក ទេវតានិងមនុស្ស ធ្វើសក្ការៈហើយ ជាព្រះអាទិត្យរបស់នរៈ ទ្រង់សម្ដែងធម៌ក្នុងពួកបរិស័ទ ។ ព្រះអង្គទ្រង់ទូន្មានប្រៀនប្រដៅថា បុគ្គលមានភោគៈច្រើន ព្រោះឲ្យទាន ទៅកើតសុគតិព្រោះសីល បានព្រះនិព្វាន ព្រោះភាវនា ។

ទេសេន្តំ មហាសទ្ធម្មំ អាទិមជ្ឈន្តសោភនំ
សុណន្តិ បរិសា សព្វា អមតំ មហារសំ ។
សុត្វា សុមធុរំ ធម្មំ បសន្នោ ជិនសាសនេ
សុគតំ សរណំ គន្ត្វា យាវជីវំ នមស្សហំ ។
មុនិនោ គន្ធកុដិយា ឱត្វាដ្ឋសឹ[1] តទា មហឹ
ចតុជ្ជាតេន គន្ធេន មាសេ អដ្ឋ ទិនេ សហំ ។
បណិធាយ សុគន្ធត្តំ សរីរស្ស វិគន្ធិនោ
តទា ជិនោ វិយាកាសិ សុគន្ធតនុលាភិតំ ។
យោ យំ គន្ធកុដិភូមឹ គន្ធេន ឧត្វាលោ[2] សកឹ
តេន កម្មវិបាកេន ឧបបន្នោ យហឹ តហឹ ។
សុគន្ធទេហោ សព្វត្ថ ភវិស្សតិ អយំ នរោ
គុណគន្ធាយុតោ ហុត្វា និព្វាយិស្សតិនាសវោ ។

១ ឱ. ឧបុញ្ញសិ ។ ម. ឱបុញ្ញសិ ។ ២ ឱ. ម. គន្ធេនោបុញ្ញតេ ។



ពួកបរិស័ទទាំងអស់ ស្ដាប់នូវសទ្ធម្មនោះ ដែលមានកម្រិតល្អ មានលំអានដើម កណ្ដាលនិងខាងចុង ដូចជាអមតធម៌មានរសដ៏ធំ ។ លុះខ្ញុំស្ដាប់នូវធម៌ ដែលមានរសផ្អែមល្ហែមហើយ ក៏ជ្រះថ្លាក្នុងសាសនាព្រះជិនស្រី ដល់នូវព្រះសុគតជាទីពឹង ទមស្កាផ្តេកផល់អស់ជីវិត ។ កាលនោះ ខ្ញុំលាបនូវគន្ធកុដិ របស់ព្រះមុនី ដោយក្លិនក្រអូបមានជាតិ ៤ អស់ ៨ ថ្ងៃ ក្នុងមួយខែ ហើយតំកល់ទុកនូវគ្រឿងក្រអូបនោះ ដើម្បីសរីរៈដែលមិនមានក្លិនក្រអូប ។

កាលនោះ ព្រះជិនស្រីសម្ពុទ្ធទ្រង់ទំនាយ នូវការបានខ្លួនមានក្លិនក្រអូបថា បុគ្គលណា បានលាបនូវគន្ធកុដិ ដោយក្លិនក្រអូប អស់វារៈម្តង ព្រោះតែវិបាកនៃកុសលកម្មនោះ បុគ្គលនោះ លុះកើតក្នុងទីណាក៏ដោយ នឹងមានកាយមានក្លិនក្រអូប ក្នុងទីទាំងពួង ជាអ្នកប្រកបដោយក្លិនគឺសីលគុណ មិនមានអាសវៈ នឹងបរិនិព្វាន ។

## ទសមំ ចូឡសុគន្ធត្ថេរាបទានំ

តេន កម្មេន សុកតេន ចេតនាបណិធីហិ ច
ជហិត្វា មានុសំ ទេហំ តាវតឹសំ អគញ្ឆហំ ។
បច្ឆិមេ ច ភវេ ទានិ ជាតោ វិប្បកុលេ អហំ
គព្ភេ មេ វសតោ មាតា ទេហេនាសិ សុគន្ធិកា(១) ។
យទា ច មាតុកុច្ឆិម្ហា និក្ខមាមិ តទា បុរី
សាវត្ថិ សព្វគន្ធេហិ វាសិតា វិយ វាយថ ។
បុប្ផវស្សញ្ច សុរភិ(២) ទិព្វគន្ធំ មនោរមំ
ធូបានិ(៣) ច មហគ្ឃានិ ឧបវាយឹសុ តាវទេ ។
ទេវា ច សព្វគន្ធេហិ ធូបបុប្ផេហិ(៤)តំ ឃរំ
វាសយឹសុ សុគន្ធេន យស្មឹ ជាតោ អហំ ឃរេ ។
យទា ច តរុណោ ភទ្ទោ បឋមេ យោព្វនេ ឋិតោ
តទា សេសំ(៥) សបរិសំ វិនេត្វា នរសារថិ ។

១ ឱ.ម.សុគន្ធិកា ។ ២ ឱ. សុរភី ។ ៣ ម. ធូមានិ ។ ៤ ម. ធូបបុប្ផេហិ ។ ៥ ឱ ម.សេលំ ។





ដោយកុសលកម្មដែលខ្ញុំធ្វើល្អនោះផង ដោយការតាំងទុកនូវចេតនានោះផង លុះខ្ញុំលះបង់នូវកាយជារបស់មនុស្សហើយ ក៏បានទៅកើតក្នុងឋានតាវត្តិង្ស ។ ឥឡូវនេះ ផ្លាស់មកកាន់បច្ឆិមភព ខ្ញុំបានមកកើតក្នុងត្រកូលព្រាហ្មណ៍ កាលខ្ញុំនៅក្នុងផ្ទៃនៃមាតា មាតា (របស់ខ្ញុំ) ជាស្រីមានកាយក្លិនក្រអូប ។ កាលណា ខ្ញុំចេញចាកផ្ទៃនៃមាតា កាលនោះ ក្រុងសាវត្ថីផ្សាយចេញដោយគ្រឿងក្រអូបទាំងពួង ហាក់ដូចជាគេអប់ ។ គ្រឿងជាវិការៈនៃផ្កាក្រអូប មានក្លិនដូចជាក្លិនទិព្វ ជាទីរីករាយនៃចិត្តផង ធូបទាំងឡាយមានថ្លៃដ៏ច្រើនផង ក៏ផ្សាយចេញក្នុងខណៈនោះ ។ ខ្ញុំកើតក្នុងផ្ទះណា ទេវតាទាំងឡាយអប់នូវផ្ទះនោះ ដោយគ្រឿងក្រអូបទាំងពួងផង ដោយធូបនិងផ្កាទាំងឡាយផង ដោយក្លិនទិព្វផង ។ កាលណា ខ្ញុំនៅក្មេងកំពុងចម្រើន ឋិតនៅក្នុងបឋមវ័យ កាលនោះ ព្រះនរសារថី ទ្រង់ទូន្មាននូវជនដ៏សេស ព្រមទាំងបរិស័ទ ។

តេហិ សព្វេហិ សហិតោ សាវត្ថិបុរមាគតោ

តទា ពុទ្ធានុភាវន្តំ ទិស្វា បព្វជិតោ អហំ ។

សីលំ សមាធិបញ្ញញ្ច វិមុត្តិញ្ច អនុត្តរំ

ភាវេត្វា ចតុរោ ធម្មេ បាបុណឹ អាសវក្ខយំ ។

យទា បព្វជិតោ ចាហំ យទា ច អរហំ អហុំ(១)

និព្វាយិស្សំ យទា ចាហំ គន្ធមេឃោ តទា អហុ ។

សរីរគន្ធោ ច (២)សេដ្ឋោតិសេតិ មេ(៣)

មហារហំ ចន្ទនំ ចម្បកុប្បលំ

តេជេន គន្ធេ ឥតរេ ច សព្វសោ

បសយ្ហ វាយាមិ តតោ យហឹ តហឹ ។

កិលេសា ឈាបិតា មយ្ហំ ភវា សព្វេ សមូហតា

នាគោវ ពន្ធនំ ឆេត្វា វិហរាមិ អនាសវោ ។

---

១ ឧ. អហុំ ។ ២ ម. ឯត្ថន្តរេ សកលគ្គោ អត្ថិ ។ ៣ ម. វិសេសំ មេ មហារហំ ។



ព្រះអង្គប្រកបដោយបរិស័ទទាំងឡាយ ទាំងពួងនោះ ស្តេចមកកាន់ក្រុងសាវត្ថី កាលនោះ ខ្ញុំបានឃើញនូវអានុភាពនៃព្រះពុទ្ធនោះ ហើយក៏បួស ។ ខ្ញុំអប់រំធម៌ដ៏ប្រសើរទាំង ៤ គឺសីល សមាធិ បញ្ញា និងវិមុត្តិ ហើយបានដល់នូវការអស់ទៅនៃអាសវៈ ។ ខ្ញុំបួសក្នុងកាលណាផង ខ្ញុំបានជាព្រះអរហន្តក្នុងកាលណាផង ខ្ញុំបរិនិព្វានក្នុងកាលណាផង ភ្លៀងមានក្លិនក្រអូបក៏បង្អុរចុះ ក្នុងកាលនោះ ។

ក្លិនរបស់សរីរៈខ្ញុំ ជាក្លិនដ៏ប្រសើរ គ្របសង្កត់នូវក្លិន

នៃខ្លឹមចន្ទន៍ ផ្កាចម្បា និងផ្កាឧប្បល មានថ្លៃច្រើន

ម្យ៉ាងទៀត ខ្ញុំទៅក្នុងទីណាក៏ដោយ តែងផ្សាយក្លិន

ក្រអូបគ្របសង្កត់នូវក្លិនដទៃ ដោយសព្វគ្រប់ ។

កិលេសទាំងឡាយ ខ្ញុំដុតបំផ្លាញហើយ ភពទាំងអស់

ខ្ញុំដកចោលចេញហើយ ខ្ញុំជាអ្នកមិនមានអាសវៈ ព្រោះ

បានកាត់ចំណង ដូចជាដំរី កាត់ផ្តាច់ នូវទន្លីង ។

ទសមំ ចូឡសុគន្ធត្ថេរាបទានំ

ស្វាគតំ វត មេ អាសិ ពុទ្ធសេដ្ឋស្ស សន្តិកេ
តិស្សោ វិជ្ជា អនុប្បត្តា កតំ ពុទ្ធស្ស សាសនំ ។
បដិសម្ភិទា ចតស្សោ វិមោក្ខាបិ ច អដ្ឋិមេ
ឆឡភិញ្ញា សច្ឆិកតា កតំ ពុទ្ធស្ស សាសនំ ។
ឥត្ថំ សុទំ អាយស្មា ចូឡសុគន្ធោ ថេរោ ឥមា
គាថាយោ អភាសិត្ថាតិ ។

ចូឡសុគន្ធត្ថេរស្ស អបទានំ សមត្តំ ។

ឧទ្ទានំ

កង្ខិយោ រេវតោ ថេរោ មហាលាភី ច សីវលិ
វង្គីសោ នន្ទកោ ចេវ កាឡុទាយី តថាភយោ ។
លោមសោ វនវច្ឆោ ច សុគន្ធោ ទសមោ កតោ(១)
តីណិ គាថាសតា ឥត្ថ សោឡសា ច តទុត្តរិ ។

កង្ខិយវគ្គោ ចតុបញ្ញាសោ ។

១ ម. សុគន្ធោ ចេវ ទសមោតិ ទិស្សតិ ។



ចូឡសុគន្ធត្ថេរាបទាន ទី ១០

ម ! ខ្ញុំមកល្អហើយ ក្នុងសំណាក់ព្រះពុទ្ធដ៏ប្រសើរ វិជ្ជា ៣ ខ្ញុំបានសម្រេចហើយ សាសនា របស់ព្រះពុទ្ធ ខ្ញុំបានធ្វើហើយ ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនា របស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ។

បានឮថា ព្រះចូឡសុគន្ធត្ថេរ មានអាយុ បានសម្តែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

ចប់ ចូឡសុគន្ធត្ថេរាបទាន ។

ឧទ្ទាន

កង្ខិយត្ថេរាបទាន ១ រេវតត្ថេរាបទាន ១ សីវលិត្ថេរាបទាន អ្នកមានលាភច្រើន ១ វង្គីសត្ថេរាបទាន ១ នន្ទកត្ថេរាបទាន ១ កាឡុទាយិត្ថេរាបទាន ១ អភយត្ថេរាបទាន ១ ។ លោមសកិយត្ថេរាបទាន ១ វនវច្ឆត្ថេរាបទាន ១ ចូឡសុគន្ធត្ថេរាបទាន ជាគំរប់ ១០ ក្នុងវគ្គនោះ មានគាថា ៣១៦ ។

ចប់ កង្ខិយវគ្គ ទី ៥៤ ។

# អថ វគ្គុទ្ទានំ

កណិការវ្ហយោ វគ្គោ ផលទោ តិណទាយកោ
កច្ចានោ ភទ្ទិយោ វគ្គោ គាថាយោ គណិតា វិសា(១) ។
ឆ គាថាសតានិ ច(២) ចតុរាសីតិមេវ ច
ឆបញ្ញាសំ(៣) បញ្ចសតា អបទានា បកាសិតា ។
សហ ឧទ្ទានគាថាហិ ឆសហស្សានិ ហោន្តិមា
ទ្វេ សតានិ ច គាថានំ អដ្ឋារស តទុត្តរិ ។

និដ្ឋិតា ពុទ្ធាបទានញ្ច បច្ចេកពុទ្ធាបទានញ្ច ថេរាបទានញ្ច

សមត្តានិ ។

---

១ ម. កណិការវ្ហយោ ។ ឧ. កណិការ ទិសា ។ ២ ម. ឧ. គាថាសតានិ ហិ ។ ៣ ម. ឧ. សបញ្ញាសំ ។



# ម្យ៉ាងទៀត ឧទ្ទានវគ្គ

កណិការវគ្គ ១ ផលទាយកវគ្គ ១ តិណទាយកវគ្គ ១ កច្ចា-យនវគ្គ ១ ភទ្ទិយវគ្គ ១ រាប់ជាគាថា មានចំនួន ៦០ ។ អបទានទាំងឡាយ សោតសព្វនិបាត មានគាថា ៦០០ ជាង ៨៤ ជាង ៥៥៦ ជាង ។ គាថាទាំងឡាយនេះ ព្រមទាំងឧទ្ទាន មានចំនួន ៦.២១៨ គាថា ។

ចប់ ពុទ្ធាបទាន បច្ចេកពុទ្ធាបទាន និងថេរាបទាន ។

# សុត្តន្តបិដកេ

## ខុទ្ទកនិកាយស្ស អបទានំ

## ចតុត្ថោ ភាគោ

មាតិកា — អង្កេ

### ទ្វាចត្តាឡីសមោ ភទ្ទាលិវគ្គោ


| | | |
|---|---|---|
| ភទ្ទាលិវគ្គេ | បឋមំ ភទ្ទាលិត្ថេរាបទានំ | ១ |
| | ទុតិយំ ឯកច្ឆត្តិយត្ថេរាបទានំ | ៦ |
| | តតិយំ តិណសូលកឆាទនិយត្ថេរាបទានំ | ១៥ |
| | ចតុត្ថំ មធុមំសទាយកត្ថេរាបទានំ | ២០ |
| | បញ្ចមំ នាគបល្លវកត្ថេរាបទានំ | ២២ |
| | ឆដ្ឋំ ឯកទីបិយត្ថេរាបទានំ | ២៣ |
| | សត្តមំ ឧច្ឆង្គបុប្ផិយត្ថេរាបទានំ | ២៦ |
| | អដ្ឋមំ យាគុទាយកត្ថេរាបទានំ | ២៨ |
| | នវមំ បត្ថោទនទាយកត្ថេរាបទានំ | ៣២ |
| | ទសមំ មញ្ចទាយកត្ថេរាបទានំ | ៣៥ |


# សុត្តន្តបិដក

## ខុទ្ទកនិកាយ អបទាន

## ចតុត្ថភាគ

មាតិកា — ទំព័រ

### ភទ្ទាលិវគ្គ ទី ៤២


| | | |
|---|---|---|
| ភទ្ទាលិវគ្គ | ភទ្ទាលិត្ថេរាបទាន ទី ១ | ១ |
| | ឯកច្ឆត្តិយត្ថេរាបទាន ទី ២ | ៦ |
| | តិណសូលកឆាទនិយត្ថេរាបទាន ទី ៣ | ១៥ |
| | មធុមំសទាយកត្ថេរាបទាន ទី ៤ | ២០ |
| | នាគបល្លវកត្ថេរាបទាន ទី ៥ | ២២ |
| | ឯកទីបិយត្ថេរាបទាន ទី ៦ | ២៣ |
| | ឧច្ឆង្គបុប្ផិយត្ថេរាបទាន ទី ៧ | ២៦ |
| | យាគុទាយកត្ថេរាបទាន ទី ៨ | ២៨ |
| | បត្ថោទនទាយកត្ថេរាបទាន ទី ៩ | ៣២ |
| | មញ្ចទាយកត្ថេរាបទាន ទី ១០ | ៣៥ |

# មាតិកាបត្តានិ


| មាតិកា | | អង្កេ |
|---|---|---|
| | **តេចត្តាឡីសោ សកឹសម្មជ្ជកវគ្គោ** | |
| សកឹសម្មជ្ជកវគ្គ | បឋមំ សកឹសម្មជ្ជកត្ថេរាបទានំ . . . . | ៣៨ |
| | ទុតិយំ ឯកទុស្សទាយកត្ថេរាបទានំ . . | ៤១ |
| | តតិយំ ឯកាសនទាយកត្ថេរាបទានំ . . | ៤៤ |
| | ចតុត្ថំ សត្តកទម្ពបុប្ផិយត្ថេរាបទានំ . . | ៤៩ |
| | បញ្ចមំ កោរណ្ឌបុប្ផិយត្ថេរាបទានំ . . | ៥០ |
| | ឆដ្ឋំ ឃតមណ្ឌទាយកត្ថេរាបទានំ . . | ៥២ |
| | សត្តមំ ឯកធម្មស្សវនិយត្ថេរាបទានំ . . | ៥៤ |
| | អដ្ឋមំ សុចិន្តិតត្ថេរាបទានំ . . . . . | ៥៨ |
| | នវមំ សោណ្ណកិង្កណិយត្ថេរាបទានំ . . | ៦៤ |
| | ទសមំ សោវណ្ណកោន្តរិកត្ថេរាបទានំ . . | ៦៧ |
| | **ចតុចត្តាឡីសោ ឯកវិហារិវគ្គោ** | |
| ឯកវិហារិវគ្គ | បឋមំ ឯកវិហារិយត្ថេរាបទានំ . . . . | ៧១ |
| | ទុតិយំ ឯកសង្ខិយត្ថេរាបទានំ . . . . | ៧៤ |




# សន្ទឹកប្រាប់មាតិកា


| មាតិកា | | ទំព័រ |
|---|---|---|
| | **សកឹសម្មជ្ជកវគ្គ ទី ៤៣** | |
| សកឹសម្មជ្ជកវគ្គ | សកឹសម្មជ្ជកត្ថេរាបទាន ទី ១ . . . | ៣៨ |
| | ឯកទុស្សទាយកត្ថេរាបទាន ទី ២ . . | ៤១ |
| | ឯកាសនទាយកត្ថេរាបទាន ទី ៣ . . | ៤៤ |
| | សត្តកទម្ពបុប្ផិយត្ថេរាបទាន ទី ៤ . . | ៤៩ |
| | កោរណ្ឌបុប្ផិយត្ថេរាបទាន ទី ៥ . . | ៥០ |
| | ឃតមណ្ឌទាយកត្ថេរាបទាន ទី ៦ . . | ៥២ |
| | ឯកធម្មស្សវនិយត្ថេរាបទាន ទី ៧ . . | ៥៤ |
| | សុចិន្តិតត្ថេរាបទាន ទី ៨ . . . . | ៥៨ |
| | សោណ្ណកិង្កណិយត្ថេរាបទាន ទី ៩ . | ៦៤ |
| | សោវណ្ណកោន្តរិកត្ថេរាបទាន ទី ១០ . | ៦៧ |
| | **ឯកវិហារិវគ្គ ទី ៤៤** | |
| ឯកវិហារិវគ្គ | ឯកវិហារិយត្ថេរាបទាន ទី ១ . . . . | ៧១ |
| | ឯកសង្ខិយត្ថេរាបទាន ទី ២ . . . | ៧៤ |

មាតិកា | អង្គ


ឯកវិហារិវគ្គ
តតិយំ បាដិហិរសញ្ញកត្ថេរាបទានំ . . . ៧៦
ចតុត្ថំ ញាណត្ថវិកត្ថេរាបទានំ . . . . ៧៨
បញ្ចមំ ឧច្ឆុខណ្ឌិកត្ថេរាបទានំ . . . . ៨០
ឆដ្ឋំ កឡម្ពទាយកត្ថេរាបទានំ . . . . ៨២
សត្តមំ អម្ពាដកទាយកត្ថេរាបទានំ . . . ៨៣
អដ្ឋមំ ហរីតកិទាយកត្ថេរាបទានំ . . . ៨៤
នវមំ អម្ពបិណ្ឌិយត្ថេរាបទានំ . . . . ៨៦
ទសមំ ជម្ពុផលិយត្ថេរាបទានំ . . . . ៨៨


## បញ្ចបញ្ញាសមោ វិភេទកវគ្គោ


វិភេទកវគ្គ
បឋមំ វិភេទកពីជិយត្ថេរាបទានំ . . . ៩០
ទុតិយំ កោលទាយកត្ថេរាបទានំ . . . ៩១
តតិយំ បេលុវផលិយត្ថេរាបទានំ . . . ៩៣
ចតុត្ថំ ភល្លាតកទាយកត្ថេរាបទានំ . . . ៩៤


មាតិកា | ទំព័រ


ឯកវិហារិវគ្គ
បាដិហិរសញ្ញកត្ថេរាបទាន ទី ៣ . . . ៧៦
ញាណត្ថវិកត្ថេរាបទាន ទី ៤ . . . . ៧៨
ឧច្ឆុខណ្ឌិកត្ថេរាបទាន ទី ៥ . . . . ៨០
កឡម្ពទាយកត្ថេរាបទាន ទី ៦ . . . ៨២
អម្ពាដកទាយកត្ថេរាបទាន ទី ៧ . . . ៨៣
ហរីតកិទាយកត្ថេរាបទាន ទី ៨ . . . ៨៤
អម្ពបិណ្ឌិយត្ថេរាបទាន ទី ៩ . . . . ៨៦
ជម្ពុផលិយត្ថេរាបទាន ទី ១០ . . . ៨៨


## វិភេទកវគ្គ ទី ៥៥


វិភេទកវគ្គ
វិភេទកពីជិយត្ថេរាបទាន ទី ១ . . . ៩០
កោលទាយកត្ថេរាបទាន ទី ២ . . . ៩១
បេលុវផលិយត្ថេរាបទាន ទី ៣ . . . ៩៣
ភល្លាតកទាយកត្ថេរាបទាន ទី ៤ . . . ៩៤

# អាទិកបត្តានិ


| មាតិកា | | អង្កេ |
|---|---|---|
| វិភេទកវគ្គេ | បញ្ចមំ ទុម្ពុប្ផិយត្ថេរាបទានំ . . . . | ៩៦ |
| | ឆដ្ឋំ អម្ពាដកិយត្ថេរាបទានំ . . . . . | ៩៧ |
| | សត្តមំ សីហាសនិកត្ថេរាបទានំ . . . | ៩៩ |
| | អដ្ឋមំ បាទបីឋិយត្ថេរាបទានំ . . . . | ១០០ |
| | នវមំ វេទិការកត្ថេរាបទានំ . . . . | ១០២ |
| | ទសមំ ពោធិឃរការកត្ថេរាបទានំ . . . | ១០៤ |


## ឆចត្តាឡីសោ ជគតិវគ្គោ


| | | |
|---|---|---|
| ជគតិវគ្គេ | បឋមំ ជគតិទាយកត្ថេរាបទានំ . . . | ១០៧ |
| | ទុតិយំ មោរហត្ថិយត្ថេរាបទានំ . . . | ១០៨ |
| | តតិយំ សីហាសនពីជនិយត្ថេរាបទានំ . . | ១១០ |
| | ចតុត្ថំ តិណុក្កធារិយត្ថេរាបទានំ . . . | ១១១ |
| | បញ្ចមំ អក្កមនទាយកត្ថេរាបទានំ . . . | ១១២ |
| | ឆដ្ឋំ វនកោរណ្ឌិយត្ថេរាបទានំ . . . . | ១១៣ |
| | សត្តមំ ឯកច្ឆត្តិយត្ថេរាបទានំ . . . | ១១៤ |


# សន្ទិកប្រៀបធៀប


| មាតិកា | | ទំព័រ |
|---|---|---|
| វិភេទកវគ្គ | ទុម្ពុប្ផិយត្ថេរាបទាន ទី ៥ . . . . . | ៩៦ |
| | អម្ពាដកិយត្ថេរាបទាន ទី ៦ . . . . . | ៩៧ |
| | សីហាសនិកត្ថេរាបទាន ទី ៧ . . . . . | ៩៩ |
| | បាទបីឋិយត្ថេរាបទាន ទី ៨ . . . . . | ១០០ |
| | វេទិការកត្ថេរាបទាន ទី ៩ . . . . . | ១០២ |
| | ពោធិឃរការកត្ថេរាបទាន ទី ១០ . . . . | ១០៤ |


## ជគតិវគ្គ ទី ៤៦


| | | |
|---|---|---|
| ជគតិវគ្គ | ជគតិទាយកត្ថេរាបទាន ទី ១ . . . . . | ១០៧ |
| | មោរហត្ថិយត្ថេរាបទាន ទី ២ . . . . . | ១០៨ |
| | សីហាសនពីជនិយត្ថេរាបទាន ទី ៣ . . . | ១១០ |
| | តិណុក្កធារិយត្ថេរាបទាន ទី ៤ . . . . | ១១១ |
| | អក្កមនទាយកត្ថេរាបទាន ទី ៥ . . . . | ១១២ |
| | វនកោរណ្ឌិយត្ថេរាបទាន ទី ៦ . . . . | ១១៣ |
| | ឯកច្ឆត្តិយត្ថេរាបទាន ទី ៧ . . . . | ១១៤ |

# មាតិកាបត្តានិ


| មាតិកា | | អង្កេ |
| --- | --- | --- |
| ផគ្គិវគ្គ | អដ្ឋមំ ជាតិបុប្ផិយត្ថេរាបទានំ . . . | ១១៦ |
| | នវមំ សត្តិបណ្ណិយត្ថេរាបទានំ . . . | ១១៨ |
| | ទសមំ គន្ធបូជកត្ថេរាបទានំ. . . . | ១១៩ |


## សត្តចត្តាឡីសោ សាលបុប្ផិវគ្គោ


| | | |
| --- | --- | --- |
| សាលបុប្ផិវគ្គ | បឋមំ សាលកុសុមិយត្ថេរាបទានំ . . | ១២១ |
| | ទុតិយំ ចិតកបូជកត្ថេរាបទានំ . . . | ១២២ |
| | តតិយំ ចិតកនិព្វាបកត្ថេរាបទានំ. . . | ១២៣ |
| | ចតុត្ថំ សេតុទាយកត្ថេរាបទានំ. . . | ១២៤ |
| | បញ្ចមំ សុមនតាលវណ្ដិយត្ថេរាបទានំ . | ១២៥ |
| | ឆដ្ឋំ អវដផលិយត្ថេរាបទានំ . . . | ១២៦ |
| | សត្តមំ លពុជផលទាយកត្ថេរាបទានំ . | ១២៧ |
| | អដ្ឋមំ បិលក្ខុផលទាយកត្ថេរាបទានំ . . | ១២៨ |
| | នវមំ សយម្បដិភាណិយត្ថេរាបទានំ . . | ១២៩ |
| | ទសមំ និមិត្តព្យាករណិយត្ថេរាបទានំ . | ១៣២ |




# សន្លឹកប្រាប់មាតិកា


| មាតិកា | | ទំព័រ |
| --- | --- | --- |
| ផគ្គិវគ្គ | ជាតិយបុប្ផិយត្ថេរាបទាន ទី ៨ . . . . | ១១៦ |
| | សត្តិបណ្ណិយត្ថេរាបទាន ទី ៩ . . . . | ១១៨ |
| | គន្ធបូជកត្ថេរាបទាន ទី ១០ . . . . | ១១៩ |


## សាលបុប្ផិវគ្គ ទី ៤៧


| | | |
| --- | --- | --- |
| សាលបុប្ផិវគ្គ | សាលកុសុមិយត្ថេរាបទាន ទី ១ . . . | ១២១ |
| | ចិតកបូជកត្ថេរាបទាន ទី ២ . . . | ១២២ |
| | ចិតកនិព្វាបកត្ថេរាបទាន ទី ៣ . . . | ១២៣ |
| | សេតុទាយកត្ថេរាបទាន ទី ៤ . . . | ១២៤ |
| | សុមនតាលវណ្ដិយត្ថេរាបទាន ទី ៥ . . | ១២៥ |
| | អវដផលិយត្ថេរាបទាន ទី ៦ . . . . | ១២៦ |
| | លពុជផលទាយកត្ថេរាបទាន ទី ៧ . . | ១២៧ |
| | បិលក្ខុផលទាយកត្ថេរាបទាន ទី ៨ . . | ១២៨ |
| | សយម្បដិភាណិយត្ថេរាបទាន ទី ៩ . . | ១២៩ |
| | និមិត្តព្យាករណិយត្ថេរាបទាន ទី ១០ . . | ១៣២ |

# មាតិកាបត្តាវ


| មាតិកា | | អង្កេ |
|---|---|---|
| | **អដ្ឋចត្តាឡីសោ នឡមាលិវគ្គោ** | |
| នឡមាលិវគ្គ | បឋមំ នឡមាលិយត្ថេរាបទានំ . . . | ១៣៦ |
| | ទុតិយំ មណិបូជកត្ថេរាបទានំ . . . | ១៣៧ |
| | តតិយំ ឧក្កាសតិកត្ថេរាបទានំ . . . | ១៤១ |
| | ចតុត្ថំ សុមនវីជនិយត្ថេរាបទានំ . . . | ១៤៤ |
| | បញ្ចមំ កុម្មាសទាយកត្ថេរាបទានំ . . | ១៤៥ |
| | ឆដ្ឋំ កុសដ្ឋកទាយកត្ថេរាបទានំ . . . | ១៤៦ |
| | សត្តមំ គិរិបុន្នាគិយត្ថេរាបទានំ . . . | ១.៧ |
| | អដ្ឋមំ វល្លិការផលទាយកត្ថេរាបទានំ . | ១៤៩ |
| | នវមំ បានធិទាយកត្ថេរាបទានំ . . . | ១៥០ |
| | ទសមំ បុឡិនចង្កមិយត្ថេរាបទានំ . . | ១៥៣ |
| | **ឯកូនបញ្ញាសមោ បង្សុកូលវគ្គោ** | |
| បង្សុកូលវគ្គ | បឋមំ បង្សុកូលសញ្ញកត្ថេរាបទានំ . . | ១៥៦ |
| | ទុតិយំ ពុទ្ធសញ្ញកត្ថេរាបទានំ . . . | ១៥៧ |




# សន្លឹកប្រាប់មាតិកា


| មាតិកា | | ទំព័រ |
|---|---|---|
| | **នឡមាលិវគ្គ ទី ៤៨** | |
| នឡមាលិវគ្គ | នឡមាលិយត្ថេរាបទាន ទី ១ . . . | ១៣៦ |
| | មណិបូជកត្ថេរាបទាន ទី ២ . . . | ១៣៧ |
| | ឧក្កាសតិកត្ថេរាបទាន ទី ៣ . . . | ១៤១ |
| | សុមនវីជនិយត្ថេរាបទាន ទី ៤ . . . | ១៤៤ |
| | កុម្មាសទាយកត្ថេរាបទាន ទី ៥ . . . | ១៤៥ |
| | កុសដ្ឋកទាយកត្ថេរាបទាន ទី ៦ . . . | ១៤៦ |
| | គិរិបុន្នាគិយត្ថេរាបទាន ទី ៧ . . . | ១៤៧ |
| | វល្លិការផលទាយកត្ថេរាបទាន ទី ៨ . . | ១៤៩ |
| | បានធិទាយកត្ថេរាបទាន ទី ៩ . . . | ១៥០ |
| | បុឡិនចង្កមិយត្ថេរាបទាន ទី ១០ . . . | ១៥៣ |
| | **បង្សុកូលវគ្គ ទី ៤៩** | |
| បង្សុកូលវគ្គ | បង្សុកូលសញ្ញកត្ថេរាបទាន ទី ១ . . | ១៥៦ |
| | ពុទ្ធសញ្ញកត្ថេរាបទាន ទី ២ . . . | ១៥៧ |

# មាតិកាបត្ថាន


| មាតិកា | | អង្កេ |
|---|---|---|
| បំសុកូលវគ្គោ | តតិយំ ភិសទាយកត្ថេរាបទានំ . . . | ១៦១ |
| | ចតុត្ថំ ញាណត្ថវិកត្ថេរាបទានំ . . . | ១៦៤ |
| | បញ្ចមំ ចន្ទនមាលិយត្ថេរាបទានំ . . . | ១៧០ |
| | ឆដ្ឋំ ធាតុបូជកត្ថេរាបទានំ . . . . | ១៧៥ |
| | សត្តមំ បុឡិនុប្បាទកត្ថេរាបទានំ . . . | ១៧៦ |
| | អដ្ឋមំ តរណិយត្ថេរាបទានំ . . . . | ១៨៤ |
| | នវមំ ធម្មរុចិត្ថេរាបទានំ . . . . . | ១៨៧ |
| | ទសមំ សាលមណ្ឌបិយត្ថេរាបទានំ . . | ១៩២ |


## បញ្ចាសមោ កិង្កណិបុប្ផវគ្គោ


| | | |
|---|---|---|
| កឹកណិបុប្ផវគ្គោ | បឋមំ តីណិកឹកណិបុប្ផិយត្ថេរាបទានំ . | ១៩៩ |
| | ទុតិយំ បំសុកូលបូជកត្ថេរាបទានំ . . . | ២០០ |
| | តតិយំ កោរណ្ឌបុប្ផិយត្ថេរាបទានំ . . . | ២០២ |
| | ចតុត្ថំ កឹសុកបុប្ផិយត្ថេរាបទានំ . . . | ២០៤ |
| | បញ្ចមំ ឧបឌ្ឍទុស្សទាយកត្ថេរាបទានំ . . | ២០៥ |




# សន្លឹកប្រាប់មាតិកា


| មាតិកា | | ទំព័រ |
|---|---|---|
| បំសុកូលវគ្គ | ភិសទាយកត្ថេរាបទាន ទី ៣ . . . | ១៦១ |
| | ញាណត្ថវិកត្ថេរាបទាន ទី ៤ . . . | ១៦៤ |
| | ចន្ទនមាលិយត្ថេរាបទាន ទី ៥ . . . | ១៧០ |
| | ធាតុបូជកត្ថេរាបទាន ទី ៦ . . . . | ១៧៥ |
| | បុឡិនុប្បាទកត្ថេរាបទាន ទី ៧ . . . | ១៧៦ |
| | តរណិយត្ថេរាបទាន ទី ៨ . . . . | ១៨៤ |
| | ធម្មរុចិត្ថេរាបទាន ទី ៩ . . . . | ១៨៧ |
| | សាលមណ្ឌបិយត្ថេរាបទាន ទី ១០ . . | ១៩២ |


## កឹកណិបុប្ផវគ្គ ទី ៥០


| | | |
|---|---|---|
| កឹកណិបុប្ផវគ្គ | តីណិកឹកណិបុប្ផិយត្ថេរាបទាន ទី ១ . . | ១៩៩ |
| | បំសុកូលបូជកត្ថេរាបទាន ទី ២ . . . | ២០០ |
| | កោរណ្ឌបុប្ផិយត្ថេរាបទាន ទី ៣ . . . | ២០២ |
| | កឹសុកបុប្ផិយត្ថេរាបទាន ទី ៤ . . . | ២០៤ |
| | ឧបឌ្ឍទុស្សទាយកត្ថេរាបទាន ទី ៥ . . | ២០៥ |

# មាតិកាបាឡិ


| មាតិកា | | អង្ក |
|---|---|---|
| កឹកណិបុប្ផវគ្គ | ឆដ្ឋំ ឃតមណ្ឌទាយកត្ថេរាបទានំ . . | ៦០៧ |
| | សត្តមំ ឧទកទាយកត្ថេរាបទានំ . . . | ៦០៩ |
| | អដ្ឋមំ បុឡិនថូបិយត្ថេរាបទានំ . . . | ៦១១ |
| | នវមំ នឡកុដិកទាយកត្ថេរាបទានំ . . | ៦១៧ |
| | ទសមំ បិយាលផលទាយកត្ថេរាបទានំ . | ៦១៩ |

## ឯកបញ្ញាសោ កណិការវគ្គោ

| | | |
|---|---|---|
| កណិការវគ្គ | បឋមំ តីណិកណិការបុប្ផិយត្ថេរាបទានំ . | ៦២២ |
| | ទុតិយំ ឯកបត្តទាយកត្ថេរាបទានំ . . | ៦២៨ |
| | តតិយំ កាសុមារិកផលទាយកត្ថេរាបទានំ . | ៦៣១ |
| | ចតុត្ថំ អវដផលិយត្ថេរាបទានំ . . . . | ៦៣២ |
| | បញ្ចមំ ចារផលិយត្ថេរាបទានំ . . . | ៦៣៣ |
| | ឆដ្ឋំ មាតុលុង្គផលទាយកត្ថេរាបទានំ . | ៦៣៤ |
| | សត្តមំ អជេលផលទាយកត្ថេរាបទានំ . | ៦៣៦ |




# សន្លឹកប្រាប់មាតិកា


| មាតិកា | | ទំព័រ |
|---|---|---|
| កឹកណិបុប្ផវគ្គ | ឃតមណ្ឌទាយកត្ថេរាបទាន ទី ៦ . . | ៦០៧ |
| | ឧទកទាយកត្ថេរាបទាន ទី ៧ . . . | ៦០៩ |
| | បុឡិនថូបិយត្ថេរាបទាន ទី ៨ . . . | ៦១១ |
| | នឡកុដិកទាយកត្ថេរាបទាន ទី ៩ . . | ៦១៧ |
| | បិយាលផលទាយកត្ថេរាបទាន ទី ១០ . | ៦១៩ |

## កណិការវគ្គ ទី ៥១

| | | |
|---|---|---|
| កណិការវគ្គ | តីណិកណិការបុប្ផិយត្ថេរាបទាន ទី ១ . | ៦២២ |
| | ឯកបត្តទាយកត្ថេរាបទាន ទី ២ . . . | ៦២៨ |
| | កាសុមារិកផលទាយកត្ថេរាបទាន ទី ៣ . | ៦៣១ |
| | អវដផលិយត្ថេរាបទាន ទី ៤ . . . . | ៦៣២ |
| | ចារផលិយត្ថេរាបទាន ទី ៥ . . . . | ៦៣៣ |
| | មាតុលុង្គផលទាយកត្ថេរាបទាន ទី ៦ . | ៦៣៤ |
| | អជេលផលទាយកត្ថេរាបទាន ទី ៧ . | ៦៣៦ |

## [illegible]


| មាតិកា | | អង្គ |
|---|---|---|
| គណិកាវគ្គ | អដ្ឋមំ អសោកផលិយត្ថេរាបទានំ . . . | ៦៣៧ |
| | នវមំ ភាគផលិយត្ថេរាបទានំ . . . | ៦៣៨ |
| | ទសមំ នាលិកេរផលទាយកត្ថេរាបទានំ . | ៦៣៩ |


## ទ្វេបញ្ញាសោ ផលទាយកវគ្គោ


| | | |
|---|---|---|
| ផលទាយកវគ្គ | បឋមំ កុរញ្ជិយផលទាយកត្ថេរាបទានំ . . | ៦៦២ |
| | ទុតិយំ កបិដ្ឋផលទាយកត្ថេរាបទានំ . . | ៦៦៣ |
| | តតិយំ កោសុម្ភផលិយត្ថេរាបទានំ . . | ៦៦៤ |
| | ចតុត្ថំ កេតកបុប្ផិយត្ថេរាបទានំ . . . | ៦៦៥ |
| | បញ្ចមំ នាគបុប្ផិយត្ថេរាបទានំ . . . . | ៦៦៧ |
| | ឆដ្ឋំ បុប្ផិយត្ថេរាបទានំ . . . . . | ៦៦៨ |
| | សត្តមំ កុដជបុប្ផិយត្ថេរាបទានំ . . . | ៦៦៩ |
| | អដ្ឋមំ ឃោសសញ្ញកត្ថេរាបទានំ . . | ៦៧១ |


## សេចក្តីប្រែរាយពាក្យ


| មាតិកា | | ទំព័រ |
|---|---|---|
| គណិកាវគ្គ | អសោកផលិយត្ថេរាបទាន ទី ៨ . . . | ៦៣៧ |
| | ភាគផលិយត្ថេរាបទាន ទី ៩ . . . | ៦៣៨ |
| | នាលិកេរផលទាយកត្ថេរាបទាន ទី ១០ . | ៦៣៩ |


## ផលទាយកវគ្គ ទី ៥២


| | | |
|---|---|---|
| ផលទាយកវគ្គ | កុរញ្ជិយផលទាយកត្ថេរាបទាន ទី ១ . . | ៦៦២ |
| | កបិដ្ឋផលទាយកត្ថេរាបទាន ទី ២ . . | ៦៦៣ |
| | កោសុម្ភផលិយត្ថេរាបទាន ទី ៣ . . | ៦៦៤ |
| | កេតកបុប្ផិយត្ថេរាបទាន ទី ៤ . . . | ៦៦៥ |
| | នាគបុប្ផិយត្ថេរាបទាន ទី ៥ . . . . | ៦៦៧ |
| | អជ្ជុនបុប្ផិយត្ថេរាបទាន ទី ៦ . . . | ៦៦៨ |
| | កុដជបុប្ផិយត្ថេរាបទាន ទី ៧ . . . | ៦៦៩ |
| | ឃោសសញ្ញកត្ថេរាបទាន ទី ៨ . . . | ៦៧១ |

## មាតិកាបាលិ


| មាតិកា | | អង្កា |
|---|---|---|
| ផលទាយកវគ្គ | នវមំ សត្តផលទាយកត្ថេរាបទានំ . . | ២៤២ |
| | ទសមំ បទុមធារិយត្ថេរាបទានំ . . . | ២៤៧ |


### តេបញ្ញាសោ តិណទាយកវគ្គោ


| | | |
|---|---|---|
| តិណទាយកវគ្គ | បឋមំ តិណមុដ្ឋិទាយកត្ថេរាបទានំ . . | ២៤៩ |
| | ទុតិយំ មញ្ចទាយកត្ថេរាបទានំ . . . | ២៥១ |
| | តតិយំ សរណគមនិយត្ថេរាបទានំ . . | ២៥៥ |
| | ចតុត្ថំ អព្ភញ្ជនទាយកត្ថេរាបទានំ . . . | ២៥៦ |
| | បញ្ចមំ សុបដទាយកត្ថេរាបទានំ . . . | ២៥៨ |
| | ឆដ្ឋំ ទណ្ឌទាយកត្ថេរាបទានំ . . . . | ២៦៥ |
| | សត្តមំ គិរិនេលបូជកត្ថេរាបទានំ . . . | ២៦៨ |
| | អដ្ឋមំ ពោធិសម្មជ្ជកត្ថេរាបទានំ . . . | ២៦៩ |
| | នវមំ អាមណ្ឌផលទាយកត្ថេរាបទានំ. . | ២៧៦ |
| | ទសមំ សុគន្ធត្ថេរាបទានំ . . . . | ២៧៨ |




## ប្រែជាខ្មែរ


| មាតិកា | | ទំព័រ |
|---|---|---|
| ផលទាយកវគ្គ | សត្តផលទាយកត្ថេរាបទាន ទី ៩ . . | ២៤២ |
| | បទុមធារិយត្ថេរាបទាន ទី ១០ . . . | ២៤៧ |


### តិណទាយកវគ្គ ទី ៥៣


| | | |
|---|---|---|
| តិណទាយកវគ្គ | តិណមុដ្ឋិទាយកត្ថេរាបទាន ទី ១ . . . | ២៤៩ |
| | មញ្ចទាយកត្ថេរាបទាន ទី ២ . . . | ២៥១ |
| | សរណគមនិយត្ថេរាបទាន ទី ៣ . . | ២៥៥ |
| | អព្ភញ្ជនទាយកត្ថេរាបទាន ទី ៤ . . . | ២៥៦ |
| | សុបដទាយកត្ថេរាបទាន ទី ៥ . . . | ២៥៨ |
| | ទណ្ឌទាយកត្ថេរាបទាន ទី ៦ . . . | ២៦៥ |
| | គិរិនេលបូជកត្ថេរាបទាន ទី ៧ . . . | ២៦៨ |
| | ពោធិសម្មជ្ជកត្ថេរាបទាន ទី ៨ . . . | ២៦៩ |
| | អាមណ្ឌផលទាយកត្ថេរាបទាន ទី ៩ . . | ២៧៦ |
| | សុគន្ធត្ថេរាបទាន ទី ១០ . . . . | ២៧៨ |

## [illegible]


| មាតិកា | | អង្កេ |
|---|---|---|
| | **ចតុប្បញ្ញាសមោ កច្ចាយនវគ្គោ** | |
| កច្ចាយនវគ្គ | បឋមំ មហាកច្ចាយនត្ថេរាបទានំ . . . | ២៨៦ |
| | ទុតិយំ វក្កលិត្ថេរាបទានំ . . . . . | ២៩១ |
| | តតិយំ មហាកប្បិនត្ថេរាបទានំ . . . . | ២៩៨ |
| | ចតុត្ថំ ទព្វមល្លបុត្តត្ថេរាបទានំ . . . | ៣០៥ |
| | បញ្ចមំ កុមារកស្សបត្ថេរាបទានំ . . . | ៣១៣ |
| | ឆដ្ឋំ ពាហិយត្ថេរាបទានំ . . . . . | ៣១៩ |
| | សត្តមំ មហាកោដ្ឋិតត្ថេរាបទានំ . . . | ៣២៨ |
| | អដ្ឋមំ ឧរុវេលកស្សបត្ថេរាបទានំ . . . | ៣៣៣ |
| | នវមំ រាធត្ថេរាបទានំ . . . . . . | ៣៤២ |
| | ទសមំ មោឃរាជត្ថេរាបទានំ . . . . | ៣៤៨ |
| | **បញ្ចបញ្ញាសមោ ភទ្ទិយវគ្គោ** | |
| ភទ្ទិយវគ្គ | បឋមំ លកុណ្ឌកភទ្ទិយត្ថេរាបទានំ . . | ៣៥៥ |
| | ទុតិយំ កង្ខារេវតត្ថេរាបទានំ . . . . | ៣៦១ |




## [illegible]


| មាតិកា | | ទំព័រ |
|---|---|---|
| | **កច្ចាយនវគ្គ ទី ៥៤** | |
| កច្ចាយនវគ្គ | មហាកច្ចាយនត្ថេរបទាន ទី ១ . . . | ២៨៦ |
| | វក្កលិត្ថេរបទាន ទី ២ . . . . . | ២៩១ |
| | មហាកប្បិនត្ថេរបទាន ទី ៣ . . . . | ២៩៨ |
| | ទព្វមល្លបុត្តត្ថេរបទាន ទី ៤ . . . | ៣០៥ |
| | កុមារកស្សបត្ថេរបទាន ទី ៥ . . . | ៣១៣ |
| | ពាហិយត្ថេរបទាន ទី ៦ . . . . . | ៣១៩ |
| | មហាកោដ្ឋិតត្ថេរបទាន ទី ៧ . . . | ៣២៨ |
| | ឧរុវេលកស្សបត្ថេរបទាន ទី ៨ . . . | ៣៣៣ |
| | រាធត្ថេរបទាន ទី ៩ . . . . . . | ៣៤២ |
| | មោឃរាជត្ថេរបទាន ទី ១០ . . . . | ៣៤៨ |
| | **ភទ្ទិយវគ្គ ទី ៥៥** | |
| ភទ្ទិយវគ្គ | លកុណ្ឌកភទ្ទិយត្ថេរបទាន ទី ១ . . | ៣៥៥ |
| | កង្ខារេវតត្ថេរបទាន ទី ២ . . . . | ៣៦១ |

# មាតិកាបត្តានិ

| មាតិកា | | អង្ក |
|---|---|---|
| ភទ្ទិយវគ្គ | តតិយំ សីវលិត្ថេរាបទានំ . . . . | ៣៦៨ |
| | ចតុត្ថំ វង្គីសត្ថេរាបទានំ . . . . . | ៣៧៣ |
| | បញ្ចមំ នន្ទកត្ថេរាបទានំ . . . . | ៣៨៦ |
| | ឆដ្ឋំ កាឡុទាយិត្ថេរាបទានំ . . . | ៣៨៧ |
| | សត្តមំ អភយត្ថេរាបទានំ . . . . | ៣៩២ |
| | អដ្ឋមំ លោមសកង្គិយត្ថេរាបទានំ . . . | ៣៩៨ |
| | នវមំ វនវច្ឆត្ថេរាបទានំ . . . . . | ៤០៣ |
| | ទសមំ ចូឡសុគន្ធត្ថេរាបទានំ . . . | ៤០៧ |

# សន្លឹកប្រាប់មាតិកា

| មាតិកា | | ទំព័រ |
|---|---|---|
| ភទ្ទិយវគ្គ | សីវលិត្ថេរាបទាន ទី ៣ . . . . | ៣៦៨ |
| | វង្គីសត្ថេរាបទាន ទី ៤ . . . . . | ៣៧៣ |
| | នន្ទកត្ថេរាបទាន ទី ៥ . . . . . | ៣៨២ |
| | កាឡុទាយិត្ថេរាបទាន ទី ៦ . . . . | ៣៨៧ |
| | អភយត្ថេរាបទាន ទី ៧ . . . . . | ៣៩២ |
| | លោមសកង្គិយត្ថេរាបទាន ទី ៨ . . . | ៣៩៨ |
| | វនវច្ឆត្ថេរាបទាន ទី ៩ . . . . . | ៤០៣ |
| | ចូឡសុគន្ធត្ថេរាបទាន ទី ១០ . . . | ៤០៧ |

## សុទ្ធាសុទ្ធបត្តំ

| សុទ្ធបាឋោ | អសុទ្ធបាឋោ | អង្កេ | បង្តិលេខាយំ |
| --- | --- | --- | --- |
| គុត្តស្ស | គុន្តស្ស | ១៤ | ៧ |
| សេដ្ឋោ | វិសេដ្ឋោ | ១៥ | ១៥ |
| ទុស្សីលោ | ទុសីលោ | ១៦ | ៥ |
| សម្ពុទ្ធ | សម្ពុទ្ធំ | ៣០ | ១១ |
| ឧទរ | ឧទរេ | ៥៨ | ៣ |
| ភវតោ | ភវាតោ | ៥៩ | ១៣ |
| វិហារេយ | វិហារេយ | ៧១ | ៦ |
| សន្តិបទទុត្តំ | សន្តិបទមទុត្តំ | ១០៥ | ១៤ |
| តរា | តរោ | ១១៦ | ៦ |
|  | ១២១ | ១២១ | (លេខទំព័រ) |
|  | ១២៣ | ១២៣ | ,, |
| ខុទ្ទកនិកាយស្ស | ខុទ្ទកកនិកាយស្ស | ១៤៤ | ១ |
| ,, | ,, | ១៥០ | ,, |
| សទំ | សុទំ | ១៥៣ | ៨ |
| ទុក្ខា | ទុក្ខា | ,, | ៦ |



## សុទ្ធាសុទ្ធបត្តំ

| សុទ្ធបាឋោ | អសុទ្ធបាឋោ | អង្កេ | បង្តិលេខាយំ |
| --- | --- | --- | --- |
|  | ១៥៥ | ១៥៥ | (លេខទំព័រ) |
| មាមកោ | បាមកោ | ១៦៦ | ៩ |
| អតាសត | អកាសត | ១៦៧ | ៥ |
| បុប្ផិន | បុប្ផិន | ១៧៦ | ៩ |
| អគ្គិកា | អគ្គិកា | ១៧៨ | ៨ |
| អបប្បំ | អប្បប្បំ | ១៨៦ | ៤ |
| ធាតិមោក្ខស្ស | ធាតិមោក្ខស្ស | ១៨៩ | ៤ |
| ទបចិត្តកា | ទបចិត្តកា | ២០៧ | [illegible] |
| កិលេសា | កិលេសា | ២០៨ | ១៤ |
| កិច្ច | កិច្ច | ២១៤ | ១០ |
|  | ២២១ | ២២១ | (លេខទំព័រ) |
| បុប្ផេភត្តបាតំ | បុប្ផយេភត្តបាតំ | ២២៥ | ១ |
| វេកា | វិវេកា | ២៣៨ | ៩ |
| នាលិកេរ | នាលិកេរំ | ២៤១ | ១០ |
| កិណ្ណា | កិណ្ណា | ២៤៩ | ១៤ |

## វិរុទ្ធាវិរុទ្ធបត្រ

| វិរុទ្ធបាឋ | អវិរុទ្ធបាឋ | អង្គ | វជ្ជលេខាយ |
|---|---|---|---|
| គិណាតាយក្រោ | គិណាតាយកក្រោ | ៤៧៤ | ១ |
| អាតិរេណ្ឌា | សាតិរេណ្ណា | ៦៦០ | ៨ |
| សត្តម៉ | គតិយំ | ៦៦៣ | ១ |
| ទទកតាយកក្រោបតាខំ | សរណោតមនិយក្រោបតាខំ | ៦៦៣ | ,, |
| សរណាជមនេ | សរណាគមនេ | ៦៦៣ | ១៣ |
| អាម្សៀ | អមាម្សៀ | ៤៧១ | ១០ |
| ចរគោហំ | ចុរគោហំ | ៦៨០ | ៨ |
| ថរេ | ថេរេ | ៣ ៨ | ៨ |
| បដកេ | បិដកេ | ៣៤០ | ១ |
| ទរវេលាយ | ទុរវេលាយ | ៣៣៨ | ១៣ |
| ទុរវេលា | ទុរវេលា | ៣៤០ | ១៤ |
| គរេ តាធិ | គរេតានិ | ៣៦៣ | ៨ |
| នរសោចិ | នរសោចេ | ៣៩៣ | ៧ |
| ទុត្តិស | ទុត្តិស | ៤០៨ | ៦ |

---



## សន្លឹកប្រាប់ពាក្យខុស-ត្រូវ

| ពាក្យខុស | ពាក្យត្រូវ | ទំព័រ | បន្ទាត់ |
|---|---|---|---|
| ខ្មែ | ខ្មែ | ៧ | ៩ |
| គណិការ | គណិការ | ៨ | ៣ |
| ចំមិន | ចំអិន | ៣៦ | ១១ |
| មានលំដាប់ | តាមលំដាប់ | ៩៤ | ៣ |
| លោកនាយក | លោកនាយក | ១០៨ | ១៤ |
| បម្អិយ | បម្អិយ | ១១៦ | ៤ |
| | ១១៩ | ១១៩ | (លេខទំព័រ) |
| | ១៤១ | ១៤១ | ,, |
| | ១៤៣ | ១៤៣ | ,, |
| | ១៤៥ | ១៤៥ | ,, |
| (៦៦) | (៦១) | ១៣៦ | ៣ |
| លោកតាយ | លោកតាយក | ១៣៨ | ,, |
| គគ្គក | គក្កក | ១៥៤ | ៣ |
| តាយកេ- | តាយកាកេ- | ១៥៥ | ,, |

## សន្លឹកប្រាប់ពាក្យខុស-ត្រូវ

| ពាក្យខុស | ពាក្យត្រូវ | ទំព័រ | បន្ទាត់ |
|---|---|---|---|
| លោកនាកយកថា | លោកនាយកកថា | ១៦៥ | ៣ |
| ធាដិមាតុ | ធាតិមាតុ | ១៨៩ | ៦ |
| ព្រ | ព្រះ | ,, | ១៥ |
| ១០៤ | ៤០៤ | (លេខទំព័រ) | |
| ផុក | ផុក | ៤០៨ | ១៣ |
| ដីរ | ដ៏រ | ៤១៩ | ១១ |
| | ៤៤១ | ៤៤១ | (លេខទំព័រ) |
| ខន | ខន់ | ៤៤៣ | ១៤ |
| សុខស្ស: | សុខស្សន: | ៤៤៩ | ១៤ |
| កាក់ | កាត់ | ៤៥១ | ,, |
| ទ្រល់ | ទ្រន់ | ៤៩៨ | ៤ |
| សិរ្ស: | សិរ | ៣០៧ | ៦ |
| សល់នៅ | សល់នៅ | ៣១០ | ១៥ |
| បុផ្ន | បុប្ផន | ៣១១ | ១១ |



## សន្លឹកប្រាប់ពាក្យខុស-ត្រូវ

| ពាក្យខុស | ពាក្យត្រូវ | ទំព័រ | បន្ទាត់ |
|---|---|---|---|
| ដើម្ប | ដើម្បី | ៣៣៧ | ៦ |
| ខុទ្ទនិកាយ | ខុទ្ទកនិកាយ | ៣៥០ | ១ |
| ព្រនាម | ព្រះនាម | ៣៤៨ | ១៣ |
| កន្ធកខ | កន្ធកខ: | ៣៧៦ | ១៧ |
| ដូចជាសា | ដូចជាសា- | ៤០៩ | ៤ |
| ទៃទេ | ទៃទេ- | ៤០៩ | ៥ |
| ញុំញី | ញាំញី | ៤០៩ | ៧ |